# ព្រះ
# ត្រៃបិដកបាលី
និង
## សេចក្ដីប្រែជាភាសាខ្មែរ
# វិនយបិដក
## មហាវគ្គ ទុតិយភាគ
# ៧

វស្សូបនាយិកក្ខន្ធកៈ បវារណក្ខន្ធកៈ
ចម្មក្ខន្ធកៈ និង ភេសជ្ជក្ខន្ធកៈ

បោះពុម្ពលើកទី ២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស ២៥០០

# វិនយបិដក មហាវគ្គ

## ទុតិយភាគ

៧

វស្សូបនាយិកក្ខន្ធកៈ បវារណាក្ខន្ធកៈ

ចម្មក្ខន្ធកៈ និង ភេសជ្ជក្ខន្ធកៈ

ព. ស. ២៥០០

# ទុតិយោ ភាគោ

## វស្សូបនាយិកក្ខន្ធកំ

(១) តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ភគវតា ភិក្ខូនំ វស្សាវាសោ អបញ្ញត្តោ ហោតិ ។ តេធ[១] ភិក្ខូ ហេមន្តម្បិ គិម្ហម្បិ វស្សម្បិ ចារិកំ ចរន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ហេមន្តម្បិ គិម្ហម្បិ វស្សម្បិ ចារិកំ ចរិស្សន្តិ ហរិតានិ តិណានិ សម្មទ្ទន្តា ឯកិន្ទ្រិយំ ជីវំ វិហេឋេន្តា ពហូ ខុទ្ទកេ បាណេ សង្ឃាតំ អាបាទេន្តា ឥមេ ហិ នាម អញ្ញតិត្ថិយា ទុរក្ខាតធម្មា វស្សាវាសំ អល្លិយិស្សន្តិ សង្កាសយិស្សន្តិ[២] ឥមេ ហិ នាម សកុន្តកា រុក្ខគ្គេសុ កុលាវកានិ ករិត្វា វស្សាវាសំ អល្លិយិស្សន្តិ សង្កាសយិស្សន្តិ ឥមេ បន សមណា សក្យបុត្តិយា ហេមន្តម្បិ គិម្ហម្បិ វស្សម្បិ ចារិកំ ចរន្តិ ហរិតានិ

១ និមសេតុ តេធបនភិក្ខូតិ ពុច្ចកត ។ ២ ឱ. សង្កាបយិស្សន្តិ ។

# ភាគទី ២

## វស្សូបនាយិកក្ខន្ធកៈ

(១) សម័យនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង ការនៅចាំវស្សា ព្រះមានព្រះភាគមិនទាន់បានបញ្ញត្តដល់ភិក្ខុទាំងឡាយនៅឡើយ ។ ភិក្ខុទាំងនោះក៏ចេញដើរទៅកាន់ចារិកអស់ហេមន្តរដូវខ្លះ អស់គិម្ហរដូវខ្លះ អស់វស្សានរដូវខ្លះ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តិយ៍មិនសមបើនឹងដើរទៅកាន់ចារិកអស់ហេមន្តរដូវខ្លះ អស់គិម្ហរដូវខ្លះ អស់វស្សានរដូវខ្លះ ដើរជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀននូវឥន្ទ្រិយដែលមានជីវិតមានឥន្ទ្រិយតែ ១ ញ៉ាំងសត្វតូចៗ ជាច្រើនឲ្យដល់នូវសេចក្តីវិនាសសោះ សូម្បីពួកបរិព្វាជកមានលទ្ធិដទៃទាំងនេះដែលជាអ្នកពោលធម៌អាក្រក់ ម្តេចគង់នឹងសម្ងំឈប់សម្រាកនៅចាំវស្សា សូម្បីទាំងពួកសត្វស្លាបទាំងទៀតសោត ក៏គង់ធ្វើសំបុកលើចុងឈើទាំងឡាយ ហើយនឹងសម្ងំឈប់សម្រាកនៅចាំវស្សាដែរ ចំណែកពួកសមណៈជាសក្យបុត្តិយ៍នេះនៅតែដើរទៅកាន់ចារិក អស់ហេមន្តរដូវខ្លះ អស់គិម្ហរដូវខ្លះ អស់វស្សានរដូវខ្លះ ដើរជាន់ស្មៅស្រស់

តិណានិ សម្មទ្ទន្តា ឯកិន្ទ្រិយំ ជីវំ វិហេឋេន្តា ពហូ ខុទ្ទកេ បាណេ សង្ឃាតំ អាបាទេន្តាតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ វស្សំ ឧបគន្តុន្តិ ។

(២) អថខោ ភិក្ខូនំ ឯតទហោសិ កទា នុ ខោ វស្សំ ឧបគន្តព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ វស្សានេ វស្សំ ឧបគន្តុន្តិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កតិ នុ ខោ វស្សូបនាយិកាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ទ្វេមា ភិក្ខវេ វស្សូបនាយិកា បុរិមិកា បច្ឆិមិកា អបរជ្ជុគតាយ អាសាឡ្ហិយា បុរិមិកា ឧបគន្តព្វា មាសគតាយ



ទាំងឡាយ បៀតបៀនសត្វដែលមានជីវិតមានឥន្ទ្រិយតែ ១ ញាំញីសត្វតូចៗ ជាច្រើនឲ្យដល់នូវសេចក្តីវិនាស ។ កាលមនុស្សទាំងនោះកំពុងតែពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮហើយ ។ គ្រានោះឯង ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើនូវធម្មីកថាក្នុងវេលានោះឯង រួចហើយទើបទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកអនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សា(១) ។

(៦) គ្រានោះឯង ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា យើងគួរចូលវស្សាក្នុងកាលណាហ្ន៎ ។ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សាក្នុងវស្សានរដូវ ។ លំដាប់នោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ថ្ងៃចូលវស្សាតើមានប៉ុន្មានហ្ន៎ ។ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ថ្ងៃចូលវស្សានេះមានពីរ គឺថ្ងៃបុរិមិកា(២) វស្សា ១ ថ្ងៃបច្ឆិមិកា(៣) វស្សា ១ ភិក្ខុត្រូវចូលបុរិមិកាវស្សាក្នុងថ្ងៃបន្ទាប់នៃថ្ងៃពេញ

---

១ អដ្ឋកថា អធិប្បាយថា ក្នុងវស្សានរដូវភិក្ខុត្រូវចូលវស្សាឲ្យគ្រប់ជាដរាប ។ ២ ថ្ងៃចូលវស្សាមុន ។ ៣ ថ្ងៃចូលវស្សាក្រោយ ។

អាសាឡ្ហិយា បច្ឆិមិកា ឧបគន្តព្វា ឥមា ខោ ភិក្ខវេ ទ្វេ វស្សូបនាយិកាតិ ។

(៣) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ វស្សំ ឧបគន្ត្វា អន្តរាវស្សំ ចារិកំ ចរន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ហេមន្តម្បិ គិម្ហម្បិ វស្សម្បិ ចារិកំ ចរិស្សន្តិ ហរិតានិ តិណានិ សម្មទ្ទន្តា ឯកិន្ទ្រិយំ ជីវំ វិហេឋេន្តា ពហូ ខុទ្ទកេ បាណេ សង្ឃាតំ អាបាទេន្តា ឥមេ ហិ នាម អញ្ញតិត្ថិយា ទុរក្ខាតធម្មា វស្សាវាសំ អល្លីយិស្សន្តិ សង្កាសយិស្សន្តិ ឥមេ ហិ នាម សកុន្តកា[*] រុក្ខគ្គេសុ កុលាវកានិ ករិត្វា វស្សាវាសំ អល្លីយិស្សន្តិ សង្កាសយិស្សន្តិ ឥមេ បន សមណា សក្យបុត្តិយា ហេមន្តម្បិ គិម្ហម្បិ វស្សម្បិ ចារិកំ ចរន្តិ ហរិតានិ តិណានិ សម្មទ្ទន្តា ឯកិន្ទ្រិយំ ជីវំ វិហេឋេន្តា ពហូ ខុទ្ទកេ បាណេ សង្ឃាតំ អាបាទេន្តាតិ ។

* សកុន្តាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។



បូណ៌មីនៃអាសាឍ (គឺថ្ងៃ ១៥ កើតខែអាសាឍ) ភិក្ខុត្រូវចូលបច្ឆិមិកាវស្សា គឺថ្ងៃដែលកន្លងហួស ១ ខែអំពីថ្ងៃពេញបូណ៌មីនៃអាសាឍ (គឺថ្ងៃ ១៥ កើតខែស្រាពណ៍) ម្នាលភិក្ខុទាំងឡាយ ថ្ងៃចូលវស្សាមានតែពីរយ៉ាងនេះឯង ។

(៣) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបានចូលវស្សាហើយក៏ចេញដើរទៅកាន់ចារិកក្នុងកណ្ដាលវស្សា ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា (តាមន័យនោះទៀត) ថា ពួកសមណៈជាសក្យបុត្តិយ៍មិនសមបើនឹងដើរទៅកាន់ចារិកសព្វហេមន្តរដូវខ្លះ សព្វគិម្ហរដូវខ្លះ សព្វវស្សានរដូវខ្លះ ដើរជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀនឥន្ទ្រីដែលមានជីវិតមានឥន្ទ្រិយតែមួយ ញាំញីពួកសត្វតូចៗ ជាច្រើនឲ្យដល់នូវសេចក្ដីវិនាសនោះ យ៉ាងដូចជាពួកតិរ្ថិយទាំងនេះដែលពោលធម៌អាក្រក់ម្ដេចក៏ចេះសម្ងំលាក់ខ្លួនប្រមាណនៅចាំវស្សា ពួកសត្វស្លាបទាំងនេះទៀតសោតក៏ចេះធ្វើសំបុកទាំងឡាយនៅលើចុងឈើទាំងឡាយ ហើយនឹងសម្ងំនៅចាំវស្សាដូចគ្នាដែរ ចំណែកពួកសមណៈជាសក្យបុត្តិយ៍នេះម្ដេចឡើយក៏ទៅតែដើរទៅកាន់ចារិកសព្វហេមន្តរដូវខ្លះ សព្វគិម្ហរដូវខ្លះ សព្វវស្សានរដូវខ្លះ ដើរជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀនឥន្ទ្រីដែលមានជីវិតមានឥន្ទ្រិយតែមួយ ញាំញីពួកសត្វតូចៗ ជាច្រើនឲ្យដល់នូវសេចក្ដីវិនាស ។

អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ វស្សំ ឧបគន្ត្វា អន្តរាវស្សំ ចារិកំ ចរិស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ វស្សំ ឧបគន្ត្វា បុរិមំ វា តេមាសំ បច្ឆិមំ វា តេមាសំ អវសិត្វា ចារិកា បក្កមិតព្វា យោ បក្កមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[៦] តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ន ឥច្ឆន្តិ វស្សំ ឧបគន្តុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ វស្សំ ន ឧបគន្តព្វំ យោ ន ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ តទហុវស្សូបនាយិកាយ វស្សំ អនុបគន្តុកាមា សញ្ចិច្ច អាវាសំ អតិក្កមន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ តទហុ-



កាលមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮហើយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុចូលវស្សាហើយមិនសមបើនឹងចេញដើរទៅកាន់ចារិកក្នុងកណ្តាលវស្សាសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រោះនិទាននុ៎ះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថារួច ហើយត្រាស់ហៅភិក្ខុទាំងឡាយមកបញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុចូលវស្សាហើយ មិននៅចាំបុរិមិកាវស្សាអស់ ៣ ខែ ឬបច្ឆិមិកាវស្សាអស់ ៣ ខែ មិនត្រូវចៀសចេញទៅកាន់ចារិកឡើយ ភិក្ខុណាចៀសចេញទៅ ត្រូវអាបត្តិទុក្កដ ។

(៦) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមិនប្រាថ្នានឹងចូលវស្សា ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនចូលវស្សាឡើយ (គឺត្រូវតែចូលវស្សា) ភិក្ខុណាមិនចូលវស្សា ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមិនប្រាថ្នានឹងចូលវស្សាក្នុងថ្ងៃចូលវស្សានោះ ក៏ក្លែងដើរចេញពីអាវាស ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិន

វស្សូបនាយិកាយ វស្សំ អនុបគន្តុកាមេន សញ្ចិច្ច អាវាសោ អតិក្កមិតព្ពោ យោ អតិក្កមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៥) តេន ខោ បន សមយេន រាជា មាគធោ សេនិយោ ពិម្ពិសារោ វស្សំ ឧក្កឌ្ឍិតុកាមោ ភិក្ខូនំ សន្តិកេ ទូតំ បាហេសិ យទិ បនាយ្យា អាគមេ ជុណ្ហេ វស្សំ ឧបគច្ឆេយ្យុន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ រាជូនំ អនុវត្តិតុន្តិ ។

(៦) អថខោ ភគវា រាជគហេ យថាភិរន្តំ វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន សាវត្ថី តទវសរិ ។ តត្រ សុទំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន កោសលេសុ ជនបទេសុ ឧទេនេន ឧបាសកេន សង្ឃំ ឧទ្ទិស្ស វិហារោ ការាបិតោ ហោតិ ។ សោ ភិក្ខូនំ សន្តិកេ ទូតំ



ប្រាថ្នាមិនចូលវស្សា គឺភិក្ខុដែលចេញពីអាវាសទៅក្នុងថ្ងៃចូលវស្សានោះ មិនបានទេ ភិក្ខុណាចេញដើរទៅ ត្រូវអាបត្តិទុក្កដ ។

(៥) សម័យនោះឯង ព្រះបាទមាគធរាជសេនិយពិម្ពិសារ ទ្រង់មានសេចក្តីប្រាថ្នាដើម្បីនឹងលើកវស្សា[១] ក៏បញ្ជូនរាជទូតទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា លោកម្ចាស់ទាំងឡាយសូមចូលវស្សាក្នុងខែខាងមុខ (ខែអាសាឍក្រោយ) ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រព្រឹត្តទៅតាមស្តេចទាំងឡាយចុះ ។

(៦) គ្រានោះឯង ព្រះមានព្រះភាគគង់ក្នុងក្រុងរាជគ្រឹះ គួរដល់អធ្យាស្រ័យហើយ ទ្រង់យាងសំដៅទៅឯក្រុងសាវត្ថី ទ្រង់យាងទៅកាន់ចារិកដោយលំដាប់ស្រុក ទើបបានដល់ទៅក្រុងសាវត្ថី ។ បានឮថា ព្រះមានព្រះភាគគង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថីនោះឯង ។ សម័យនោះឯង ក្នុងកោសលជនបទ មានឧបាសកឈ្មោះឧទេន បានឲ្យគេធ្វើវិហារចំពោះសង្ឃ ។ ឧបាសកនោះក៏បាន

១ អដ្ឋកថា ថា ទ្រង់មានសេចក្តីប្រាថ្នានឹងលើកវស្សាឲ្យឃ្លាតខែវស្សាចេញ គឺប្រាថ្នានឹងធ្វើឲ្យស្រាកលំហែឡើងទៅដល់ខែអាសាឍទី ២ (ខែអាសាឍខាងដើម ហៅបឋមាសាឍ ខែដែលលើកខាងក្រោយ ហៅទុតិយាសាឍ) ។

បាហេសិ(១) អាគច្ឆន្តុ ភទ្ទន្តា ឥច្ឆាមិ ទានញ្ច ទាតុំ ធម្មញ្ច សោតុំ ភិក្ខូ ច បស្សិតុន្តិ ។ ភិក្ខូ ឯវមាហំសុ ភគវតា អាវុសោ បញ្ញត្តំ ន វស្សំ ឧបគន្ត្វា បុរិមំ វា តេមាសំ បច្ឆិមំ វា តេមាសំ អវសិត្វា ចារិកា បក្កមិតព្វាតិ អាគមេតុ ឧទេនោ ឧបាសកោ យាវ ភិក្ខូ វស្សំ វសន្តិ វស្សំ វុត្ថា អាគមិស្សន្តិ សចេ បនស្ស អច្ចាយិកំ ករណីយំ តត្ថេវ អាវាសិកានំ ភិក្ខូនំ សន្តិកេ វិហារំ បតិដ្ឋាបេតូតិ ។ ឧទេនោ ឧបាសកោ ឧជ្ឈាយតិ ខិយ្យតិ វិបាចេតិ កថំ ហិ នាម ភទ្ទន្តា មយា បហិតេ(២) ន អាគច្ឆិស្សន្តិ អហំ ហិ ទាយកោ ការកោ សង្ឃុបដ្ឋាកោតិ ។ អស្សោសុំ ខោ ភិក្ខូ ឧទេនស្ស ឧបាសកស្ស ឧជ្ឈាយន្តស្ស ខិយ្យន្តស្ស វិបាចេន្តស្ស ។ អថ ខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថ ខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ សត្តន្នំ

១ បាហេសីតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ បហិតេតិ កត្ថចិ បោត្ថកេ ទិស្សតិ ។



បញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ដ្បិតខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង ស្តាប់ធម៌ផង នឹងបានឃើញភិក្ខុទាំងឡាយផង ។ ភិក្ខុទាំងឡាយនិយាយយ៉ាងនេះវិញថា នែអាវុសោ ព្រះមានព្រះភាគបានបញ្ញត្តហើយថា ភិក្ខុទាំងឡាយចូលវស្សាហើយមិនបាននៅចាំបុរិមិកាវស្សាអស់ ៣ ខែ ឬបច្ឆិមិកាវស្សាអស់ ៣ ខែទេ មិនត្រូវចេញដើរទៅកាន់ចារិកឡើយ សូមឲ្យឧទេនឧបាសកបង្អង់ចាំសិន ទំរាំតែភិក្ខុទាំងឡាយនៅចាំវស្សារួច លុះចាំវស្សារួចហើយមុខជានឹងទៅ បើឧបាសកនោះមានការត្រូវធ្វើជាប្រញាប់ សូមឲ្យតាំងវិហារក្នុងសំណាក់ភិក្ខុទាំងឡាយដែលនៅក្នុងអាវាសនោះចុះ ។ ឯឧទេនឧបាសកក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយកាលបើខ្ញុំបានបញ្ជូនតំណាងទៅហើយ មិនសមបើនឹងមិននិមន្តមកសោះ ដ្បិតខ្ញុំជាទាយក ជាអ្នកធ្វើការ៖ ជាឧបដ្ឋាករបស់សង្ឃ ។ កាលឧទេនឧបាសកកំពុងតែពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ ។ វេលានោះ ភិក្ខុទាំងនោះក៏ក្រាបទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងវេលានោះឯង រួចហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកអនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ កាលបើជន

សត្តាហករណីយេន បហិតេ គន្តុំ ន ត្វេវ អប្បហិតេ ភិក្ខុស្ស ភិក្ខុនិយា សិក្ខមានាយ សាមណេរស្ស សាមណេរិយា ឧបាសកស្ស ឧបាសិកាយ អនុជានាមិ ភិក្ខវេ ឥមេសំ សត្តន្នំ សត្តាហករណីយេន បហិតេ គន្តុំ ន ត្វេវ អប្បហិតេ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ឧបាសកេន សង្ឃំ ឧទ្ទិស្ស វិហារោ ការាបិតោ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អាគច្ឆន្តុ ភទ្ទន្តា ឥច្ឆាមិ ទានញ្ច ទាតុំ ធម្មញ្ច សោតុំ ភិក្ខូ ច បស្សិតុន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន បហិតេ ន ត្វេវ អប្បហិតេ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ឧបាសកេន សង្ឃំ ឧទ្ទិស្ស អឌ្ឍយោគោ ការាបិតោ ហោតិ ។បេ។ បាសាទោ ការាបិតោ ហោតិ ។ ហម្មិយំ ការាបិតំ



ទាំង ៧ ពួក គឺភិក្ខុ ១ ភិក្ខុនី ១ សិក្ខមានា ១ សាមណេរ ១ សាមណេរី ១ ឧបាសក ១ ឧបាសិកា ១ បានបញ្ជូនបម្រើមកហើយ តថាគតអនុញ្ញាតឲ្យភិក្ខុទៅដោយសត្តាហករណីយ (កិច្ចដែលគួរធ្វើបាន ៧ ថ្ងៃ) កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ម្នាលភិក្ខុទាំងឡាយ កាលបើជនទាំង ៧ ពួកនេះ បានបញ្ជូនបម្រើមកហើយ តថាគតអនុញ្ញាតឲ្យភិក្ខុទៅបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់ក្នុងរវាង ៧ ថ្ងៃ[១] ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកបានឲ្យគេធ្វើវិហារឧទ្ទិសចំពោះសង្ឃហើយ ។ បើឧបាសកនោះបញ្ជូនបម្រើមកក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបានបញ្ជូនបម្រើមកហើយ ភិក្ខុត្រូវទៅដោយសត្តាហករណីយបាន កាលបើគ្មានគេបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកបានឲ្យគេធ្វើរោងអឌ្ឍយោគឧទ្ទិសចំពោះសង្ឃ ។បេ។ ឲ្យគេធ្វើប្រាសាទក៏ដី ។ ឲ្យគេធ្វើប្រាសាទ

---

១ សេចក្តីថា ភិក្ខុលើកសត្តាហៈចេញទៅក្រៅសីមាហើយ ត្រូវត្រឡប់មកវិញឲ្យទាន់ក្នុងអរុណថ្ងៃទី ៧ វិញ កុំទៅលើសហួសអរុណថ្ងៃទី ៨ ឡើយ ។

ហោតិ ។ គុហា ការាបិតា ហោតិ ។ បរិវេណំ ការា-បិតំ ហោតិ ។ កោដ្ឋកោ ការាបិតោ ហោតិ ។ ឧបដ្ឋានសាលា ការាបិតា ហោតិ ។ អគ្គិសាលា ការាបិតា ហោតិ ។ កប្បិយកុដិ ការាបិតា ហោតិ ។ វច្ចកុដិ ការាបិតា ហោតិ ។ ចង្កមោ ការាបិតោ ហោតិ ។ ចង្កមនសាលា ការាបិតា ហោតិ ។ ឧទ-បានោ ការាបិតោ ហោតិ ។ ឧទបានសាលា ការា-បិតា ហោតិ ។ ជន្តាឃរំ ការាបិតំ ហោតិ ។ ជន្តា-ឃរសាលា ការាបិតា ហោតិ ។ បោក្ខរណី ការា-បិតា ហោតិ ។ មណ្ឌបោ ការាបិតោ ហោតិ ។ អារាមោ ការាបិតោ ហោតិ ។ អារាមវត្ថុ ការាបិតំ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អាគច្ឆន្តុ ភទ្ទន្តា ឥច្ឆាមិ ទានញ្ច ទាតុំ ធម្មញ្ច សោតុំ ភិក្ខូ ច បស្សិតុន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណី-យេន បហិតេ ន ត្វេវ អប្បហិតេ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ឧបាសកេន សង្ឃមុទ្ទិស្ស





សម្បុលគ្រឹល ។ ឲ្យគេធ្វើគុហា ។ ឲ្យគេធ្វើបរិវេណ ។ ឲ្យគេធ្វើបន្ទប់ ។ ឲ្យគេធ្វើសាលាសម្រាប់ឋាន ។ ឲ្យគេធ្វើរោងភ្លើង ។ ឲ្យគេធ្វើកប្បិយ-កុដិ ។ ឲ្យគេធ្វើវច្ចកុដិ (បង្គន់) ។ ឲ្យគេធ្វើទីចង្ក្រម ។ ឲ្យគេធ្វើរោងចង្ក្រម ។ ឲ្យគេធ្វើអណ្តូងទឹក ។ ឲ្យគេធ្វើសាលានៅខាងអណ្តូងទឹក ។ ឲ្យគេធ្វើផ្ទះជាទីក្សោកាយ ។ ឲ្យគេធ្វើសាលាសម្រាប់ប្រើប្រាស់នៅខាងផ្ទះជាទីក្សោកាយ ។ ឲ្យគេធ្វើស្រះ ។ ឲ្យគេធ្វើមណ្ឌប ។ ឲ្យគេធ្វើអារាម ។ ឲ្យគេធ្វើទីអារាម ។ បើឧបាសកនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមកហើយ ភិក្ខុត្រូវទៅដោយសត្តាហករណីយធុរៈ កាលបើគ្មានគេបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកចំពោះភិក្ខុ[illegible]

ភិក្ខូ ឧទ្ទិស្ស ។ បេ ។ សង្ឃំ ភិក្ខុំ ឧទ្ទិស្ស វិហារោ ការាបិតោ ហោតិ ។ អឌ្ឍយោគោ ការាបិតោ ហោតិ ។ បាសាទោ ការាបិតោ ហោតិ ។ ហម្មិយំ ការាបិតំ ហោតិ ។ គុហា ការាបិតា ហោតិ ។ បរិវេណំ ការាបិតំ ហោតិ ។ កោដ្ឋកោ ការាបិតោ ហោតិ ។ ឧបដ្ឋានសាលា ការាបិតា ហោតិ ។ អគ្គិសាលា ការាបិតា ហោតិ ។ កប្បិយកុដិ ការាបិតា ហោតិ ។ វច្ចកុដិ ការាបិតា ហោតិ ។ ចង្កមោ ការាបិតោ ហោតិ ។ ចង្កមនសាលា ការាបិតា ហោតិ ។ ឧទបានោ ការាបិតោ ហោតិ ។ ឧទបានសាលា ការាបិតា ហោតិ ។ ជន្តាឃរំ ការាបិតំ ហោតិ ។ ជន្តាឃរសាលា ការាបិតា ហោតិ ។ បោក្ខរណី ការាបិតា ហោតិ ។ មណ្ឌបោ ការាបិតោ ហោតិ ។ អារាមោ ការាបិតោ ហោតិ ។ អារាមវត្ថុ ការាបិតំ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អាគច្ឆន្តុ ភទន្តា ឥច្ឆាមិ ទានញ្ច ទាតុំ ធម្មញ្ច សោតុំ ភិក្ខូ ច បស្សិតុន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន



រូប ។ បេ ។ ចុះឧបាសកធ្វើវិហារចំពោះភិក្ខុ ១ រូប ។ ឲ្យគេធ្វើអឌ្ឍយោគ ។ ឲ្យគេធ្វើប្រាសាទរាង ។ ឲ្យគេធ្វើប្រាសាទជម្រាលស្រទីល ។ ឲ្យគេធ្វើគុហា ។ ឲ្យគេធ្វើបរិវេណ ។ ឲ្យគេធ្វើបន្ទប់ទឹក ។ ឲ្យគេធ្វើរោងសម្រាប់ឆាន់ ។ ឲ្យគេធ្វើរោងភ្លើង ។ ឲ្យគេធ្វើកប្បិយកុដិ ។ ឲ្យគេធ្វើវច្ចកុដិ ។ ឲ្យគេធ្វើទីចង្ក្រម ។ ឲ្យគេធ្វើរោងសម្រាប់ចង្ក្រម ។ ឲ្យគេធ្វើអណ្ដូងទឹក ។ ឲ្យគេធ្វើសាលាសម្រាប់ប្រើប្រាស់នៅតាមអណ្ដូងទឹក ។ ឲ្យគេធ្វើផ្ទះជាទីកម្ដៅកាយ ។ ឲ្យគេធ្វើសាលាក្បែរផ្ទះជាទីកម្ដៅកាយ ។ ឲ្យគេធ្វើស្រះ ។ ឲ្យគេធ្វើមណ្ឌប ។ ឲ្យគេធ្វើអារាម ។ ឲ្យគេធ្វើទីអារាម ។ បើឧបាសកនោះបញ្ជូនបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងឲ្យទានផង នឹងស្ដាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមក ភិក្ខុគប្បីទៅដោយសត្តាហករណីយ

បហិតេ ន ត្វេវ អប្បហិតេ សត្តាហំ សន្និវត្តោ កា-តព្ពោ ។ ៥៥ ។ ឥធ បន ភិក្ខវេ ឧបាសកេន ភិក្ខុនីសង្ឃំ ឧទ្ទិស្ស សម្ពហុលា ភិក្ខុនិយោ ឧទ្ទិស្ស ឯកំ ភិក្ខុនឹ ឧទ្ទិស្ស សម្ពហុលា សិក្ខមានាយោ ឧទ្ទិស្ស ឯកំ សិក្ខមានំ ឧទ្ទិស្ស សម្ពហុលេ សាមណេរេ ឧទ្ទិស្ស ឯកំ សាមណេរំ ឧទ្ទិស្ស សម្ពហុលា សាមណេរិយោ ឧទ្ទិស្ស ឯកំ សាមណេរឹ ឧទ្ទិស្ស វិហារោ ការាបិតោ ហោតិ ។ អឌ្ឍយោគោ ការាបិតោ ហោតិ ។ បាសាទោ ការាបិតោ ហោតិ ។ ហម្មិយំ ការាបិតំ ហោតិ ។ គុហា ការាបិតា ហោតិ ។ បរិវេណំ ការាបិតំ ហោតិ ។ កោដ្ឋកោ ការាបិតោ ហោតិ ។ ឧបដ្ឋានសាលា ការាបិតា ហោតិ ។ អគ្គិសាលា ការាបិតា ហោតិ ។ កប្បិយកុដិ ការាបិតា ហោតិ ។ វច្ចកុដិ ការាបិតា ហោតិ ។ ចង្កមោ ការាបិតោ ហោតិ ។ ចង្កមនសាលា ការាបិតា ហោតិ ។ ឧទបានោ ការាបិតោ ហោតិ ។ ឧទបានសាលា ការាបិតា ហោតិ ។ ជន្តាឃរំ



បាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុគប្បីធ្វើការត្រឡប់វិលមកវិញក្នុងរវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកបានឲ្យគេធ្វើវិហារចំពោះភិក្ខុនីសង្ឃ ចំពោះភិក្ខុនីច្រើនរូប ចំពោះភិក្ខុនី ១ រូប ចំពោះសិក្ខមានាច្រើនរូប ចំពោះសិក្ខមានា ១ រូប ចំពោះសាមណេរច្រើនរូប ចំពោះសាមណេរ ១ រូប ចំពោះសាមណេរីច្រើនរូប ចំពោះសាមណេរី ១ រូប ។ បានឲ្យគេធ្វើអឌ្ឍយោគ ។ ឲ្យគេធ្វើប្រាសាទ ។ ឲ្យគេធ្វើប្រាសាទដំបូលត្រដិល ។ ឲ្យគេធ្វើគុហា ។ ឲ្យគេធ្វើបរិវេណ ។ ឲ្យគេធ្វើខ្លោងទ្វារ ។ ឲ្យគេធ្វើរោងសម្រាប់ដាំ ។ ឲ្យគេធ្វើរោងភ្លើង ។ ឲ្យគេធ្វើកប្បិយកុដិ ។ ឲ្យគេធ្វើវច្ចកុដិ ។ ឲ្យគេធ្វើទីចង្ក្រម ។ ឲ្យគេធ្វើរោងចង្ក្រម ។ ឲ្យគេធ្វើអណ្ដូងទឹក ។ ឲ្យគេធ្វើរោងសម្រាប់ប្រើប្រាស់នៅខាងអណ្ដូងទឹក ។ ឲ្យគេធ្វើ

ការាបិតា ហោតិ ។ មណ្ឌបោ ការាបិតោ ហោតិ ។ អារាមោ ការាបិតោ ហោតិ ។ អារាមវត្ថុំ ការាបិតំ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អាគច្ឆន្តុ ភទ្ទន្តា ឥច្ឆាមិ ទានញ្ច ទាតុំ ធម្មញ្ច សោតុំ ភិក្ខូ ច បស្សិតុន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន បហិតេ ន ត្វេវ អប្បហិតេ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ឧបាសកេន អត្តនោ អត្ថាយ និវេសនំ ការាបិតំ ហោតិ ។ សយនិឃរំ ការាបិតំ ហោតិ ។ ឧទោសិតោ ការាបិតោ ហោតិ ។ អដ្ដោ ការាបិតោ ហោតិ ។ មាឡោ ការាបិតោ ហោតិ ។ អាបណោ ការាបិតោ ហោតិ ។ អាបណសាលា ការាបិតា ហោតិ ។ បាសាទោ ការាបិតោ ហោតិ ។ ហម្មិយំ ការាបិតំ ហោតិ ។ គុហា ការាបិតា ហោតិ ។ បរិវេណំ ការាបិតំ ហោតិ ។ កោដ្ឋកោ ការាបិតោ ហោតិ ។ ឧបដ្ឋានសាលា ការាបិតា ហោតិ ។ អគ្គិសាលា ការាបិតា ហោតិ ។ រសវតី ការាបិតា



ស្រះ ។ ឲ្យគេធ្វើមណ្ឌប ។ ឲ្យគេធ្វើអារាម ។ ឲ្យគេធ្វើទីដីអារាម ។ បើទាយកនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកដ៏ចំរើនទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផងនឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហករណីយធុរៈ កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុគប្បីធ្វើការត្រឡប់វិញក្នុងរវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកណាឲ្យគេធ្វើទីនៅដើម្បីខ្លួនឯងវិញ ។ ឲ្យគេធ្វើផ្ទះសម្រាប់ដេក ។ ឲ្យគេធ្វើឃ្លាំង ។ ឲ្យគេធ្វើប៉ម(បញ្ចា) ។ ឲ្យគេធ្វើប្រាសាទមូលវែង ។ ឲ្យគេធ្វើរានផ្សារ ។ ឲ្យគេធ្វើរោងក្នុងផ្សារ ។ ឲ្យគេធ្វើប្រាសាទ ។ ឲ្យគេធ្វើប្រាសាទដំបូលក្រឹល ។ ឲ្យគេធ្វើគុហា ។ ឲ្យគេធ្វើបរិវេណ ។ ឲ្យគេធ្វើបន្ទប់ទឹក ។ ឲ្យគេធ្វើរោងសម្រាប់ជុំគ្នា ។ ឲ្យគេធ្វើរោងភ្លើង ។ ឲ្យ

ហោតិ ។ វច្ចកុដិ ការាបិតា ហោតិ ។ ចង្កមោ ការាបិតោ ហោតិ ។ ចង្កមនសាលា ការាបិតា ហោតិ ។ ឧទបានោ ការាបិតោ ហោតិ ។ ឧទបានសាលា ការាបិតា ហោតិ ។ ជន្តាឃរំ ការាបិតំ ហោតិ ។ ជន្តាឃរសាលា ការាបិតា ហោតិ ។ បោក្ខរណី ការាបិតា ហោតិ ។ មណ្ឌបោ ការាបិតោ ហោតិ ។ អារាមោ ការាបិតោ ហោតិ ។ អារាមវត្ថុ ការាបិតំ ហោតិ ។ បុត្តស្ស វា វារេយ្យំ ហោតិ ធីតុយា វា វារេយ្យំ ហោតិ គិលានោ វា ហោតិ អភិញ្ញាតំ វា សុត្តន្តំ ភណតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អាគច្ឆន្តុ ភទន្តា ឥមំ សុត្តន្តំ បរិយាបុណិស្សន្តិ បុរាយំ សុត្តន្តោ ន[1] បលុជ្ជតីតិ ។ អញ្ញតរំ វា បនស្ស កិច្ចំ ហោតិ ករណីយំ វា ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អាគច្ឆន្តុ ភទន្តា ឥច្ឆាមិ ទានញ្ច ទាតុំ ធម្មញ្ច សោតុំ ភិក្ខូ ច បស្សិតុន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន បហិតេ ន ត្វេវ អប្បហិតេ

១ ម. នលុជ្ជតិ ។



គេធ្វើផ្ទះសម្រាប់បរិភោគអាហារ ១ ឬគេធ្វើវច្ចកុដី ១ ឬគេធ្វើទីចង្ក្រម ១ ឬគេធ្វើរោងចង្ក្រម ១ ឬគេធ្វើអណ្តូងទឹក ១ ឬគេធ្វើរោងសម្រាប់ប្រើប្រាស់នៅតាមអណ្តូងទឹក ១ ឬគេធ្វើផ្ទះជាទីកម្តៅកាយ ១ ឬគេធ្វើសាលាក្បែរផ្ទះជាទីកម្តៅកាយ ១ ឬគេធ្វើស្រះ ១ ឬគេធ្វើមណ្ឌប ១ ឬគេធ្វើអារាម ១ ឬគេធ្វើទីដីអារាម ១ មានការដណ្តឹង (កូនស្រី) ដើម្បីកូនប្រុសក្តី មានការដណ្តឹង (កូនប្រុស) ដើម្បីកូនស្រីក្តី គេមានជម្ងឺក្តី គេប្រាប់ព្រះសូត្រដែលគេដឹងច្បាស់ក្តី ១ បើឧបាសកនោះបញ្ជូនបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយថា សូមលោកដ៏ចំរើនទាំងឡាយនិមន្តមករៀនយកព្រះសូត្រនេះ កុំឲ្យព្រះសូត្រនេះសាបសូន្យទៅឡើយ ១ មួយវិញទៀត ឧបាសកនោះមានកិច្ចឯណានីមួយក្តី មានកិច្ចគួរធ្វើ (ខានមិនបាន) ក្តី ១ បើឧបាសកនោះបញ្ជូនបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយថា សូមលោកដ៏ចំរើនទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង ១ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនគួរទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់

សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ
ឧបាសកេន សង្ឃំ ឧទ្ទិស្ស វិហារោ ការាបិតោ
ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ
អាគច្ឆន្តុ ភទ្ទន្តា ឥច្ឆាមិ ទានញ្ច ទាតុំ ធម្មញ្ច សោតុំ
ភិក្ខូ ច បស្សិតុន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន
បហិតេ ន ត្វេវ អប្បហិតេ សត្តាហំ សន្និវត្តោ កា-
តព្វោ ។ ឥធ បន ភិក្ខវេ ឧបាសកេន សង្ឃំ ឧទ្ទិស្ស
អឌ្ឍយោគោ ការាបិតោ ហោតិ ។ បាសាទោ ការា-
បិតោ ហោតិ ។ ហម្មិយំ ការាបិតំ ហោតិ ។ គុហា
ការាបិតា ហោតិ ។ បរិវេណំ ការាបិតំ ហោតិ ។
កោដ្ឋកោ ការាបិតោ ហោតិ ។ ឧបដ្ឋានសាលា
ការាបិតា ហោតិ ។ អគ្គិសាលា ការាបិតា ហោតិ ។
កប្បិយកុដិ ការាបិតា ហោតិ ។ វច្ចកុដិ ការាបិ-
តា ហោតិ ។ ចង្កមោ ការាបិតោ ហោតិ ។ ចង្កមន-
សាលា ការាបិតា ហោតិ ។ ឧទបានោ ការាបិ-
តោ ហោតិ ។ ឧទបានសាលា ការាបិតា ហោតិ ។
ជន្តាឃរំ ការាបិតំ ហោតិ ។ ជន្តាឃរសាលា ការាបិតា



វិលវិញក្នុងកំណត់ ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមាន
ឧបាសិកាបានឲ្យគេធ្វើវិហារចំពោះសង្ឃ ។ បើឧបាសិកានោះបញ្ជូន
បម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្ត
មក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុ
ទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមក
ហើយ ភិក្ខុគប្បីទៅដោយសត្តាហករណីយធុរៈ កាលបើគេមិនបញ្ជូន
បម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងកំណត់ ៧
ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសិកាបានឲ្យគេ
ធ្វើអឌ្ឍយោគចំពោះសង្ឃ ។ ឲ្យគេធ្វើប្រាសាទថែវ ។ ឲ្យគេធ្វើប្រាសាទ
ជំពូលត្រើល ។ ឲ្យគេធ្វើគុហា ។ ឲ្យគេធ្វើបរិវេណ ។ ឲ្យគេធ្វើបន្ទប់
ទឹក ។ ឲ្យគេធ្វើរោងសម្រាប់ឆាន់ ។ ឲ្យគេធ្វើរោងភ្លើង ។ ឲ្យគេធ្វើកប្បិយ
កុដិ ។ ឲ្យគេធ្វើវច្ចកុដិ ។ ឲ្យគេធ្វើទីចង្ក្រម ។ ឲ្យគេធ្វើរោងចង្ក្រម ។
ឲ្យគេធ្វើអណ្តូងទឹក ។ ឲ្យគេធ្វើរោងសម្រាប់ប្រើប្រាស់នៅមាត់អណ្តូង
ទឹក ។ ឲ្យគេធ្វើផ្ទះជាទីកម្តៅកាយ ។ ឲ្យគេធ្វើសាលាក្បែរផ្ទះជាទីកម្តៅ

ហោតិ ។ បោក្ខរណី ការាបិតា ហោតិ ។ មណ្ឌបោ ការាបិតោ ហោតិ ។ អារាមោ ការាបិតោ ហោតិ ។ អារាមវត្ថុ ការាបិតំ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អាគច្ឆន្តុ អយ្យា ឥច្ឆាមិ ទានញ្ច ទាតុំ ធម្មញ្ច សោតុំ ភិក្ខូ ច បស្សិតុន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន បហិតេ ន ត្វេវ អប្បហិតេ ។ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ឧបាសកេន សម្ពហុលេ ភិក្ខូ ឧទ្ទិស្ស ។ បេ ។ ឯកំ ភិក្ខុំ ឧទ្ទិស្ស ភិក្ខុនីសង្ឃំ ឧទ្ទិស្ស សម្ពហុលា ភិក្ខុនិយោ ឧទ្ទិស្ស ឯកំ ភិក្ខុនឹ ឧទ្ទិស្ស សម្ពហុលា សិក្ខមានាយោ ឧទ្ទិស្ស ឯកំ សិក្ខមានំ ឧទ្ទិស្ស សម្ពហុលេ សាមណេរេ ឧទ្ទិស្ស ឯកំ សាមណេរំ ឧទ្ទិស្ស សម្ពហុលា សាមណេរិយោ ឧទ្ទិស្ស ឯកំ សាមណេរឹ ឧទ្ទិស្ស ។ បេ ។ អត្តនោ អត្ថាយ និវេសនំ ការាបិតំ ហោតិ ។ សយនិឃរំ ការាបិតំ ហោតិ ។ ឧទ្ទោសិតោ ការាបិតោ ហោតិ ។ អដ្ដោ ការាបិតោ



កាយ ១ ឲ្យគេធ្វើស្រះ ១ ឲ្យគេធ្វើមណ្ឌប ១ ឲ្យគេធ្វើអារាម ១ ឲ្យគេធ្វើទីអារាម ១ បើឧបាសកនោះបញ្ជូនបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្ដាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង ១ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមក ភិក្ខុគប្បីទៅដោយសត្តាហករណីយធុរៈ កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវត្រឡប់មកក្រោយវិញក្នុងរវាង ៧ ថ្ងៃ ១ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកគេបានធ្វើវិហារចំពោះភិក្ខុច្រើនរូប ១ ។បេ។ ចំពោះភិក្ខុ ១ រូប ចំពោះភិក្ខុនីសង្ឃ ចំពោះភិក្ខុនីច្រើនរូប ចំពោះភិក្ខុនី ១ រូប ចំពោះសិក្ខមានាច្រើនរូប ចំពោះសិក្ខមានា ១ រូប ចំពោះសាមណេរច្រើនរូប ចំពោះសាមណេរ ១ រូប ចំពោះសាមណេរីច្រើនរូប ចំពោះសាមណេរី ១ រូប ១ ។បេ។ បានឲ្យគេធ្វើលំនៅចំពោះខ្លួនឯង ១ ឲ្យគេធ្វើផ្ទះសម្រាប់ដេក ១ ឲ្យគេធ្វើឃ្លាំង ១ ឲ្យគេធ្វើប៉ម ( បញ្ហា ) ១

ហោតិ ។ មាឡោ ការាបិតោ ហោតិ ។ អាបណោ ការាបិតោ ហោតិ ។ អាបណសាលា ការាបិតា ហោតិ ។ បាសាទោ ការាបិតោ ហោតិ ។ ហម្មិយំ ការាបិតំ ហោតិ ។ គុហា ការាបិតា ហោតិ ។ បរិវេណំ ការាបិតំ ហោតិ ។ កោដ្ឋកោ ការាបិតោ ហោតិ ។ ឧបដ្ឋានសាលា ការាបិតា ហោតិ ។ អគ្គិ-សាលា ការាបិតា ហោតិ ។ រសវតី ការាបិតា ហោតិ ។ វច្ចកុដិ ការាបិតា ហោតិ ។ ចង្កមោ ការាបិតោ ហោតិ ។ ចង្កមនសាលា ការាបិតា ហោតិ ឧទបានោ ការាបិតោ ហោតិ ។ ឧទបានសាលា ការាបិតា ហោតិ ។ បោក្ខរណី ការាបិតា ហោតិ ។ មណ្ឌបោ ការាបិតោ ហោតិ ។ អារាមោ ការាបិតោ ហោតិ ។ អារាមវត្ថុ ការាបិតំ ហោតិ ។ បុត្តស្ស វា វារេយ្យំ ហោតិ ធីតុយា វា វារេយ្យំ ហោតិ គិលានោ វា ហោតិ អភិញ្ញាតំ វា សុត្តន្តំ ភណតិ ។ សាធុ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អាគច្ឆន្តុ អយ្យា ឥមំ សុត្តន្តំ បរិយាបុណិស្សន្តិ បុរាយំ សុត្តន្តោ ប[១]

១ . [illegible]





ឲ្យគេធ្វើប្រាសាទបួនជ្រុង ។ ឲ្យគេធ្វើហាងផ្សារ ។ ឲ្យគេធ្វើរោងហាងផ្សារ ។ ឲ្យគេធ្វើប្រាសាទវែង ។ ឲ្យគេធ្វើប្រាសាទដំបូលត្រើល ។ ឲ្យគេធ្វើគុហា ។ ឲ្យគេធ្វើបរិវេណ ។ ឲ្យគេធ្វើបន្ទប់ទឹក ។ ឲ្យគេធ្វើរោងសម្រាប់បរិភោគអាហារ ។ ឲ្យគេធ្វើរោងភ្លើង ។ ឲ្យគេធ្វើផ្ទះសម្រាប់ចំអិនអាហារ ។ ឲ្យគេធ្វើវច្ចកុដិ ។ ឲ្យគេធ្វើទីចង្ក្រម ។ ឲ្យគេធ្វើរោងចង្ក្រម ។ ឲ្យគេធ្វើអណ្ដូងទឹក ។ ឲ្យគេធ្វើរោងសម្រាប់ប្រើប្រាស់នៅមាត់អណ្ដូងទឹក ។ ឲ្យគេធ្វើស្រះ ។ ឲ្យគេធ្វើមណ្ឌប ។ ឲ្យគេធ្វើអារាម ។ ឲ្យគេធ្វើទីដីអារាម ។ មានការដណ្ដឹង (កូនស្រី) ដើម្បីកូនប្រុសក្ដី មានការដណ្ដឹង (កូនប្រុស) ដើម្បីកូនស្រីក្ដី គេមានជម្ងឺក្ដី គេប្រាប់ព្រះសូត្រដែលល្បីគេដឹងប្រាកដក្ដី ។ បើឧបាសកនោះបញ្ជូនបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមករៀនយកនូវព្រះសូត្រនេះ កុំឲ្យ

បលុជ្ជតិ ។ អញ្ញតរំ ច បនស្ស កិច្ចំ ហោតិ ករ-
ណីយំ វា ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិ-
ណេយ្យ អាគច្ឆន្តុ អយ្យា ឥច្ឆាមិ ទានញ្ច ទាតុំ
ធម្មញ្ច សោតុំ ភិក្ខូ ច បស្សិតុន្តិ ។ គន្តព្វំ ភិក្ខវេ
សត្តាហករណីយេន បហិតេ ន ត្វេវ អប្បហិតេ សត្តា-
ហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុ-
សង្ឃំ ឧទ្ទិស្ស ភិក្ខុនិយោ សង្ឃំ ឧទ្ទិស្ស សិក្ខមា-
នាយ សង្ឃំ ឧទ្ទិស្ស សាមណេរេ សង្ឃំ ឧទ្ទិស្ស
សាមណេរិយា សង្ឃំ ឧទ្ទិស្ស សម្ពហុលេ ភិក្ខូ ឧទ្ទិស្ស
ឯកំ ភិក្ខុំ ឧទ្ទិស្ស ភិក្ខុនីសង្ឃំ ឧទ្ទិស្ស សម្ពហុលា
ភិក្ខុនិយោ ឧទ្ទិស្ស ឯកំ ភិក្ខុនឹ ឧទ្ទិស្ស សម្ពហុលា
សិក្ខមានាយោ ឧទ្ទិស្ស ឯកំ សិក្ខមានំ ឧទ្ទិស្ស
សម្ពហុលេ សាមណេរេ ឧទ្ទិស្ស ឯកំ សាមណេរំ
ឧទ្ទិស្ស សម្ពហុលា សាមណេរិយោ ឧទ្ទិស្ស ឯកំ
សាមណេរឹ ឧទ្ទិស្ស ។ បេ ។ អត្តនោ អត្ថាយ វិហារោ
ការាបិតោ ហោតិ ។ អឌ្ឍយោគោ ការាបិតោ ហោតិ ។
បាសាទោ ការាបិតោ ហោតិ ។ ហម្មិយំ ការាបិតំ

ព្រះសង្ឃនេះសាងសង់ឲ្យទៅហើយ ។ ម្យ៉ាងទៀត បើទាយិកានោះមាន
កិច្ចណាមួយក្ដី មានកិច្ចត្រូវធ្វើ (ការមង្គល) ក្ដី ។ បើទាយិកានោះ
បញ្ជូនបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយ
និមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្ដាប់ធម៌ផង នឹងឃើញ
ភិក្ខុទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើគេបញ្ជូនបម្រើមក
ហើយ ភិក្ខុគប្បីទៅដោយសត្តាហករណីយធុរៈ កាលបើគេមិនបញ្ជូន
បម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុង ៧
ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានទាយកឲ្យគេធ្វើវិហារចំ-
ពោះសង្ឃ ភិក្ខុនីឲ្យគេធ្វើវិហារចំពោះសង្ឃ សិក្ខមានាឲ្យគេធ្វើវិហារចំពោះ
សង្ឃ សាមណេរឲ្យគេធ្វើវិហារចំពោះសង្ឃ សាមណេរីឲ្យគេធ្វើវិហារចំ-
ពោះសង្ឃ ចំពោះភិក្ខុច្រើនរូប ចំពោះភិក្ខុ ១ រូប ចំពោះភិក្ខុនីសង្ឃ ចំពោះ
ភិក្ខុនីច្រើនរូប ចំពោះភិក្ខុនី ១ រូប ចំពោះសិក្ខមានាច្រើនរូប ចំពោះសិក្ខ-
មានា ១ រូប ចំពោះសាមណេរច្រើនរូប ចំពោះសាមណេរ ១ រូប ចំពោះ
សាមណេរីច្រើនរូប ចំពោះសាមណេរី ១ រូប ។ បេ ។ បានឲ្យគេធ្វើវិហារ
ចំពោះខ្លួនឯង ។ ឲ្យគេធ្វើអឌ្ឍយោគ ។ ឲ្យគេធ្វើប្រាសាទវែង ។ ឲ្យគេ

ហោតិ ។ គុហា ការាបិតា ហោតិ ។ បរិវេណំ ការាបិតំ ហោតិ ។ កោដ្ឋកោ ការាបិតោ ហោតិ ។ ឧបដ្ឋានសាលា ការាបិតា ហោតិ ។ អគ្គិសាលា ការាបិតា ហោតិ ។ កប្បិយកុដិ ការាបិតា ហោតិ ។ វច្ចកុដិ ការាបិតា ហោតិ ។ ចង្កមោ ការាបិតោ ហោតិ ។ ចង្កមនសាលា ការាបិតា ហោតិ ។ ឧទបានោ ការាបិតោ ហោតិ ។ ឧទបានសាលា ការាបិតា ហោតិ ។ បោក្ខរណី ការាបិតា ហោតិ ។ មណ្ឌបោ ការាបិតោ ហោតិ ។ អារាមោ ការាបិតោ ហោតិ ។ អារាមវត្ថុ ការាបិតំ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អាគច្ឆន្តុ ភទ្ទន្តា ឥច្ឆាមិ ទានញ្ច ទាតុំ ធម្មញ្ច សោតុំ ភិក្ខូ ច បស្សិតុន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន បហិតេ ន ត្វេវ អប្បហិតេ សត្តាហំ សន្និវត្តោ កាតព្វោ ។

(៧) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ សោ ភិក្ខូនំ សន្តិកេ ទូតំ បាហេសិ អហំ ហិ គិលានោ អាគច្ឆន្តុ ភិក្ខូ ឥច្ឆាមិ



ធ្វើប្រាសាទដំបូលស្រលិប ។ ឲ្យគេធ្វើគុហា ។ ឲ្យគេធ្វើបរិវេណ ។ ឲ្យគេធ្វើបន្ទប់ទឹក ។ ឲ្យគេធ្វើរោងសម្រាប់បំរើគោតុបការ ។ ឲ្យគេធ្វើរោងភ្លើង ។ ឲ្យគេធ្វើកប្បិយកុដិ ។ ឲ្យគេធ្វើវច្ចកុដិ ។ ឲ្យគេធ្វើទីចង្ក្រម ។ ឲ្យគេធ្វើរោងចង្ក្រម ។ ឲ្យគេជីកអណ្ដូងទឹក ។ ឲ្យគេធ្វើរោងសម្រាប់ប្រើប្រាស់នៅអណ្ដូងទឹក ។ ឲ្យគេធ្វើស្រះ ។ ឲ្យគេធ្វើមណ្ឌប ។ ឲ្យគេធ្វើអារាម ។ ឲ្យគេធ្វើទីអារាម ។ បើឧបាសកនោះបានបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង ចង់ស្ដាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើគេបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហករណីយកិច្ច កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនគួរទៅទេ ភិក្ខុត្រូវតែត្រឡប់មកវិញក្នុងកំណត់ ៧ ថ្ងៃ ។

(៧) សម័យនោះឯង មានភិក្ខុ១រូបមានជម្ងឺ ។ ភិក្ខុនោះបានបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ខ្ញុំមានជម្ងឺ សូមភិក្ខុ

ភិក្ខូនំ អាគតន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។
អនុជានាមិ ភិក្ខវេ បញ្ចន្នំ សត្តាហករណីយេន អប្ប-
ហិតេបិ គន្តុំ បគេវ បហិតេ ភិក្ខុស្ស ភិក្ខុនិយា សិក្ខ-
មានាយ សាមណេរស្ស សាមណេរិយា អនុជានាមិ
ភិក្ខវេ ឥមេសំ បញ្ចន្នំ សត្តាហករណីយេន អប្បហិ-
តេបិ គន្តុំ បគេវ បហិតេ សត្តាហំ សន្និវត្តោ កា-
តព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុ គិលានោ ហោតិ ។
សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ
គិលានោ អាគច្ឆន្តុ ភិក្ខូ ឥច្ឆាមិ ភិក្ខូនំ អាគតន្តិ ។
គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ
បហិតេ គិលានភត្តំ វា បរិយេសិស្សាមិ គិលានុបដ្ឋា-
កភត្តំ វា បរិយេសិស្សាមិ គិលានភេសជ្ជំ វា បរិយេ-



ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ភិក្ខុទាំងឡាយ
ក៏ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាត
ថា ម្នាលភិក្ខុទាំងឡាយ កាលបើសហធម្មិកបុគ្គលទាំង ៥ ពួក គឺភិក្ខុ ១
ភិក្ខុនី ១ សិក្ខមានា ១ សាមណេរ ១ សាមណេរី ១ មិនបានបញ្ជូន
បម្រើមក ក៏តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសត្តាហករណីយ
បាន ចំនឹងនិយាយទៅថ្វីដល់កិច្ចដែលគេបានបញ្ជូនបម្រើមកហើយនោះ
ម្នាលភិក្ខុទាំងឡាយ ពួកសហធម្មិកបុគ្គលទាំង ៥ ពួកនេះទុកជាមិនបាន
បញ្ជូនបម្រើមក ក៏តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសត្តាហករណីយ
បាន ចំនឹងនិយាយទៅថ្វីដល់កិច្ចដែលគេបានបញ្ជូនបម្រើមកនោះ ភិក្ខុត្រូវ
ធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសា-
សនានេះ មានភិក្ខុឈឺ ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុ
ទាំងឡាយថា ខ្ញុំឈឺមានជម្ងឺ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុ
ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ បើទុកជាភិក្ខុឈឺនោះមិន
បានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន ចំនឹង
និយាយទៅថ្វីដល់កិច្ចដែលគេបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើ
ការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងស្វែងរកភត្ត
សម្រាប់ភិក្ខុឈឺក្ដី នឹងស្វែងរកភត្តសម្រាប់ភិក្ខុបម្រើជម្ងឺក្ដី នឹងស្វែងរកថ្នាំ

បេសិស្សាមិ បុច្ឆិស្សាមិ វា ឧបដ្ឋហិស្សាមិ វាតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស អន-ភិរតិ ឧប្បន្នា ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អនភិរតិ មេ ឧប្បន្នា អាគច្ឆន្តុ ភិក្ខូ ឥច្ឆាមិ ភិក្ខូនំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករ-ណីយេន អប្បហិតេបិ បគេវ បហិតេ អនភិរតិំ វូបកាសេស្សាមិ វា វូបកាសាបេស្សាមិ វា ធម្មកថំ វាស្ស ករិស្សាមីតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស កុក្កុច្ចំ ឧប្បន្នំ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ កុក្កុច្ចំ មេ ឧប្បន្នំ អាគច្ឆន្តុ ភិក្ខូ ឥច្ឆាមិ ភិក្ខូនំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ កុក្កុច្ចំ វិនោទេស្សាមិ វា វិនោទាបេស្សាមិ វា ធម្មកថំ វាស្ស



សម្រាប់ភិក្ខុឈឺ ឬនឹងសាកសួរជម្ងឺ ឬនឹងបម្រើជម្ងឺ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ សេចក្ដីអផ្សុក ( ចង់សឹក ) កើតឡើងដល់ភិក្ខុ ។ បើភិក្ខុនោះបញ្ជូនបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយថា សេចក្ដីអផ្សុកកើតឡើងដល់ខ្ញុំហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ បើទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយធុរៈ នឹងនិយាយទៅថ្វីដល់ភិក្ខុដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញដោយគិតថា អាត្មាអញនឹងបំបាត់សេចក្ដីអផ្សុកដោយខ្លួនឯង ឬនឹងឲ្យអ្នកដទៃបំបាត់ ឬនឹងធ្វើនូវធម្មកថាដល់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ សេចក្ដីរង្កៀសកើតឡើងដល់ភិក្ខុហើយ ។ បើភិក្ខុនោះបញ្ជូនបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយថា សេច-ក្ដីរង្កៀសកើតឡើងដល់ខ្ញុំហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ បើទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយធុរៈ នឹងនិយាយទៅថ្វីដល់ភិក្ខុដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងបន្ទោបង់នូវសេចក្ដីរង្កៀសដោយខ្លួនឯង ឬឲ្យអ្នកដទៃបន្ទោបង់ ឬនឹងធ្វើនូវធម្មកថា

ការិស្សាមីតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ តេន ខោ បន ភិក្ខវេ ភិក្ខុស្ស ទិដ្ឋិគតំ ឧប្បន្នំ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ ទិដ្ឋិគតំ មេ ឧប្បន្នំ អាគច្ឆន្តុ ភិក្ខូ ឥច្ឆាមិ ភិក្ខូនំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ ទិដ្ឋិគតំ វិវេចេស្សាមិ វា វិវេចាបេស្សាមិ វា ធម្មកថំ វាស្ស កា-រិស្សាមីតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ តេន ខោ បន ភិក្ខវេ ភិក្ខុ គរុធម្មំ អជ្ឈាបន្នោ ហោតិ បរិវាសារហោ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ គរុធម្មំ អជ្ឈាបន្នោ បរិវាសារហោ អាគច្ឆន្តុ ភិក្ខូ ឥច្ឆាមិ ភិក្ខូនំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ បរិវាសទានំ ឧស្សុក្កំ ករិ-ស្សាមិ វា អនុស្សាវេស្សាមិ វា គណបូរកោ វា ភវិស្សា-មីតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ តេន ខោ បន ភិក្ខវេ



ដល់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ទិដ្ឋិខុសកើតឡើងដល់ភិក្ខុហើយ ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ទិដ្ឋិខុសកើតឡើងដល់ខ្ញុំហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំចង់ឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ បើទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក គឺភិក្ខុគប្បីទៅ ដោយសត្តាហករណីយធុរៈ គឺនិយាយទៅថ្វីដល់ភិក្ខុដែលភិក្ខុបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់ទៅវិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងដោះឬនឹងឲ្យអ្នកដទៃដោះនូវទិដ្ឋិខុស ឬនឹងធ្វើនូវធម្មកថាដល់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុត្រូវគរុធម៌ហើយគួរដល់បរិវាស ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ខ្ញុំត្រូវគរុ-ធម៌ហើយ គួរដល់បរិវាស សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក គឺភិក្ខុគប្បីទៅ ដោយសត្តាហករណីយធុរៈ គឺនិយាយទៅថ្វីដល់ភិក្ខុដែលភិក្ខុបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់ទៅវិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់-ខ្វាយ ឬនឹងសូត្រ (កម្មវាចា) ឬនឹងជាគណបូរកៈ (គឺជាអ្នកបំពេញគណៈសង្ឃ) ក្នុងការឲ្យបរិវាស ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ

ភិក្ខុ មូលាយ បដិកស្សនារហោ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អយំ ហិ មូលាយ បដិកស្សនារហោ អាគច្ឆន្តុ ភិក្ខូ ឥច្ឆាមិ ភិក្ខូនំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ មូលាយ បដិកស្សនំ ឧស្សុក្កំ ករិស្សាមិ វា អនុស្សាវេស្សាមិ វា គណបូរកោ វា ភវិស្សាមីតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ៩៨ ឥធ បន ភិក្ខវេ ភិក្ខុ មានត្តារហោ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អយំ ហិ មានត្តារហោ អាគច្ឆន្តុ ភិក្ខូ ឥច្ឆាមិ ភិក្ខូនំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ មានត្តទានំ ឧស្សុក្កំ ករិស្សាមិ វា អនុស្សាវេស្សាមិ វា គណបូរកោ វា ភវិស្សាមីតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ៩៩ ឥធ បន ភិក្ខវេ ភិក្ខុ អព្ភានារហោ ហោតិ ។ សោ ចេ ភិក្ខូនំ



មានភិក្ខុគួរនឹងទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ខ្ញុំគួរនឹងទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយធុរៈ នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយឬនឹងសូត្រ (កម្មវាចា) ឬជាគណបូរកៈក្នុងការទាញនូវអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុគួរដល់មានត្ត ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ខ្ញុំគួរដល់មានត្តហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំចង់ឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហករណីយធុរៈ នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយឬនឹងសូត្រ ( កម្មវាចា ) ឬនឹងជាគណបូរកៈក្នុងការឲ្យមានត្ត ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុគួរដល់អព្ភានកម្ម ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយ

សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ អព្ភានារហោ អា-គច្ឆន្តុ ភិក្ខូ ឥច្ឆាមិ ភិក្ខូនំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ អព្ភានំ ឧស្សុក្កំ ករិស្សាមិ វា អនុស្សាវេស្សាមិ វា គណបូ-រកោ វា ភវិស្សាមីតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស សង្ឃោ កម្មំ កត្តុកាមោ ហោតិ តជ្ជនីយំ វា និយស្សំ វា បព្វាជនីយំ វា បដិ-សារណីយំ វា ឧក្ខេបនីយំ វា ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ សង្ឃោ មេ កម្មំ កត្តុ-កាមោ អាគច្ឆន្តុ ភិក្ខូ ឥច្ឆាមិ ភិក្ខូនំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ កិន្តិ នុ ខោ សង្ឃោ កម្មំ ន ករេយ្យ ល-ហុកាយ វា បរិណាមេយ្យាតិ សត្តាហំ សន្និវត្តោ កា-តព្វោ ។ កតំ វា បនស្ស ហោតិ សង្ឃេន កម្មំ តជ្ជ-នីយំ វា និយស្សំ វា បព្វាជនីយំ វា បដិសារណីយំ



ថា ខ្ញុំគួរដល់អព្ភានកម្មហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់ភិក្ខុដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់-ខ្វាយឬនឹងសូត្រ (កម្មវាចា) ឬនឹងជាគណបូរកៈក្នុងអព្ភានកម្ម ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ សង្ឃមានសេចក្តីប្រាថ្នាដើម្បីធ្វើនូវកម្មគឺតជ្ជ-នីយកម្ម និយស្សកម្ម បព្វាជនីយកម្ម បដិសារណីយកម្ម ឧក្ខេបនីយ-កម្ម ដល់ភិក្ខុហើយ ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ឥឡូវសង្ឃមានសេចក្តីប្រាថ្នាដើម្បីធ្វើនូវកម្មដល់ខ្ញុំហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់ភិក្ខុដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃដោយគិតថា សង្ឃមិនគួរធ្វើនូវកម្ម ឬគួរបង្អោនទៅរកដើម្បីកម្មស្រាលដោយទំនាយដូចម្តេចហ្ន៎ ។ ម្យ៉ាងទៀត កម្ម គឺតជ្ជនីយកម្ម និយស្សកម្ម បព្វាជនីយកម្ម បដិសារណីយកម្ម ឧក្ខេបនីយកម្ម សង្ឃបានធ្វើ

វា ឧក្ខេបនីយំ វា ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ សង្ឃោ មេ កម្មំ អកាសិ អាគច្ឆន្តុ ភិក្ខូ ឥច្ឆាមិ ភិក្ខូនំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ កិន្តិ នុ ខោ សង្ឃោ សម្មា វត្តេយ្យ លោមំ បាតេយ្យ នេត្ថារំ វត្តេយ្យ សង្ឃោ តំ កម្មំ បដិប្បស្សម្ភេយ្យាតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុនី គិលានា ហោតិ ។ សា ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ គិលានា អាគច្ឆន្តុ អយ្យា ឥច្ឆាមិ អយ្យានំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ គិលានភត្តំ វា បរិយេសិស្សាមិ គិលានុបដ្ឋាកភត្តំ វា បរិយេសិស្សាមិ គិលានភេសជ្ជំ វា បរិយេសិស្សាមិ បុច្ឆិស្សាមិ វា ឧបដ្ឋហិស្សាមិ វាតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុនិយា



ដល់ភិក្ខុនោះហើយ ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សង្ឃសម្រេចបាននូវកម្មដល់ខ្ញុំហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន ចាំបាច់និយាយទៅថ្វីដល់ភិក្ខុដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា ភិក្ខុនោះគួរប្រព្រឹត្តវត្តដោយប្រពៃ គួរសម្រួលរោម គួរប្រព្រឹត្តវត្តសមគួរដល់កិរិយាលោះខ្លួនចេញចាកទោស សង្ឃគប្បីរម្ងាប់នូវកម្មនោះចេញដោយប្រការដូចម្តេចហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុនីឈឺ ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ព្រោះខ្ញុំមានជម្ងឺ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន ចាំបាច់និយាយទៅថ្វីដល់ភិក្ខុនីដែលភិក្ខុនីបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងស្វែងរកគិលានភត្ត ស្វែងរកគិលានុបដ្ឋាកភត្ត ស្វែងរកគិលានភេសជ្ជៈក្តី នឹងសួរជម្ងឺក្តី នឹងបម្រើជម្ងឺក្តី ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សេចក្តីកម្រេក

ភិក្ខុនិយា អនភិរតិ ឧប្បន្នា ហោតិ ។ សា ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អនភិរតិ មេ ឧប្បន្នា អាគច្ឆន្តុ អយ្យា ឥច្ឆាមិ អយ្យានំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ អនភិរតឹ វូបកាសេស្សាមិ វា វូបកាសាបេស្សាមិ វា ធម្មកថំ វាស្សា ការិស្សាមីតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុនិយា កុក្កុច្ចំ ឧប្បន្នំ ហោតិ ។ សា ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ កុក្កុច្ចំ មេ ឧប្បន្នំ អាគច្ឆន្តុ អយ្យា ឥច្ឆាមិ អយ្យានំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ កុក្កុច្ចំ វិនោទេស្សាមិ វា វិនោទាបេស្សាមិ វា ធម្មកថំ វាស្សា ការិស្សាមីតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុនិយា



កើតឡើងដល់ភិក្ខុនីហើយ ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សេចក្ដីអផ្សុកកើតឡើងដល់ខ្ញុំហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក គឺភិក្ខុគប្បីទៅដោយសត្តាហករណីយធុរៈ នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃដោយគិតថា អាត្មាអញនឹងរំងាប់សេចក្ដីអផ្សុករបស់ភិក្ខុនី ឬនឹងឲ្យអ្នកដទៃរំងាប់ ឬនឹងធ្វើធម្មកថាដល់ភិក្ខុនីនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីសាសនានេះ សេចក្ដីរង្កៀសកើតឡើងដល់ភិក្ខុនីហើយ ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សេចក្ដីរង្កៀសកើតឡើងដល់ខ្ញុំហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក គឺភិក្ខុគប្បីទៅដោយសត្តាហករណីយធុរៈ នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុនីបញ្ជូនបម្រើមកៈហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងបន្ទោបង់ ឬនឹងឲ្យអ្នកដទៃបន្ទោបង់នូវសេចក្ដីរង្កៀស ឬនឹងធ្វើធម្មកថាដល់ភិក្ខុនីនោះ ។ ម្នាលភិក្ខុ

ទិដ្ឋិគតំ ឧប្បន្នំ ហោតិ ។ សា ចេ ភិក្ខុនីនំ សន្តិកេ ទូតំ បហិណេយ្យ ទិដ្ឋិគតំ មេ ឧប្បន្នំ អាគច្ឆន្តុ អយ្យា ឥច្ឆាមិ អយ្យានំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ ទិដ្ឋិគតំ វិវេចេស្សាមិ វា វិវេចាបេស្សាមិ វា ធម្មកថំ វាស្ស ករិស្សាមីតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុនី គរុធម្មំ អជ្ឈាបន្នា ហោតិ មានត្តារហា ។ សា ចេ ភិក្ខុនីនំ សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ គរុធម្មំ អជ្ឈាបន្នា មានត្តារហា អាគច្ឆន្តុ អយ្យា ឥច្ឆាមិ អយ្យានំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ មានត្តទានំ ឧស្សុក្កំ ករិស្សាមីតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុនី មូលាយ បដិកស្សនារហា ហោតិ ។ សា ចេ ភិក្ខុនីនំ



ទាំងឡាយ ក្នុងសាសនានេះ ទិដ្ឋិគតកើតឡើងដល់ភិក្ខុនីហើយ ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ទិដ្ឋិគតកើតឡើងដល់ខ្ញុំហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់ភិក្ខុដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងដោះ ឬនឹងឲ្យអ្នកដទៃជួយដោះនូវទិដ្ឋិគត ឬនឹងធ្វើនូវធម្មកថាដល់ភិក្ខុនីនោះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុនីត្រូវគរុធម៌គួរដល់មានត្តហើយ ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំត្រូវគរុធម៌គួរដល់មានត្តហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់ភិក្ខុដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយក្នុងការឲ្យនូវមានត្ត ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុនីគួរនឹងទាញអត្តភាពមកក្នុងមូលាបត្តិ ។

សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ មូលាយ បដិកស្ស-
នារហា អាគច្ឆន្តុ អយ្យា ឥច្ឆាមិ អយ្យានំ អាគតន្តិ ។
គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ ប-
គេវ បហិតេ មូលាយ បដិកស្សនំ ឧស្សុក្កំ ករិស្សាមីតិ
សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុនី
អព្ភានារហា ហោតិ ។ សា ចេ ភិក្ខូនំ សន្តិកេ ទូតំ
បហិណេយ្យ អហំ ហិ អព្ភានារហា អាគច្ឆន្តុ អយ្យា
ឥច្ឆាមិ អយ្យានំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករ-
ណីយេន អប្បហិតេបិ បគេវ បហិតេ អព្ភានំ ឧស្សុក្កំ
ករិស្សាមីតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន
ភិក្ខវេ ភិក្ខុនិយា សង្ឃោ កម្មំ កត្តុកាមោ ហោតិ
តជ្ជនីយំ វា និយស្សំ វា បព្វាជនីយំ វា បដិសា-
រណីយំ វា ឧក្ខេបនីយំ វា ។ សា ចេ ភិក្ខូនំ



បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ខ្ញុំករុណា
គួរនឹងទាញអន្តរាបត្តិមកចូលក្នុងមូលាបត្តិ សូមលោកម្ចាស់ទាំងឡាយនិមន្ត
មក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ
ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហ-
ករណីយបាន ចាំបាច់និយាយទៅថ្វីដល់ភិក្ខុដែលភិក្ខុនីបញ្ជូនបម្រើមកហើយ
នោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញ
នឹងធ្វើសេចក្ដីខ្វល់ខ្វាយក្នុងការទាញអន្តរាបត្តិមកចូលក្នុងមូលាបត្តិ ។ ម្នាល
ភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុនីគួរដល់អព្ភានកម្មហើយ ។
បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ខ្ញុំករុណា
គួរដល់អព្ភានកម្មហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណា
ប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជា
ភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហករណីយ
បាន ចាំបាច់និយាយទៅថ្វីដល់ភិក្ខុដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុ
ត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើ
សេចក្ដីខ្វល់ខ្វាយក្នុងអព្ភានកម្ម ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនា
នេះ សង្ឃប្រាថ្នានឹងធ្វើកម្មគឺ តជ្ជនីយកម្មក្ដី និយស្សកម្មក្ដី បព្វាជនីយកម្មក្ដី
បដិសារណីយកម្មក្ដី ឧក្ខេបនីយកម្មក្ដី ដល់ភិក្ខុនី ។ បើភិក្ខុនីនោះ

សន្តិកេ ទូតំ បហិណេយ្យ សង្ឃោ មេ កម្មំ កត្តុ-
កាមោ អាគច្ឆន្តុ អយ្យា ឥច្ឆាមិ អយ្យានំ អាគតន្តិ ។
គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ
បហិតេ កិន្តិ នុ ខោ សង្ឃោ កម្មំ ន ករេយ្យ
លហុកាយ វា បរិណាមេយ្យាតិ សត្តាហំ សន្និវត្តោ
កាតព្វោ ។ កតំ វា បនស្សា ហោតិ សង្ឃេន កម្មំ
តជ្ជនីយំ វា និយស្សំ វា បព្វាជនីយំ វា បដិសារណីយំ
វា ឧក្ខេបនីយំ វា ។ សា ចេ ភិក្ខូនំ សន្តិកេ ទូតំ
បហិណេយ្យ សង្ឃោ មេ កម្មំ អកាសិ អាគច្ឆន្តុ
អយ្យា ឥច្ឆាមិ អយ្យានំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ
សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ កិន្តិ
នុ ខោ សម្មា វត្តេយ្យ លោមំ បាតេយ្យ នេត្ថារំ វត្តេយ្យ
សង្ឃោ តំ កម្មំ បដិប្បស្សម្ភេយ្យាតិ សត្តាហំ
សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ សិក្ខមានា





បញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សង្ឃប្រុងនឹងធ្វើកម្មដល់ខ្ញុំ
ករុណាហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោក
ម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបាន
បញ្ជូនបម្រើមក ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន ដោយនិយាយ
ទៅថាដល់កិច្ចដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់
វិលវិញក្នុងរវាង ៧ ថ្ងៃដោយគិតថា សង្ឃមិនគួរធ្វើកម្មឬគួរតែបង្អោនទៅ
ជាកម្មស្រាលដោយប្រការដូចម្តេចហ្ន៎ ។ មួយទៀត សង្ឃបានធ្វើកម្ម
គឺតជ្ជនីយកម្ម និយស្សកម្ម បព្វាជនីយកម្ម បដិសារណីយកម្ម
ឧក្ខេបនីយកម្ម ដល់ភិក្ខុនីនោះហើយ ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅ
ក្នុងសំណាក់ភិក្ខុទាំងឡាយថា សង្ឃបានធ្វើកម្មដល់ខ្ញុំករុណាហើយ សូម
លោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយ
និមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើ
មក ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន ដោយនិយាយទៅថាដល់កិច្ច
ដែលភិក្ខុនីបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ
ក្នុងរវាង ៧ ថ្ងៃដោយគិតថា ភិក្ខុនីនោះគួរប្រព្រឹត្តដោយប្រពៃ គួរបន្ទាប
រោម គួរប្រព្រឹត្ត សមគួរដល់កិរិយារលាស់ខ្លួនចេញចាកទោស សង្ឃ
គប្បីរម្ងាប់កម្មនោះដោយប្រការដូចម្តេចហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី

គិលានា ហោតិ ។ សា ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ គិលានា អាគច្ឆន្តុ អយ្យា ឥច្ឆាមិ អយ្យានំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ គិលានភត្តំ វា បរិយេសិស្សាមិ គិលានុបដ្ឋាកភត្តំ វា បរិយេសិស្សាមិ គិលានភេសជ្ជំ វា បរិយេសិស្សាមិ បុច្ឆិស្សាមិ វា ឧបដ្ឋហិស្សាមិ វាតិ ។ សត្តាហំ សន្និវត្តោ កាតព្វោ ។

ឥធ បន ភិក្ខវេ សិក្ខមានាយ អនភិរតិ ឧប្បន្នា ហោតិ ។បេ។ កុក្កុច្ចំ ឧប្បន្នំ ហោតិ ។ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ ។ សិក្ខា កុប្បិតា ហោតិ ។ សា ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ សិក្ខា មេ កុប្បិតា អាគច្ឆន្តុ អយ្យា ឥច្ឆាមិ អយ្យានំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ សិក្ខាសមាទានំ ឧស្សុក្កំ ករិស្សាមីតិ,



សាសនានេះ សិក្ខមានាមានជម្ងឺ ។ បើសិក្ខមានានោះបញ្ជូនបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយថា ព្រោះខ្ញុំមានជម្ងឺ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាសិក្ខមានានោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន ចាំបាច់និយាយទៅថ្វីដល់កិច្ចដែលសិក្ខមានាបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងស្វែងរកគិលានភត្ត ឬនឹងស្វែងរកគិលានុបដ្ឋាកភត្ត ឬនឹងស្វែងរកគិលានភេសជ្ជៈ ឬនឹងសួរជម្ងឺ ឬនឹងបម្រើជម្ងឺ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សេចក្ដីអផ្សុកកើតឡើងដល់សិក្ខមានាហើយ ។បេ។ សេចក្ដីរង្កៀសកើតឡើងហើយ ។ ទិដ្ឋិខុសកើតឡើងហើយ ។ សិក្ខាកម្រើក (គឺដាច់សិក្ខាសម្មតិ) ហើយ ។ បើសិក្ខមានានោះបញ្ជូនបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយថា ឥឡូវសិក្ខារបស់ខ្ញុំករុណាកម្រើកហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាសិក្ខមានានោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន ចាំបាច់និយាយទៅថ្វីដល់កិច្ចដែលសិក្ខមានាបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃដោយគិតថា អាត្មាអញ

សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ សិក្ខមានា ឧបសម្បជ្ជិតុកាមា ហោតិ ។ សា ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ ឧប-សម្បជ្ជិតុកាមា អាគច្ឆន្តុ អយ្យា ឥច្ឆាមិ អយ្យានំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ ឧបសម្បទំ ឧស្សុក្កំ ករិស្សាមិ វា អនុស្សាវេស្សាមិ វា គណបូរកោ វា ភវិស្សាមីតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ សាមណេរោ គិលានោ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ គិលានោ អាគច្ឆន្តុ ភិក្ខូ ឥច្ឆាមិ ភិក្ខូនំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ គិលានភត្តំ វា បរិយេសិស្សាមិ គិលានុបដ្ឋាកភត្តំ



ទៅធ្វើសេចក្ដីខ្វល់ខ្វាយក្នុងការសមាទានសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានសិក្ខមានាប្រាថ្នានឹងឧបសម្បទា ។ បើសិក្ខមានានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ខ្ញុំនេះប្រាថ្នានឹងឧបសម្បទា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាសិក្ខមានានោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន ចាំបាច់និយាយទៅថ្វីដល់ភិក្ខុដែលសិក្ខមានាបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងធ្វើសេចក្ដីខ្វល់ខ្វាយក្នុងឧបសម្បទា ឬនឹងសូត្រ (កម្មវាចា) ឬនឹងជាគណបូរកៈក្នុងឧបសម្បទាកម្ម ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានសាមណេរឈឺ ។ បើសាម-ណេរនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ខ្ញុំករុណាឈឺ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន ចាំបាច់និយាយទៅថ្វីដល់ភិក្ខុដែលសាមណេរបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងជួយស្វែងរកគិលានភត្ត ស្វែងរក

វា បរិយេសិស្សាមិ គិលានភេសជ្ជំ វា បរិយេសិស្សាមិ បុច្ឆិស្សាមិ វា ឧបដ្ឋហិស្សាមិ វាតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ សាមណេរស្ស អនភិរតិ ឧប្បន្នា ហោតិ ។បេ។ កុក្កុច្ចំ ឧប្បន្នំ ហោតិ ។ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ ។ សាមណេរោ វស្សំ បុច្ឆិតុកាមោ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ វស្សំ បុច្ឆិតុកាមោ អាគច្ឆន្តុ ភិក្ខូ ឥច្ឆាមិ ភិក្ខូនំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហំ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ បុច្ឆិស្សាមិ វា អាចិក្ខិស្សាមិ វាតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ សាមណេរោ ឧបសម្បទាបេក្ខោ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ ឧបសម្បជ្ជិតុកាមោ អាគច្ឆន្តុ ភិក្ខូ ឥច្ឆាមិ ភិក្ខូនំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ



គិលានុបដ្ឋាកភត្ត ស្វែងរកគិលានភេសជ្ជៈ សាកសួរផង បម្រើផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីត្រឡប់មកវិញ ក្នុងសាសនានេះ សេចក្ដីអផ្សុកកើតឡើងដល់សាមណេរ ។បេ។ សេចក្ដីរង្កៀសកើតឡើងដល់សាមណេរ ។ ទិដ្ឋិកើតឡើងដល់សាមណេរ ។ សាមណេរមានការប្រាថ្នាដើម្បីសួរនូវវស្សា ។ បើសាមណេរនោះបញ្ជូនបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយថា ខ្ញុំករុណាមានការប្រាថ្នាដើម្បីសួរនូវវស្សា សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហករណីយធុរៈ នឹងនិយាយទៅថ្វីដល់ភិក្ខុដែលសាមណេរបញ្ជូនបម្រើមកហើយនោះ ភិក្ខុគប្បីធ្វើការត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងសាកសួរវស្សាឬនឹងប្រាប់វស្សា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានសាមណេរចង់ឧបសម្បទា ។ បើសាមណេរនោះបញ្ជូនបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយថា ខ្ញុំករុណាចង់ឧបសម្បទា សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហករណីយធុរៈ នឹងនិយាយទៅថ្វីដល់ភិក្ខុដែល

ឧបសម្បទំ ឧស្សុក្កំ ការិស្សាមិ វា អនុស្សាវេស្សាមិ វា គណបូរកោ វា ភវិស្សាមីតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ សាមណេរោ គិលានោ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ គិលានោ អាគច្ឆន្តុ អយ្យា ឥច្ឆាមិ អយ្យានំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ គិលានភត្តំ វា បរិយេសិស្សាមិ គិលានុបដ្ឋាកភត្តំ វា បរិយេសិស្សាមិ គិលានភេសជ្ជំ វា បរិយេសិស្សាមិ បុច្ឆិស្សាមិ វា ឧបដ្ឋហិស្សាមិ វាតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ សាមណេរស្ស អនភិរតិ ឧប្បន្នា ហោតិ ។ កុក្កុច្ចំ ឧប្បន្នំ ហោតិ ។ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ ។ សាមណេរោ វស្សំ បុច្ឆិតុកាមោ ហោតិ ។ សិក្ខំ សមាទិយិតុកាមោ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ សិក្ខំ





សាមណេរបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងធ្វើសេចក្ដីខ្វល់ខ្វាយ ឬនឹងស្មូត្រ (កម្មវាចា) ឬនឹងជាគណបូរកៈក្នុងឧបសម្បទាកម្ម ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានសាមណេរឈឺ ។ បើសាមណេរនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ព្រោះខ្ញុំមានជំងឺ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរនោះ មិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន ចាំបាច់ពោលទៅថ្វីដល់ភិក្ខុដែលសាមណេរបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងស្វែងរកគិលានភត្តឬស្វែងរកគិលានុបដ្ឋាកភត្តឬស្វែងរកគិលានភេសជ្ជៈ ឬសួរជម្ងឺ ឬបម្រើជម្ងឺ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សេចក្ដីអផ្សុកកើតឡើងដល់សាមណេរ ។ សេចក្ដីរង្កៀសកើតឡើងដល់សាមណេរ ។ ទិដ្ឋិខុសកើតឡើងដល់សាមណេរ ។ សាមណេរមានសេចក្ដីប្រាថ្នា ដើម្បីនឹងសួរឆ្នាំវស្សា ។ មានសេចក្ដីប្រាថ្នា ដើម្បីសមាទាននូវសិក្ខា ។ បើសាមណេរនោះ បញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ព្រោះខ្ញុំមានសេចក្ដីប្រាថ្នា ដើម្បីសមាទាននូវសិក្ខា សូមលោកម្ចាស់

សមាទិយិតុកាមា អាគច្ឆន្តុ អយ្យា ឥច្ឆាមិ អយ្យានំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ សិក្ខាសមាទានំ ឧស្សុក្កំ ករិស្សាមីតិ សត្តាហំ សន្និវត្តោ កាតព្វោតិ ។

(៤) តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ មាតា គិលានា ហោតិ ។ សា បុត្តស្ស សន្តិកេ ទូតំ បាហេសិ អហំ ហិ គិលានា ឥច្ឆាមិ បុត្តស្ស អាគតន្តិ ។ អថ ខោ តស្ស ភិក្ខុនោ ឯតទហោសិ ភគវតា បញ្ញត្តំ សត្តន្នំ សត្តាហករណីយេន បហិតេ គន្តុំ ន ត្វេវ អប្បហិតេ បញ្ចន្នំ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ អយញ្ច មេ មាតា គិលានា សា ច អនុបាសិកា កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជា-



ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន ចាំបាច់និយាយទៅថ្វីដល់ភិក្ខុដែលសាមណេរីបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិញក្នុងវេលា ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងធ្វើនូវសេចក្តីខ្វល់ខ្វាយក្នុងការសមាទានសិក្ខា ។

(៤) សម័យនោះឯង មាតារបស់ភិក្ខុ ១ រូបមានជម្ងឺ ។ មាតានោះក៏បានបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុជាកូនថា ដ្បិតខ្ញុំមានជម្ងឺ ខ្ញុំចង់ឲ្យលោកកូននិមន្តមក ។ គ្រាវេលានោះ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយថា កាលបើជនទាំង ៧ ពួកបានបញ្ជូនបម្រើមកហើយ ភិក្ខុគួរទៅដោយសត្តាហករណីយបាន កាលបើជនទាំង ៧ ពួក មិនបញ្ជូនបម្រើមកទេ ភិក្ខុមិនគួរទៅទេ ចំណែកឯពួកសហធម្មិកបុគ្គលទាំង ៥ វិញ មិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគួរទៅដោយសត្តាហករណីយបាន ចាំបាច់និយាយទៅថ្វីដល់ភិក្ខុដែលគេបញ្ជូនបម្រើមកហើយនោះ តែឥឡូវមាតារបស់អញនេះមានជម្ងឺ តែមាតានោះមិនមែនជាឧបាសិកា តើអាត្មាអញត្រូវប្រតិបត្តិដូចម្តេចហ្ន៎ ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាត

នាមិ ភិក្ខវេ សត្តន្នំ សត្តាហករណីយេន អប្បហិតេ-
បិ គន្តុំ បគេវ បហិតេ ភិក្ខុស្ស ភិក្ខុនិយា សិក្ខមានា-
យ សាមណេរស្ស សាមណេរិយា មាតុយា ច បិតុស្ស
ច អនុជានាមិ ភិក្ខវេ ឥមេសំ សត្តន្នំ សត្តាហករ-
ណីយេន អប្បហិតេបិ គន្តុំ បគេវ បហិតេ សត្តាហំ
សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស មាតា
គិលានា ហោតិ ។ សា ចេ បុត្តស្ស សន្តិកេ ទូតំ
បហិណេយ្យ អហំ ហិ គិលានា អាគច្ឆតុ មេ បុត្តោ
ឥច្ឆាមិ បុត្តស្ស អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហ-
ករណីយេន អប្បហិតេបិ បគេវ បហិតេ គិលានភត្តំ
វា បរិយេសិស្សាមិ គិលានុបដ្ឋាកភត្តំ វា បរិយេ-
សិស្សាមិ គិលានភេសជ្ជំ វា បរិយេសិស្សាមិ បុច្ឆិស្សាមិ
វា ឧបដ្ឋហិស្សាមិ វាតិ សត្តាហំ សន្និវត្តោ កាតព្វោ ។
ឥធ បន ភិក្ខវេ ភិក្ខុស្ស បិតា គិលានោ ហោតិ ។ សោ
ចេ បុត្តស្ស សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ



១ ម្នាលភិក្ខុទាំងឡាយ ទុកជាពួកជនទាំង ៧ គឺ ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី មាតា បិតា មិនបានបញ្ជូនបម្រើមក ក៏តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសត្តាហករណីយបាន ចាំបាច់និយាយទៅថ្វី ដល់កិច្ចដែលគេបានបញ្ជូនបម្រើមកហើយនោះ ម្នាលភិក្ខុទាំងឡាយ ទុកជាពួកជនទាំង ៧ នេះមិនបានបញ្ជូនបម្រើមក ក៏តថាគតអនុញ្ញាតឲ្យភិក្ខុទៅដោយសត្តាហករណីយបាន ចាំបាច់និយាយទៅថ្វីដល់កិច្ចដែលគេបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិញក្នុងរវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មាតារបស់ភិក្ខុមានជម្ងឺ ។ បើមាតានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុជាកូនថា ខ្ញុំឈឺមានជម្ងឺ សូមលោកកូនរបស់ខ្ញុំនិមន្តមក ខ្ញុំចង់ឲ្យលោកកូននិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាមាតាមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន ចាំបាច់និយាយទៅថ្វីដល់កិច្ចដែលមាតាបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងស្វែងរកគិលានភត្ត នឹងស្វែងរកគិលានុបដ្ឋាកភត្ត នឹងស្វែងរកគិលានភេសជ្ជ ឬនឹងសួរជម្ងឺ ឬនឹងបម្រើជម្ងឺ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បិតារបស់ភិក្ខុមានជម្ងឺ ។ បើបិតានោះបញ្ជូនបម្រើទៅ

គិលានោ អាគច្ឆតុ មេ បុត្តោ ឥច្ឆាមិ បុត្តស្ស អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន អប្បហិតេបិ បគេវ បហិតេ គិលានភត្តំ វា បរិយេសិស្សាមិ គិលានុបដ្ឋាកភត្តំ វា បរិយេសិស្សាមិ គិលានភេសជ្ជំ វា បរិយេសិស្សាមិ បុច្ឆិស្សាមិ វា ឧបដ្ឋហិស្សាមិ វាតិ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ភាតា គិលានោ ហោតិ ។ សោ ចេ ភាតុនោ សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ គិលានោ អាគច្ឆតុ មេ ភាតា ឥច្ឆាមិ ភាតុនោ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន បហិតេ ន ត្វេវ អប្បហិតេ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ភគិនី គិលានា ហោតិ ។ សា ចេ ភិក្ខុស្ស សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ គិលានា អាគច្ឆតុ មេ ភាតា ឥច្ឆាមិ ភាតុនោ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន



កាន់សំណាក់ភិក្ខុជាកូនថា ព្រោះខ្ញុំមានជម្ងឺ សូមឲ្យលោកកូនរបស់ខ្ញុំនិមន្តមក ខ្ញុំចង់ឲ្យលោកកូននិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាបិតាមិនបានបញ្ជូនបម្រើមក ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន ទំនងនិយាយទៅថ្វីដល់ភិក្ខុដែលបិតាបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងស្វែងរកគិលានភត្ត នឹងស្វែងរកគិលានុបដ្ឋាកភត្ត នឹងស្វែងរកគិលានភេសជ្ជៈ ឬនឹងសួរជម្ងឺ ឬនឹងបម្រើជម្ងឺ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ បងប្អូនប្រុសរបស់ភិក្ខុមានជម្ងឺ ។ បើបងប្អូនប្រុសនោះបញ្ជូនបម្រើទៅកាន់សំណាក់ភិក្ខុជាបងប្អូនថា ព្រោះខ្ញុំមានជម្ងឺ សូមឲ្យលោកជាបងប្អូនរបស់ខ្ញុំនិមន្តមក ខ្ញុំចង់ឲ្យលោកជាបងប្អូននិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ កាលបើបងប្អូនប្រុសបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន បើបងប្អូនប្រុសមិនបានបញ្ជូនបម្រើមកទេ ភិក្ខុមិនគួរទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ បងប្អូនស្រីរបស់ភិក្ខុមានជម្ងឺ ។ បើបងប្អូនស្រីនោះបញ្ជូនបម្រើទៅកាន់សំណាក់ភិក្ខុថា ព្រោះខ្ញុំមានជម្ងឺ សូមឲ្យលោកជាបងប្អូនប្រុសរបស់ខ្ញុំនិមន្តមក ខ្ញុំត្រូវការឲ្យលោកជាបងប្អូនប្រុសនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ កាលបើបងប្អូនស្រីបានបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហករណីយ

បហិតេ ន ត្វេវ អប្បហិតេ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ញាតកោ គិលានោ ហោតិ ។ សោ ចេ ភិក្ខុស្ស សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ គិលានោ អាគច្ឆតុ ភទ្ទន្តោ ឥច្ឆាមិ ភទ្ទន្តស្ស អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន បហិតេ ន ត្វេវ អប្បហិតេ សត្តាហំ សន្និវត្តោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ភតកោ គិលានោ ហោតិ ។ សោ ចេ ភិក្ខូនំ សន្តិកេ ទូតំ បហិណេយ្យ អហំ ហិ គិលានោ អាគច្ឆន្តុ ភិក្ខូ ឥច្ឆាមិ ភិក្ខូនំ អាគតន្តិ ។ គន្តព្វំ ភិក្ខវេ សត្តាហករណីយេន បហិតេ ន ត្វេវ អប្បហិតេ សត្តាហំ សន្និវត្តោ កាតព្វោតិ ។

(៥) តេន ខោ បន សមយេន សង្ឃស្ស វិហារោ[១] ឧទ្រិយតិ ។ អញ្ញតរេន ឧបាសកេន អរញ្ញេ ភណ្ឌំ ឆេទាបិតំ ហោតិ ។ សោ ភិក្ខូនំ សន្តិកេ

១. វិហារោ ។



បាន កាលបើបងប្អូនស្រីមិនបានបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិញក្នុងរវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ញាតិរបស់ភិក្ខុមានជម្ងឺ ។ បើញាតិនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុថា ព្រោះខ្ញុំមានជម្ងឺ សូមឲ្យលោកដ៏ចំរើននិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកដ៏ចំរើននិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ កាលបើញាតិបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន កាលបើញាតិមិនបានបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិញក្នុងរវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ អ្នកធ្វើការឈ្នួលរបស់ភិក្ខុមានជម្ងឺ ។ បើអ្នកធ្វើការឈ្នួលនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ព្រោះខ្ញុំករុណាមានជម្ងឺ សូមឲ្យភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកធ្វើការឈ្នួលបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន កាលបើអ្នកធ្វើការឈ្នួលមិនបានបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិញក្នុងរវាង ៧ ថ្ងៃ ។

(៥) សម័យនោះឯង មហាវិហាររបស់សង្ឃបាក់បែកទ្រុឌទ្រោមទៅ មានឧបាសកម្នាក់ បានឲ្យគេកាប់យកគ្រឿងឈើទៅក្នុងព្រៃ ។ ឧបាសកនោះក៏បានបញ្ជូនបម្រើទៅ ក្នុងសំណាក់ភិក្ខុទាំងឡាយថា បើ

ទូតំ បាហេសិ សចេ ភទ្ទន្តា តំ ភណ្ឌំ អាវហាបេយ្យុំ ទជ្ជាហំ តំ ភណ្ឌន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សង្ឃករណីយេន គន្តុំ សត្តាហំ សន្និវត្តោ កាតព្វោតិ ។

វស្សូបនាយិកភាណវារំ និដ្ឋិតំ បឋមំ ។

(១០) តេន ខោ បន សមយេន កោសលេសុ ជនបទេសុ អញ្ញតរស្មឹ អាវាសេ វស្សូបគតា ភិក្ខូ វាឡេហិ ឧព្ពាឡ្ហា ហោន្តិ ។ គណ្ហិំសុបិ បរិបាតិំសុបិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ឥធ បន ភិក្ខវេ ភិក្ខូ វស្សូបគតា វាឡេហិ ឧព្ពាឡ្ហា ហោន្តិ ។ គណ្ហន្តិបិ បរិបាតេន្តិបិ ។ ឯសេវ អន្តរាយោតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ ភិក្ខូ វស្សូបគតា



លោកសីនឹងកើតតាំងឲ្យមានតប្បុរសនាំយកគ្រឿងឈើនោះទៅបាន ខ្ញុំករុណានឹងប្រគេនគ្រឿងឈើនោះ ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសង្ឃករណីយៈ (កិច្ចដែលសង្ឃត្រូវធ្វើ) បាន ហើយត្រូវត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃ ។

ចប់ ភាណវារៈ សំដែងអំពីភិក្ខុនៅចាំវស្សាជាបឋម ។

(១០) សម័យនោះឯង ភិក្ខុទាំងឡាយបានចាំវស្សាក្នុងអាវាស ១ ក្នុងកោសលជនបទ ពួកសត្វសាហាវតែងទៅបៀតបៀន ។ ពួកសត្វសាហាវនោះមកចាប់ភិក្ខុទាំងនោះខ្លះ មកពោមព័ទ្ធបង្អើលភិក្ខុទាំងនោះខ្លះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ភិក្ខុទាំងឡាយបានចូលវស្សាហើយ មានពួកសត្វសាហាវមកបៀតបៀន ។ ចាប់យកភិក្ខុទាំងនោះទៅក៏ មកពោមព័ទ្ធបង្អើលភិក្ខុទាំងនោះក៏ ។ ភិក្ខុទាំងឡាយត្រូវធ្វើទុកក្នុងចិត្តថា អន្តរាយនេះឯងមានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ ។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ភិក្ខុទាំងឡាយបានចូលវស្សាហើយ ពួក

ភិក្ខូ សរីសបេហិ ឧព្ពាឡ្ហា ហោន្តិ ។ ឌំសន្តិបិ បរិបា-
តេន្តិបិ ។ ឯសេវ អន្តរាយោតិ បក្កមិតព្វំ ។ អនា-
បត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតា
ភិក្ខូ ចោរេហិ ឧព្ពាឡ្ហា ហោន្តិ ។ វិលុម្បន្តិបិ អាកោ-
ដេន្តិបិ ។ ឯសេវ អន្តរាយោតិ បក្កមិតព្វំ ។ អនាបត្តិ
វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតា ភិក្ខូ
បិសាចេហិ ឧព្ពាឡ្ហា ហោន្តិ ។ អាវិសន្តិបិ ហនន្តិបិ[១] ។
ឯសេវ អន្តរាយោតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេ-
ទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតានំ ភិក្ខូនំ គាមោ
អគ្គិនា ទឌ្ឍោ ហោតិ ។ ភិក្ខូ បិណ្ឌកេន កិលមន្តិ ។

១ ឱជំ ហរន្តីតិ កត្ថចិ បោត្ថកេ ទិស្សតិ ។





សត្វមានពិស[១] មកបៀតបៀន ។ សត្វទាំងនោះចឹកខ្លះ មក
រោមព័ទ្ធបន្ទើលភិក្ខុទាំងនោះខ្លះ ។ ភិក្ខុទាំងនោះត្រូវតាំងចិត្តថា ការណ៍
នេះឯងមានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ ។ ភិក្ខុទាំងនោះដាច់
វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បើ
ភិក្ខុទាំងឡាយចូលវស្សាហើយ មានពួកចោរមកបៀតបៀន ។ ចោរទាំង
នោះប្លន់ភិក្ខុទាំងឡាយខ្លះ វាយសំពងភិក្ខុទាំងឡាយខ្លះ ។ ភិក្ខុទាំងនោះ
ត្រូវតាំងចិត្តថា ការណ៍នេះឯងមានសេចក្តីអន្តរាយ ហើយចៀសចេញទៅ
ចុះ ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ
ភិក្ខុក្នុងសាសនានេះ ភិក្ខុទាំងឡាយចូលវស្សាហើយ មានពួកបិសាច
បៀតបៀន ។ បិសាចទាំងនោះចូលទៅ (ក្នុងសរីរៈរបស់ភិក្ខុទាំងឡាយ
នោះ) ខ្លះ ចាប់យក (ភិក្ខុទាំងឡាយនោះ) ទៅខ្លះ ។ ភិក្ខុទាំងនោះត្រូវតាំង
ចិត្តថា ការណ៍នេះឯងមានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ ។
ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ
ភិក្ខុក្នុងសាសនានេះ ភិក្ខុទាំងឡាយចូលវស្សាហើយ ស្រាប់តែភ្លើងឆេះ
ស្រុកជាទីគោចរ ។ ភិក្ខុទាំងឡាយក៏លំបាកដោយការបិណ្ឌបាត

១ សរីសបៈ សំដៅយកសត្វល្មូនដែលមានពិស មានពស់ខ្លែងជាដើម ។

ឋានេ អន្តរាយោតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតានំ ភិក្ខូនំ សេនាសនំ អគ្គិនា ទឌ្ឍំ ហោតិ ។ ភិក្ខូ សេនាសនេន កិលមន្តិ ។ ឋានេ អន្តរាយោតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតានំ ភិក្ខូនំ គាមោ ឧទកេន វុឡ្ហោ ហោតិ ។ ភិក្ខូ បិណ្ឌកេន កិលមន្តិ ។ ឋានេ អន្តរាយោតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតានំ ភិក្ខូនំ សេនាសនំ ឧទកេន វុឡ្ហំ ហោតិ ។ ភិក្ខូ សេនាសនេន កិលមន្តិ ។ ឋានេ អន្តរាយោតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្សាតិ ។

[១១] តេន ខោ បន សមយេន អញ្ញតរស្មឹ អាវាសេ វស្សូបគតានំ ភិក្ខូនំ គាមោ ចោរេហិ វុដ្ឋាសិ ។



ភិក្ខុទាំងនោះត្រូវតាំងចិត្តថា ការស់នៅនេះឯងមានសេចក្ដីអន្តរាយ ហើយចៀសចេញទៅចុះ ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុទាំងឡាយចូលវស្សាហើយ ស្រាប់តែភ្លើងឆេះទីសេនាសនៈ ។ ភិក្ខុទាំងឡាយក៏លំបាកដោយទីសេនាសនៈ ។ ភិក្ខុទាំងនោះត្រូវតាំងចិត្តថា ការស់នៅនេះឯងមានសេចក្ដីអន្តរាយ ហើយចៀសចេញទៅចុះ ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុទាំងឡាយចូលវស្សាហើយ ស្រាប់តែមានទឹកជន់មកលិចស្រុកជាទីគោចរ ។ ភិក្ខុទាំងឡាយក៏លំបាកដោយអាហារបិណ្ឌបាត ។ ភិក្ខុទាំងនោះត្រូវតាំងចិត្តថា ការស់នៅនេះឯងមានសេចក្ដីអន្តរាយ ហើយចៀសចេញទៅចុះ ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានទឹកជន់លិចទីសេនាសនៈរបស់ពួកភិក្ខុដែលចូលវស្សាហើយ ។ ភិក្ខុទាំងឡាយក៏លំបាកដោយទីសេនាសនៈ ។ ភិក្ខុទាំងនោះត្រូវតាំងចិត្តថា ការស់នៅនេះឯងមានសេចក្ដីអន្តរាយ ហើយចៀសចេញទៅចុះ ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។

[១១] សម័យនោះឯង កាលភិក្ខុទាំងឡាយចូលវស្សាហើយ ក្នុងអាវាស ១ ស្រាប់តែមានពួកចោរមកតោក្នុងស្រុកជាទីគោចរ ។

ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ យេន គាមោ តេន គន្តុន្តិ ។ គាមោ ទ្វេធា ភិជ្ជិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ យេន គាមា ពហុតរា តេន គន្តុន្តិ ។ ពហុតរា អស្សទ្ធា ហោន្តិ អប្បសន្នា ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ យេន សទ្ធា បសន្នា តេន គន្តុន្តិ ។

[១៦] តេន ខោ បន សមយេន កោសលេសុ ជនបទេសុ អញ្ញតរស្មិំ អាវាសេ វស្សូបគតា ភិក្ខូ ន លភិំសុ លូខស្ស បណីតស្ស ភោជនស្ស យាវទត្ថំ បារិបូរឹ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ឥធ បន ភិក្ខវេ វស្សូបគតា ភិក្ខូ ន លភន្តិ លូខស្ស បណីតស្ស ភោជនស្ស យាវទត្ថំ បារិបូរឹ ។ ឯសេវ



ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ ស្រុកជាទីគោចរមានក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយទៅនៅក្នុងទីនោះចុះ ។ ចំណែកអ្នកស្រុកបែកគ្នាទៅជាពីរផ្នែក ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ អ្នកស្រុកទាំងឡាយមានចំនួនច្រើនជាងនៅក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយទៅនៅក្នុងទីនោះបាន ។ (ចំណែក) អ្នកស្រុកដែលឥតមានសទ្ធា ឥតមានសេចក្តីជ្រះថ្លា ច្រើនជាង ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកស្រុកដែលមានសទ្ធាជ្រះថ្លា មាននៅក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយទៅនៅក្នុងទីនោះឯង ។

[១៦] សម័យនោះឯង ក្នុងកោសលជនបទ មានពួកភិក្ខុចូលវស្សាក្នុងអាវាស ១ កន្លែង មិនបានភោជនសៅហ្មង ឬឧត្តម ឲ្យបានឆ្អែតពេញលេញម្តងសោះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកភិក្ខុដែលចូលវស្សាហើយ មិនបានភោជនសៅហ្មង ឬឧត្តម ឲ្យបានឆ្អែតពេញលេញទេ ។ ភិក្ខុទាំងនោះគប្បីដឹងថា អាពាធនេះឯងជាន

អន្តរាយោតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតោ ភិក្ខុ លភតិ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ ន លភតិ សប្បាយានិ ភោជនានិ ។ បេ ។ អន្តរាយោតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតោ ភិក្ខុ លភតិ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ លភតិ សប្បាយានិ ភោជនានិ ន លភតិ សប្បាយានិ ភេសជ្ជានិ ។ បេ ។ អន្តរាយោតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតោ ភិក្ខុ លភតិ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ លភតិ សប្បាយានិ ភោជនានិ លភតិ សប្បាយានិ ភេសជ្ជានិ ន លភតិ បតិរូបំ ឧបដ្ឋាកំ ។ បេ ។ អន្តរាយោតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតំ ភិក្ខុំ ឥត្ថី និមន្តេតិ



សេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ ។ ភិក្ខុនោះឈ្មោះថាដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុដែលចូលវស្សាហើយបានភោជនសៅហ្មង ឬឧត្តមល្មមត្រូវការពេញលេញ ហើយ តែមិនបានភោជនទាំងឡាយជាទីសប្បាយសោះ ។ ភិក្ខុនោះត្រូវតាំងចិត្តថា ហេតុនេះឯងមានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ ។ ភិក្ខុនោះឈ្មោះថាដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានភោជនសៅហ្មងឬឧត្តមល្មមត្រូវការពេញលេញ បានភោជនទាំងឡាយក៏ជាទីសប្បាយ តែមិនបានភេសជ្ជៈទាំងឡាយជាទីសប្បាយសោះ ។ ភិក្ខុនោះត្រូវតាំងចិត្តថា ហេតុនេះឯងមានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ ។ ភិក្ខុនោះឈ្មោះថាដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុដែលចូលវស្សាហើយ បានភោជនសៅហ្មងឬឧត្តមល្មមត្រូវការពេញលេញ បានភោជនទាំងឡាយក៏ជាទីសប្បាយ បានភេសជ្ជៈទាំងឡាយក៏ជាទីសប្បាយ តែមិនបានអ្នកបម្រើគួរសមសោះ ។ ភិក្ខុនោះត្រូវតាំងចិត្តថា ហេតុនេះឯងមានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ ។ ភិក្ខុនោះឈ្មោះថាដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានស្ត្រីមកបបួលភិក្ខុ

ឯហិ ភន្តេ ហិរញ្ញំ វា តេ ទេមិ សុវណ្ណំ វា តេ ទេមិ ខេត្តំ វា តេ ទេមិ វត្ថុំ វា តេ ទេមិ គាវុំ វា តេ ទេមិ គាវឹ វា តេ ទេមិ ទាសំ វា តេ ទេមិ ទាសឹ វា តេ ទេមិ ធីតរំ វា តេ ទេមិ ភរិយត្ថាយ អហំ វា តេ ភរិយា ហោមិ អញ្ញំ វា តេ ភរិយំ អានេមីតិ ។ តត្រ ចេ ភិក្ខុនោ ឯវំ ហោតិ លហុបរិវត្តំ ខោ ចិត្តំ វុត្តំ ភគវតា សិយាបិ មេ ព្រហ្មចរិយស្ស អន្តរាយោតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតំ ភិក្ខុំ វេសី និមន្តេតិ ។ បេ ។ ថុល្លកុមារី និមន្តេតិ បណ្ឌកោ និមន្តេតិ ញាតកា និមន្តេន្តិ រាជានោ និមន្តេន្តិ ចោរា និមន្តេន្តិ ធុត្តា និមន្តេន្តិ ឯហិ ភន្តេ ហិរញ្ញំ វា តេ ទេម សុវណ្ណំ វា តេ ទេម ខេត្តំ វា តេ ទេម វត្ថុំ វា តេ ទេម គាវុំ វា តេ ទេម





ដែលចូលវស្សាហើយថា លោកម្ចាស់ចូរនិមន្តមក ខ្ញុំករុណាប្រគេនប្រាក់លោកម្ចាស់ ខ្ញុំករុណាប្រគេនមាសលោកម្ចាស់ ខ្ញុំករុណាប្រគេនស្រែលោកម្ចាស់ ខ្ញុំករុណាប្រគេនចំការលោកម្ចាស់ ខ្ញុំករុណាប្រគេនគោឈ្មោលលោកម្ចាស់ ខ្ញុំករុណាប្រគេនគោញីលោកម្ចាស់ ខ្ញុំករុណាប្រគេនខ្ញុំប្រុសលោកម្ចាស់ ខ្ញុំករុណាប្រគេនខ្ញុំស្រីលោកម្ចាស់ ខ្ញុំករុណាប្រគេនកូនស្រីដើម្បីធ្វើជាភរិយាលោកម្ចាស់ ខ្ញុំករុណាជាភរិយាលោកម្ចាស់ ខ្ញុំករុណានឹងនាំស្រីដទៃមកធ្វើជាភរិយាលោកម្ចាស់ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្ដីត្រិះរិះឃើញថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ចិត្តជាធម្មជាតដែលប្រែប្រួលឆាប់រហ័សរហួនពិត នឹងធ្វើព្រហ្មចរិយធម៌របស់អាត្មាអញនឹងមានសេចក្ដីអន្តរាយ ដូច្នេះហើយត្រូវចៀសចេញទៅចុះ ។ ភិក្ខុនោះដាច់វស្សាតែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានស្រីផ្កាមាសមកប្រលោមភិក្ខុដែលចូលវស្សាហើយ ។ បេ ។ ថុល្លកុមារី (ស្រីចាស់ក្រមុំ) មកប្រលោម ខ្ទើយមកប្រលោម ពួកញាតិមកប្រលោម ពួកស្ដេចមកប្រលោម ពួកចោរមកប្រលោម ពួកអ្នកលេងមកប្រលោមថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់និមន្តមក យើងខ្ញុំប្រគេនប្រាក់លោកម្ចាស់ យើងខ្ញុំប្រគេនមាសលោកម្ចាស់ យើងខ្ញុំប្រគេនស្រែលោកម្ចាស់ យើងខ្ញុំប្រគេនចំការលោកម្ចាស់ យើងខ្ញុំប្រគេនគោឈ្មោលលោកម្ចាស់ យើងខ្ញុំប្រគេន

គាវិំ វា តេ ទេមិ ទាសំ វា តេ ទេមិ ទាសិំ វា តេ ទេមិ ធីតរំ វា តេ ទេមិ ភរិយត្ថាយ អញ្ញំ វា តេ ភរិយំ អានេមីតិ ។ តត្រ ចេ ភិក្ខុនោ ឯវំ ហោតិ លហុបរិវត្តំ ខោ ចិត្តំ វុត្តំ ភគវតា សិយាបិ មេ ព្រហ្មចរិយស្ស អន្តរាយោតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតោ ភិក្ខុ អស្សាមិកំ និធឹ បស្សតិ ។ តត្រ ចេ ភិក្ខុនោ ឯវំ ហោតិ លហុបរិវត្តំ ខោ ចិត្តំ វុត្តំ ភគវតា សិយាបិ មេ ព្រហ្មចរិយស្ស អន្តរាយោតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតោ ភិក្ខុ បស្សតិ សម្ពហុលេ ភិក្ខូ សង្ឃភេទាយ បរក្កមន្តេ ។ តត្រ ចេ ភិក្ខុនោ ឯវំ ហោតិ គរុកោ ខោ សង្ឃភេទោ វុត្តោ ភគវតា មា មយិ សម្មុខីភូតេ សង្ឃោ ភិជ្ជីតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតោ ភិក្ខុ



គោញីលោកក្ដី យើងនឹងប្រគេនទាសប្រុសលោកក្ដី យើងនឹងប្រគេនទាសីស្រីលោកក្ដី យើងនឹងប្រគេនកូនស្រីដើម្បីធ្វើជាភរិយាលោកក្ដី យើងនឹងនាំយកស្រីដទៃមកធ្វើជាភរិយាលោកក្ដី ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ចិត្តជាធម្មជាតដែលវិលប្រែប្រួលរហ័សរហួនពេក ក្រែងមានសេចក្ដីអន្តរាយដល់ព្រហ្មចរិយធម៌របស់អាត្មាអញ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយឃើញកំណប់ទ្រព្យឥតមានម្ចាស់ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ចិត្តជាធម្មជាតដែលវិលប្រែប្រួលរហ័សរហួនពេក ក្រែងមានសេចក្ដីអន្តរាយដល់ព្រហ្មចរិយធម៌របស់អញ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយឃើញភិក្ខុច្រើនរូបកំពុងព្យាយាមដើម្បីបំបែកសង្ឃ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្ដីត្រិះរិះយ៉ាងនេះថា សង្ឃភេទព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាមានទោសធ្ងន់ សូមកុំឲ្យសង្ឃបែកគ្នាក្នុងទីចំពោះមុខអញឡើយ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ

សុណាតិ សម្ពហុលា កិរ ភិក្ខូ សង្ឃភេទាយ បរក្កមន្តីតិ ។ តត្រ ចេ ភិក្ខុនោ ឯវំ ហោតិ គរុកោ ខោ សង្ឃភេទោ វុត្តោ ភគវតា មា មយិ សម្មុខីភូតេ សង្ឃោ ភិជ្ជីតិ បក្កមិតព្ពំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ៩០ ឥធ ភិក្ខវេ វស្សូបគតោ ភិក្ខុ សុណាតិ អមុកស្មឹ កិរ អាវាសេ សម្ពហុលា ភិក្ខូ សង្ឃភេទាយ បរក្កមន្តីតិ ។ តត្រ ចេ ភិក្ខុនោ ឯវំ ហោតិ តេ ខោ មេ ភិក្ខូ មិត្តា តេសាហំ វក្ខាមិ គរុកោ ខោ អាវុសោ សង្ឃភេទោ វុត្តោ ភគវតា មា អាយស្មន្តានំ សង្ឃភេទោ រុច្ចិត្ថាតិ ករិស្សន្តិ មេ វចនំ សុស្សូសិស្សន្តិ សោតំ ឱទហិស្សន្តីតិ បក្កមិតព្ពំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ៩១ ឥធ ភិក្ខវេ វស្សូបគតោ ភិក្ខុ សុណាតិ អមុកស្មឹ កិរ អាវាសេ សម្ពហុលា ភិក្ខូ សង្ឃភេទាយ បរក្កមន្តីតិ ។ តត្រ ចេ ភិក្ខុនោ ឯវំ ហោតិ តេ





បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ពួកភិក្ខុច្រើនរូបព្យាយាមដើម្បីបំបែកសង្ឃ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្ដីត្រិះរិះយ៉ាងនេះថា ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាមានទោសធ្ងន់ សូមកុំឲ្យសង្ឃបែកគ្នាក្នុងទីចំពោះមុខអាត្មាអញឡើយ ដូច្នេះហើយត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយបានឮដំណឹងថា ក្នុងអាវាសឯណោះ មានភិក្ខុច្រើនរូបព្យាយាមដើម្បីបំបែកសង្ឃ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្ដីត្រិះរិះយ៉ាងនេះថា ភិក្ខុទាំងនោះជាមិត្តរបស់អាត្មាអញ អាត្មាអញនឹងនិយាយនឹងភិក្ខុទាំងនោះថា នែអាវុសោ ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាមានទោសធ្ងន់ អស់លោកដ៏មានអាយុកុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុទាំងនោះមុខជានឹងធ្វើតាម មុខជានឹងប្រាថ្នាដើម្បីស្ដាប់ពាក្យអាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្ដាប់ ដូច្នេះហើយត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថាក្នុងអាវាសឯណោះ មានភិក្ខុច្រើនរូបព្យាយាមដើម្បីបំបែកសង្ឃ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្ដីត្រិះរិះយ៉ាងនេះថា ភិក្ខុទាំងនោះ

ខោ មេ ភិក្ខូ ន មិត្តា អបិច យេ តេសំ មិត្តា តេ មេ មិត្តា ត្យាហំ វក្ខាមិ តេ វុត្តា តេ វក្ខន្តិ គរុកោ ខោ អាវុសោ សង្ឃភេទោ វុត្តោ ភគវតា មា អាយស្មន្តានំ សង្ឃភេទោ រុច្ចិត្ថាតិ ករិស្សន្តិ មេ វចនំ សុស្សូសិស្សន្តិ សោតំ ឱទហិស្សន្តីតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតោ ភិក្ខុ សុណាតិ អមុកស្មឹ កិរ អាវាសេ សម្ពហុលេហិ ភិក្ខូហិ សង្ឃោ ភិន្នោតិ ។ តត្រ ចេ ភិក្ខុនោ ឯវំ ហោតិ តេ ខោ មេ ភិក្ខូ មិត្តា ត្យាហំ វក្ខាមិ គរុកោ ខោ អាវុសោ សង្ឃភេទោ វុត្តោ ភគវតា មា អាយស្មន្តានំ សង្ឃភេទោ រុច្ចិត្ថាតិ ករិស្សន្តិ មេ វចនំ សុស្សូសិស្សន្តិ សោតំ ឱទហិស្សន្តីតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតោ ភិក្ខុ សុណាតិ អមុកស្មឹ កិរ អាវាសេ សម្ពហុលេហិ

៤៦
វិនយបិដក មហាវគ្គ

មិនមែនជាមិត្តរបស់អាត្មាអញទេ ប៉ុន្តែជាភិក្ខុទាំងឡាយណាដែលជាមិត្តរបស់ភិក្ខុទាំងឡាយនោះ ភិក្ខុទាំងនោះក៏ជាមិត្តរបស់អាត្មាអញដែរ អញនឹងនិយាយប្រាប់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះ លុះអាត្មាអញបាននិយាយទៅហើយ មុខជានឹងនិយាយប្រាប់ភិក្ខុទាំងនោះថា នែអាវុសោ ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាមានទោសធ្ងន់ អស់លោកដ៏មានអាយុកុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុទាំងនោះមុខជានឹងធ្វើតាមមុខជានឹងប្រុងប្រយ័ត្នស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះសង្ឃមុខជានឹងបែក ព្រោះភិក្ខុច្រើនរូប ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុទាំងនោះជាមិត្តរបស់អញ ។ នឹងនិយាយប្រាប់ភិក្ខុទាំងនោះថា នែអាវុសោ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាការបំបែកសង្ឃមានទោសធ្ងន់ លោកដ៏មានអាយុទាំងឡាយកុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុទាំងនោះនឹងធ្វើតាម នឹងប្រុងប្រយ័ត្នស្តាប់ពាក្យរបស់អញ នឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បាន

## វស្សូបនាយិកក្ខន្ធកេ វស្សូបគតានំ សង្ឃភេទេ ឧប្បន្នេ

ភិក្ខូហិ សង្ឃោ ភិន្នោតិ ។ តត្រ ចេ ភិក្ខុនោ ឯវំ ហោតិ តេ ខោ មេ ភិក្ខូ ន មិត្តា អបិ ច យេ តេសំ មិត្តា តេ មេ មិត្តា ត្យាហំ វក្ខាមិ តេ វុត្តា តេ វក្ខន្តិ គរុកោ ខោ អាវុសោ សង្ឃភេទោ វុត្តោ ភគវតា មា អាយស្មន្តានំ សង្ឃភេទោ រុច្ចិត្ថាតិ ករិស្សន្តិ មេ វចនំ សុស្សូសិស្សន្តិ សោតំ ឱទហិស្សន្តីតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតោ ភិក្ខុ សុណាតិ អមុកស្មឹ កិរ អាវាសេ សម្ពហុលា ភិក្ខុនិយោ សង្ឃភេទាយ បរក្កមន្តីតិ ។ តត្រ ចេ ភិក្ខុនោ ឯវំ ហោតិ តា ខោ មេ ភិក្ខុនិយោ មិត្តា តាហំ វក្ខាមិ គរុកោ ខោ ភគិនិយោ សង្ឃភេទោ វុត្តោ ភគវតា មា ភគិនីនំ



## វស្សូបនាយិកក្ខន្ធកៈ ការបំបែកសង្ឃកើតដល់ពួកភិក្ខុដែលចូលវស្សា-

ឮដំណឹងថា ក្នុងអាវាសឯណោះ សង្ឃមុខជានឹងបែកព្រោះភិក្ខុច្រើនរូប ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុទាំងឡាយនោះឯងមិនមែនជាមិត្តរបស់អាត្មាទេ ប៉ុន្តែថាភិក្ខុទាំងឡាយណាដែលជាមិត្តរបស់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះក៏ជាមិត្តរបស់អាត្មាអញដែរ អាត្មាអញនឹងនិយាយប្រាប់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះលុះអាត្មាអញនិយាយទៅហើយ មុខជានឹងនិយាយប្រាប់ភិក្ខុទាំងនោះថា នែអាវុសោ ការបំបែកសង្ឃព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាមានទោសធ្ងន់ អស់លោកដ៏មានអាយុ កុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុទាំងនោះមុខជានឹងធ្វើតាម មុខជានឹងប្រុងប្រយ័ត្នស្តាប់ពាក្យ អាត្មាអញមុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះដាច់វស្សា ក៏មិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះមានភិក្ខុនីច្រើនរូបព្យាយាមដើម្បីបំបែកសង្ឃ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុនីទាំងនោះ ជាមិត្តរបស់អាត្មាអញពិត អាត្មាអញនឹងនិយាយប្រាប់ភិក្ខុនីទាំងនោះថា នែនាងទាំងឡាយ ការបំបែកសង្ឃព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាមានទោសធ្ងន់ អស់នាង

សង្ឃភេទោ រុច្ចិត្ថាតិ ករិស្សន្តិ មេ វចនំ សុស្សូសិស្សន្តិ សោតំ ឱទហិស្សន្តីតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតោ ភិក្ខុ សុណាតិ អមុកស្មឹ កិរ អាវាសេ សម្ពហុលា ភិក្ខុនិយោ សង្ឃភេទាយ បរក្កមន្តីតិ ។ តត្រ មេ ភិក្ខុនិយោ មិត្តា ហោន្តិ តា ចេ មេ ភិក្ខុនិយោ ន មិត្តា អបិច យា តាសំ មិត្តា តា មេ មិត្តា តាហំ វក្ខាមិ តា វុត្តា តា វក្ខន្តិ គរុកោ ខោ ភគិនិយោ សង្ឃភេទោ វុត្តោ ភគវតា មា ភគិនីនំ សង្ឃភេទោ រុច្ចិត្ថាតិ ករិស្សន្តិ មេ វចនំ សុស្សូសិស្សន្តិ សោតំ ឱទហិស្សន្តីតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតោ ភិក្ខុ សុណាតិ អមុកស្មឹ កិរ អាវាសេ សម្ពហុលាហិ ភិក្ខុនីហិ សង្ឃោ ភិន្នោតិ ។ តត្រ មេ ភិក្ខុនិយោ មិត្តា ហោន្តិ តា ចេ មេ ភិក្ខុនិយោ មិត្តា



កំពុងលុះចិត្តនឹងការបំបែកសង្ឃហើយ ពួកភិក្ខុនីនោះមុខជានឹងធ្វើតាម មុខជានឹងប្រុងប្រៀបដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយត្រូវចៀសចេញទៅចុះ ។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះមានភិក្ខុនីច្រើនរូប ព្យាយាមដើម្បីបំបែកសង្ឃ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុនីទាំងនោះមិនមែនជាមិត្តរបស់អាត្មាអញមែន ប៉ុន្តែថា ភិក្ខុនីណាដែលជាមិត្តរបស់ភិក្ខុនីទាំងនោះ ភិក្ខុនីទាំងនោះក៏ជាមិត្តរបស់អាត្មាអញដែរ អាត្មាអញនឹងនិយាយប្រាប់ភិក្ខុនីទាំងនោះ ភិក្ខុនីទាំងនោះលុះអាត្មាអញនិយាយទៅហើយ មុខជានិយាយប្រាប់ភិក្ខុនីទាំងនោះថា នែនាងទាំងឡាយ ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាមានទោសធ្ងន់ ពួកនាង កុំលុះចិត្តនឹងការបំបែកសង្ឃឡើយ ពួកភិក្ខុនីនោះមុខជានឹងធ្វើតាម មុខជានឹងប្រុងប្រៀបដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយត្រូវចៀសចេញទៅចុះ ។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះសង្ឃមុខជាបែកព្រោះពួកភិក្ខុនីច្រើនរូប ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា

### វស្សូបនាយិកក្ខន្ធកំ វស្សច្ឆេទការណំ សង្ឃភេទោ ខន្ធកោ

តាហំ វក្ខាមិ គរុកោ ខោ ភគិនិយោ សង្ឃភេទោ វុត្តោ ភគវតា មា ភគិនីនំ សង្ឃភេទោ រុចិត្ថាតិ ករិស្សន្តិ មេ វចនំ សុស្សូសិស្សន្តិ សោតំ ឱទហិស្សន្តីតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។ ឥធ បន ភិក្ខវេ វស្សូបគតោ ភិក្ខុ សុណាតិ អមុកស្មឹ កិរ អាវាសេ សម្ពហុលាហិ ភិក្ខុនីហិ សង្ឃោ ភិន្នោតិ ។ តត្រ ចេ ភិក្ខុនោ ឯវំ ហោតិ តា ខោ មេ ភិក្ខុនិយោ ន មិត្តា អបិច យា តាសំ មិត្តា តា មេ មិត្តា តាហំ វក្ខាមិ តា វុត្តា តា វក្ខន្តិ គរុកោ ខោ ភគិនិយោ សង្ឃភេទោ វុត្តោ ភគវតា មា ភគិនីនំ សង្ឃភេទោ រុចិត្ថាតិ ករិស្សន្តិ មេ វចនំ សុស្សូសិស្សន្តិ សោតំ ឱទហិស្សន្តីតិ បក្កមិតព្វំ ។ អនាបត្តិ វស្សច្ឆេទស្ស ។



### វស្សូបនាយិកក្ខន្ធកៈ ការបំបែកសង្ឃកើតដល់ភិក្ខុដែលចូលវស្សា

ភិក្ខុនីទាំងនោះ ជាមិត្តរបស់អាត្មាអញដោយពិត អាត្មាអញនឹងនិយាយប្រាប់ភិក្ខុនីទាំងនោះថា នែនាងទាំងឡាយ ការបំបែកសង្ឃព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាមានទោសធ្ងន់ អស់ទាំងនាង កុំពេញចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុនីទាំងនោះមុខជានឹងធ្វើតាម មុខជាប្រាថ្នាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះសង្ឃមុខជានឹងបែកព្រោះភិក្ខុនីច្រើនរូប ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុនីទាំងនោះមិនមែនជាមិត្តរបស់អាត្មាអញពិតមែន ប៉ុន្តែថា ភិក្ខុនីទាំងឡាយណាដែលជាមិត្តរបស់ភិក្ខុនីទាំងនោះ ភិក្ខុនីទាំងឡាយនោះក៏ជាមិត្តរបស់អាត្មាអញដែរ អាត្មាអញនឹងនិយាយប្រាប់ភិក្ខុនីទាំងនោះ ភិក្ខុនីទាំងនោះលុះអាត្មាអញនិយាយទៅហើយ នឹងនិយាយប្រាប់ភិក្ខុនីទាំងនោះថា នែនាងទាំងឡាយ ការបំ-បែកសង្ឃព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាមានទោសធ្ងន់ ពួកនាងកុំពេញចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុនីទាំងនោះមុខជានឹងធ្វើតាម មុខជាប្រាថ្នាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ ។

[១៣] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ វជេ វស្សំ ឧបគន្តុកាមោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ វជេ វស្សំ ឧបគន្តុន្តិ ។ វជោ វុដ្ឋាសិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ យេន វជោ តេន គន្តុន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ឧបកដ្ឋាយ វស្សូបនាយិកាយ សត្ថេន គន្តុកាមោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សត្ថេ វស្សំ ឧបគន្តុន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ឧបកដ្ឋាយ វស្សូបនាយិកាយ នាវាយ គន្តុកាមោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ នាវាយ វស្សំ ឧបគន្តុន្តិ ។



[១៣] សម័យនោះឯង ភិក្ខុ១រូបមានសេចក្តីប្រាថ្នាដើម្បីចូលវស្សាក្នុងលំនៅរបស់គង្វាលគោ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សាក្នុងលំនៅរបស់គង្វាលគោបាន ។ ឯលំនៅរបស់គង្វាលគោក៏រើចេញទៅ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ លំនៅគង្វាលគោទៅក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទៅក្នុងទីនោះបាន ។ សម័យនោះឯង មានភិក្ខុ១រូប កាលថ្ងៃចូលវស្សាកាន់តែជិតហើយ ក៏ប្រាថ្នាដើម្បីទៅដោយពួកឈ្មួញរទេះ(១) ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សាក្នុងពួកឈ្មួញរទេះបាន ។ សម័យនោះឯង មានភិក្ខុ១រូប កាលថ្ងៃចូលវស្សាកាន់តែជិតហើយ ក៏ប្រាថ្នាដើម្បីទៅដោយទូក ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សាក្នុងទូកបាន ។

---

១ ក្នុងដីកាថា ប្រជុំជន ។

(១៦) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ រុក្ខសុសិរេ វស្សំ ឧបគច្ឆតិ(១) ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ សេយ្យថាបិ បិសាចិល្លិកាតិ(២) ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ រុក្ខសុសិរេ វស្សំ ឧបគន្តព្វំ យោ ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន ភិក្ខូ រុក្ខវិដភិយា វស្សំ ឧបគច្ឆន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ សេយ្យថាបិ មិគលុទ្ទកាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ រុក្ខវិដភិយា វស្សំ ឧបគន្តព្វំ យោ ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៧) តេន ខោ បន សមយេន ភិក្ខូ អជ្ឈោកាសេ វស្សំ ឧបគច្ឆន្តិ ។ ទេវេ វស្សន្តេ រុក្ខមូលំបិ និព្វកោសំបិ ឧបធាវន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ អជ្ឈោកាសេ វស្សំ ឧបគន្តព្វំ យោ ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ

១. ម. តេន ខោ បន សមយេន ភិក្ខូ រុក្ខសុសិរេ វស្សំ ឧបគច្ឆន្តិ ។ ២ ម. បិសាចិល្លិកា-តិ [illegible] [illegible] ។



(១៦) សម័យនោះឯង មានភិក្ខុ ១ រូបចូលវស្សាក្នុងប្រហោងឈើ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងនោះដូចជាពួកបិសាច ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ភិក្ខុមិនត្រូវចូលវស្សាក្នុងប្រហោងឈើទេ ភិក្ខុណាចូល ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ភិក្ខុទាំងឡាយចូលវស្សាលើប្រគាប់ឈើ ។ ពួកមនុស្សក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងនោះដូចជាពួកព្រានម្រឹគ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាលើប្រគាប់ឈើទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ ។

(១៧) សម័យនោះឯង ភិក្ខុទាំងឡាយចូលវស្សាក្នុងទីវាល ។ ដល់វេលាភ្លៀងធ្លាក់មក ភិក្ខុទាំងនោះក៏ស្ទុះរត់ទៅរកម្លប់ឈើខ្លះ យុំស្បៀខ្លះ (សំយាបបង្គួរស្បៀ) ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាក្នុងទីវាលទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង

បន សមយេន ភិក្ខូ អសេនាសនិកា វស្សំ ឧបគច្ឆន្តិ
សីតេនបិ ឧណ្ហេនបិ កិលមន្តិ ។ ភគវតោ ឯតមត្ថំ
អារោចេសុំ ។ ន ភិក្ខវេ អសេនាសនិកេន វស្សំ
ឧបគន្តព្វំ យោ ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្សាតិ ។
តេន ខោ បន សមយេន ភិក្ខូ ឆវកុដិកាយ វស្សំ
ឧបគច្ឆន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ
សេយ្យថាបិ ឆវឌាហកាតិ[១] ។ ភគវតោ ឯតមត្ថំ
អារោចេសុំ ។ ន ភិក្ខវេ ឆវកុដិកាយ វស្សំ ឧប-
គន្តព្វំ យោ ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន
ខោ បន សមយេន ភិក្ខូ ឆត្តេ វស្សំ ឧបគច្ឆន្តិ ។
មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ សេយ្យថាបិ
គោបាលកាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន
ភិក្ខវេ ឆត្តេ វស្សំ ឧបគន្តព្វំ យោ ឧបគច្ឆេយ្យ អាបត្តិ
ទុក្កដស្សាតិ ។ តេន ខោ បន សមយេន ភិក្ខូ
ចាដិយា វស្សំ ឧបគច្ឆន្តិ ។ មនុស្សា ឧជ្ឈាយន្តិ
ខីយន្តិ វិបាចេន្តិ សេយ្យថាបិ តិត្ថិយាតិ ។ ភគវតោ

១. ម. ឆវដាហកាតិ ។



ភិក្ខុទាំងឡាយចូលវស្សាឥតមានទីសេនាសនៈឡើយ ក៏លំបាកដោយ
ត្រជាក់ខ្លះដោយក្តៅខ្លះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុះចំពោះ
ព្រះដ៏មានព្រះភាគ ។ ព្រះអង្គបញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវ
ចូលវស្សាដោយឥតមានទីសេនាសនៈទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ ។
សម័យនោះឯង ភិក្ខុទាំងឡាយចូលវស្សាក្នុងខ្ទមខ្មោច ។ មនុស្សទាំង
ឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងនោះដូចជាពួកដុត
ខ្មោច ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះ
ភាគ ។ ព្រះអង្គបញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាក្នុង
ខ្ទមខ្មោចទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ភិក្ខុទាំង
ឡាយ ចូលវស្សាក្នុងឆត្រ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល
បន្តុះបង្អាប់ថា ភិក្ខុទាំងនោះដូចជាពួកអ្នកគង្វាលគោ ។ ភិក្ខុទាំងឡាយក្រាប
ទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គបញ្ញត្តថា ម្នាលភិក្ខុ
ទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាក្នុងឆត្រទេ ភិក្ខុណាចូល ត្រូវអាបត្តិ
ទុក្កដ ។ សម័យនោះឯង ភិក្ខុទាំងឡាយចូលវស្សាក្នុងពាងទឹក ។
មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងនោះ
ដូចជាពួកតិរ្ថិយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុះចំពោះព្រះដ៏មាន

ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ចាដិយា វស្សំ ឧបគន្តព្វំ យោ ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[១៦] តេន ខោ បន សមយេន សាវត្ថិយា សង្ឃេន កតិកា កតា ហោតិ អន្តោវស្សំ ន បព្វាជេតព្វន្តិ ។ វិសាខាយ មិគារមាតុយា នត្តា ភិក្ខូ ឧបសង្កមិត្វា បព្វជ្ជំ យាចិ ។ ភិក្ខូ ឯវមាហំសុ សង្ឃេន ខោ អាវុសោ កតិកា កតា អន្តោវស្សំ ន បព្វាជេតព្វន្តិ អាគមេហិ អាវុសោ យាវ ភិក្ខូ វស្សំ វសន្តិ វស្សំ វុត្ថា បព្វាជេស្សន្តីតិ ។ អថខោ តេ ភិក្ខូ វស្សំ វុត្ថា វិសាខាយ មិគារមាតុយា នត្តារំ ឯតទវោចុំ ឯហិ ទានិ អាវុសោ បព្វជាហីតិ ។ សោ ឯវមាហ សចាហំ ភន្តេ បព្វជិតោ អស្សំ អភិរមេយ្យាមហំ ន ទានាហំ ភន្តេ បព្វជិស្សាមីតិ ។ វិសាខា មិគារមាតា ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម អយ្យា ឯវរូបំ កតិកំ ករិស្សន្តិ អន្តោវស្សំ ន បព្វាជេតព្វន្តិ



ព្រះអង្គ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាក្នុងពាងទឹកទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ ។

[១៦] សម័យនោះឯង ក្នុងក្រុងសាវត្ថី សង្ឃបានធ្វើកតិកា (ច្បាប់) ថា ភិក្ខុមិនត្រូវបំបួសកុលបុត្តក្នុងកណ្តាលវស្សាឡើយ ។ ស្រាប់តែចៅរបស់នាងវិសាខាជាមាតាមិគារសេដ្ឋីបានចូលទៅរកពួកភិក្ខុហើយសូមបួស ។ ភិក្ខុទាំងឡាយក៏បាននិយាយទៅវិញយ៉ាងនេះថា នែអ្នកដ៏មានអាយុ សង្ឃបានធ្វើកតិកាថា មិនត្រូវឲ្យភិក្ខុណាបំបួសកុលបុត្តក្នុងកណ្តាលវស្សាឡើយ នែអ្នកដ៏មានអាយុ អ្នកឯងចូរបង្អង់សិនចាំតែភិក្ខុទាំងឡាយនៅចាំវស្សា លុះចាំវស្សារួចហើយនឹងបំបួស ។ គ្រានោះ ភិក្ខុទាំងនោះលុះចាំវស្សារួចហើយ ក៏បាននិយាយពាក្យនេះនឹងចៅរបស់នាងវិសាខាជាមាតាមិគារសេដ្ឋីថា នែអ្នកដ៏មានអាយុ អ្នកឯងចូរមកបួសក្នុងកាលឥឡូវនេះចុះ ។ បុរសនោះពោលតបយ៉ាងនេះវិញថា បពិត្រលោកដ៏ចំរើន ប្រសិនបើខ្ញុំករុណាបានបួសរួចស្រេចហើយ ខ្ញុំករុណានឹងត្រេកអរពេកណាស់ បពិត្រលោកដ៏ចំរើន ឥឡូវនេះខ្ញុំករុណាខានបួសហើយ ។ នាងវិសាខាជាមាតាមិគារសេដ្ឋីក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយមិនសមបើនឹងធ្វើកតិកាបែបយ៉ាងនេះថា ភិក្ខុមិនត្រូវបំបួស

កំ កាលំ ធម្មោ ន ចរិតព្វោតិ ។ អស្សោសុំ ខោ ភិក្ខូ វិសាខាយ មិគារមាតុយា ឧជ្ឈាយន្តិយា ខិយ្យន្តិយា វិបាចេន្តិយា ។ អថ ខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ឯវរូបា កតិកា កាតព្វា អន្តរាវស្សំ ន បព្វាជេតព្វន្តិ យោ ករេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៧) តេន ខោ បន សមយេន អាយស្មតា ឧបនន្ទេន សក្យបុត្តេន រញ្ញោ បសេនទិស្ស កោសលស្ស វស្សាវាសោ បដិស្សុតោ ហោតិ បុរិមិកាយ ។ សោ តំ អាវាសំ គច្ឆន្តោ អទ្ទស អន្តរាមគ្គេ ទ្វេ អាវាសេ ពហុចីវរកេ ។ តស្ស ឯតទហោសិ យន្នូនាហំ ឥមេសុ ទ្វីសុ អាវាសេសុ វស្សំ វសេយ្យំ ឯវំ មេ ពហុំ ចីវរំ ឧប្បជ្ជិស្សតីតិ ។ សោ តេសុ ទ្វីសុ អាវាសេសុ វស្សំ វសិ ។ រាជា បសេនទិ កោសលោ ឧជ្ឈាយតិ ខិយ្យតិ វិបាចេតិ កថំ ហិ នាម អយ្យោ ឧបនន្ទោ សក្យបុត្តោ អម្ហាកំ វស្សាវាសំ បដិស្សុណិត្វា វិសំវាទេស្សតិ ននុ ភគវតា អនេកបរិយាយេន មុសាវាទោ



កុលបុត្ត ក្នុងកណ្តាលវស្សានោះ ឯភិក្ខុមិនត្រូវប្រព្រឹត្តធម៌តាមកំណត់កាលដូច្នោះទេ ។ កាលនាងវិសាខាជាមាតាមិគារសេដ្ឋីកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ ។ គ្រានោះឯង ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើកតិកាបែបនេះថា ភិក្ខុមិនត្រូវបំបួសកុលបុត្តក្នុងកណ្តាលវស្សាទេ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ ។

(១៧) សម័យនោះឯង ឧបនន្ទសក្យបុត្តមានអាយុបានទទួលប្រគេនស្តេចបសេនទិកោសលថា ទីនៅចាំវស្សាដោយបុរិមិកាវស្សា ។ ឧបនន្ទនោះកាលដើរទៅកាន់អាវាសនោះ ក៏បានឃើញអាវាសពីរក្នុងកណ្តាលផ្លូវ ជាអាវាសមានចីវរច្រើន ។ ឧបនន្ទនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរអាត្មាអញនៅចាំវស្សាក្នុងអាវាសទាំងពីរនេះចុះ ចីវរមុខជានឹងកើតដល់អាត្មាអញជាច្រើនដោយអាការយ៉ាងនេះ ។ ឧបនន្ទនោះក៏បាននៅចាំវស្សាក្នុងអាវាសទាំងពីរនោះ ។ ស្តេចបសេនទិកោសលក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ឧបនន្ទសក្យបុត្តបានទទួលប្រគេនថា អញនៅចាំវស្សាហើយ មិនសមបើនឹងធ្វើឲ្យខុសពាក្យប្រគេនទៅវិញសោះ ព្រះមានព្រះភាគទ្រង់តិះដៀលពាក្យមុសាវាទ

គរហិតោ មុសាវាទា វេរមណី បសត្ថាតិ ។ អស្សោសុំ ខោ ភិក្ខូ រញ្ញោ បសេនទិស្ស កោសលស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ រញ្ញោ បសេនទិស្ស កោសលស្ស វស្សាវាសំ បដិស្សុណិត្វា វិសំវាទេស្សតិ ននុ ភគវតា អនេកបរិយាយេន មុសាវាទោ គរហិតោ មុសាវាទា វេរមណី បសត្ថាតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ បដិបុច្ឆិ សច្ចំ កិរ ត្វំ ឧបនន្ទ រញ្ញោ បសេនទិស្ស កោសលស្ស វស្សាវាសំ បដិស្សុណិត្វា វិសំវាទេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស រញ្ញោ បសេនទិស្ស កោសលស្ស វស្សាវាសំ បដិស្សុណិត្វា វិសំវាទេស្សសិ ននុ មយា មោឃបុរិស អនេកបរិយាយេន មុសាវាទោ គរហិតោ





ទ្រង់សរសើរតែការវៀរចាកពាក្យមុសាក៏ទេដោយអនេកបរិយាយ ។ កាលស្ដេចបសេនទិកោសលកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧបនន្ទជាសក្យបុត្តដ៏មានអាយុ ចុះទទួលពាក្យស្ដេចបសេនទិកោសលថានឹងនៅចាំវស្សាហើយមិនសមបើនឹងធ្វើឲ្យខុសពាក្យប្ដេជ្ញាទៅវិញសោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលពាក្យមុសាក៏ទ ទ្រង់សរសើរតែការវៀរចាកពាក្យមុសាក៏ទេដោយអនេកបរិយាយ ។ គ្រានោះ ភិក្ខុទាំងនោះក៏ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃក្នុងវេលានោះ ហើយទ្រង់សួរចំពោះឧបនន្ទជាសក្យបុត្តដ៏មានអាយុថា ម្នាលឧបនន្ទ ឮថាអ្នកឯងទទួលពាក្យស្ដេចបសេនទិកោសលថានឹងនៅចាំវស្សា ហើយធ្វើឲ្យខុសពាក្យប្ដេជ្ញាទៅវិញ ពិតមែនឬ ។ ឧបនន្ទក្រាបទូលថា ពិតមែនព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងទទួលពាក្យស្ដេចបសេនទិកោសលថានឹងនៅចាំវស្សាហើយ មិនសមបើនឹងធ្វើឲ្យខុសពាក្យប្ដេជ្ញាទៅវិញសោះ ម្នាលមោឃបុរស តថាគតបានតិះដៀលពាក្យមុសាក៏ទ បានសរសើរតែការវៀរ

មុសាភណ្ឌា វេហាសណំ ឋបេន្តា ទេតិ មោឃយម៉ុស អប្បសន្នោ·
ចិក ចសាធាយ ។ បេ ។ វិតរោហិត្វា ឧទ្ទំ គាឋំ ឝាត្វា
ភិក្ខុ អាមន្តេសិ វត្ត បច ភិក្ខវេ ភិក្ខុនា វស្សាភណ្ឌោ
ឋបេត្វា យោជិ ចុម្មិកាយ ។ សោ តំ អាកស៉ំ
ឥជ្ជេត្វា ឋស្សតិ អត្តភាវស្ស វេ អាកាសេ គហេត្វា ។
យស្ស ឃរំ យោជិ យន្ទ្រាហំ វេមេសុ ទុស្សុ អាកាសេសុ
វស្សំ អសយ្យំ ឃរំ មេ គហិតុំ ទីរាំ ទុវិញ្ញូ ស្សតិតិ ។
សោ កេសុ ទុស្សុ អាកាសេសុ វស្សំ វសតិ ។ តស្ស
ភិក្ខវេ ភិក្ខុនោ ចុម្មិកា ច ន បញ្ញាយតិ បដិស្សវេ
ច អាបត្តិ ទុក្កដស្ស ។ វត្ត បច ភិក្ខវេ ភិក្ខុនា
វស្សាភណ្ឌោ ឋបេត្វា យោជិ ចុម្មិកាយ ។ សោ
តំ អាកស៉ំ ឥជ្ជេត្វា តហិត្វា ទុរោសដ្ឋំ អាកោតិ
ធាជ្ជេបទេ(១) វិហារំ ឧបេតិ សេនាសនំ បញ្ញាបេតិ ធា.
និយំ បរិភោជនីយំ ឧបដ្ឋាបេតិ បរិវេណំ សម្មជ្ជតិ ។
សោ តទហេវ អករណីយោ បក្កមតិ ។ តស្ស ភិក្ខវេ

១ ម. ធាតិបេទ ។



ជាកញ្ចក្សមុសាភ័ណ្ឌ ដោយការលោតយោយ ម្ចាស់ពាយបុរស រាំតើ
នេះមិនបានមើលទាំងផលដែលមិនពាន់ព្រះព្រហ្ម ព្រះបាទឡើងសិក្ខា ។ បេ ។
ចែនបាទ្រសហើយត្រូវនឹងទឹកជា ទ្រង់ទ្រាស់ហៅភិក្ខុទាំងឡាយមក
ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលវេចជា
នៅចាំវស្សាដោយបុម្មិកាវស្សាហើយ ។ ភិក្ខុនោះកំពុងនៃដើរទៅកាន់
អាកាសនានាក់បានរញ្ជាកាសតីការកណ្តាលវត្ត ជាអាកាសទាំង
ពីរបែទ ។ ភិក្ខុនោះនាសបចត្តិត្រិះយោមនេះជា បើថ្លោះ ខ្មាតា
អញ្ចនីនៅចាំវស្សា ក្នុងអាកាសទាំងពីរនេះចុះ ពីរមុខជាទីកើតផល
ការគ្នាញជាប្រែទ ដោយអាការយ៉ាងនេះ ។ ភិក្ខុនោះកំនៅចាំវស្សា
ក្នុងអាកាសទាំងពីរនោះ ។ ម្នាលភិក្ខុទាំងឡាយ បុម្មិកាវស្សារបស់
ភិក្ខុនោះមិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យ
ប្រញ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបាន
ទទួលវេចជានៅចាំវស្សាដោយបុម្មិកាវស្សាហើយ ។ ភិក្ខុនោះកាល
ទីដើរទៅកាន់អាកាសនោះ កំពុងរំលោសបងាវិទ្រៅ លុះដល់ថ្ងៃ
ចូលវស្សា ដើម្បីចូលទៅវិហារ ក្រាលសេនាសនៈដាក់ទឹកឆាន់ទឹកប្រើ
ប្រាស់ បោសព្រៃសទីធ្លាវេណា ។ ក្នុងថ្ងៃនោះឯង ភិក្ខុនោះមានកិច្ច
ក៏ទៅនៃដើរឡើយ ហើយក៏ដើរចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុនោ បុរិមិកា ច ន បញ្ញាយតិ បដិស្សុតេ ច អាបត្តិ ទុក្កដស្ស ។ ឥធ បន ភិក្ខវេ ភិក្ខុនា វស្សាវាសោ បដិស្សុតោ ហោតិ បុរិមិកាយ ។ សោ តំ អាវាសំ គច្ឆន្តោ ពហិទ្ធា ឧបោសថំ ករោតិ បាដិបទេ វិហារំ ឧបេតិ សេនាសនំ បញ្ញាបេតិ បានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ បរិវេណំ សម្មជ្ជតិ ។ សោ តទហេវ សករណីយោ បក្កមតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមិកា ច ន បញ្ញាយតិ បដិស្សុតេ ច អាបត្តិ ទុក្កដស្ស ។ ឥធ បន ភិក្ខវេ ភិក្ខុនា វស្សាវាសោ បដិស្សុតោ ហោតិ បុរិមិកាយ ។ សោ តំ អាវាសំ គច្ឆន្តោ ពហិទ្ធា ឧបោសថំ ករោតិ បាដិបទេ វិហារំ ឧបេតិ សេនាសនំ បញ្ញាបេតិ បានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ បរិវេណំ សម្មជ្ជតិ ។ សោ ទ្វីហតីហំ វសិត្វា សករណីយោ បក្កមតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមិកា ច ន បញ្ញាយតិ បដិស្សុតេ ច អាបត្តិ ទុក្កដស្ស ។ ឥធ បន ភិក្ខវេ ភិក្ខុនា វស្សាវាសោ បដិស្សុតោ ហោតិ បុរិមិកាយ ។ សោ តំ អាវាសំ គច្ឆន្តោ





ឯបុរិមិកាវស្សា របស់ភិក្ខុនោះមិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្ដេជ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ គឺសាសនានេះ បើភិក្ខុបានទទួលប្ដេជ្ញាចាំទីនៅចាំវស្សាដោយបុរិមិកាវស្សាហើយ ។ ភិក្ខុនោះកាលដើរទៅកាន់អាវាសនោះក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ ១ កើតទើបចូលទៅកាន់វិហារ ក្រាលសេនាសនៈ ដំកល់ទឹកឆាន់ទឹកប្រើប្រាស់ បោសប្រាសទីបរិវេណ ។ គឺថ្ងៃនោះ ភិក្ខុនោះប្រកបដោយកិច្ចត្រូវធ្វើ ហើយក៏ដើរចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សារបស់ភិក្ខុនោះ ក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្ដេជ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ គឺសាសនានេះ បើភិក្ខុបានទទួលប្ដេជ្ញាចាំ នៅចាំវស្សាដោយបុរិមិកាវស្សាហើយ ។ ភិក្ខុនោះកាលដើរទៅកាន់អាវាសនោះក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ ១ កើតទើបចូលទៅកាន់វិហារ ក្រាលសេនាសនៈ រៀបដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសប្រាសទីបរិវេណ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃ ស្រាប់តែមានកិច្ចត្រូវធ្វើកើតឡើង ហើយក៏ដើរចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សារបស់ភិក្ខុនោះក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្ដេជ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ គឺសាសនានេះ បើភិក្ខុបានទទួលប្ដេជ្ញាចាំនៅចាំវស្សាដោយបុរិមិកាវស្សាហើយ ។ ភិក្ខុនោះកាលដើរទៅកាន់អាវាសនោះ

ពហិទ្ធា ឧបោសថំ ករោតិ បាដិបទេ វិហារំ ឧបេតិ សេនាសនំ បញ្ញាបេតិ បានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ បរិវេណំ សម្មជ្ជតិ ។ សោ ទ្វីហតីហំ វសិត្វា សករណីយោ បក្កមតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមិកា ច ន បញ្ញាយតិ បដិស្សវេ ច អាបត្តិ ទុក្កដស្ស ។ ឥធ បន ភិក្ខវេ ភិក្ខុនា វស្សាវាសោ បដិស្សុតោ ហោតិ បុរិមិកាយ ។ សោ តំ អាវាសំ គច្ឆន្តោ ពហិទ្ធា ឧបោសថំ ករោតិ បាដិបទេ វិហារំ ឧបេតិ សេនាសនំ បញ្ញាបេតិ បានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ បរិវេណំ សម្មជ្ជតិ ។ សោ ទ្វីហតីហំ វសិត្វា សត្តាហករណីយេន បក្កមតិ ។ សោ តំ សត្តាហំ ពហិទ្ធា វីតិនាមេតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមិកា ច ន បញ្ញាយតិ បដិស្សវេ ច អាបត្តិ ទុក្កដស្ស ។ ឥធ បន ភិក្ខវេ ភិក្ខុនា វស្សាវាសោ បដិស្សុតោ ហោតិ បុរិមិកាយ ។ បេ ។ សោ ទ្វីហតីហំ វសិត្វា សត្តាហករណីយេន បក្កមតិ ។ សោ តំ សត្តាហំ អន្តោ សន្និវត្តំ ករោតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមិកា ច



ក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ ១ កើត ក៏ចូលទៅកាន់វិហារ ក្រាលសេនាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសប្រាសទីបរិវេណ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃហើយ ក្រោកចាកដោយកិច្ចគួរធ្វើ ក៏ដើរចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សារបស់ភិក្ខុនោះក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្តេជ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្តេជ្ញាចាំនៅចាំវស្សា ដោយបុរិមិកាវស្សាហើយ ។ ភិក្ខុនោះកាលនឹងដើរទៅកាន់អាវាសនោះ ក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ ១ កើត ក៏ចូលទៅកាន់វិហារ រៀបក្រាលសេនាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសប្រាសទីបរិវេណ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃ ក៏ដើរចេញទៅដោយសត្តាហករណីយ ។ ភិក្ខុនោះនៅខាងក្រៅ (អាវាស) ហួស ៧ ថ្ងៃនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សា របស់ភិក្ខុនោះមិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្តេជ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្តេជ្ញាចាំនៅចាំវស្សាដោយបុរិមិកាវស្សាហើយ ។ បេ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃក៏ដើរចេញទៅដោយសត្តាហករណីយ ។ ភិក្ខុនោះវិលត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សារបស់

បញ្ញាយតិ បដិស្សវេ ច អាបត្តិ ។ ឥធ បន ភិក្ខវេ ភិក្ខុនា វស្សាវាសោ បដិស្សុតោ ហោតិ បុរិមិកាយ ។ សោ តំ អាវាសំ គច្ឆន្តោ ពហិទ្ធា ឧបោសថំ ករោតិ បាដិបទេ វិហារំ ឧបេតិ សេនាសនំ បញ្ញាបេតិ បានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ បរិវេណំ សម្មជ្ជតិ ។ សោ សត្តាហំ អនាគតាយ បវារណាយ សករណីយោ បក្ក-មតិ ។ អាគច្ឆេយ្យ វា សោ ភិក្ខវេ ភិក្ខុ តំ អាវាសំ ន វា អាគច្ឆេយ្យ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមិកា ច បញ្ញាយតិ បដិស្សវេ ច អនាបត្តិ ។ ឥធ បន ភិក្ខវេ ភិក្ខុនា វស្សាវាសោ បដិស្សុតោ ហោតិ បុរិមិកាយ ។ សោ តំ អាវាសំ គន្ត្វា ឧបោសថំ ករោតិ បាដិបទេ វិហារំ ឧបេតិ សេនាសនំ បញ្ញាបេតិ បានីយំ បរិភោជ-នីយំ ឧបដ្ឋាបេតិ បរិវេណំ សម្មជ្ជតិ ។ សោ តទហេវ អករណីយោ បក្កមតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិ-មិកា ច ន បញ្ញាយតិ បដិស្សវេ ច អាបត្តិ ទុក្ក-ដស្ស ។ ឥធ បន ភិក្ខវេ ភិក្ខុនា វស្សាវាសោ



ភិក្ខុនោះក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិ ព្រោះទទួលពាក្យគេផង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលពាក្យគេថានឹងនៅចាំវស្សា ដោយបុរិមិកាវស្សាហើយ ។ ភិក្ខុនោះកាលនឹងដើរទៅកាន់អាវាសនោះក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ ១ កើតចូលទៅកាន់វិហារ ក្រាលសេនាសនៈ រៀបដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសក្រឡាបរិវេណ ។ ភិក្ខុនោះកាលបើនៅខ្វះ ៧ ថ្ងៃទៀតនឹងដល់ថ្ងៃបវារណា ក៏ប្រកបកិច្ចដែលត្រូវធ្វើហើយដើរចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះបានមកកាន់អាវាសនោះក្តី មិនបានមកកាន់អាវាសនោះក្តី ។ ម្នាលភិក្ខុទាំងឡាយ ឯបុរិមិកាវស្សារបស់ភិក្ខុនោះក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិព្រោះទទួលពាក្យគេផង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលពាក្យគេថានឹងនៅចាំវស្សាដោយបុរិមិកាវស្សាហើយ ។ ភិក្ខុនោះទៅកាន់អាវាសនោះក៏ធ្វើឧបោសថ លុះដល់ថ្ងៃ ១ កើតទើបចូលទៅកាន់វិហាររៀបក្រាលសេនាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសក្រឡាបរិវេណ ។ ក្នុងថ្ងៃនោះឯង ភិក្ខុនោះឥតមានកិច្ចរវល់នឹងធ្វើឡើយ ហើយក៏ដើរចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ ឯបុរិមិកាវស្សារបស់ភិក្ខុនោះក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យគេផង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ

បដិស្សុតោ ហោតិ បុរិមិកាយ ។ សោ តំ អាវាសំ គន្ត្វា ឧបោសថំ ករោតិ បាដិបទេ វិហារំ ឧបេតិ សេនាសនំ បញ្ញបេតិ បានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ បរិវេណំ សម្មជ្ជតិ ។ សោ តទហេវ សករណីយោ បក្កមតិ ។ បេ ។ សោ ទ្វីហតីហំ វសិត្វា អករណីយោ បក្កមតិ ។ បេ ។ សោ ទ្វីហតីហំ វសិត្វា សករណីយោ បក្កមតិ ។ បេ ។ សោ ទ្វីហតីហំ វសិត្វា សត្តាហករណីយេន បក្កមតិ ។ សោ តំ សត្តាហំ ពហិទ្ធា វីតិនាមេតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមិកា ច ន បញ្ញាយតិ បដិស្សវេ ច អាបត្តិ ទុក្កដស្ស ។ បេ ។ សោ ទ្វីហតីហំ វសិត្វា សត្តាហករណីយេន បក្កមតិ ។ សោ តំ សត្តាហំ អន្តោ សន្និវត្តំ ករោតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមិកា ច បញ្ញាយតិ បដិស្សវេ ច អនាបត្តិ ។ ៤៦ ឥធ បន ភិក្ខវេ ភិក្ខុនា វស្សាវាសោ បដិស្សុតោ ហោតិ បុរិមិកាយ ។ សោ តំ អាវាសំ គន្ត្វា ឧបោសថំ ករោតិ បាដិបទេ



បើភិក្ខុបានទទួលពាក្យគេថានឹងនៅចាំវស្សា ដោយបុរិមិកាវស្សាហើយ ។ ភិក្ខុនោះទៅកាន់អាវាសនោះធ្វើឧបោសថ លុះដល់ថ្ងៃ ១ រោច ទើបចូលទៅកាន់វិហារ រៀបក្រាលសេនាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសច្រាសទីបរិវេណ ។ ក្នុងថ្ងៃនោះឯង ភិក្ខុនោះក៏ប្រកបដោយកិច្ចដែលត្រូវធ្វើ ថយចេញទៅ ។ បេ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃ ឥតមានកិច្ចអ្វីក៏ថយចេញទៅ ។ បេ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃ ប្រកបដោយកិច្ចការក៏ថយចេញទៅ ។ បេ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃ ក៏ថយចេញទៅដោយសត្តាហករណីយ ។ ភិក្ខុនោះទៅខាងក្រៅ (អាវាស) ឲ្យហួសកំណត់ ៧ ថ្ងៃនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សា របស់ភិក្ខុនោះក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យគេផងដែរ ។ បេ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃ ក៏ថយចេញទៅដោយសត្តាហករណីយ ។ ភិក្ខុនោះត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សារបស់ភិក្ខុនោះក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិព្រោះទទួលពាក្យគេផងដែរ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលពាក្យគេថានឹងនៅចាំវស្សា ដោយបុរិមិកាវស្សាហើយ ។ ភិក្ខុនោះទៅកាន់អាវាសនោះធ្វើឧបោសថ លុះដល់ថ្ងៃ ១ រោច ទើបចូលទៅកាន់វិហារ រៀបក្រាលសេនាសនៈ

វិហារំ ឧបេតិ សេនាសនំ បញ្ញាបេតិ ពានីយំ បរិភោជ-
នីយំ ឧបដ្ឋាបេតិ បរិវេណំ សម្មជ្ជតិ ។ សោ សត្តាហំ
អនាគតាយ បវារណាយ សករណីយោ បក្កមតិ ។
អាគច្ឆេយ្យ វា សោ ភិក្ខវេ ភិក្ខុ តំ អាវាសំ ន វា
អាគច្ឆេយ្យ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមិកា ច
បញ្ញាយតិ បដិស្សវេ ច អនាបត្តិ ។

(១៨) ឥធ បន ភិក្ខវេ ភិក្ខុនា វស្សាវាសោ បដិស្សុ-
តោ ហោតិ បច្ឆិមិកាយ ។ សោ តំ អាវាសំ គច្ឆន្តោ
ពហិទ្ធា ឧបោសថំ ករោតិ បាដិបទេ វិហារំ ឧបេតិ សេនា-
សនំ បញ្ញាបេតិ ពានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ បរិ-
វេណំ សម្មជ្ជតិ ។ សោ តទហេវ អករណីយោ បក្កម-
តិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បច្ឆិមិកា ច ន បញ្ញាយ-
តិ បដិស្សវេ ច អាបត្តិ ទុក្កដស្ស ។ ឥធ បន ភិក្ខវេ ភិក្ខុ-
នា វស្សាវាសោ បដិស្សុតោ ហោតិ បច្ឆិមិកាយ ។ សោ
តំ អាវាសំ គច្ឆន្តោ ពហិទ្ធា ឧបោសថំ ករោតិ បាដិបទេ
វិហារំ ឧបេតិ សេនាសនំ បញ្ញាបេតិ ពានីយំ បរិភោជ-
នីយំ ឧបដ្ឋាបេតិ បរិវេណំ សម្មជ្ជតិ ។ សោ តទហេវ



ដំកល់ទឹកឆាន់ទឹកប្រើប្រាស់ បោសច្រាសបរិវេណ ។ ភិក្ខុនោះ
កាលបើនៅ ៧ ថ្ងៃទៀតទើបដល់ថ្ងៃបវារណា ក៏ប្រកបដោយកិច្ច ហើយ
ចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមកកាន់អាវាសនោះក្តី
មិនបានមកក្តី ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សា របស់ភិក្ខុនោះ
ក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិ ព្រោះទទួលពាក្យបដិញ្ញាផង ។

(១៨) ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបាន
ទទួលបដិញ្ញាគេថានៅចាំវស្សាដោយបច្ឆិមិកាវស្សាហើយ ។ ភិក្ខុនោះកាល
ដើរទៅកាន់អាវាសនោះក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ ១ កើត
ទើបចូលទៅកាន់វិហារ រៀបក្រាលសេនាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើ
ប្រាស់ បោសច្រាសបរិវេណ ។ ភិក្ខុនោះឥតមានកិច្ច ក៏ចៀស
ចេញទៅក្នុងថ្ងៃនោះឯង ។ ម្នាលភិក្ខុទាំងឡាយ បច្ឆិមិកាវស្សា របស់
ភិក្ខុនោះក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យ
បដិញ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបាន
ទទួលបដិញ្ញាគេថានៅចាំវស្សា ដោយបច្ឆិមិកាវស្សាហើយ ។ ភិក្ខុនោះ
កាលដើរទៅកាន់អាវាសនោះ ក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ
១ កើត ទើបចូលទៅកាន់វិហារ រៀបក្រាលសេនាសនៈ ដំកល់ទឹក
ឆាន់ ទឹកប្រើប្រាស់ បោសច្រាសបរិវេណ ។ ភិក្ខុនោះមាន

សករណីយោ បក្កមតិ ។ បេ ។ សោ ទ្វីហតីហំ វសិត្វា អករណីយោ បក្កមតិ ។ បេ ។ សោ ទ្វីហតីហំ វសិត្វា សករណីយោ បក្កមតិ ។ បេ ។ សោ ទ្វីហតីហំ វសិត្វា សត្តាហករណីយេន បក្កមតិ ។ សោ តំ សត្តាហំ ពហិទ្ធា វីតិនាមេតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បច្ឆិមិកា ច ន បញ្ញាយតិ បដិស្សវេ ច អាបត្តិ ទុក្កដស្ស ។ ឥធ បន ភិក្ខវេ ភិក្ខុនា វស្សាវាសិកោ បដិស្សុតោ ហោតិ បច្ឆិមិកាយ ។ សោ តំ អាវាសំ គច្ឆន្តោ ពហិទ្ធា ឧបោ-សថំ ករោតិ បាដិបទេ វិហារំ ឧបេតិ សេនាសនំ បញ្ញាបេតិ បានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ បរិវេណំ សម្មជ្ជតិ ។ សោ ទ្វីហតីហំ វសិត្វា សត្តាហករណីយេន បក្កមតិ ។ សោ តំ សត្តាហំ អន្តោ សន្និវត្តំ ករោតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បច្ឆិមិកា ច បញ្ញាយតិ បដិស្សវេ ច អនាបត្តិ ។ ឥធ បន ភិក្ខវេ ភិក្ខុនា វស្សាវាសិកោ បដិ-ស្សុតោ ហោតិ បច្ឆិមិកាយ ។ បេ ។ សោ សត្តាហំ



កិច្ចដែលត្រូវធ្វើក៏ចៀសចេញទៅក្នុងថ្ងៃនោះឯង ។ បេ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃ ឥតមានកិច្ចធ្វើក៏ចៀសចេញទៅ ។ បេ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃ មានកិច្ចដែលត្រូវធ្វើក៏ចៀសចេញទៅ ។ បេ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃ ក៏ចៀសចេញទៅដោយសត្តាហករណីយ ។ ភិក្ខុនោះនៅខាងក្រៅរហូតកំណត់៧ថ្ងៃនោះទៅ ។ បច្ឆិមិកាវស្សារបស់ភិក្ខុនោះក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដព្រោះទទួលពាក្យប្តេជ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្តេជ្ញាគេថានៅចាំវស្សាដោយបច្ឆិមិកាវស្សាហើយ ។ ភិក្ខុនោះកាលនឹងចេញដើរទៅកាន់អាវាសក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ១រោចទើបចូលទៅកាន់វិហាររៀបក្រាលសេនាសនៈ តំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសច្រាសទីបរិវេណ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃហើយក៏ចៀសចេញទៅដោយសត្តាហករណីយ ។ ភិក្ខុនោះត្រឡប់វិលមកវិញក្នុងរវាង៧ថ្ងៃនោះ ។ ម្នាលភិក្ខុទាំងឡាយ បច្ឆិមិកាវស្សារបស់ភិក្ខុនោះក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិព្រោះទទួលពាក្យប្តេជ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលពាក្យប្តេជ្ញាគេថានៅចាំវស្សាដោយបច្ឆិមិកាវស្សាហើយ ។ បេ ។ ភិក្ខុនោះកាលបើ

អនាគតាយ កោមុទិយា ចាតុម្មាសិនិយា សករណីយោ បក្កមតិ ។ អាគច្ឆេយ្យ វា សោ ភិក្ខវេ ភិក្ខុ កោមុទិំ ចាតុម្មាសិនិំ ន វា អាគច្ឆេយ្យ ។ តស្ស ភិក្ខវេ ភិក្ខុនោ បច្ឆិមិកា ច បញ្ញាយតិ បដិស្សវេ ច អនាបត្តិ ។ ឥធ បន ភិក្ខវេ ភិក្ខុនា វស្សាវាសោ បដិស្សុតោ ហោតិ បច្ឆិមិកាយ ។ សោ តំ អាវាសំ គន្ត្វា ឧបោសថំ ករោតិ បាដិបទេន វិហារំ ឧបេតិ សេនាសនំ បញ្ញាបេតិ បានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ បរិវេណំ សម្មជ្ជតិ ។ សោ តទហេវ អករណីយោ បក្កមតិ ។ បេ ។ សោ តទហេវ សករណីយោ បក្កមតិ ។ បេ ។ សោ ទ្វីហតីហំ វសិត្វា អករណីយោ បក្កមតិ ។ បេ ។ សោ ទ្វីហតីហំ វសិត្វា សករណីយោ បក្កមតិ ។ បេ ។ សោ ទ្វីហតីហំ វសិត្វា សត្តាហករណីយេន បក្កមតិ ។ សោ តំ សត្តាហំ ពហិទ្ធា វីតិនាមេតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បច្ឆិមិកា ច ន បញ្ញាយតិ បដិស្សវេ ច អាបត្តិ ទុក្កដស្ស ។ បេ ។ សោ ទ្វីហតីហំ វសិត្វា សត្តាហករណីយេន បក្កមតិ ។ សោ តំ



នៅខ្វះ ៧ ថ្ងៃទៀតគឺដល់ថ្ងៃចាតុម្មាសិនីនៃកោមុទី គឺថ្ងៃជាទីគ្រប់ ៤ ខែនៃរដូវភ្លៀង (១៤ កើតខែកត្តិក) មានកិច្ចដែលត្រូវធ្វើក៏ចៀសចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះបានមកកាន់អាវាសនោះក្តី មិនបានមកក្តី ។ ម្នាលភិក្ខុទាំងឡាយ បច្ឆិមិកាវស្សារបស់ភិក្ខុនោះក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិព្រោះទទួលពាក្យព្រមផង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលព្រមនឹងនៅចាំវស្សាដោយបច្ឆិមិកាវស្សាហើយ ។ ភិក្ខុនោះទៅកាន់អាវាសនោះហើយក៏ធ្វើឧបោសថដល់ថ្ងៃ ១ កើតទើបចូលទៅកាន់វិហាររៀបក្រាលសេនាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសព្រាសទីបរិវេណ ។ ភិក្ខុនោះឥតមានកិច្ចក៏ចៀសចេញទៅក្នុងថ្ងៃនោះឯង ។ បេ ។ ភិក្ខុនោះមានកិច្ចដែលត្រូវធ្វើក៏ចៀសចេញទៅក្នុងថ្ងៃនោះឯង ។ បេ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃ ឥតមានកិច្ចធ្វើក៏ចៀសចេញទៅ ។ បេ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃមានកិច្ចដែលត្រូវធ្វើក៏ចៀសចេញទៅ ។ បេ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃក៏ចៀសចេញទៅដោយសត្តាហករណីយ ។ ភិក្ខុនោះនៅខាងក្រៅហួសកំណត់ ៧ ថ្ងៃទៅ ។ ម្នាលភិក្ខុទាំងឡាយ បច្ឆិមិកាវស្សារបស់ភិក្ខុនោះក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដព្រោះទទួលពាក្យព្រមផង ។ បេ ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃក៏ចៀសចេញទៅដោយសត្តាហករណីយ ។ ភិក្ខុនោះត្រឡប់មកវិញក្នុង

សត្តាហំ អន្តោ សន្និវត្តំ ករោតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បច្ឆិមិកា ច បញ្ញាយតិ បដិស្សវេ ច អនាបត្តិ ។ ឥធ បន ភិក្ខវេ ភិក្ខុនា វស្សាវាសោ បដិស្សុតោ ហោតិ បច្ឆិមិកាយ ។ បេ ។ សោ សត្តាហំ អនាគតាយ កោមុទិយា ចាតុម្មាសិនិយា សករណីយោ បក្កមតិ ។ អាគច្ឆេយ្យ វា សោ ភិក្ខវេ ភិក្ខុ តំ អាវាសំ ន វា អាគច្ឆេយ្យ ។ តស្ស ភិក្ខវេ ភិក្ខុនោ បច្ឆិមិកា ច បញ្ញាយតិ បដិស្សវេ ច អនាបត្តីតិ ។

វស្សូបនាយិកក្ខន្ធកំ និដ្ឋិតំ ។

តស្សុទ្ទានំ

[១៨៤] ឧបគន្តុំ កទា ចេវ
កតិ អន្តរវស្ស ច
ន ឥច្ឆន្តិ ច សញ្ចិច្ច



ទើបនាំថ្ងៃនោះ ។ ម្នាលភិក្ខុទាំងឡាយ បច្ឆិមិកាវស្សារបស់ភិក្ខុនោះក៏ប្រាកដផងដែរ ភិក្ខុនោះមិនត្រូវអាបត្តិព្រោះទទួលពាក្យព្រមផងដែរ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលព្រមគេថានៅចាំវស្សាដោយបច្ឆិមិកាវស្សាហើយ ។ បេ ។ ភិក្ខុនោះកាលបើនៅខ្វះ៧ថ្ងៃទៀតនឹងដល់ថ្ងៃជាទីរីកនៃឈូកកុមុទ ដែលជាទីបំផុតនៃខែរដូវភ្លៀង (១៥កើតខែកត្តិក) មានកិច្ចដែលត្រូវធ្វើទៀត ក៏ចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមកកាន់អាវាសនោះក្តី មិនបានមកក្តី ។ ម្នាលភិក្ខុទាំងឡាយ បច្ឆិមិកាវស្សារបស់ភិក្ខុនោះក៏ប្រាកដផងដែរ ភិក្ខុនោះមិនត្រូវអាបត្តិព្រោះទទួលពាក្យព្រមផងដែរ ។

ចប់ វស្សូបនាយិកក្ខន្ធកៈទី ៣ ។

ឧទ្ទាននៃវស្សូបនាយិកក្ខន្ធកៈនោះ គឺ

[១៨៤] រឿងព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុចូល
វស្សា ១ ពួកភិក្ខុគិតថា យើងត្រូវចូលវស្សាក្នុងកាលណាហ្ន៎ ១
ពួកភិក្ខុគិតថាថ្ងៃចូលវស្សាមានប៉ុន្មានយ៉ាង ១ ពួកឆព្វគ្គិយ
ភិក្ខុបានចូលវស្សាហើយចេញដើរទៅកាន់ចារិកក្នុងកណ្តាល
វស្សា ១ មិនប្រាថ្នានឹងចូលវស្សា ១ វេលាជិតចូលវស្សាហើយ
ក៏រំលងចេញទៅកាន់អាវាសដទៃ ១ ស្តេចពិម្ពិសារប្រាថ្នានឹង

ឧក្កឌ្ឍិតុំ ឧបាសកោ
គិលានោ មាតា ច បិតា
ភាតា ច អថ ញាតកោ
ភិក្ខុគតិកោ វិហារេ
វាឡា ចាបិ សរីសបា
ចោរា ចេវ បិសាចា ច
ទឌ្ឍា តទុភយេន ច
វុឡ្ហោទកេន វុដ្ឋាសិ
ពហុតរា ច ទាយកា
លូខប្បណីតសប្បាយ
ភេសជ្ជុបដ្ឋាកេន ច
ឥត្ថី វេសី កុមារី ច
បណ្ឌកោ ញាតកេន ច
រាជា ចោរា ធុត្តា និធិ





ការលើកថ្ងៃ ១ ឧបាសកបានឲ្យគេកសាងវិហារចំពោះសង្ឃ ១ ភិក្ខុមានជម្ងឺ ១ មាតានឹងបិតារបស់ភិក្ខុមានជម្ងឺ ១ បងប្អូនរបស់ភិក្ខុមានជម្ងឺ ១ ញាតិរបស់ភិក្ខុមានជម្ងឺ ១ អ្នកធ្វើការឈ្នួលរបស់ភិក្ខុមានជម្ងឺ ១ វិហារទ្រុឌទ្រោម ១ សត្វសាហាវបៀតបៀនពួកភិក្ខុ ១ សត្វមានពិសបៀតបៀនពួកភិក្ខុ ១ ពួកចោរបៀតបៀនពួកភិក្ខុ ១ ពួកបិសាចបៀតបៀនពួកភិក្ខុ ១ ភ្លើងឆេះស្រុកនឹងឆេះទាំងសេនាសនៈទាំងពីររឿង ១ ទឹកលិចស្រុក ១ ពោរមកតាំងនៅក្នុងស្រុក ១ ពួកទាយកជាច្រើនឥតមានសព្វគ្រប់ ១ ភិក្ខុនៅចាំវស្សាក្នុងទីកាត់សង្វាង ហើយមិនដែលបានគេជូនភោជនាហារឬឧត្តមធាតុឲ្យគ្រប់គ្រាន់ពេញលេញ ១ ភិក្ខុនៅចាំវស្សា ហើយមិនដែលបានគេជូនថ្នាំឲ្យសប្បាយ ១ ភិក្ខុបានភេសជ្ជៈជាទីសប្បាយ ហើយតែមិនបានឧបដ្ឋាកដ៏សមគួរ ១ ស្រីប្រលោមភិក្ខុ ១ ស្រីផ្កាមាសប្រលោមភិក្ខុ ១ នាងកុមារីប្រលោមភិក្ខុ ១ មនុស្សខ្ទើយប្រលោមភិក្ខុ ១ ញាតិប្រលោមភិក្ខុ ១ ស្ដេចប្រលោមភិក្ខុ ១ ពួកចោរប្រលោមភិក្ខុ ១ ពួកអ្នកលេងប្រលោមភិក្ខុ ១ ភិក្ខុ

កេណា អឌ្ឍវេធេន ច

វេជា សត្ថា ច ជាតំ ច

សុសិរ វិដភាយ ច

អជ្ឈោកាសេ វស្សិកសោ

អសេនាសនកេ ច

ឆវកុដិកា ឆត្តេ ច

ចាដិយា ច ឧបេន្តិ តេ

កតិកា បដិស្សុណិត្វា

តហត្ថា ច ឧពោសថា

បុរិមិកា បច្ឆិមិកា

យថាញាយេន[1] យោជយេ

អករណីយោ[2] បក្កមតិ

សករណីយោ[3] តថេវ ច

ទ្វីហាតិកា ច ចុត[4]

១ ម. យថាញាយេន ។ ២ ម. អករណី ។ ៣ ម. សករណី ។ ៤ ម. ចុត ។



ឃើញកំណល់ព្រៃ ១ ភិក្ខុឃើញភិក្ខុច្រើនរូបពួក ឃោមបំបែក
សង្ឃ ១ ភិក្ខុ៨ពួកព្យាករឲ្យច្បាស់ដ៏ ភិក្ខុនីភិក្ខុនីពួក ឃោមបំ-
បែកសង្ឃ ១ ភិក្ខុចូលវស្សាក្នុងលំនៅរបស់គង្វាលគោ ១
ភិក្ខុចូលវស្សាក្នុងពួកឈ្មួញរទេះ ១ ភិក្ខុចូលវស្សាក្នុងទូក ១
ភិក្ខុចូលវស្សាក្នុងប្រហោងឈើ ១ ភិក្ខុចូលវស្សាលើប្រគាបឈើ ១
ភិក្ខុចូលវស្សាក្នុងទីវាល ១ ភិក្ខុចាំវស្សាឥតមានទីសេនាសនៈ ១
ភិក្ខុចូលវស្សាក្នុងខ្ទមខ្មោច ១ ក្រោមឆត្រ ១ ក្នុងពាងទឹក ១
សង្ឃធ្វើប្រជុំគ្នាថា កុំឲ្យបំបួសកុលបុត្រក្នុងវស្សា ១ ភិក្ខុទទួល
ព្រមជានឹងនៅចាំបុរិមិកាវស្សាឬបច្ឆិមិកាវស្សា ហើយធ្វើឧបោសថ
ខាងក្រៅ បណ្ដាំភិក្ខុប្រែបកតាមសមគួរដល់ន័យ ១ ភិក្ខុឥត
មានកិច្ចធុរៈហើយចៀសចេញទៅ ១ ភិក្ខុមានកិច្ចហើយចៀស
ចេញទៅ ១ ភិក្ខុនៅអស់ពីរបីថ្ងៃទៅ ដោយសត្តាហករណីយ

សត្ថា មហាការុណិកោ យេន ចិ

សត្ថា ហ ជាតកា ទេវ

អាការុញ្ញយុ បយុ[១] ក

វត្ថុត្តយេ អត្ថិតា

គន្ថមត្ថំ និសាមយេ ។

ឥតិ ខុទ្ទកេ វត្ថុ ទេ បណ្ណាស ។

១ ឧ. ន សំយុត្ត ។





ហើយទ្រង់ប្រោសសត្វ ១ អៅទ្ទះ ៣ ដែលទៀតនិងផលជាបក-
ណោ កិច្ចនោះទៅលាយសត្ថាហាករុណីយហើយទ្រង់បរមគ
កាន់តាក់សនោះគ្គី មិនបានទ្រង់បរមគកាន់តាក់សនោះគ្គី ១
បណ្ឌិតបរិបត្តិបានក្នុងទីនដែលមានដៃបដ់ទៀបយកទ្រ
ខុទ្ទនៃរឿងទាំងអស់លាហាល ។

ក្នុងខុទ្ទកៈនេះមានរឿង ៩២ ។

## បវារណក្ខន្ធកៈ

[២០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា សន្ទិដ្ឋា សម្ភត្តា ភិក្ខូ កោសលេសុ ជនបទេសុ អញ្ញតរស្មឹ អាវាសេ វស្សំ ឧបគច្ឆឹសុ ។ អថ ខោ តេសំ ភិក្ខូនំ ឯតទហោសិ កេន នុ ខោ មយំ ឧបាយេន សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសេយ្យាម ន ច បិណ្ឌកេន កិលមេយ្យាមាតិ ។ អថ ខោ តេសំ ភិក្ខូនំ ឯតទហោសិ សចេ ខោ មយំ អញ្ញមញ្ញំ នេវ អាលបេយ្យាម ន សល្លបេយ្យាម យោ បឋមំ គាមតោ បិណ្ឌាយ បដិក្កមេយ្យ សោ អាសនំ បញ្ញបេយ្យ បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបេយ្យ អវក្ការបាតឹ ធោវិត្វា ឧបដ្ឋាបេយ្យ បានីយំ បរិភោជនីយំ ឧបដ្ឋាបេយ្យ យោ បច្ឆា គាមតោ បិណ្ឌាយ បដិក្កមេយ្យ សចស្ស ភុត្តាវសេសោ សចេ អាកង្ខេយ្យ ភុញ្ជេយ្យ នោ ចេ

## បវារណក្ខន្ធកំ

[២០] សម័យនោះឯង ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង មានភិក្ខុច្រើនរូប ជាមិត្រដែលធ្លាប់ជួបប្រទះគ្នាផង ជាមិត្រស្និទ្ធស្នាលផង បានចូលវស្សានៅក្នុងអាវាស ១ ក្នុងកោសលជនបទ ។ គ្រានោះ ភិក្ខុទាំងនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ដោយឧបាយដូចម្ដេចហ្ន៎ យើងនឹងបានព្រមព្រៀងគ្នា រីករាយ មិនវិវាទគ្នា នៅចាំវស្សាឲ្យបានស្រួលផង មិនលំបាកដោយសារបិណ្ឌបាតផង ។ លំដាប់នោះឯង ភិក្ខុទាំងនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា បើយើងមិននិយាយគ្នា មិនប្រាស្រ័យគ្នាទៅវិញទៅមក ភិក្ខុណាត្រឡប់មកពីបិណ្ឌបាតអំពីស្រុកមុនគេ ភិក្ខុនោះគប្បីក្រាលអាសនៈ ដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់ដាក់ជើងដែលលាងរួចហើយ ដាក់ក្បឿងសម្រាប់ជូតជើងដែលមិនទាន់លាង គប្បីលាងភាជន៍សម្រាប់ផ្ទុកបាយ ហើយយកទៅដាក់ទុក គប្បីដាក់ទឹកឆាន់ និងទឹកប្រើប្រាស់ ភិក្ខុណាត្រឡប់មកពីបិណ្ឌបាតអំពីស្រុកក្រោយគេ បើមានបិណ្ឌបាតសល់អំពីភិក្ខុនោះឆាន់ បើភិក្ខុនោះប្រាថ្នា គប្បីឆាន់ចុះ

អាកង្ខេយ្យ អប្បហរិតេ វា ឆឌ្ឌេយ្យ អប្បាណកេ វា ឧទកេ ឱបិលាបេយ្យ សោ អាសនំ ឧទ្ធរេយ្យ បាទោទកំ បាទបីឋំ បាទកឋលិកំ បដិសាមេយ្យ អវក្ការបាតឹ ធោវិត្វា បដិសាមេយ្យ បានីយំ បរិភោជនីយំ បដិសាមេយ្យ ភត្តគ្គំ សម្មជ្ជេយ្យ យោ បស្សេយ្យ បានីយឃដំ វា បរិភោជនីយឃដំ វា វច្ចឃដំ វា រិត្តំ តុច្ឆំ សោ ឧបដ្ឋាបេយ្យ សចស្ស ហោតិ អវិសយ្ហំ ហត្ថវិការេន ទុតិយំ អាមន្តេត្វា ហត្ថវិលង្ឃកេន ឧបដ្ឋាបេយ្យ ន ត្វេវ តប្បច្ចយា វាចំ ភិន្ទេយ្យ ឯវំ ខោ មយំ សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសេយ្យាម ន ច បិណ្ឌកេន កិលមេយ្យាមាតិ ។ អថ ខោ តេ ភិក្ខូ អញ្ញមញ្ញំ នេវ អាលបឹសុ ន សល្លបឹសុ យោ បឋមំ គាមតោ បិណ្ឌាយ បដិក្កមតិ សោ អាសនំ បញ្ញាបេតិ បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបតិ អវក្ការបាតឹ ធោវិត្វា ឧបដ្ឋាបេតិ បានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ យោ បច្ឆា គាមតោ បិណ្ឌាយ បដិក្កមតិ សចេ ហោតិ ភុត្តាវសេសោ សចេ អាកង្ខតិ



បើមិនប្រាថ្នាទេ ត្រូវចាក់ចោលនៅលើទីដែលគ្មានស្មៅស្រស់ ឬផ្អាប់ចោលនៅក្នុងទឹកដែលគ្មានសត្វ (កំពូត) ភិក្ខុនោះត្រូវលើកអាសនៈ ទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង ទីនទ្រៀងសម្រាប់ជូតជើង ត្រូវលាងភាជន៍សម្រាប់ផ្ទុកកាកសំណល់ហើយរៀបចំទុកដាក់ ត្រូវទុកដាក់ទឹកឆាន់ ទឹកប្រើប្រាស់ ត្រូវបោសសម្អាតរោងភត្ត ភិក្ខុណាឃើញក្អមដាក់ទឹកឆាន់ក្តី ក្អមដាក់ទឹកប្រើប្រាស់ក្តី ក្អមលាងវច្ចៈក្តី ដែលរលីងទទេ ភិក្ខុនោះត្រូវដងកល់ទុក បើភិក្ខុនោះមិនអាច ព្រោះវិការដៃ (ឈើដៃ) ត្រូវហៅគ្នា ដោយអាការកួយដៃមកជួយដំកល់ទុក តែកុំឲ្យបញ្ចេញវាចាព្រោះបច្ច័យនោះឡើយ យ៉ាងនេះឯង ទើបយើងជាសមគ្គព្រមព្រៀង ស្មោះសរ មិនវិវាទគ្នា នៅចាំវស្សាស្រួលផង មិនលំបាកដោយអាហារបិណ្ឌបាតផង ។ គ្រានោះឯង ភិក្ខុទាំងនោះក៏លែងនិយាយរកគ្នា លែងជជែកគ្នាទៅវិញទៅមក ភិក្ខុណាត្រឡប់មកពីបិណ្ឌបាតអំពីស្រុកមុនគេ ភិក្ខុនោះក៏ក្រាលអាសនៈ ដំកល់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង ទីនទ្រៀងសម្រាប់ជូតជើង លាងភាជន៍សម្រាប់ផ្ទុកកាកសំណល់ហើយដំកល់ទុក ដំកល់ទឹកឆាន់ និងទឹកប្រើប្រាស់ ភិក្ខុណាត្រឡប់មកពីបិណ្ឌបាតអំពីស្រុកក្រោយគេ បើមានអាហារសេសសល់អំពីភិក្ខុនោះឆាន់ បើភិក្ខុនោះប្រាថ្នា

ភុញ្ជតិ នោ ចេ អាកង្ខតិ អប្បហរិតេ វា ឆឌ្ឌេតិ អប្បា-
ណកេ វា ឧទកេ ឱបិលាបេតិ សោ អាសនំ ឧទ្ធរតិ
បាទោទកំ បាទបីឋំ បាទកឋលិកំ បដិសាមេតិ
អវក្ការបាតឹ ធោវិត្វា បដិសាមេតិ បានីយំ បរិភោជនីយំ
បដិសាមេតិ ភត្តគ្គំ សម្មជ្ជតិ យោ បស្សតិ បានីយឃដំ
វា បរិភោជនីយឃដំ វា វច្ចឃដំ វា រិត្តំ តុច្ឆំ សោ
ឧបដ្ឋាបេតិ សចស្ស ហោតិ អវិសយ្ហំ ហត្ថវិការេន
ទុតិយំ អាមន្តេត្វា ហត្ថវិលង្ឃកេន ឧបដ្ឋាបេតិ ន
ត្វេវ តប្បច្ចយា វាចំ ភិន្ទតិ ។

(៦១) អាចិណ្ណំ ខោ បនេតំ វស្សំវុត្ថានំ ភិក្ខូនំ
ភគវន្តំ ទស្សនាយ ឧបសង្កមិតុំ ។ អថខោ តេ ភិក្ខូ
វស្សំវុត្ថា តេមាសច្ចយេន សេនាសនំ សំសាមេត្វា
បត្តចីវរមាទាយ យេន សាវត្ថី តេន បក្កមឹសុ អនុ-
បុព្វេន យេន សាវត្ថី ជេតវនំ អនាថបិណ្ឌិកស្ស អារា-
មោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ
អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ អាចិណ្ណំ ខោ បនេតំ
ពុទ្ធានំ ភគវន្តានំ អាគន្តុកេហិ ភិក្ខូហិ សទ្ធឹ



ក៏ឆាន់ទៅ បើមិនប្រាថ្នាទេ ចាក់ចោលទៅលើទីគ្មានស្មៅស្រស់ឬជ្រលក់ចោល
ទៅក្នុងទឹកដែលគ្មានសត្វ ភិក្ខុនោះរើអាសនៈចេញ ទុកដាក់ទឹកសម្រាប់
លាងជើង តាំងសម្រាប់ទ្រជើង គ្រឿងសម្រាប់ដុសជើង លាងភាជន៍
សម្រាប់ផ្ទុកកាកបាយ ហើយរៀបទុកដាក់ ទុកដាក់ទឹកឆាន់និងទឹកប្រើប្រាស់
បោសសម្អាតរោងភត្ត ភិក្ខុណាឃើញក្អមសម្រាប់ដាក់ទឹកឆាន់ក្តី ក្អម
សម្រាប់ដាក់ទឹកប្រើប្រាស់ក្តី ក្អមដាក់ទឹកសម្រាប់ជម្រះក្តី ដែលរលីងទទេ
ភិក្ខុនោះក៏ដាក់ទុក បើភិក្ខុនោះមិនអាច ព្រោះធ្ងន់ពេក ក៏ហៅភិក្ខុ
ដោយអាការធ្វើដៃមកឱ្យជួយលើកទុក តែមិនបញ្ចេញវាចា ព្រោះ
បច្ច័យនោះឡើយ ។

(៦១) ការដែលចូលទៅគាល់ព្រះមានព្រះភាគនុ៎ះ ជាទំនៀមរបស់
ភិក្ខុទាំងឡាយដែលចាំវស្សារួចហើយ ។ វេលានោះឯង ភិក្ខុទាំងនោះ
លុះនៅចាំវស្សាគ្រប់ត្រៃមាសហើយ ក៏រៀបចំទុកដាក់សេនាសនៈរួចកាន់
យកបាត្រនិងចីវរចេញដើរសំដៅទៅក្រុងសាវត្ថី លុះដើរទៅដោយលំ-
ដាប់ហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគក្នុងវត្តជេតពនរបស់អនាថ-
បិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំ
ព្រះមានព្រះភាគរួចអង្គុយនៅក្នុងទីដ៏សមគួរ ។ ការរីករាយជាមួយនឹង
ពួកភិក្ខុជាអាគន្តុកៈនុ៎ះឯង ជាទំនៀមរបស់ព្រះពុទ្ធមានព្រះភាគទាំងឡាយ

បដិសម្មោទិតុំ ។ អថខោ ភគវា តេ ភិក្ខូ ឯតទវោច កច្ចិ ភិក្ខវេ ខមនីយំ កច្ចិ យាបនីយំ កច្ចិ សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសិត្ថ ន ច បិណ្ឌកេន កិលមិត្ថាតិ ។ ខមនីយំ ភគវា យាបនីយំ ភគវា សមគ្គា ច មយំ ភន្តេ សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសិម្ហា ន ច បិណ្ឌកេន កិលមិម្ហាតិ ។ ជានន្តាបិ តថាគតា បុច្ឆន្តិ ជានន្តាបិ ន បុច្ឆន្តិ កាលំ វិទិត្វា បុច្ឆន្តិ កាលំ វិទិត្វា ន បុច្ឆន្តិ អត្ថសញ្ហិតំ តថាគតា បុច្ឆន្តិ នោ អនត្ថសញ្ហិតំ អនត្ថសញ្ហិតេ សេតុឃាតោ តថាគតានំ ។ ទ្វីហាការេហិ ពុទ្ធា ភគវន្តោ ភិក្ខូ បដិបុច្ឆន្តិ ធម្មំ វា ទេសេស្សាម



(នៃព្រះអង្គ) ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវព្រះពុទ្ធដីកានេះ នឹងពួកភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយល្មមអត់ធន់សេចក្តីទុក្ខបានឬទេ ល្មមឲ្យឥរិយាបថប្រព្រឹត្តទៅស្រួលបានឬទេ អ្នកទាំងឡាយជាអ្នកព្រមព្រៀងគ្នា ស្រុះស្រួលគ្នា មិនទាស់ទែងគ្នា នៅចាំវស្សាដោយសប្បាយហើយឬ មួយទៀត អ្នកទាំងឡាយមិនលំបាកដោយបិណ្ឌបាតទេឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំល្មមអត់ធន់សេចក្តីទុក្ខបាន បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំល្មមឲ្យឥរិយាបថប្រព្រឹត្តទៅស្រួលបាន បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំក៏ព្រមព្រៀងគ្នា ស្រុះស្រួលគ្នា មិនទាស់ទែងគ្នា នៅចាំវស្សាតាមសប្បាយ មួយទៀត យើងខ្ញុំមិនលំបាកដោយបិណ្ឌបាតទេ ។ ព្រះតថាគតទាំងឡាយទ្រង់ជ្រាបហើយត្រាស់សួរក៏មាន ទ្រង់ជ្រាបហើយមិនត្រាស់សួរ (ក៏មាន) ទ្រង់ជ្រាបកាលគួរហើយទើបត្រាស់សួរ (ក៏មាន) ទ្រង់ជ្រាបកាលគួរហើយមិនត្រាស់សួរ (ក៏មាន) ព្រះតថាគតទាំងឡាយត្រាស់សួរចំពោះតែហេតុដែលប្រកបដោយប្រយោជន៍ មិនទ្រង់ត្រាស់សួរហេតុដែលឥតប្រយោជន៍ឡើយ (ព្រោះ) ហេតុដែលឥតប្រយោជន៍ ព្រះតថាគតទាំងឡាយទ្រង់ផ្តាច់បង់ដោយអរិយមគ្គហើយ ។ ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគត្រាស់សួរចំពោះភិក្ខុទាំងឡាយដោយអាការពីរយ៉ាង

សាវកានំ វា សិក្ខាបទំ បញ្ញាបេស្សាមាតិ ។ អថខោ ភគវា តេ ភិក្ខូ ឯតទវោច យថាកថំ បន តុម្ហេ ភិក្ខវេ សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសិត្ថ ន ច បិណ្ឌកេន កិលមិត្ថាតិ ។ ឥធ មយំ ភន្តេ សម្ពហុលា សន្ទិដ្ឋា សម្ភត្តា ភិក្ខូ កោសលេសុ ជនបទេសុ អញ្ញតរស្មឹ អាវាសេ វស្សំ ឧបគច្ឆិម្ហា តេសំ នោ ភន្តេ អម្ហាកំ ឯតទហោសិ កេន នុ ខោ មយំ ឧបាយេន សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសេយ្យាម ន ច បិណ្ឌកេន កិលមេយ្យាមាតិ តេសំ នោ ភន្តេ អម្ហាកំ ឯតទហោសិ សចេ ខោ មយំ អញ្ញមញ្ញំ នេវ អាលបេយ្យាម ន សល្លបេយ្យាម យោ បឋមំ គាមតោ បិណ្ឌាយ បដិក្កមេយ្យ សោ អាសនំ បញ្ញាបេយ្យ បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបេយ្យ អវក្ការបាតិំ ធោវិត្វា ឧបដ្ឋាបេយ្យ បានីយំ បរិភោជនីយំ ឧបដ្ឋាបេយ្យ យោ បច្ឆា គាមតោ បិណ្ឌាយ បដិក្កមេយ្យ



នឹងទ្រង់ត្រាស់សួរដោយទ្រង់គិតថា តថាគតនឹងសំដែងធម៌ឬក៏ នឹងបញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយឬក៏ ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដីកាទៅនឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយព្រមព្រៀងគ្នា ស្រួសស្រួលគ្នា មិនទាស់ទែងគ្នានៅចាំវស្សា ដោយសប្បាយយ៉ាងណាទៅ មួយទៀត អ្នកទាំងឡាយមិនលំបាកដោយបិណ្ឌបាតទេឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំជាភិក្ខុច្រើនរូបជាមិត្តបានជួបប្រទះគ្នាជាមិត្ត សេពគប់គ្នាមាំមួនចូលទៅចាំវស្សាក្នុងអាវាសមួយខាងកោសលជនបទនេះ បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងនោះមានសេចក្តីត្រិះរិះដូច្នេះថា យើងនឹងបានជាបុគ្គលព្រមព្រៀងគ្នា ស្រួសស្រួលគ្នា កុំទាស់ទែងគ្នានៅចាំវស្សាដោយសប្បាយ មួយទៀត យើងមិនគប្បីលំបាកដោយបិណ្ឌបាតដោយឧបាយដូចម្ដេចហ្ន៎ បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងនោះមានសេចក្តីត្រិះរិះដូច្នេះទៀតថា ប្រសិនបើយើងកុំគប្បីហៅគេគ្នា កុំគប្បីចរចាគ្នានៅវិញទៅមក ភិក្ខុណាត្រឡប់មកពីបិណ្ឌបាតក្នុងស្រុកមុនគេ ភិក្ខុនោះត្រូវរៀបចំអាសនៈ ដាក់ទឹកលាងជើង តាំងទីជើង ទ្រនាប់សំរាប់ដុសជើង លាងភាជន៍សំរាប់ដាក់កាកគ្រួបហើយដាក់ទុក ហើយដាក់ទឹកផឹកទឹកប្រើប្រាស់ ភិក្ខុណាត្រឡប់មកអំពីបិណ្ឌបាត

សចស្ស ភុត្តាវសេសោ សចេ អាកង្ខេយ្យ ភុញ្ជេយ្យ នោ ចេ អាកង្ខេយ្យ អប្បហរិតេ វា ឆឌ្ឌេយ្យ អប្បាណកេ វា ឧទកេ ឱបិលាបេយ្យ សោ អាសនំ ឧទ្ធរេយ្យ បាទោទកំ បាទបីឋំ បាទកឋលិកំ បដិសាមេយ្យ អវក្ការបាតឹ ធោវិត្វា បដិសាមេយ្យ បានីយំ បរិភោជនីយំ បដិសាមេយ្យ ភត្តគ្គំ សម្មជ្ជេយ្យ យោ បស្សេយ្យ បានីយឃដំ វា បរិភោជនីយឃដំ វា វច្ចឃដំ វា រិត្តំ តុច្ឆំ សោ ឧបដ្ឋាបេយ្យ សចស្ស ហោតិ អវិសយ្ហំ ហត្ថវិការេន ទុតិយំ អាមន្តេត្វា ហត្ថវិលង្ឃកេន ឧបដ្ឋាបេយ្យ ន ត្វេវ តប្បច្ចយា វាចំ ភិន្ទេយ្យ ឯវំ ខោ មយំ សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសេយ្យាម ន ច បិណ្ឌកេន កិលមេយ្យាមាតិ អថខោ មយំ ភន្តេ អញ្ញមញ្ញំ នេវ អាលបិម្ហា ន សល្លបិម្ហា



ក្នុងស្រុកក្រោយគេ បើមានអាហារសេសសល់អំពីភិក្ខុឆាន់ បើភិក្ខុនោះចង់ឆាន់ក៏ឆាន់ចុះ បើមិនចង់ឆាន់ទេ គឺចាក់ចោលលើទីដែលគ្មានស្មៅស្រស់ ឬចាក់ចោលក្នុងទឹកដែលគ្មានសត្វ ភិក្ខុនោះត្រូវរៀបអាសនៈ ត្រូវទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់ដាក់ជើង ទីដីឥដ្ឋសម្រាប់ជូតជើង ត្រូវលាងភាជន៍សម្រាប់ដាក់កាកហើយយកទៅទុកដាក់ រួចត្រូវទុកដាក់ទឹកផឹកទឹកប្រើប្រាស់ ត្រូវបោសរោងឆាន់ ភិក្ខុណាឃើញក្អមទឹកផឹកក្តី ក្អមទឹកប្រើប្រាស់ក្តី ក្អមដាក់ទឹកសម្រាប់លាងវច្ចៈក្តី ដែលរលីងទទេ ត្រូវភិក្ខុនោះដក់លើទុក បើភិក្ខុនោះមិនអាច (នឹងធ្វើការនោះម្នាក់) ត្រូវធ្វើវិការដៃ (គឺលើកដៃជាដើម) ត្រូវឲ្យហៅភិក្ខុទីពីរ ឲ្យជួយលើកទុក មិនត្រូវបញ្ចេញវាចាព្រោះហេតុនោះឡើយ កាលបើធ្វើយ៉ាងនេះហើយ ទើបបានយើងទាំងឡាយជាបុគ្គលព្រមព្រៀងគ្នា ស្រុះស្រួលគ្នា មិនទាស់ទែងគ្នា នៅចាំវស្សាដោយសប្បាយ មួយវិញទៀត យើងទាំងឡាយមិនលំបាកដោយដុំបាយផង បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះឯង យើងខ្ញុំមិនបានហៅគ្នា មិនបានពោលគ្នាទៅវិញទៅមកទេ ភិក្ខុណាត្រឡប់មកអំពី

យោ បឋមំ គាមតោ បិណ្ឌាយ បដិក្កមតិ សោ អាសនំ បញ្ញាបេតិ បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបតិ អវក្ការបាតឹ ធោវិត្វា ឧបដ្ឋាបេតិ បានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ យោ បច្ឆា គាមតោ បិណ្ឌាយ បដិក្កមតិ សចេ ហោតិ ភុត្តាវសេសោ សចេ អាកង្ខតិ ភុញ្ជតិ នោ ចេ អាកង្ខតិ អប្បហរិតេ វា ឆឌ្ឌេតិ អប្បាណកេ វា ឧទកេ ឱបិលាបេតិ សោ អាសនំ ឧទ្ធរតិ បាទោទកំ បាទបីឋំ បាទកឋលិកំ បដិសាមេតិ អវក្ការបាតឹ ធោវិត្វា បដិសាមេតិ បានីយំ បរិភោជនីយំ បដិសាមេតិ ភត្តគ្គំ សម្មជ្ជតិ យោ បស្សតិ បានីយឃដំ វា បរិភោជនីយឃដំ វា វច្ចឃដំ វា រិត្តំ តុច្ឆំ សោ ឧបដ្ឋាបេតិ សចស្ស ហោតិ អវិសយ្ហំ ហត្ថវិការេន ទុតិយំ អាមន្តេត្វា ហត្ថវិលង្ឃកេន ឧបដ្ឋាបេតិ ន ត្វេវ តប្បច្ចយា វាចំ ភិន្ទតិ ឯវំ ខោ មយំ ភន្តេ សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសិម្ហា ន ច បិណ្ឌកេន កិលមិម្ហាតិ ។



បិណ្ឌបាតត្រឡប់មកមុនគេ ភិក្ខុនោះក៏ក្រាលអាសនៈ ដាក់ទុកនូវទឹកលាងជើង តាំងទ្រនាប់ជើងនិងថែនាប់សម្រាប់ដុសជើង លាងភាជន៍សម្រាប់ដាក់កាកហើយដាក់ទុក រួចដាក់ទឹកផឹកទឹកប្រើប្រាស់ ភិក្ខុណាត្រឡប់មកអំពីបិណ្ឌបាតត្រឡប់ក្រោយគេ បើមានភត្តសេសសល់អំពីភិក្ខុឆាន់ បើភិក្ខុនោះប្រាថ្នានឹងឆាន់ក៏ឆាន់ទៅ បើមិនប្រាថ្នាទេ ភិក្ខុនោះក៏ចាក់ចោលលើដីដែលគ្មានស្មៅស្រស់ក៏បាន បណ្តោយក្នុងទឹកដែលគ្មានសត្វក៏បាន ភិក្ខុនោះលើកអាសនៈចេញហើយទុកដាក់ទឹកលាងជើង តាំងទ្រនាប់ជើងនិងថែនាប់សម្រាប់ដុសជើង លាងភាជន៍សម្រាប់ដាក់កាកហើយយកទៅទុក រួចទុកដាក់ទឹកផឹកទឹកប្រើប្រាស់ បោសរោងភត្ត ភិក្ខុណាឃើញក្អមដាក់ទឹកផឹកក្តី ក្អមដាក់ទឹកប្រើប្រាស់ក្តី ក្អមទឹកសម្រាប់លាងវច្ចៈក្តី ដែលទទេ ភិក្ខុនោះក៏ចូរយកមកដាក់ទុក បើភិក្ខុនោះមិនអាច (នឹងធ្វើការនោះបាន) ក្រវីកដៃ (ឈប់ដៃជាដើម) ភិក្ខុនោះបក់ដៃហៅភិក្ខុទីពីរឲ្យជួយយកមកដាក់ទុក មិនបានបំបែកវាចាព្រោះហេតុនោះឡើយ បពិត្រព្រះអង្គដ៏ចំរើន តាមរបៀបនេះហើយ ពួកខ្ញុំព្រះអង្គព្រមព្រៀងគ្នា ស្រុះស្រួលគ្នា មិនទាស់ទែងគ្នា នៅចាំវស្សាជាសុខស្រួល មួយវិញទៀត ពួកខ្ញុំមិនលំបាកដោយបិណ្ឌបាតឡើយ ។

(៦៦) អថខោ ភគវា ភិក្ខូ អាមន្តេសិ អផាសុញ្ញេវ កិរ ភិក្ខវេ មោឃបុរិសា វុត្ថា សមានា ផាសុម្ហា វុត្ថាតិ បដិជានន្តិ បសុសំវាសញ្ញេវ កិរ ភិក្ខវេ មោឃបុរិសា វុត្ថា សមានា ផាសុម្ហា វុត្ថាតិ បដិជានន្តិ ឯឡកសំវាសញ្ញេវ កិរ ភិក្ខវេ មោឃបុរិសា វុត្ថា សមានា ផាសុម្ហា វុត្ថាតិ បដិជានន្តិ សបត្តសំវាសញ្ញេវ កិរ ភិក្ខវេ មោឃបុរិសា វុត្ថា សមានា ផាសុម្ហា វុត្ថាតិ បដិជានន្តិ កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា មូគព្វតំ តិត្ថិយសមាទានំ សមាទិយិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ មូគព្វតំ តិត្ថិយសមាទានំ សមាទិយិតព្វំ យោ សមាទិយេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ វស្សំវុត្ថានំ ភិក្ខូនំ តីហិ ឋានេហិ បវារេតុំ ទិដ្ឋេន វា សុតេន វា



(៦៦) គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ហៅភិក្ខុទាំងឡាយ មកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថាមោឃបុរសទាំងឡាយនេះ នៅ (ចាំវស្សា) មិនសប្បាយទេ (តែ) ប្ដេជ្ញាថាខ្លួនជាអ្នកនៅដោយសប្បាយ ម្នាលភិក្ខុទាំងឡាយ ឮថាមោឃបុរសទាំងឡាយនេះនៅដូចជាការនៅរួមរបស់បសុសត្វ (សត្វចិញ្ចឹម) ហើយប្ដេជ្ញាថាខ្លួនជាអ្នកនៅសប្បាយ ម្នាលភិក្ខុទាំងឡាយ ឮថាមោឃបុរសទាំងឡាយនេះនៅដូចជាការនៅរួមរបស់សត្វពពែ (តែ) ប្ដេជ្ញាថាខ្លួនជាអ្នកនៅសប្បាយ ម្នាលភិក្ខុទាំងឡាយ ឮថាមោឃបុរសទាំងឡាយនេះនៅដូចជាការនៅរបស់បុគ្គលប្រមាថ (តែ) ប្ដេជ្ញាថាខ្លួនជាអ្នកនៅដោយសប្បាយ ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងឡាយនេះ មិនសមបើនឹងសមាទានមូគវត្ត (វត្តរបស់មនុស្សគ) ដែលជាតិត្ថិយសមាទាន (សមាទានរបស់តិរ្ថិយ) ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនទាន់ឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុសមាទានមូគវត្តដែលជាតិត្ថិយសមាទានទេ ភិក្ខុណាសមាទាន ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយដែលនៅចាំវស្សារួចហើយបវារណា ដោយស្ថានបីយ៉ាង គឺដោយឃើញក្ដី

បរិសង្កាយ វា ។ សា វោ ភវិស្សតិ អញ្ញមញ្ញានុលោមតា អាបត្តិវុដ្ឋានតា វិនយបុរេក្ខារតា ។ ឯវញ្ច បន ភិក្ខវេ បវារេតព្វំ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អជ្ជ បវារណា ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ បវារេយ្យាតិ ។ ថេរេន ភិក្ខុនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ សង្ឃំ អាវុសោ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ទុតិយម្បិ អាវុសោ សង្ឃំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ តតិយម្បិ អាវុសោ សង្ឃំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមីតិ ។ នវកេន ភិក្ខុនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ សង្ឃំ



ដោយឮក្តី ដោយរង្កៀសក្តី ។ បវារណានោះជាការអនុលោមដើម្បីពោលប្រដៅខ្លួនគ្នានឹងគ្នា ជាការចេញចាកអាបត្តិ ជាការធ្វើវិន័យឲ្យជាប្រធាន នឹងប្រាកដដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ គប្បីអ្នកទាំងឡាយបវារណាយ៉ាងនេះ ។ ភិក្ខុដែលឈ្លាសប្រតិពលឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ថ្ងៃនេះជាថ្ងៃបវារណា ។ បើបវារណាកម្មមានកាលគួរដល់សង្ឃហើយ សូមសង្ឃបវារណា ។ ភិក្ខុជាថេរៈធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាងអង្គុយច្រហោងផ្គងអញ្ជលីឡើងហើយនិយាយយ៉ាងនេះនឹងសង្ឃថា នែអាវុសោ ខ្ញុំសូមបវារណានឹងសង្ឃ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ ហើយពោលចំពោះខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម នែអាវុសោ ខ្ញុំសូមបវារណានឹងសង្ឃជាគំរប់ពីរដង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះហើយពោលចំពោះខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម នែអាវុសោ ខ្ញុំសូមបវារណានឹងសង្ឃជាគំរប់បីដង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះ ហើយពោលចំពោះខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម ។ ភិក្ខុនវកៈធ្វើឧត្តរាសង្គឆៀងស្មាម្ខាង អង្គុយច្រហោងផ្គងអញ្ជលីឡើង ហើយនិយាយ

ភន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិការិស្សាមិ ទុតិយម្បិ ភន្តេ សង្ឃំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិការិស្សាមិ តតិយម្បិ ភន្តេ សង្ឃំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិការិស្សាមីតិ ។

(៦៣) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ថេរេសុ ភិក្ខូសុ ឧក្កុដិកំ និសិន្នេសុ បវារយមានេសុ អាសនេសុ អច្ឆន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ថេរេសុ ភិក្ខូសុ ឧក្កុដិកំ និសិន្នេសុ បវារយមានេសុ អាសនេសុ អច្ឆិស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខូ ថេរេសុ ភិក្ខូសុ ឧក្កុដិកំ និសិន្នេសុ បវារយមានេសុ



បវារណានឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមបវារណានឹងសង្ឃ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះហើយពោលចំពោះខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមបវារណានឹងសង្ឃជាគំរប់ពីរដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះហើយពោលចំពោះខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមបវារណានឹងសង្ឃជាគំរប់បីដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះហើយពោលចំពោះខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម ។

[៦៣] សម័យនោះឯង កាលដែលភិក្ខុទាំងឡាយ ជាថេរៈកំពុងអង្គុយច្រហោងបវារណា ពួកឆព្វគ្គិយភិក្ខុក៏នៅលើអាសនៈទាំងឡាយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោសតិះដៀលបន្តុះបង្អាប់ថា កាលដែលភិក្ខុទាំងឡាយជាថេរៈកំពុងអង្គុយច្រហោងបវារណា មិនសមបើពួកឆព្វគ្គិយភិក្ខុហ៊ាននៅលើអាសនៈទាំងឡាយសោះ ។ ទើបភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថាកាលដែលភិក្ខុទាំងឡាយជាថេរៈកំពុងអង្គុយច្រហោងបវារណា ពួកឆព្វគ្គិយភិក្ខុ

អាសនេសុ អច្ឆន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃ-បុរិសា ថេរេសុ ភិក្ខូសុ ឧក្កុដិកំ និសិន្នេសុ បវារ-យមានេសុ អាសនេសុ អច្ឆិស្សន្តិ ។ នេតំ ភិក្ខវេ អប្ប-សន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ ថេរេសុ ភិក្ខូសុ ឧក្កុដិកំ និសិន្នេសុ បវារយមានេសុ អាសនេសុ អច្ឆិ-តព្វំ យោ អច្ឆេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ សព្វេហេវ ឧក្កុដិកំ និសិន្នេហិ បវារេតុំ ។ តេន ខោ បន សមយេន អញ្ញតរោ ថេរោ ជរាទុព្វលោ យាវ សព្វេ បវារេន្តិ[១] ឧក្កុដិកំ និសិន្នោ អាគមយមានោ មុច្ឆិតោ បបតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តទន្តរា ឧក្កុដិកំ និសីទិតុំ យាវ បវារេតិ បវារេត្វា អាសនេ និសីទិតុន្តិ ។

១ ម. បវារេន្តី ។



នៅលើអាសនៈ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះមានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធមានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ កាលដែលភិក្ខុទាំងឡាយជាថេរៈអង្គុយច្រហោងបវារណា មោឃបុរសទាំងឡាយនោះមិនសមបើនឹងហ៊ាននៅលើអាសនៈទាំងឡាយទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ កាលដែលភិក្ខុជាថេរៈទាំងឡាយអង្គុយច្រហោងបវារណា ភិក្ខុមិនត្រូវនៅលើអាសនៈទាំងឡាយទេ ភិក្ខុណានៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងអស់នោះ អង្គុយច្រហោងហើយបវារណា ។ គ្រាសម័យនោះឯង ព្រះថេរៈមួយអង្គថយកំឡាំងដោយជរា កាលបើអង្គុយច្រហោងនៅចាំភិក្ខុទាំងឡាយបវារណាសព្វគ្នា ក៏ដួលផ្ងប់ដួលទៅ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអង្គុយច្រហោង ក្នុងវេលាដែលខ្លួនកំពុងបវារណា លុះបវារណារួចហើយ ទើបអង្គុយលើអាសនៈបាន ។

(៦៦) អថខោ ភិក្ខូនំ ឯតទហោសិ កតិ នុ ខោ បវារណាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ទ្វេមា ភិក្ខវេ បវារណា ចាតុទ្ទសិកា បណ្ណរសិកា ច ឥមា ខោ ភិក្ខវេ ទ្វេ បវារណាតិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កតិ នុ ខោ បវារណាកម្មានីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ចត្តារិមានិ ភិក្ខវេ បវារណាកម្មានិ អធម្មេន វគ្គំ បវារណាកម្មំ អធម្មេន សមគ្គំ បវារណាកម្មំ ធម្មេន វគ្គំ បវារណាកម្មំ ធម្មេន សមគ្គំ បវារណាកម្មំ ។ តត្រ ភិក្ខវេ យទិទំ អធម្មេន វគ្គំ បវារណាកម្មំ ន ភិក្ខវេ ឯវរូបំ បវារណាកម្មំ កាតព្វំ ន ច មយា ឯវរូបំ បវារណាកម្មំ អនុញ្ញាតំ ។



(៦៦) លំដាប់នោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះ ដូច្នេះថា បវារណាមានប៉ុន្មានយ៉ាងហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បវារណាមានពីរយ៉ាង គឺចាតុទ្ទសិកាបវារណា(១) ១ បណ្ណរសិកាបវារណា(២) ១ ម្នាលភិក្ខុទាំងឡាយ បវារណាមានតែពីរយ៉ាងប៉ុណ្ណោះឯង ។ លំដាប់នោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា បវារណាកម្មមានប៉ុន្មានហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ បវារណាកម្មទាំងនេះមាន ៤ គឺបវារណាកម្មជាវគ្គ មិនត្រូវតាមធម៌ ១ បវារណាកម្មព្រមព្រៀងគ្នា តែមិនត្រូវតាមធម៌ ១ បវារណាកម្មជាវគ្គ តែត្រូវតាមធម៌ ១ បវារណាកម្មព្រមព្រៀងគ្នាត្រូវតាមធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បវារណាកម្មទាំង ៤ នោះ បវារណាកម្មណាជាវគ្គ តែមិនត្រូវតាមធម៌ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនត្រូវធ្វើបវារណាកម្មបែបនេះទេ មួយទៀត តថាគតមិនអនុញ្ញាតបវារណាកម្មបែបនេះទេ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបវារណាកម្មទាំង

១ បវារណាក្នុងថ្ងៃទី ១៤ ។ ២ បវារណាក្នុងថ្ងៃទី ១៥ ។

តត្រ ភិក្ខវេ យទិទំ អធម្មេន សមគ្គំ បវារណាកម្មំ ន ភិក្ខវេ ឯវរូបំ បវារណាកម្មំ កាតព្វំ ន ច មយា ឯវរូបំ បវារណាកម្មំ អនុញ្ញាតំ ។ តត្រ ភិក្ខវេ យទិទំ ធម្មេន វគ្គំ បវារណាកម្មំ ន ន ភិក្ខវេ ឯវរូបំ បវារណាកម្មំ កាតព្វំ ន ច មយា ឯវរូបំ បវារណាកម្មំ អនុញ្ញាតំ ។ តត្រ ភិក្ខវេ យទិទំ ធម្មេន សមគ្គំ បវារណាកម្មំ ឯវរូបំ ភិក្ខវេ បវារណាកម្មំ កាតព្វំ ឯវរូបំ មយា បវារណាកម្មំ អនុញ្ញាតំ ។ តស្មាតិហ ភិក្ខវេ ឯវរូបំ បវារណាកម្មំ ករិស្សាម យទិទំ ធម្មេន សមគ្គន្តិ ឯវំ ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[៤៨] អថខោ ភគវា ភិក្ខូ អាមន្តេសិ សន្និបតថ ភិក្ខវេ សង្ឃោ បវារេស្សតីតិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច អត្ថិ ភន្តេ ភិក្ខុ គិលានោ សោ អនាគតោតិ ។ អនុជានាមិ ភិក្ខវេ គិលានេន



៤ នោះ បវារណាកម្មណា ព្រមព្រៀងគ្នាតែមិនត្រូវតាមធម៌ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនត្រូវធ្វើបវារណាកម្មបែបនេះ មួយទៀត តថាគតមិនអនុញ្ញាតបវារណាកម្មបែបនេះ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបវារណាកម្មទាំង ៤ នោះ បវារណាកម្មណាជាពួកតែត្រូវតាមធម៌ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនត្រូវធ្វើបវារណាកម្មបែបនេះ មួយទៀត តថាគតមិនអនុញ្ញាតបវារណាកម្មបែបនេះ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបវារណាកម្មទាំង ៤ នោះ បវារណាកម្មណា ព្រមព្រៀងគ្នាត្រូវតាមធម៌ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវធ្វើបវារណាកម្មបែបនេះចុះ តថាគតអនុញ្ញាតបវារណាកម្មបែបនេះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះត្រូវសិក្សាដូច្នេះថា បវារណាកម្មណា ព្រមព្រៀងគ្នាត្រូវតាមធម៌ យើងទាំងឡាយនឹងធ្វើបវារណាកម្មបែបនេះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវតែសិក្សាយ៉ាងនេះឯង ។

(៤៨) គ្រានោះឯង ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកទាំងឡាយប្រជុំគ្នាចុះ (ព្រោះ) សង្ឃនឹងបវារណា ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់បន្ទូលយ៉ាងនេះហើយ ភិក្ខុមួយរូប ទើបក្រាបទូលព្រះមានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន នៅមានភិក្ខុឈឺ ភិក្ខុនោះមិនបានមក ។ ព្រះមានព្រះ

ភិក្ខុនា បវារណំ ទាតុំ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វា ។ តេន គិលានេន ភិក្ខុនា ឯកំ ភិក្ខុំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ បវារណំ ទម្មិ បវារណំ មេ ហរ មមត្ថាយ បវារេហីតិ កាយេន វិញ្ញាបេតិ វាចាយ វិញ្ញាបេតិ កាយេន វាចាយ វិញ្ញាបេតិ ទិន្នា ហោតិ បវារណា ។ ន កាយេន វិញ្ញាបេតិ ន វាចាយ វិញ្ញាបេតិ ន កាយេន វាចាយ វិញ្ញាបេតិ ន ទិន្នា ហោតិ បវារណា ។ ឯវញ្ចេតំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ សោ ភិក្ខវេ គិលានោ ភិក្ខុ មញ្ចេន វា បីឋេន វា សង្ឃមជ្ឈេ អានេត្វា បវារេតព្វំ ។ សចេ ភិក្ខវេ គិលានុបដ្ឋាកានំ ភិក្ខូនំ ឯវំ ហោតិ សចេ ខោ មយំ គិលានំ ឋានា ចាវេស្សាម អាពាធោ វា អភិវឌ្ឍិស្សតិ កាលង្កិរិយា វា ភវិស្សតីតិ ។ ន ភិក្ខវេ គិលានោ ឋានា ចាវេតព្វោ សង្ឃេន តត្ថ គន្ត្វា បវារេតព្វំ ន ត្វេវ វគ្គេន សង្ឃេន បវារេតព្វំ





ភាសន្រ្ទើមនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឈឺឲ្យនូវបវារណាបាន ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯបវារណានោះត្រូវឲ្យយ៉ាងនេះ ។ ត្រូវភិក្ខុឈឺនោះចូលទៅរកភិក្ខុមួយរូបធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាងអង្គុយច្រហោងផ្គងអញ្ជលីឡើងហើយ និយាយយ៉ាងនេះនឹងភិក្ខុនោះថា ខ្ញុំសូមឲ្យបវារណា លោកចូរនាំបវារណារបស់ខ្ញុំទៅ លោកចូរបវារណាដើម្បីប្រយោជន៍ដល់ខ្ញុំផង ។ ភិក្ខុនោះបញ្ជាក់(សេចក្តី)ដោយកាយ(ក្តី) បញ្ជាក់ដោយវាចា(ក្តី) បញ្ជាក់ដោយកាយនឹងវាចា(ក្តី) ក៏ឈ្មោះថាភិក្ខុនោះឲ្យបវារណាហើយ ។ (បើ)ភិក្ខុឈឺមិនបញ្ជាក់ដោយកាយ មិនបញ្ជាក់ដោយវាចា មិនបញ្ជាក់ដោយកាយនឹងវាចាទេ មិនឈ្មោះថាភិក្ខុឈឺនោះឲ្យបវារណាឡើយ ។ បើសង្ឃបានឧបការឲ្យបវារណានុ៎ះយ៉ាងនេះហើយ ការបានដូច្នុះជាការល្អ បើសង្ឃមិនបានទេ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវនាំភិក្ខុឈឺនោះដោយគ្រែឬតាំងមកកាន់ទីជាកណ្តាលសង្ឃហើយសឹមបវារណា ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកភិក្ខុអ្នកបម្រើភិក្ខុឈឺមានសេចក្តីត្រិះរិះយ៉ាងនេះថា បើយើងទាំងឡាយឲ្យភិក្ខុឈឺឃ្លាតចាកទី ការអាពាធនឹងកាន់តែចំរើនឬនឹងធ្វើកាលកិរិយា (មិនខាន) ។ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវឲ្យភិក្ខុឈឺឃ្លាតចាកទីទេ ត្រូវសង្ឃទៅបវារណាក្នុងទីនោះ មិនត្រូវសង្ឃបវារណាជាពួកឡើយ បើ

បវារេយ្យ ចេ អាបត្តិ ទុក្កដស្ស ។ បវារណាហារកោ
ចេ ភិក្ខវេ ទិន្នាយ បវារណាយ តត្ថេវ បក្កមតិ អញ្ញស្ស
ទាតព្វា បវារណា ។ បវារណាហារកោ ចេ ភិក្ខវេ ទិន្នា-
យ បវារណាយ តត្ថេវ វិព្ភមតិ ។ បេ ។ កាលំ ករោតិ
សាមណេរោ បដិជានាតិ សិក្ខំ បច្ចក្ខាតកោ បដិជានា-
តិ អន្តិមវត្ថុំ អជ្ឈាបន្នកោ បដិជានាតិ ឧម្មត្តកោ ប-
ដិជានាតិ ខិត្តចិត្តោ បដិជានាតិ វេទនដ្ដោ បដិជានាតិ
អាបត្តិយា អទស្សនេ ឧក្ខិត្តកោ បដិជានាតិ អាបត្តិយា
អប្បដិកម្មេ ឧក្ខិត្តកោ បដិជានាតិ បាបិកាយ
ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកោ បដិជានាតិ
បណ្ឌកោ បដិជានាតិ ថេយ្យសំវាសកោ បដិជានាតិ
តិត្ថិយបក្កន្តកោ បដិជានាតិ តិរច្ឆានគតោ បដិជានាតិ
មាតុឃាតកោ បដិជានាតិ បិតុឃាតកោ បដិជានាតិ
អរហន្តឃាតកោ បដិជានាតិ ភិក្ខុនីទូសកោ បដិ-
ជានាតិ សង្ឃភេទកោ បដិជានាតិ លោហិតុប្បាទកោ
បដិជានាតិ ឧភតោព្យញ្ជនកោ បដិជានាតិ អញ្ញស្ស
ទាតព្វា បវារណា ។ បវារណាហារកោ ចេ ភិក្ខវេ
ទិន្នាយ បវារណាយ អន្តរាមគ្គេ បក្កមតិ អនាហដា



បវារណា ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុឈឺឲ្យ
បវារណាហើយ បើភិក្ខុអ្នកនាំបវារណាចៀសចេញទៅក្នុងទីនោះទៅ ត្រូវ
ភិក្ខុនោះឲ្យបវារណាដល់ភិក្ខុដទៃ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុ
ឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណាសឹកក្នុងទីនោះឯង ។ បេ ។
ស្លាប់(ឬ)ប្តេជ្ញាខ្លួនជាសាមណេរ ប្តេជ្ញាខ្លួនជាអ្នកលាសិក្ខា ប្តេជ្ញាខ្លួនជា
អ្នកត្រូវអន្តិមវត្ថុ ប្តេជ្ញាខ្លួនជាមនុស្សឆ្កួត ប្តេជ្ញាខ្លួនជាអ្នកមានចិត្តរវើរវាយ
ប្តេជ្ញាខ្លួនជាអ្នកមានវេទនាគ្របសង្កត់ ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្ត
ព្រោះមិនឃើញអាបត្តិ ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្តព្រោះមិនធ្វើតប
អាបត្តិ (មិនសំដែងអាបត្តិ) ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិន
លះបង់ទិដ្ឋិអាក្រក់ ប្តេជ្ញាខ្លួនជាបណ្ឌក ប្តេជ្ញាខ្លួនជាថេយ្យសំវាសក ប្តេ-
ជ្ញាខ្លួនជាអ្នកចូលទៅកាន់ពួកតិរ្ថិយ ប្តេជ្ញាខ្លួនជាតិរច្ឆាន ប្តេជ្ញាខ្លួនជាអ្នក
សំឡាប់មាតា ប្តេជ្ញាខ្លួនជាអ្នកសំឡាប់បិតា ប្តេជ្ញាខ្លួនជាអ្នកសំឡាប់ព្រះ
អរហន្ត ប្តេជ្ញាខ្លួនជាអ្នកប្រទូស្តភិក្ខុនី ប្តេជ្ញាខ្លួនជាអ្នកបំបែកសង្ឃ ប្តេជ្ញា
ខ្លួនជាអ្នកធ្វើព្រះលោហិតឲ្យពុះពងឡើង ប្តេជ្ញាខ្លួនជាមនុស្សមានភេទពីរ
ត្រូវភិក្ខុនោះឲ្យបវារណាដល់ភិក្ខុដទៃ ។ ម្នាលភិក្ខុទាំងឡាយ កាល
ដែលភិក្ខុឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណាចៀសចេញទៅ
ក្នុងពាក់កណ្តាលផ្លូវ មិនហៅថាបាននាំបវារណាមកដល់ឡើយ ។ ម្នាល

ហោតិ បវារណា ។ បវារណាហារកោ ចេ ភិក្ខវេ ទិន្នាយ បវារណាយ អន្តរាមគ្គេ វិព្ភមតិ កាលំ ករោតិ ។ បេ ។ ឧភតោព្យញ្ជនកោ បដិជានាតិ អនាហដា ហោតិ បវារណា ។ បវារណាហារកោ ចេ ភិក្ខវេ ទិន្នាយ បវារណាយ សង្ឃប្បត្តោ បក្កមតិ អាហដា ហោតិ បវារណា ។ បវារណាហារកោ ចេ ភិក្ខវេ ទិន្នាយ បវារណាយ សង្ឃប្បត្តោ វិព្ភមតិ កាលំ ករោតិ ។ បេ ។ ឧភតោព្យញ្ជនកោ បដិជានាតិ អាហដា ហោតិ បវារណា ។ បវារណាហារកោ ចេ ភិក្ខវេ ទិន្នាយ បវារណាយ សង្ឃប្បត្តោ សុត្តោ ន អារោចេតិ អាហដា ហោតិ បវារណា បវារណាហារកស្ស អនាបត្តិ ។ បវារណាហារកោ ចេ ភិក្ខវេ ទិន្នាយ បវារណាយ សង្ឃប្បត្តោ សមាបន្នោ ន អារោចេតិ អាហដា ហោតិ បវារណា បវារណាហារកស្ស អនាបត្តិ ។ បវារណាហារកោ ចេ ភិក្ខវេ ទិន្នាយ បវារណាយ សង្ឃប្បត្តោ បមត្តោ ន អារោចេតិ



ភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណា សឹកក្នុងកណ្តាលផ្លូវទៅ (ក្តី) ស្លាប់ទៅ (ក្តី) ។ បេ ។ ប្តេជ្ញាខ្លួនជាមនុស្សមានភេទពីរ (ក្តី) មិនហៅថាបាននាំបវារណាមកដល់ទេ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណាទៅដល់សង្ឃហើយ ទើបបានចៀសចេញទៅ បវារណាឈ្មោះថាបាននាំមកដល់ហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណាទៅដល់សង្ឃហើយ ទើបបានសឹក (ក្តី) ស្លាប់ (ក្តី) ។ បេ ។ ប្តេជ្ញាខ្លួនជាមនុស្សមានភេទពីរ (ក្តី) បវារណាឈ្មោះថាបាននាំមកដល់ហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណាទៅដល់សង្ឃហើយ ដេកលក់មិនបានប្រាប់ បវារណាឈ្មោះថាបាននាំមកដល់ហើយ ភិក្ខុអ្នកនាំបវារណាមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណាទៅដល់សង្ឃហើយចូលសមាបត្តិទៅមិនបានប្រាប់ បវារណាឈ្មោះថាបាននាំមកដល់ហើយ ភិក្ខុអ្នកនាំបវារណាមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណាទៅដល់សង្ឃហើយភ្លេចមិនបានប្រាប់

អាហដា ហោតិ បវារណា បវារណាហារកស្ស អនា-
បត្តិ ។ បវារណាហារកោ ចេ ភិក្ខវេ ទិន្នាយ បវារណាយ
សង្ឃប្បត្តោ សញ្ចិច្ច ន អារោចេតិ អាហដា ហោតិ
បវារណា បវារណាហារកស្ស អាបត្តិ ទុក្កដស្ស ។
អនុជានាមិ ភិក្ខវេ តទហុប្បវារណាយ បវារណំ
ទេន្តេន ឆន្ទម្បិ ទាតុំ សន្តិ សង្ឃស្ស ករណីយន្តិ ។

(៦៦) តេន ខោ បន សមយេន អញ្ញតរំ ភិក្ខុំ
តទហុប្បវារណាយ ញាតកា គណ្ហិំសុ ។ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ ឥធ បន ភិក្ខវេ ភិក្ខុំ តទហុប្ប-
វារណាយ ញាតកា គណ្ហន្តិ ។ តេ ញាតកា ភិក្ខូ-
ហិ ឯវមស្សុ វចនីយា ឥង្ឃ អាយស្មន្តោ ឥមំ ភិក្ខុំ
មុហុត្តំ មុញ្ចថ យាវាយំ ភិក្ខុ បវារេតីតិ ។ ឯវញ្ចេតំ
លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ តេ ញាតកា
ភិក្ខូហិ ឯវមស្សុ វចនីយា ឥង្ឃ អាយស្មន្តោ
មុហុត្តំ ឯកមន្តំ ហោថ យាវាយំ ភិក្ខុ បវារណំ
ទេតីតិ ។ ឯវញ្ចេតំ លភេថ ឥច្ចេតំ កុសលំ នោ ចេ



បវារណាឈ្មោះថាបាននាំមកដល់ហើយ ភិក្ខុអ្នកនាំបវារណាមិនត្រូវអាបត្តិ
ទេ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឲ្យបវារណាហើយបើភិក្ខុអ្នកនាំ
បវារណាទៅដល់សង្ឃហើយក្លែងមិនប្រាប់ បវារណាឈ្មោះថាបាននាំមក
ដល់ហើយ (តែ) ភិក្ខុអ្នកនាំបវារណាត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំង
ឡាយ ក្នុងថ្ងៃបវារណានោះ(បើ)សង្ឃមានកិច្ចត្រូវធ្វើ តថាគតអនុញ្ញាត
ឲ្យភិក្ខុកាលដែលឲ្យបវារណាហើយត្រូវឲ្យឆន្ទៈផង ។

(៦៦) គ្រានោះឯង ពួកញាតិចាប់ភិក្ខុមួយអង្គក្នុងថ្ងៃបវារណា
នោះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។
ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះបើមាន
ពួកញាតិចាប់ភិក្ខុក្នុងថ្ងៃបវារណានោះ ។ ត្រូវភិក្ខុទាំងឡាយនិ-
យាយនឹងពួកញាតិនោះយ៉ាងនេះថា នែអ្នកដ៏មានអាយុទាំងឡាយ
សូមអ្នកទាំងឡាយលែងភិក្ខុនេះមួយភ្លែតសិន ទំរាំភិក្ខុនេះបវារណា
រួច ។ បើសង្ឃបាននូវសេចក្ដីយល់ព្រមនុ៎ះដូច្នេះហើយ ការដែលបាននុ៎ះ
ជាការល្អ បើមិនបានទេ ត្រូវភិក្ខុទាំងឡាយនិយាយនឹងពួកញាតិ
នោះយ៉ាងនេះថា នែអ្នកដ៏មានអាយុទាំងឡាយ សូមអ្នកទាំងឡាយទៅ
ក្នុងទីដ៏សមគួរមួយភ្លែតសិនទំរាំភិក្ខុនេះឲ្យបវារណារួច ។ បើសង្ឃបាន
សេចក្ដីយល់ព្រមនុ៎ះដូច្នេះហើយ ការបាននុ៎ះជាការល្អ បើមិនបានទេ

លភេថ តេ ញាតកា ភិក្ខូហិ ឯវមស្សុ វចនីយា ឥង្ឃ តុម្ហេ. អាយស្មន្តោ ឥមំ ភិក្ខុំ មុហុត្តំ និស្សីមំ នេថ យាវ សង្ឃោ បវារេតីតិ ។ ឯវញ្ចេតំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ ន ត្វេវ វគ្គេន សង្ឃេន បវារេតព្វំ បវារេយ្យ ចេ អាបត្តិ ទុក្កដស្ស ។ ឥធ បន ភិក្ខវេ ភិក្ខុំ តទហុប្បវារណាយ រាជានោ គណ្ហន្តិ ចោរា គណ្ហន្តិ ធុត្តា គណ្ហន្តិ ភិក្ខុបច្ចត្ថិកា គណ្ហន្តិ ។ តេ ភិក្ខុបច្ចត្ថិកា ភិក្ខូហិ ឯវមស្សុ វចនីយា ឥង្ឃ តុម្ហេ អាយស្មន្តោ ឥមំ ភិក្ខុំ មុហុត្តំ មុញ្ចថ យាវាយំ ភិក្ខុ បវារេតីតិ ។ ឯវញ្ចេតំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ តេ ភិក្ខុបច្ចត្ថិកា ភិក្ខូហិ ឯវមស្សុ វចនីយា ឥង្ឃ តុម្ហេ អាយស្មន្តោ មុហុត្តំ ឯកមន្តំ ហោថ យាវាយំ ភិក្ខុ បវារណំ ទេតីតិ ។ ឯវញ្ចេតំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ តេ ភិក្ខុបច្ចត្ថិកា ភិក្ខូហិ ឯវមស្សុ វចនីយា ឥង្ឃ តុម្ហេ អាយស្មន្តោ



ត្រូវភិក្ខុទាំងឡាយនិយាយនឹងពួកញាតិទាំងនោះយ៉ាងនេះថា នែអ្នកដ៏មានអាយុទាំងឡាយ សូមអ្នកទាំងឡាយនាំភិក្ខុនេះទៅកាន់ទីក្រៅសីមាមួយរំពេចសិនទំរាំតែសង្ឃបវារណារួច ។ បើសង្ឃបានសេចក្ដីយល់ព្រមនុះផ្លូវនុះហើយ ការបាននុះជាការល្អ បើមិនបានទេ មិនត្រូវសង្ឃបវារណាដោយពួកឡើយ បើបវារណា ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះបើស្ដេចទាំងឡាយចាប់ភិក្ខុ (ក្ដី) ពួកចោរចាប់ភិក្ខុ (ក្ដី) ពួកអ្នកលេងចាប់ភិក្ខុ (ក្ដី) ពួកភិក្ខុជាសត្រូវចាប់ភិក្ខុ (ក្ដី) ក្នុងថ្ងៃបវារណានោះ ។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងពួកភិក្ខុជាសត្រូវទាំងនោះយ៉ាងនេះថា នែលោកដ៏មានអាយុទាំងឡាយ សូមអស់លោកទាំងឡាយលែងភិក្ខុនេះមួយរំពេចសិន ទំរាំភិក្ខុនេះបវារណារួច ។ បើសង្ឃបានសេចក្ដីយល់ព្រមនុះផ្លូវនុះហើយ ការបាននុះជាការល្អ បើមិនបានទេ ត្រូវភិក្ខុទាំងឡាយនិយាយនឹងភិក្ខុជាសត្រូវទាំងនោះយ៉ាងនេះថា នែលោកដ៏មានអាយុទាំងឡាយ សូមលោកទាំងឡាយទៅក្នុងទីដ៏សមគួរមួយរំពេចសិន ទំរាំភិក្ខុនេះឲ្យបវារណារួច ។ បើសង្ឃបានសេចក្ដីយល់ព្រមនុះផ្លូវនុះហើយ ការបាននុះជាការល្អ បើមិនបានទេ ត្រូវភិក្ខុទាំងឡាយនិយាយនឹងពួកភិក្ខុជាសត្រូវទាំងនោះយ៉ាងនេះថា នែលោកដ៏មានអាយុទាំងឡាយ សូមអស់លោក

ឥមំ ភិក្ខុំ ឧព្ភក្កំ ចិសីមំ នេថ យាវ សង្ឃោ បវារេតីតិ ។ ឯវញ្ចេតំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ ន ច្វេវ វគ្គេន សង្ឃេន បវារេតព្វំ បវារេយ្យ ចេ អាបត្តិ ទុក្កដស្សាតិ ។

(៤៧) តេន ខោ បន សមយេន អញ្ញតរស្មឹ អាវាសេ តទហុ បវារណាយ បញ្ច ភិក្ខូ វិហរន្តិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ ភគវតា បញ្ញត្តំ សង្ឃេន បវារេតព្វន្តិ មយញ្ចម្ហា បញ្ច ជនា កថំ នុ ខោ អម្ហេហិ បវារេតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បញ្ចន្នំ សង្ឃេ បវារេតុន្តិ ។ តេន ខោ បន សមយេន អញ្ញតរស្មឹ អាវាសេ តទហុ បវារណាយ ចត្តារោ ភិក្ខូ វិហរន្តិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ ភគវតា អនុញ្ញាតំ បញ្ចន្នំ សង្ឃេ បវារេតុំ មយញ្ចម្ហា ចត្តារោ ជនា កថំ នុ ខោ អម្ហេហិ បវារេតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ចតុន្នំ អញ្ញមញ្ញំ បវារេតុំ ។



ដាក់ភិក្ខុនេះទៅកាន់ទីក្រៅសីមាមួយកែងសិន ចាំសង្ឃបវារណារួច ។ បើសង្ឃបានសេចក្ដីយល់ព្រមនុ៎ះដូច្នេះហើយ ការបាននុ៎ះជាការល្អ បើមិនបានទេ មិនត្រូវសង្ឃបវារណាដោយពួកឡើយ បើបវារណា ត្រូវអាបត្តិទុក្កដ ។

(៤៧) គង់សម័យនោះឯង ភិក្ខុ ៥ រូបនៅក្នុងអាវាសមួយក្នុងថ្ងៃបវារណានោះ ។ គ្រានោះ ភិក្ខុទាំងឡាយមានសេចក្ដីត្រិះរិះដូច្នេះថា ព្រះមានព្រះភាគទ្រង់បញ្ញត្តហើយថា ត្រូវភិក្ខុបវារណាដោយសង្ឃបវារណា ក៏ឥឡូវនេះយើងទាំងឡាយជាជន ៥ រូប តើត្រូវយើងទាំងឡាយបវារណាដូចម្ដេច ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ៥ រូបបវារណា ដោយសង្ឃបវារណា ។ សម័យនោះឯង ភិក្ខុ ៤ រូបនៅក្នុងអាវាសមួយក្នុងថ្ងៃបវារណានោះ ។ គ្រានោះ ភិក្ខុទាំងឡាយនោះមានសេចក្ដីត្រិះរិះ ដូច្នេះថា ព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុ ៥ រូបបវារណា ដោយសង្ឃបវារណា ក៏ឥឡូវនេះ យើងទាំងឡាយជាជន ៤ រូប តើត្រូវយើងទាំងឡាយបវារណាដូចម្ដេច ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ៤ រូបបវារណា

ឯវញ្ច បន ភិក្ខវេ បវារេតព្វំ ។ ព្យត្តេន ភិក្ខុនា បដិ-
ពលេន តេ ភិក្ខូ ញាបេតព្វា សុណន្តុ មេ អាយស្មន្តោ
អជ្ជ បវារណា ។ យទាយស្មន្តានំ បត្តកល្លំ មយំ
អញ្ញមញ្ញំ បវារេយ្យាមាតិ ។ ថេរេន ភិក្ខុនា ឯកំសំ
ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គ-
ហេត្វា តេ ភិក្ខូ ឯវមស្សុ វចនីយា អហំ អាវុសោ
អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ
វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ
បដិករិស្សាមិ ទុតិយម្បិ អាវុសោ អាយស្មន្តេ បវារេមិ
ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អា-
យស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ
តតិយម្បិ អាវុសោ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន
វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ
ឧបាទាយ បស្សន្តោ បដិករិស្សាមីតិ ។ នវកេន
ភិក្ខុនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិ-
ត្វា អញ្ជលឹ បគ្គហេត្វា តេ ភិក្ខូ ឯវមស្សុ វចនីយា



ដល់គ្នានឹងគ្នាបាន ។ ម្នាលភិក្ខុទាំងឡាយ ត្រូវបវារណាយ៉ាងនេះ ។
ត្រូវភិក្ខុដែលឈ្លាសប្រតិពលឲ្យភិក្ខុទាំងឡាយនោះយល់ថា សូមលោក
ដ៏មានអាយុទាំងឡាយស្តាប់ខ្ញុំ ថ្ងៃនេះជាថ្ងៃបវារណា ។ បើបវារណា-
កម្មមានកាលគួរដល់លោកដ៏មានអាយុទាំងឡាយហើយ ត្រូវយើងទាំង
ឡាយបវារណាដល់គ្នានឹងគ្នា ។ ត្រូវភិក្ខុជាថេរៈធ្វើឧត្តរាសង្គៈឆៀងស្មា
ម្ខាងអង្គុយច្រហោងហើយផ្គងអញ្ជលីទៀងនិយាយនឹងភិក្ខុទាំងឡាយ
នោះយ៉ាងនេះថា នែអាវុសោ ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុទាំង
ឡាយ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយ
អាស្រ័យនូវសេចក្តីអនុគ្រោះនិយាយ (រំលឹក) ខ្ញុំ កាលបើខ្ញុំឃើញនឹង
ធ្វើតាម នែអាវុសោ ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុទាំងឡាយ
ជាគំរប់ពីរដងដែរ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុ
ទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះនិយាយ (ដាស់តឿន) ខ្ញុំ កាល
បើខ្ញុំឃើញនឹងធ្វើតាម នែអាវុសោ ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុ
ទាំងឡាយជាគំរប់បីដងដែរ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោក
ដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះនិយាយ (រំលឹក) ខ្ញុំ
កាលបើខ្ញុំឃើញនឹងធ្វើតាម ។ ត្រូវភិក្ខុថ្មីធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាងអង្គុយ
ច្រហោងផ្គងអញ្ជលីទៀងនិយាយនឹងភិក្ខុទាំងឡាយនោះថា

អហំ ភន្តេ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ទុតិយម្បិ ភន្តេ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ តតិយម្បិ ភន្តេ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមីតិ ។ តេន ខោ បន សមយេន អញ្ញតរស្មឹ អាវាសេ តទហុបវារណាយ តយោ ភិក្ខូ វិហរន្តិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ ភគវតា អនុញ្ញាតំ បញ្ចន្នំ សង្ឃេ បវារេតុំ ចតុន្នំ អញ្ញមញ្ញំ បវារេតុំ មយញ្ចម្ហា តយោ ជនា កថំ នុ ខោ អម្ហេហិ បវារេតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តិណ្ណន្នំ អញ្ញមញ្ញំ បវារេតុំ ។ ឯវញ្ច បន ភិក្ខវេ



បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុទាំងឡាយ ដោយឃើញក្ដីឮក្ដីរង្កៀសក្ដី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្ដីអនុគ្រោះនិយាយ (ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុទាំងឡាយជាគំរប់ពីរដងផង ដោយឃើញក្ដីឮក្ដីរង្កៀសក្ដី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្ដីអនុគ្រោះនិយាយ (ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុទាំងឡាយជាគំរប់បីដងផង ដោយឃើញក្ដីឮក្ដីរង្កៀសក្ដី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្ដីអនុគ្រោះនិយាយ (ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម ។ ក៏សម័យនោះឯង ភិក្ខុ ៣ រូបនៅក្នុងអាវាសមួយក្នុងថ្ងៃបវារណានោះ ។ គ្រានោះ ភិក្ខុទាំងឡាយនោះមានសេចក្ដីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុ ៥ រូបបវារណាដោយសង្ឃបវារណា ឲ្យភិក្ខុ ៤ រូបបវារណាដល់គ្នានឹងគ្នា ចុះឥឡូវនេះ យើងទាំងឡាយជា ៣ រូប តើយើងទាំងឡាយត្រូវបវារណាដូចម្ដេច ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ៣ រូបបវារណាដល់គ្នានឹងគ្នាបាន ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយ

បវារេតព្វំ ។ ព្យត្តេន ភិក្ខុនា បដិពលេន តេ ភិក្ខូ ញា-
បេតព្វា សុណន្តុ មេ អាយស្មន្តោ អជ្ជ បវារណា ។ យ-
ទាយស្មន្តានំ បត្តកល្លំ មយំ អញ្ញមញ្ញំ បវារេយ្យាមា-
តិ ។ ថេរេន ភិក្ខុនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ
និសីទិត្វា អញ្ជលឹ បគ្គហេត្វា តេ ភិក្ខូ ឯវមស្សុ វចនីយា
អហំ អាវុសោ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា
បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ
បស្សន្តោ បដិករិស្សាមិ ទុតិយម្បិ អាវុសោ អាយស្មន្តេ
បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អា-
យស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សា-
មិ តតិយម្បិ អាវុសោ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា
សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុ-
កម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមីតិ ។ នវកេន
ភិក្ខុនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសី-
ទិត្វា អញ្ជលឹ បគ្គហេត្វា តេ ភិក្ខូ ឯវមស្សុ វចនីយា
អហំ ភន្តេ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន



បវារណាយ៉ាងនេះ ។ ត្រូវភិក្ខុដែលឆ្លាសប្រតិភាពឲ្យភិក្ខុទាំងឡាយ
នោះដឹងថា សូមលោកដ៏មានអាយុទាំងឡាយស្ដាប់ខ្ញុំ ថ្ងៃនេះជាថ្ងៃបវារ-
ណា ។ បើបវារណាកម្មមានកាលគួរដល់លោកដ៏មានអាយុទាំងឡាយ
ហើយ ត្រូវយើងទាំងឡាយបវារណាដល់គ្នានឹងគ្នា ។ ត្រូវភិក្ខុជាថេរៈ
ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាងហើយ អង្គុយច្រហោង ផ្គងអញ្ជលីឡើងហើយ
និយាយនឹងភិក្ខុទាំងឡាយនោះយ៉ាងនេះថា នែអាវុសោ ខ្ញុំសូមបវារណា
នឹងលោកដ៏មានអាយុទាំងឡាយ ដោយឃើញក្ដី ឮក្ដី រង្កៀសក្ដី សូម
លោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្ដីអនុគ្រោះនិយាយ (ដាស់
តឿន) ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម ។ នែអាវុសោ ខ្ញុំសូមបវារណានឹង
លោកដ៏មានអាយុទាំងឡាយជាគំរប់ពីរដងដែរ ដោយឃើញក្ដីឮក្ដីរង្កៀស
ក្ដី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្ដីអនុគ្រោះនិយាយ
(ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម ។ នែអាវុសោ ខ្ញុំសូមបវារ-
ណានឹងលោកដ៏មានអាយុទាំងឡាយជាគំរប់បីដងដែរ ដោយឃើញក្ដី ឮក្ដី
រង្កៀសក្ដី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្ដីអនុគ្រោះ
និយាយ (ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម ។ ត្រូវភិក្ខុដែលថ្មី
ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាងហើយអង្គុយច្រហោងផ្គងអញ្ជលីឡើងហើយនិយាយ
យ៉ាងនេះនឹងភិក្ខុទាំងឡាយនោះ បពិត្រលោកដ៏ចំរើន ខ្ញុំសូម
បវារណានឹងលោកដ៏មានអាយុទាំងឡាយដោយឃើញក្ដីឮក្ដីរង្កៀសក្ដី

វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ទុតិយម្បិ ភន្តេ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ តតិយម្បិ ភន្តេ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមីតិ ។ តេន ខោ បន សមយេន អញ្ញតរស្មឹ អាវាសេ តទហុ បវារណាយ ទ្វេ ភិក្ខូ វិហរន្តិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ ភគវតា អនុញ្ញាតំ បញ្ចន្នំ សង្ឃេន បវារេតុំ ចតុន្នំ អញ្ញមញ្ញំ បវារេតុំ តិណ្ណន្នំ អញ្ញមញ្ញំ បវារេតុំ មយញ្ចម្ហ ទ្វេ ជនា កថំ នុ ខោ អម្ហេហិ បវារេតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ទ្វិន្នំ អញ្ញមញ្ញំ បវារេតុំ ។ ឯវញ្ច បន ភិក្ខវេ បវារេតព្វំ ។ ថេរេន ភិក្ខុនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា នវោ



សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះនិយាយ (ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុទាំងឡាយ ជាគំរប់ពីរដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះនិយាយ (ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុទាំងឡាយ ជាគំរប់បីដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះនិយាយ (ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម ។ ក៏សម័យនោះឯង ភិក្ខុពីររូបនៅក្នុងអាវាសមួយ ក្នុងថ្ងៃបវារណានោះ ។ គ្រានោះ ភិក្ខុទាំងឡាយនោះមានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យភិក្ខុ ៥ រូប បវារណាដោយសង្ឃបវារណា ឲ្យភិក្ខុ ៤ រូប បវារណាដល់គ្នានឹងគ្នា ឲ្យភិក្ខុ ៣ រូប បវារណាដល់គ្នានឹងគ្នា ឥឡូវនេះ យើងទាំងឡាយជាផងពីររូប តើយើងត្រូវបវារណាដូចម្តេច ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុពីររូបបវារណាដល់គ្នានឹងគ្នាបាន ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុបវារណាយ៉ាងនេះ ។ ត្រូវភិក្ខុជាថេរៈធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាងហើយអង្គុយច្រហោងផ្គងអញ្ជលីហើយត្រូវនិយាយ

## បវារណាកម្មៈ ទីគ អត្ថុទ្ធាប្បវារណា

ភិក្ខុ ថេរស្ស វចនីយោ អហំ អាវុសោ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទតុ មំ អាយស្មា អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ទុតិយម្បិ អាវុសោ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទតុ មំ អាយស្មា អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ តតិយម្បិ អាវុសោ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទតុ មំ អាយស្មា អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមីតិ ។ នវកេន ភិក្ខុនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ថេរោ ភិក្ខុ ថេរស្ស វចនីយោ អហំ ភន្តេ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទតុ មំ អាយស្មា អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ទុតិយម្បិ ភន្តេ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទតុ មំ អាយស្មា អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ តតិយម្បិ ភន្តេ អាយស្មន្តំ បវារេមិ



## បវារណាកម្មៈ ភិក្ខុធំប្រាប់បវារណាចំពោះភិក្ខុតូច

ព្រះថេរគប្បីភិក្ខុថា ម្នាលអាវុសោ ខ្ញុំសូមបវារណាចំពោះលោកដ៏មានអាយុ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុអាស្រ័យនូវសេចក្តីអនុគ្រោះនិយាយ (ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម ម្នាលអាវុសោ ខ្ញុំសូមបវារណាចំពោះលោកដ៏មានអាយុជាគំរប់ពីរដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុអាស្រ័យនូវសេចក្តីអនុគ្រោះនិយាយ (ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម ម្នាលអាវុសោ ខ្ញុំសូមបវារណាចំពោះលោកដ៏មានអាយុ ជាគំរប់បីដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុអាស្រ័យនូវសេចក្តីអនុគ្រោះនិយាយ (ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម ។ ត្រូវភិក្ខុថ្មីធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាងហើយ អង្គុយច្រហោងផ្គងអញ្ជលី ទើបនិយាយយ៉ាងនេះនឹងភិក្ខុជាថេរៈថា បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណាចំពោះលោកដ៏មានអាយុដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុអាស្រ័យនូវសេចក្តីអនុគ្រោះនិយាយ (ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណាចំពោះលោកដ៏មានអាយុ ជាគំរប់ពីរដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុអាស្រ័យនូវសេចក្តីអនុគ្រោះនិយាយ (ដាស់តឿន) ខ្ញុំកាលបើខ្ញុំឃើញនឹងធ្វើតាម បពិត្រលោកដ៏ចំរើនខ្ញុំសូមបវារណាចំពោះលោកដ៏មានអាយុ ជាគំរប់បីដងផង ដោយឃើញក្តីឮក្តីរង្កៀសក្តី

ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ
អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមីតិ ។ តេន
ខោ បន សមយេន អញ្ញតរស្មឹ អាវាសេ តទហុ បវារ-
ណាយ ឯកោ ភិក្ខុ វិហរតិ ។ អថខោ តស្ស ភិក្ខុនោ
ឯតទហោសិ ភគវតា អនុញ្ញាតំ បញ្ចន្នំ សង្ឃេ បវារេតុំ
ចតុន្នំ អញ្ញមញ្ញំ បវារេតុំ តិណ្ណន្នំ អញ្ញមញ្ញំ បវារេតុំ ទ្វិន្នំ
អញ្ញមញ្ញំ បវារេតុំ អហញ្ចម្ហិ ឯកកោ កថំ នុ ខោ
មយា បវារេតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។
ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុ បវារណា-
យ ឯកោ ភិក្ខុ វិហរតិ ។ តេន ភិក្ខវេ ភិក្ខុនា យត្ថ
ភិក្ខូ បដិក្កមន្តិ ឧបដ្ឋានសាលាយ វា មណ្ឌបេ វា
រុក្ខមូលេ វា សោ ទេសោ សម្មជ្ជិត្វា បានីយំ បរិភោ-
ជនីយំ ឧបដ្ឋាបេត្វា អាសនំ បញ្ញាបេត្វា បទីបំ កត្វា
និសីទិតព្វំ ។ សចេ អញ្ញេ ភិក្ខូ អាគច្ឆន្តិ តេហិ សទ្ធឹ
បវារេតព្វំ ។ នោ ចេ អាគច្ឆន្តិ អជ្ជ មេ បវារណាតិ អធិដ្ឋា-
តព្វំ ។ នោ ចេ អធិដ្ឋហេយ្យ អាបត្តិ ទុក្កដស្ស ។ តត្រ
ភិក្ខវេ យត្ថ បញ្ច ភិក្ខូ វិហរន្តិ ន ឯកស្ស បវារណំ



សូមលោកដ៏មានអាយុអាស្រ័យនូវសេចក្តីអនុគ្រោះនិយាយ (ដាស់តឿន)
ខ្ញុំ កាលបើខ្ញុំឃើញនឹងធ្វើតាម ។ ក៏សម័យនោះឯង ភិក្ខុមួយរូបនៅក្នុង
អាវាសមួយក្នុងថ្ងៃបវារណានោះ ។ ឯភិក្ខុនោះក៏មានសេចក្តីត្រិះរិះដូច្នេះថា
ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុ៥រូបបវារណាដោយសង្ឃបវារណា
ឲ្យភិក្ខុ៤រូបបវារណាដល់គ្នានឹងគ្នា ឲ្យភិក្ខុ៣រូបបវារណាដល់គ្នានឹងគ្នា
ឲ្យភិក្ខុពីររូបបវារណាដល់គ្នានឹងគ្នា ចំណែកអាត្មាអញនៅតែម្នាក់ឯង គួរ
អាត្មាអញបវារណាដូចម្តេចហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំ-
ពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ
ក៏ក្នុងសាសនានេះ ភិក្ខុមួយរូបនៅក្នុងអាវាសមួយ ក្នុងថ្ងៃបវារណានោះ ។
ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុចៀសចេញទៅអំពីប្រទេសណា គឺឧបដ្ឋាន-
សាលា(១)ក្តី មណ្ឌបក្តី គល់ឈើក្តី ត្រូវភិក្ខុនោះបោសប្រទេសនោះហើយដំ-
កល់ទុកនូវទឹកឆាន់ទឹកប្រើប្រាស់ ត្រូវក្រាលអាសនៈ ធ្វើប្រទីបហើយត្រូវ
គង់នៅ ។ បើមានភិក្ខុទាំងឡាយដទៃមក ត្រូវភិក្ខុនោះបវារណាជាមួយ
នឹងភិក្ខុទាំងឡាយនោះចុះ បើគ្មានភិក្ខុទាំងឡាយមកទេ ត្រូវភិក្ខុនោះ
អធិដ្ឋានថាថ្ងៃនេះជាថ្ងៃបវារណារបស់អញ បើមិនអធិដ្ឋានទេ ត្រូវអាបត្តិ
ទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសណា ១ ដែលមានភិក្ខុនៅ៥រូប
ភិក្ខុ៤រូប មិនត្រូវនាំបវារណារបស់ភិក្ខុ១រូបហើយបវារណាដោយសង្ឃប-

១ សាលាធំ ។

អាហរិត្វា ចតូហិ សង្ឃេន បវារេតព្វំ បវារេយ្យុំ ចេ អាបត្តិ ទុក្កដស្ស ។ តត្រ ភិក្ខវេ យត្ថ ចត្តារោ ភិក្ខូ វិហរន្តិ ន ឯកស្ស បវារណំ អាហរិត្វា តីហិ អញ្ញមញ្ញំ បវារេតព្វំ បវារេយ្យុំ ចេ អាបត្តិ ទុក្កដស្ស ។ តត្រ ភិក្ខវេ យត្ថ តយោ ភិក្ខូ វិហរន្តិ ន ឯកស្ស បវារណំ អាហរិត្វា ទ្វីហិ អញ្ញមញ្ញំ បវារេតព្វំ បវារេយ្យុំ ចេ អាបត្តិ ទុក្កដស្ស ។ តត្រ ភិក្ខវេ យត្ថ ទ្វេ ភិក្ខូ វិហរន្តិ ន ឯកស្ស បវារណំ អាហរិត្វា ឯកេន អធិដ្ឋាតព្វំ អធិដ្ឋហេយ្យ ចេ អាបត្តិ ទុក្កដស្សាតិ ។

(៦៨) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ តទហុ បវារណាយ អាបត្តឹ អាបន្នោ ហោតិ ។ អថ ខោ តស្ស ភិក្ខុនោ ឯតទហោសិ ភគវតា បញ្ញត្តំ ន សាបត្តិកេន បវារេតព្វន្តិ អហញ្ចម្ហិ អាបត្តឹ អាបន្នោ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ឥធ បន ភិក្ខវេ ភិក្ខុ តទហុ បវារណាយ អាបត្តឹ អាបន្នោ ហោតិ ។ តេន ភិក្ខវេ ភិក្ខុនា ឯកំ ភិក្ខុំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ





បវារណាក្នុងអាវាសនោះទេ បើបវារណា ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសណា ១ ដែលមានភិក្ខុនៅ ៤ រូប ភិក្ខុ ៣ រូប មិនត្រូវនាំបវារណារបស់ភិក្ខុ ១ រូបមក ហើយបវារណាដល់គ្នានឹងគ្នាក្នុងអាវាសនោះទេ បើបវារណា ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសណា ១ ដែលមានភិក្ខុនៅ ៣ រូប ភិក្ខុ ២ រូប មិនត្រូវនាំបវារណារបស់ភិក្ខុ ១ រូបមក ហើយបវារណាដល់គ្នានឹងគ្នាក្នុងអាវាសនោះទេ បើបវារណា ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសណា ១ ដែលមានភិក្ខុនៅ ២ រូប ភិក្ខុ ១ រូប មិនត្រូវនាំបវារណារបស់ភិក្ខុ ១ រូបមក ហើយអធិដ្ឋានក្នុងអាវាសនោះទេ ។ បើអធិដ្ឋាន ត្រូវអាបត្តិទុក្កដ ។

(៦៨) គ្រាសម័យនោះឯង ភិក្ខុ ១ រូប ត្រូវអាបត្តិក្នុងថ្ងៃបវារណានោះ ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយថា ភិក្ខុដែលមានអាបត្តិមិនត្រូវបវារណាទេ ចំណែកខ្លួនអាត្មាអញត្រូវអាបត្តិហើយ តើអាត្មាអញត្រូវប្រតិបត្តិដូចម្តេចហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុត្រូវអាបត្តិក្នុងថ្ងៃបវារណានោះ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះចូលទៅរកភិក្ខុ ១ រូប ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង អង្គុយច្រហោងផ្គងអញ្ជលីប្រណម្យ ពោលយ៉ាងនេះ

កំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ អាវុសោ ឥត្ថន្នាមំ អាបត្តឹ អាបន្នោ តំ បដិទេសេមីតិ ។ តេន វត្តព្វោ បស្សសីតិ ។ អាម បស្សាមីតិ ។ អាយតឹ សំវរេយ្យាសីតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ តទហុប្បវារណាយ អាបត្តិយា វេមតិកោ ហោតិ ។ តេន ភិក្ខវេ ភិក្ខុនា ឯកំ ភិក្ខុំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ អាវុសោ ឥត្ថន្នាមាយ អាបត្តិយា វេមតិកោ យទា និព្វេមតិកោ ភវិស្សាមិ តទា តំ អាបត្តឹ បដិករិស្សាមីតិ វត្វា បវារេតព្វំ ។ ន ត្វេវ តប្បច្ចយា បវារណាយ អន្តរាយោ កាតព្វោតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ បវារយមានោ អាបត្តឹ សរតិ ។ អថខោ តស្ស ភិក្ខុនោ ឯតទហោសិ ភគវតា បញ្ញត្តំ ន សាបត្តិកេន បវារេតព្វន្តិ អហញ្ចម្ហិ អាបត្តឹ អាបន្នោ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។



នឹងភិក្ខុនោះថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិឈ្មោះនេះហើយ ខ្ញុំសូមសំដែងអាបត្តិនោះចេញ ។ ត្រូវភិក្ខុអ្នកទទួលអាបត្តិនោះនិយាយថា លោកឃើញឬទេ ។ ភិក្ខុអ្នកសំដែងនោះឆ្លើយថា អើខ្ញុំឃើញ ។ ភិក្ខុអ្នកទទួលអាបត្តិត្រូវប្រាប់ថា ត្រូវលោកសង្រួមតទៅ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុសង្ស័យនឹងអាបត្តិក្នុងថ្ងៃបវារណានោះ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះចូលទៅរកភិក្ខុ ១ រូប ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង អង្គុយច្រហោងផ្គងអញ្ជលីហើយនិយាយយ៉ាងនេះនឹងភិក្ខុនោះថា ម្នាលអាវុសោ ខ្ញុំមានសេចក្ដីសង្ស័យនឹងអាបត្តិឈ្មោះនេះ កាលណាខ្ញុំអស់សេចក្ដីសង្ស័យខ្ញុំនឹងធ្វើតប ( សំដែង ) នូវអាបត្តិនោះក្នុងកាលនោះ លុះពោលដូច្នេះហើយ ត្រូវបវារណាចុះ ។ មិនត្រូវភិក្ខុធ្វើនូវសេចក្ដីអន្តរាយដល់បវារណា ព្រោះហេតុប៉ុណ្ណោះទេ ។ ក៏សម័យនោះឯង ភិក្ខុ ១ រូបកំពុងតែបវារណា ក៏រលឹកឃើញអាបត្តិ ។ ទើបភិក្ខុនោះមានសេចក្ដីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយថា ភិក្ខុដែលមានអាបត្តិមិនត្រូវបវារណាទេ ឥឡូវអាត្មាអញត្រូវអាបត្តិហើយ តើអាត្មាអញត្រូវប្រតិបត្តិដូចម្ដេចហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះ

ឥធ បន ភិក្ខវេ ភិក្ខុ បវារយមានោ អាបត្តិំ សរតិ ។ តេន ភិក្ខវេ ភិក្ខុនា សាមន្តោ ភិក្ខុ ឯវមស្ស វចនីយោ អហំ អាវុសោ ឥត្ថន្នាមំ អាបត្តិំ អាបន្នោ ឥតោ វុដ្ឋហិត្វា តំ អាបត្តិំ បដិករិស្សាមីតិ វត្វា បវារេតព្វំ ។ ន ត្វេវ តប្បច្ចយា បវារណាយ អន្តរាយោ កាតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុ បវារយមានោ អាបត្តិយា វេមតិកោ ហោតិ ។ តេន ភិក្ខវេ ភិក្ខុនា សាមន្តោ ភិក្ខុ ឯវមស្ស វចនីយោ អហំ អាវុសោ ឥត្ថន្នាមាយ អាបត្តិយា វេមតិកោ យទា និព្វេមតិកោ ភវិស្សាមិ តទា តំ អាបត្តិំ បដិករិស្សាមីតិ វត្វា បវារេតព្វំ ។ ន ត្វេវ តប្បច្ចយា បវារណាយ អន្តរាយោ កាតព្វោតិ ។ តេន ខោ បន សមយេន អញ្ញតរស្មឹ អាវាសេ តទហុបវារណាយ សព្វោ សង្ឃោ សភាគំ អាបត្តិំ អាបន្នោ ហោតិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ ភគវតា បញ្ញត្តំ ន សភាគា អាបត្តិ ទេសេតព្វា ន សភាគា អាបត្តិ បដិគ្គហេតព្វាតិ អយញ្ច សព្វោ សង្ឃោ សភាគំ អាបត្តិំ អាបន្នោ





ចំពោះព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុកំពុងតែបវារណា ក៏រលឹកឃើញអាបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះនិយាយយ៉ាងនេះនឹងភិក្ខុជិតខាងថា នែអាវុសោ ខ្ញុំត្រូវអាបត្តិឈ្មោះនេះហើយ ខ្ញុំចេញពីទីនេះហើយនឹងសំដែងអាបត្តិនោះចេញ លុះពោលដូច្នេះហើយត្រូវបវារណាចុះ ។ មិនត្រូវភិក្ខុធ្វើនូវសេចក្តីអន្តរាយដល់បវារណា ព្រោះហេតុប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុកំពុងតែបវារណា ហើយមានសេចក្តីសង្ស័យនឹងអាបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះនិយាយយ៉ាងនេះនឹងភិក្ខុជិតខាងថា នែអាវុសោ ខ្ញុំមានសេចក្តីសង្ស័យនឹងអាបត្តិឈ្មោះនេះ កាលណាខ្ញុំអស់សេចក្តីសង្ស័យ ខ្ញុំនឹងសំដែងអាបត្តិនោះចេញក្នុងកាលនោះ លុះពោលដូច្នេះហើយ ត្រូវបវារណាចុះ ។ មិនត្រូវភិក្ខុធ្វើសេចក្តីអន្តរាយដល់បវារណា ព្រោះហេតុប៉ុណ្ណោះទេ ។ ក៏សម័យនោះឯង សង្ឃទាំងអស់ក្នុងអាវាស១ ត្រូវសភាគាបត្តិ (អាបត្តិដូចគ្នា) ក្នុងថ្ងៃបវារណានោះ ។ ភិក្ខុទាំងឡាយនោះមានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយថា ភិក្ខុមិនត្រូវសំដែងសភាគាបត្តិ មិនត្រូវទទួលសភាគាបត្តិ (នឹងគ្នាទេ) ឯសង្ឃនេះសុទ្ធតែត្រូវសភាគាបត្តិហើយ

កថំ នុ ខោ អម្ហេហិ បដិបជ្ជិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុប្បវារណាយ សព្វោ សង្ឃោ សភាគំ អាបត្តឹ អាបន្នោ ហោតិ ។ តេហិ ភិក្ខវេ ភិក្ខូហិ ឯកោ ភិក្ខុ សាមន្តា អាវាសា សជ្ជុកំ បាហេតព្វោ គច្ឆាវុសោ តំ អាបត្តឹ បដិករិត្វា អាគច្ឆ មយំ តេ សន្តិកេ តំ អាបត្តឹ បដិករិស្សាមាតិ ។ ឯវញ្ចេតំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ សព្វោ សង្ឃោ សភាគំ អាបត្តឹ អាបន្នោ យទា អញ្ញំ ភិក្ខុំ សុទ្ធំ អនាបត្តិកំ បស្សិស្សតិ តទា តស្ស សន្តិកេ តំ អាបត្តឹ បដិករិស្សតីតិ វត្វា បវារេតព្វំ ។ ន ត្វេវ តប្បច្ចយា បវារណាយ អន្តរាយោ កាតព្វោ ។ ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុប្បវារណាយ សព្វោ សង្ឃោ សភាគាយ អាបត្តិយា វេមតិកោ ហោតិ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ



តើយើងទាំងឡាយត្រូវប្រតិបត្តិដូចម្តេចហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសនានេះ បើសង្ឃទាំងអស់គ្នាក្នុងកាលមួយត្រូវសភាគាបត្តិក្នុងថ្ងៃបវារណានោះ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះបញ្ជូនភិក្ខុ ១ រូបទៅកាន់អាវាសជិតខាងក្នុងថ្ងៃនោះថា ម្នាលអាវុសោ ចូរលោកទៅសំដែងអាបត្តិនោះហើយមកវិញ យើងទាំងឡាយនឹងសំដែងអាបត្តិនោះក្នុងសំណាក់លោក ។ បើសង្ឃបានការសំដែងអាបត្តិនុ៎ះដូច្នេះហើយ ការបាននុ៎ះជាការល្អ បើមិនបានទេ ត្រូវភិក្ខុដែលឆ្លាសប្រតិពលឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ផ្សង) សង្ឃទាំងអស់នេះត្រូវសភាគាបត្តិហើយ កាលណាបើសង្ឃឃើញភិក្ខុដទៃបរិសុទ្ធមិនមានអាបត្តិ សង្ឃនឹងសំដែងអាបត្តិនោះក្នុងសំណាក់ភិក្ខុនោះកាលនោះ លុះពោលដូច្នេះហើយ ត្រូវបវារណាចុះ ។ មិនត្រូវសង្ឃធ្វើសេចក្តីអន្តរាយដល់បវារណា ព្រោះហេតុប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសនានេះ បើសង្ឃទាំងអស់គ្នាក្នុងកាលមួយមានសេចក្តីសង្ស័យចំពោះសភាគាបត្តិក្នុងថ្ងៃបវារណានោះ ត្រូវភិក្ខុដែលឆ្លាសប្រតិពលឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃទាំងអស់

មេ គាថា សមុដ្ឋានា អយំ សព្វា សមុដ្ឋានា សកាកាយ អាបត្តិយោ វេទិតព្វា យថា បុគ្គលិកោ ភិក្ខុ ឥធ តំ អាបត្តិ បដិការិស្សតីតិ វុត្តា បករណេ ។ ឆ ទ្វេ គម្ពីរោ បករណេ អន្តរាយោ តានញ្ញាតិ ។

បឋមកណ្ឌំ និដ្ឋិតំ ។

(៤៩) គេន ទោ បន សមយេន អញ្ញាតរស្ស ភាភិស គហបតិករោ សន្តិកាយ ភាភិសិតា ភិក្ខុ សន្តិ-បតិសុ បញ្ចំ មគ្គិតោ ។ គេ ឧ ជាតិសុ អព្ភញ្ញ ភាភិសិតា ភិក្ខុ អយាគតាតិ ។ គេ ជម្មស្សញ្ញោ វិន-យស្សញ្ញោ វុត្តា សមត្តស្សញ្ញោ បករសុំ ។ គេហិ ប-ភាយមានេ អជេញ្ញ ភាភិសិតា ភិក្ខុ អាគន្តុសុ តហុត-ក ។ គគនោ បរមត្ថំ អាបេបេសុំ ។ វត បន ភិក្ខវេ អញ្ញតរស្មិំ ភាភិសេ គហបតិករណេយ សន្តិកេណ ភាភិសិតា ភិក្ខុ សន្តិបតិខ្ញុំ បញ្ចំ មគ្គិតោ ។ គេ ធ ជាតិខ្លួ អព្ភញ្ញ ភាភិសិតា ភិក្ខុ អយាគតាតិ ។ គេ ជម្មស្សញ្ញោ វិនយស្សញ្ញោ វុត្តា សមត្តស្សញ្ញោ





ទេសនានូវសេចក្តីសន្និដ្ឋានទាំងសាមាបត្តិ កាលណាសន្និសិទ្ធិសេចក្តី សង្ស័យ សន្និដ្ឋានដែលបានបត្តិតោះបេញ កាលនោះ ល្អះពោលថ្មួន ហើយ ត្រូវបករណ៍ពុះ ។ មិនត្រូវសន្និដ្ឋានដែលសេចក្តីអន្តរាយដល់បករណ ត្រូវនេះហាក្តីប្រណ្ណេះទេ ។

ចប់ បឋមភាណវារៈ ។

(៤៩) កំណត់ យាះនោះឯង ពួកតាក់សុំកក្ខិក្ខុ (អ្នកនៅត្រីភាគសេ) ជាច្រើនប្រមាណ ៥ រូប ចុះទៅដល់ប្រទេសដទៃ ប្រជុំគ្នាក្នុងកាក់សមួយក្នុងថ្ងៃ បករណនោះ ។ ភិក្ខុទាំងនោះមិនដឹងថាមានពួកតាក់សុំកក្ខិក្ខុឯទៀត មិនបានមកដល់ ។ ភិក្ខុទាំងឡាយនោះសំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថាព្រមព្រៀងគ្នាហើយបករណ ។ កាល ដែលភិក្ខុទាំងឡាយនោះកំពុងបករណ ស្រាប់តែមានពួកតាក់សុំកក្ខិក្ខុឯ-ទៀតច្រើនជាងមកដល់ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះ ព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសនេះ បើក្នុងកាក់សមួយមានពួកតាក់សុំកក្ខិក្ខុជាច្រើន គឺ ៥ រូប ចុះទៅដល់ប្រទេសដទៃ ប្រជុំគ្នាក្នុងថ្ងៃបករណនោះ ។ ភិក្ខុទាំងនោះមិនដឹង ថាមានពួកតាក់សុំកក្ខិក្ខុឯទៀតមិនបានមកដល់ ។ ភិក្ខុទាំងឡាយនោះសំ-គាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថាព្រមព្រៀង

បវារេន្តិ ។ តេហិ បវារិយមានេ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ពហុតរា ។ តេហិ ភិក្ខវេ ភិក្ខូហិ បុន បវារេតព្វំ បវារិតានំ អនាបត្តិ ។ ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុប្បវារណាយ សម្ពហុលា អាវាសិកា ភិក្ខូ សន្និបតន្តិ បញ្ច វា អតិរេកា វា ។ តេ ន ជានន្តិ អត្ថញ្ញេ អាវាសិកា ភិក្ខូ អនាគតាតិ ។ តេ ធម្មសញ្ញិនោ វិនយសញ្ញិនោ វគ្គា សមគ្គសញ្ញិនោ បវារេន្តិ ។ តេហិ បវារិយមានេ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ សមសមា ។ បវារិតា សុប្បវារិតា អវសេសេហិ បវារេតព្វំ បវារិតានំ អនាបត្តិ ។ ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុប្បវារណាយ សម្ពហុលា អាវាសិកា ភិក្ខូ សន្និបតន្តិ បញ្ច វា អតិរេកា វា ។ តេ ន ជានន្តិ អត្ថញ្ញេ អាវាសិកា ភិក្ខូ អនាគតាតិ ។ តេ ធម្មសញ្ញិនោ វិនយសញ្ញិនោ វគ្គា សមគ្គសញ្ញិនោ បវារេន្តិ ។ តេហិ បវារិយមានេ





ហើយក៏ចាំតាមបវារណា ។ កាលដែលភិក្ខុទាំងនោះកំពុងបវារណា ស្រាប់តែមានពួកអាវាសិកភិក្ខុឯទៀតច្រើនជាងមកដល់ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះបវារណាម្តងទៀត ភិក្ខុទាំងឡាយដែលបវារណាហើយមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយមានពួកអាវាសិកភិក្ខុជាច្រើន គឺ៥រូបឬជាង៥រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ ។ ភិក្ខុទាំងនោះមិនដឹងថាមានពួកអាវាសិកភិក្ខុឯទៀត មិនទាន់មកដល់ ។ ភិក្ខុទាំងនោះសំគាល់ថាជាធម៌សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថាព្រមព្រៀងក៏ចាំតាមបវារណាទៅ ។ កាលដែលភិក្ខុទាំងនោះកំពុងបវារណា ស្រាប់តែមានពួកអាវាសិកភិក្ខុឯទៀតស្មើៗគ្នាមកដល់ ។ ភិក្ខុទាំងឡាយដែលបវារណាហើយក៏ឈ្មោះថាបានបវារណាល្អហើយ ត្រូវតែភិក្ខុទាំងឡាយដែលនៅសល់អំពីនោះបវារណា ពួកភិក្ខុដែលបានបវារណាហើយមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយមានពួកអាវាសិកភិក្ខុជាច្រើន គឺ៥រូបឬជាង៥រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ ។ ភិក្ខុទាំងនោះមិនដឹងថាមានពួកអាវាសិកភិក្ខុឯទៀតមិនទាន់មកដល់ ។ ភិក្ខុទាំងនោះសំគាល់ថាជាធម៌សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថាព្រមព្រៀងហើយក៏បវារណាទៅ ។ កាលដែលភិក្ខុទាំងនោះកំពុងបវារណា

អញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ពហុតរា ។ បវារិតា សុប្បវារិតា អវសេសេហិ បវារេតព្វំ បវារិតានំ អនាបត្តិ ។ ៨៤ ២៤ ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុប្បវារណាយ សម្ពហុលា អាវាសិកា ភិក្ខូ សន្និ- បតន្តិ បញ្ច វា អតិរេកា វា ។ តេ ន ជានន្តិ អត្ថញ្ញេ អាវាសិកា ភិក្ខូ អនាគតាតិ ។ តេ ធម្មសញ្ញិនោ វិន- យសញ្ញិនោ វគ្គា សមគ្គសញ្ញិនោ បវារេន្តិ ។ តេហិ បវា- រិយមានេ អញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ពហុតរា ។ តេហិ ភិក្ខវេ ភិក្ខូហិ បុន បវារេតព្វំ បវារិតានំ អនាបត្តិ ។ ។បេ។ អញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ សមសមា ។ បវារិតា សុប្បវារិតា តេសំ សន្តិកេ បវារេតព្វំ បវារិតានំ អនាបត្តិ ។ ។បេ។ អញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ថោកតរា ។ បវារិតា សុប្បវារិតា តេសំ សន្តិកេ





(លោះតែពួកអាវាសិកភិក្ខុឯទៀត) គឺច្រើនជាងមកដល់ ។ ភិក្ខុដែលបានបវារណា ហើយក៏ឈ្មោះថាបវារណាល្អហើយ (ត្រូវពួកភិក្ខុដែលនៅសល់អំពីនោះ បវារណា ភិក្ខុទាំងឡាយដែលបានបវារណាហើយមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសជាទីនៅនៃភិក្ខុណាមួយ មានពួកអាវា- សិកភិក្ខុច្រើនរូប គឺ ៥ រូបឬលើស ៥ រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណា នោះ ។ ភិក្ខុទាំងនោះមិនដឹងថាមានពួកអាវាសិកភិក្ខុឯទៀតមិនទាន់មក ដល់ ។ ភិក្ខុទាំងឡាយនោះ គឺសំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួក ទេ តែសំគាល់ថាព្រមព្រៀង ហើយបវារណាទៅ ។ កាលដែលភិក្ខុទាំង នោះកំពុងតែនឹងបវារណានៅ ក៏មានពួកអាវាសិកភិក្ខុឯទៀតច្រើនជាងមក ដល់ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងនោះបវារណាម្ដងទៀត ភិក្ខុដែល បានបវារណាហើយមិនត្រូវអាបត្តិទេ ។បេ។ ក៏មានពួកអាវាសិកភិក្ខុចំនួន ស្មើ ៗ គ្នាមកដល់ ។ ភិក្ខុទាំងឡាយដែលបានបវារណាហើយក៏ឈ្មោះ ថាបវារណាហើយល្អ (ត្រូវពួកអាវាសិកភិក្ខុឯទៀត) បវារណាក្នុងសំណាក់ភិក្ខុ ទាំងឡាយនោះចុះ ភិក្ខុដែលបានបវារណាហើយមិនត្រូវអាបត្តិទេ ។បេ។ ក៏មានពួកអាវាសិកភិក្ខុឯទៀតតិចជាងមកដល់ ។ ពួកភិក្ខុដែលបវារណា ហើយក៏ឈ្មោះថាបានបវារណាល្អហើយ (ត្រូវ (ពួកភិក្ខុដែលមកក្រោយ)

បវារេតព្វំ បវារកានំ អនាបត្តិ ។ ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុ បវារណាយ សម្ពហុលា អាវាសិកា ភិក្ខូ សន្និបតន្តិ បញ្ច វា អតិរេកា វា ។ តេ ន ជានន្តិ អត្ថញ្ញេ អាវាសិកា ភិក្ខូ អនាគតាតិ ។ តេ ធម្មសញ្ញិនោ វិនយសញ្ញិនោ វគ្គា សមគ្គសញ្ញិនោ បវារេន្តិ ។ តេហិ បវារិតមត្តេ អវុដ្ឋិតាយ បរិសាយ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ពហុតរា ។ តេហិ ភិក្ខវេ ភិក្ខូហិ បុន បវារេតព្វំ ។ បវារកានំ អនាបត្តិ ។ បេ ។ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ សមសមា ។ បេ ។ ថោកតរា ។ បវារិតា សុបវារិតា តេសំ សន្តិកេ បវារេតព្វំ បវារកានំ អនាបត្តិ ។ ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុ បវារណាយ សម្ពហុលា អាវាសិកា ភិក្ខូ សន្និបតន្តិ បញ្ច វា អតិរេកា វា ។ តេ ន ជានន្តិ អត្ថញ្ញេ អាវាសិកា ភិក្ខូ



បវារណាក្នុងសំណាក់ភិក្ខុទាំងឡាយ (ដែលបវារណាហើយ) នោះចុះ ភិក្ខុដែលបានបវារណាហើយមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះបើក្នុងអាវាសណាមួយមានពួកអាវាសិកភិក្ខុជាច្រើនគឺ ៥ រូបឬជាង ៥ រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ ។ ភិក្ខុទាំងនោះមិនដឹងថាមានពួកអាវាសិកភិក្ខុឯទៀតមិនទាន់មកដល់ ។ ភិក្ខុទាំងនោះក៏សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថាព្រមព្រៀងហើយបវារណាទៅ ។ កាលដែលភិក្ខុទាំងឡាយនោះទើបតែនឹងបវារណារួច ភិក្ខុបរិស័ទមិនទាន់ក្រោកចេញទៅឡើយ ក៏ពួកអាវាសិកភិក្ខុឯទៀតច្រើនជាងមកដល់ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះបវារណាម្តងទៀត ។ ពួកភិក្ខុដែលបានបវារណាហើយមិនត្រូវអាបត្តិទេ ។ បេ ។ ក៏មានពួកអាវាសិកភិក្ខុឯទៀតចំនួនស្មើៗ គ្នាមកដល់ ។ បេ ។ តិចជាង ។ ភិក្ខុទាំងឡាយដែលបានបវារណាហើយឈ្មោះថាបវារណាល្អហើយ (ពួកភិក្ខុដែលមិនទាន់បវារណា) ត្រូវបវារណាក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ ពួកភិក្ខុដែលបានបវារណាហើយមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះបើក្នុងអាវាសណាមួយមានពួកអាវាសិកភិក្ខុជាច្រើនគឺ ៥ រូបឬជាង ៥ រូបឡើងទៅប្រជុំគ្នាក្នុងថ្ងៃបវារណានោះ ។ ភិក្ខុទាំងឡាយនោះមិនដឹងថាមានពួកអាវាសិកភិក្ខុឯទៀតមិនទាន់

## បវារណក្ខន្ធកេ អនាបត្តិបណ្ណរសកំ

អញ្ញាតកានិ ។ បេ ។ តេ ធម្មសញ្ញិនោ វិនយសញ្ញិនោ វគ្គា សមគ្គសញ្ញិនោ បវារេន្តិ ។ តេហិ បវារិតមត្តេ ឯកច្ចាយ វុដ្ឋិតាយ បរិសាយ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ពហុតរា ។ តេហិ ភិក្ខវេ ភិក្ខូហិ បុន បវារេតព្វំ បវារិតានំ អនាបត្តិ ។ បេ ។ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ សមសមា ។ បេ ។ ថោកតរា ។ បវារិតា សុបវារិតា អវសេសេហិ សន្តិកេ បវារេតព្វំ បវារិតានំ អនាបត្តិ ។ ៩០

ឥធ ភិក្ខវេ អញ្ញតរស្មិំ អាវាសេ តទហុប្បវារណាយ សម្ពហុលា អាវាសិកា ភិក្ខូ សន្និបតន្តិ បញ្ច វា អតិរេកា វា ។ តេ ជានន្តិ អត្ថញ្ញេ អាវាសិកា ភិក្ខូ អនាគតាតិ ។ តេ ធម្មសញ្ញិនោ វិនយសញ្ញិនោ វគ្គា សមគ្គសញ្ញិនោ បវារេន្តិ ។ តេហិ បវារិតមត្តេ សព្វាយ វុដ្ឋិតាយ បរិសាយ



## បវារណក្ខន្ធកៈ ភិក្ខុអ្នកបវារណាមិនត្រូវអាបត្តិមាន ១៥ លើក

មកដល់ ។ ភិក្ខុទាំងនោះសំគាល់ថាជាធម៌សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថាព្រមព្រៀងគ្នា ហើយក៏បវារណាទៅ ។ កាលដែលភិក្ខុទាំងឡាយនោះទើបតែនឹងបវារណារួច ភិក្ខុបរិស័ទពួកខ្លះក្រោកចេញទៅហើយ ក៏មានពួកអាវាសិកភិក្ខុឯទៀតជាច្រើនជាងមកដល់ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះបវារណាម្តងទៀត ពួកភិក្ខុដែលបានបវារណាហើយ មិនត្រូវអាបត្តិទេ ។ បេ ។ ក៏មានពួកអាវាសិកភិក្ខុឯទៀតស្មើៗគ្នាមកដល់ ។ បេ ។ តិចជាង ។ ភិក្ខុដែលបវារណាហើយក៏ឈ្មោះថាបានបវារណាល្អហើយ ភិក្ខុ(ដែលមិនទាន់បវារណា)ត្រូវបវារណាក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ ភិក្ខុទាំងឡាយដែលបានបវារណាហើយ មិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយមានពួកអាវាសិកភិក្ខុជាច្រើនគឺ ៥ រូបឬជាង ៥ រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ ។ ភិក្ខុទាំងនោះដឹងថា មានពួកអាវាសិកភិក្ខុឯទៀតមិនទាន់មកដល់ ។ ភិក្ខុទាំងនោះសំគាល់ថាជាធម៌សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថាព្រមព្រៀងគ្នា ហើយក៏បវារណាទៅ ។ កាលដែលភិក្ខុទាំងនោះទើបតែនឹងបវារណារួច ភិក្ខុបរិស័ទទាំងអស់ក្រោកចេញហើយ

អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ពហុតរា ។ តេហិ ភិក្ខវេ ភិក្ខូហិ បុន បវារេតព្វំ បវារិតានំ អនាបត្តិ ។ បេ ។ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ សមសមា ។ បេ ។ ថោកតរា ។ បវារិតា សុប្បវារិតា តេសំ សន្តិកេ បវារេតព្វំ បវារិតានំ អនាបត្តិ ។

អនាបត្តិបណ្ណរសកំ និដ្ឋិតំ ។

[៣១] ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុប្បវារណាយ សម្ពហុលា អាវាសិកា ភិក្ខូ សន្និបតន្តិ បញ្ច វា អតិរេកា វា ។ តេ ជានន្តិ អត្ថញ្ញេ អាវាសិកា ភិក្ខូ អនាគតាតិ ។ តេ ធម្មសញ្ញិនោ វិនយសញ្ញិនោ វគ្គា សមគ្គសញ្ញិនោ បវារេន្តិ ។ តេហិ បវារិយមានេ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ពហុតរា ។ តេហិ ភិក្ខវេ ភិក្ខូហិ បុន បវារេតព្វំ បវារិតានំ អាបត្តិ ទុក្កដស្ស ។ បេ ។ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ សមសមា ។ បេ ។ ថោកតរា ។ បវារិតា សុប្បវារិតា



ក៏មានពួកអាវាសិកភិក្ខុឯទៀតដទៃច្រើនជាងមកដល់ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះបវារណាម្ដងទៀតចុះ ភិក្ខុទាំងឡាយដែលបវារណាហើយមិនត្រូវអាបត្តិទេ ។ បេ ។ ក៏មានពួកអាវាសិកភិក្ខុឯទៀតស្មើៗគ្នាមកដល់ ។ បេ ។ តិចជាង ។ ភិក្ខុដែលបវារណាហើយ ក៏ឈ្មោះថាបានបវារណាល្អហើយ ភិក្ខុ (ដែលមិនទាន់បវារណា) ត្រូវបវារណាក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ ភិក្ខុដែលបវារណាហើយមិនត្រូវអាបត្តិទេ ។

ចប់ រឿងភិក្ខុបវារណាមិនត្រូវអាបត្តិ មាន ១៥ យ៉ាង ។

[៣១] ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសនោះឯក្នុងថ្ងៃបវារណា-មួយមានពួកអាវាសិកភិក្ខុជាច្រើនគឺ ៥ រូបឬជាង ៥ រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ ។ ភិក្ខុទាំងឡាយនោះដឹងថាមានពួកអាវាសិកភិក្ខុឯទៀតមកមិនទាន់ដល់ ។ ភិក្ខុទាំងឡាយនោះសំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួក តែសំគាល់ថាព្រមព្រៀងគ្នា ហើយក៏បវារណាទៅ ។ កាលភិក្ខុទាំងឡាយនោះកំពុងបវារណា ក៏មានពួកអាវាសិកភិក្ខុឯទៀតច្រើនជាងមកដល់ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះបវារណាម្ដងទៀត ភិក្ខុដែលបវារណាហើយត្រូវអាបត្តិទុក្កដ ។ បេ ។ ក៏មានពួកអាវាសិកភិក្ខុឯទៀតស្មើៗគ្នាមកដល់ ។ បេ ។ តិចជាង ។ ភិក្ខុទាំងឡាយដែលបវារណាហើយ ក៏ឈ្មោះថាបានបវារណាដោយល្អហើយ

អវសេសេហិ បវារេតព្វំ បវារិតានំ អាបត្តិ ទុក្កដស្ស ។

ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុ បវារណាយ សម្ពហុលា អាវាសិកា ភិក្ខូ សន្និបតន្តិ បញ្ច វា អតិរេកា វា ។ តេ ជានន្តិ អត្ថញ្ញេ អាវាសិកា ភិក្ខូ អនាគតាតិ ។ តេ ធម្មសញ្ញិនោ វិនយសញ្ញិនោ វគ្គា សមគ្គសញ្ញិនោ បវារេន្តិ ។ តេហិ បវារិយមានេ ។ បេ ។ អវុដ្ឋិតាយ បរិសាយ ឯកច្ចាយ វុដ្ឋិតាយ បរិសាយ សព្វាយ វុដ្ឋិតាយ បរិសាយ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ពហុតរា ។ បេ ។ សមសមា ។ បេ ។ ថោកតរា ។ បវារិតា សុបវារិតា តេសំ សន្តិកេ បវារេតព្វំ បវារិតានំ អាបត្តិ ទុក្កដស្ស ។

វគ្គសមគ្គសញ្ញិបណ្ណរសកំ និដ្ឋិតំ ។





ត្រូវភិក្ខុដែលនៅសល់អំពីនោះបវារណាចុះ ពួកភិក្ខុដែលបវារណាហើយ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសនោះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើនគឺ ៥ រូបឬជាង ៥ រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ ។ ភិក្ខុទាំងឡាយនោះដឹងថាមានពួកអាវាសិកភិក្ខុឯទៀតមិនទាន់មកដល់ ។ ភិក្ខុទាំងឡាយនោះសំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថាព្រមព្រៀងគ្នា ហើយក៏បវារណាទៅ ។ កាលដែលភិក្ខុទាំងនោះកំពុងតែនឹងបវារណានៅ ។ បេ ។ ភិក្ខុបរិសទ្យមិនទាន់ក្រោក ភិក្ខុបរិសទ្យពួកខ្លះក្រោកហើយ ភិក្ខុបរិសទ្យទាំងអស់ក្រោកចេញហើយ ទើបមានពួកអាវាសិកភិក្ខុឯទៀតច្រើនជាងមកដល់ ។ បេ ។ ស្មើគ្នា ។ បេ ។ តិចជាង ។ ពួកភិក្ខុដែលបវារណាហើយ ក៏ឈ្មោះថាបានបវារណាល្អហើយ ពួកភិក្ខុ (ដែលមិនទាន់បវារណា) ត្រូវបវារណាក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ ពួកភិក្ខុដែលបវារណាហើយ ត្រូវអាបត្តិទុក្កដ ។

ចប់ រឿងពួកភិក្ខុជាពួកតែសំគាល់ថាព្រមព្រៀងគ្នាមាន ១៥ យ៉ាង ។

(៣១) ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុបោសថេ សម្ពហុលា អាវាសិកា ភិក្ខូ សន្និបតន្តិ ចត្តារោ វា អតិរេកា វា ។ តេ ជានន្តិ អត្ថញ្ញេ អាវាសិកា ភិក្ខូ អនាគតាតិ ។ តេ កប្បតិ នុ ខោ អម្ហាកំ ឧបោសថោ ន នុ ខោ កប្បតីតិ វេមតិកា ឧបោសថំ ។ តេហិ ឧទ្ទិស្សមានេ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ពហុតរា ។ តេហិ ភិក្ខវេ ភិក្ខូហិ បុន បាតិមោក្ខំ ឧទ្ទិសិតព្វំ អាបត្តិ ទុក្កដស្ស ។បេ។ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ សមសមា ។បេ។ ថោកតរា ។ ឧទ្ទិដ្ឋំ សុឧទ្ទិដ្ឋំ អវសេសំ សោតព្វំ ឧទ្ទេសកានំ អាបត្តិ ទុក្កដស្ស ។ ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុបោសថេ សម្ពហុលា អាវាសិកា ភិក្ខូ សន្និបតន្តិ ចត្តារោ វា អតិរេកា វា ។ តេ ជានន្តិ អត្ថញ្ញេ អាវាសិកា ភិក្ខូ អនាគតាតិ ។ តេ កប្បតិ នុ ខោ អម្ហាកំ ឧបោសថោ ន នុ ខោ កប្បតីតិ វេមតិកា ឧបោសថំ ។ តេហិ ឧទ្ទិដ្ឋមត្តេ ។បេ។ អវុដ្ឋិតាយ



(៣១) ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើនគឺ ៤ រូបឬជាង ៤ រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃឧបោសថនោះ ។ ភិក្ខុទាំងឡាយនោះដឹងថាមានពួកអាវាសិកភិក្ខុឯទៀតមិនទាន់មកដល់ ។ ពួកភិក្ខុទាំងឡាយនោះមានសេចក្ដីសង្ស័យថាគួរ ដែរ ខ្លួនយើងទាំងឡាយធ្វើឧបោសថ ឬមិនគួរទេ (ហើយក៏នាំគ្នា) ធ្វើឧបោសថទៅ ។ កាលដែលភិក្ខុទាំងឡាយនោះកំពុងតែធ្វើឧបោសថ ក៏មានពួកអាវាសិកភិក្ខុឯទៀតច្រើនជាងមកដល់ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះធ្វើឧបោសថម្ដងទៀត ពួកភិក្ខុដែលធ្វើឧបោសថហើយ ត្រូវអាបត្តិទុក្កដ ។បេ។ ក៏មានពួកអាវាសិកភិក្ខុឯទៀតស្មើៗ គ្នាមកដល់ ។បេ។ តិចជាង ។ ពួកភិក្ខុដែលធ្វើឧបោសថហើយក៏ឈ្មោះថាបានធ្វើឧបោសថល្អហើយ ត្រូវពួកភិក្ខុដែលនៅសល់តែផ្ទៃនោះធ្វើឧបោសថចុះ ពួកភិក្ខុដែលធ្វើឧបោសថហើយត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះបើក្នុងអាវាសណាមួយមានពួកអាវាសិកភិក្ខុជាច្រើនគឺ ៤ រូបឬជាង ៤ រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃឧបោសថនោះ ។ ភិក្ខុទាំងនោះដឹងថាមានពួកអាវាសិកភិក្ខុឯទៀតមិនទាន់មកដល់ ។ តែពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យថា ខ្លួនយើងទាំងឡាយធ្វើឧបោសថឬមិនគួរទេ (ហើយក៏នាំគ្នា) ធ្វើឧបោសថទៅ ។ កាលដែលពួកភិក្ខុទាំងនោះទើបតែនឹងធ្វើឧបោសថហើយ ។បេ។ ភិក្ខុបរិសទ្យមិន

បរិសាយ ឯកច្ចាយ វុដ្ឋិតាយ បរិសាយ សព្វាយ វុដ្ឋិតាយ បរិសាយ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ពហុតរា ។បេ។ សមសមា ។បេ។ ថោកតរា ។ បវារិតា សុប្បវារិតា តេសំ សន្តិកេ បវារេតព្វំ បវារិតានំ អាបត្តិ ទុក្កដស្ស ។

វេមតិកបណ្ណរសកំ និដ្ឋិតំ ។

[៣២] ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុ បវារណាយ សម្ពហុលា អាវាសិកា ភិក្ខូ សន្និបតន្តិ បញ្ច វា អតិរេកា វា ។ តេ ជានន្តិ អត្ថញ្ញេ អាវាសិកា ភិក្ខូ អនាគតាតិ ។ តេ កប្បតិ នុ ខោ អម្ហាកំ បវារេតុំ នម្ហាកំ ន កប្បតីតិ កុក្កុច្ចបកតា បវារេន្តិ ។ តេហិ បវារិយមានេ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ពហុតរា ។ តេហិ ភិក្ខវេ ភិក្ខូហិ បុន បវារេតព្វំ បវារិតានំ អាបត្តិ ទុក្កដស្ស ។បេ។ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ សមសមា ។បេ។ ថោកតរា ។



ទាន់ក្រោកចេញ ភិក្ខុបរិសទ្យពួកខ្លះក្រោកចេញហើយ ភិក្ខុបរិសទ្យទាំងអស់ក្រោកចេញហើយ ទើបមានពួកអាវាសិកភិក្ខុឯទៀតច្រើនជាងមកដល់ ។បេ។ ស្មើៗគ្នា ។បេ។ តិចជាង ។ ពួកភិក្ខុដែលបវារណាហើយ ឈ្មោះថាបានបវារណាល្អហើយ ពួកភិក្ខុ (ដែលមិនទាន់បវារណា) ត្រូវបវារណាក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ ពួកភិក្ខុដែលបវារណាហើយ ត្រូវអាបត្តិទុក្កដ ។

ចប់រឿងពួកភិក្ខុមានសេចក្ដីសង្ស័យមាន ១៥ យ៉ាង ។

[៣២] ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសនោះ បើក្នុងថ្ងៃបវារណាមួយមានពួកអាវាសិកភិក្ខុជាច្រើន គឺ ៥ រូបឬជាង ៥ រូបទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ ។ ភិក្ខុទាំងនោះដឹងថាមានពួកអាវាសិកភិក្ខុឯទៀតមិនទាន់មកដល់ ។ ភិក្ខុទាំងនោះកើតសេចក្ដីរង្កៀសថា យើងទាំងឡាយគួរតែបវារណា មិនមែនថាយើងមិនគួរបវារណាទេដូច្នេះ ហើយក៏បវារណាទៅ ។ កាលដែលភិក្ខុទាំងឡាយនោះកំពុងតែបវារណា ទើបមានអាវាសិកភិក្ខុឯទៀតច្រើនជាងមកដល់ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវពួកភិក្ខុទាំងនោះបវារណាម្ដងទៀត ឯពួកភិក្ខុដែលបវារណាហើយត្រូវអាបត្តិទុក្កដ ។បេ។ ទើបមានពួកអាវាសិកភិក្ខុឯទៀតស្មើៗគ្នាមកដល់ ។បេ។ តិចជាង ។

បវារិតា សុប្បវារិតា អវសេសេហិ បវារេតព្វំ បវារិតានំ អាបត្តិ ទុក្កដស្ស ។ ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុ បវារណាយ សម្ពហុលា អាវាសិកា ភិក្ខូ សន្និបតន្តិ បញ្ច វា អតិរេកា វា ។ តេ ជានន្តិ អត្ថញ្ញេ អាវាសិកា ភិក្ខូ អនាគតាតិ ។ តេ កប្បតេវ អម្ហាកំ បវារេតុំ នម្ហាកំ ន កប្បតីតិ កុក្កុច្ចប្បកតា បវារេន្តិ ។ តេសំ បវារិយមានេ ។បេ។ អវុដ្ឋិតាយ បរិសាយ ឯកច្ចាយ វុដ្ឋិតាយ បរិសាយ សព្វាយ វុដ្ឋិតាយ បរិសាយ អញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ពហុតរា ។បេ។ សមសមា ។បេ។ ថោកតរា ។ បវារិតា សុប្បវារិតា តេសំ សន្តិកេ បវារេតព្វំ បវារិតានំ អាបត្តិ ទុក្កដស្ស ។

កុក្កុច្ចបកតបណ្ណរសកំ និដ្ឋិតំ ។



ពួកភិក្ខុដែលបវារណាហើយក៏ឈ្មោះថាបានបវារណាល្អហើយ ត្រូវតែពួកភិក្ខុដែលនៅសល់ពីនោះបវារណាចុះ ពួកភិក្ខុដែលបវារណាហើយត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសនានេះបើកាលណាមួយ មានពួកអាវាសិកភិក្ខុជាច្រើន ៥ រូបឬជាង ៥ រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ ។ ភិក្ខុទាំងនោះដឹងថាមានពួកអាវាសិកភិក្ខុដទៃទៀតមិនទាន់មកដល់ ។ ភិក្ខុទាំងនោះមានសេចក្ដីរង្កៀសថា យើងទាំងឡាយ គួរតែបវារណា មិនមែនថាយើងទាំងឡាយមិនគួរបវារណាទេដូច្នេះហើយ ក៏បវារណាទៅ ។ កាលដែលភិក្ខុទាំងឡាយនោះទើបតែនឹងបវារណាហើយ ។បេ។ ភិក្ខុបរិសទ្យមិនទាន់ក្រោកចេញ ភិក្ខុបរិសទ្យពួកខ្លះក្រោកចេញទៅហើយ ភិក្ខុបរិសទ្យទាំងអស់ក្រោកចេញទៅហើយ ទើបមានពួកអាវាសិកភិក្ខុដទៃទៀតច្រើនជាងមកដល់ ។បេ។ ស្មើគ្នា ។បេ។ តិចជាង ។ ពួកភិក្ខុដែលបវារណាហើយក៏ឈ្មោះថាបានបវារណាល្អហើយ ពួកភិក្ខុ (ដែលមិនទាន់បានបវារណា) ត្រូវបវារណាក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ ភិក្ខុដែលបវារណាហើយត្រូវអាបត្តិទុក្កដ ។

ចប់រឿងពួកភិក្ខុមានសេចក្ដីរង្កៀសមាន ១៥ យ៉ាង ។

(៣៣) ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុប្បវារណាយ សម្ពហុលា អាវាសិកា ភិក្ខូ សន្និបតន្តិ បញ្ច វា អតិរេកា វា ។ តេ ជានន្តិ អត្ថញ្ញេ អាវាសិកា ភិក្ខូ អនាគតាតិ ។ តេ ធម្មសញ្ញិនោ វិនយសញ្ញិនោ ភេទបុរេក្ខារា បវារេន្តិ ។ តេហិ បវារិយមានេ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ពហុតរា ។ តេហិ ភិក្ខវេ ភិក្ខូហិ បុន បវារេតព្វំ បវារិតានំ អាបត្តិ ថុល្លច្ចយស្ស ។ បេ ។ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ សមសមា ។ បេ ។ ថោកតរា ។ បវារិតា សុប្បវារិតា អវសេសេហិ បវារេតព្វំ បវារិតានំ អាបត្តិ ថុល្លច្ចយស្ស ។ ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុប្បវារណាយ សម្ពហុលា អាវាសិកា ភិក្ខូ សន្និបតន្តិ បញ្ច វា អតិរេកា វា ។ តេ ជានន្តិ អត្ថញ្ញេ អាវាសិកា ភិក្ខូ អនាគតាតិ ។ តេ ធម្មសញ្ញិនោ វិនយសញ្ញិនោ ភេទបុរេក្ខារា បវារេន្តិ ។ តេហិ



(៣៣) ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានអាវាសិកភិក្ខុទាំងឡាយច្រើន គឺ ៥ រូបឬលើស ៥ រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ ។ ភិក្ខុទាំងឡាយនោះដឹងថា មានពួកអាវាសិកភិក្ខុឯទៀតមិនទាន់មកដល់ ។ ភិក្ខុទាំងឡាយនោះមានចំណាំនឹងបំបែកសង្ឃថា ភិក្ខុទាំងឡាយនុ៎ះវិនាសទៅចុះ ភិក្ខុទាំងឡាយនុ៎ះប្រវិនាសទៅចុះ ប្រយោជន៍អ្វីដោយភិក្ខុទាំងឡាយនោះជួបជុំហើយ ក៏បវារណាទៅ ។ កាលបើភិក្ខុទាំងនោះកំពុងតែបវារណា ស្រាប់តែមានពួកអាវាសិកភិក្ខុឯទៀតច្រើនជាងមកដល់ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះបវារណាម្ដងទៀត ពួកភិក្ខុដែលបានបវារណាហើយ ត្រូវអាបត្តិថុល្លច្ច័យ ។ បេ ។ បើមានពួកអាវាសិកភិក្ខុឯទៀតស្មើៗគ្នាមកដល់ ។ បេ ។ តិចជាង ។ ពួកភិក្ខុដែលបវារណាហើយក៏ឈ្មោះថាបានបវារណាល្អហើយ ត្រូវតែពួកភិក្ខុដែលនៅសល់អំពីនោះបវារណាចុះ ពួកភិក្ខុដែលបានបវារណាហើយ ត្រូវអាបត្តិថុល្លច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុច្រើន គឺ ៥ រូបឬលើស ៥ រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ ។ ភិក្ខុទាំងឡាយនោះដឹងថា មានពួកអាវាសិកភិក្ខុឯទៀតមកមិនទាន់ដល់ ។ (ក) ពួកភិក្ខុទាំងនោះមានចំណាំនឹងបំបែកសង្ឃថា ភិក្ខុទាំងឡាយនុ៎ះ

អត្ថាតិ ភេទបុរេក្ខារា បវារេន្តិ ។ តេហិ បវារិតមត្តេ ។ បេ ។ អវុដ្ឋិតាយ បរិសាយ ឯកច្ចាយ វុដ្ឋិតាយ បរិសាយ សព្វាយ វុដ្ឋិតាយ បរិសាយ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ ពហុតរា ។ តេហិ ភិក្ខវេ ភិក្ខូហិ បុន បវារេតព្វំ បវារិតានំ អាបត្តិ ថុល្លច្ចយស្ស ។ បេ ។ អថញ្ញេ អាវាសិកា ភិក្ខូ អាគច្ឆន្តិ សមសមា ។ បេ ។ ថោកតរា ។ បវារិតា សុបវារិតា តេសំ សន្តិកេ បវារេតព្វំ បវារិតានំ អាបត្តិ ថុល្លច្ចយស្ស ។

ភេទបុរេក្ខារបណ្ណរសកំ និដ្ឋិតំ ។

(៣៤) ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុបវារណាយ សម្ពហុលា អាវាសិកា ភិក្ខូ សន្និបតន្តិ បញ្ច វា អតិរេកា វា ។ តេ ន ជានន្តិ អញ្ញេ អាវាសិកា ភិក្ខូ អន្តោសីមំ ឱក្កមន្តីតិ ។ បេ ។ តេ ន ជានន្តិ អញ្ញេ អាវាសិកា ភិក្ខូ អន្តោសីមំ ឱក្កន្តាតិ



ចូរផុតទៅចុះ ភិក្ខុចាំវស្សាយទាំងនុ៎ះចូរវិនាសទៅចុះ ត្រូវការអ្វីដោយភិក្ខុចាំវស្សាយនោះផុតនុ៎ះហើយ ក៏បវារណាទៅ ។ កាលបើភិក្ខុចាំវស្សាយនោះទើបតែនឹងបវារណាហើយ ។ បេ ។ ភិក្ខុបរិសទ្យមិនទាន់ក្រោកចេញ ភិក្ខុបរិសទ្យពួកខ្លះក្រោកចេញហើយ ភិក្ខុបរិសទ្យទាំងអស់ក្រោកចេញហើយ ទើបមានពួកអាវាសិកភិក្ខុឯទៀតច្រើនជាងមកដល់ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុចាំវស្សាយនោះបវារណាម្ដងទៀត ពួកភិក្ខុដែលបានបវារណាហើយ ត្រូវអាបត្តិថុល្លច្ច័យ ។ បេ ។ ទើបមានពួកអាវាសិកភិក្ខុឯទៀតស្មើៗគ្នាមកដល់ ។ បេ ។ តិចជាង ។ ពួកភិក្ខុដែលបវារណាហើយ គឺឈ្មោះថាបានបវារណាល្អហើយ ត្រូវភិក្ខុចាំវស្សាយនោះបវារណាក្នុងសំណាក់ភិក្ខុចាំវស្សាយនោះចុះ ពួកភិក្ខុដែលបានបវារណាហើយត្រូវអាបត្តិថុល្លច្ច័យ ។

ចប់រឿងពួកភិក្ខុមានចំណង់នឹងបំបែកសង្ឃមាន ១៥ យ៉ាង ។

(៣៤) ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើនគឺ ៥ រូបឬជាង ៥ រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ ។ ភិក្ខុចាំវស្សាយនោះមិនដឹងថាមានពួកអាវាសិកភិក្ខុឯទៀតកំពុងដើរចូលមកដល់ខាងក្នុងសីមា ។ បេ ។ ភិក្ខុចាំវស្សាយនោះមិនដឹងថា មានពួកអាវាសិកភិក្ខុឯទៀតដើរចូលមកដល់ខាងក្នុងសីមា ។ បេ ។ ភិក្ខុ

។បេ។ តេ ន បស្សន្តិ អញ្ញេ អាវាសិកេ ភិក្ខូ អន្តោសីមំ ឱក្កមន្តេ ។បេ។ តេ ន បស្សន្តិ អញ្ញេ អាវាសិកេ ភិក្ខូ អន្តោសីមំ ឱក្កន្តេ ។បេ។ តេ ន សុណន្តិ អញ្ញេ អាវាសិកា ភិក្ខូ អន្តោសីមំ ឱក្កមន្តីតិ ។បេ។ តេ ន សុណន្តិ អញ្ញេ អាវាសិកា ភិក្ខូ អន្តោសីមំ ឱក្កន្តាតិ ។ អាវាសិកេន អាវាសិកា ឯកសតបញ្ចសត្តតិ តិកនយតោ អាវាសិកេន អាគន្តុកា អាគន្តុកេន អាវាសិកា អាគន្តុកេន អាគន្តុកា បេយ្យាលមុខេន សត្ត តិកសតានិ ហោន្តិ ។

[៣៩] ឥធ បន ភិក្ខវេ អាវាសិកានំ ភិក្ខូនំ ចាតុទ្ទសោ ហោតិ អាគន្តុកានំ បណ្ណរសោ ។ សចេ អាវាសិកា ពហុតរា ហោន្តិ អាគន្តុកេហិ អាវាសិកានំ អនុវត្តិតព្វំ ។ សចេ សមសមា ហោន្តិ អាគន្តុកេហិ អាវាសិកានំ អនុវត្តិតព្វំ ។ សចេ អាគន្តុកា ពហុតរា ហោន្តិ អាវាសិកេហិ អាគន្តុកានំ អនុវត្តិតព្វំ ។ ឥធ បន ភិក្ខវេ អាវាសិកានំ ភិក្ខូនំ បណ្ណរសោ ហោតិ អាគន្តុកានំ ចាតុទ្ទសោ ។ សចេ អាវាសិកា





ទាំងឡាយនោះមិនឃើញពួកអាវាសិកភិក្ខុឯទៀតកំពុងដើរចូលមកដល់ខាងក្នុងសីមា ។បេ។ ភិក្ខុទាំងឡាយនោះមិនឃើញពួកអាវាសិកភិក្ខុឯទៀតបានដើរចូលមកដល់ខាងក្នុងសីមា ។បេ។ ពួកភិក្ខុទាំងនោះមិនឮថាពួកអាវាសិកភិក្ខុឯទៀតកំពុងដើរចូលមកខាងក្នុងសីមា ។បេ។ ពួកភិក្ខុទាំងនោះមិនឮថាពួកអាវាសិកភិក្ខុឯទៀតបានដើរចូលមកខាងក្នុងសីមា ។ ពួកអាវាសិកភិក្ខុនឹងអាវាសិកភិក្ខុមានន័យ ១៧៥ តិក ពួកអាគន្តុកភិក្ខុនឹងអាវាសិកភិក្ខុមានន័យ១៧៥តិក ពួកអាវាសិកភិក្ខុនឹងអាគន្តុកភិក្ខុមានន័យ១៧៥ តិក ពួកអាគន្តុកភិក្ខុនឹងអាគន្តុកភិក្ខុមានន័យ ១៧៥ តិក ត្រូវជា៧០០ តិក តាមរបៀបបេយ្យាលមុខ ។

(៣៩) ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះបើមានពួកអាវាសិកភិក្ខុប្រកាន់ថាថ្ងៃ១៤ ពួកអាគន្តុកភិក្ខុប្រកាន់ថាថ្ងៃ ១៥ ។ បើពួកអាវាសិកភិក្ខុច្រើនជាង ត្រូវពួកអាគន្តុកភិក្ខុប្រព្រឹត្តតាមអាវាសិកភិក្ខុ ។ បើមានចំនួនស្មើ ៗ គ្នា ត្រូវពួកអាគន្តុកភិក្ខុប្រព្រឹត្តតាមពួកអាវាសិកភិក្ខុវិញ ។ បើពួកអាគន្តុកភិក្ខុមានចំនួនច្រើនជាង ត្រូវពួកអាវាសិកភិក្ខុប្រព្រឹត្តតាមពួកអាគន្តុកភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកអាវាសិកភិក្ខុយល់ថាថ្ងៃ១៥ពួកអាគន្តុកភិក្ខុយល់ថាថ្ងៃ១៤ ។ បើពួកអាវា-

ពហុតរា ហោន្តិ អាគន្តុកេហិ អាវាសិកានំ អនុវត្តិតព្វំ ។ សចេ សមសមា ហោន្តិ អាគន្តុកេហិ អាវាសិកានំ អនុវត្តិតព្វំ ។ សចេ អាគន្តុកា ពហុតរា ហោន្តិ អាវាសិកេហិ អាគន្តុកានំ អនុវត្តិតព្វំ ។ ឥធ បន ភិក្ខវេ អាវាសិកានំ ភិក្ខូនំ បាដិបទោ ហោតិ អាគន្តុកានំ បណ្ណរសោ ។ សចេ អាវាសិកា ពហុតរា ហោន្តិ អាវាសិកេហិ អាគន្តុកានំ នាកាមា ទាតព្វា សាមគ្គី អាគន្តុកេហិ និស្សីមំ គន្ត្វា បវារេតព្វំ ។ សចេ សមសមា ហោន្តិ អាវាសិកេហិ អាគន្តុកានំ នាកាមា ទាតព្វា សាមគ្គី អាគន្តុកេហិ និស្សីមំ គន្ត្វា បវារេតព្វំ ។ សចេ អាគន្តុកា ពហុតរា ហោន្តិ អាវាសិកេហិ អាគន្តុកានំ សាមគ្គី វា ទាតព្វា និស្សីមំ វា គន្តព្វំ ។ ឥធ បន ភិក្ខវេ អាវាសិកានំ ភិក្ខូនំ បណ្ណរសោ ហោតិ អាគន្តុកានំ បាដិបទោ ។ សចេ អាវាសិកា ពហុតរា ហោន្តិ អាគន្តុកេហិ អាវាសិកានំ សាមគ្គី វា ទាតព្វា និស្សីមំ វា គន្តព្វំ ។ សចេ សមសមា ហោន្តិ អាគន្តុកេហិ



សិកភិក្ខុមានចំនួនច្រើនជាង ត្រូវពួកអាគន្តុកភិក្ខុប្រព្រឹត្តតាមពួកអាវាសិកភិក្ខុ ។ បើចំនួនស្មើៗគ្នា ត្រូវពួកអាគន្តុកភិក្ខុប្រព្រឹត្តតាមពួកអាវាសិកភិក្ខុវិញ ។ បើពួកអាគន្តុកភិក្ខុមានចំនួនច្រើនជាង ត្រូវពួកអាវាសិកភិក្ខុប្រព្រឹត្តតាមពួកអាគន្តុកភិក្ខុចុះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាវាសិកភិក្ខុយល់ថា ថ្ងៃ១ កើតឬ១ រោច ពួកអាគន្តុកភិក្ខុយល់ថាថ្ងៃ ១៥ ។ បើពួកអាវាសិកភិក្ខុមានចំនួនច្រើនជាង មិនត្រូវពួកអាវាសិកភិក្ខុឲ្យសាមគ្គីដល់ពួកអាគន្តុកភិក្ខុទេ ត្រូវពួកអាគន្តុកភិក្ខុទៅកាន់ទីក្រៅសីមាហើយបវារណាចុះ ។ បើស្មើៗគ្នា មិនត្រូវពួកអាវាសិកភិក្ខុឲ្យសាមគ្គីដល់ពួកអាគន្តុកភិក្ខុឡើយ ត្រូវពួកអាគន្តុកភិក្ខុទៅកាន់ទីក្រៅសីមាហើយបវារណាចុះ ។ បើពួកអាគន្តុកភិក្ខុច្រើនជាង ត្រូវពួកអាវាសិកភិក្ខុឲ្យសាមគ្គីដល់ពួកអាគន្តុកភិក្ខុ ឬត្រូវទៅកាន់ទីក្រៅសីមា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាវាសិកភិក្ខុយល់ថាថ្ងៃ១៥ ពួកអាគន្តុកភិក្ខុយល់ថាថ្ងៃ១ កើតឬ១ រោច ។ បើពួកអាវាសិកភិក្ខុច្រើនជាង ត្រូវពួកអាគន្តុកភិក្ខុឲ្យសាមគ្គីដល់អាវាសិកភិក្ខុ ឬត្រូវទៅកាន់ទីក្រៅសីមា ។ បើពួកភិក្ខុទាំងនោះស្មើៗគ្នា ត្រូវពួកអាគន្តុកភិក្ខុឲ្យសាមគ្គីដល់ពួកអាវាសិកភិក្ខុ

អាវាសិកានំ សាមគ្គី វា ទាតព្វា និស្សីមំ វា គន្តព្វំ ។ សចេ អាគន្តុកា ពហុតរា ហោន្តិ អាគន្តុកេហិ អាវាសិកានំ អកាមា ទាតព្វា សាមគ្គី អាវាសិកេហិ និស្សីមំ គន្ត្វា បវារេតព្វំ ។

[៣៦] ឥធ បន ភិក្ខវេ អាគន្តុកា ភិក្ខូ បស្សន្តិ អាវាសិកានំ ភិក្ខូនំ អាវាសិកាការំ អាវាសិកលិង្គំ អាវាសិកនិមិត្តំ អាវាសិកុទ្ទេសំ សុប្បញ្ញត្តំ មញ្ចបីឋំ ភិសិពិម្ពោហនំ បានីយំ បរិភោជនីយំ សុបដ្ឋិតំ បរិវេណំ សុសម្មដ្ឋំ ។ បស្សិត្វា វេមតិកា ហោន្តិ អត្ថិ នុ ខោ អាវាសិកា ភិក្ខូ នត្ថិ នុ ខោតិ ។ តេ វេមតិកា ន វិចិនន្តិ អវិចិនិត្វា បវារេន្តិ អាបត្តិ ទុក្កដស្ស ។ បេ ។ តេ វេមតិកា វិចិនន្តិ វិចិនិត្វា ន បស្សន្តិ អបស្សិត្វា បវារេន្តិ អនាបត្តិ ។ តេ វេមតិកា វិចិនន្តិ វិចិនិត្វា បស្សន្តិ បស្សិត្វា ឯកតោ បវារេន្តិ អនាបត្តិ ។ តេ វេមតិកា វិចិនន្តិ វិចិនិត្វា បស្សន្តិ បស្សិត្វា នានា បវារេន្តិ អាបត្តិ ទុក្កដស្ស ។ តេ វេមតិកា វិចិនន្តិ





ឬត្រូវទៅកាន់ទីក្រៅសីមា ។ បើពួកអាគន្តុកភិក្ខុច្រើនជាង មិនត្រូវពួកអាគន្តុកភិក្ខុឲ្យសាមគ្គីដល់ពួកអាវាសិកភិក្ខុឡើយ ត្រូវពួកអាវាសិកភិក្ខុទៅកាន់ទីក្រៅសីមា ហើយបវារណាចុះ ។

[៣៦] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាគន្តុកភិក្ខុ ឃើញអាការរបស់អាវាសិកភិក្ខុ ភេទរបស់អាវាសិកភិក្ខុ និមិត្តរបស់អាវាសិកភិក្ខុ ឧទ្ទេសរបស់អាវាសិកភិក្ខុ គ្រែនិងតាំងគួរនឹងទីដេកដែលពួកអាវាសិកភិក្ខុលាតក្រាលដោយល្អហើយ ទឹកឆាន់ទឹកប្រើដែលពួកអាវាសិកភិក្ខុដម្កល់ល្អហើយ បរិវេណដែលពួកអាវាសិកភិក្ខុបោសស្អាតហើយ ។ លុះឃើញហើយក៏មានសេចក្តីសង្ស័យថា មានពួកអាវាសិកភិក្ខុឬគ្មានទេ ។ ពួកអាគន្តុកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ មិនពិនិត្យរកមើល លុះមិនពិនិត្យហើយក៏បវារណា ត្រូវអាបត្តិទុក្កដ ។ បេ ។ ពួកអាគន្តុកភិក្ខុទាំងនោះសង្ស័យហើយក៏ពិនិត្យ លុះពិនិត្យហើយមិនឃើញ លុះមិនឃើញហើយក៏បវារណា មិនត្រូវអាបត្តិទេ ។ ពួកអាគន្តុកភិក្ខុទាំងនោះសង្ស័យ ហើយពិនិត្យមើល លុះពិនិត្យហើយឃើញ លុះឃើញហើយក៏បវារណាជាមួយគ្នា មិនត្រូវអាបត្តិទេ ។ ពួកអាគន្តុកភិក្ខុទាំងនោះសង្ស័យហើយក៏ពិនិត្យ លុះពិនិត្យហើយឃើញ លុះឃើញហើយក៏បវារណាផ្សេងៗគ្នា ត្រូវអាបត្តិទុក្កដ ។ អាគន្តុកភិក្ខុទាំងនោះមានសេចក្តីសង្ស័យហើយពិនិត្យ

វិចិនិត្វា បស្សន្តិ បស្សិត្វា នស្សន្តេតេ វិនស្សន្តេតេ កោ តេហិ អត្ថោតិ ភេទបុរេក្ខារា បវារេន្តិ អាបត្តិ ថុល្លច្ចយស្ស ។ ឥធ បន ភិក្ខវេ អាគន្តុកា ភិក្ខូ សុណន្តិ អាវាសិកានំ ភិក្ខូនំ អាវាសិកាការំ អាវាសិកលិង្គំ អាវាសិកនិមិត្តំ អាវាសិកុទ្ទេសំ ចង្កមន្តានំ បទសទ្ទំ សជ្ឈាយសទ្ទំ ឧក្កាសិតសទ្ទំ ខិបិតសទ្ទំ ។ សុត្វា វេមតិកា ហោន្តិ អត្ថិ នុ ខោ អាវាសិកា ភិក្ខូ នត្ថិ នុ ខោតិ ។ តេ វេមតិកា ន វិចិនន្តិ អវិចិនិត្វា បវារេន្តិ អាបត្តិ ទុក្កដស្ស ។ បេ ។ តេ វេមតិកា វិចិនន្តិ វិចិនិត្វា ន បស្សន្តិ អបស្សិត្វា បវារេន្តិ អនាបត្តិ ។ តេ វេមតិកា វិចិនន្តិ វិចិនិត្វា បស្សន្តិ បស្សិត្វា ឯកតោ បវារេន្តិ អនាបត្តិ ។ តេ វេមតិកា វិចិនន្តិ វិចិនិត្វា បស្សន្តិ បស្សិត្វា បាដេក្កំ បវារេន្តិ អាបត្តិ ទុក្កដស្ស ។





មើល លុះពិនិត្យមើលក៏ឃើញ លុះឃើញហើយក៏មានបំណងនឹងបំបែកសង្ឃដោយគិតថា ពួកភិក្ខុទាំងនុះចូរបាត់ទៅ ពួកភិក្ខុទាំងនុះចូរវិនាសទៅ ត្រូវការអ្វីដោយពួកភិក្ខុទាំងនោះ ហើយក៏បវារណា ត្រូវអាបត្តិថុល្លច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាគន្តុកភិក្ខុឮអាការរបស់អាវាសិកភិក្ខុ ភេទរបស់អាវាសិកភិក្ខុ និមិត្តរបស់អាវាសិកភិក្ខុ ឧទ្ទេសរបស់អាវាសិកភិក្ខុ សូរជើងរបស់ពួកអាវាសិកភិក្ខុកំពុងចង្ក្រម សំឡេងស្វាធ្យាយ (សូត្រធម៌) សំឡេងក្អក សំឡេងកណ្តាស់របស់ពួកអាវាសិកភិក្ខុ ។ លុះឮហើយមានសេចក្តីសង្ស័យថា មានពួកអាវាសិកភិក្ខុឬគ្មានទេ ។ ពួកអាគន្តុកភិក្ខុទាំងនោះមានសេចក្តីសង្ស័យហើយមិនពិនិត្យមើល លុះមិនពិនិត្យហើយក៏បវារណាទៅ ត្រូវអាបត្តិទុក្កដ ។ បេ ។ ពួកអាគន្តុកភិក្ខុទាំងនោះមានសេចក្តីសង្ស័យហើយពិនិត្យមើល លុះពិនិត្យមើលហើយមិនឃើញ លុះមិនឃើញហើយក៏បវារណាទៅ មិនត្រូវអាបត្តិទេ ។ ពួកអាគន្តុកភិក្ខុទាំងនោះមានសេចក្តីសង្ស័យហើយពិនិត្យមើល លុះពិនិត្យមើលហើយក៏ឃើញ លុះឃើញហើយ ក៏បវារណាជាមួយគ្នា មិនត្រូវអាបត្តិទេ ។ ពួកអាគន្តុកភិក្ខុទាំងនោះមានសេចក្តីសង្ស័យហើយក៏ពិនិត្យមើល លុះពិនិត្យមើលហើយក៏ឃើញ លុះឃើញហើយក៏បវារណាផ្សេងៗ

តេ វេមតិកា វិចិនន្តិ វិចិនិត្វា បស្សន្តិ បស្សិត្វា នស្សន្ត-

តេ វិនស្សន្តេតេ កោ តេហិ អត្ថោតិ ភេទបុរេក្ខារា

បវារេន្តិ អាបត្តិ ថុល្លច្ចយស្ស ។ ឥធ បន ភិក្ខវេ អាវាសិ-

កា ភិក្ខូ បស្សន្តិ អាគន្តុកានំ ភិក្ខូនំ អាគន្តុកាការំ

អាគន្តុកលិង្គំ អាគន្តុកនិមិត្តំ អាគន្តុកុទ្ទេសំ អញ្ញាតកំ

បត្តំ អញ្ញាតកំ ចីវរំ អញ្ញាតកំ និសីទនំ បាទានំ ធោតំ

ឧទកនិស្សេកំ ។ បស្សិត្វា វេមតិកា ហោន្តិ អត្ថិ នុ ខោ

អាគន្តុកា ភិក្ខូ នត្ថិ នុ ខោតិ ។ តេ វេមតិកា ន

វិចិនន្តិ អវិចិនិត្វា បវារេន្តិ អាបត្តិ ទុក្កដស្ស ។ បេ ។

តេ វេមតិកា វិចិនន្តិ វិចិនិត្វា ន បស្សន្តិ អបស្សិត្វា

បវារេន្តិ អនាបត្តិ ។ តេ វេមតិកា វិចិនន្តិ វិចិនិត្វា

បស្សន្តិ បស្សិត្វា ឯកតោ បវារេន្តិ អនាបត្តិ ។ តេ វេម-



នា ត្រូវអាបត្តិទុក្កដ ។ ពួកអាគន្តុកភិក្ខុទាំងនោះមានសេចក្តីសង្ស័យហើយ

ពិនិត្យមើល លុះពិនិត្យមើលហើយឃើញ លុះឃើញហើយមានបំណងនឹង

បំបែកសង្ឃដោយគិតថា ចូរលោកទាំងនុ៎ះផុតទៅចុះ ចូរលោកទាំងនុ៎ះ

វិនាសទៅចុះ ត្រូវការអ្វីដោយភិក្ខុទាំងនោះជួបជុំហើយ ក៏បវារណា ត្រូវ

អាបត្តិថុល្លច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាវាសិក-

ភិក្ខុឃើញអាការរបស់អាគន្តុកភិក្ខុ ភេទរបស់អាគន្តុកភិក្ខុ និមិត្តរបស់អា-

គន្តុកភិក្ខុ ឧទ្ទេសរបស់អាគន្តុកភិក្ខុ បាត្រដែលខ្លួនមិនស្គាល់ ចីវរដែលខ្លួន

មិនស្គាល់ សំពត់និសីទនៈដែលខ្លួនមិនស្គាល់ ស្នាមដែលស្រោចទឹកលាង

ជើងរបស់ពួកអាគន្តុកភិក្ខុ ។ លុះឃើញហើយក៏មានសេចក្តីសង្ស័យថា

មានពួកអាគន្តុកភិក្ខុឬគ្មានទេ ។ ពួកអាវាសិកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ

ហើយមិនពិនិត្យមើល លុះមិនពិនិត្យមើលហើយក៏បវារណា ត្រូវអាបត្តិ

ទុក្កដ ។ បេ ។ ពួកអាវាសិកភិក្ខុទាំងនោះមានសេចក្តីសង្ស័យហើយក៏ពិនិត្យ

មើល លុះពិនិត្យមើលហើយមិនឃើញ លុះមិនឃើញហើយ ក៏បវារណា

មិនត្រូវអាបត្តិទេ ។ ពួកអាវាសិកភិក្ខុទាំងនោះមានសេចក្តីសង្ស័យហើយ

ក៏ពិនិត្យមើល លុះពិនិត្យមើលហើយឃើញ លុះឃើញហើយបវារណា

ជាមួយគ្នា មិនត្រូវអាបត្តិទេ ។ ពួកអាវាសិកភិក្ខុទាំងនោះមានសេចក្តី

តិកោ វិចិនន្តិ វិចិនិត្វា បស្សន្តិ បស្សិត្វា ចាជេន្តិ ម-
ក្ខេន្តិ អាបត្តិ ទុក្កដស្ស ។ តេ ថេរិកា វិចិនន្តិ
វិចិនិត្វា បស្សន្តិ បស្សិត្វា ជស្សន្តេ វិបស្សន្តេ
តោ ភេទា អត្តោតិ ភេជន្តុបក្កមេន មក្ខេន្តិ អាបត្តិ ទុក្ក-
ដស្ស ។ ៩០ ២០ ភិក្ខវេ អាកាសិកា ភិក្ខូ សុណាតិ
អាគន្តុកានំ ភិក្ខូនំ អាគន្តុកាចារំ អាគន្តុកវត្តំ អា-
គន្តុកានិមិត្តំ អាគន្តុកានុវត្តំ អាគន្តុកញ្ញាណំ បនទស្សំ ទុហា-
ហាជាប្បមជេស្វំ ទុក្កដសិនស្សំ ទិមិតសន្និ ។ សន្តា
ថេរិកា មោចន្តិ អត្ថំ ទុ ចោ អាគន្តុកា ភិក្ខូ ជម្ពុ ទុ
ចោតិ ។ តេ ថេរិកា ន វិចិនន្តិ អវិចិនិត្វា មក្ខេន្តិ អាបត្តិ





សង្ស័យហើយពិនិត្យមើល លុះពិនិត្យហើយឃើញ លុះឃើញហើយក៏បោក-
ណោកញែកគ្នា ត្រូវអាបត្តិទុក្កដ ។ ពួកអាគន្តុកភិក្ខុទាំងនោះមានសេចក្តី
សង្ស័យហើយក៏ពិនិត្យមើល លុះពិនិត្យមើលហើយឃើញ លុះឃើញ
ហើយមានសេចក្តីមិនបែកសង្ស័យដោយនឹកថា ពួកភិក្ខុទាំងនេះធ្លាក់ទៅក្នុង
ពួកភិក្ខុទាំងនេះមិនធ្លាក់ទៅក្នុង ត្រូវតែធ្វើដោយពួកភិក្ខុទាំងនោះផ្លូវនេះហើយ
ក៏បោកណោកទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹង
នេះ បើពួកអាគន្តុកភិក្ខុបាទពួកអាគារបស់អាគន្តុកភិក្ខុ គេឲ្យរបស់អាគន្តុក-
ភិក្ខុ និមិត្តរបស់អាគន្តុកភិក្ខុ ទន្ទេសរបស់អាគន្តុកភិក្ខុ ស្ពានដីរបស់ពួក
អាគន្តុកភិក្ខុគ្រូវកំដរមក ស្ពានគោះស្បែកជើង ស្ពានគ្គន ស្ពានគណ្ណាស់របស់
ពួកអាគន្តុកភិក្ខុ ។ លុះក្នុងហើយក៏មានសេចក្តីសង្ស័យថា មានពួកអាគន្តុក-
ភិក្ខុមកនេះ ។ ពួកអាគន្តុកភិក្ខុទាំងនោះមានសេចក្តីសង្ស័យហើយមិន
ពិនិត្យមើល លុះមិនពិនិត្យមើលហើយក៏បោកណោក ត្រូវអាបត្តិទុក្កដ ។ បេ ។

ទុដ្ឋុល្លស្ស ។បេ។ តេ វេមតិកា វិចិនន្តិ វិចិនិត្វា ន បស្សន្តិ អបស្សិត្វា បក្កមន្តិ អនាបត្តិ ។ តេ វេមតិកា វិចិនន្តិ វិចិនិត្វា បស្សន្តិ បស្សិត្វា ឯកតោ បក្កមន្តិ អនាបត្តិ ។ តេ វេមតិកា វិចិនន្តិ វិចិនិត្វា បស្សន្តិ បស្សិត្វា បាដេក្កំ បក្កមន្តិ អាបត្តិ ទុក្កដស្ស ។ តេ វេមតិកា វិចិនន្តិ វិចិនិត្វា បស្សន្តិ បស្សិត្វា នស្សន្តុ ឥមេ វិនស្សន្តុ ឥមេ កិមេហិ អម្ហាកន្តិ ភេទបុរេក្ខារា បក្កមន្តិ អាបត្តិ ថុល្លច្ចយស្ស ។

(៣៧) ឥធ បន ភិក្ខវេ អាគន្តុកា ភិក្ខូ បស្សន្តិ អាវាសិកេ ភិក្ខូ នានាសំវាសកេ ។ តេ សមានសំវាសកទិដ្ឋឹ បដិលភន្តិ សមានសំវាសកទិដ្ឋឹ បដិលភិត្វា ន បុច្ឆន្តិ អបុច្ឆិត្វា ឯកតោ បក្កមន្តិ អនាបត្តិ ។បេ។ តេ បុច្ឆន្តិ បុច្ឆិត្វា នាភិវិតរន្តិ



ពួកអាវាសិកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យហើយពិនិត្យមើល លុះពិនិត្យហើយមិនឃើញ លុះមិនឃើញហើយ ក៏ចៀសចេញទៅ មិនត្រូវអាបត្តិទេ ។ ពួកអាវាសិកទាំងនោះមានសេចក្ដីសង្ស័យហើយពិនិត្យមើល លុះពិនិត្យមើលហើយឃើញ លុះឃើញហើយក៏ចៀសចេញជាមួយគ្នា មិនត្រូវអាបត្តិទេ ។ ពួកអាវាសិកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យហើយពិនិត្យមើល លុះពិនិត្យមើលហើយឃើញ លុះឃើញហើយក៏ចៀសចេញរៀងខ្លួន ត្រូវអាបត្តិទុក្កដ ។ ពួកអាវាសិកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យហើយពិនិត្យមើល លុះពិនិត្យមើលហើយឃើញ លុះឃើញហើយក៏មានបំណងទីទៃបែកសង្ឃដោយគិតថា ចូរភិក្ខុទាំងនុះបាត់ទៅចុះ ចូរភិក្ខុទាំងនុះវិនាសទៅចុះ ត្រូវការអ្វីដោយភិក្ខុទាំងនោះដល់យើងហើយ ក៏ចៀសចេញទៅ ត្រូវអាបត្តិថុល្លច្ច័យ ។

(៣៧) ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើបរិសទជាពួកអាគន្តុកភិក្ខុបានឃើញពួកអាវាសិកភិក្ខុមានសំវាសផ្សេងគ្នា ។ ពួកអាគន្តុកភិក្ខុទាំងនោះត្រឡប់បានសេចក្ដីយល់ថា មានសំវាសស្មើគ្នាវិញ លុះត្រឡប់បានសេចក្ដីយល់ថាមានសំវាសស្មើគ្នាហើយមិនសួរ (លទ្ធិ) លុះមិនសួរហើយក៏ចៀសចេញជាមួយគ្នាទៅ មិនត្រូវអាបត្តិទេ ។បេ។ ពួកអាគន្តុកភិក្ខុទាំងនោះសួរ លុះសួរហើយក៏មិនអាចត្រួសត្រាយបាន គឺមិន

អនភិវិតរិត្វា ឯកតោ បវារេន្តិ អាបត្តិ ទុក្កដស្ស ។ តេ បុច្ឆន្តិ បុច្ឆិត្វា នាភិវិតរន្តិ អនភិវិតរិត្វា បាដេក្កំ បវារេន្តិ អនាបត្តិ ។ ឥធ បន ភិក្ខវេ អាគន្តុកា ភិក្ខូ បស្សន្តិ អាវាសិកេ ភិក្ខូ សមានសំវាសកេ ។ តេ នានាសំវាសកទិដ្ឋឹ បដិលភន្តិ នានាសំវាសកទិដ្ឋឹ បដិលភិត្វា ន បុច្ឆន្តិ អបុច្ឆិត្វា ឯកតោ បវារេន្តិ អាបត្តិ ទុក្កដស្ស ។ បេ ។ តេ បុច្ឆន្តិ អបុច្ឆិត្វា អភិវិតរន្តិ អភិវិតរិត្វា បាដេក្កំ បវារេន្តិ អាបត្តិ ទុក្កដស្ស ។ តេ បុច្ឆន្តិ បុច្ឆិត្វា អភិវិតរន្តិ អភិវិតរិត្វា ឯកតោ បវារេន្តិ អនាបត្តិ ។ តេ បុច្ឆន្តិ បុច្ឆិត្វា នាភិវិតរន្តិ អនភិវិតរិត្វា បាដេក្កំ បវារេន្តិ អនាបត្តិ ។ ឥធ បន ភិក្ខវេ អាគន្តុកា ភិក្ខូ បស្សន្តិ អាវាសិកេ ភិក្ខូ នានាសំវាសកេ ។ តេ សមានសំវាសកទិដ្ឋឹ បដិលភន្តិ



គឺឲ្យភិក្ខុអស់នោះលះបង់ទិដ្ឋិសង្ខាន លុះស្រាយសង្ស័យមិនបានហើយ ក៏បវារណាជាមួយគ្នាទៅ ត្រូវអាបត្តិទុក្កដ ។ ពួកអាគន្តុកភិក្ខុទាំងនោះសួរ លុះសួរហើយក៏មិនអាចស្រាយសង្ស័យបាន លុះស្រាយសង្ស័យមិនបានហើយ ក៏បវារណាឡែកគ្នា មិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើប្រសិនជាពួកអាគន្តុកភិក្ខុឃើញពួកអាវាសិកភិក្ខុមានសំវាសស្មើគ្នា ។ ពួកអាគន្តុកភិក្ខុទាំងនោះត្រឡប់បានសេចក្តីយល់ថា ពួកអាវាសិកភិក្ខុមានសំវាសផ្សេងគ្នាទៅវិញ លុះត្រឡប់បានសេចក្តីយល់ថាមានសំវាសផ្សេងគ្នាហើយមិនសួរ (សោះ) លុះមិនសួរហើយក៏បវារណាជាមួយគ្នាទៅ ត្រូវអាបត្តិទុក្កដ ។ បេ ។ ពួកអាគន្តុកភិក្ខុទាំងនោះសួរ លុះសួរហើយក៏ស្រាយសង្ស័យបាន គឺឲ្យពួកអាវាសិកភិក្ខុលះបង់ទិដ្ឋិសង្ខាន លុះស្រាយសង្ស័យបានហើយក៏បវារណាឡែកគ្នា ត្រូវអាបត្តិទុក្កដ ។ ពួកអាគន្តុកភិក្ខុទាំងនោះសួរ លុះសួរហើយក៏ស្រាយសង្ស័យបាន លុះស្រាយសង្ស័យបានហើយ ក៏បវារណាជាមួយគ្នា មិនត្រូវអាបត្តិទេ ។ ពួកអាគន្តុកភិក្ខុទាំងនោះសួរ លុះសួរហើយស្រាយសង្ស័យមិនបាន លុះស្រាយសង្ស័យមិនបានហើយ ក៏បវារណាឡែកគ្នាទៅ មិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាគន្តុកភិក្ខុបានឃើញពួកអាវាសិកភិក្ខុមានសំវាសផ្សេងគ្នា ។ (តែ) ពួកអាគន្តុកភិក្ខុទាំងនោះ ត្រឡប់បានសេចក្តីយល់ថា ពួកអាវាសិកភិក្ខុ

សមានសំវាសកទិដ្ឋឹ បដិលភិត្វា ន បុច្ឆន្តិ អបុច្ឆិត្វា ឯកតោ ឧបោសថំ ករោន្តិ អនាបត្តិ ។ បេ ។ តេ បុច្ឆន្តិ បុច្ឆិត្វា នាភិវិតរន្តិ អនភិវិតរិត្វា ឯកតោ ឧបោសថំ ករោន្តិ អាបត្តិ ទុក្កដស្ស ។ តេ បុច្ឆន្តិ បុច្ឆិត្វា នាភិវិតរន្តិ អនភិវិតរិត្វា បាដេក្កំ ឧបោសថំ ករោន្តិ អនាបត្តិ ។ ឥធ បន ភិក្ខវេ អាវាសិកា ភិក្ខូ បស្សន្តិ អាគន្តុកេ ភិក្ខូ សមានសំវាសកេ ។ តេ នានាសំវាសកទិដ្ឋឹ បដិលភន្តិ នានាសំវាសកទិដ្ឋឹ បដិលភិត្វា ន បុច្ឆន្តិ អបុច្ឆិត្វា ឯកតោ ឧបោសថំ ករោន្តិ អាបត្តិ ទុក្កដស្ស ។ បេ ។ តេ បុច្ឆន្តិ បុច្ឆិត្វា អភិវិតរន្តិ អភិវិតរិត្វា បាដេក្កំ ឧបោសថំ ករោន្តិ អាបត្តិ ទុក្កដស្ស ។ តេ បុច្ឆន្តិ បុច្ឆិត្វា អភិវិតរន្តិ អភិវិតរិត្វា ឯកតោ ឧបោសថំ ករោន្តិ អនាបត្តិ ។

(៣៨) ន ភិក្ខវេ តទហុបោសថេ សភិក្ខុកា អាវាសា អភិក្ខុកោ អាវាសោ គន្តព្វោ អញ្ញត្រ សង្ឃេន





មានសំវាសស្មើគ្នាទៅវិញ លុះត្រឡប់បានសេចក្តីយល់ថា ពួកភិក្ខុ មានសំវាសស្មើគ្នាហើយមិនសួរ លុះមិនសួរហើយក៏ធ្វើឧបោសថជាមួយគ្នា ទៅមិនត្រូវអាបត្តិទេ ។ បេ ។ ពួកអាវាសិកភិក្ខុទាំងនោះសួរ លុះសួរហើយ ស្រឡះសង្ស័យមិនបាន លុះស្រឡះសង្ស័យមិនបានហើយក៏ធ្វើឧបោសថជាមួយគ្នាទៅ ត្រូវអាបត្តិទុក្កដ ។ ពួកអាវាសិកភិក្ខុទាំងនោះសួរ លុះសួរហើយស្រឡះសង្ស័យមិនបាន លុះស្រឡះសង្ស័យមិនបានហើយក៏ធ្វើឧបោសថឡែកគ្នា មិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាវាសិកភិក្ខុ បានឃើញពួកអាគន្តុកភិក្ខុមានសំវាសស្មើគ្នា ។ (ក) ពួកអាវាសិកភិក្ខុទាំងនោះត្រឡប់បានសេចក្តីយល់ថា ពួកអាគន្តុកភិក្ខុមានសំវាសផ្សេងគ្នាទៅវិញ លុះត្រឡប់បានសេចក្តីយល់ថាមានសំវាសផ្សេងគ្នាហើយមិនសួរ លុះមិនសួរហើយក៏ធ្វើឧបោសថជាមួយគ្នាទៅ ត្រូវអាបត្តិទុក្កដ ។ បេ ។ ពួកអាវាសិកភិក្ខុទាំងនោះសួរ លុះសួរហើយស្រឡះសង្ស័យបាន លុះស្រឡះសង្ស័យបានហើយក៏ធ្វើឧបោសថឡែកគ្នា ត្រូវអាបត្តិទុក្កដ ។ ពួកអាវាសិកភិក្ខុទាំងនោះសួរ លុះសួរហើយស្រឡះសង្ស័យបាន លុះស្រឡះសង្ស័យបានហើយក៏ធ្វើឧបោសថជាមួយគ្នាទៅ មិនត្រូវអាបត្តិទេ ។

(៣៨) ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថនោះមិនត្រូវភិក្ខុទាំងឡាយចេញពីអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលគ្មានភិក្ខុទេ

អញ្ញត្រ អន្តរាយា ។ ន ភិក្ខវេ តទហុបោសថេ សភិក្ខុកា អាវាសា អភិក្ខុកោ អនាវាសោ គន្តព្វោ អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។ ន ភិក្ខវេ តទហុបោសថេ សភិក្ខុកា អាវាសា អភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។ ន ភិក្ខវេ តទហុបោសថេ សភិក្ខុកា អនាវាសា អភិក្ខុកោ អាវាសោ គន្តព្វោ អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។ ន ភិក្ខវេ តទហុបោសថេ សភិក្ខុកា អនាវាសា អភិក្ខុកោ អនាវាសោ គន្តព្វោ អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។ ន ភិក្ខវេ តទហុបោសថេ សភិក្ខុកា អនាវាសា អភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។ ន ភិក្ខវេ តទហុបោសថេ សភិក្ខុកា អាវាសា វា អនាវាសា វា អភិក្ខុកោ អាវាសោ គន្តព្វោ អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។ ន ភិក្ខវេ តទហុបោសថេ សភិក្ខុកា អាវាសា វា អនាវាសា វា



វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថនោះ មិនត្រូវភិក្ខុទាំងឡាយចេញពីអាវាសដែលមានភិក្ខុ ទៅកាន់អនាវាស (ទីមិនមែនអាវាស) ដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថនោះមិនត្រូវភិក្ខុចេញពីអាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថនោះមិនត្រូវភិក្ខុចេញពីអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថនោះ មិនត្រូវភិក្ខុចេញពីអនាវាសដែលមានភិក្ខុទៅកាន់អនាវាសដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថនោះមិនត្រូវភិក្ខុចេញពីអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថនោះ មិនត្រូវភិក្ខុចេញពីអាវាសឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថនោះ មិនត្រូវភិក្ខុចេញពីអាវាសឬអនា-

អភិក្ខុកោ អនាវាសោ គន្តព្វោ អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។ ន ភិក្ខវេ តទហុបវារណាយ សភិក្ខុកា អាវាសា វា អនាវាសា វា អភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។ ន ភិក្ខវេ តទហុបវារណាយ សភិក្ខុកា អាវាសា សភិក្ខុកោ អាវាសោ គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។ ន ភិក្ខវេ តទហុបវារណាយ សភិក្ខុកា អាវាសា សភិក្ខុកោ អនាវាសោ គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។ ន ភិក្ខវេ តទហុបវារណាយ សភិក្ខុកា អាវាសា សភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។ ន ភិក្ខវេ តទហុបវារណាយ សភិក្ខុកា អនាវាសា សភិក្ខុកោ អាវាសោ ។ បេ ។ អនាវាសោ ។ បេ ។ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ



វាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះមិនត្រូវភិក្ខុចេញពីអាវាសឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះមិនត្រូវភិក្ខុចេញពីអាវាសដែលមានភិក្ខុទៅកាន់អាវាសដែលមានភិក្ខុនោះទេ គឺអាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេងគ្នា វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះមិនត្រូវភិក្ខុចេញពីអាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលមានភិក្ខុទេ គឺអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេងគ្នា វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះមិនត្រូវភិក្ខុចេញពីអាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុទេ គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេងគ្នា វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុចេញពីអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុទេ ។ បេ ។ ទៅកាន់អនាវាស ។ បេ ។ ទៅកាន់អាវាសឬអនាវាសទេ គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាស

នានាសំវាសកា អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។ ន ភិក្ខវេ តទហុបវារណាយ សភិក្ខុកា អាវាសា វា អនាវាសា វា សភិក្ខុកោ អាវាសោ ។ បេ ។ អនាវាសោ ។ បេ ។ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។ គន្តព្វោ ភិក្ខវេ តទហុបវារណាយ សភិក្ខុកា អាវាសា សភិក្ខុកោ អាវាសោ ។ បេ ។ អនាវាសោ ។ បេ ។ អាវាសោ វា អនាវាសោ វា យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុំ ។ គន្តព្វោ ភិក្ខវេ តទហុបវារណាយ សភិក្ខុកា អនាវាសា សភិក្ខុកោ អាវាសោ ។ បេ ។ អនាវាសោ ។ បេ ។ អាវាសោ វា អនាវាសោ វា យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុំ ។ គន្តព្វោ ភិក្ខវេ តទហុបវារណាយ សភិក្ខុកា អាវាសា វា អនាវាសា វា សភិក្ខុកោ អាវាសោ ។ បេ ។ អនាវាសោ



ផ្សេងគ្នា វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ គឺថ្ងៃបវារណានោះ មិនត្រូវភិក្ខុចេញពីអាវាសឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុទេ ។បេ។ ទៅកាន់អនាវាសទេ ។បេ។ ទៅកាន់អាវាសឬអនាវាសទេ គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេងគ្នា វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ គឺថ្ងៃបវារណានោះ ភិក្ខុត្រូវចេញពីអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុបាន ។បេ។ ទៅកាន់អនាវាស ។បេ។ ទៅកាន់អាវាសឬអនាវាស គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយភិក្ខុដឹងថាអាវាសណា អាត្មាអញអាចទៅទាន់ក្នុងថ្ងៃនេះជាប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ គឺថ្ងៃបវារណានោះ ភិក្ខុត្រូវចេញពីអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុបាន ។បេ។ ទៅកាន់អនាវាស ។បេ។ ទៅកាន់អាវាសឬអនាវាស គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយភិក្ខុដឹងថា អាវាសណា អាត្មាអញអាចទៅទាន់ក្នុងថ្ងៃនេះជាប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ គឺថ្ងៃបវារណានោះ ភិក្ខុត្រូវចេញពីអាវាសឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុបាន ។បេ។ ទៅកាន់អនាវាស ។បេ។

។ បេ ។ អាវាសោ វា អនាវាសោ វា យត្ថស្សុ ភិក្ខូ ស-
មានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ ។

[៣៩] ន ភិក្ខវេ ភិក្ខុនិយា និសិន្នបរិសាយ បវារេ-
តព្វំ យោ បវារេយ្យ អាបត្តិ ទុក្កដស្ស ។ ន ភិក្ខវេ សិក្ខ-
មានាយ ន សាមណេរស្ស ន សាមណេរិយា ន សិក្ខំ
បច្ចក្ខាតកស្ស ន អន្តិមវត្ថុំ អជ្ឈាបន្នកស្ស និសិន្នប-
រិសាយ បវារេតព្វំ យោ បវារេយ្យ អាបត្តិ ទុក្កដស្ស ។ ន
ភិក្ខវេ អាបត្តិយា អទស្សនេ ឧក្ខិត្តកស្ស និសិន្នប-
រិសាយ បវារេតព្វំ យោ បវារេយ្យ យថាធម្មោ ការេតព្វោ ។
ន អាបត្តិយា អប្បដិកម្មេ ឧក្ខិត្តកស្ស ន បាបិកាយ
ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកស្ស និសិន្នបរិសាយ
បវារេតព្វំ យោ បវារេយ្យ យថាធម្មោ ការេតព្វោ ។
ន បណ្ឌកស្ស និសិន្នបរិសាយ បវារេតព្វំ យោ
បវារេយ្យ អាបត្តិ ទុក្កដស្ស ។ ន ថេយ្យសំវាស-
កស្ស ន តិត្ថិយបក្កន្តកស្ស ន តិរច្ឆានគតស្ស





ទៅកាន់អាវាសមួយនោះ គឺអាវាសមួយណាដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយភិក្ខុក៏ដឹងថាអាវាសណា អាត្មាអញអាចទៅដល់ក្នុងថ្ងៃនេះបាន ។

[៣៩] ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុបវារណាក្នុងបរិសទ្យដែលមានភិក្ខុនីអង្គុយជាមួយផងទេ ភិក្ខុណាបវារណា ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុបវារណាក្នុងបរិសទ្យដែលមានសិក្ខមានា សាមណេរ សាមណេរី បុគ្គលអ្នកលាសិក្ខា បុគ្គលអ្នកត្រូវអន្តិមវត្ថុអង្គុយជាមួយផងទេ ភិក្ខុណាបវារណា ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុបវារណាក្នុងបរិសទ្យដែលមានភិក្ខុត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិអង្គុយជាមួយផងទេ ភិក្ខុណាបវារណា ត្រូវតែឲ្យធ្វើភិក្ខុនោះតាមធម៌ (គឺឲ្យសំដែងអាបត្តិចេញ) ។ មិនត្រូវភិក្ខុបវារណាក្នុងបរិសទ្យដែលមានភិក្ខុត្រូវសង្ឃលើកវត្តព្រោះមិនសំដែងអាបត្តិ ភិក្ខុត្រូវសង្ឃលើកវត្តព្រោះមិនលះបង់ទិដ្ឋិអាក្រក់អង្គុយជាមួយផងទេ ភិក្ខុណាបវារណា ត្រូវតែឲ្យធ្វើភិក្ខុនោះតាមធម៌ ។ មិនត្រូវភិក្ខុបវារណាក្នុងបរិសទ្យដែលមានបណ្ឌក (ខ្ទើយ) អង្គុយជាមួយផងទេ ភិក្ខុណាបវារណា ត្រូវអាបត្តិទុក្កដ ។ មិនត្រូវភិក្ខុបវារណាក្នុងបរិសទ្យដែលមានបុគ្គលជាថេយ្យសំវាសក[១] បុគ្គលបែរចេញទៅចូលសាសនាតិរ្ថិយ តិរច្ឆាន

---

១ លួចសំវាស ។

ច មាតុឃាតកស្ស ច បិតុឃាតកស្ស ច អរហន្ត-ឃាតកស្ស ច ភិក្ខុនិទូសកស្ស ច សង្ឃភេទកស្ស ច លោហិតុប្បាទកស្ស ច ឧភតោព្យញ្ជនកស្ស បំសុទ្ធបរិសាយ បព្វាជេតព្វោ យោ បព្វាជេយ្យ អាបត្តិ ទុក្កដស្ស ។ ន ភិក្ខវេ សរិកសំឃប្បាវណាណាលេន បព្វាជេតព្វោ អញ្ញត្រ អវុឌ្ឍិកាយ បរិសាយ ។ ន ច ភិក្ខវេ អប្បាវណាយ បព្វាជេតព្វោ អញ្ញត្រ សង្ឃសាមគ្គិយាតិ ។

ទុតិយភាណវារំ និដ្ឋិតំ ។

[៦០] តេន ខោ បន សមយេន កោសលេសុ ជន-បទេសុ អញ្ញតរស្មឹ អាវាសេ គណហុប្បាវណាយ សមញ្ញ-គយំ[១] អហោសិ ។ ភិក្ខូ ជាសត្ថីសុ ភេកចិតាំ បព្វជុំ ។ ពាគវតោ បរិមន្ត្វំ អាពេទេសុំ ។ អនុជានាមិ ភិក្ខវេ ទេ-ភចិតាំ បព្វជេតុំ ។ ពាគ្វ្យតាំ សញ្ញាគយំ អហោសិ ។





បុគ្គលអ្នកសម្លាប់មាតា អ្នកសម្លាប់បិតា អ្នកសម្លាប់ព្រះអរហន្ត អ្នកប្រទូស្តភិក្ខុនី អ្នកបំបែកសង្ឃ អ្នកធ្វើលោហិតុប្បាទ (ធ្វើព្រះលោហិតព្រះពុទ្ធឲ្យពុះឡើង) បុគ្គលជាឧភតោព្យញ្ជនកៈ (មនុស្សមានភេទពីរ) អន្ទួយជាមួយផងដែរ ភិក្ខុណាបព្វជ្ជា ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុបព្វជ្ជា ដោយឲ្យបព្វជ្ជា ឈ្មោះជាបរិក្ខារ (មានបរិក្ខារត្រូវគេរឹបអូសយកហើយ) រៀរលែងតែបរិសុទ្ធមិនទាន់ត្រាក ចេញ ។ ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុបព្វជ្ជាក្នុងថ្ងៃមិនមែនថ្ងៃបព្វជ្ជាទេ រៀរលែងតែសង្ឃសាមគ្គីបព្វជ្ជាចេញ ។

ចប់ ទុតិយភាណវារៈ ។

[៦០] គឺសម័យនោះឯង មានអាវាសមួយក្នុងកោសលជនបទកើតសញ្ញាភ័យ(១) ក្នុងថ្ងៃបព្វជ្ជានោះ ។ ភិក្ខុទាំងឡាយមិនអាចនឹងបព្វជ្ជា ដាក់ភេទចិតាបព្វជ្ជា (បព្វជ្ជាជាគំរប់ញាតិ) បាន ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបព្វជ្ជាជាភេទចិតាបព្វជ្ជា (បព្វជ្ជាជាគំរប់ពីរដង) បាន ។ (កាលនោះ) សញ្ញាភ័យពិតជាទាំង

ភិក្ខូ នាសក្ខឹសុ ទ្វេវាចិកំ បវារេតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឯកវាចិកំ បវារេតុន្តិ ។ ពាឡ្ហតរំ សពរភយំ អហោសិ ។ ភិក្ខូ នាសក្ខឹសុ ឯកវាចិកំ បវារេតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សមានវស្សិកំ បវារេតុន្តិ ។ តេន ខោ បន សមយេន អញ្ញតរស្មឹ អាវាសេ តទហុ បវារណាយ មនុស្សេហិ ទានំ ទេន្តេហិ យេភុយ្យេន រត្តិ ខេបិតា ហោតិ ។ អថ ខោ តេសំ ភិក្ខូនំ ឯតទហោសិ មនុស្សេហិ ទានំ ទេន្តេហិ យេភុយ្យេន រត្តិ ខេបិតា សចេ សង្ឃោ តេវាចិកំ បវារេស្សតិ អប្បវារិតោវ សង្ឃោ ភវិស្សតិ អថាយំ រត្តិ វិភាយិស្សតិ កថំ នុ ខោ អម្ហេហិ បដិបជ្ជិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុប្បវារណាយ មនុស្សេហិ ទានំ ទេន្តេហិ យេភុយ្យេន រត្តិ ខេបិតា ហោតិ ។



ជាងមុនកើតឡើងទៀត ។ ភិក្ខុទាំងឡាយមិនអាចនឹងបវារណាជាទ្វេវាចិកបវារណាបាន ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបវារណាជាឯកវាចិកបវារណា (បវារណាតែម្ដងៗ) បាន ។ សពរភ័យក៏កាន់តែខ្លាំងជាងមុនកើតឡើងទៀត ។ (កាលនោះ) ភិក្ខុទាំងឡាយមិនអាចបវារណាជាឯកវាចិកបវារណាបាន ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបវារណា ជាសមានវស្សិកបវារណា (ឲ្យភិក្ខុដែលមានវស្សាស្មើៗ គ្នាបវារណាព្រមគ្នា) បាន ។ ក៏សម័យនោះឯង ក្នុងអាវាសមួយ មានពួកមនុស្ស (មក) ឲ្យទានក្នុងថ្ងៃបវារណានោះ អស់រាត្រីជាច្រើន (ជិតភ្លឺ) ។ ទើបភិក្ខុទាំងឡាយនោះមានសេចក្ដីត្រិះរិះដូច្នេះថា ពួកមនុស្សទាំងនេះឲ្យទានអស់រាត្រីជាច្រើន បើសង្ឃនឹងបវារណាជាតេវាចិកបវារណា សង្ឃនឹងមិនបានបវារណាមិនទាន់ ដ្បិតរាត្រីនេះជិតភ្លឺហើយ តើយើងទាំងឡាយត្រូវប្រតិបត្តិដូចម្ដេច ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកមនុស្សឲ្យទានក្នុងថ្ងៃបវារណានោះ អស់រាត្រីជាច្រើន ។ បើពួកភិក្ខុទាំង

តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ មនុស្សេហិ ទានំ ទេន្តេហិ យេភុយ្យេន រត្តិ ខេបិតា សចេ សង្ឃោ តេវាចិកំ បវារេស្សតិ អប្បវារិតោ ច សង្ឃោ ភវិស្សតិ អថាយំ រត្តិ វិភាយិស្សតីតិ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ មនុស្សេហិ ទានំ ទេន្តេហិ យេភុយ្យេន រត្តិ ខេបិតា ។ សចេ សង្ឃោ តេវាចិកំ បវារេស្សតិ អប្បវារិតោ ច សង្ឃោ ភវិស្សតិ អថាយំ រត្តិ វិភាយិស្សតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ទ្វេវាចិកំ ឯកវាចិកំ សមានវស្សិកំ បវារេយ្យាតិ ។ ៤៤ ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុ បវារណាយ ភិក្ខូហិ ធម្មំ ភណន្តេហិ សុត្តន្តិកេហិ សុត្តន្តំ សង្គាយន្តេហិ វិនយធរេហិ វិនយំ វិនិច្ឆិនន្តេហិ ធម្មកថិកេហិ ធម្មំ សាកច្ឆន្តេហិ ភិក្ខូហិ កលហំ ករោន្តេហិ យេភុយ្យេន រត្តិ ខេបិតា ហោតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ ភិក្ខូហិ កលហំ ករោន្តេហិ យេភុយ្យេន រត្តិ ខេបិតា សចេ សង្ឃោ តេវាចិកំ បវារេស្សតិ អប្បវារិតោ ច សង្ឃោ ភវិស្សតិ អថាយំ



ដោយមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកមនុស្សដែលឲ្យទានអស់រាត្រីជាច្រើន បើសង្ឃនឹងបវារណាជាតេវាចិកបវារណា សង្ឃនឹងបវារណាមិនទាន់ ស្រែករាត្រីនឹងភ្លឺហើយ ។ ត្រូវភិក្ខុដែលឈ្លាសប្រតិពលឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ផ្សែកមាន) ពួកមនុស្សអ្នកឲ្យទានអស់រាត្រីជាច្រើន ។ បើសង្ឃនឹងបវារណាជាតេវាចិកបវារណា សង្ឃនឹងបវារណាមិនទាន់ទេ ស្រែករាត្រីនឹងភ្លឺហើយ ។ បើកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃបវារណា ជាទ្វេវាចិកបវារណា ជាឯកវាចិកបវារណា ជាសមានវស្សិកាបវារណា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសនោះ បើក្នុងថ្ងៃបវារណាមួយមានពួកភិក្ខុនិយាយធម៌ ពួកភិក្ខុរៀនព្រះសូត្រសង្គាយនា (ទៀងទាត់) ព្រះសូត្រ ពួកភិក្ខុជាវិនយធរវិនិច្ឆ័យវិន័យ ពួកភិក្ខុធម្មកថិកសាកច្ឆាធម៌ ពួកភិក្ខុធ្វើសេចក្តីឈ្លោះគ្នា ក្នុងថ្ងៃបវារណានោះ អស់រាត្រីជាច្រើន ។ បើពួកភិក្ខុក្នុងអាវាសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកភិក្ខុធ្វើសេចក្តីឈ្លោះគ្នា អស់រាត្រីជាច្រើន បើសង្ឃនឹងបវារណា ជាតេវាចិកបវារណា សង្ឃនឹងបវារណាមិនទាន់

វត្ថុ វិកាលេ អធិករណំ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ
ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ ភិក្ខូនំ ក-
លហំ ភណ្ឌនំ យេភុយ្យេន វត្ថុ វេមតិកា ។ សចេ
សង្ឃោ តេហិ ចិត្តំ បកាសេត្វា អត្ថុក្ករោតិ ។ សង្ឃោ
ភវិស្សតិ អជ្ឈាយំ វត្ថុ វិកាលិ ។ យទិ សង្ឃស្ស
បត្តកល្លំ សង្ឃោ ទ្វេកចិត្តំ ឯកាភិចិត្តំ សមាទិយេយ្យ
បកាសេយ្យាតិ ។ តេន ខោ បន សមយេន កោសម្ពិយំ
ជនបទេសុ អញ្ញតរស្មិំ អាវាសេ សម្បហុលា អាវាសិកា
មហាភិក្ខុសង្ឃោ សន្និបតិតោ ហោតិ ។ បរិក្ខិត្តា អ-
នោវស្សិកា ហោតិ មហា ច អាវាសោ ទុក្ខិតោ ហោតិ ។
អថខោ តេសំ ភិក្ខូនំ ឯតទហោសិ អយំ ខោ មហាភិក្ខុ-
សង្ឃោ សន្និបតិតោ បរិក្ខិត្តា អនោវស្សិកា មហា ច អា-
វាសោ ទុក្ខិតោ សចេ សង្ឃោ តេហិ ចិត្តំ បកាសេត្វា អធិ-
ករិតោ ។ សង្ឃោ ភវិស្សតិ អជ្ឈាយំ អាវាសោ បាវស្សិកោ
គាថំ ន ខោ អត្ថុបតិ បដិបជ្ជិតព្វន្តិ ។ តទាតោ ឯក-
មត្តំ អាវាសេសុ ។ តេ ច បន ភិក្ខូ អញ្ញតរស្មិំ



ព្រោះកើតទៀតក្តីហើយ ។ ត្រូវភិក្ខុដែលឈ្លាសប្រតិពលឲ្យសង្ឃដឹងថា
បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ពួកភិក្ខុប្រើសេចក្តីឈ្លោះគ្នា
អស់ក្តីជាច្រើន ។ បើសង្ឃនឹងវិនិច្ឆ័យអធិករណ៍ជាគរុបាចិត្តអធិករណ៍ សង្ឃ
នឹងវិនិច្ឆ័យអធិករណ៍មិនទាន់ ព្រោះកើតទៀតក្តីហើយ បើអម្បូរមានកាលគួរដល់
សង្ឃហើយ គួរសង្ឃអធិករណ៍ ជាប្រក្រតីអធិករណ៍ ជាឯកពិតអធិករ-
ណ ជាសមាធវស្តីអធិករណ៍ ។ ក្នុងការស្មួយ ក្នុងកោសលជន-
បទមានភិក្ខុសង្ឃច្រើនប្រជុំគ្នាក្នុងវិហារអធិករណ៍នោះ ទាំងដែលគស់ក្បៀចកំបែ
មហាមេឃគាំនរទៀប (គឺទឹកធ្លាក់ភ្លៀងធំ) ។ ទើបភិក្ខុទាំងនោះមាន
សេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុសង្ឃនេះប្រជុំគ្នាច្រើនម៉្លេះ ទាំងដែលគស់ក្បៀច
កំបែ មហាមេឃគាំនរទៀបហើយ បើសង្ឃនឹងវិនិច្ឆ័យអធិករណ៍ជាគរុបាចិត្តអធិក-
រណ៍ សង្ឃនឹងវិនិច្ឆ័យអធិករណ៍មិនហើយជាប្រាកដ ភ្លៀងនេះនឹងធ្លាក់ចុះមិន
ខាន គួរគប្បីប្រតិបត្តិដូចម្តេចហ្ន៎ ។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរ
នុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់បន្ទូលថា ម្នាលភិក្ខុ
ទាំងឡាយ ក្នុងអាវាសនោះ បើក្នុងអាវាសណាមួយមានភិក្ខុសង្ឃច្រើន

អាវាសេ តទហុ បវារណាយ មហាភិក្ខុសង្ឃោ សន្និប-
តិតោ ហោតិ ។ បរិត្តញ្ច អនោវស្សិកំ ហោតិ មហា ច
មេឃោ ឧគ្គតោ ហោតិ ។ អថ ខោ ភិក្ខូនំ ឯតទហោសិ
អយំ ខោ មហាភិក្ខុសង្ឃោ សន្និបតិតោ បរិត្តញ្ច អនោ-
វស្សិកំ មហា ច មេឃោ ឧគ្គតោ សចេ សង្ឃោ តេវាចិកំ
បវារេស្សតិ អប្បវារិតោ ច សង្ឃោ ភវិស្សតិ អថាយំ
មេឃោ បវស្សិស្សតីតិ ។ ព្យត្តេន ភិក្ខុនា បដិពលេន
សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ
មហាភិក្ខុសង្ឃោ សន្និបតិតោ ។ បរិត្តញ្ច អនោវស្សិកំ
មហា ច មេឃោ ឧគ្គតោ ។ សចេ សង្ឃោ តេវាចិកំ
បវារេស្សតិ អប្បវារិតោ ច សង្ឃោ ភវិស្សតិ អថាយំ មេ-
ឃោ បវស្សិស្សតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ
ទ្វេវាចិកំ ឯកវាចិកំ សមានវស្សិកំ បវារេយ្យាតិ ។
ឥធ បន ភិក្ខវេ អញ្ញតរស្មឹ អាវាសេ តទហុ បវារណា-
យ រាជន្តរាយោ ហោតិ ។ បេ ។ ចោរន្តរាយោ ហោតិ ។
អគ្យន្តរាយោ ហោតិ ។ ឧទកន្តរាយោ ហោតិ ។



ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ ៗ ទីគង់ជ្រៀងក៏តូច ភ្លៀងធំក៏តាំងឡើងហើយ ។
បើពួកភិក្ខុក្នុងអាវាសនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុសង្ឃនេះ
ប្រជុំគ្នាច្រើនពេកម៉្លេះ ទីដែលគង់ជ្រៀងក៏តូច ភ្លៀងធំក៏តាំងឡើងហើយ
បើសង្ឃនឹងបវារណាជាតេវាចិកបវារណា សង្ឃនឹងបវារណាមិនហើយជា
ប្រាកដ ភ្លៀងនឹងធ្លាក់ចុះមិនខាន ។ ត្រូវភិក្ខុដែលឈ្លាសប្រតិពលឲ្យសង្ឃ
ដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ([illegible]) ភិក្ខុសង្ឃ
នេះប្រជុំគ្នាច្រើនណាស់ ។ ទីគង់ជ្រៀងក៏តូច ភ្លៀងធំក៏តាំងឡើងហើយ ។
បើសង្ឃនឹងបវារណា ជាតេវាចិកបវារណា សង្ឃនឹងបវារណាមិនហើយ
ជាប្រាកដ ភ្លៀងនឹងធ្លាក់ចុះមិនខាន ។ បើកម្មមានកាលគួរដល់សង្ឃហើយ
សង្ឃគប្បីបវារណា ជាទ្វេវាចិកបវារណា ជាឯកវាចិកបវារណា ជាសមាន-
វស្សិកបវារណា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាស
ណាមួយមានការអន្តរាយអំពីស្តេច ក្នុងថ្ងៃបវារណានោះ ។ បេ ។ មានការ
អន្តរាយអំពីចោរ ។ មានការអន្តរាយអំពីភ្លើង ។ មានការអន្តរាយអំពីទឹក ។

មនុស្សន្តរាយោ ហោតិ ។ អមនុស្សន្តរាយោ ហោតិ ។ វាឡន្តរាយោ ហោតិ ។ សិរឹសបន្តរាយោ ហោតិ ។ ជីវិតន្តរាយោ ហោតិ ។ ព្រហ្មចរិយន្តរាយោ ហោតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ ព្រហ្មចរិយន្តរាយោ សចេ សង្ឃោ តេវាចិកំ បវារេស្សតិ អប្បវារិតោ វ សង្ឃោ ភវិស្សតិ អថាយំ ព្រហ្មចរិយន្តរាយោ ភវិស្សតីតិ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ព្រហ្មចរិយន្តរាយោ សចេ សង្ឃោ តេវាចិកំ បវារេស្សតិ អប្បវារិតោ វ សង្ឃោ ភវិស្សតិ អថាយំ ព្រហ្មចរិយន្តរាយោ ភវិស្សតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ទ្វេវាចិកំ ឯកវាចិកំ សមានវស្សិកំ បវារេយ្យាតិ ។

[៤០] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សាបត្តិកា បវារេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ សាបត្តិកេន បវារេតព្វំ យោ បវារេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ យោ សា-



មានការអន្តរាយអំពីមនុស្ស ១ មានការអន្តរាយអំពីអមនុស្ស (មានខ្មោចចំណោចជាដើម) ១ មានការអន្តរាយអំពីសត្វសាហាវ ១ មានការអន្តរាយអំពីសត្វលូនវារ (ពស់ខ្លួកសំប) ១ មានការអន្តរាយដល់ជីវិត ១ មានការអន្តរាយដល់ព្រហ្មចារ្យ ១ បើពួកភិក្ខុទាំងនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាសេចក្តីអន្តរាយដល់ព្រហ្មចារ្យ បើសង្ឃនឹងបវារណាជាតេវាចិកបវារណា សង្ឃនឹងបវារណាមិនទាន់ហើយជាប្រាកដ ទីនឹងមានការអន្តរាយដល់ព្រហ្មចារ្យនេះមិនខាន ១ ត្រូវភិក្ខុឈ្លាសប្រតិពលឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ នេះជាការអន្តរាយដល់ព្រហ្មចារ្យ បើសង្ឃនឹងបវារណាជាតេវាចិកបវារណា សង្ឃនឹងបវារណាមិនទាន់ហើយជាប្រាកដ ការអន្តរាយដល់ព្រហ្មចារ្យនេះមុខជានឹងកើតឡើងមិនខាន ១ បើគួរមានកាលគួរដល់សង្ឃហើយ គួរសង្ឃបវារណាជាទ្វេវាចិកបវារណា ជាឯកវាចិកបវារណា ជាសមានវស្សិកបវារណា ១

[៤១] គឺសម័យនោះឯង ពួកភិក្ខុឆព្វគ្គិយ៍មានអាបត្តិ (ជាត្រូវអាបត្តិ) ហើយបវារណា ១ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ១ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានអាបត្តិមិនត្រូវបវារណាទេ ភិក្ខុណាបវារណា ត្រូវអាបត្តិទុក្កដ ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមានអាបត្តិហើយបវារណា

បត្តិកោ បវារេតិ តស្ស ឱកាសំ ការាបេត្វា អាបត្តិយា ចោទេតុន្តិ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឱកាសំ ការាបិយមានា ន ឥច្ឆន្តិ ឱកាសំ កាតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឱកាសំ អករោន្តស្ស បវារណំ ឋបេតុំ ។ ឯវញ្ច បន ភិក្ខវេ ឋបេតព្វា តទហុ បវារណាយ ចាតុទ្ទសេ វា បណ្ណរសេ វា តស្មឹ បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ ឧទាហរិតព្វំ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ បុគ្គលោ សាបត្តិកោ បវារេតិ តស្ស បវារណំ ឋបេមិ ន តស្មឹ សម្មុខីភូតេ បវារេតព្វន្តិ ។ ឋបិតា ហោតិ បវារណាតិ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ បុរម្ហាកំ បេសលា ភិក្ខូ បវារណំ ឋបេន្តីតិ បដិកច្ចេវ សុទ្ធានំ ភិក្ខូនំ អនាបត្តិកានំ អវត្ថុស្មឹ អការណេ បវារណំ ឋបេន្តិ បវារិតានម្បិ បវារណំ ឋបេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។



គប្បីអនុញ្ញាតឲ្យភិក្ខុសុំឱកាសហើយចោទអាបត្តិដល់ភិក្ខុនោះ ។ ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុកាលដែលភិក្ខុឯទៀតសុំឱកាសមិនព្រមធ្វើឱកាសឲ្យ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឃាត់នូវបវារណាដល់ភិក្ខុដែលមិនធ្វើឱកាស (មិនបើកឲ្យ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវឃាត់បវារណាយ៉ាងនេះ គឺត្រូវភិក្ខុស្រែកក្នុងកណ្តាលសង្ឃចំពោះបុគ្គលនោះដែលមានខ្លួនចំពោះមុខក្នុងថ្ងៃបវារណានោះគឺថ្ងៃទី ១៤ ឬថ្ងៃទី ១៥ ថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បុគ្គលឈ្មោះនេះប្រកបដោយអាបត្តិហើយបវារណា ខ្ញុំសូមឃាត់នូវបវារណារបស់បុគ្គលនោះ មិនគួរសង្ឃបវារណាក្នុងទីបុគ្គលនោះដែលមានខ្លួនចំពោះមុខទេ ។ បវារណាឈ្មោះថា ភិក្ខុបានឃាត់ហើយ ។ ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុគិតថា ពួកភិក្ខុមានសីលជាទីស្រឡាញ់មុខជានឹងឃាត់បវារណារបស់ពួកយើងជាមុនហើយ ក៏ចាំក្រោះឃាត់បវារណាដល់ពួកភិក្ខុដែលបរិសុទ្ធមិនត្រូវអាបត្តិ ដោយឥតមានរឿងឥតមានហេតុផង ដែលចាំឃាត់បវារណាដល់ពួកភិក្ខុដែលបានបវារណាហើយផង ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះ

ច ភិក្ខវេ សុទ្ធានំ ភិក្ខូនំ អនាបត្តិកានំ អវត្ថុស្មិំ អការណេ បវារណា ឋបេតព្វា យោ ឋបេយ្យ អាបត្តិ ទុក្កដស្ស ។ ន ច ភិក្ខវេ បវារិតេនបិ បវារណា ឋបេតព្វា យោ ឋបេយ្យ អាបត្តិ ទុក្កដស្ស ។

(៦៦) យា ខោ ភិក្ខវេ ឋបិតា ហោតិ បវារណា ។ យា អដ្ឋបិតា ។ កតមញ្ច ភិក្ខវេ អដ្ឋបិតា ហោតិ បវារណា ។ តេវាចិកាយ ចេ ភិក្ខវេ បវារណាយ ភាសិតាយ លបិតាយ បរិយោសិតាយ បវារណំ ឋបេតិ អដ្ឋបិតា ហោតិ បវារណា ទ្វេវាចិកាយ ចេ ភិក្ខវេ ឯកវាចិកាយ ចេ ភិក្ខវេ សមានវស្សិកាយ ចេ ភិក្ខវេ បវារណាយ ភាសិតាយ លបិតាយ បរិយោសិតាយ បវារណំ ឋបេតិ អដ្ឋបិតា ហោតិ បវារណា ។ យា សា ភិក្ខវេ អដ្ឋបិតា ហោតិ បវារណា ។ កតមញ្ច ភិក្ខវេ ឋបិតា



ទ្រង់ត្រាស់បន្ទូលថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុឃាត់បវារណា ដល់ពួកភិក្ខុដែលបរិសុទ្ធ ដែលមិនត្រូវអាបត្តិ ដោយឥតមានរឿង ឥតមានហេតុទេ ភិក្ខុណាឃាត់ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឃាត់បវារណា ដល់ពួកភិក្ខុដែលបានបវារណាហើយទេ ភិក្ខុណាឃាត់ ត្រូវអាបត្តិទុក្កដ ។

(៦៦) ម្នាលភិក្ខុទាំងឡាយ បវារណាដែលភិក្ខុបានឃាត់ហើយ ដោយប្រការដូច្នេះឯង ។ បវារណាដែលភិក្ខុឃាត់មិនបានដូចមានសេចក្តីដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ បវារណាដែលភិក្ខុឃាត់មិនបានតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ជាការនៃតេវាចិកបវារណា ដែលសង្ឃបានសូត្រហើយ បានពោលហើយ បានបញ្ចប់ស្រេចហើយ បវារណានោះជាភិក្ខុឃាត់មិនបាន ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ជាការនៃទ្វេវាចិកបវារណា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ជាការនៃឯកវាចិកបវារណា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ជាការនៃសមានវស្សិកបវារណា ដែលសង្ឃបានសូត្រហើយ បានពោលហើយ បានបញ្ចប់ស្រេចហើយ បវារណានោះជាភិក្ខុឃាត់មិនបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បវារណាដែលភិក្ខុមិនត្រូវឃាត់ដូច្នេះ បានសំដែងមកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បវារណាដែលឈ្មោះថា

ហោតិ បវារណា ។ តេវាចិកាយ ចេ ភិក្ខវេ បវារណាយ ភាសិតាយ លបិតាយ អបរិយោសិតាយ(១) បវារណំ ឋបេតិ ឋបិតា ហោតិ បវារណា ។ ទ្វេវាចិកាយ ចេ ភិក្ខវេ ឯកវាចិកាយ ចេ ភិក្ខវេ សមានវស្សិកាយ ចេ ភិក្ខវេ បវារណាយ ភាសិតាយ លបិតាយ អបរិយោសិតាយ បវារណំ ឋបេតិ ឋបិតា ហោតិ បវារណា ។ ឯវំ ខោ ភិក្ខវេ ឋបិតា ហោតិ បវារណា ។

(៦៣) ឥធ បន ភិក្ខវេ តទហុបវារណាយ ភិក្ខុ ភិក្ខុស្ស បវារណំ ឋបេតិ ។ តញ្ចេ ភិក្ខុំ អញ្ញេ ភិក្ខូ ជានន្តិ អយំ ខោ អាយស្មា អបរិសុទ្ធកាយសមាចារោ អបរិសុទ្ធវចីសមាចារោ អបរិសុទ្ធាជីវោ ពាលោ អព្យត្តោ ន បដិពលោ អនុយុញ្ជិយមានោ អនុយោគំ ទាតុន្តិ ។ អលំ ភិក្ខុ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទន្តិ ឱមទ្ទិត្វា សង្ឃេន បវារេតព្វំ ។

១ ម. បរិយោសិតាយ ។



ភិក្ខុឃាត់បានតាមតែផ្លូវម្តេច ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ដោយការតេវាចិកបវារណាដែលសង្ឃបានសូត្រហើយ បានពោលហើយតែមិនទាន់ចប់ បវារណាឈ្មោះថាភិក្ខុបានឃាត់ហើយ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ដោយការទ្វេវាចិកបវារណា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណាដោយការឯកវាចិកបវារណា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ដោយការសមានវស្សិកបវារណា ដែលសង្ឃបានសូត្រហើយ បានពោលហើយតែមិនទាន់ចប់ បវារណាឈ្មោះថាភិក្ខុបានឃាត់ហើយ ។ ម្នាលភិក្ខុទាំងឡាយ បវារណាឈ្មោះថាភិក្ខុបានឃាត់ហើយដូចពោលមកនេះឯង ។

(៦៣) ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើប្រសិនជាមានភិក្ខុឃាត់បវារណារបស់ភិក្ខុដទៃក្នុងថ្ងៃបវារណានោះ ។ បើពួកភិក្ខុឯទៀតបានស្គាល់ភិក្ខុនោះថា លោកដ៏មានអាយុនេះឯងមានកាយសមាចារមិនបរិសុទ្ធ(១) មានវចីសមាចារមិនបរិសុទ្ធ(២) មានអាជីវៈមិនបរិសុទ្ធ(៣) ល្ងង់មិនឆ្លាស កាលបើគេដេញដោលសួរក៏មិនអាចឆ្លើយតបនឹងគេបាន ។ គួរសង្ឃសង្រ្កិនសង្រ្កាមថា នែភិក្ខុ កុំឡើយ លោកកុំធ្វើការបង្កហេតុ កុំឈ្លោះគ្នា កុំតាស់តែងគ្នា កុំធ្វើការវិវាទគ្នាឡើយ ដូច្នេះហើយ សឹមបវារណាចុះ ។

១ សេចក្តីប្រព្រឹត្តិដោយកាយមិនបរិសុទ្ធ ។ ២ សេចក្តីប្រព្រឹត្តិដោយវាចាមិនបរិសុទ្ធ ។ ៣ សេចក្តីចិញ្ចឹមជីវិតមិនបរិសុទ្ធ ។

ឥធ បន ភិក្ខវេ តទហុប្បវារណាយ ភិក្ខុ ភិក្ខុស្ស បវារណំ ឋបេតិ ។ តញ្ចេ ភិក្ខុំ អញ្ញេ ភិក្ខូ ជានន្តិ អយំ ខោ អាយស្មា បរិសុទ្ធកាយសមាចារោ អបរិសុទ្ធវចីសមាចារោ អបរិសុទ្ធអាជីវោ ពាលោ អព្យត្តោ ន បដិពលោ អនុយុញ្ជិយមានោ អនុយោគំ ទាតុន្តិ ។ អលំ ភិក្ខុ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទន្តិ ឱមទ្ទិត្វា សង្ឃេន បវារេតព្វំ ។ ឥធ បន ភិក្ខវេ តទហុប្បវារណាយ ភិក្ខុ ភិក្ខុស្ស បវារណំ ឋបេតិ ។ តញ្ចេ ភិក្ខុំ អញ្ញេ ភិក្ខូ ជានន្តិ អយំ ខោ អាយស្មា បរិសុទ្ធកាយសមាចារោ បរិសុទ្ធវចីសមាចារោ អបរិសុទ្ធអាជីវោ ពាលោ អព្យត្តោ ន បដិពលោ អនុយុញ្ជិយមានោ អនុយោគំ ទាតុន្តិ ។ អលំ ភិក្ខុ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទន្តិ ឱមទ្ទិត្វា សង្ឃេន បវារេតព្វំ ។ ឥធ បន ភិក្ខវេ តទហុប្បវារណាយ ភិក្ខុ ភិក្ខុស្ស បវារណំ ឋបេតិ ។ តញ្ចេ ភិក្ខុំ អញ្ញេ ភិក្ខូ ជានន្តិ អយំ ខោ អាយស្មា



ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុឃាត់បវារណាចំពោះភិក្ខុឯទៀត ក្នុងថ្ងៃបវារណានោះ ។ បើពួកភិក្ខុឯទៀតបានស្គាល់ភិក្ខុនោះថា លោកដ៏មានអាយុនេះ ជាអ្នកមានកាយសមាចារបរិសុទ្ធ តែមានវចីសមាចារមិនបរិសុទ្ធ មានអាជីវៈមិនបរិសុទ្ធ ល្ងង់ខ្លៅ កាលបើមានគេចោទសួរ ក៏មិនអាចឆ្លើយតបការចោទសួរបាន ។ ត្រូវសង្ឃសង្កិតសង្កិនថា នែភិក្ខុ កុំឡើយ លោកកុំធ្វើការបង្កហេតុ កុំឈ្លោះគ្នា កុំទាស់ទែងគ្នា កុំវិវាទគ្នាឡើយ ដូច្នេះហើយ សឹមបវារណា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុឃាត់បវារណាចំពោះភិក្ខុឯទៀតក្នុងថ្ងៃបវារណានោះ ។ បើពួកភិក្ខុឯទៀតបានស្គាល់ភិក្ខុនោះថា លោកដ៏មានអាយុនេះ ជាអ្នកមានកាយសមាចារបរិសុទ្ធ មានវចីសមាចារបរិសុទ្ធ តែមានអាជីវៈមិនបរិសុទ្ធ ល្ងង់ខ្លៅ កាលបើមានគេចោទសួរ ក៏មិនអាចឆ្លើយតបការចោទសួរបាន ។ ត្រូវសង្ឃសង្កិតសង្កិនថា នែភិក្ខុ លោកកុំធ្វើការបង្កហេតុ កុំឈ្លោះគ្នា កុំទាស់ទែងគ្នា កុំវិវាទគ្នាឡើយ ដូច្នេះហើយ សឹមបវារណាចុះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុឃាត់បវារណាចំពោះភិក្ខុឯទៀតក្នុងថ្ងៃបវារណានោះ ។ បើពួកភិក្ខុឯទៀតស្គាល់ភិក្ខុនោះថា លោកដ៏មានអាយុនេះ

បរិសុទ្ធកាយសមាចារោ បរិសុទ្ធវចីសមាចារោ បរិ-
សុទ្ធាជីវោ ពាលោ អព្យត្តោ ន បដិពលោ អនុយុញ្ជិ-
យមានោ អនុយោគំ ទាតុំ ។ អលំ ភិក្ខុ មា ភណ្ឌនំ
មា កលហំ មា វិគ្គហំ មា វិវាទន្តិ ឱមទ្ទិត្វា សង្ឃេន
បវារេតព្វំ ។ ឥធ បន ភិក្ខវេ តទហុបវារណាយ ភិក្ខុ
ភិក្ខុស្ស បវារណំ ឋបេតិ ។ តញ្ចេ ភិក្ខុំ អញ្ញេ ភិក្ខូ
ជានន្តិ អយំ ខោ អាយស្មា បរិសុទ្ធកាយសមាចារោ
បរិសុទ្ធវចីសមាចារោ បរិសុទ្ធាជីវោ បណ្ឌិតោ ព្យត្តោ
មេធាវី បដិពលោ អនុយុញ្ជិយមានោ អនុយោគំ ទា-
តុំ ។ សោ ឯវមស្ស វចនីយោ យំ ខោ ត្វំ អាវុសោ
ឥមស្ស ភិក្ខុនោ បវារណំ ឋបេសិ កិម្ហិ នំ ឋបេសិ
សីលវិបត្តិយា ឋបេសិ អាចារវិបត្តិយា ឋបេសិ ទិដ្ឋិ-
វិបត្តិយា ឋបេសីតិ ។ សោ ចេ ឯវំ វទេយ្យ សីលវិបត្តិ-
យា ឋបេមិ អាចារវិបត្តិយា ឋបេមិ ទិដ្ឋិវិបត្តិយា ឋបេ-
មីតិ ។ សោ ឯវមស្ស វចនីយោ ជានាតិ បនាយស្មា
សីលវិបត្តឹ ជានាតិ អាចារវិបត្តឹ ជានាតិ ទិដ្ឋិវិបត្តិន្តិ ។



ទុកជាមានកាយសមាចារបរិសុទ្ធ មានវចីសមាចារបរិសុទ្ធ មានអាជីវៈបរិសុទ្ធ
តែល្ងង់មិនឈ្លាស កាលគេដេញដោលសួរក៏មិនអាចឆ្លើយដោះស្រាយបាន ។ ត្រូវ
សង្ឃសង្រ្កិនសង្រ្កិតថា កុំឡើយភិក្ខុ លោកកុំធ្វើជម្លោះ កុំឈ្លោះ
គ្នា កុំតស៊ូទាស់ទែងគ្នា កុំវិវាទគ្នានឹងគ្នាឡើយ ហើយសឹមបវារណាចុះ ។ ម្នាលភិក្ខុ
ទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុឃាត់បវារណាចំពោះភិក្ខុដទៃក្នុង
ថ្ងៃបវារណានោះ ។ បើពួកភិក្ខុដទៃស្គាល់ភិក្ខុនោះថា លោកដ៏មាន
អាយុនេះមានកាយសមាចារបរិសុទ្ធ មានវចីសមាចារបរិសុទ្ធ មានអា-
ជីវៈបរិសុទ្ធ ជាបណ្ឌិតឈ្លាសមានប្រាជ្ញា កាលគេដេញដោលសួរអាចឆ្លើយ
ដោះស្រាយបាន ។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងភិក្ខុនោះថា នែអាវុ-
សោ លោកឃាត់បវារណាចំពោះភិក្ខុនេះ លោកឃាត់បវារណា
នោះព្រោះហេតុអ្វី លោកឃាត់ព្រោះសីលវិបត្តិ ឬឃាត់ព្រោះអាចារ-
វិបត្តិ ឬឃាត់ព្រោះទិដ្ឋិវិបត្តិ ។ បើភិក្ខុអ្នកឃាត់នោះនិយាយយ៉ាងនេះថា
ខ្ញុំឃាត់ព្រោះសីលវិបត្តិ ខ្ញុំឃាត់ព្រោះអាចារវិបត្តិ ខ្ញុំឃាត់ព្រោះទិដ្ឋិ-
វិបត្តិ ។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងភិក្ខុនោះយ៉ាងនេះថា លោក
ដ៏មានអាយុស្គាល់សីលវិបត្តិ ស្គាល់អាចារវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិដែរឬ ។

សោ ចេ ឯវំ វទេយ្យ ជានាមិ ខោ អហំ អាវុសោ សីលវិ-
បត្តឹ ជានាមិ អាចារវិបត្តឹ ជានាមិ ទិដ្ឋិវិបត្តិន្តិ ។ សោ
ឯវមស្ស វចនីយោ កតមា បនាវុសោ សីលវិបត្តិ កតម-
មា អាចារវិបត្តិ កតមា ទិដ្ឋិវិបត្តីតិ ។ សោ ចេ ឯវំ វទេយ្យ
ចត្តារិ បារាជិកានិ តេរស សង្ឃាទិសេសា អយំ សី-
លវិបត្តិ ថុល្លច្ចយំ បាចិត្តិយំ បាដិទេសនីយំ ទុក្កដំ
ទុព្ភាសិតំ អយំ អាចារវិបត្តិ មិច្ឆាទិដ្ឋិ អន្តគ្គាហិកា
ទិដ្ឋិ អយំ ទិដ្ឋិវិបត្តីតិ ។ សោ ឯវមស្ស វចនីយោ យំ
ខោ ត្វំ អាវុសោ ឥមស្ស ភិក្ខុនោ បវារណំ ឋបេសិ ទិដ្ឋេន
ឋបេសិ សុតេន ឋបេសិ បរិសង្កាយ ឋបេសីតិ ។ សោ
ចេ ឯវំ វទេយ្យ ទិដ្ឋេន វា ឋបេមិ សុតេន វា ឋបេមិ
បរិសង្កាយ វា ឋបេមីតិ ។ សោ ឯវមស្ស វចនីយោ យំ
ខោ ត្វំ អាវុសោ ឥមស្ស ភិក្ខុនោ ទិដ្ឋេន បវារណំ
ឋបេសិ កិន្តេ ទិដ្ឋំ កិន្តិ តេ ទិដ្ឋំ កទា តេ ទិដ្ឋំ
កត្ថ តេ ទិដ្ឋំ បារាជិកំ អជ្ឈាបន្នោ ទិដ្ឋោ សង្ឃា-
ទិសេសំ អជ្ឈាបន្នោ ទិដ្ឋោ ថុល្លច្ចយំ បាចិត្តិយំ
បាដិទេសនីយំ ទុក្កដំ ទុព្ភាសិតំ អជ្ឈាបន្នោ ទិដ្ឋោ



បើភិក្ខុនោះនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំស្គាល់សីលវិបត្តិ អាចារវិបត្តិ
ទិដ្ឋិវិបត្តិ ជាប្រាកដ ។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងភិក្ខុនោះយ៉ាងនេះថា
នែអាវុសោ ចុះដូចម្តេចហៅថាសីលវិបត្តិ ដូចម្តេចហៅថាអាចារវិបត្តិ ដូច
ម្តេចហៅថាទិដ្ឋិវិបត្តិ ។ បើភិក្ខុនោះនិយាយយ៉ាងនេះថា បារាជិក ៤ សង្ឃា-
ទិសេស ១៣ នេះហៅថាសីលវិបត្តិ ថុល្លច្ច័យ បាចិត្តិយ បាដិទេសនីយ
ទុក្កដ ទុព្ភាសិតនេះហៅថាអាចារវិបត្តិ មិច្ឆាទិដ្ឋិ និងអន្តគ្គាហិកទិដ្ឋិនេះហៅ
ថាទិដ្ឋិវិបត្តិ ។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងភិក្ខុនោះយ៉ាងនេះថា នែ
អាវុសោ លោកឃាត់បវារណាចំពោះភិក្ខុនេះ ព្រោះឃាត់ដោយឃើញ ឬ
ឃាត់ដោយឮ ឬឃាត់ដោយរង្កៀស ។ បើភិក្ខុនោះនិយាយយ៉ាងនេះ
ថា ខ្ញុំឃាត់ដោយឃើញក្តី ខ្ញុំឃាត់ដោយឮក្តី ខ្ញុំឃាត់ដោយរង្កៀសក្តី ។
ត្រូវភិក្ខុទាំងឡាយនិយាយនឹងភិក្ខុនោះយ៉ាងនេះ នែអាវុសោ លោក
ឃាត់បវារណាចំពោះភិក្ខុនេះ ដោយឃើញ តើលោកឃើញហេតុដូចម្តេច
លោកឃើញភិក្ខុធ្វើអ្វីនោះ លោកឃើញក្នុងកាលណា លោកឃើញ
ក្នុងទីណា កាលភិក្ខុនោះត្រូវអាបត្តិបារាជិក លោកឃើញដែរឬ កាល
ភិក្ខុនេះត្រូវអាបត្តិសង្ឃាទិសេស លោកឃើញដែរឬ កាលភិក្ខុនេះត្រូវ
អាបត្តិថុល្លច្ច័យ បាចិត្តិយ បាដិទេសនីយ ទុក្កដ ទុព្ភាសិត លោកឃើញ

កត្ថ ច ត្វំ អហោសិ កត្ថ ចាយំ ភិក្ខុ អហោសិ កិញ្ច ត្វំ ករោសិ កិញ្ចាយំ ភិក្ខុ ករោតីតិ ។ សោ ចេ ឯវំ វទេយ្យ ន ខោ អហំ អាវុសោ ឥមស្ស ភិក្ខុនោ ទិដ្ឋេន ចោទេមិ អបិច សុតេន ចោទេមីតិ ។ សោ ឯវមស្ស វចនីយោ យំ ខោ ត្វំ អាវុសោ ឥមស្ស ភិក្ខុនោ សុតេន ចោទេសិ កិន្តេ សុតំ កិន្តិ តេ សុតំ កទា តេ សុតំ កត្ថ តេ សុតំ បារាជិកំ អជ្ឈាបន្នោតិ សុតំ សង្ឃាទិសេសំ អជ្ឈាបន្នោតិ សុតំ ថុល្លច្ចយំ បាចិត្តិយំ បាដិទេសនីយំ ទុក្កដំ ទុព្ភាសិតំ អជ្ឈាបន្នោតិ សុតំ ភិក្ខុស្ស សុតំ ភិក្ខុនិយា សុតំ សិក្ខមានាយ សុតំ សាមណេរស្ស សុតំ សាមណេរិយា សុតំ ឧបាសកស្ស សុតំ ឧបាសិកាយ សុតំ រាជូនំ សុតំ រាជមហាមត្តានំ សុតំ តិត្ថិយានំ សុតំ តិត្ថិយសាវកានំ សុតន្តិ ។ សោ ចេ ឯវំ វទេយ្យ ន ខោ អហំ អាវុសោ ឥមស្ស ភិក្ខុនោ សុតេន ចោទេមិ អបិច បរិសង្កាយ ចោទេមិ



ដែរឬ ចាំណែកលោកនៅក្នុងទីណា ឯភិក្ខុនេះនៅក្នុងទីណា លោកធ្វើអ្វីខ្លះ ភិក្ខុនេះធ្វើអ្វីខ្លះ ។ បើភិក្ខុនោះនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំមិនមែនឃាត់បវារណាចំពោះភិក្ខុនេះដោយឃើញទេ ខ្ញុំឃាត់បវារណាដោយឮទេតើ ។ ត្រូវភិក្ខុចាំវិន័យនិយាយនឹងភិក្ខុនោះយ៉ាងនេះថា នែអាវុសោ លោកឃាត់បវារណាណាចំពោះភិក្ខុនេះដោយឮ លោកឮនោះដូចម្តេចគឺបវារណានោះ លោកឮអ្វី លោកឮក្នុងកាលណា លោកឮក្នុងទីណា លោកឮថាភិក្ខុនេះត្រូវអាបត្តិបារាជិកហើយឬ លោកឮថាភិក្ខុនេះត្រូវអាបត្តិសង្ឃាទិសេសហើយឬ លោកឮថាភិក្ខុនេះត្រូវអាបត្តិថុល្លច្ច័យ អាបត្តិបាចិត្តិយ បាដិទេសនីយ ទុក្កដ ទុព្ភាសិតហើយឬ លោកឮពីភិក្ខុឬ លោកឮពីភិក្ខុនីឬ ឮពីនាងសិក្ខមានាឬ ឮពីសាមណេរឬ ឮពីសាមណេរីឬ ឮពីឧបាសកឬ ឮពីឧបាសិកាឬ ឮពីស្តេចទាំងឡាយឬ ឮពីពួកមហាមាត្យស្តេចឬ ឮពីពួកតិរ្ថិយឬ ឮពីពួកសាវកតិរ្ថិយ ។ បើភិក្ខុនោះនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំមិនបានឃាត់បវារណាចំពោះភិក្ខុនេះដោយឮទេ ខ្ញុំឃាត់បវារណាដោយរង្កៀសទេតើ ។

បាចិត្តិ ។ សោ ឯវមស្ស វចនីយោ យំ ខោ ត្វំ អាវុសោ ឥមស្ស ភិក្ខុនោ បរិសង្កាយ បវារណំ ឋបេសិ កឹ បរិសង្កសិ កិន្តិ បរិសង្កសិ កទា បរិសង្កសិ កត្ថ បរិសង្កសិ បារាជិកំ អជ្ឈាបន្នោតិ បរិសង្កសិ សង្ឃាទិសេសំ អជ្ឈាបន្នោតិ បរិសង្កសិ ថុល្លច្ចយំ បាចិត្តិយំ បាដិទេសនីយំ ទុក្កដំ ទុព្ភាសិតំ អជ្ឈាបន្នោតិ បរិសង្កសិ ភិក្ខុស្ស សុត្វា បរិសង្កសិ ភិក្ខុនិយា សុត្វា បរិសង្កសិ សិក្ខមានាយ សុត្វា បរិសង្កសិ សាមណេរស្ស សុត្វា បរិសង្កសិ សាមណេរិយា សុត្វា បរិសង្កសិ ឧបាសកស្ស សុត្វា បរិសង្កសិ ឧបាសិកាយ សុត្វា បរិសង្កសិ រាជូនំ សុត្វា បរិសង្កសិ រាជមហាមត្តានំ សុត្វា បរិសង្កសិ តិត្ថិយានំ សុត្វា បរិសង្កសិ តិត្ថិយសាវកានំ សុត្វា បរិសង្កសីតិ ។ សោ ចេ ឯវំ វទេយ្យ ន ខោ អហំ អាវុសោ ឥមស្ស ភិក្ខុនោ បរិសង្កាយ បវារណំ ឋបេមិ អបិច អហម្បិ(១) ន ជានាមិ កេនចាហំ(២) ឥមស្ស ភិក្ខុនោ បវារណំ ឋបេមីតិ ។ សោ ចេ ភិក្ខុ ចោទកោ ភិក្ខុ អនុយោគេន វិញ្ញូនំ សព្រហ្មចារីនំ ចិត្តំ ន

១. ម. អហំ ។ ២. ម. កេន អហំ ។





ត្រូវភិក្ខុទាំងឡាយនិយាយនឹងភិក្ខុនោះយ៉ាងនេះថា នែអាវុសោ លោកឃាត់បវារណាចំពោះភិក្ខុនេះដោយរង្កៀស លោករង្កៀសដូចម្តេច ក្នុងបវារណានោះ ហេតុអ្វីក៏លោករង្កៀស លោករង្កៀសក្នុងកាលណា លោករង្កៀសក្នុងទីណា លោករង្កៀសថាភិក្ខុនេះត្រូវអាបត្តិបារាជិកហើយឬ លោករង្កៀសថាភិក្ខុនេះត្រូវអាបត្តិសង្ឃាទិសេសហើយឬ លោករង្កៀសថាភិក្ខុនេះត្រូវអាបត្តិថុល្លច្ច័យ បាចិត្តិយ បាដិទេសនីយ ទុក្កដ ទុព្ភាសិតហើយឬ លោករង្កៀសព្រោះឮពីភិក្ខុឬ លោករង្កៀសព្រោះឮពីភិក្ខុនីឬ លោករង្កៀសព្រោះឮពីសិក្ខមានាឬ លោករង្កៀសព្រោះឮពីសាមណេរឬ លោករង្កៀសព្រោះឮពីសាមណេរីឬ លោករង្កៀសព្រោះឮពីឧបាសកឬ លោករង្កៀសព្រោះឮពីឧបាសិកាឬ លោករង្កៀសព្រោះឮពីពួកស្តេចឬ លោករង្កៀសព្រោះឮពីពួកមហាមាត្យស្តេចឬ លោករង្កៀសព្រោះឮពីពួកតិរ្ថិយឬ លោករង្កៀសព្រោះឮពីពួកសាវកតិរ្ថិយឬ ។ បើភិក្ខុនោះនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំមិនមែនឃាត់បវារណាចំពោះភិក្ខុនេះដោយរង្កៀសទេ មួយវិញទៀតខ្ញុំក៏មិនដឹងថា ខ្ញុំឃាត់បវារណាចំពោះភិក្ខុនោះដោយហេតុអ្វីទេ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកចោទនោះមិនធ្វើចិត្តរបស់ពួកសព្រហ្មចារីជាវិញ្ញូ

អារាធេតិ អនុទ្ធស្តោ ចុទិតោ ភិក្ខូតិ អលំ វចៈ-
នាយ ។ សោ ចេ ភិក្ខវេ ចោទកោ ភិក្ខុ អនុ-
យោគេន វិញ្ញូ សព្រហ្មចារី ចិត្តំ អារាធេតិ ឧទ្ធ-
ស្តោ ចុទិតោ ភិក្ខូតិ អលំ វចនាយ ។ សោ ចេ
ភិក្ខវេ ចោទកោ ភិក្ខុ អមូលកេន បារាជិកេន
អនុទ្ធំសិតំ បដិជានាតិ សង្ឃាទិសេសំ អារោបេត្វា[១]
សង្ឃេន បវារេតព្វំ ។ សោ ចេ ភិក្ខវេ ចោទកោ
ភិក្ខុ អមូលកេន សង្ឃាទិសេសេន អនុទ្ធំសិតំ បៈ-
ដិជានាតិ យថាធម្មំ ការាបេត្វា សង្ឃេន បវារេ-
តព្វំ ។ សោ ចេ ភិក្ខវេ ចោទកោ ភិក្ខុ អមូលកេន
ថុល្លច្ចយេន បាចិត្តិយេន បាដិទេសនីយេន ទុក្ក-
ដេន ទុព្ភាសិតេន អនុទ្ធំសិតំ បដិជានាតិ យថាធម្មំ
ការាបេត្វា សង្ឃេន បវារេតព្វំ ។ សោ ចេ ភិក្ខវេ ចុទិ-
តោ ភិក្ខុ បារាជិកំ អជ្ឈាបន្នោតិ បដិជានាតិ នាសេត្វា
សង្ឃេន បវារេតព្វំ ។ សោ ចេ ភិក្ខវេ ចុទិតោ ភិក្ខុ
សង្ឃាទិសេសំ អជ្ឈាបន្នោតិ បដិជានាតិ សង្ឃាទិសេសំ

១ ករេត្វា ។



ត្រេកអរតាមការសាកសួរទេ គួរនិយាយថាភិក្ខុដែលត្រូវគេចោទមិនខូច
ភិក្ខុនោះមិនទៀលទេ គឺអស់ពាក្យទេ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នក
ចោទនោះសួរចិត្តរបស់សព្រហ្មចារីជាវិញ្ញូ ត្រេកអរតាមសេចក្ដីសាកសួ-
រ គួរនិយាយថាភិក្ខុដែលត្រូវគេចោទ ភិក្ខុនោះគិតជៀសពុំបាន (មានទោស) ។
ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកចោទនោះប្ដេជ្ញាចំពោះភិក្ខុដែលខ្លួនតាម
កំចាត់ (ចោទ) ដោយអាបត្តិបារាជិកគ្មានមូល ត្រូវសង្ឃលើកអាបត្តិ
សង្ឃាទិសេស (ចំពោះភិក្ខុអ្នកចោទនោះ) ហើយសឹមបវារណាចុះ ។
ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកចោទនោះប្ដេជ្ញាចំពោះភិក្ខុដែលខ្លួនតាម
កំចាត់ (ចោទ) ដោយអាបត្តិសង្ឃាទិសេសមិនមានមូល ត្រូវសង្ឃឲ្យភិក្ខុ
នោះធ្វើតាមធម៌ (ត្រូវសំដែងអាបត្តិចេញ) ហើយសឹមបវារណាចុះ ។
ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកចោទនោះប្ដេជ្ញាចំពោះភិក្ខុដែលខ្លួនតាម
កំចាត់ដោយអាបត្តិថុល្លច្ច័យ បាចិត្តិយ បាដិទេសនីយ ទុក្កដ ទុព្ភាសិតឥត
មូលគ្មាន ត្រូវសង្ឃឲ្យភិក្ខុនោះធ្វើតាមធម៌ (សំដែងអាបត្តិចេញ) ហើយ
សឹមបវារណាចុះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុដែលត្រូវគេចោទប្ដេជ្ញាខ្លួនថា
ត្រូវអាបត្តិបារាជិក ត្រូវសង្ឃធ្វើនាសនកម្ម (ចំពោះភិក្ខុនោះ) ហើយសឹម
បវារណាចុះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុដែលត្រូវគេចោទនោះប្ដេជ្ញាខ្លួន
ថាត្រូវអាបត្តិសង្ឃាទិសេស ត្រូវសង្ឃលើកអាបត្តិសង្ឃាទិសេសហើយ

អារោបេត្វា សង្ឃោ បវារេតព្វោ ។ សោ ចេ ភិក្ខវេ ចុទិតោ ភិក្ខុ ថុល្លច្ចយំ បាចិត្តិយំ បាដិទេសនីយំ ទុក្កដំ ទុព្ភាសិតំ អជ្ឈាបន្នោតិ បដិជានាតិ យថាធម្មំ ការាបេត្វា សង្ឃោ បវារេតព្វោ ។

(៥៥) ឥធ បន ភិក្ខវេ ភិក្ខុ តទហុបវារណាយ ថុល្លច្ចយំ អជ្ឈាបន្នោ ហោតិ ។ ឯកច្ចេ ភិក្ខូ ថុល្លច្ចយទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ សង្ឃាទិសេសទិដ្ឋិនោ ហោន្តិ ។ យេ តេ ភិក្ខវេ ភិក្ខូ ថុល្លច្ចយទិដ្ឋិនោ តេហិ សោ ភិក្ខវេ ភិក្ខុ ឯកមន្តំ អបនេត្វា យថាធម្មំ ការាបេត្វា សង្ឃំ ឧបសង្កមិត្វា ឯវមស្ស វចនីយោ យំ ខោ សោ អាវុសោ ភិក្ខុ អាបត្តឹ អាបន្នោ សាស្ស យថាធម្មំ បដិកតា យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ បវារេយ្យាតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ តទហុបវារណាយ ថុល្លច្ចយំ អជ្ឈាបន្នោ ហោតិ ។ ឯកច្ចេ ភិក្ខូ ថុល្លច្ចយទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ បាចិត្តិយទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ ថុល្លច្ចយទិដ្ឋិនោ ហោន្តិ ឯកច្ចេ



សឹមបវារណាចុះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុដែលត្រូវគេចោទនោះប្តេជ្ញាខ្លួនថាត្រូវអាបត្តិថុល្លច្ច័យ បាចិត្តិយ បាដិទេសនីយ ទុក្កដ ទុព្ភាសិត ត្រូវសង្ឃឲ្យភិក្ខុនោះធ្វើតាមធម៌ (សំដែងអាបត្តិ) ហើយសឹមបវារណាចុះ ។

(៥៥) ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុត្រូវអាបត្តិថុល្លច្ច័យក្នុងថ្ងៃបវារណានោះ ។ មានភិក្ខុពួកខ្លះយល់ថាអាបត្តិថុល្លច្ច័យ មានភិក្ខុពួកខ្លះយល់ថាសង្ឃាទិសេស ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាដែលយល់ថាអាបត្តិថុល្លច្ច័យ ម្នាលភិក្ខុទាំងឡាយ ត្រូវពួកភិក្ខុនោះនាំភិក្ខុ (ត្រូវអាបត្តិ) នោះចេញទៅកាន់ទីស្ងាត់ម្ខាងហើយ ឲ្យភិក្ខុនោះធ្វើតាមធម៌ ត្រូវត្រឡប់ចូលទៅកាន់សង្ឃហើយនិយាយយ៉ាងនេះថា នែអាវុសោ ភិក្ខុនោះត្រូវអាបត្តិណាហើយ ភិក្ខុនោះបានសំដែងអាបត្តិនោះតាមធម៌ហើយ បើកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃបវារណា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុត្រូវអាបត្តិថុល្លច្ច័យក្នុងថ្ងៃបវារណានោះ ។ មានភិក្ខុពួកខ្លះយល់ថាអាបត្តិថុល្លច្ច័យ មានភិក្ខុពួកខ្លះយល់ថាអាបត្តិបាចិត្តិយ មានភិក្ខុពួកខ្លះយល់ថាអាបត្តិថុល្លច្ច័យ មានភិក្ខុពួកខ្លះ

ភិក្ខូ បាដិទេសនីយទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ ថុល្លច្ចយទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ ទុក្កដទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ ថុល្លច្ចយទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ ទុព្ភាសិតទិដ្ឋិនោ ហោន្តិ ។ យេ តេ ភិក្ខវេ ភិក្ខូ ថុល្លច្ចយទិដ្ឋិនោ តេហិ សោ ភិក្ខវេ ភិក្ខុ ឯកមន្តំ អបនេត្វា យថាធម្មំ ការាបេត្វា សង្ឃំ ឧបសង្កមិត្វា ឯវមស្ស វចនីយោ យំ ខោ សោ អាវុសោ ភិក្ខុ អាបត្តឹ អាបន្នោ សាស្ស យថាធម្មំ បដិកតា យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ បវារេយ្យាតិ ។ ៩០ ឥធ ភិក្ខវេ ភិក្ខុ តទហុបវារណាយ បាចិត្តិយំ អជ្ឈាបន្នោ ហោតិ បាដិទេសនីយំ អជ្ឈាបន្នោ ហោតិ ទុក្កដំ អជ្ឈាបន្នោ ហោតិ ទុព្ភាសិតំ អជ្ឈាបន្នោ ហោតិ ។ ឯកច្ចេ ភិក្ខូ ទុព្ភាសិតទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ សង្ឃាទិសេសទិដ្ឋិនោ ហោន្តិ ។ យេ តេ ភិក្ខវេ ភិក្ខូ ទុព្ភាសិតទិដ្ឋិនោ តេហិ សោ ភិក្ខវេ ភិក្ខុ ឯកមន្តំ អបនេត្វា យថាធម្មំ ការាបេត្វា សង្ឃំ ឧបសង្កមិត្វា ឯវមស្ស វចនីយោ យំ ខោ សោ អាវុសោ ភិក្ខុ អាបត្តឹ



យល់ថាអាបត្តិបាដិទេសនីយ មានភិក្ខុពួកខ្លះយល់ថាអាបត្តិថុល្លច្ច័យ មានភិក្ខុពួកខ្លះយល់ថាអាបត្តិទុក្កដ មានភិក្ខុពួកខ្លះយល់ថាអាបត្តិថុល្លច្ច័យ មានភិក្ខុពួកខ្លះយល់ថាអាបត្តិទុព្ភាសិត ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាដែលយល់ថាអាបត្តិថុល្លច្ច័យ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុពួកនោះនាំភិក្ខុនោះចេញទៅកាន់ទីគួរមួយ ឲ្យធ្វើតាមធម៌ (សំដែងអាបត្តិ) ហើយសឹមចូលមករកសង្ឃរួចត្រូវនិយាយយ៉ាងនេះថា នែអាវុសោ ភិក្ខុនោះត្រូវអាបត្តិណា ភិក្ខុនោះក៏បានសំដែងអាបត្តិនោះតាមធម៌ហើយ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីបវារណា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុត្រូវអាបត្តិបាចិត្តិយ ត្រូវអាបត្តិបាដិទេសនីយ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិទុព្ភាសិត ក្នុងថ្ងៃបវារណានោះ ។ មានភិក្ខុពួកខ្លះយល់ថាត្រូវអាបត្តិទុព្ភាសិត ភិក្ខុពួកខ្លះយល់ថាត្រូវអាបត្តិសង្ឃាទិសេស ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាដែលយល់ថាត្រូវអាបត្តិទុព្ភាសិត ម្នាលភិក្ខុទាំងឡាយ ត្រូវពួកភិក្ខុនោះនាំភិក្ខុនោះចេញទៅកាន់ទីគួរមួយ ឲ្យធ្វើតាមធម៌ហើយសឹមចូលទៅរកសង្ឃរួចនិយាយយ៉ាងនេះថា នែអាវុសោ ភិក្ខុនោះត្រូវអាបត្តិណា

អាបន្នោ សាស្ស យថាធម្មំ បដិកតា យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឱសារេយ្យាតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ គណបុព្វការណាយ ទុព្ភាសិតំ អជ្ឈាបន្នោ ហោតិ ។ ឯកច្ចេ ភិក្ខូ ទុព្ភាសិតទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ ថុល្លច្ចយទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ ទុព្ភាសិតទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ បាចិត្តិយទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ ទុព្ភាសិតទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ បាដិទេសនីយទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ ទុព្ភាសិតទិដ្ឋិនោ ហោន្តិ ឯកច្ចេ ភិក្ខូ ទុក្កដទិដ្ឋិនោ ហោន្តិ ។ យេ តេ ភិក្ខវេ ភិក្ខូ ទុព្ភាសិតទិដ្ឋិនោ តេហិ សោ ភិក្ខវេ ភិក្ខុ ឯកមន្តំ អបនេត្វា យថាធម្មំ ការាបេត្វា សង្ឃំ ឧបសង្កមិត្វា ឯវមស្ស វចនីយោ យំ ខោ សោ អាវុសោ ភិក្ខុ អាបត្តិំ អាបន្នោ សាស្ស យថាធម្មំ បដិកតា យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឱសារេយ្យាតិ ។



ភិក្ខុនោះក៏បានសំដែងអាបត្តិនោះតាមធម៌ហើយ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីបពារណាចុះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុត្រូវអាបត្តិទុព្ភាសិតក្នុងបរិវារណានោះ ។ មានភិក្ខុពួកខ្លះយល់ថាត្រូវអាបត្តិទុព្ភាសិត ភិក្ខុពួកខ្លះយល់ថាត្រូវអាបត្តិថុល្លច្ចយ មានភិក្ខុពួកខ្លះយល់ថាត្រូវអាបត្តិទុព្ភាសិត ភិក្ខុពួកខ្លះយល់ថាត្រូវអាបត្តិបាចិត្តិយ ភិក្ខុពួកខ្លះយល់ថាត្រូវអាបត្តិទុព្ភាសិត ភិក្ខុពួកខ្លះយល់ថាត្រូវអាបត្តិបាដិទេសនីយ មានភិក្ខុពួកខ្លះយល់ថាត្រូវអាបត្តិទុព្ភាសិត ភិក្ខុពួកខ្លះយល់ថាត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាដែលយល់ថាត្រូវអាបត្តិទុព្ភាសិត ម្នាលភិក្ខុទាំងឡាយ ត្រូវពួកភិក្ខុនោះនាំភិក្ខុនោះចេញទៅកាន់ទីស្ងាត់ ឲ្យធ្វើតាមធម៌ហើយត្រូវចូលទៅរកសង្ឃរួច និយាយយ៉ាងនេះថា ម្នាលអាវុសោ ភិក្ខុនោះត្រូវអាបត្តិណា ភិក្ខុនោះបានសំដែងអាបត្តិនោះតាមធម៌ហើយ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីបពារណាចុះ ។

(៤៨) ឥធ បន ភិក្ខវេ ភិក្ខុ តទហុប្បវារណាយ សង្ឃមជ្ឈេ ឧទាហរេយ្យ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ វត្ថុ បញ្ញាយតិ ន បុគ្គលោ យទិ សង្ឃស្ស បត្តកល្លំ វត្ថុំ ឋបេត្វា សង្ឃោ បវារេយ្យាតិ ។ សោ ឯវមស្ស វចនីយោ ភគវតា ខោ អាវុសោ វិសុទ្ធានំ បវារណា បញ្ញត្តា សចេ វត្ថុ បញ្ញាយតិ ន បុគ្គលោ ឥទានេវ នំ វទេហីតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ តទហុប្បវារណាយ សង្ឃមជ្ឈេ ឧទាហរេយ្យ សុណាតុ មេ ភន្តេ សង្ឃោ អយំ បុគ្គលោ បញ្ញាយតិ ន វត្ថុ យទិ សង្ឃស្ស បត្តកល្លំ បុគ្គលំ ឋបេត្វា សង្ឃោ បវារេយ្យាតិ ។ សោ ឯវមស្ស វចនីយោ ភគវតា ខោ អាវុសោ សមគ្គានំ បវារណា បញ្ញត្តា សចេ បុគ្គលោ បញ្ញាយតិ ន វត្ថុ ឥទានេវ នំ វទេហីតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ តទហុប្បវារណាយ សង្ឃមជ្ឈេ ឧទាហរេយ្យ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ វត្ថុញ្ច បុគ្គលោ ច



(៤៨) ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុស្រែកឡើងក្នុងកណ្តាលសង្ឃក្នុងថ្ងៃបវារណានោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុនេះប្រាកដ តែបុគ្គលមិនប្រាកដ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីឃាត់វត្ថុហើយសឹមបវារណា ។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តបវារណា ដើម្បីឲ្យភិក្ខុទាំងឡាយស្អាតវិសេស បើវត្ថុប្រាកដ តែបុគ្គលមិនប្រាកដទេ ចូរអ្នកប្រាប់វត្ថុនោះឥឡូវនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះបើមានភិក្ខុស្រែកឡើងក្នុងកណ្តាលសង្ឃក្នុងថ្ងៃបវារណានោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ម្ចាស់) បុគ្គលនេះប្រាកដ តែវត្ថុមិនប្រាកដទេ បើកម្មមានកាលគួរដល់សង្ឃហើយ សូមសង្ឃឃាត់នូវបុគ្គលហើយសឹមបវារណា ។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តបវារណាដើម្បីឲ្យពួកភិក្ខុព្រមព្រៀងគ្នា បើបុគ្គលប្រាកដ តែវត្ថុមិនប្រាកដទេ ចូរអ្នកប្រាប់បុគ្គលនោះឥឡូវនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុស្រែកឡើងក្នុងកណ្តាលសង្ឃក្នុងថ្ងៃបវារណានោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ម្ចាស់) វត្ថុនេះក្តី បុគ្គលក្តី

បញ្ញាយតិ យទិ សង្ឃស្ស បត្តកល្លំ វត្ថុញ្ច បុគ្គលញ្ច ឋបេត្វា សង្ឃោ បវារេយ្យាតិ ។ សោ ឯវមស្ស វចនីយោ ភគវតា ខោ អាវុសោ វិសុទ្ធានញ្ច សមគ្គានញ្ច បវារណា បញ្ញត្តា សចេ វត្ថុញ្ច បុគ្គលោ ច បញ្ញាយតិ ឥធានេវ នំ វទេហីតិ ។ បុព្វេ ចេ ភិក្ខវេ បវារណាយ វត្ថុ បញ្ញាយតិ បច្ឆា បុគ្គលោ កល្លំ វចនាយ ។ បុព្វេ ចេ ភិក្ខវេ បវារណាយ បុគ្គលោ បញ្ញាយតិ បច្ឆា វត្ថុ កល្លំ វចនាយ ។ បុព្វេ ចេ ភិក្ខវេ បវារណាយ វត្ថុញ្ច បុគ្គលោ ច បញ្ញាយតិ តញ្ចេ កតាយ បវារណាយ ឧក្កោដេតិ ឧក្កោដនកំ បាចិត្តិយន្តិ ។

(៤៦) តេន ខោ បន សមយេន សម្ពហុលា សន្ទិដ្ឋា សម្ភត្តា ភិក្ខូ កោសលេសុ ជនបទេសុ អញ្ញតរស្មឹ អាវាសេ វស្សំ ឧបគច្ឆឹសុ ។ តេសំ សាមន្តា អញ្ញេ ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា





ក៏ប្រកាស បើកម្មមានកាលគួរដល់សង្ឃហើយ (ត្រូវសង្ឃឃាត់ទាំងវត្ថុ ទាំងបុគ្គលហើយសឹមបវារណា ។ ត្រូវភិក្ខុទាំងឡាយនិយាយយ៉ាងនេះ នឹងភិក្ខុនោះថា នែអាវុសោ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តបវារណា ដើម្បីឲ្យភិក្ខុទាំងឡាយបរិសុទ្ធផង ដើម្បីឲ្យភិក្ខុទាំងឡាយព្រមព្រៀងគ្នាផង បើវត្ថុនឹងបុគ្គលប្រាកដ ចូរលោកប្រាប់វត្ថុនឹងបុគ្គលនោះក្នុងកាលឥឡូវនេះមក ។ ម្នាលភិក្ខុទាំងឡាយ បើវត្ថុប្រាកដមុនបវារណា បុគ្គលប្រាកដក្រោយបវារណា គួរនឹងពោលបាន ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលប្រាកដមុនបវារណា វត្ថុប្រាកដក្រោយបវារណា គួរនឹងពោលបាន ។ ម្នាលភិក្ខុទាំងឡាយ បើវត្ថុនឹងបុគ្គលប្រាកដមុនបវារណា កាលបើសង្ឃបានធ្វើបវារណាហើយ បើភិក្ខុសើរើកម្មនោះឡើង ត្រូវឧក្កោដនកបាចិត្តិយ (ត្រូវបាចិត្តិយព្រោះការសើរើ) ។

(៤៦) ក៏សម័យនោះឯង ពួកភិក្ខុច្រើនរូបដែលជាមិត្រគ្រាន់តែឃើញគ្នា ទីជាមិត្រជាប់ចិត្ត (មិត្រស្និទ្ធស្នាលម៉ាំមួន) ចូលទៅចាំវស្សាក្នុងអាវាសមួយក្នុងកោសលជនបទ ។ ពួកភិក្ខុដទៃដែលនៅជិតខាងភិក្ខុទាំងឡាយនោះ ធ្វើសេចក្តីប្រកួតប្រកាន់គ្នា ធ្វើសេចក្តីឈ្លោះគ្នា ធ្វើសេចក្តីទាស់ទែងគ្នា ធ្វើពាក្យលើគ្នា ជាអ្នកធ្វើអធិករណ៍ក្នុងសង្ឃចូលទៅ

វស្សំ ឧបគច្ឆិំសុ ឯវំ តេសំ ភិក្ខូនំ វស្សំ វុត្ថានំ បវា-
រណាយ បវារណំ ឋបេស្សាមាតិ ។ អស្សោសុំ ខោ
តេ ភិក្ខូ អម្ហាកំ កិរ សមន្តា អញ្ញេ ភិក្ខូ ភណ្ឌន-
ការកា កលហការកា វិវាទការកា ភស្សការកា
សង្ឃេ អធិករណការកា វស្សំ ឧបគតា ឯវំ តេសំ
ភិក្ខូនំ វស្សំ វុត្ថានំ បវារណាយ បវារណំ ឋបេស្សាមា-
តិ កថំ នុ ខោ អម្ហេហិ បដិបជ្ជិតព្ពន្តិ ។ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ ឥធ បន ភិក្ខវេ សម្ពហុលា
សន្ទិដ្ឋា សម្ភត្តា ភិក្ខូ អញ្ញតរស្មឹ អាវាសេ វស្សំ ឧប-
គច្ឆន្តិ ។ តេសំ សមន្តា អញ្ញេ ភិក្ខូ ភណ្ឌនការកា
កលហការកា វិវាទការកា ភស្សការកា សង្ឃេ
អធិករណការកា វស្សំ ឧបគច្ឆន្តិ ឯវំ តេសំ ភិក្ខូនំ
វស្សំ វុត្ថានំ បវារណាយ បវារណំ ឋបេស្សាមាតិ ។
អនុជានាមិ ភិក្ខវេ តេហិ ភិក្ខូហិ ទ្វេ តយោ ឧបោ-
សថេ ចាតុទ្ទសិកេ កាតុំ កថំ មយំ តេហិ ភិក្ខូហិ



ចាំវស្សាដោយគិតថា កាលបើភិក្ខុទាំងនោះនៅចាំវស្សារួចហើយ ពួក
យើងនឹងឃាត់បវារណា ក្នុងថ្ងៃដែលបវារណា ។ ពួកភិក្ខុទាំងនោះបានឮ
ដំណឹងថា ពួកភិក្ខុឯទៀតដែលនៅជិតខាងនៃយើង ជាអ្នកធ្វើសេចក្តីប្រកួតប្រ-
កាន់ ធ្វើសេចក្តីឈ្លោះប្រកែក ធ្វើសេចក្តីទាស់ទែងគ្នា ធ្វើតែរឿងឥតការ ជាអ្នក
ធ្វើអធិករណ៍ក្នុងសង្ឃ មកចូលចាំវស្សាដោយគិតថា កាលបើភិក្ខុទាំងនោះ
នៅចាំវស្សារួចហើយ ពួកយើងនឹងឃាត់បវារណា ក្នុងថ្ងៃដែលបវារណា ពួក
យើងត្រូវធ្វើយ៉ាងដូចម្តេចហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ
ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ
ក្នុងសាសនានេះ បើមានពួកភិក្ខុច្រើនរូប ជាមិត្តដែលធ្លាប់ឃើញគ្នា ជាមិត្រ
ស្និទ្ធស្នាល ចាំវស្សាក្នុងអាវាសមួយ ។ ពួកភិក្ខុឯទៀតដែលនៅ
ជិតខាងពួកភិក្ខុទាំងនោះ ជាអ្នកធ្វើសេចក្តីប្រកួតប្រកាន់ ធ្វើសេចក្តីឈ្លោះ
ប្រកែក ធ្វើសេចក្តីទាស់ទែង ធ្វើតែរឿងឥតការ ជាអ្នកធ្វើអធិករណ៍ក្នុងសង្ឃ ចូល
មកចាំវស្សាដោយគិតថា កាលបើភិក្ខុទាំងនោះ នៅចាំវស្សារួចហើយ
ពួកយើងនឹងឃាត់បវារណា ក្នុងថ្ងៃដែលបវារណា ។ ម្នាលភិក្ខុទាំងឡាយ
តថាគតអនុញ្ញាតឲ្យពួកភិក្ខុទាំងនោះ ធ្វើចាតុទ្ទសីឧបោ-
សថ(១) ដោយគិតថា ធ្វើដូចម្តេច ពួកយើងនឹងបវារណាឲ្យបានមុនពួកភិក្ខុ

---

១ ក្នុងវស្សា ៣ ខែ បើមានហេតុសង្ស័យដូច្នោះ ត្រូវធ្វើចាតុទ្ទសីឧបោសថពីរដងឬបីដង
គឺ ឧបោសថទី ៣-៤-៥ ។ ...

ក្នុងខែ ... ។

បឋមសំ ឧបាយោ ... ។ ឥធ ភិក្ខវេ ភិក្ខុ កណ្ហ-
ធម្មការកោ កលហការកោ វិវាទការកោ ភស្សការកោ
សង្ឃេ អធិករណការកោ អាភស្ស អាវុសោ តេហិ
ភិក្ខវេ អាភស្សរេហិ ភិក្ខូហិ សទ្ធិំ សទ្ធិំ សម្មោទិត្វា
ឧបាគច្ឆតិ ឧបាគន្ត្វា វត្តព្វា ឧបាវិតា ទេ មយំ អាវុសោ
យថា កាយស្ស ភេទា មរណា អថ អាភេទ្ធតិ ។ ឥធ
ភិក្ខវេ ភិក្ខុ កណ្ហធម្មការកោ កលហការកោ វិវាទការ-
កោ ភស្សការកោ សង្ឃេ អធិករណការកោ អសវិហារ
តំ អាភស្ស អាវុសោ តេហិ ភិក្ខវេ អាភស្សរេហិ ភិក្ខូហិ
អាសនំ បញ្ញាបេតព្វំ បាទោទកំ បាទបីឋំ បាទកថលិកំ
ឧបនិក្ខិបិតព្វំ បច្ចុគ្គន្ត្វា បត្តចីវរំ បដិគ្គហេតព្វំ បានីយេន
បុច្ឆិតព្វា ។ តេសំ វិសុទ្ធិ ចិត្តស្ស បិ ឥន្ទ្រា ឧបាគន្ត្វា ។
ឧបាគន្ត្វា វត្តព្វា ឧបាវិតា ទេ មយំ អាវុសោ យថា
កាយស្ស ភេទា មរណា អថ អាភេទ្ធតិ ។ ឯកច្ចំ លភេថ
កំឡេងកុសលំ ឥធ ទេ លភេថ អាភស្សរេហិ ភិក្ខូហិ





ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុជាអ្នកធ្វើសេចក្ដីប្រកួតប្រ-
កាន់គ្នា ធ្វើសេចក្ដីឈ្លោះប្រកែកគ្នា ធ្វើសេចក្ដីទាស់ទែងគ្នា ធ្វើវិវាទ-
គ្នា ធ្វើអធិករណ៍ក្នុងសង្ឃទាំងនោះ មកកាន់អាវាស ម្នាលភិក្ខុទាំង
ឡាយ ព្រោះភិក្ខុអ្នកនៅក្នុងអាវាសទាំងនោះប្រជុំគ្នាបរិភោគភាយ ១ ចុះ ល្មុះ
បរិភោគហើយ ព្រោះនិយាយថា នែអាវុសោ យើងទាំងឡាយបានបរិភោគ
ល្អហើយ លោកដ៏មានអាយុទាំងឡាយសំគាល់ហេតុណា កំពុងធ្វើហេតុ
នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុដែលជាអ្នកធ្វើសេចក្ដីប្រកួត
ប្រកាន់គ្នា ធ្វើសេចក្ដីឈ្លោះគ្នា វិវាទគ្នា ធ្វើវិវាទគ្នា ធ្វើអធិករណ៍
ក្នុងសង្ឃទាំងនោះមិនបានដើររៀងគ្នាហើយមកកាន់អាវាសនោះ ម្នាលភិក្ខុ
ទាំងឡាយ ព្រោះភិក្ខុអ្នកនៅក្នុងអាវាសទាំងនោះក្រោកអាសនៈទទួលចិត្ត
ណាទីហើយ ទាំងទីអំហើយ ក្រោះចុះស្រោចជើង ក្រាក្រោកទៀត
ទទួលយកបាត្រនិងចីវរ ក្រោះស្រួលភិក្ខុទាំងនោះដោយទឹកផឹក ។ ក្រោះ
ប៉ះកាន់ភិក្ខុទាំងនោះហើយទៅកាន់ទីក្រោសីមាហើយសំឡឹងបរិភោគចុះ ។
ល្មុះបរិភោគហើយ ក្រោះនិយាយថា នែអាវុសោ យើងទាំងឡាយបាន
បរិភោគល្អហើយ លោកដ៏មានអាយុទាំងឡាយសំគាល់ហេតុណា ចូរ
ធ្វើហេតុនោះចុះ ។ បើភិក្ខុបានកិច្ចនោះ ដោយកាយបុរាណហើយ
កាលបានទីនៅគាល់ បើមិនបានទេ ក្រោះភិក្ខុអ្នកនៅក្នុងអាវាសដែល

ព្យត្តេន បដិពលេន អាវាសិកា ភិក្ខូ ញាបេតព្វា សុណន្តុ មេ អាយស្មន្តោ អាវាសិកា យទាយស្មន្តានំ បត្តកល្លំ ឥទានិ ឧបោសថំ ករេយ្យាម បាតិមោក្ខំ ឧទ្ទិសេយ្យាម អាគមេ កាឡេ បវារេយ្យាមាតិ ។ តេ ចេ ភិក្ខវេ ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា តេ ភិក្ខូ ឯវំ វទេយ្យុំ សាធុ អាវុសោ ឥទានេវ នោ បវារេថាតិ ។ តេ ឯវមស្សុ វចនីយា អនិស្សរា ខោ តុម្ហេ អាវុសោ អម្ហាកំ បវារណាយ ន តាវ មយំ បវារេស្សាមាតិ ។ តេ ចេ ភិក្ខវេ ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា តំ កាឡំ អនុវសេយ្យុំ អាវាសិកេហិ ភិក្ខុនា ព្យត្តេន បដិពលេន អាវាសិកា ភិក្ខូ ញាបេតព្វា សុណន្តុ មេ អាយស្មន្តោ អាវាសិកា យទាយស្មន្តានំ បត្តកល្លំ ឥទានិ ឧបោសថំ ករេយ្យាម បាតិមោក្ខំ ឧទ្ទិសេយ្យាម អាគមេ ជុណ្ហេ បវារេយ្យាមាតិ ។



ឈ្លាសប្រតិពលឲ្យពួកភិក្ខុអ្នកនៅក្នុងអាវាសផ្ចង់ចាំថា សូមលោកដ៏មានអាយុទាំងឡាយដែលនៅក្នុងអាវាសស្ដាប់ខ្ញុំ បើកម្មមានកាលគួរដល់លោកដ៏មានអាយុទាំងឡាយណាហើយ យើងត្រូវធ្វើឧបោសថ ត្រូវសំដែងបាតិមោក្ខ ត្រូវបវារណា ក្នុងកាឡបក្ខដែលមកដល់ក្នុងខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុជាអ្នកធ្វើសេចក្ដីប្រកួតប្រកាន់ ធ្វើសេចក្ដីឈ្លោះប្រកែក ធ្វើសេចក្ដីទាស់ទែង ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃទាំងនោះនិយាយយ៉ាងនេះនឹងអាវាសិកភិក្ខុទាំងនោះថា នែអាវុសោ ទុំសូមអញ្ជើញ ចូរលោកទាំងឡាយបវារណាចំពោះយើងក្នុងកាលឥឡូវនេះចុះ ។ ត្រូវអាវាសិកភិក្ខុនិយាយនឹងភិក្ខុទាំងនោះយ៉ាងនេះថា នែអាវុសោ លោកទាំងឡាយមិនមែនជាធំក្នុងការបវារណារបស់យើងទេ យើងមិនទាន់បវារណានៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុអ្នកធ្វើសេចក្ដីប្រកួតប្រកាន់ ធ្វើសេចក្ដីឈ្លោះប្រកែក ធ្វើសេចក្ដីទាស់ទែង ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃទាំងនោះនៅរហូតអស់កាឡបក្ខនោះ ត្រូវអាវាសិកភិក្ខុដែលឈ្លាសប្រតិពលឲ្យពួកអាវាសិកភិក្ខុផ្ចង់ចាំដោយពាក្យដូច្នេះថា សូមលោកដ៏មានអាយុទាំងឡាយដែលនៅក្នុងអាវាសស្ដាប់ខ្ញុំ បើកម្មមានកាលគួរដល់លោកដ៏មានអាយុទាំងឡាយហើយ យើងទាំងឡាយត្រូវធ្វើឧបោសថ ត្រូវសំដែងបាតិមោក្ខ ត្រូវបវារណាក្នុងជុណ្ហបក្ខដែលមក

បវារណក្ខន្ធកោ ភណ្ឌនការកវត្ថុ

តេ ចេ ភិក្ខវេ ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា តេ ភិក្ខូ ឯវំ វទេយ្យុំ សាធុ អាវុសោ ឥទានេវ នោ បវារេថាតិ ។ តេ ឯវមស្សុ វចនីយា អនិស្សរា ខោ តុម្ហេ អាវុសោ អម្ហាកំ បវារណាយ ន តាវ មយំ បវារេស្សាមាតិ ។ តេ ចេ ភិក្ខវេ ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា តម្បិ ជុណ្ហំ អនុវសេយ្យុំ តេហិ ភិក្ខវេ ភិក្ខូហិ សព្វេហេវ អាគមេ ជុណ្ហេ កោមុទិយា ចាតុមាសិនិយា អកាមា បវារេតព្វំ ។ តេហិ ចេ ភិក្ខវេ ភិក្ខូហិ បវារិយមានេ គិលានោ អគិលានស្ស បវារណំ ឋបេតិ សោ ឯវមស្សុ វចនីយោ អាយស្មា ខោ គិលានោ គិលានោ ច អនុយោគក្ខមោ វុត្តោ ភគវតា អាគមេហិ អាវុសោ យាវ



បវារណក្ខន្ធកៈ ពួកភិក្ខុអ្នកធ្វើនូវសេចក្តីប្រកួតប្រកាន់ជាដើម

ដល់ក្នុងកាលឥឡូវនេះ ទើបគួរ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុអ្នកធ្វើសេចក្តីប្រកួតប្រកាន់ ធ្វើសេចក្តីឈ្លោះ ធ្វើសេចក្តីវិវាទ ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ ក្នុងសង្ឃទាំងនោះ និយាយយ៉ាងនេះនឹងភិក្ខុទាំងនោះថា នែអាវុសោ ខ្ញុំសូមអង្វរ ចូរលោកទាំងឡាយបវារណាចំពោះយើងទាំងឡាយក្នុងកាលឥឡូវនេះចុះ ។ ត្រូវអាវាសិកភិក្ខុទាំងឡាយនិយាយយ៉ាងនេះនឹងភិក្ខុទាំងឡាយនោះថា នែអាវុសោ លោកទាំងឡាយមិនមែនជាម្ចាស់ក្នុងការបវារណារបស់យើងទេ យើងមិនទាន់បវារណាទៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុអ្នកធ្វើសេចក្តីប្រកួតប្រកាន់ ធ្វើសេចក្តីឈ្លោះ ធ្វើសេចក្តីទាស់ទែង ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ ក្នុងសង្ឃទាំងនោះនៅចាល់តែអស់បុណ្ណមីនោះទៀត ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងនោះទាំងអស់គ្នា បវារណាដោយការមិនចង់ក្នុងតិថីចាតុម៌ ៤ ខែនៃសរទរដូវជាទីរីកនៃផ្កាកុមុទក្នុងបុណ្ណបក្ខ ដែលមកដល់ឥឡូវនេះ (ថ្ងៃពេញបូណ៌មីខែកត្តិក) ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះកំពុងតែបវារណា ហើយមានភិក្ខុឈឺឃាត់បវារណាដល់ភិក្ខុមិនឈឺ ត្រូវភិក្ខុដទៃនិយាយនឹងភិក្ខុឈឺនោះយ៉ាងនេះថា លោកដ៏មានអាយុជាអ្នកមានជម្ងឺ ធម្មតាភិក្ខុឈឺ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ជាបុគ្គលមិនគាប់ចិត្តនឹងការសាកសួរទេ នែអាវុសោ ចូរលោករង់ចាំទាល់

អរោគោ ហោសិ អរោគោ អាកង្ខមានោ ចោទេស្ស-សីតិ ។ ឯវញ្ចេ វុច្ចមានោ ចោទេតិ អនាទរិយេ បាចិត្តិយំ ។ តេហិ ចេ ភិក្ខវេ ភិក្ខូហិ បវារិយមានេ អគិលានោ គិលានស្ស បវារណំ ឋបេតិ សោ ឯវមស្ស វចនីយោ អយំ ខោ អាវុសោ ភិក្ខុ គិលានោ គិលានោ ច អននុយោគក្ខមោ វុត្តោ ភគវតា អាគមេហិ អាវុសោ យាវ អយំ ភិក្ខុ អរោគោ ហោតិ អរោគំ អាកង្ខមានោ ចោទេស្សសីតិ ។ ឯវញ្ចេ វុច្ចមានោ ចោទេតិ អនាទរិយេ បាចិត្តិយំ ។ តេហិ ចេ ភិក្ខវេ ភិក្ខូហិ បវារិយមានេ គិលានោ គិលានស្ស បវារណំ ឋបេតិ សោ ឯវមស្ស វចនីយោ អាយស្មន្តា ខោ គិលានា គិលានោ ច អននុយោគក្ខមោ វុត្តោ ភគវតា អាគមេហិ អាវុសោ យាវ អរោគា ហោថ អរោគោ អរោគំ អាកង្ខមានោ ចោទេស្សសីតិ ។



លោកជាអ្នកសុខ ដល់លោកជាអ្នកសុខហើយ កាលបើត្រូវការនឹងចោទក៏ចោទចុះ ។ កាលបើភិក្ខុនិយាយយ៉ាងនេះហើយ ភិក្ខុដែលឈឺនោះនៅតែចោទ ត្រូវអាបត្តិបាចិត្តិយ ព្រោះមិនអើពើ (នឹងពាក្យយាត់) ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះកំពុងតែបវារណា ហើយមានភិក្ខុមិនឈឺ ឃាត់បវារណាដល់ភិក្ខុឈឺ ត្រូវភិក្ខុដទៃនិយាយនឹងភិក្ខុមិនឈឺនោះយ៉ាងនេះថា ម្នាលអាវុសោ ភិក្ខុនេះឯងឈឺ ក៏ឈ្មោះភិក្ខុឈឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាជាបុគ្គលមិនគួរដល់ការសួរដេញដោលទេ ម្នាលអាវុសោ ចូរលោករង់ចាំទាល់តែភិក្ខុនេះជាអ្នកសុខ ដល់លោកនេះជាអ្នកសុខហើយ កាលបើលោកត្រូវការនឹងចោទក៏ចោទចុះ ។ កាលបើភិក្ខុដទៃនិយាយយ៉ាងនេះហើយ ភិក្ខុមិនឈឺនោះនៅតែចោទ ត្រូវអាបត្តិបាចិត្តិយ ព្រោះមិនអើពើ (នឹងពាក្យយាត់) ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងឡាយនោះកំពុងតែបវារណា ហើយមានភិក្ខុឈឺឃាត់បវារណាដល់ភិក្ខុឈឺ ត្រូវភិក្ខុដទៃនិយាយយ៉ាងនេះនឹងភិក្ខុនោះថា លោកដ៏មានអាយុទាំងឡាយជាអ្នកឈឺ ក៏ឈ្មោះភិក្ខុឈឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាមិនគួរដល់ការសួរដេញដោលឡើយទេ ម្នាលអាវុសោ ចូរលោកចាំទាល់តែលោកទាំងឡាយជាអ្នក ដល់លោកដែលមានរោគ (នោះ) ជាសះស្បើយហើយ កាលបើលោកត្រូវការនឹងចោទលោកភិក្ខុដែលឥតរោគ (នោះចុះ) ។

ឋវេញ្ញ វត្ថុមានោ ហោនេតិ អធានេយ ខាទិតុំ ។ តេហិ ចេ ភិក្ខូហិ ភិក្ខុហិ បវារយមានេ អភិណាគោ អភិណាចស្ស បវារណំ ឋបេតិ ។ ឧភោ សង្ឃេន សមនុយុញ្ជិត្វា សមនុគ្គាហិត្វា យថាធម្មំ ការាបេត្វា សង្ឃេន បវារេតព្វន្តិ ។

[២៤៧] តេន ខោ បន សមយេន សម្ពហុលា សន្ទិដ្ឋា សម្ភត្តា ភិក្ខូ កោសលេសុ ជនបទេសុ អញ្ញតរស្មឹ អាវាសេ វស្សំ ឧបគច្ឆឹសុ ។ តេសំ សមគ្គានំ សម្មោទមានានំ អវិវទមានានំ វិហរតំ អញ្ញតរោ ផាសុវិហារោ អធិគតោ ហោតិ ។ អថ ខោ តេសំ ភិក្ខូនំ ឯតទហោសិ អម្ហាកំ ខោ សមគ្គានំ សម្មោទមានានំ អវិវទមានានំ វិហរតំ អញ្ញតរោ ផាសុវិហារោ អធិគតោ សចេ មយំ ឥទានិ បវារេស្សាម សិយាបិ ភិក្ខូ បវារេត្វា ចារិកំ បក្កមេយ្យុំ ឯវំ មយំ ឥមម្ហា ផាសុវិហារា បរិពាហិរា ភវិស្សាម កថំ នុ ខោ អម្ហេហិ



កាលបើភិក្ខុដទៃនិយាយយ៉ាងនេះហើយ ភិក្ខុណាមួយនោះនៅតែចោទ ត្រូវតាមវិធីកុបចិត្តយ ក្រោមមិនទើតើ (មិនពាក្យយាក់) ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុទាំងពីរពួកនោះក៏ភូមិដែលបវារណា ហើយមានភិក្ខុមិនឈឺយាក់បវារណាដល់ភិក្ខុមិនឈឺ ។ ត្រូវសង្ឃបញ្ចោលភិក្ខុទាំងពីរប្រការដោយត្រឹមត្រូវ សាកសួរដោយត្រឹមត្រូវហើយឲ្យភិក្ខុទាំងនោះធ្វើតាមធម៌ (គឺសំដែងទោសបត្តិ) ហើយសឹមបវារណាចុះ ។

(២៤៧) គ្រាសម័យនោះឯង ពួកភិក្ខុច្រើនរូបជាមិត្តធ្លាប់ឃើញគ្នា ជាមិត្តស្និទ្ធស្នាលនឹងគ្នា ចូលនៅចាំវស្សាក្នុងអាវាសមួយក្នុងកោសលជនបទ ។ កាលភិក្ខុទាំងនោះព្រមព្រៀងគ្នាសោះសារគ្នាមិនវិវាទគ្នា ហើយក៏បានដល់នូវធម៌មួយដែលជាគ្រឿងនៅសប្បាយ[1] ។ គ្រានោះឯង ភិក្ខុទាំងនោះមានសេចក្តីត្រិះរិះដូច្នេះថា កាលយើងទាំងឡាយព្រមព្រៀងគ្នារីករាយគ្នាមិនទាស់ទែងគ្នា ក៏បានដល់នូវធម៌មួយដែលជាគ្រឿងនៅសប្បាយហើយ តបើពេលនេះ បើយើងទាំងឡាយនឹងបវារណា គង់នឹងមានពួកភិក្ខុដែលបវារណារួចហើយ ចៀសចេញទៅកាន់ចារិក យើងទាំងឡាយមុខជានឹងឃ្លាតចាកធម៌ជាគ្រឿងនៅសប្បាយនេះដោយពិតប្រាកដមិនខាន យើងទាំងឡាយ

១ អដ្ឋកថា សំដៅយកសមថៈ ឬវិបស្សនា ដែលទើបនឹងបាន នៅទន់ ឬ ខ្ចីនៅឡើយ ។

បដិបជ្ជិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ឥធ បន ភិក្ខវេ សម្ពហុលា សន្ទិដ្ឋា សម្ភត្តា ភិក្ខូ អញ្ញតរស្មឹ អាវាសេ វស្សំ ឧបគច្ឆន្តិ ។ តេសំ សមគ្គានំ សម្មោទមានានំ អវិវទមានានំ វិហរតំ អញ្ញតរោ ផាសុវិហារោ អធិគតោ ហោតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អម្ហាកំ ខោ សមគ្គានំ សម្មោទមានានំ អវិវទមានានំ វិហរតំ អញ្ញតរោ ផាសុវិហារោ អធិគតោ សចេ មយំ ឥទានិ បវារេស្សាម សិយាបិ ភិក្ខូ បវារេត្វា ចារិកំ បក្កមេយ្យុំ ឯវំ មយំ ឥមម្ហា ផាសុវិហារា បរិពាហិរា ភវិស្សាមាតិ ។ អនុជានាមិ ភិក្ខវេ តេហិ ភិក្ខូហិ បវារណាសង្គហំ កាតុំ ។ ឯវញ្ច បន ភិក្ខវេ កាតព្វោ ។ សព្វេហេវ ឯកជ្ឈំ សន្និបតិតព្វំ ។ សន្និបតិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ សមគ្គានំ សម្មោទមានានំ អវិវទមានានំ វិហរតំ អញ្ញតរោ ផាសុវិហារោ អធិគតោ ។



ត្រូវប្រតិបត្តិដូចម្ដេច ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់បន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុជាច្រើនជាមិត្តឃើញគ្នាជាមិត្តស្និទ្ធស្នាលមាំមួន ចូលទៅចាំវស្សាក្នុងអាវាសមួយ ។ ភិក្ខុទាំងឡាយនោះជាអ្នកព្រមព្រៀងស្មោះសរគ្នា មិនទាស់ទែងគ្នា ហើយបានដល់នូវធម៌ម្យ៉ាងដែលជាគ្រឿងនៅសប្បាយ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនៅក្នុងអាវាសនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា យើងទាំងឡាយជាអ្នកព្រមព្រៀងរីករាយគ្នា មិនវិវាទគ្នា បានដល់នូវធម៌ម្យ៉ាងដែលជាគ្រឿងនៅសប្បាយ ហើយក្នុងវេលានេះ បើប្រសិនជាយើងនឹងបវារណា គង់មានពួកភិក្ខុដែលបវារណារួចហើយចៀសចេញទៅកាន់ចារិក យើងទាំងឡាយមុខជានឹងឃ្លាតចាកធម៌ជាគ្រឿងនៅសប្បាយនេះ ដោយអាការដូច្នេះមិនខាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយនោះធ្វើបវារណាសង្គហៈ ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯបវារណាសង្គហៈនោះ ត្រូវភិក្ខុធ្វើយ៉ាងនេះ ។ ត្រូវភិក្ខុទាំងអស់ប្រជុំក្នុងទីជាមួយគ្នា ។ លុះប្រជុំគ្នាហើយ ត្រូវភិក្ខុដែលឈ្លាសប្រតិពលឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ យើងទាំងឡាយជាអ្នកព្រមព្រៀងគ្នា ស្មោះសរគ្នា មិនវិវាទគ្នា បានដល់នូវធម៌ម្យ៉ាងដែលជាគ្រឿងនៅសប្បាយហើយ ។

## បារាយណវគ្គោ សមត្ថទីបំ បារាយណសុត្តមាតិកា

សព្វេ មយំ ឥទានិ បរិវេសក្ខុម សំយាបិ ភិក្ខុ បករេត្វា ជាតិកំ បត្ថាមេយ្យំ បរំ មយំ ឥមម្ហា ជាសុរិយាភ បរិភាហារ គរិសក្ខម ។ យទិ សព្វស្ស បត្តកាលំ សង្ខេប្ប បារាយណសុត្តំ ការេយ្យ ឥទានិ ទុតិយម្បិ ការេយ្យ ជាតិហេតុំ ទុក្ខំលេយ្យ អាគមំ កោមុទិយា ចាតុម្មាសិនិយា បករេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អជ្ជាតំ សមត្តាចំ សម្មោទមានាចំ សភិទមានាចំ វិហារំ អញ្ញាតកេ ជាសុរិយាភេ អតិភភោ ។ សព្វេ មយំ ឥទានិ បរិវេសក្ខុម សំហោមិ ភិក្ខុ បករេត្វា ជាតិកំ បត្ថាមេយ្យំ បរំ មយំ ឥមម្ហា ជាសុរិយាភ បរិភាហារ គរិសក្ខម ។ សង្ខេប្ប បារាយណសុត្តំ ការេតំ ឥទានិ ទុតិយម្បិ ការំសក្ខំ ជាតិហេតុំ ទុក្ខំសិស្សតិ អាគមេ កោមុទិយា ចាតុម្មាសិនិយា បករេស្សតិ ។ យស្សាយស្មតោ ខមតិ បារាយណសុត្តស្ស ការណំ ឥទានិ ទុតិយម្បិ ការំស្សតិ ជាតិហេតុំ ទុក្ខំសិស្សតិ អាគមេ កោមុទិយា ចាតុម្មាសិនិយា បករេស្សតិ សោ



## បារាយណវគ្គ៖ ការធ្វើបារាយណសុត្តបទៈនៃពួកភិក្ខុក្នុងថ្ងៃចូលវស្សាដំបូង

គឺពេលនេះ បើប្រសិនជាយើងទាំងឡាយនឹងបារាយណទៅ នឹងមានពួកភិក្ខុដែលបានបារាយណហើយចេញទៅកាន់ទិស យើងទាំងឡាយមុខជានឹងឃ្លាតចាកធម៌ជាគ្រឿងនៅសប្បាយនេះ ដោយអាការដូច្នេះមិនខាន ។ បើកម្មាននកាលគួរដល់សង្ឃហើយ សូមសង្ឃធ្វើបារាយណសុត្តបទៈ គួរធ្វើឧបោសថគួរសំដែងបាតិមោក្ខ សូមបារាយណគឺថ្ងៃទី ១៤ រោចខែស្រាពណ៍ដែលជាទីកើតនៃផ្កាកុមុទគឺ (បុណ្ណមក្ខ) ដែលមកដល់គឺកាលឥឡូវនេះ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ យើងទាំងឡាយជាអ្នកព្រមព្រៀងគ្នា រីករាយនឹងគ្នា មិនទាស់ទែងគ្នា បានដល់នូវធម៌ណាដែលជាគ្រឿងនៅសប្បាយហើយ ។ គឺពេលនេះ បើយើងទាំងឡាយនឹងបារាយណទៅនឹងមានពួកភិក្ខុដែលបានបារាយណហើយទៀតចេញទៅកាន់ទិស យើងទាំងឡាយមុខជានឹងឃ្លាតចាកធម៌ជាគ្រឿងនៅសប្បាយនេះ ដោយអាការដូច្នេះមិនខាន ។ ឥឡូវសង្ឃធ្វើបារាយណសុត្តបទៈ ធ្វើឧបោសថ សំដែងបាតិមោក្ខនឹងបារាយណគឺថ្ងៃទី ១៤ រោចខែស្រាពណ៍ដែលជាទីកើតនៃផ្កាកុមុទគឺ (បុណ្ណមក្ខ) ដែលមកដល់គឺកាលឥឡូវនេះ ។ ការធ្វើបារាយណសុត្តបទៈ គឺជាសង្ឃនឹងធ្វើឧបោសថ សំដែងបាតិមោក្ខ នឹងបារាយណគឺថ្ងៃទី ១៤ រោចខែស្រាពណ៍ជាទីកើតនៃផ្កាកុមុទគឺ (បុណ្ណមក្ខ) ដែលមកដល់គឺកាលឥឡូវនេះ គាប់ចិត្តដល់លោកម្ចាស់អង្គណា អង្គលោក

តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នោ សង្ឃេន បវារណាសង្គហោ ឥទានិ ឧបោសថំ ករិស្សតិ បាតិមោក្ខំ ឧទ្ទិសិស្សតិ អាគមេ កោមុទិយា ចាតុម្មាសិនិយា បវារេស្សតិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ តេហិ ចេ ភិក្ខវេ ភិក្ខូហិ កតេ បវារណាសង្គហេ អញ្ញតរោ ភិក្ខុ ឯវំ វទេយ្យ ឥច្ឆាមហំ អាវុសោ ជនបទចារិកំ បក្កមិតុំ អត្ថិ មេ ជនបទេ ករណីយន្តិ ។ សោ ឯវមស្ស វចនីយោ សាធុ អាវុសោ បវារេត្វា គច្ឆាហីតិ ។ សោ ចេ ភិក្ខវេ ភិក្ខុ បវារយមានោ អញ្ញតរស្ស ភិក្ខុនោ បវារណំ ឋបេតិ សោ ឯវមស្ស វចនីយោ អនិស្សរោ ខោ មេ ត្វំ អាវុសោ បវារណាយ ន តាវាហំ បវារេស្សាមីតិ ។ តស្ស ចេ ភិក្ខវេ ភិក្ខុនោ បវារយមានស្ស



ម្ចាស់អង្គនោះស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា គួរលោកម្ចាស់អង្គនោះនិយាយឡើង ។ បវារណាសង្គហៈ នឹងជាសង្ឃឲ្យហើយ ឥឡូវនេះធ្វើឧបោសថ សំដែងបាតិមោក្ខនេះ នឹងបវារណាក្នុងថ្ងៃពេញបូណ៌មី ៤ ខែ នៃខែកត្តិកជាទី កោមុទីនៃថ្ងៃបុណ្ណមី (ពេញបូណ៌មី) ដែលមកដល់ក្នុងកាលខាងមុខនេះ សង្ឃបានធ្វើរួចហើយ ។ បវារណាសង្គហៈនោះគាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវកិច្ចនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងឡាយនោះធ្វើបវារណាសង្គហៈហើយ មានភិក្ខុណាមួយនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំប្រាថ្នានឹងចេញទៅកាន់ចារិកក្នុងជនបទ ព្រោះខ្ញុំមានកិច្ចត្រូវធ្វើក្នុងជនបទ ។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងភិក្ខុនោះយ៉ាងនេះថា នែអាវុសោ ខ្ញុំសូមអង្វរលោកសិន គួរលោកបវារណាហើយសឹមទៅចុះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនោះកំពុងតែបវារណា ឃាត់បវារណាភិក្ខុណាមួយ គួរភិក្ខុដែលត្រូវគេឃាត់នោះនិយាយយ៉ាងនេះនឹងភិក្ខុអ្នកឃាត់នោះថា នែអាវុសោ លោកមិនមែនជាធំក្នុងការបវារណារបស់ខ្ញុំទេ ខ្ញុំនឹងមិនទាន់បវារណា ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ កំពុងតែបវារណា

អញ្ញតរោ ភិក្ខុ តស្ស ភិក្ខុនោ បរិក្ខារំ ឋបេតិ ទុក្កដោ សង្ឃេន សមនុយុញ្ជិត្វា បដិជានាបេត្វា យថាធម្មំ ការាបេតព្វោ ។ សោ ចេ ភិក្ខុ ភិក្ខុ ដំឡេង តំ ការណំ ។ ចំណែក ពុទ្ធនៅ អង្គុរ កោដុនិយា ធាតុម្នាសំងំយា នំ អាភិសំ អាគច្ឆតិ តេហិ ចេ ភិក្ខុហិ ភិក្ខុហិ បរិវ័យ ធា- ទេ អញ្ញតរោ ភិក្ខុ តស្ស ភិក្ខុនោ បរិក្ខារំ ឋបេតិ សោ ឋវមស្ស វចនីយោ អធិស្សរោ ខោ ទេ ត្វំ អាវុសោ បរិភោគាយ បតិតោ អបាត្តិ ។ តេហិ ចេ ភិក្ខុហិ ភិក្ខុហិ បរិវ័យមាទេ សោ ភិក្ខុ អញ្ញតរស្ស ភិក្ខុនោ បរិ- ណាំ ឋបេតិ ។ ទុក្កដោ សង្ឃេន សមនុយុញ្ជិត្វា សម- នុញ្ញាបេត្វា យថាធម្មំ ការាបេតព្វោ សង្ឃេន បរិវារកត្តិ ។

បាចិត្តិយកណ្ឌ ចិត្តំ ចតុត្ថំ ។

នវមំ ខន្ធក វគ្គំ ឧបត្ថម្ភំ ។





ហើយមានភិក្ខុណាមួយយកបរិក្ខារភិក្ខុនោះ ត្រូវសង្ឃដេញដោលសួរភិក្ខុ ទាំងពីររូប លុះសាកសួរហើយសឹមឲ្យភិក្ខុទាំងពីរធ្វើតាមធម៌ (គឺសំដែង អាបត្តិ) ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនោះបានសម្រេចកិច្ចនោះក្នុងខណៈ ហើយត្រឡប់មកកាន់ការសំរាប់នោះវិញ ធ្វើកិច្ចនៅថ្ងៃទី ៤ ទៅនៅសេចក្តីស្មើ ជាទីកន្លែងដំណើរ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងឡាយនោះកំពុងនៅបរិវ- ណោ ហើយមានភិក្ខុណាមួយយកបរិវារណាដល់ភិក្ខុនោះ ភិក្ខុដែល ត្រូវគេយកនោះនិយាយនឹងភិក្ខុអ្នកយកនោះយ៉ាងនេះថា នែអាវុសោ លោកមិនមែនជាអ្នកគ្រប់គ្រងការបរិវារណារបស់ខ្ញុំទេ ខ្ញុំបានបរិវារណាហើយ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងឡាយនោះកំពុងនៅបរិវារណា ភិក្ខុ នោះយកបរិវារណារបស់ភិក្ខុណាមួយ ។ ត្រូវសង្ឃដេញដោលសាកសួរ ភិក្ខុទាំងពីររូប លុះដេញដោលសាកសួរហើយឲ្យភិក្ខុទាំងពីររូបធ្វើតាមធម៌ ហើយសឹមបរិវារណាដោយសង្ឃបរិវារណាចុះ ។

ចប់ បរិវារណាខន្ធកៈ ទី ៤ ។

រឿងក្នុងខន្ធកៈនេះមាន ៤៦ រឿង ។

តស្សុទ្ទានំ

[៤៨] វស្សំ វុត្ថា កោសលេសុ

អាគមុ(១) សត្ថុ ទស្សនំ

អផាសុំ បសុសំវាសំ

អញ្ញមញ្ញានុលោមតា

បច្ចាគតសុខេ ទ្វេ ច

កម្មុត្តិណា ចញ្ញាតកា(២)

ភជា ទោភ ច ទុក្កា ច

កិច្ចុបច្ឆន្ទិកា តថា

បញ្ច ចតុតយោ ទ្វេកោ

១ ម. លភមុំ ។ ២ ម. តម្មំ តិណាចញ្ញាតកា ។





ឧទ្ទាននៃបវារណាក្ខន្ធកៈនោះ គឺ

[៤៨] រឿងពួកភិក្ខុនៅចាំវស្សាក្នុងកោសលជនបទ មកគាល់ព្រះសាស្ដា ១ រឿងភិក្ខុនៅប្រៀបដូចពពួកសត្វ (គឺសត្វដែលគេចិញ្ចឹម) មិនជាទីសប្បាយ ១ រឿងបវារណាជាការអនុលោមដល់គ្នានឹងគ្នា ១ រឿងពួកឆព្វគ្គិយភិក្ខុអង្គុយលើអាសនៈក្នុងវេលាដែលភិក្ខុជាថេរៈកំពុងបវារណា ១ រឿងបវារណាមានពីរយ៉ាង ១ រឿងបវារណាកម្មមួយយ៉ាង ១ រឿងព្រះអង្គទ្រង់អនុញ្ញាតឲ្យភិក្ខុឈឺឲ្យបវារណា ១ រឿងញាតិចាប់ភិក្ខុក្នុងថ្ងៃបវារណា ១ រឿងស្ដេចចាប់ភិក្ខុក្នុងថ្ងៃបវារណា ១ រឿងពួកចោរចាប់ភិក្ខុក្នុងថ្ងៃបវារណា ១ រឿងពួកអ្នកលេងចាប់ភិក្ខុក្នុងថ្ងៃបវារណា ១ រឿងភិក្ខុជាសត្រូវចាប់ភិក្ខុក្នុងថ្ងៃបវារណា ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុប្រាំរូបធ្វើបវារណាដោយសង្ឃបវារណា ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុបួនរូបបវារណាដល់គ្នានឹងគ្នា ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុបីរូបបវារណាដល់គ្នានឹងគ្នា ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុពីររូបបវារណាដល់គ្នានឹងគ្នា ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុមួយរូប

អាបន្នោ វេមតិ សរេ

សព្វោ សង្ឃោ វេមតិកោ

ពហុសមា ច ថោកិកា

អាវាសិកា ចតុទ្ទស

លិង្គសំវាសកា ឧភោ

គន្តព្វំ ន និសិន្នាយ

ឆន្ទទានេ បវារណា[១]

សវរេហិ[២] ខេបិតា មេឃោ

អន្តរា ច បវារណា

ន ឥច្ឆន្តិ បវារេតុំ

---

១ ឱ. ឆន្ទទានបវារណា ។ ២ ឱ. សវរេហិ ។





អធិដ្ឋានបវារណា ១ រឿងភិក្ខុត្រូវអាបត្តិក្នុងថ្ងៃបវារណា ១ រឿងភិក្ខុសង្ស័យអាបត្តិក្នុងថ្ងៃបវារណា ១ រឿងភិក្ខុកំពុងតែបវារណាហើយរលឹកឃើញអាបត្តិ ១ រឿងសង្ឃទាំងអស់ត្រូវសភាគាបត្តិក្នុងថ្ងៃបវារណា ១ រឿងសង្ឃទាំងអស់សង្ស័យសភាគាបត្តិ ១ រឿងភិក្ខុនៅក្នុងអាវាសច្រើនជាង និងស្មើគ្នានឹងតិចជាង ១ រឿងពួកអាវាសិកភិក្ខុប្រកាន់ថាថ្ងៃដប់បួន តែពួកអាគន្តុកភិក្ខុប្រកាន់ថាថ្ងៃដប់ប្រាំ ១ រឿងភេទនិងសំវាសទាំងពីររបស់អាវាសិកភិក្ខុនិងអាគន្តុកភិក្ខុ ១ រឿងភិក្ខុទៅកាន់អាវាសដែលមានភិក្ខុក្នុងថ្ងៃបវារណា ១ រឿងភិក្ខុមិនត្រូវបវារណាក្នុងបរិសទ្យដែលភិក្ខុនីអង្គុយជាមួយ ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុបវារណាក្នុងការឲ្យឆន្ទៈ ១ រឿងសវរភ័យ ១ រឿងមនុស្សឲ្យទានក្នុងថ្ងៃបវារណាដរាបដល់ទៀបភ្លឺ ១ រឿងមានភ្លៀងក្នុងថ្ងៃបវារណា ១ រឿងការអន្តរាយដល់បវារណា ១ រឿងព្រះអង្គទ្រង់ហាមមិនឲ្យភិក្ខុមានអាបត្តិធ្វើបវារណា ១ រឿងពួកឆព្វគ្គិយភិក្ខុគិតថាពួកបេសលភិក្ខុឃាត់បវារណាដល់ពួកយើង

អជ្ជុប្បត្តា ច គិលានោ

កាម្ហិ ជាតំ(១) ការកមញ្ញុ

និដ្ឋេន សុតសត្តាយ

បោនតោ ចុតិតោ ច

ជុល្ហត្ត ច គណ្ហាំ

បវារណាស្ស សង្គហោ(២)

អធិស្សាកេ បវារយេតិ ។

១ ។ ម. ភ. ១ ២ ។. បវារណសង្គហោ ឯ ។



ហើយប្រញាប់យកបវារណា ជាមុន ១ រឿងភិក្ខុយកបវារណា មិនបាន ១ រឿងភិក្ខុយកបវារណា ដល់ភិក្ខុឥតសាគសនៃបវា-រណា ១ (សេចក្តីសួរថា លោកយកបវារណា) ព្រោះហេតុអ្វី ១ រឿងសួរថាតែក្តីប្តូរម្តងទេ ១ រឿងយកបវារណា ដោយឃើញ ដោយឮ ដោយសង្ស័យ ១ រឿងភិក្ខុអ្នកចោទ ១ រឿងភិក្ខុ ដែលត្រូវចោទ ១ រឿងភិក្ខុត្រូវអាបត្តិមួយប៉ុណ្ណោះ ១ រឿងវត្ថុ និងបុគ្គល ១ រឿងភិក្ខុអ្នកធ្វើការវិវាទហេតុ ១ រឿងបវារណា សង្គហៈ ១ រឿងភិក្ខុមិនយកដំណឹងការបវារណា ១ រឿងសង្ឃគ្រូ សាកសួរភិក្ខុទាំងពីររូប ហើយភិក្ខុទាំងពីររូបធ្វើតាមបង់ ហើយសំរេចបវារណា ១ ។

# ចម្មក្ខន្ធកំ

[២៤] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តេន ខោ បន សមយេន រាជា មាគធោ សេនិយោ ពិម្ពិសារោ អសីតិយា គាមិកសហស្សេសុ ឥស្សរិយាធិបច្ចំ(១) រជ្ជំ ការេតិ ។ តេន ខោ បន សមយេន ចម្បាយំ សោណោ នាម កោឡិវិសោ សេដ្ឋិបុត្តោ សុខុមាលោ ហោតិ ។ តស្ស បាទតលេសុ លោមានិ ជាតានិ ហោន្តិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ តានិ អសីតិ(២) គាមិកសហស្សានិ សន្និបាតាបេត្វា កេនចិទេវ ករណីយេន សោណស្ស កោឡិវិសស្ស សន្តិកេ ទូតំ បាហេសិ អាគច្ឆតុ សោណោ ឥច្ឆាមិ សោណស្ស អាគតន្តិ ។

---

១ ឱ. ឥស្សរាធិបច្ចំ ។ ២ អសីតិ គាមិកសហស្សានិ កត្ថចិ បោត្ថកេ ទិស្សតិ ។

# ចម្មក្ខន្ធកៈ

[២៤] សម័យនោះ ព្រះពុទ្ធមានព្រះភាគ គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះបាទមាគធសេនិយពិម្ពិសារសោយរាជ្យជាឥស្សរាធិបតិលើអ្នកស្រុកតូច ៨ ម៉ឺន ។ សម័យនោះឯង ក្នុងក្រុងចម្បា មានកូនសេដ្ឋីម្នាក់ឈ្មោះសោណៈ ជាកោឡិវិសគោត្រ ហើយជាសុខុមាលជាតិ ។ សេដ្ឋីបុត្តនោះមានរោមដុះត្រង់បាតជើងទាំងពីរ ។ គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់ប្រជុំពួកអ្នកស្រុកតូច ៨ ម៉ឺន ហើយទ្រង់បញ្ជូនរាជទូតទៅក្នុងសំណាក់សោណៈកោឡិវិសដោយការកិច្ចអ្វីមួយថា សោណៈចូរមក ព្រោះយើងចង់ឲ្យសោណៈមក ។

អថខោ សោណស្ស កោឡិវិសស្ស មាតាបិតរោ សោណំ កោឡិវិសំ ឯតទវោចុំ រាជា តេ តាត សោណ បាទេ ទក្ខិតុកាមោ មា ខោ ត្វំ តាត សោណ យេន រាជា តេន បាទេ អភិប្បសារេយ្យាសិ រញ្ញោ បុរតោ បល្លង្កេន និសីទ និសិន្នស្ស តេ រាជា បាទេ ទក្ខិស្សតីតិ ។ អថខោ សោណំ កោឡិវិសំ សិវិកាយ អានេសុំ ។ អថខោ សោណោ កោឡិវិសោ យេន រាជា មាគធោ សេនិយោ ពិម្ពិសារោ តេនុបសង្កមិ ឧបសង្កមិត្វា រាជានំ មាគធំ សេនិយំ ពិម្ពិសារំ អភិវាទេត្វា រញ្ញោ បុរតោ បល្លង្កេន និសីទិ ។ អទ្ទសា ខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ សោណស្ស កោឡិវិសស្ស បាទតលេសុ លោមានិ ជាតានិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ តានិ អសីតិ គាមិកសហស្សានិ ទិដ្ឋធម្មិកេ អត្ថេ អនុសាសិត្វា ឧយ្យោជេសិ តុម្ហេ ខ្វត្ថ ភណេ មយា ទិដ្ឋធម្មិកេ អត្ថេ អនុសាសិតា



វេលានោះឯង មាតាបិតានៃសោណកោឡិវិសបាននិយាយពាក្យនេះនឹងសោណកោឡិវិសថា នែសោណៈកូន ឥឡូវស្ដេចចង់ទតមើលជើងរបស់អ្នក នែសោណៈកូន អ្នកឯងកុំលាបាច់លាជើងចង្អុលស្ដេចឡើយ អ្នកឯងគួរអង្គុយពែនភ្នែនចំពោះព្រះភក្ត្រស្ដេចចុះ កាលបើអ្នកអង្គុយនៅហើយស្ដេចនឹងទតឃើញជើងអ្នកហើយ ។ គ្រានោះឯង ពួកជនក៏បាននាំសោណកោឡិវិសមកដោយគ្រែស្នែង ( មកថ្វាយស្ដេច. ) ។ ខណៈនោះ សោណកោឡិវិសក៏បានចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសារ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះបាទមាគធសេនិយពិម្ពិសាររួចហើយអង្គុយពែនភ្នែនចំពោះព្រះភក្ត្រស្ដេច ។ ឯព្រះបាទមាគធសេនិយពិម្ពិសារក៏បានទតទៅឃើញរោមទាំងឡាយដែលដុះក្នុងបាតជើងរបស់សោណកោឡិវិស ។ គ្រានោះឯង ព្រះបាទមាគធសេនិយពិម្ពិសារទ្រង់បានប្រដៅប្រយោជន៍ (១) ទាំងឡាយជាបច្ចុប្បន្ន ចំពោះពួកអ្នកស្រុកទាំង ៨ ម៉ឺននោះស្រេចហើយក៏ទ្រង់បញ្ជូនទៅវិញថា នែនាយទាំងឡាយ យើងបានប្រដៅអ្នកទាំងអស់គ្នាក្នុងប្រយោជន៍ជាបច្ចុប្បន្នហើយ

១ (អដ្ឋកថា) សំដៅយកអំពើទាំងឡាយ មានការភ្ជួរស្រែនិងលក់ដូរជាដើមដែលប្រកបដោយធម៌ និងចិញ្ចឹមមាតាបិតាដែលប្រកបដោយធម៌ ។

គច្ឆថ ភគវន្តំ[១] បយិរុបាសថ សោ នោ ភគវា សម្ប-រាយិកេ អត្ថេ អនុសាសិស្សតីតិ ។ អថខោ តានិ អសីតិ គាមិកសហស្សានិ យេន គិជ្ឈកូដោ បព្វតោ តេនុបសង្កមឹសុ ។ តេន ខោ បន សមយេន អា-យស្មា សាគតោ ភគវតោ ឧបដ្ឋាកោ ហោតិ ។ អថខោ តានិ អសីតិ គាមិកសហស្សានិ យេនាយស្មា សាគ-តោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ សាគតំ ឯតទវោចុំ ឥមានិ ភន្តេ អសីតិ គាមិកសហស្សានិ ឥធូបសង្កន្តានិ ភគវន្តំ ទស្សនាយ សាធុ មយំ ភន្តេ លភេយ្យាម ភគវន្តំ ទស្សនាយាតិ ។ តេនហិ តុម្ហេ អាយស្មន្តោ មុហុត្តំ ឥធេវ តាវ ហោថ យាវាហំ ភគវន្តំ បដិវេទេមីតិ ។ អថខោ អាយស្មា សាគតោ តេសំ អសីតិ-យា គាមិកសហស្សានំ បុរតោ បេក្ខមានានំ បាដិកាយ និមុជ្ជិត្វា ភគវតោ បុរតោ ឧម្មុជ្ជិត្វា ភគវន្តំ ឯតទវោច ឥមានិ ភន្តេ អសីតិ គាមិកសហស្សានិ ឥធូបសង្កន្តានិ

១ ម. តំ ភគវន្តំ ។



អ្នកទាំងឡាយចូលនាំគ្នាទៅវិញចុះ តែអ្នកទាំងឡាយត្រូវនាំគ្នាទៅគាល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគនោះមុខជាទំនងប្រៀនប្រដៅនូវប្រ-យោជន៍ទាំងឡាយក្នុងបរលោកដល់យើងទាំងឡាយ ។ វេលានោះឯង ពួកអ្នកស្រុកទាំង ៨ ម៉ឺននោះបាននាំគ្នាទៅឯគិជ្ឈកូដ ។ សម័យនោះឯង ព្រះសាគតដ៏មានអាយុជាអ្នកបំរើព្រះដ៏មានព្រះភាគ ។ វេលានោះ ពួកអ្នកស្រុកទាំង ៨ ម៉ឺននោះបានចូលទៅរកព្រះសាគតដ៏មានអាយុ លុះចូលទៅដល់ហើយក៏បាននិយាយពាក្យនេះនឹងព្រះសាគតដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ឥឡូវពួកអ្នកស្រុកទាំង ៨ ម៉ឺននេះបានចូលមកក្នុងទីនេះដើម្បីឃើញព្រះដ៏មានព្រះភាគ បពិត្រលោកដ៏ចំរើន យើងខ្ញុំគួរបានឃើញព្រះដ៏មានព្រះភាគដោយល្អប្រពៃ ។ ព្រះសាគតក៏តបវិញថា នែអ្នកដ៏មានអាយុទាំងឡាយ បើដូច្នោះ អ្នករាល់គ្នាឈប់បន្តិចចាំអាត្មានៅទីនេះ១ស្របក់ចុះ ចាំអាត្មាក្រាបទូលព្រះដ៏មានព្រះភាគសិន ។ គ្រានោះឯង កាលពួកអ្នកស្រុកទាំង៨ម៉ឺននោះកំពុងតែសំឡឹងមើលក្នុងទីចំពោះមុខ ព្រះសាគតដ៏មានអាយុក៏ជ្រែកចុះទៅផែនថ្ម[១] ហើយទៅផុសក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ រួចក៏បានពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវមានពួកអ្នកស្រុកទាំង៨ម៉ឺននេះបាន

១ អដ្ឋកថា ថា ផែនថ្មមានសណ្ឋានដូចព្រះចន្ទពាក់កណ្ដាលដែលនៅខាងក្រោមជណ្ដើរ ។

ភគវន្តំ ទស្សនាយ យស្សទានិ ភន្តេ ភគវា កាលំ មញ្ញតីតិ ។ តេនហិ ត្វំ សាគត វិហារបច្ឆាយាយំ អាសនំ បញ្ញបេហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា សាគតោ ភគវតោ បដិស្សុណិត្វា បីឋំ គហេត្វា ភគវតោ បុរតោ និមុជ្ជិត្វា តេសំ អសីតិយា គាមិកសហស្សានំ បុរតោ បេក្ខមានានំ បាដិកាយ ឧម្មុជ្ជិត្វា វិហារបច្ឆាយាយំ អាសនំ បញ្ញបេសិ ។ អថខោ ភគវា វិហារា និក្ខមិត្វា វិហារបច្ឆាយាយំ បញ្ញត្តេ អាសនេ និសីទិ ។ អថខោ តានិ អសីតិ គាមិកសហស្សានិ យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិំសុ ។ អថខោ តានិ អសីតិ គាមិកសហស្សានិ អាយស្មន្តំយេវ សាគតំ សមន្នាហរន្តិ នោ តថា ភគវន្តំ ។ អថខោ ភគវា តេសំ អសីតិយា គាមិកសហស្សានំ ចេតសា ចេតោបរិវិតក្កមញ្ញាយ អាយស្មន្តំ សាគតំ អាមន្តេសិ តេនហិ ត្វំ សាគត



ចូលមកក្នុងទីនេះដើម្បីឃើញព្រះដ៏មានព្រះភាគ បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគរមែងជ្រាបនូវកាលគួរជាប្រយោជន៍ក្នុងកាលឥឡូវនេះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នែសាគត បើដូច្នោះ អ្នកចូរទៅរៀបចំក្រាលអាសនៈត្រង់ម្លប់នៃវិហារចុះ ។ ព្រះសាគតដ៏មានអាយុបានទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ហើយក៏នាំយកតាំងដែលមុជចុះក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ កាលអ្នកស្រុកតាំង៨ម៉ឺននោះកំពុងសំឡឹងមើលក្នុងទីចំពោះមុខ ក៏ស្រាប់តែទៅផុសចេញផែនថ្មហើយក្រាលអាសនៈត្រង់ម្លប់នៃវិហារ ។ វេលានោះ ព្រះមានព្រះភាគទ្រង់យាងចេញអំពីវិហារទៅគង់នៅលើអាសនៈដែលព្រះសាគតក្រាលទុកក្រោមត្រង់ម្លប់នៃវិហារ ។ លំដាប់នោះឯង ពួកអ្នកស្រុកតាំង៨ម៉ឺននោះបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ គ្រានោះ ពួកអ្នកស្រុកតាំង ៨ ម៉ឺននោះក៏ខំបែរកត់ចំណាំនឹងព្រះសាគតដ៏មានអាយុទៅវិញ មិនបានខំបែរកត់ចំណាំនឹងព្រះដ៏មានព្រះភាគដូច្នោះឡើយ ។ វេលានោះឯង ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់នូវការត្រិះរិះក្នុងចិត្តរបស់ពួកអ្នកស្រុកតាំង ៨ ម៉ឺនដោយព្រះទ័យនោះហើយ ទើបទ្រង់ត្រាស់ហៅព្រះសាគតដ៏មានអាយុមកថា នែសាគត បើដូច្នោះអ្នកចូរសំដែង

ភិយ្យោសោ មត្តាយ ឧត្តរិមនុស្សធម្មំ ឥទ្ធិបាដិហារិយំ ទស្សេស្សតីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា សាគតោ ភគវ-តោ បដិស្សុណិត្វា វេហាសំ អព្ភុគ្គន្ត្វា អាកាសេ អន្ត-លិក្ខេ ចង្កមតិបិ តិដ្ឋតិបិ និសីទតិបិ សេយ្យំបិ កប្បេតិ បធូបាយតិបិ(១) បជ្ជលតិបិ អន្តរធាយតិបិ ។ អថខោ អា-យស្មា សាគតោ អាកាសេ អន្តលិក្ខេ អនេកវិហិតំ ឧត្ត-រិមនុស្សធម្មំ ឥទ្ធិបាដិហារិយំ ទស្សេត្វា ភគវតោ បាទេសុ សិរសា និបតិត្វា ភគវន្តំ ឯតទវោច សត្ថា មេ ភន្តេ ភគវា សាវកោហមស្មិ សត្ថា មេ ភន្តេ ភគវា សាវកោ-ហមស្មីតិ ។ អថខោ តានិ អសីតិ គាមិកសហស្សានិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ សាវកោបិ នាម ឯវំ-មហិទ្ធិកោ ភវិស្សតិ ឯវំមហានុភាវោ អហោ នូន សត្ថា-តិ ភគវន្តំយេវ សមន្នាហរន្តិ នោ តថា អាយស្មន្តំ

១ ម. ធូមាយតិ ។



ឥទ្ធិបាដិហារិយ៍ដែលជាធម៌របស់មនុស្សជាន់ខ្ពស់ឲ្យក្រៃលែងឡើងទៅទៀត ។ ព្រះសាគតដ៏មានអាយុបានទទួលស្ដាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ហោះទៅលើវេហាស៍ ចង្ក្រម គឺដើរខ្លះ ឈរខ្លះ អង្គុយខ្លះ ដេកខ្លះ បណ្ដាលឲ្យកើតផ្សែងខ្លះ បណ្ដាលឲ្យកើតភ្លើងខ្លះ បាត់ខ្លួនទៅខ្លះ ក្នុងវេហាស៍ គឺអាកាស ។ វេលានោះ ព្រះសាគតដ៏មានអាយុ លុះបានសំដែងឥទ្ធិបាដិហារិយ៍ ជាធម៌របស់មនុស្សជាន់ខ្ពស់ មានប្រការច្រើនយ៉ាងទៅលើវេហាស៍ គឺអាកាសរួចហើយ ក៏មកក្រាបសំពះ ទៀបព្រះបាទនៃព្រះមានព្រះភាគ ហើយក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ជាគ្រូរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគ ជាគ្រូរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក ។ ខណៈនោះ អ្នកស្រុកចំនួន ៨ ម៉ឺននោះក៏ពោលថា ម្នាលអ្នកដ៏ចំរើន គួរអស្ចារ្យពេកណាស់ ម្នាលអ្នកដ៏ចំរើន ហេតុដែលមិនធ្លាប់កើតមានឡើងហើយតើ សូម្បីសាវកបានឫទ្ធិ មានអានុភាពច្រើនម្ល៉េះទៅហើយ ចំណង់បើគ្រូនឹងមានឫទ្ធានុភាពក្រៃលែង ជាមិនខានពិតប្រាកដ ហើយបែរមកផ្ចង់ចិត្តនឹងព្រះដ៏មានព្រះភាគវិញ មិនបែរមកផ្ចង់ចិត្តនឹងព្រះសាគត

សាគតំ ។ អថខោ ភគវា តេសំ អសីតិយា គាមិកសហស្សានំ ចេតសា ចេតោ បរិវិតក្កមញ្ញាយ អនុបុព្វិកថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា តេ ភគវា អញ្ញាសិ កល្លចិត្តេ មុទុចិត្តេ វិនីវរណចិត្តេ ឧទគ្គចិត្តេ បសន្នចិត្តេ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ តេសំ អសីតិយា គាមិកសហស្សានំ តស្មិំយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។ តេ ទិដ្ឋធម្មា បត្តធម្មា



ដ៏មានអាយុជាច្រើនទៀតឡើយ ។ វេលានោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ជ្រាបសេចក្តីបរិវិតក្កក្នុងចិត្តរបស់ពួកអ្នកស្រុកចំនួន ៨ ម៉ឺននោះ ដោយព្រះហឫទ័យហើយ ទើបទ្រង់សំដែងនូវអនុបុព្វីកថា ឯអនុបុព្វីកថានោះតើដូចម្តេចខ្លះ គឺព្រះអង្គទ្រង់សំដែងទានកថា សីលកថា សគ្គកថា សំដែងទោសរបស់កាមគុណដែលជារបស់លាមកសៅហ្មង និងអានិសង្សក្នុងការចេញបួស ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់បានជ្រាបថាពួកជនទាំងនោះមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តរីករាយឡើង មានចិត្តជ្រះថ្លាក្នុងវេលាណាហើយ ក៏ទ្រង់សំដែងនូវធម្មទេសនាដែលព្រះពុទ្ធទាំងឡាយតែងលើកឡើងសំដែងដោយព្រះអង្គឯង គឺសំដែងទុក្ខ ហេតុដែលនាំឲ្យកើតទុក្ខ សេចក្តីរលត់នៃទុក្ខ និងផ្លូវដែលដល់នូវសេចក្តីរលត់ទុក្ខ ក្នុងវេលានោះ ។ សំពត់ស្អាតប្រាសចាកកន្ទក់មានពណ៌ខ្មៅគួរទទួលយកគ្រឿងជ្រលក់ដោយល្អយ៉ាងណាមិញ ធម្មចក្ខុ (គឺសោតាបត្តិមគ្គ) ឥតមានធូលី ឥតមានមន្ទិល ក៏កើតឡើងដល់ពួកអ្នកស្រុក ៨ ម៉ឺននោះលើអាសនៈនោះថា ធម្មជាតឯណានីមួយ មានសេចក្តីកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ រមែងមានសេចក្តីរលត់ទៅវិញជាធម្មតា យ៉ាងនោះឯង ។ ពួកជនទាំងនោះក៏បានឃើញនូវអរិយសច្ចធម៌ហើយ បានដល់នូវអរិយសច្ចធម៌ហើយ

វិទិតធម្មា បរិយោគាឡ្ហធម្មា តិណ្ណវិចិកិច្ឆា វិគតកថំ-
កថា វេសារជ្ជប្បត្តា អបរប្បច្ចយា សត្ថុ សាសនេ
ភគវន្តំ ឯតទវោចុំ អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ
សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ
វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ
វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ
ឯវមេវំ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ
ឯតេ មយំ ភន្តេ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុ-
សង្ឃញ្ច ឧបាសកេ នោ ភគវា ធារេតុ អជ្ជតគ្គេ
បាណុបេតំ សរណំ គតេតិ ។

(៩០) អថខោ សោណស្ស កោឡិវិសស្ស ឯតទ-
ហោសិ យថា យថា ខោ អហំ ភគវតា ធម្មំ ទេសិតំ
អាជានាមិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្ត-





បានដឹងច្បាស់នូវអរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌
ហើយ ឆ្លងផុតសេចក្ដីសង្ស័យ ប្រាសចេញចាកសេចក្ដីងឿងឆ្ងល់ដល់នូវ
សេចក្ដីក្លៀវក្លា មិនបាច់ជឿបុគ្គលដទៃក្នុងសាសនានៃព្រះសាស្ដា ក៏បាន
ក្រាបបង្គំទូលភាសិតនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន
ច្បាស់ណាស់ហើយ បពិត្រព្រះអង្គដ៏ចំរើន ច្បាស់ណាស់ហើយ បពិត្រ
ព្រះអង្គដ៏ចំរើន បុគ្គលផ្ងារឡើងនូវភាជន៍ដែលគេផ្កាប់ចុះ ឬបើកឡើងនូវ
វត្ថុដែលគេបិទ ឬប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ឬក៏ទ្រោលបំភ្លឺប្រទីបប្រេងក្នុង
ទីងងឹតដោយគិតថា ពួកជនដែលមានចក្ខុនឹងបានឃើញនូវរូបទាំងឡាយ
យ៉ាងណាមិញ ធម៌ដែលព្រះដ៏មានព្រះភាគបានសំដែងដោយអនេកបរិ-
យាយ ក៏ដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងឡាយនេះសូមដល់
នូវព្រះដ៏មានព្រះភាគជាម្ចាស់ផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផងជាទី
រលឹក សូមព្រះដ៏មានព្រះភាគជាម្ចាស់ចាំទុកនូវយើងខ្ញុំថាជាឧបាសកបាន
ដល់ព្រះរតនត្រ័យជាទីរលឹកស្មើដោយជីវិតតាំងពីថ្ងៃនេះទៅ ។

(៩០) គ្រានោះ សោណកោឡិវិសមានសេចក្ដីត្រិះរិះដូច្នេះថា
ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ យ៉ាងណា ៗ អាត្មាអញ
ក៏បានដឹងជាក់ បុគ្គលដែលនៅគ្រប់គ្រងផ្ទះនេះមិនងាយនឹងប្រព្រឹត្ត

រិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ អថខោ តានិ អសីតិ គាមិកសហស្សានិ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កមឹសុ ។ អថខោ សោណោ កោឡិវិសោ អចិរបក្កន្តេសុ អសីតិយា គាមិកសហស្សេសុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោណោ កោឡិវិសោ ភគវន្តំ ឯតទវោច យថា យថាហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ ឥច្ឆាមហំ ភន្តេ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា



ព្រហ្មចរិយធម៌ឲ្យពេញលេញ ឲ្យបរិសុទ្ធដោយចំណែក ១ ដូចជាសង្ខដែលបុគ្គលដុសខាត់ហើយទេ បើដូច្នោះមានតែអាត្មាអញនឹងកោរសក់ពុកមាត់ហើយស្លៀកដណ្តប់សំពត់កាសាយៈចេញចាកផ្ទះហើយ បួសក្នុងភាពនៃបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ ។ ខណៈនោះ ពួកអ្នកស្រុកទាំង ៨ ម៉ឺននោះក៏បានត្រេកអររីករាយនឹងធម៌ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយក៏ក្រោកចេញចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចធ្វើប្រទក្សិណហើយក៏ចៀសចេញទៅ ។ វេលានោះឯង សោណកោឡិវិស កាលបើពួកអ្នកស្រុកទាំង ៨ ម៉ឺនចៀសចេញទៅមិនយូរប៉ុន្មាន បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ សោណកោឡិវិស លុះអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះអង្គទ្រង់សំដែងហើយយ៉ាងណា ៗ ខ្ញុំព្រះអង្គក៏ដឹងច្បាស់ទាំងអស់ បុគ្គលដែលនៅគ្រប់គ្រងផ្ទះមិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបានពេញលេញ ឲ្យបានបរិសុទ្ធដោយចំណែក ១ ដូចជាសង្ខដែលបុគ្គលដុសខាត់ហើយទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចង់កោរសក់នឹងពុកមាត់ហើយស្លៀកដណ្តប់

អគារស្មា អនគារិយំ បព្វជិតុំ បព្វាជេតុ មំ ភន្តេ ភគវាតិ ។ អលត្ថ ខោ សោណោ កោឡិវិសោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ច បនាយស្មា សោណោ សីតវនេ វិហរតិ ។ តស្ស អច្ចារទ្ធវីរិយស្ស ចង្កមតោ បាទា ភិជ្ជិំសុ ។ ចង្កមោ លោហិតេន ផុដ្ឋោ[១] ហោតិ សេយ្យថាបិ គវាឃាតនំ ។ អថ ខោ អាយស្មតោ សោណស្ស រហោគតស្ស បដិ-សល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យេ ខោ កេចិ ភគវតោ សាវកា អារទ្ធវីរិយា វិហរន្តិ អហំ តេសំ អញ្ញតរោ អថ ច បន មេ នានុបាទាយ អាសវេហិ ចិត្តំ វិមុច្ចតិ សំវិជ្ជន្តិ ខោ បន មេ កុលេ ភោគា សក្កា ភោគេ ច ភុញ្ជិតុំ បុញ្ញានិ ច កាតុំ យន្នូនាហំ ហី-នាយាវត្តិត្វា ភោគេ ច ភុញ្ជេយ្យំ បុញ្ញានិ ករេយ្យន្តិ ។

---

១. ផុដោ ។



សំពត់កាសាយៈ ចេញចាកផ្ទះហើយ ចូលកាន់ភាពនៃបុគ្គលមិនមានប្រយោ-ជន៍ដោយផ្ទះ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទ្រង់ព្រះមេត្តា បំបួសខ្ញុំព្រះអង្គ ។ សោណៈពោលសូមបព្វជ្ជាចាប់ឧបសម្បទាក្នុងសំណាក់ព្រះមានព្រះភាគ លុះព្រះសោណៈដ៏មានអាយុបានឧបសម្បទាមិនយូរប៉ុន្មាន ក៏បានទៅនៅក្នុងព្រៃសីតវ័ន (ព្រៃត្រជាក់) ។ កាលសោណ-កុមារនោះប្រារព្ធព្យាយាមខ្លាំងដើរចង្ក្រមទៅ បាតាជើងរបស់លោកក៏បែក (ចេញឈាម) ។ ទីចង្ក្រមក៏ប្រឡាក់ដោយឈាម ដូចជាទីដែលសម្រាប់សម្លាប់គោ ។ គ្រានោះ កាលព្រះសោណៈដ៏មានអាយុសម្ងំគង់នៅស្ងាត់ ក៏កើតការត្រិះរិះក្នុងចិត្តយ៉ាងនេះថា ពួកសាវ័កឯណាមួយនៃព្រះដ៏មានព្រះ-ភាគដែលមានព្យាយាមប្រឹងប្រែង បណ្ដាសាវ័កទាំងនោះ អាត្មាអញក៏ជាសាវ័កមួយដែរ តែបើទុកជាដូច្នោះ ក៏ចិត្តរបស់អាត្មាអញនៅមិនទាន់ផុតចាកអាសវៈដោយមិនមានឧបាទានឡើយ ឯត្រកូលរបស់អាត្មាអញក៏មានទ្រព្យសម្បត្តិច្រើនបរិបូណ៌ដែរ អាត្មាអញអាចនឹងបរិភោគទ្រព្យសម្បត្តិផង អាចនឹងធ្វើបុណ្យផង បើដូច្នោះគួរអាត្មាអញវិលត្រឡប់ទៅដើម្បីហីន-ភេទវិញ (គឺសឹក) ហើយនឹងបរិភោគទ្រព្យសម្បត្តិផង ធ្វើបុណ្យផង ។

អថខោ ភគវា អាយស្មតោ សោណស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ គិជ្ឈកូដេ បព្វតេ អន្តរហិតោ សីតវនេ បាតុរហោសិ ។ អថខោ ភគវា សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ សេនាសនចារិកំ អាហិណ្ឌន្តោ យេនាយស្មតោ សោណស្ស ចង្កមោ តេនុបសង្កមិ ។ អទ្ទសា ខោ ភគវា អាយស្មតោ សោណស្ស ចង្កមំ លោហិតេន ផុដ្ឋំ ទិស្វាន ភិក្ខូ អាមន្តេសិ កស្ស ន្វាយំ[១] ភិក្ខវេ ចង្កមោ លោហិតេន ផុដ្ឋោ សេយ្យថាបិ គវាឃាតនន្តិ ។ អាយស្មតោ ភន្តេ សោណស្ស អច្ចារទ្ធវីរិយស្ស ចង្កមតោ បាទា ភិជ្ជឹសុ តស្សាយំ ចង្កមោ លោហិតេន ផុដ្ឋោ សេយ្យថាបិ គវាឃាតនន្តិ ។ អថខោ ភគវា យេនាយស្មតោ សោណស្ស វិហារោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។

១ ត្វាយន្តិបិ កត្ថចិ បោត្ថកេ ទិស្សតិ ។



សំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបសេចក្តីត្រិះរិះក្នុងចិត្តរបស់ព្រះសោណៈដ៏មានអាយុដោយព្រះទ័យហើយ ក៏ស្រាប់តែបាត់ព្រះអង្គពីលើភ្នំគិជ្ឈកូដទៅប្រាកដព្រះអង្គនៅឯព្រៃសីតវន ប្រៀបដូចបុរសមានកម្លាំងលាចេញនូវដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដៃដែលខ្លួនលាចេញ ។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់សេនាសនចារិកជាមួយនឹងភិក្ខុទាំងច្រើនរូប បានយាងសំដៅទៅកាន់ទីចង្ក្រមរបស់ព្រះសោណៈដ៏មានអាយុនោះ ។ ព្រះមានព្រះភាគក៏បានទតទៅឃើញទីចង្ក្រមរបស់ព្រះសោណៈដ៏មានអាយុប្រឡាក់ដោយឈាម លុះទតឃើញហើយក៏ត្រាស់ហៅភិក្ខុទាំងឡាយមកសួរថា ម្នាលភិក្ខុទាំងឡាយ ទីចង្ក្រមនេះ ជាទីចង្ក្រមរបស់អ្នកណា បានជាប្រឡាក់ដោយឈាមដូចជាទីសម្រាប់សម្លាប់គោ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលព្រះសោណៈដ៏មានអាយុទំព្យាយាមដើរចង្ក្រមទៅ បាទារបស់លោកក៏បែក នេះជាទីចង្ក្រមរបស់លោកនោះដែលប្រឡាក់ដោយឈាម ដូចជាទីដែលសម្រាប់សម្លាប់គោ ។ វេលានោះ ព្រះមានព្រះភាគទ្រង់យាងចូលទៅកាន់វិហាររបស់ព្រះសោណៈដ៏មានអាយុ លុះយាងចូលទៅដល់ហើយ ក៏ទ្រង់គង់នៅលើអាសនៈដែលគេបានក្រាលទុក ។

អាយស្មាបិ ខោ សោណោ ភគវន្តំ អភិវាទេត្វា ឯកម-
ន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ
សោណំ ភគវា ឯតទវោច ននុ តេ សោណ រហោគត-
ស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ
យេ ខោ កេចិ ភគវតោ សាវកា អារទ្ធវីរិយា វិហរន្តិ
អហំ តេសំ អញ្ញតរោ អថ ច បន មេ នានុបាទាយ អា-
សវេហិ ចិត្តំ វិមុច្ចតិ សំវិជ្ជន្តិ ខោ បន មេ កុលេ ភោ-
គា សក្កា ភោគេ ច ភុញ្ជិតុំ បុញ្ញានិ ច កាតុំ យន្នូ-
នាហំ ហីនាយាវត្តិត្វា ភោគេ ច ភុញ្ជេយ្យំ បុញ្ញានិ
ច ករេយ្យន្តិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញសិ សោណ
កុសលោ ត្វំ បុព្វេ អគារិកភូតោ វីណាយ តន្តិស្ស-
រេតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញសិ សោណ យទា
តេ វីណាយ តន្តិយោ អច្ចាយិកា[១] ហោន្តិ អបិ នុ តេ

១ ម. អច្ចាយតា ។



ចំណែកខាងព្រះសោណៈដ៏មានអាយុ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ
រួចហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះសោណៈដ៏មានអាយុគង់
នៅក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលយ៉ាង
នេះថា នែសោណៈ កាលអ្នកសម្ងំនៅក្នុងទីស្ងាត់ ក៏កើតការត្រិះរិះក្នុងចិត្ត
យ៉ាងនេះថា ពួកសាវកណាមួយរបស់ព្រះមានព្រះភាគ ដែលមានព្យា-
យាមប្រឹងប្រែង បណ្ដាសាវកទាំងនោះ អាត្មាអញក៏ជាសាវកមួយដែរ
តែបើទុកជាដូច្នោះ គឺចិត្តរបស់អាត្មាអញនៅមិនទាន់ផុតចាកអាសវៈទាំង
ឡាយ ដោយមិនមានឧបាទានឡើយ ម្យ៉ាងទៀត ទ្រព្យសម្បត្តិក្នុងត្រកូល
របស់អាត្មាអញក៏មានបរិបូណ៌ អាត្មាអញអាចនឹងបរិភោគទ្រព្យសម្បត្តិផង
ធ្វើបុណ្យផង បើដូច្នោះ គួរអាត្មាអញវិលត្រឡប់ទៅដើម្បីហីនភេទ ហើយ
បរិភោគនូវទ្រព្យសម្បត្តិផង ធ្វើបុណ្យផង ។ សោណភិក្ខុនោះក្រាប
ទូលថា បពិត្រព្រះអង្គដ៏ចំរើន ពិតមែន ។ ព្រះមានព្រះភាគទ្រង់
ត្រាស់ថា នែសោណៈ អ្នកឯងសំគាល់ហេតុនោះដូចម្ដេច កាលពីដើមអ្នក
ឯងនៅជាគ្រហស្ថ ឈ្លាសក្នុងសូរសំឡេងខ្សែពិណឬ ។ ព្រះ
សោណៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ពិតមែន ។ ព្រះមានព្រះ
ភាគទ្រង់ត្រាស់ថា នែសោណៈ អ្នកឯងសំគាល់ហេតុនោះដូចម្ដេច កាល
ណាខ្សែពិណរបស់អ្នកតឹងពេកទៅ អើពិណរបស់អ្នកឯង មានសំឡេង

វីណា តស្មិំ សមយេ សរវតី វា ហោតិ កម្មញ្ញា វាតិ ។ នោ ហេតំ ភន្តេតិ ។ តំ កឹ មញ្ញសិ សោណ យទា តេ វីណាយ តន្តិយោ អតិសិថិលា ហោន្តិ អបិ នុ តេ វីណា តស្មិំ សមយេ សរវតី វា ហោតិ កម្មញ្ញា វាតិ ។ នោ ហេតំ ភន្តេតិ ។ តំ កឹ មញ្ញសិ សោណ យទា តេ វីណាយ តន្តិយោ នេវ អច្ចាយតា ហោន្តិ នាតិសិ-ថិលា សមេ គុណេ បតិដ្ឋិតា អបិ នុ តេ វីណា តស្មិំ សមយេ សរវតី វា ហោតិ កម្មញ្ញា វាតិ ។ ឯវំ ភន្តេតិ ។ ឯវមេវ ខោ សោណ អច្ចារទ្ធវីរិយំ ឧទ្ធច្ចាយ សំវត្តតិ អតិ-សិថិលវីរិយំ កោសជ្ជាយ សំវត្តតិ តស្មាតិហ ត្វំ សោណ វីរិយសមតំ អធិដ្ឋាហិ(១) ឥន្ទ្រិយានញ្ច សមតំ បដិវិជ្ឈ តត្ថ ច និមិត្តំ គណ្ហាហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា សោណោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា

១ ម. អធិដ្ឋហ ។



ពីរោះឬ គួរដល់ការប្រគំក្នុងកាលនោះដែរឬ ។ ព្រះសោណៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ការនុ៎ះមិនមែនដូច្នោះទេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែសោណៈ អ្នកសំគាល់ហេតុនោះដូចម្តេច កាលណាខ្សែពិណរបស់អ្នកធូរពេក តើពិណរបស់អ្នកនឹងមានសំឡេងពីរោះឬ គួរដល់ការប្រគំក្នុងកាលនោះដែរឬ ។ ព្រះសោណៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ការនុ៎ះមិនមែនដូច្នោះទេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែសោណៈ អ្នកសំគាល់ហេតុនោះដូចម្តេច កាលណាខ្សែពិណរបស់អ្នកមិនតឹងពេក មិនធូរពេក តាំងនៅក្នុងគុណដ៏ល្មម តើពិណរបស់អ្នកនឹងមានសំឡេងពីរោះឬ គួរដល់ការប្រគំក្នុងកាលនោះដែរឬ ។ ព្រះសោណៈនោះក្រាបទូលថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែសោណៈ សេចក្តីព្យាយាមដែលតឹងពេកនាំឲ្យកើតសេចក្តីរាយមាយ សេចក្តីព្យាយាមដែលធូរពេក នាំឲ្យកើតសេចក្តីខ្ជិលច្រអូស ដូចខ្សែពិណយ៉ាងនោះឯង ព្រោះហេតុនោះ នែសោណៈ ក្នុងវេលានេះ អ្នកចូរតាំងសេចក្តីព្យាយាមឲ្យស្មើក្នុងធម្មវិធីយ៉ាងនេះ ត្រូវចម្រើនឥន្ទ្រិយទាំងឡាយឲ្យស្មើគ្នាផង ត្រូវកាន់យកនូវនិមិត្តក្នុងសមថៈនោះផង ។ ព្រះសោណៈដ៏មានអាយុបានទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគដោយពាក្យថា ព្រះករុណា ព្រះអង្គ ។ វេលានោះឯង ព្រះមានព្រះភាគ

អាយស្មន្តំ សោណំ ឥមិនា ឱវាទេន ឱវទិត្វា សេយ្យ-ថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ ប-សារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ សីតវនេ អាយស្មតោ សោណស្ស បមុខេ អន្តរហិតោ គិជ្ឈកូដេ បព្ពតេ បាតុរហោសិ ។ អថខោ អាយស្មា សោណោ អបរេន សមយេន វីរិយសមតំ អធិដ្ឋាសិ ឥន្ទ្រិយានញ្ច សមតំ បដិវិជ្ឈិ តត្ថ ច និមិត្តំ អគ្គហេ-សិ ។ អថខោ អាយស្មា សោណោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្-ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា សោណោ អរហតំ អហោសិ ។



ទ្រង់ទូន្មានព្រះសោណៈដ៏មានអាយុដោយឱវាទនេះហើយ ទើបទ្រង់បាត់ព្រះអង្គពីទីចំពោះមុខនៃព្រះសោណៈដ៏មានអាយុ នៅក្នុងព្រៃសីត-វន ហើយទ្រង់ប្រាកដនៅលើភ្នំគិជ្ឈកូដវិញ ប្រៀបដូចជាបុរសដែលមានកំលាំងលាដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដៃដែលខ្លួនលាចេញ ។ លំដាប់នោះ លុះសម័យតមក ព្រះសោណៈដ៏មានអាយុក៏បានតាំងសេចក្ដីព្យាយាមស្មើ បានប្រើឥន្ទ្រិយទាំង ៥ ក៏ស្មើគ្នាផង បានកាន់យកនូវនិមិត្តក្នុងសមថៈនោះឯង ។ វេលានោះ ព្រះសោណៈដ៏មានអាយុបានចៀសចេញទៅតែម្នាក់ឯង ឥតមានសេចក្ដីប្រមាទឡើយ ព្យាយាមដុតបង់នូវកិលេស បញ្ជូនចិត្តឲ្យបែរទៅ (កាន់ព្រះនិព្វាន) ពួកកុលបុត្រដែលចេញចាកផ្ទះហើយ ចេញបួសគឺភាពជាបុគ្គលមិនមានប្រយោជន៍ដោយផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា (ព្រះសោណៈ) ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយ ដោយបញ្ញារបស់ខ្លួនដោយខ្លួនឯងក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅដោយកិរិយាបថទាំង ៤ មិនយូរប៉ុន្មាន ក៏បានដឹងច្បាស់ថា ជាតិកំណើតរបស់អាត្មាអញ អស់ហើយ ព្រហ្មចរិយធម៌អញក៏បាននៅចប់ហើយ កិច្ចដែលត្រូវធ្វើ អញក៏បានធ្វើហើយ និងមានកិច្ចដទៃអំពីកិច្ចនេះទៅទៀតគ្មានឡើយ ។ បណ្ដាព្រះអរហន្តទាំងឡាយ ព្រះសោណៈដ៏មានអាយុក៏ជាព្រះអរហន្តអង្គមួយដែរ ។

(៥១) អថខោ អាយស្មតោ សោណស្ស អរហត្តំ បត្តស្ស ឯតទហោសិ យន្នូនាហំ ភគវតោ សន្តិកេ អញ្ញំ ព្យាករេយ្យន្តិ ។ អថខោ អាយស្មា សោណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សោណោ ភគវន្តំ ឯតទវោច យោ សោ ភន្តេ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញាវិមុត្តោ សោ ឆដ្ឋានានិ អធិមុត្តោ ហោតិ នេក្ខម្មាធិមុត្តោ ហោតិ បវិវេកាធិមុត្តោ ហោតិ អព្យាបជ្ឈាធិមុត្តោ ហោតិ ឧបាទានក្ខយាធិមុត្តោ ហោតិ តណ្ហាក្ខយាធិមុត្តោ ហោតិ

១ អព្យាបជ្ជំ ឥតិ បោត្ថកេ ទិស្សតិ ។



X (៥១) លំដាប់នោះ កាលព្រះសោណៈដ៏មានអាយុបានសម្រេចព្រះអរហត្តហើយក៏មានសេចក្តីរំពឹងថា បើដូច្នោះមានតែអាត្មាអញនឹងសំដែងនូវគុណនៃអរហត្តផល ក្នុងសំណាក់ព្រះមានព្រះភាគ ។ វេលានោះ ព្រះសោណៈដ៏មានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគរួចអង្គុយទៅក្នុងទីដ៏សមគួរ ។ ព្រះសោណៈដ៏មានអាយុអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលភាសិតនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណាជាព្រះអរហន្តខីណាស្រព បានសម្រេចព្រហ្មចរិយធម៌ហើយ មានកិច្ចសម្រេចហើយ មានភារៈដាក់ចុះហើយ(១) បានសម្រេចប្រយោជន៍របស់ខ្លួនហើយ មានកិលេសជាគ្រឿងប្រកបសត្វក្នុងភពអស់ហើយ មានចិត្តផុតស្រឡះហើយ (ចាកកិលេស) ព្រោះដឹងដោយប្រពៃ ភិក្ខុនោះមានអធ្យាស្រ័យបង្អោនទៅកាន់ហេតុទាំង ៦ យ៉ាង គឺ មានអធ្យាស្រ័យបង្អោនទៅកាន់នេក្ខម្ម(២) (គឺអរហត្ត) ១ មានអធ្យាស្រ័យបង្អោនទៅក្នុងទីស្ងាត់ ១ មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនព្យាបាទ ១ មានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ជាគ្រឿងអស់ទៅនៃឧបាទាន ១ មានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ជាគ្រឿងអស់ទៅនៃតណ្ហា ១ មានអធ្យាស្រ័យបង្អោន

១ កិលេស ១០ ឈ្មោះថាខន្ធ ៥ ជាដើមឈ្មោះថាភារៈគឺគ្រឿងធ្ងន់ ដែលលោកជាអ្នកមានភារៈដាក់ចុះហើយ គឺលះអស់ដោយកិលេសនិងខន្ធជាដើមនោះពុំកើតទៀត ។ ២ នេក្ខម្មជាបាលី បាន ជាប់នេះព្រោះចេញចាកកាមគុណនៃគេហ ។

អសម្មោហាធិមុត្តោ ហោតិ សិយា ខោ បន ភន្តេ ឥធេកច្ចស្ស អាយស្មតោ ឯវមស្ស កេវលំ សទ្ធាមត្តកំ នូន អយមាយស្មា និស្សាយ នេក្ខម្មាធិមុត្តោតិ ន ខោ បនេតំ ភន្តេ ឯវំ ទដ្ឋព្វំ ខីណាសវោ ភន្តេ ភិក្ខុ វុសិតវា កតករណីយោ ករណីយមត្តនោ អសមនុបស្សន្តោ កតស្ស វា បដិចយំ ខយា រាគស្ស វីតរាគត្តា នេក្ខម្មាធិមុត្តោ ហោតិ ខយា ទោសស្ស វីតទោសត្តា នេក្ខម្មាធិមុត្តោ ហោតិ ខយា មោហស្ស វីតមោហត្តា នេក្ខម្មាធិមុត្តោ ហោតិ សិយា ខោ បន ភន្តេ ឥធេកច្ចស្ស អាយស្មតោ ឯវមស្ស លាភសក្ការសិលោកំ នូន អយមាយស្មា និកាមយមានោ បវិវេកាធិមុត្តោតិ ន ខោ បនេតំ ភន្តេ ឯវំ ទដ្ឋព្វំ ខីណាសវោ ភន្តេ ភិក្ខុ វុសិតវា កតករណីយោ



ទៅកាន់សេចក្តីមិនវង្វេង ១ បពិត្រព្រះអង្គដ៏ចំរើន មានហេតុថា ក្នុងលោកនេះ មានលោកដ៏មានអាយុពួកខ្លះ មានសេចក្តីត្រិះរិះដូច្នេះថា លោកដ៏មានអាយុនេះ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់នេក្ខម្មៈ ព្រោះអាស្រ័យនូវគុណ ត្រឹមតែសេចក្តីជឿប៉ុណ្ណោះឯង បពិត្រព្រះអង្គដ៏ចំរើន បុគ្គលកុំគប្បីយល់ហេតុនេះ ដូច្នេះឡើយ បពិត្រព្រះអង្គដ៏ចំរើន ឯភិក្ខុដែលជាព្រះខីណាស្រព បានសិក្សាព្រហ្មចារ្យចប់ហើយ មានកិច្ចសម្រេចហើយ កាលមិនបានពិចារណាខ្លួន ដែលមានកិច្ចត្រូវធ្វើ មិនបានពិចារណាឃើញសេចក្តីចំរើននៃកិច្ច ដែលខ្លួនបានធ្វើហើយ បានឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់នេក្ខម្មៈ ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់នេក្ខម្មៈ ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់នេក្ខម្មៈ ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈហើយ បពិត្រព្រះអង្គដ៏ចំរើន មានហេតុថា ក្នុងលោកនេះ មានលោកដ៏មានអាយុពួកខ្លះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកដ៏មានអាយុនេះ ជាអ្នកប្រាថ្នាលាភសក្ការៈ និងសេចក្តីសរសើរហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅក្នុងទីស្ងាត់ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលកុំគប្បីយល់ហេតុនេះ ដូច្នេះឡើយ បពិត្រព្រះអង្គដ៏ចំរើន ឯភិក្ខុជាព្រះខីណាស្រព បានសិក្សាព្រហ្មចារ្យចប់ហើយ មាន

ករណីយមត្តនោ អសមនុបស្សន្តោ កតស្ស វា បដិចយំ ខយា រាគស្ស វីតរាគត្តា បវិវេកាធិមុត្តោ ហោតិ ខយា ទោសស្ស វីតទោសត្តា បវិវេកាធិមុត្តោ ហោតិ ខយា មោហស្ស វីតមោហត្តា បវិវេកាធិមុត្តោ ហោតិ សិយា ខោ បន ភន្តេ ឥធេកច្ចស្ស អាយស្មតោ ឯវមស្ស សីល-ព្វតបរាមាសំ នូន អយមាយស្មា សារតោ បច្ចាគច្ឆន្តោ អព្យាបជ្ជាធិមុត្តោតិ ។ ន ខោ បនេតំ ភន្តេ ឯវំ ទដ្ឋព្វំ ខីណាសវោ ភន្តេ ភិក្ខុ វុសិតវា កតករណីយោ ករណីយមត្តនោ អសមនុបស្សន្តោ កតស្ស វា បដិចយំ ខយា រាគស្ស វីតរាគត្តា អព្យាបជ្ជាធិមុត្តោ ហោតិ ខយា ទោសស្ស វីតទោសត្តា អព្យាបជ្ជាធិមុត្តោ ហោតិ



កិច្ចសម្រេចហើយ មិនបានពិចារណាឃើញនូវខ្លួនដែលមានកិច្ចត្រូវធ្វើ ឬមិនបានពិចារណាឃើញសេចក្តីចំរើននៃកិច្ចដែលខ្លួនបានធ្វើហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅក្នុងទីដ៏ស្ងាត់ ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅក្នុងទីដ៏ស្ងាត់ ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅក្នុងទីដ៏ស្ងាត់ ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈហើយ បពិត្រព្រះអង្គដ៏ចំរើន មានហេតុថា ក្នុងលោកនេះ មានលោកដ៏មានអាយុក្នុងទីនេះ មានសេចក្តីនឹកយ៉ាងនេះថា លោកដ៏មានអាយុនេះកាលត្រឡប់មកកាន់សេចក្តីប្រកាន់សីលប្រកាន់វត្តដោយសារៈថាពិត ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនព្យាបាទ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលកុំគប្បីយល់ហេតុនេះដូច្នេះឡើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុជាព្រះខីណាស្រពបានសិក្សាព្រហ្មចរិយចប់ហើយ មានកិច្ចសម្រេចហើយ មិនបានពិចារណាឃើញនូវខ្លួនដែលមានកិច្ចត្រូវធ្វើឬមិនបានពិចារណាឃើញនូវសេចក្តីចំរើននៃកិច្ចដែលខ្លួនធ្វើហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនព្យាបាទ ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនព្យាបាទ ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅ

ខយា មោហស្ស វីតមោហត្តា អព្យាបជ្ជាធិមុត្តោ ហោតិ ខយា រាគស្ស វីតរាគត្តា ឧបាទានក្ខយាធិមុត្តោ ហោតិ ខយា ទោសស្ស វីតទោសត្តា ឧបាទានក្ខយាធិមុត្តោ ហោតិ ខយា មោហស្ស វីតមោហត្តា ឧបាទានក្ខយាធិមុត្តោ ហោតិ ខយា រាគស្ស វីតរាគត្តា តណ្ហាក្ខយាធិមុត្តោ ហោតិ ខយា ទោសស្ស វីតទោសត្តា តណ្ហាក្ខយាធិមុត្តោ ហោតិ ខយា មោហស្ស វីតមោហត្តា តណ្ហាក្ខយាធិមុត្តោ ហោតិ ខយា រាគស្ស វីតរាគត្តា អសម្មោហាធិមុត្តោ ហោតិ ខយា ទោសស្ស វីតទោសត្តា អសម្មោហាធិមុត្តោ ហោតិ ខយា មោហស្ស វីតមោហត្តា អសម្មោហាធិមុត្តោ ហោតិ ឯវំ សម្មាវិមុត្តចិត្តស្ស ភន្តេ ភិក្ខុនោ ភុសា ចេបិ ចក្ខុវិញ្ញេយ្យា



កាន់សេចក្តីមិនព្យាបាទ ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ជាគ្រឿងអស់ទៅនៃឧបាទាន ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ជាគ្រឿងអស់ទៅនៃឧបាទាន ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ជាគ្រឿងអស់ទៅនៃឧបាទាន ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ជាគ្រឿងអស់ទៅនៃតណ្ហា ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ជាគ្រឿងអស់ទៅនៃតណ្ហា ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ជាគ្រឿងអស់ទៅនៃតណ្ហា ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនវង្វេង ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនវង្វេង ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនវង្វេង ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈហើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណា បើមានចិត្តផុតស្រឡះប្រពៃយ៉ាងនេះហើយ [illegible]

រូបា ចក្ខុស្ស អាបាថំ អាគច្ឆន្តិ នេវស្ស ចិត្តំ បរិយាទិយន្តិ អមិស្សីកតមេវស្ស ចិត្តំ ហោតិ ឋិតំ អានេញ្ជប្បត្តំ[១] វយញ្ចស្សានុបស្សតិ ភុសា ចេបិ សោតវិញ្ញេយ្យា សទ្ទា... ឃានវិញ្ញេយ្យា គន្ធា... ជិវ្ហាវិញ្ញេយ្យា រសា... កាយវិញ្ញេយ្យា ផោដ្ឋព្វា ។ មនោវិញ្ញេយ្យា ធម្មា មនស្ស អាបាថំ អាគច្ឆន្តិ នេវស្ស ចិត្តំ បរិយាទិយន្តិ អមិស្សីកតមេវស្ស ចិត្តំ ហោតិ ឋិតំ អានេញ្ជប្បត្តំ វយញ្ចស្សានុបស្សតិ សេយ្យថាបិ ភន្តេ សេលោ បព្វតោ អច្ឆិទ្ទោ អសុសិរោ ឯកគ្ឃនោ បុរត្ថិមាយ ចេបិ ទិសាយ អាគច្ឆេយ្យ ភុសា វាតវុដ្ឋិ នេវ នំ សង្កម្បេយ្យ

១ ម. អានេញ្ជប្បត្តំ ។



មានកំឡាំងខ្លាំងគប្បីដឹងច្បាស់ដោយភ្នែក មកកាន់ត្រង់នៃភ្នែក ក៏មិនបានគ្របសង្កត់ចិត្តរបស់ភិក្ខុនោះបានឡើយ ចិត្តរបស់ភិក្ខុនោះដែលអារម្មណ៍មិនបានធ្វើឲ្យច្រឡំដោយកិលេស ជាចិត្តឋិតនៅខ្ជាប់ខ្ជួន ឥតមានកម្រើកដោយតណ្ហាហើយ ពិចារណាឃើញនូវសេចក្តីកើតឡើងនិងសេចក្តីរលត់ទៅនៃចិត្តនោះ បើសំឡេងទាំងឡាយដែលមានកំឡាំងខ្លាំងគប្បីដឹងច្បាស់ដោយត្រចៀកបាន... ក្លិនទាំងឡាយដែលមានកំឡាំងខ្លាំងគប្បីដឹងច្បាស់ដោយច្រមុះបាន... រសទាំងឡាយដែលមានកំឡាំងខ្លាំងគប្បីដឹងច្បាស់ដោយអណ្តាតបាន... ផោដ្ឋព្វៈ (គឺអារម្មណ៍ដែលមកប៉ះត្រូវកាយ) ទាំងឡាយដែលមានកំឡាំងខ្លាំងគប្បីដឹងច្បាស់ដោយកាយបាន... ធម្មារម្មណ៍ (គឺអារម្មណ៍ដែលកើតនឹងចិត្ត) ទាំងឡាយដែលមានកំឡាំងខ្លាំងគប្បីដឹងច្បាស់ដោយចិត្តបាន មកកាន់ផ្លូវនៃចិត្ត ក៏គ្របសង្កត់ចិត្តរបស់លោកនោះមិនបានឡើយ ចិត្តរបស់លោកនោះដែលអារម្មណ៍មិនបានធ្វើឲ្យច្រឡំដោយកិលេស ជាចិត្តឋិតនៅខ្ជាប់ខ្ជួន ឥតមានកម្រើកដោយតណ្ហាហើយ លោកបានពិចារណាឃើញនូវសេចក្តីកើតឡើងនិងសេចក្តីរលត់ទៅនៃចិត្តនោះ បពិត្រព្រះអង្គដ៏ចំរើន ឧបមាដូចជាភ្នំថ្ម - ឥតធ្លុះឥតប្រហោង ជាភ្នំតាន់ស្អិត បើមានសំណុំខ្យល់ដែលមានកំឡាំងខ្លាំងបក់មកអំពីទិសខាងកើតក្តី ក៏ញាំងភ្នំនោះ ឲ្យកម្រើកមិនបាន

ឆ សម្បការេយ្យ ឆ សម្បវេធេយ្យ បច្ចិនាយ ទេមិ

និសាយ អាគច្ឆេយ្យ ពុសា ភក្ខុន្ធិ ។បេ។ ទក្ខកាយ ទេមិ

និសាយ អាគច្ឆេយ្យ ពុសា ភក្ខុន្ធិ ។បេ។ ឧត្តិណាយ

ទេមិ និសាយ អាគច្ឆេយ្យ ពុសា ភក្ខុន្ធិ នេវ ឆ

សន្តិមេយ្យ ន សម្បការេយ្យ ន សម្បវេធេយ្យ បរិមេវ

ទោ កន្តិ បរិ សម្មាវិមុត្តចិត្តស្ស ភិក្ខុនោ ពុសា ទេមិ

ចក្ខុវិញ្ញេយ្យា រូបា ចក្ខុស្ស អាបាថំ អាគច្ឆន្តិ នេវស្ស

ចិត្តំ បរិយាទិយន្តិ អមិស្សីកតមេវស្ស ចិត្តំ ហោតិ ឋិតំ

អានេញ្ជប្បត្តំ វយញ្ចស្សានុបស្សតិ ពុសា ទេមិ សោត-

វិញ្ញេយ្យា សទ្ទា… ឃានវិញ្ញេយ្យា គន្ធា… ជិវ្ហាវិញ្ញេយ្យា



ឲ្យរំជួយមិនបាន ឲ្យញាប់ញ័រមិនបានឡើយ បើមានសំណុំរូបដែល

មានកំឡាំងខ្លាំងចំបក់បោកមកក្នុងវិស័យនៃចក្ខុក្តី ។បេ។ បើមាន

សំណុំរូបដែលមានកំឡាំងខ្លាំងចំបក់បោកមកក្នុងវិស័យនៃកាយក្តី ។បេ។

បើមានសំណុំរូបដែលមានកំឡាំងខ្លាំងចំបក់បោកមកក្នុងវិស័យនៃចិត្តក្តី

ក៏ញ៉ាំងចិត្តនោះឲ្យកម្រើកមិនបាន ឲ្យរំជួយមិនបាន ឲ្យញាប់ញ័រមិន

បានឡើយ មកពីព្រោះអត្តចិត្តចំរើន ក្នុងកាលមានចិត្តផុតស្រឡះដោយ

ប្រពៃយ៉ាងនេះហើយ បើប្រៀបដូចជាសសរដែលមានកំឡាំងខ្លាំងខំនឹងដីច្បាស់

ដោយដែក មកកាន់គន្ធនីក្នុងក្តី ក៏ស្រែបស្អិតចិត្តរបស់លោកនោះ

មិនបានឡើយ ចិត្តរបស់លោកនោះដែលអារម្មណ៍មិនបានធ្វើឲ្យប្រែប្រួល

ដោយកិលេស ជាចិត្តឋិតនៅខ្ជាប់ខ្ជួន ឥតមានកម្រើកដោយតណ្ហា

លោកពិចារណាឃើញសេចក្តីកើតឡើងនិងសេចក្តីវិនាសទៅនៃចិត្តនោះ

បើសំឡេងទាំងឡាយ ដែលមានកំឡាំងខ្លាំងដែលគប្បីដឹងច្បាស់ដោយត្រចៀក

ក្តី… ក្លិនទាំងឡាយ ដែលមានកំឡាំងខ្លាំងដែលគប្បីដឹងច្បាស់ដោយច្រមុះក្តី…

រសទាំងឡាយ ដែលមានកំឡាំងខ្លាំងដែលគប្បីដឹងច្បាស់ដោយអណ្តាតក្តី…

វេសា... កាយវិញ្ញេយ្យា ផោដ្ឋព្វា... មនោវិញ្ញេយ្យា ធម្មា មនស្ស អាបាថំ អាគច្ឆន្តិ នេវស្ស ចិត្តំ បរិយាទិយន្តិ អមិស្សីកតមេវស្ស ចិត្តំ ហោតិ ឋិតំ អានេញ្ជប្បត្តំ វយញ្ចស្សានុបស្សតីតិ ។

(៩២) នេក្ខម្មំ អធិមុត្តស្ស
បវិវេកញ្ច ចេតសោ
អព្យាបជ្ឈាធិមុត្តស្ស
ឧបាទានក្ខយស្ស ច
តណ្ហក្ខយាធិមុត្តស្ស
អសម្មោហញ្ច ចេតសោ
ទិស្វា អាយតនុប្បាទំ
សម្មា ចិត្តំ វិមុច្ចតិ
តស្ស សម្មាវិមុត្តស្ស
សន្តចិត្តស្ស ភិក្ខុនោ
កតស្ស បដិចយោ នត្ថិ





ផោដ្ឋព្វៈទាំងឡាយដែលគប្បីដឹងច្បាស់ដោយកាយក្តី .... ធម្មារម្មណ៍ទាំងឡាយដែលគប្បីដឹងច្បាស់ដោយចិត្តមកកាន់ផ្លូវចិត្តក្តី ក៏ប្រែបរួលចិត្តរបស់លោកនោះមិនបានឡើយ ចិត្តរបស់លោកនោះដែលអារម្មណ៍មិនបានធ្វើឲ្យប្រែប្រួលដោយកិលេស ជាចិត្តឋិតនៅស្ងប់ខ្ជួនដល់ការមិនកម្រើកដោយតណ្ហា លោករមែងពិចារណានូវសេចក្តីកើតឡើងនិងវិនាសនៃចិត្តនោះ ក៏មានឧបមេយ្យដូច្នោះឯង ។

(៩២) ភិក្ខុកាលបើមានអធ្យាស្រ័យបង្អោនទៅកាន់នេក្ខម្មៈ (គឺសាសនា)ផង មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីស្ងប់ស្ងាត់នៃចិត្តផង មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនព្យាបាទផង មានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ជាគ្រឿងអស់ទៅនៃឧបាទានផង មានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ជាគ្រឿងអស់ទៅនៃតណ្ហាផង មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនវង្វេងនៃចិត្តផង ចិត្តក៏ផុតស្រឡះដោយប្រពៃព្រោះបានឃើញនូវសេចក្តីកើតនិងសេចក្តីវិនាសនៃអាយតនៈ កាលភិក្ខុនោះមានចិត្តផុតស្រឡះហើយដោយប្រពៃ មានចិត្តស្ងប់ហើយ សេចក្តីចំរើននៃកុសលដែលភិក្ខុនោះបានធ្វើហើយក៏គ្មាន

ករណីយំ(១) ន វិជ្ជតិ ។
សេលោ យថា ឯកឃនោ
វាតេន ន សមីរតិ
ឯវំ រូបា រសា សទ្ទា
គន្ធា ផស្សា ច កេវលា
ឥដ្ឋា ធម្មា អនិដ្ឋា ច
នប្បវេធេន្តិ តាទិនោ
ឋិតំ ចិត្តំ វិប្បមុត្តំ
វយញ្ចស្សានុបស្សតីតិ ។

[៨៣] អថ ខោ ភគវា ភិក្ខូ អាមន្តេសិ ឯវំ ខោ ភិក្ខវេ កុលបុត្តា អញ្ញំ ព្យាករោន្តិ អត្ថោ ច វុត្តោ អត្តា ច អនុបនីតោ អថ ច បនិធេកច្ចេ មោឃបុរិសា ហសមានកា(២) មញ្ញេ អញ្ញំ ព្យាករោន្តិ តេ បច្ឆា វិឃាតំ អាបជ្ជន្តីតិ ។ អថខោ ភគវា អាយស្មន្តំ សោណំ អាមន្តេសិ ត្វំ ខោសិ សោណ សុខុមាលោ

១ ឱ. ករណីយញ្ច ។ ២ ហសមានកាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។





កិច្ចដែលគួរធ្វើទៀតមិនមាន ។ ថ្មដែលតាន់ស្កួតមិនញាប់ញ័រដោយខ្យល់ យ៉ាងណាមិញ រូប សំឡេង ក្លិន រស ផស្សៈ និងធម្មារម្មណ៍ទាំងអស់ ដែលជាទីគាប់ចិត្តក្តី មិនជាទីគាប់ចិត្តក្តី គឺញុំាងចិត្តរបស់ភិក្ខុជាតាទិបុគ្គល(១)ឲ្យញាប់ញ័រមិនបាន យ៉ាងនោះដែរ ចិត្តរបស់ភិក្ខុនោះ ជាចិត្តឋិតនៅខ្ជាប់ខ្ជួន ជាចិត្តផុតស្រឡះចាកកិលេសហើយ ភិក្ខុនោះក៏ពិចារណាឃើញសេចក្តីកើតឡើងនិងសេចក្តីរលត់នៃចិត្តនោះ ។

[៨៣] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ពួកកុលបុត្ត តែងប្រកាសគុណគឺអរហត្តផលយ៉ាងនេះឯង ពួកកុលបុត្តទាំងនោះ បានប្រកាសសេចក្តីនៃបុគ្គលជាអរហត្តផល មិនបាននាំបង្អួតខ្លួនទៅដោយអំនួតថា ខ្លួនជាព្រះអរហន្តផង ម្យ៉ាងទៀត ក្នុងលោកនេះ មានពួកមោឃបុរសខ្លះ ប្រកាសព្រះអរហត្តផល ចំនួនដូចជាសើចលេង មោឃបុរសទាំងនោះតែងដល់នូវសេចក្តីចង្អៀតចង្អល់ ក្នុងកាលជាខាងក្រោយ (មិនខានឡើយ) ។ វេលានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះសោណៈដ៏មានអាយុថា ម្នាលសោណៈ អ្នកឯងជាបុគ្គលកើតដោយ

១ (អដ្ឋកថា) បុគ្គលដែលមិនញាប់ញ័រដោយសេចក្តីត្រេកអរនិងសេចក្តីអន់ចិត្ត ក្នុងអារម្មណ៍ជាទីគាប់ចិត្ត និងអារម្មណ៍មិនជាទីគាប់ចិត្ត ។

អនុជានាមិ តេ សោណ ឯកបលាសិកំ ឧបាហនំ ។ អហំ ខោ ភន្តេ អសីតិសកដវាហេ ហិរញ្ញំ ឱហាយ អនគារិយំ បព្វជិតោ សត្តហត្ថិកញ្ច អនីកំ តស្ស មេ ភវិស្សន្តិ វត្តារោ សោណោ កោឡិវិសោ អសីតិសកដវាហេ ហិរញ្ញំ ឱហាយ អនគារិយំ បព្វជិតោ សត្តហត្ថិកញ្ច អនីកំ សោ ទានាយំ ឯកបលាសិកាសុ ឧបាហនាសុ សត្តោតិ[១] សចេ ភគវា ភិក្ខុសង្ឃស្ស អនុជានិស្សតិ អហម្បិ បរិភុញ្ជិស្សាមិ នោ ចេ ភគវា ភិក្ខុសង្ឃស្ស អនុជានិស្សតិ អហម្បិ ន បរិភុញ្ជិស្សាមីតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ឯកបលាសិកំ ឧបាហនំ ន ភិក្ខវេ ទិគុណា ឧបាហនា ធារេតព្វា ន តិគុណា ឧបាហនា ធារេតព្វា ន គណង្គណូបាហនា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

១ សត្តាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។



សេចក្តីសុខ នៃសោណៈ ដូច្នេះ តថាគតអនុញ្ញាតស្បែកជើងមួយជាន់ដល់អ្នក ។ ព្រះសោណៈនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានលះបង់ប្រាក់ចំនួន ៨០ រទេះធំ (គឺ ១ រទេះដាក់កណ្តាលរទេះតូច) ផង បានលះបង់នូវពួកសេនាប្រកបដោយដំរី ៧ ផង ហើយបានចេញពីផ្ទះមកបួសក្នុងផ្នួសនៃបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ ជនទាំងឡាយមុខជានឹងពោល (តិះដៀល) ដល់ខ្ញុំព្រះអង្គថា សោណកោឡិវិសបានលះបង់ប្រាក់ចំនួន ៨០ រទេះយ៉ាងធំផង បានលះបង់នូវពួកសេនាប្រកបដោយដំរី ៧ ផង ហើយបានចេញចាកផ្ទះមកបួសក្នុងផ្នួសនៃបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ ឥឡូវនេះ សោណកោឡិវិសនេះនៅជាប់ចំពាក់នឹងស្បែកជើងមួយជាន់ បើព្រះដ៏មានព្រះភាគនឹងទ្រង់អនុញ្ញាតដល់ភិក្ខុសង្ឃ ទើបខ្ញុំព្រះអង្គបានប្រើប្រាស់ បើព្រះដ៏មានព្រះភាគមិនទ្រង់អនុញ្ញាតដល់ភិក្ខុសង្ឃ ខ្ញុំព្រះអង្គមិនបានប្រើប្រាស់ទេ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើនូវធម្មីកថាក្នុងហេតុនោះហើយ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវស្បែកជើងមួយជាន់ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើង ២ ជាន់ មិនត្រូវពាក់ស្បែកជើង ៣ ជាន់ មិនត្រូវពាក់ស្បែកជើង ៤ ជាន់ឡើងទៅទេ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ ។

[៨៤] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សព្វនីលិកា ឧបាហនាយោ ធារេន្តិ ។បេ។ សព្វបីតិកា ឧបាហនាយោ ធារេន្តិ ។ សព្វលោហិតិកា ឧបាហនាយោ ធារេន្តិ ។ សព្វមញ្ជេដ្ឋិកា ឧបាហនាយោ ធារេន្តិ ។ សព្វកណ្ហា ឧបាហនាយោ ធារេន្តិ ។ សព្វមហារង្គរត្តា ឧបាហនាយោ ធារេន្តិ ។ សព្វមហានាមរត្តា ឧបាហនាយោ ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ សព្វនីលិកា ឧបាហនា ធារេតព្វា ន សព្វបីតិកា ឧបាហនា ធារេតព្វា ន សព្វលោហិតិកា ឧបាហនា ធារេតព្វា ន សព្វមញ្ជេដ្ឋិកា ឧបាហនា ធារេតព្វា ន សព្វកណ្ហា ឧបាហនា ធារេតព្វា ន សព្វមហារង្គរត្តា ឧបាហនា ធារេតព្វា ន សព្វមហានាមរត្តា ឧបាហនា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ នីល-



[៨៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុពាក់ស្បែកជើងពណ៌ខៀវសុទ្ធ (ដូចពណ៌ផ្កាត្រកៀត) ។បេ។ ពាក់ស្បែកជើងពណ៌លឿងសុទ្ធ (ដូចពណ៌ផ្កាកណ្ណិការ) ។ ពាក់ស្បែកជើងពណ៌ក្រហមសុទ្ធ (ដូចពណ៌ផ្កាច្បារ) ។ ពាក់ស្បែកជើងពណ៌ហង្សបាទសុទ្ធ (ដូចពណ៌ស្បែង) ។ ពាក់ស្បែកជើងពណ៌ខ្មៅសុទ្ធ (ដូចពណ៌ថ្នាំ) ។ ពាក់ស្បែកជើងពណ៌ក្រហមក្រមៅសុទ្ធ (ដូចពណ៌ខ្នងក្អែប) ។ ពាក់ស្បែកជើងពណ៌លឿងទុំសុទ្ធ (ដូចពណ៌ស្លឹកឈើទុំ ឬដូចផ្កាឈូក) ។ មនុស្សទាំងឡាយតិះពោលទោសតិះដៀលបន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថដែលបរិភោគនូវកាមគុណ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើងពណ៌ខៀវសុទ្ធ មិនត្រូវពាក់ស្បែកជើងពណ៌លឿងសុទ្ធ មិនត្រូវពាក់ស្បែកជើងពណ៌ក្រហមសុទ្ធ មិនត្រូវពាក់ស្បែកជើងពណ៌ហង្សបាទសុទ្ធ មិនត្រូវពាក់ស្បែកជើងពណ៌ខ្មៅសុទ្ធ មិនត្រូវពាក់ស្បែកជើងពណ៌ក្រហមក្រមៅសុទ្ធ មិនត្រូវពាក់ស្បែកជើងពណ៌លឿងទុំសុទ្ធឡើយ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុពាក់

កវទ្ធិកា ឧបាហនាយោ ធារេន្តិ ។ បីតកវទ្ធិកា ឧបាហនាយោ ធារេន្តិ ។ លោហិតកវទ្ធិកា ឧបាហនាយោ ធារេន្តិ ។ មញ្ជេដ្ឋកវទ្ធិកា ឧបាហនាយោ ធារេន្តិ ។ កណ្ហវទ្ធិកា ឧបាហនាយោ ធារេន្តិ ។ មហារង្គរត្តវទ្ធិកា ឧបាហនាយោ ធារេន្តិ ។ មហានាមរត្តវទ្ធិកា ឧបាហនាយោ ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ នីលកវទ្ធិកា ឧបាហនា ធារេតព្វា ។ ន បីតកវទ្ធិកា ឧបាហនា ធារេតព្វា ។ ន លោហិតកវទ្ធិកា ឧបាហនា ធារេតព្វា ។ ន មញ្ជេដ្ឋកវទ្ធិកា ឧបាហនា ធារេតព្វា ។ ន កណ្ហវទ្ធិកា ឧបាហនា ធារេតព្វា ។ ន មហារង្គរត្តវទ្ធិកា ឧបាហនា ធារេតព្វា ។ ន មហានាមរត្តវទ្ធិកា ឧបាហនា ធារេតព្វា ។ យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ខល្លកពទ្ធា ឧបាហនាយោ ធារេន្តិ ។ បុដពទ្ធា ឧបាហនាយោ ធារេន្តិ ។ បាលិគុណ្ឋិមា(១) ឧបាហនាយោ

---

១ បាលិគុណ្ឋិកាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។



ស្បែកជើងមានខ្សែខៀវ ។ ពាក់ស្បែកជើងមានខ្សែលឿង ។ ពាក់ស្បែកជើងមានខ្សែក្រហម ។ ពាក់ស្បែកជើងមានខ្សែហង្សបាទ ។ ពាក់ស្បែកជើងមានខ្សែខ្មៅ ។ ពាក់ស្បែកជើងមានខ្សែក្រហមក្រមៅ ។ ពាក់ស្បែកជើងមានខ្សែលឿងទុំ ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថដែលបរិភោគនូវកាមគុណ ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើងមានខ្សែខៀវទេ មិនត្រូវពាក់ស្បែកជើងមានខ្សែលឿង មិនត្រូវពាក់ស្បែកជើងមានខ្សែក្រហម មិនត្រូវពាក់ស្បែកជើងមានខ្សែហង្សបាទ មិនត្រូវពាក់ស្បែកជើងមានខ្សែខ្មៅ មិនត្រូវពាក់ស្បែកជើងមានខ្សែក្រហមក្រមៅ មិនត្រូវពាក់ស្បែកជើងមានខ្សែលឿងទុំទេ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុពាក់ស្បែកជើងចងកែង ។ ពាក់ស្បែកជើងស្រោបជើងទាំងអស់ត្រួតស្មងជើង (ដូចជាស្បែកជើងអ្នកស្រុកយោនកៈ) ។ ពាក់ស្បែកជើងដែលគេក្រងជាបៀមចងខ្នងជើង ។

ធារេន្តិ ។ តូលបុណ្ណិកា ឧបាហនាយោ ធារេន្តិ ។ តិត្តិរ-
បត្តិកា ឧបាហនាយោ ធារេន្តិ ។ មេណ្ឌវិសាណវទ្ធិកា
ឧបាហនាយោ ធារេន្តិ ។ អជវិសាណវទ្ធិកា ឧបាហ-
នាយោ ធារេន្តិ ។ វិច្ឆិកាឡិកា ឧបាហនាយោ ធារេន្តិ ។
មោរបិញ្ឆបរិសិព្វិតា(១) ឧបាហនាយោ ធារេន្តិ ។ ចិត្រា
ឧបាហនាយោ ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ
វិបាចេន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ខល្លកពទ្ធា ឧបាហ-
នា ធារេតព្វា ន បុដពទ្ធា ឧបាហនា ធារេតព្វា ន បា-
លិគុណ្ឋិមា(២) ឧបាហនា ធារេតព្វា ន តូលបុណ្ណិកា
ឧបាហនា ធារេតព្វា ន តិត្តិរបត្តិកា ឧបាហនា ធារេ-
តព្វា ន មេណ្ឌវិសាណវទ្ធិកា ឧបាហនា ធារេតព្វា ន
អជវិសាណវទ្ធិកា ឧបាហនា ធារេតព្វា ន វិច្ឆិកាឡិកា
ឧបាហនា ធារេតព្វា ន មោរបិញ្ឆបរិសិព្វិតា ឧបាហនា
ធារេតព្វា ន ចិត្រា ឧបាហនា ធារេតព្វា យោ ធារេយ្យ
អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន
ឆព្វគ្គិយា ភិក្ខូ សីហចម្មបរិក្ខដា ឧបាហនាយោ





ពាក់ស្បែកជើងដែលញាត់ដោយគរ ១ ពាក់ស្បែកជើងមានខ្សែវិចិត្រដូច
ស្លាបទទា ១ ពាក់ស្បែកជើងមានខ្សែមានសណ្ឋានដូចស្នែងចៀម ១ ពាក់
ស្បែកជើងមានខ្សែមានសណ្ឋានដូចស្នែងពពែ ១ ពាក់ស្បែកជើងមាន
ខ្សែមានសណ្ឋានដូចកន្ទុយខ្ទួយ ១ ពាក់ស្បែកជើងដែលដាក់ស្រេះ
ដោយព្រុយកន្ទុយក្ងោក ១ ពាក់ស្បែកជើងដែលវិចិត្រ (ផ្សេងៗ) ១ ។
មនុស្សទាំងឡាយក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ដូចជាពួកគ្រហ-
ស្ថដែលបរិភោគនូវកាមគុណ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះ
ព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុ
មិនត្រូវពាក់ស្បែកជើងបិទកែង មិនត្រូវពាក់ស្បែកជើងដែលរុំស្រោមជើង
ទាំងអស់ហួសស្មងជើង មិនត្រូវពាក់ស្បែកជើងដែលគេក្រងជាបៀបចង
នូវជើង មិនត្រូវពាក់ស្បែកជើងដែលញាត់ដោយគរ មិនត្រូវពាក់ស្បែក
ជើងដែលមានខ្សែវិចិត្រដូចស្លាបទទា មិនត្រូវពាក់ស្បែកជើងមានខ្សែមាន
សណ្ឋានដូចស្នែងចៀម មិនត្រូវពាក់ស្បែកជើងមានខ្សែមានសណ្ឋានដូច
ស្នែងពពែ មិនត្រូវពាក់ស្បែកជើងមានខ្សែមានសណ្ឋានដូចកន្ទុយខ្ទួយ
មិនត្រូវពាក់ស្បែកជើងដែលគេស្រេះដោយព្រុយកន្ទុយក្ងោក មិនត្រូវពាក់
ស្បែកជើងដែលវិចិត្រ (ផ្សេងៗ) ឡើយ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ ។
សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុពាក់ស្បែកជើងដែលបំពាក់ដោយស្បែក

ធារេន្តិ ។ ព្យគ្ឃចម្មបរិក្ខដា ឧបាហនាយោ ធារេន្តិ ។ ទីបិចម្មបរិក្ខដា ឧបាហនាយោ ធារេន្តិ ។ អជិនចម្មបរិក្ខដា ឧបាហនាយោ ធារេន្តិ ។ ឧទ្ទចម្មបរិក្ខដា ឧបាហនាយោ ធារេន្តិ ។ មជ្ជារចម្មបរិក្ខដា ឧបាហនាយោ ធារេន្តិ ។ កាឡកចម្មបរិក្ខដា ឧបាហនាយោ ធារេន្តិ ។ ឧលូកចម្មបរិក្ខដា ឧបាហនាយោ ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ សីហចម្មបរិក្ខដា ឧបាហនា ធារេតព្វា ន ព្យគ្ឃចម្មបរិក្ខដា ឧបាហនា ធារេតព្វា ន ទីបិចម្មបរិក្ខដា ឧបាហនា ធារេតព្វា ន អជិនចម្មបរិក្ខដា ឧបាហនា ធារេតព្វា ន ឧទ្ទចម្មបរិក្ខដា ឧបាហនា ធារេតព្វា ន មជ្ជារចម្មបរិក្ខដា ឧបាហនា ធារេតព្វា ន កាឡកចម្មបរិក្ខដា ឧបាហនា ធារេតព្វា ន ឧលូកចម្មបរិក្ខដា ឧបាហនា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។



សត្វសីហៈ ។ ពាក់ស្បែកជើងដែលចំជាយដោយស្បែកខ្លាធំ ។ ពាក់ស្បែកជើងដែលចំជាយដោយស្បែកខ្លាដំបង ។ ពាក់ស្បែកជើងដែលចំជាយដោយស្បែកខ្លារខិន ។ ពាក់ស្បែកជើងដែលចំជាយដោយស្បែកភេ ។ ពាក់ស្បែកជើងដែលចំជាយដោយស្បែកឆ្មា ។ ពាក់ស្បែកជើងដែលចំជាយដោយស្បែកសត្វកន្ធែន ។ ពាក់ស្បែកជើងដែលចំជាយដោយស្បែកមៀម ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថដែលបរិភោគនូវកាមគុណ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកសត្វសីហៈ មិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកខ្លាធំ មិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកខ្លាដំបង មិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកខ្លារខិន មិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកភេ មិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកឆ្មា មិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកសត្វកន្ធែន មិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកមៀម ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ ។

ចម្មក្ខន្ធកំ អនុញ្ញា គុណង្គុណូបាហនា

(៨៩) អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសិ អញ្ញតរេន ភិក្ខុនា បច្ឆាសមណេន ។ អថខោ សោ ភិក្ខុ ខញ្ជមានោ ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ ។ អទ្ទសា ខោ អញ្ញតរោ ឧបាសកោ គុណង្គុណូបាហនំ[១] អារោហិត្វា ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន ឧបាហនា ឱរោហិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ អភិវាទេត្វា ឯតទវោច កិស្ស ភន្តេ អយ្យោ ខញ្ជតីតិ ។ បាទា មេ អាវុសោ ផលិតាតិ ។ ហន្ទ ភន្តេ ឧបាហនាយោតិ ។ អលំ អាវុសោ បដិក្ខិត្តា ភគវតា គុណង្គុណូបាហនាតិ ។ គណ្ហាហេតា ភិក្ខុ ឧបាហនាយោតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ

១ ម. គណង្គណូបាហនំ ។



ចម្មក្ខន្ធកៈ ស្បែកជើង ៤ ជាន់ឡើងទៅដែលគេពាក់ហើយដោះព្រលែង (ស្បែកជើងចាស់)

(៨៩) គ្រានោះឯង ព្រះមានព្រះភាគទ្រង់ស្បង់ក្នុងវេលាព្រឹកព្រលឹម ហើយប្រដាប់បាត្រនិងចីវរ យាងចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត មានភិក្ខុ ១ រូបជាបច្ឆាសមណៈ (អ្នកសមណៈតាមក្រោយ) ។ ភិក្ខុនោះខ្ចកជើងដើរតាមក្រោយ ៗ ព្រះដ៏មានព្រះភាគ ក្នុងវេលានោះ ។ មានឧបាសកម្នាក់ពាក់ស្បែកជើង ៤ ជាន់ឡើងទៅ បានឃើញព្រះដ៏មានព្រះភាគទ្រង់យាងមកពីចម្ងាយ លុះឃើញហើយក៏ដោះស្បែកជើងចេញ ហើយចូលសំដៅទៅព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំភិក្ខុនោះហើយ ក៏បាននិយាយពាក្យនេះថា បពិត្រលោកដ៏ចំរើន លោកម្ចាស់ហេតុអ្វីបានជាខ្ចក ។ ភិក្ខុនោះប្រាប់ថា នែអ្នកដ៏មានអាយុ បាតជើងរបស់អាត្មាបែក ។ ឧបាសកនោះនិយាយថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ទទួលយកស្បែកជើងចុះ ។ ភិក្ខុនោះតបថា នែអ្នកដ៏មានអាយុ ល្មមហើយកុំ ព្រោះស្បែកជើង ៤ ជាន់ឡើងទៅ ព្រះដ៏មានព្រះភាគបានទ្រង់ហាមឃាត់ស្រេចហើយ ។ ព្រះសាស្ដាទ្រង់បន្ទូលថា នែភិក្ខុ ចូរអ្នកទទួលយកស្បែកជើងនេះចុះ ។ ព្រោះនិទាននេះ បករណ៍នេះ ទើបព្រះដ៏មានព្រះភាគបានធ្វើធម្មីកថាក្នុងវេលានោះ រួច

អាមន្តេសិ អនុជានាមិ ភិក្ខវេ ឱមុក្កំ គុណង្គុណូបាហនំ ។ ន ភិក្ខវេ នវា គុណង្គុណូបាហនា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[៨៦] តេន ខោ បន សមយេន ភគវា អជ្ឈោកាសេ អនុបាហនោ ចង្កមតិ ។ សត្ថា អនុបាហនោ ចង្កមតីតិ ថេរា ភិក្ខូ អនុបាហនា ចង្កមន្តិ ។ ឆព្ពគ្គិយា ភិក្ខូ សត្ថរិ អនុបាហនេ ចង្កមមានេ ថេរេសុបិ ភិក្ខូសុ អនុបាហនេសុ ចង្កមមានេសុ សឧបាហនា ចង្កមន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ សត្ថរិ អនុបាហនេ ចង្កមមានេ ថេរេសុបិ ភិក្ខូសុ អនុបាហនេសុ ចង្កមមានេសុ សឧបាហនា ចង្កមិស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។



ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកអនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវស្បែកជើងជាន់ឡើងទៅ ដែលគេពាក់ហើយ ដោះមកប្រគេន (គឺជាស្បែកជើងចាស់) ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើងជាន់ឡើងទៅដែលជាស្បែកជើងថ្មីទេ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ ។

[៨៦] សម័យនោះឯង ព្រះដ៏មានព្រះភាគមិនបានទ្រង់ទ្រង់ព្រះបាទុកា (ហើយ) ទ្រង់ចង្រ្កមនៅក្នុងទីវាល ។ ឯពួកភិក្ខុចាស់ក៏មិនពាក់ស្បែកជើងដើរចង្រ្កម ដោយគិតឃើញថា ព្រះសាស្តាមិនទ្រង់ទ្រង់ព្រះបាទុកា ហើយទ្រង់ចង្រ្កម ។ កាលបើព្រះបរមសាស្តាមិនទ្រង់ទ្រង់ព្រះបាទុកា ហើយទ្រង់ចង្រ្កម ពួកភិក្ខុចាស់ក៏មិនពាក់ស្បែកជើងហើយចង្រ្កម (គឺដើរតាមម្នាក់) ឯពួកឆព្វគ្គិយភិក្ខុក៏ពាក់ស្បែកជើងហើយចង្រ្កម ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា កាលបើព្រះបរមសាស្តាមិនបានទ្រង់ទ្រង់ព្រះបាទុកា កំពុងចង្រ្កមក្តី ពួកភិក្ខុចាស់មិនបានពាក់ស្បែកជើងកំពុងចង្រ្កមក្តី ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងហ៊ានពាក់ស្បែកជើងដើរចង្រ្កមសោះ ។ វេលានោះឯង ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខូ សត្ថរិ អនុបាហនេ ចង្កមមានេ គរុសុបិ ភិក្ខូសុ អនុបាហនេសុ ចង្ក-មមានេសុ សឧបាហនា ចង្កមន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា សត្ថរិ អនុបាហនេ ចង្កមមានេ គរុ-សុបិ ភិក្ខូសុ អនុបាហនេសុ ចង្កមមានេសុ សឧ-បាហនា ចង្កមិស្សន្តិ ឥមេហិ នាម ភិក្ខវេ គិហីនោ[១] ឱទាតវសនា អភិជីវនិកស្ស សិប្បស្ស ការណា អាចរិយេសុ សគារវា សប្បតិស្សា សភាគវុត្តិកា វិហរិស្សន្តិ ឥធ ខោ តំ ភិក្ខវេ សោភេថ យំ តុម្ហេ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា អាចរិយេសុ អាចរិយមត្តេសុ ឧបជ្ឈាយេសុ ឧបជ្ឈាយមត្តេសុ អ-គារវា អប្បតិស្សា អសភាគវុត្តិកា វិហរេយ្យាថ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា

១ ម. គិហី ។ គិហីកាមភោគិនោ ពុទ្ធិ យោធ្លេ ចិស្សតិ ។



ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា កាលព្រះបរម-សាស្តាមិនបានទ្រង់ទូនព្រះបាទុកាកំពុងចង្ក្រមក្តី ពួកភិក្ខុចាស់មិនបានពាក់ស្បែកជើងកំពុងចង្ក្រមក្តី ពួកឆព្វគ្គិយភិក្ខុក៏ពាក់ស្បែកជើងហើយដើរចង្ក្រម ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំង-ឡាយ កាលព្រះសាស្តាមិនបានទ្រង់ទូនព្រះបាទុកាកំពុងចង្ក្រមក្តី ពួកភិក្ខុចាស់មិនបានពាក់ស្បែកជើងកំពុងចង្ក្រមក្តី មោឃបុរសទាំងនោះមិនសមបើនឹងហ៊ានពាក់ស្បែកជើងហើយដើរចង្ក្រមទេ ម្នាលភិក្ខុទាំងឡាយ ពួកគ្រហស្ថដែលស្លៀកស ពួកនេះមានសេចក្តីគោរពកោតក្រែងក្នុងអាចារ្យ មានការចិញ្ចឹមជីវិតស្មើគ្នា ព្រោះហេតុនៃសិល្បសាស្ត្រសម្រាប់ចិញ្ចឹមជីវិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ គួរតែប្រព្រឹត្តឲ្យល្អ ព្រោះថាអ្នកទាំងឡាយបានបួសមកក្នុងធម្មវិន័យដែលតថាគតបានសំដែងដោយល្អយ៉ាងនេះហើយ គួរតែគោរពកោតក្រែង មានសេចក្តីចិញ្ចឹមជីវិតស្មើគ្នា ក្នុងអាចារ្យក្តី ក្នុងភិក្ខុស្មើដោយអាចារ្យក្តី ក្នុងឧបជ្ឈាយ៍ក្តី ក្នុងភិក្ខុស្មើដោយឧបជ្ឈាយ៍ក្តី ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនបានធ្វើនាំពួកជនដែលមិនទាន់បានជ្រះថ្លា ឲ្យជ្រះថ្លាឡើងទេ ។ បេ ។ លុះទ្រង់បន្ទោសរួចទ្រង់

ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ អាចរិយេសុ អាចរិយមត្តេសុ ឧបជ្ឈាយេសុ ឧបជ្ឈាយមត្តេសុ អនុបាហនេសុ ចង្កមមានេសុ សឧបាហនេន ចង្កមិតព្វំ យោ ចង្កមេយ្យ អាបត្តិ ទុក្កដស្ស ។ ន[១] ភិក្ខវេ អជ្ឈារាមេ ឧបាហនា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៨៧) តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ បាទខីលាពាធោ ហោតិ ។ ភិក្ខូ តំ ភិក្ខុំ បរិគ្គហេត្វា ឧច្ចារំបិ បស្សាវំបិ និក្ខាមេន្តិ ។ អទ្ទសា ខោ ភគវា សេនាសនចារិកំ អាហិណ្ឌន្តោ តេ ភិក្ខូ តំ ភិក្ខុំ បរិគ្គហេត្វា ឧច្ចារំបិ បស្សាវំបិ និក្ខាមេន្តេ ទិស្វាន យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច កឹ ឥមស្ស ភិក្ខវេ ភិក្ខុនោ អាពាធោតិ ។ ឥមស្ស ភន្តេ អាយស្មតោ បាទខីលាពាធោ ឥមំ មយំ បរិគ្គហេត្វា ឧច្ចារំបិ បស្សាវំបិ និក្ខាមេមាតិ ។

១ [illegible]



ទើបទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ កាលបើអាចារ្យ (ក្តី) ភិក្ខុដែលស្មើដោយអាចារ្យ (ក្តី) ឧបជ្ឈាយ៍ (ក្តី) ភិក្ខុដែលស្មើដោយឧបជ្ឈាយ៍ (ក្តី) មិនបានពាក់ស្បែកជើងដើរចង្ក្រមទេ ភិក្ខុមិនត្រូវពាក់ស្បែកជើងហើយដើរចង្ក្រមទេ ភិក្ខុណាដើរចង្ក្រម ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើងក្នុងវត្តទេ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ ។

[៨៧] សម័យនោះឯង មានភិក្ខុ ១ រូប កើតរោគដំបៅលេចនៅបាតជើង ។ ភិក្ខុទាំងឡាយក៏បានគ្រាហ៍យកភិក្ខុនោះទៅឲ្យបន្ទោបង់ឧច្ចារៈផង បស្សាវៈផង ។ ព្រះមានព្រះភាគ ទ្រង់យាងទៅកាន់សេនាសនចារិក ក៏បានទតទៅឃើញភិក្ខុទាំងនោះកំពុងគ្រាហ៍យកភិក្ខុនោះទៅឲ្យបន្ទោបង់ឧច្ចារៈផង បស្សាវៈផង លុះឃើញហើយ ក៏ទ្រង់យាងចូលទៅរកភិក្ខុនោះ លុះយាងចូលទៅដល់ហើយ ទើបទ្រង់ត្រាស់បន្ទូលនឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះកើតរោគអ្វី ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន រីលោកដ៏មានអាយុនេះកើតរោគដំបៅលេចនៅបាតជើង ពួកខ្ញុំព្រះអង្គក៏គ្រាហ៍យកលោកដ៏មានអាយុនេះទៅឲ្យបន្ទោបង់ឧច្ចារៈផង បស្សាវៈផង ។

### បញ្ញត្តិ៖ បាទខីលាពាធិកភិក្ខុ

(៩៨) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ
បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជា-
នាមិ ភិក្ខវេ យស្ស បាទា វា ទុក្ខា បាទា វា ផាលិតា
បាទខីលាពាធោ វា ឧបាហនំ អារោហិតុំ ។ តេន ខោ
បន សមយេន ភិក្ខូ អធោតេហិ បាទេហិ មញ្ចម្បិ
បីឋម្បិ អភិរុហន្តិ ចីវរម្បិ សេនាសនម្បិ ទុស្សន្តិ ។
ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ
ឥទានិ មញ្ចំ វា បីឋំ វា អភិរុហិស្សាមីតិ ឧបាហនំ
អារោហិតុំ ។ តេន ខោ បន សមយេន ភិក្ខូ រត្តិយា
ឧបោសថគ្គម្បិ សន្និសជ្ជម្បិ គច្ឆន្តា អន្ធការេ ខាណុម្បិ
កណ្ដកម្បិ អក្កមន្តិ បាទា ទុក្ខា ហោន្តិ ។ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អជ្ឈារាមេ
ឧបាហនំ ធារេតុំ ឧក្កំ បទីបំ កត្ត-
រទណ្ឌន្តិ ។ តេន
ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ រត្តិយា បច្ចូសសម-
យំ បច្ចុដ្ឋាយ កដ្ឋបាទុកាយោ អភិរុហិត្វា អជ្ឈោ-



### បញ្ញត្តិៈ និទានភិក្ខុមានរោគដំបៅលេចទៅបាតជើង

(៩៨) ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ
ទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ មក
ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ (បើ) ភិក្ខុណា មានជើងឈឺក្តី
មានជើងបែកក្តី មានរោគដំបៅលេចទៅបាតជើងក្តី តថាគតអនុញ្ញាត
ឲ្យភិក្ខុនោះពាក់ស្បែកជើងបាន ។ សម័យនោះឯង ភិក្ខុទាំងឡាយមិន
បានលាងជើងហើយស្រាប់តែឡើងទៅកាន់គ្រែខ្លះ តាំងខ្លះ ធ្វើឲ្យប្រឡាក់
ចីវរនឹងសេនាសនៈ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះ
មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគត
អនុញ្ញាតឲ្យភិក្ខុពាក់ស្បែកជើងបាន ដោយគិតថាក្នុងវេលានេះ អាត្មា
អញនឹងឡើងគ្រែឬតាំង ។ សម័យនោះឯង ក្នុងវេលាយប់ មានពួក
ភិក្ខុដើរទៅកាន់រោងឧបោសថខ្លះ ទីប្រជុំអង្គុយខ្លះ ក៏ជាន់ទៅលើគល់
ឈើខ្លះ លើបន្លាខ្លះ ក្នុងទីងងឹត ជើងរបស់ភិក្ខុទាំងនោះក៏មានទុក្ខ-
វេទនា ។ ភិក្ខុទាំងឡាយក៏បានក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមាន
ព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគត
អនុញ្ញាតឲ្យភិក្ខុពាក់ស្បែកជើង កាន់គប់ភ្លើង ប្រទីប នឹងឈើច្រត់
ក្នុងទីអារាមបាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុក្រោកឡើងក្នុង
បច្ចូសសម័យនៃរាត្រី (ជិតភ្លឺ) ក៏ពាក់ទ្រនាប់ជើងឈើ ហើយចង្ក្រមក្នុង

ការេ ចង្កមន្តិ ឧច្ចាសទ្ទា មហាសទ្ទា ខដខដសទ្ទា អនេកវិហិតំ តិរច្ឆានកថំ កថេន្តា សេយ្យថីទំ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ យុទ្ធកថំ អន្នកថំ បានកថំ វត្ថកថំ សយនកថំ មាលាកថំ គន្ធកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ បុរិសកថំ សូរកថំ វិសិខាកថំ កុម្ភដ្ឋានកថំ បុព្វបេតកថំ នានត្តកថំ លោកក្ខាយិកំ សមុទ្ទក្ខាយិកំ ឥតិភវាភវកថំ ឥតិ វា កីដកេបិ អក្កមិត្វា មារេន្តិ ភិក្ខូបិ សមាធិម្ហា ចាវេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ



ពីរោល មានសំឡេងលើកហ៊ោ មានសំឡេងខ្លាំង មានសំឡេងចាក់ខ្ទះ ហើយនិយាយតិរច្ឆានកថាផ្សេងៗ គឺនិយាយពីស្តេច និយាយពីចោរ និយាយពីមហាមាត្យ និយាយពីសេនា និយាយពីភ័យ និយាយពីចម្បាំង និយាយពីគ្រឿងស៊ី និយាយពីគ្រឿងផឹក និយាយពីសំពត់ និយាយពីការដេក និយាយពីកម្រងផ្កា និយាយពីគ្រឿងក្រអូប និយាយពីញាតិ និយាយពីយាន និយាយពីស្រុក និយាយពីនិគម និយាយពីនគរ និយាយពីជនបទ និយាយពីស្រី និយាយពីប្រុស និយាយពីបុគ្គលដែលក្លៀវក្លា និយាយពីច្រកផ្លូវ និយាយពីកន្លែងកំពង់ទឹក (គឺកំពង់ទឹក) និយាយពីបុព្វប្រេត (គឺញាតិដែលស្លាប់ទៅហើយ) និយាយពីពាក្យឥតប្រយោជន៍មានប្រការផ្សេងៗ និយាយពីរឿងកុហកក្នុងលោក (មានរឿងក្អែកសកុកក្រហមជាដើម) និយាយពីរឿងផឹកសមុទ្រ និយាយពីសេចក្តីចំរើន និងសេចក្តីសាបសូន្យ ហើយជាន់លើសត្វល្អិតៗឲ្យស្លាប់ផង ឲ្យភិក្ខុទាំងឡាយឃ្លាតចាកសមាធិផង ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី

កដ្ឋបាទុកាយោ អភិរុហិត្វា អជ្ឈោកាសេ ចង្កមិស្សន្តិ ឧច្ចាសទ្ទា មហាសទ្ទា ខដខដសទ្ទា អនេកវិហិតំ តិរច្ឆានកថំ កថេន្តា សេយ្យថីទំ រាជកថំ ចោរកថំ ។បេ។ ឥតិភវាភវកថំ ឥតិ វា កីដកម្បិ អក្កមិត្វា មារេន្តិ ភិក្ខូបិ សមាធិម្ហា ចាវេន្តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខូ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ កដ្ឋបាទុកាយោ អភិរុហិត្វា អជ្ឈោកាសេ ចង្កមន្តិ ឧច្ចាសទ្ទា មហាសទ្ទា ខដខដសទ្ទា អនេកវិហិតំ តិរច្ឆានកថំ កថេន្តា សេយ្យថីទំ រាជកថំ ចោរកថំ ។បេ។ ឥតិភវាភវកថំ ឥតិ វា កីដកម្បិ អក្កមិត្វា មារេន្តិ ភិក្ខូបិ សមាធិម្ហា ចាវេន្តីតិ ។ សច្ចំ ភគវាតិ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ កដ្ឋបាទុកា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។



ហើយពាក់ស្បែកជើងឈើដើរក្នុងទីវាល មានសំឡេងរហ៊ោ សំឡេងខ្លាំង សំឡេងខ្ទុកខ្ទះ ហើយនិយាយតិរច្ឆានកថាផ្សេងៗ គឺនិយាយពីស្តេច និយាយពីចោរ ។បេ។ និយាយពីសេចក្តីចំរើននិងសេចក្តីសាបសូន្យផ្សេងៗ ហើយជាន់លើសត្វល្អិតៗ ឲ្យស្លាប់ខ្លះ ឲ្យភិក្ខុទាំងឡាយឃ្លាតចាកសមាធិខ្លះផង ។ គ្រានោះឯង ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកឆព្វគ្គិយភិក្ខុ ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រីហើយ ក៏ពាក់ស្បែកជើងឈើដើរទៅក្នុងទីវាល មានសំឡេងរហ៊ោ សំឡេងខ្លាំង សំឡេងខ្ទុកខ្ទះ ហើយនិយាយតិរច្ឆានកថាផ្សេងៗ គឺនិយាយពីស្តេច និយាយពីចោរ ។បេ។ និយាយពីសេចក្តីចំរើននិងសេចក្តីសាបសូន្យផ្សេងៗ ហើយដើរជាន់លើសត្វល្អិតៗ ឲ្យស្លាប់ខ្លះ ឲ្យភិក្ខុទាំងឡាយឃ្លាតចាកសមាធិខ្លះ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។បេ។ លុះព្រះមានព្រះភាគទ្រង់បន្ទោសរួច ទ្រង់ធ្វើធម្មីកថា ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើងឈើឡើយ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ ។

(៩៩) អថខោ ភគវា ភទ្ទិយេ យថាភិរន្តំ វិហរិត្វា យេន ពារាណសី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន ពារាណសី តទវសរិ ។ តត្រ សុទំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភគវតា កដ្ឋបាទុកា បដិក្ខិត្តាតិ តាលតរុណេ ឆេទាបេត្វា តាលបត្តបាទុកាយោ ធារេន្តិ តានិ តាលតរុណានិ ឆិន្នានិ មិលាយន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា តាលតរុណេ ឆេទាបេត្វា តាលបត្តបាទុកាយោ ធារេស្សន្តិ តានិ តាលតរុណានិ ឆិន្នានិ មិលាយន្តិ ឯកិន្ទ្រិយំ សមណា សក្យបុត្តិយា ជីវំ វិហេឋេន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ អថខោ តេ ភិក្ខូ



(៩៩) គ្រានោះឯង ព្រះមានព្រះភាគទ្រង់គង់នៅក្រុងភទ្ទិយៈ ដោយសមគួរដល់ព្រះអធ្យាស្រ័យ រួចហើយទ្រង់យាងសំដៅទៅក្រុងពារាណសី ទ្រង់យាងទៅកាន់ចារិកដោយលំដាប់ក៏បានដល់ទៅក្រុងពារាណសីនោះ ។ បានឮថា ព្រះដ៏មានព្រះភាគគង់នៅក្នុងព្រៃឥសិបតនៈមិគទាយវន ទៀបក្រុងពារាណសី ។ វេលានោះឯង ពួកឆព្វគ្គិយភិក្ខុគិតថា ទ្រនាប់ជើងឈើ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ក៏ប្រើគេឲ្យកាត់ត្នោតខ្ចីទាំងឡាយ (យកមកធ្វើ) ជាទ្រនាប់ជើងស្លឹកត្នោតហើយពាក់ ឯត្នោតខ្ចីទាំងនោះលុះគេកាត់ហើយក៏ស្វិតស្រពោន ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀលបន្ទុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តមិនសមបើនឹងហ៊ានប្រើគេឲ្យកាត់ត្នោតខ្ចី (យកមកធ្វើ) ជាទ្រនាប់ជើងស្លឹកត្នោតហើយពាក់សោះ ឯដើមត្នោតខ្ចីទាំងនោះលុះគេកាត់ហើយក៏ស្វិតស្រពោន ពួកសមណៈជាសក្យបុត្តហ៊ានបៀតបៀនវត្ថុដែលមានជីវិត មានឥន្ទ្រិយតែ ១ ។ កាលមនុស្សទាំងនោះកំពុងតែពោលទោសតិះដៀលបន្ទុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ ។ វេលានោះឯង ភិក្ខុទាំងនោះក្រាបទូល

ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខូ តាលតរុណានិ ឆេទាបេត្វា តាលបត្តបាទុកាយោ ធារេន្តិ តានិ តាលតរុណានិ ឆិន្នានិ មិលាយន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា តាលតរុណានិ ឆេទាបេត្វា តាលបត្តបាទុកាយោ ធារេស្សន្តិ តានិ តាលតរុណានិ ឆិន្នានិ មិលាយន្តិ ជីវសញ្ញិនោ ហិ ភិក្ខវេ មនុស្សា រុក្ខស្មឹ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ តាលបត្តបាទុកា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភគវតា តាលបត្តបាទុកា បដិក្ខិត្តាតិ វេឡុតរុណានិ ឆេទាបេត្វា វេឡុបត្តបាទុកាយោ ធារេន្តិ តានិ វេឡុតរុណានិ ឆិន្នានិ មិលាយន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ



សេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកឆព្វគ្គិយភិក្ខុប្រើគេឲ្យកាត់ត្នោតខ្ចីៗ (យកមកធ្វើ) ជាទ្រនាប់ជើងស្លឹកត្នោតហើយពាក់ ត្នោតខ្ចីទាំងនោះលុះគេកាត់ហើយក៏ស្វិតស្រពោន ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនសមបើនឹងប្រើគេឲ្យកាត់ត្នោតខ្ចីៗ (យកមកធ្វើ) ជាទ្រនាប់ជើងស្លឹកត្នោតហើយពាក់ទេ ត្នោតខ្ចីទាំងនោះលុះគេកាត់ហើយក៏ស្វិតស្រពោនអស់ ម្នាលភិក្ខុទាំងឡាយ ព្រោះពួកមនុស្សតែងសំគាល់ថា ដើមឈើមានជីវិត ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីគាប់ចិត្តពួកជនដែលមិនទាន់ជ្រះថ្លាឲ្យបានជ្រះថ្លាឡើងទេ ។បេ។ លុះទ្រង់បន្ទោសរួចទ្រង់ធ្វើនូវធម្មីកថាហើយត្រាស់ហៅភិក្ខុទាំងឡាយមកទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ទ្រនាប់ជើងស្លឹកត្នោតឡើយ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុគិតថា ទ្រនាប់ជើងស្លឹកត្នោតព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ទើបប្រើគេឲ្យកាត់ឫស្សីខ្ចីទាំងឡាយវិញ (យកមកធ្វើ) ជាទ្រនាប់ជើងស្លឹកឫស្សីហើយពាក់ ឯឫស្សីខ្ចីទាំងនោះលុះគេកាត់ហើយក៏ស្វិតស្រពោនអស់ ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀលបន្ទុះបង្អាប់ថា

កថំ ហិ នាម សមណា សក្យបុត្តិយា វេឡុតរុណេ ឆេទាបេត្វា វេឡុបាទុកាយោ ធារេស្សន្តិ តានិ វេឡុតរុណានិ ឆិន្នានិ មិលាយន្តិ ឯកិន្ទ្រិយំ សមណា សក្យបុត្តិយា ជីវំ វិហេឋេន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ វេឡុបាទុកា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២៥០] អថខោ ភគវា ភទ្ទិយេ យថាភិរន្តំ វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន សាវត្ថី តទវសរិ ។ តត្រ សុទំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ ។ បេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អនេកវិហិតំ បាទុកមណ្ឌនានុយោគមនុយុត្តា វិហរន្តិ តិណបាទុកំ ករោន្តិបិ ការាបេន្តិបិ មុញ្ជបាទុកំ ករោន្តិបិ ការាបេន្តិបិ



ពួកសមណៈជាសក្យបុត្រមិនគួរបើនឹងហ៊ានប្រើគេឲ្យកាត់ឫស្សីខ្ចីទាំងឡាយ (យកមកធ្វើ) ជាទ្រនាប់ជើងស្លឹកឫស្សីហើយពាក់សោះ ឯឫស្សីខ្ចីទាំងនោះលុះគេកាត់ហើយក៏ស្វិតស្រពោនទៅ ពួកសមណៈជាសក្យបុត្រហ៊ានបៀតបៀនរបស់ដែលមានជីវិតមានឥន្ទ្រិយតែ ១ ។ កាលមនុស្សទាំងនោះកំពុងតែពោលទោសតិះដៀលបន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ ។ វេលានោះឯង ភិក្ខុទាំងនោះក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ទ្រនាប់ជើងស្លឹកឫស្សីឡើយ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ ។

[២៥០] គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងក្រុងភទ្ទិយៈសមគួរតាមព្រះអធ្យាស្រ័យរួចទ្រង់យាងទៅកាន់ចារិកនៃក្រុងសាវត្ថី កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ក៏បានដល់ទៅក្រុងសាវត្ថីនោះ ។ បានឮមកថា ព្រះអង្គគង់នៅក្នុងវត្តជេតពន ទៀបក្រុងសាវត្ថីនោះ ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ (ភិក្ខុដែលនៅក្នុងក្រុងសាវត្ថី) មានសេចក្ដីខ្វល់ខ្វាយក្នុងការប្រដាប់ទ្រនាប់ជើងមានប្រការផ្សេងៗ ។ គឺធ្វើទ្រនាប់ជើងស្មៅខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅបាបូស

បព្វជបាទុកំ ករោន្តិបិ ការាបេន្តិបិ ហិន្តាលបាទុកំ ករោន្តិបិ ការាបេន្តិបិ កមលបាទុកំ ករោន្តិបិ ការាបេន្តិបិ កម្ពលបាទុកំ ករោន្តិបិ ការាបេន្តិបិ រិញ្ចន្តិ ឧទ្ទេសំ បរិបុច្ឆំ អធិសីលំ អធិចិត្តំ អធិបញ្ញំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភទ្ទិយា ភិក្ខូ អនេកវិហិតំ បាទុកមណ្ឌនានុយោគមនុយុត្តា វិហរិស្សន្តិ តិណបាទុកំ ករិស្សន្តិបិ ការាបេស្សន្តិបិ មុញ្ជបាទុកំ ករិស្សន្តិបិ ការាបេស្សន្តិបិ បព្វជបាទុកំ ករិស្សន្តិបិ ការាបេស្សន្តិបិ ហិន្តាលបាទុកំ ករិស្សន្តិបិ ការាបេស្សន្តិបិ កមលបាទុកំ ករិស្សន្តិបិ ការាបេស្សន្តិបិ កម្ពលបាទុកំ ករិស្សន្តិបិ ការាបេស្សន្តិបិ រិញ្ចិស្សន្តិ ឧទ្ទេសំ បរិបុច្ឆំ អធិសីលំ អធិចិត្តំ អធិបញ្ញន្តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ



ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្រទាប់ជើងស្មៅដំណេកកន្ទេលព្រាយខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្រទាប់ជើងស្លឹកត្នោតខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្រទាប់ជើងស្មៅមានគល់ដូចផ្កាឈូកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្រទាប់ជើងសំពត់ដែលគេត្បាញដោយរោមសត្វខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ក៏លះបង់ចោលនូវបាលី អដ្ឋកថា អធិសីល អធិចិត្ត និងអធិបញ្ញា[1] ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកភទ្ទិយភិក្ខុមិនសមបើនឹងខ្វល់ខ្វាយក្នុងការតាក់តែងស្រទាប់ជើងមានប្រការផ្សេង ៗ គឺធ្វើស្រទាប់ជើងស្មៅខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្រទាប់ជើងស្មៅបាបុងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្រទាប់ជើងស្មៅដំណេកកន្ទេលព្រាយខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្រទាប់ជើងស្លឹកត្នោតខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្រទាប់ជើងស្មៅមានគល់ដូចផ្កាឈូកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្រទាប់ជើងដែលគេត្បាញដោយរោមសត្វខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ហើយលះបង់នូវបាលី អដ្ឋកថា អធិសីល អធិចិត្ត និងអធិបញ្ញាសោះ ។ វេលានោះ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាល

---

១ អដ្ឋកថា ក្នុងពាក្យនេះ គង្វាល់សេចក្តីថា អធិសីល បានខាងជាតិមោក្ខសីល ។ អធិចិត្ត បានខាងសមាបត្តិជាលោកិយ ។ អធិបញ្ញា បានខាងមគ្គញាណជាលោកុត្តរ ។

ភិក្ខវេ ឆព្វគ្គិយា ភិក្ខូ អនេកវិហិតំ បាទុកមណ្ឌនានុ-
យោគមនុយុត្តា វិហរន្តិ តិណបាទុកំ ករោន្តិបិ ការា-
បេន្តិបិ មុញ្ជបាទុកំ ករោន្តិបិ ការាបេន្តិបិ បព្វជបា-
ទុកំ ករោន្តិបិ ការាបេន្តិបិ ហិន្តាលបាទុកំ ករោន្តិបិ
ការាបេន្តិបិ កមលបាទុកំ ករោន្តិបិ ការាបេន្តិបិ
កម្ពលបាទុកំ ករោន្តិបិ ការាបេន្តិបិ រិញ្ចន្តិ ឧទ្ទេសំ
បរិបុច្ឆំ អធិសីលំ អធិចិត្តំ អធិបញ្ញំ ។ សច្ចំ ភគវាតិ ។
វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោ-
ឃបុរិសា អនេកវិហិតំ បាទុកមណ្ឌនានុយោគមនុយុ-
ត្តា វិហរិស្សន្តិ តិណបាទុកំ ករិស្សន្តិបិ ការាបេស្សន្តិបិ
មុញ្ជបាទុកំ ករិស្សន្តិបិ ការាបេស្សន្តិបិ បព្វជបាទុកំ
ករិស្សន្តិបិ ការាបេស្សន្តិបិ ហិន្តាលបាទុកំ ករិស្សន្តិបិ
ការាបេស្សន្តិបិ កមលបាទុកំ ករិស្សន្តិបិ ការា-
បេស្សន្តិបិ កម្ពលបាទុកំ ករិស្សន្តិបិ ការាបេស្សន្តិបិ



ភិក្ខុទាំងឡាយ ពួកភិក្ខុឆព្វគ្គិយ៍ខ្វល់ខ្វាយក្នុងការតាក់តែងស្បែកជើង
មានប្រការផ្សេងៗ គឺធ្វើស្បែកជើងស្មៅខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្បែ-
កជើងស្មៅយាប្លងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្បែកជើងស្មៅបំ-
ណេកខ្សាយខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្បែកជើងស្លឹកទន្សែខ្លួនឯង
ខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្បែកជើងស្មៅមានពណ៌ដូចផ្កាឈូកខ្លួនឯងខ្លះ
ប្រើគេឲ្យធ្វើខ្លះ ធ្វើស្បែកជើងសំពត់ដែលគេត្បាញដោយរោមសត្វខ្លួន
ឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ហើយលះបង់បាលី អដ្ឋកថា អធិសីល
អធិចិត្តនឹងអធិប្បញ្ញា ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រ
ព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា
ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរសទាំងនោះមិនសមបើនឹងខ្វល់ខ្វាយក្នុង
ការតាក់តែងស្បែកជើងមានប្រការផ្សេងៗ គឺធ្វើស្បែកជើងស្មៅខ្លួនឯង
ខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្បែកជើងស្មៅយាប្លងខ្លួនឯងខ្លះ ប្រើគេ
ឲ្យធ្វើខ្លះ ធ្វើស្បែកជើងស្មៅបំណេកខ្សាយខ្លួនឯងខ្លះ ប្រើគេឲ្យ
ធ្វើខ្លះ ធ្វើស្បែកជើងស្លឹកទន្សែខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្បែ-
កជើងស្មៅមានពណ៌ដូចផ្កាឈូកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើស្បែ-
កជើងសំពត់ដែលគេត្បាញដោយរោមសត្វខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ

## ចម្មក្ខន្ធកេ អកប្បិយបាទុកាបញ្ញត្តិ

ហាយិស្សន្តិ ឧទ្ទេសំ បរិបុច្ឆំ អធិសីលំ អធិចិត្តំ អធិបញ្ញំ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ តិណបាទុកា ធារេតព្វា ន មុញ្ជបាទុកា ធារេតព្វា ន បព្វជបាទុកា ធារេតព្វា ន ហិន្តាលបាទុកា ធារេតព្វា ន កមលបាទុកា ធារេតព្វា ន កម្ពលបាទុកា ធារេ-តព្វា ន សោវណ្ណមយា បាទុកា ធារេតព្វា ន រូបិយម-យា បាទុកា ធារេតព្វា ន មណិមយា បាទុកា ធារេ-តព្វា ន វេឡុរិយមយា បាទុកា ធារេតព្វា ន ផលិកម-យា បាទុកា ធារេតព្វា ន កំសមយា បាទុកា ធារេ-តព្វា ន កាចមយា បាទុកា ធារេតព្វា ន តិបុមយា បាទុកា ធារេតព្វា ន សីសមយា បាទុកា ធារេ-តព្វា ន តម្ពលោហមយា បាទុកា ធារេតព្វា យោ



## ចម្មក្ខន្ធកៈ សេចក្ដីបញ្ញត្តិនូវទ្រនាប់ជើងជាអកប្បិយ

លះបង់នូវបាលី អដ្ឋកថា អធិសីល អធិចិត្ត និងអធិប្បញ្ញា ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនបាននាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើងទេ ។ បេ ។ លុះទ្រង់បន្ទោសរួចទ្រង់ធ្វើនូវធម្មីកថា ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ទ្រនាប់ជើងស្មៅ មិនត្រូវពាក់ទ្រនាប់ជើងស្មៅយាប្លង់ មិនត្រូវពាក់ទ្រនាប់ជើងស្មៅដំលោកចន្លុយ មិនត្រូវពាក់ទ្រនាប់ជើងស្លឹកចខ្សែ មិនត្រូវពាក់ទ្រនាប់ជើងស្មៅមានពណ៌ដូចផ្កាឈូក មិនត្រូវពាក់ទ្រនាប់ជើងសំពត់ដែលគេត្បាញដោយរោមសត្វ មិនត្រូវពាក់ទ្រនាប់ជើងមាស មិនត្រូវពាក់ទ្រនាប់ជើងប្រាក់ មិនត្រូវពាក់ទ្រនាប់ជើងកែវមណី មិនត្រូវពាក់ទ្រនាប់ជើងកែវពិទូរ្យ មិនត្រូវពាក់ទ្រនាប់ជើងកែវផ្លុក មិនត្រូវពាក់ទ្រនាប់ជើងសំរិទ្ធ មិនត្រូវពាក់ទ្រនាប់ជើងកែវកញ្ចក់ មិនត្រូវពាក់ទ្រនាប់ជើងសំណប៉ាហាំង (សំណស) មិនត្រូវពាក់ទ្រនាប់ជើងសំណកក់ (សំណខ្មៅ) មិនត្រូវពាក់ទ្រនាប់ជើងទង់ដែង ភិក្ខុ

ធារេយ្យ អាបត្តិ ទុក្កដស្ស ។ ន ភិក្ខវេ កាចិ សង្កមនីយា បាទុកា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ តិស្សោ បាទុកាយោ ធុវដ្ឋានិយា អសង្កមនីយាយោ វច្ចបាទុកំ បស្សាវ-បាទុកំ អាចមនបាទុកន្តិ ។

(៦១) អថខោ ភគវា ភទ្ទិយេ យថាភិរន្តំ វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន សាវត្ថី តទវសរិ ។ តត្រ សុទំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អចិរវតិយា នទិយា គាវីនំ តរន្តីនំ វិសាណេសុបិ គណ្ហន្តិ កណ្ណេសុបិ គណ្ហន្តិ គីវាយបិ គណ្ហន្តិ ឆេប្បាយបិ គណ្ហន្តិ បិដ្ឋិម្បិ អភិរុហន្តិ រត្តចិត្តាបិ អង្គជាតំ ឆុបន្តិ វច្ឆតរីបិ ឱគាហេត្វា មារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា គាវីនំ តរន្តីនំ វិសាណេសុបិ គណ្ហិស្សន្តិ



ណាពាក់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមិនត្រូវប្រើប្រាស់ទ្រនាប់ជើង (គឺស្បែកជើង) ណាមួយដែលគួរនឹងឲ្យកម្រើកទៅបាន ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់ជើង ៣ យ៉ាងដែលគេដាក់នៅជានិច្ច ដែលគេឲ្យកម្រើកទៅមិនបាន គឺទ្រនាប់ជើងសម្រាប់បន្ទោបង់វច្ចៈ ១ ទ្រនាប់ជើងសម្រាប់បន្ទោបង់បស្សាវៈ ១ ទ្រនាប់ជើងសម្រាប់លាងជម្រះ (លាមក) ១ ។

(៦១) គ្រានោះឯង ព្រះមានព្រះភាគទ្រង់គង់ក្នុងនគរភទ្ទិយៈគួរដល់ព្រះទ័យហើយ ទ្រង់យាងទៅកាន់ចារិកក្រុងសាវត្ថី កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ក៏បានដល់ទៅក្រុងសាវត្ថីនោះ ។ បានឮមកថា ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងជេតពន របស់អនាថបិណ្ឌិក-សេដ្ឋី ជិតក្រុងសាវត្ថីនោះ ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ កាលមេគោទាំងឡាយកំពុងនឹងឆ្លងស្ទឹងអចិរវតី ក៏ចាប់ស្នែងខ្លះ ចាប់ស្លឹកត្រចៀកខ្លះ ចាប់កខ្លះ ចាប់កន្ទុយខ្លះ ឡើងជិះលើខ្នងខ្លះ មានចិត្តត្រេកអរ ក៏ស្ទាបអង្គជាតខ្លះ ចាប់ជ្រមុជកូនគោញីទឹកឲ្យស្លាប់ខ្លះ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្ត កាលមេគោទាំងឡាយកំពុងឆ្លងទឹក មិនសមបើនឹងចាប់ស្នែងខ្លះ

កណ្ណេសុបិ គណ្ហិស្សន្តិ គីវាយបិ គណ្ហិស្សន្តិ ឆេប្បាយបិ គណ្ហិស្សន្តិ បិដ្ឋិម្បិ អភិរូហិស្សន្តិ រត្តចិត្តាបិ អង្គជាតំ ឆុបិស្សន្តិ វច្ឆតរឹបិ ឱគាហេត្វា មារេស្សន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ គាវីនំ វិសាណេសុ គហេតព្វំ ។ ន កណ្ណេសុ គហេតព្វំ ។ ន គីវាយ គហេតព្វំ ។ ន ឆេប្បាយ គហេតព្វំ ។ ន បិដ្ឋិ អភិរូហិតព្វា យោ អភិរូហេយ្យ អាបត្តិ ទុក្កដស្ស ។ ន ភិក្ខវេ រត្តចិត្តេន អង្គជាតំ ឆុបិតព្វំ យោ ឆុបេយ្យ អាបត្តិ ថុល្លច្ចយស្ស ។ ន វច្ឆតរី មារេតព្វា យោ មារេយ្យ យថាធម្មោ ការេតព្វោតិ ។





ចាប់ស្លឹក(ត្រចៀក)ខ្លះ ចាប់កខ្លះ ចាប់កន្ទុយខ្លះ ឡើងជិះលើខ្នងខ្លះ មានចិត្តតម្រេក ហើយស្ទាបអង្គជាតខ្លះ ចាប់ច្រមុះកូនគោញីក្នុងទឹកឲ្យស្លាប់ខ្លះ ដូចជាពួកគ្រហស្ថអ្នកបរិភោគកាមគុណដូច្នោះ ។ កាលមនុស្សទាំងនោះ កំពុងតែពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយបានឮច្បាស់ ។ វេលានោះឯង ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចាប់ស្នែងមេគោទាំងឡាយ មិនត្រូវចាប់ស្លឹក(ត្រចៀក) មិនត្រូវចាប់ក មិនត្រូវចាប់កន្ទុយ មិនត្រូវឡើងជិះលើខ្នង ភិក្ខុណាឡើងជិះ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមិនត្រូវមានចិត្តត្រេកអរពាល់អង្គជាត(មេគោ)ឡើយ ភិក្ខុណាពាល់ ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុមិនត្រូវធ្វើកូនគោឲ្យស្លាប់ឡើយ ភិក្ខុណាធ្វើឲ្យស្លាប់ ភិក្ខុនោះនឹងយកទោសត្រូវឲ្យធ្វើតាមធម៌[១] ។

---

១ គ្រឿងសម្រាប់អាបត្តិតាមសញ្ញាបានសំរេច សញ្ញាណនេះជាដំបូងយកល្អ ។ ក្នុងអដ្ឋកថាគេសម្តែងថាសំគាល់ក្រៅតែអាបត្តិដែលមានជាតិមោក្ខ យើងនៅក្នុងណាមួយរំលាយជាប់ តាក់តែងដោយអាបត្តិក្នុងជាតិមោក្ខនោះ ព្រោះតែមានព្រាហ្មណ៍ត្រូវធ្វើតាមធម៌ ។ យ៉ាងនេះ ព្រោះបាននិយាយរួចមកហើយ ។

[៦៦] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ យានេន យាយន្តិ ឥត្ថីយុត្តេនបិ បុរិសន្តរេន បុរិសយុត្តេនបិ ឥត្ថន្តរេន ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ សេយ្យថាបិ គង្គាមហិយាយាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ យានេន យាយិតព្វំ យោ យាយេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ កោសលេសុ ជនបទេសុ សាវត្ថឹ គច្ឆន្តោ ភគវន្តំ ទស្សនាយ អន្តរាមគ្គេ គិលានោ ហោតិ ។ អថខោ សោ ភិក្ខុ មគ្គា ឱក្កម្ម អញ្ញតរស្មឹ រុក្ខមូលេ និសីទិ ។ មនុស្សា តំ ភិក្ខុំ បស្សិត្វា(១) ឯតទវោចុំ កហំ ភន្តេ អយ្យោ គមិស្សតីតិ ។ សាវត្ថឹ ខោ អហំ អាវុសោ គមិស្សាមិ ភគវន្តំ ទស្សនាយាតិ ។ ឯហិ ភន្តេ គមិស្សាមាតិ ។ នាហំ អាវុសោ សក្កោមិ គិលានោម្ហីតិ ។ ឯហិ ភន្តេ យានំ អភិរុហាតិ ។ អលំ

១ ម. ទិស្វា ។



[៦៦] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទៅដោយយានដែលគេទឹមដោយមេគោញី មានបុរសជាអ្នកបរក៏មាន ទឹមដោយគោឈ្មោល មានស្រីជាអ្នកបរក៏មាន ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកជនដែលទៅលេងទឹកស្ទឹងគង្គានិងស្ទឹងមហី ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទៅដោយយានឡើយ ភិក្ខុណាទៅ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់ក្រុងសាវត្ថីក្នុងកោសលជនបទដើម្បីគាល់ព្រះដ៏មានព្រះភាគ ដល់ពាក់កណ្តាលផ្លូវក៏មានជម្ងឺ ។ វេលានោះឯង ភិក្ខុនោះក៏ចេញចុះបញ្ចៀសពីផ្លូវ ទៅអង្គុយនៅក្រោមដើមឈើ ១ ។ មនុស្សទាំងឡាយក្រឡេកឃើញភិក្ខុនោះហើយក៏បាននិយាយពាក្យនេះថា បពិត្រលោកដ៏ចំរើន លោកម្ចាស់នឹងនិមន្តទៅទីណា ។ ភិក្ខុនោះប្រាប់ថា នែអ្នកដ៏មានអាយុ អាត្មានឹងទៅក្រុងសាវត្ថីដើម្បីគាល់ព្រះដ៏មានព្រះភាគ ។ មនុស្សទាំងនោះទូលថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់និមន្តមក យើងនឹងទៅជាមួយគ្នា ។ ភិក្ខុនោះតបថា នែអ្នកដ៏មានអាយុ អាត្មាទៅមិនរួចទេ ព្រោះអាត្មាមានជម្ងឺ ។ មនុស្សទាំងនោះទូលថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់និមន្តមកឡើងជិះយានទៅ ។ ភិក្ខុនោះតបថា នែអ្នកដ៏មានអាយុ

អាវុសោ បដិក្ខិត្តំ ភគវតា យានន្តិ ។ កុក្កុច្ចាយន្តោ យានំ នាភិរុហិ ។ អថខោ សោ ភិក្ខុ សាវត្ថឹ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ គិលានស្ស យានន្តិ ។ អថខោ ភិក្ខូនំ ឯតទ-ហោសិ ឥត្ថីយុត្តំ នុ ខោ បុរិសយុត្តំ នុ ខោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បុរិសយុត្តំ ហត្ថវដ្ដកន្តិ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ យានុគ្ឃាតេន ពាឡ្ហតរំ អផាសុ អហោសិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុ-ជានាមិ ភិក្ខវេ សិវិកំ បាដង្កិន្តិ ។



មិនឡើង ព្រោះយានព្រះដ៏មានព្រះភាគទ្រង់ហាមឃាត់ហើយ ។ ភិក្ខុនោះរង្កៀសក្នុងចិត្ត ក៏មិនឡើងជិះយានឡើយ ។ វេលានោះឯង ភិក្ខុនោះក៏ដើរទៅដល់ក្រុងសាវត្ថី ទាំងដំណាលរឿងនុ៎ះដល់ភិក្ខុទាំង-ឡាយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតយានដល់ភិក្ខុដែលមានជម្ងឺ ។ វេលានោះ ភិក្ខុទាំងឡាយមានសេចក្ដីត្រិះរិះយ៉ាងនេះថា (ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាត) យានដែលទឹមដោយសត្វញី ឬទឹមដោយសត្វឈ្មោលហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតយានដែលគេទឹមដោយសត្វឈ្មោល និងយានដែលសម្រាប់រុញដោយដៃ(១) ។ សម័យនោះឯង មានភិក្ខុ ១ រូបកើតសេចក្ដីមិនសប្បាយខ្លាំង ព្រោះទង្គិចទង្គក់ដោយយាន (យានរលាក់) ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំ-ពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវគ្រែស្នែងនិងអង្រឹងស្នែង ។

---

១ អដ្ឋកថា ថា៖ យានដែលសម្រាប់គួរឲ្យរុញដោយដៃ ទុកជាប្រុសក្ដី ស្រីក្ដី គួររុញទៅក៏បាន ។

(៦៣) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧច្ចាសយនមហាសយនានិ ធារេន្តិ សេយ្យថីទំ អាសន្ទឹ បល្លង្កំ គោណកំ ចិត្តកំ បដិកំ បដលិកំ តូលិកំ វិកតិកំ ឧទ្ទលោមឹ ឯកន្តលោមឹ កដិស្សំ កោសេយ្យំ កុត្តកំ ហត្ថត្ថរំ អស្សត្ថរំ រថត្ថរំ



(៦៣) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ឧច្ចាសយនៈ (ទីដេកខ្ពស់ហួសប្រមាណ) និងមហាសយនៈ (ទីដេកប្រណីតខ្ពង់ខ្ពស់) គឺ អាសន្ទិ (អាសនៈដែលខ្ពស់ហួសប្រមាណ)១ បល្លង្ក (គ្រែដែលមានជើងឆ្លាក់ជារូបសត្វសាហាវ)១ គោណកៈ (ព្រំដែលមានរោមវែងជាង ៤ ធ្នាប់)១ ចិត្តកៈ (កម្រាលដែលគេធ្វើដោយរោមសត្វវិចិត្រដោយរូបសត្វសាហាវ)១ បដិកៈ (កម្រាលពណ៌សដែលធ្វើដោយរោមសត្វ)១ បដលិកៈ (កម្រាលដែលធ្វើដោយរោមសត្វជាផ្កាចង្កោម)១ តូលិកៈ (កម្រាលដែលញាត់ដោយគរជាប្រក្រតី)១ វិកតិកៈ (កម្រាលដែលធ្វើដោយរោមសត្វវិចិត្រដោយរូបសត្វមានសីហៈ និងខ្លាធំជាដើម)១ ឧទ្ទលោមិ (កម្រាលដែលធ្វើដោយរោមសត្វ មានរោមក្រោងឡើងតែម្ខាង)១ ឯកន្តលោមិ (កម្រាលដែលធ្វើដោយរោមសត្វ មានរោមក្រោងឡើងទាំងសងខាង)១ កដិស្សៈ (កម្រាលដែលធ្វើដោយទិងមាសនិងសូត្រ ហើយដាក់ស្រេះដោយរតនៈ(១))១ កោសេយ្យៈ (កម្រាលដែលធ្វើដោយសរសៃសូត្រ ហើយដាក់ស្រេះដោយរតនៈ)១ កុត្តកៈ (កម្រាលដែលធ្វើដោយរោមសត្វ ល្មមនាដកីប្រើរាំ ១៦ នាក់ឈររាំបាន)១ ហត្ថត្ថរៈ (កម្រាលសម្រាប់ក្រាលលើខ្នងដំរី)១ អស្សត្ថរៈ (កម្រាលសម្រាប់ក្រាលលើខ្នងសេះ)១ រថត្ថរៈ

១ រតនៈ សំដៅយកកែវមុក្តា កែវមណី សង្ខ ថ្ម មាស និងប្រាក់ជាដើម ។

អជិនប្បវេណឹ កទលិមិគបវរបច្ចត្ថរណំ សឧត្តរច្ឆទំ ឧភតោលោហិតកូបធានំ ។ មនុស្សា វិហារ-ជាតិកំ អាហរិស្សន្តិ បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ឧច្ចាសយនមហាសយនានិ ធារេតព្វានិ សេយ្យថីទំ អាសន្ទិ បល្លង្កោ គោណកោ ចិត្តកោ បដិកា



(កម្រាលសម្រាប់ក្រាលលើថ) ។ អជិនប្បវេណិ (កម្រាលដែលធ្វើដោយស្បែកខ្លា) ។ កម្រាលដ៏ឧត្តមដែលគេធ្វើដោយស្បែកសត្វឈ្លូស ។ ខ្នើយមានពណ៌ក្រហមទាំងពីរខាង (ខ្នើយក្បាលនិងខ្នើយជើង) ព្រមទាំងពិតានដែលមានពណ៌ក្រហម ។ ៗ មនុស្សទាំងឡាយកាលដើរទៅកាន់វិហារជាតិធ្លាប់ឃើញហើយក៏ពោលទោស តិះដៀលចំពោះបព្វជិតថា ដូចជាពួកគ្រហស្ថដែលបរិភោគកាមគុណ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ឧច្ចាសយនៈនិងមហាសយនៈឡើយ គឺ អាសន្ទិ (អាសនៈដែលខ្ពស់ហួសប្រមាណ) ។ បល្លង្ក (គ្រែដែលមានជើងវិចិត្រដោយរូបសត្វសាហាវ) ។ គោណកៈ (ព្រំដែលមានរោមវែងជាង ៤ ធ្នាប់) ។ ចិត្តកៈ (កម្រាលដែលគេធ្វើដោយរោមសត្វវិចិត្រដោយរូបសត្វសាហាវ) ។ បដិកៈ (កម្រាលដែលមាន

បដលិកា តូលិកា វិកតិកា ឧទ្ទលោមី ឯកន្តលោមី កដ្ឋិស្សំ កោសេយ្យំ កុត្តកំ ហត្ថត្ថរំ អស្សត្ថរំ រថត្ថរំ អជិនប្បវេណិំ កាទលិមិគប្បវរប្បច្ចត្ថរណំ សឧត្តរច្ឆទំ ឧភតោលោហិតកូបធានំ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។



ពណ៌សធ្វើដោយរោមសត្វ)។ បដលិកៈ (កម្រាលដែលធ្វើដោយរោមសត្វជាផ្កាចង្កោម)។ តូលិកៈ (កម្រាលដែលញាត់ដោយគរប្រក្រី)។ វិកតិកៈ (កម្រាលដែលធ្វើដោយរោមសត្វវិចិត្រដោយរូបសត្វមានសីហៈ និងខ្លាធំជាដើម)។ ឧទ្ទលោមិ (កម្រាលដែលធ្វើដោយរោមសត្វមានរោមព្រាងឡើងតែម្ខាង)។ ឯកន្តលោមិ (កម្រាលដែលធ្វើដោយរោមសត្វមានរោមព្រាងឡើងទាំងសងខាង)។ កដ្ឋិស្សំ (កម្រាលដែលធ្វើដោយរត្ននិងសរសៃសូត្រហើយដាក់ស្រេះដោយកេនៈ)។ កោសេយ្យ (កម្រាលដែលធ្វើដោយសរសៃសូត្រហើយដាក់ស្រេះដោយកេនៈ)។ កុត្តកៈ (កម្រាលដែលធ្វើដោយរោមសត្វល្មមពួកស្រីរាំ ១៦ នាក់ឈររាំបាន)។ ហត្ថត្ថរៈ (កម្រាលសម្រាប់ក្រាលលើខ្នងដំរី)។ អស្សត្ថរៈ (កម្រាលសម្រាប់ក្រាលលើខ្នងសេះ)។ រថត្ថរៈ (កម្រាលសម្រាប់ក្រាលលើរថ)។ អជិនប្បវេណិ (កម្រាលដែលគេធ្វើដោយស្បែកខ្លា)។ កម្រាលដ៏ឧត្តមដែលគេធ្វើដោយស្បែកសត្វឈ្លូស។ ខ្នើយមានពណ៌ក្រហមទាំងពីរខាង (ខ្នើយក្បាលនិងខ្នើយជើង) ក្រមពិតានដែលមានពណ៌ក្រហម។ ភិក្ខុណាទៅប្រើប្រាស់ត្រូវអាបត្តិទុក្កដ ។

(៦៤) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភគវតា ឧច្ចាសយនមហាសយនានិ បដិក្ខិត្តានីតិ មហាចម្មានិ ធារេន្តិ សីហចម្មំ ព្យគ្ឃចម្មំ ទីបិចម្មំ ។ តានិ មញ្ចប្បមាណេន ឆិន្នានិ ហោន្តិ បីឋប្បមាណេន ឆិន្នានិ ហោន្តិ អន្តោបិ មញ្ចេ បញ្ញត្តានិ ហោន្តិ ពហិបិ មញ្ចេ បញ្ញត្តានិ ហោន្តិ អន្តោបិ បីឋេ បញ្ញត្តានិ ហោន្តិ ពហិបិ បីឋេ បញ្ញត្តានិ ហោន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ មហាចម្មានិ ធារេតព្វានិ សីហចម្មំ ព្យគ្ឃចម្មំ ទីបិចម្មំ យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[៦៥] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភគវតា មហាចម្មានិ បដិក្ខិត្តានីតិ គោចម្មានិ ធារេន្តិ ។ តានិ មញ្ចប្បមាណេន ឆិន្នានិ ហោន្តិ បីឋប្បមាណេន ឆិន្នានិ ហោន្តិ អន្តោបិ មញ្ចេ បញ្ញត្តានិ ហោន្តិ ពហិបិ មញ្ចេ បញ្ញត្តានិ ហោន្តិ អន្តោបិ បីឋេ បញ្ញត្តានិ ហោន្តិ ពហិបិ បីឋេ បញ្ញត្តានិ ហោន្តិ ។



(៦៤) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ គិតថា ឧច្ចាសយនៈ មហាសយនៈ ព្រះមានព្រះភាគបានទ្រង់ហាមហើយ ក៏នាំគ្នាប្រើប្រាស់ស្បែកសត្វធំ គឺស្បែកសត្វសីហៈ ស្បែកខ្លាធំ ស្បែកខ្លាដំបង ។ ស្បែកទាំងនោះពួកឆព្វគ្គិយភិក្ខុបានកាត់ឲ្យល្មមនឹងគ្រែខ្លះ កាត់ឲ្យល្មមនឹងតាំងខ្លះ ក្រាលលើគ្រែខាងក្នុងខ្លះ ក្រាលលើគ្រែខាងក្រៅខ្លះ ក្រាលលើតាំងខាងក្នុងខ្លះ ក្រាលលើតាំងខាងក្រៅខ្លះ ។ មនុស្សទាំងឡាយដើរទៅកាន់វិហារចារិកឃើញ ហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចពួកគ្រហស្ថអ្នកបរិភោគកាមគុណ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនត្រូវប្រើប្រាស់នូវស្បែកសត្វធំ គឺស្បែកសត្វសីហៈ ស្បែកខ្លាធំ ស្បែកខ្លាដំបងឡើយ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

(៦៥) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុគិតថា ស្បែកសត្វធំ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ក៏នាំគ្នាប្រើប្រាស់ស្បែកគោទាំងឡាយវិញ ។ ស្បែកគោទាំងនោះពួកឆព្វគ្គិយភិក្ខុបានកាត់ឲ្យល្មមនឹងគ្រែខ្លះ កាត់ឲ្យល្មមនឹងតាំងខ្លះ ក្រាលលើគ្រែខាងក្នុងខ្លះ ក្រាលលើគ្រែខាងក្រៅខ្លះ ក្រាលលើតាំងខាងក្នុងខ្លះ ក្រាលលើតាំងខាងក្រៅខ្លះ ។

អញ្ញតរោបិ ទហរភិក្ខុ អញ្ញតរស្ស ឧបាសកស្ស កុលុបកោ ហោតិ ។ អថខោ សោ ទហរភិក្ខុ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន តស្ស ឧបាសកស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ សោ ឧបាសកោ យេន ទហរភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ទហរភិក្ខុំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ តេន ខោ បន សមយេន តស្ស ឧបាសកស្ស វច្ឆកោ ហោតិ តរុណោ អភិរូបោ ទស្សនីយោ បាសាទិកោ ចិត្រោ សេយ្យថាបិ ទីបិច្ឆាបោ ។ អថខោ សោ ទហរភិក្ខុ តំ វច្ឆកំ សាបេក្ខោ ឧបនិជ្ឈាយតិ ។ អថខោ សោ ឧបាសកោ តំ ទហរភិក្ខុំ ឯតទវោច កិស្ស ភន្តេ អយ្យោ ឥមំ វច្ឆកំ សាបេក្ខោ ឧបនិជ្ឈាយតីតិ ។ អត្ថោ មេ អាវុសោ ឥមស្ស វច្ឆកស្ស ចម្មេនាតិ ។ អថខោ សោ ឧបាសកោ តំ វច្ឆកំ វធិត្វា ចម្មំ វិធុនិត្វា តស្ស ទហរភិក្ខុនោ អទាសិ ។ អថខោ សោ ទហរភិក្ខុ តំ ចម្មំ សង្ឃាដិយា បដិច្ឆាទេត្វា អគមាសិ ។



មិនតែប៉ុណ្ណោះ មានភិក្ខុខ្ចីមួយរូប ជាកុលូបករបស់ឧបាសកម្នាក់ ។ វេលានោះ ភិក្ខុខ្ចីនោះ លុះវេលាព្រឹកព្រហាមក៏ស្លៀកស្បង់ហើយ កាន់យកបាត្រនិងចីវរ ហើយចូលទៅកាន់ផ្ទះរបស់ឧបាសកនោះ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ លំដាប់នោះ ឧបាសកនោះក៏ចូលទៅរកភិក្ខុខ្ចី លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំភិក្ខុខ្ចីនោះ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ គ្រានោះឯង ឧបាសកនោះមានកូនគោ ១ មានរូបល្អគួរជាទីរមិលមើល នាំឲ្យកើតសេចក្តីជ្រះថ្លា ពិចិត្រ ប្រៀបដូចនឹងកូនខ្លាដំបង ។ វេលានោះ ភិក្ខុខ្ចីនោះក៏សំឡឹងមើលទៅកូនគោនោះមិនដាក់ភ្នែកសោះ ។ លំដាប់នោះ ឧបាសកនោះ បាននិយាយពាក្យនេះនឹងភិក្ខុខ្ចីនោះថា បពិត្រលោកដ៏ចំរើន ហេតុអ្វី បានជាលោកម្ចាស់សំឡឹងមើលកូនគោនេះមិនដាក់ភ្នែកសោះ ។ ភិក្ខុនោះប្រាប់ថា នែអ្នកដ៏មានអាយុ ដ្បិតអាត្មាត្រូវការស្បែកកូនគោនេះ ។ ខណៈនោះ ឧបាសកនោះក៏សម្លាប់កូនគោនោះ ហើយកន្ទុះយកស្បែកប្រគេនទៅភិក្ខុនោះ ។ គ្រានោះ ភិក្ខុខ្ចីនោះក៏យកស្បែកនោះគ្របដោយសង្ឃាដិ ហើយក៏ដើរទៅ ។

អថខោ សា គាវី វច្ឆគិទ្ធិនី តំ បាបភិក្ខុំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ ។ ភិក្ខូ បុច្ឆិំសុ កិស្ស តុយ្ហំ អាវុសោ អយំ គាវី បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធាតិ ។ អហំបិ ខោ អាវុសោ ន ជានាមិ កេន មាយំ គាវី បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធាតិ ។ តេន ខោ បន សមយេន តស្ស បាបភិក្ខុនោ សង្ឃាដិ លោហិតេន មក្ខិតា ហោតិ ។ ភិក្ខូ បុច្ឆិំសុ អយំ បន តេ អាវុសោ សង្ឃាដិ កឹ កតាតិ ។ អថខោ សោ បាបភិក្ខុ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ កឹ បន ត្វំ អាវុសោ បាណាតិបាតេ សមាទបេសីតិ ។ ឯវំ អាវុសោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ បាណាតិបាតេ សមាទបេស្សតិ ននុ ភគវតា អនេកបរិយាយេន បាណាតិបាតោ គរហិតោ បាណាតិបាតា វេរមណី បសត្ថាតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

[៦៦] អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា តំ បាបភិក្ខុំ បដិបុច្ឆិ





វេលានោះ មេគោនោះគាល័យកូនក៏ដើរតាមពីខាងក្រោយ ៗ ភិក្ខុបាបនោះ ។ ភិក្ខុទាំងឡាយក៏បាននិយាយយ៉ាងនេះថា អាវុសោ ហេតុអ្វីបានជាមេគោនេះដើរតាមពីខាងក្រោយ ៗ លោក ។ ភិក្ខុនោះប្រាប់ថា អាវុសោ ខ្ញុំមិនដឹងជាមេគោនេះមកតាមខ្ញុំពីខាងក្រោយ ៗ ដោយហេតុអ្វីទេ ។ វេលានោះឯង សង្ឃាដិរបស់ភិក្ខុបាបនោះក៏ប្រឡាក់ទៅដោយឈាម ។ ភិក្ខុទាំងឡាយបាននិយាយយ៉ាងនេះថា អាវុសោ សង្ឃាដិនេះតើអ្នកធ្វើដូចម្ដេច (បានជាប្រឡាក់) ។ ខណៈនោះ ភិក្ខុបាបនោះបានប្រាប់សេចក្ដីនុះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក៏បានសួរថា អាវុសោ លោកបានបបួលគេឲ្យបាណាតិបាតមែនឬ ។ ភិក្ខុនោះឆ្លើយថា អើ អាវុសោ ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនសមបើនឹងបបួលគេឲ្យធ្វើបាណាតិបាតសោះ ព្រោះបាណាតិបាត ព្រះដ៏មានព្រះភាគទ្រង់តិះដៀលដោយអនេកបរិយាយ ព្រះអង្គទ្រង់សរសើរតែការវៀរចាកអំពីបាណាតិបាតដូច្នោះឬ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលសេចក្ដីនុះចំពោះព្រះដ៏មានព្រះភាគ ។

[៦៦] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃក្នុងវេលានោះហើយ ទ្រង់សួរចំពោះភិក្ខុបាបនោះថា

សច្ចំ កិរ ត្វំ ភិក្ខុ បាណាតិបាតេ សមាទបេសីតិ ។
សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម
ត្វំ មោឃបុរិស បាណាតិបាតេ សមាទបេស្សសិ ននុ
មយា មោឃបុរិស អនេកបរិយាយេន បាណាតិបាតោ
គរហិតោ បាណាតិបាតា វេរមណី បសត្ថា នេតំ មោ-
ឃបុរិស អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិ-
ត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ បា-
ណាតិបាតេ សមាទបេតព្វំ យោ សមាទបេយ្យ យថា-
ធម្មោ ការេតព្វោ ។ ន ច ភិក្ខវេ គោចម្មំ ធារេតព្វំ
យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។ ន ភិក្ខវេ កិញ្ចិ
ចម្មំ ធារេតព្វំ យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។
តេន ខោ បន សមយេន មនុស្សានំ មញ្ចបិ បីឋបិ
ចម្មោនទ្ធានិ ហោន្តិ ចម្មវិនទ្ធានិ ។ ភិក្ខូ កុក្កុច្ចា-
យន្តា នាភិនិសីទន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។
អនុជានាមិ ភិក្ខវេ គិហិវិកតំ អភិនិសីទិតុំ ន ត្វេ



ម្នាលភិក្ខុ ឮថាអ្នកឯងនាំបបួលគេឲ្យធ្វើបាណាតិបាត ពិតមែនឬ ។ ភិ
ក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុ
ទ្ធមានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនសមនឹងបបួល
គេឲ្យធ្វើបាណាតិបាតសោះ ម្នាលមោឃបុរស ព្រោះតថាគតតិះដៀលបាណាតិបាតតថាគ
តបានតិះដៀលហើយដោយអនេកបរិយាយ តថាគតសរសើរនូវការវៀរចា
កបាណាតិបាតផងទេឬ ម្នាលមោឃបុរស អំពើនេះមិនបាននាំឲ្យជ្រះ
ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើងទេ ។បេ។ លុះទ្រង់បន្ទោសរួ
ហើយទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកបញ្ញត្តថា ម្នា
ភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបបួលគេឲ្យធ្វើបាណាតិបាតទេ ភិក្ខុណាបបួ
ត្រូវឲ្យធ្វើតាមធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុ
ត្រូវប្រើប្រាស់ស្បែកគោទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ម្នា
ភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ស្បែកសត្វណាមួយទេ ភិក្ខុណា
ប្រើប្រាស់ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង មានគ្រែនិងតាំងដែល
មនុស្សបាំងហើយដោយស្បែក ចងរឹតដោយស្បែក ។ ភិក្ខុទាំងឡា
រង្កៀសមិនហ៊ានអង្គុយលើ ។ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រ
មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថា
អនុញ្ញាតឲ្យភិក្ខុអង្គុយលើទីសេនាសនៈដែលជាគិហិវិកត (របស់

អភិនិបជ្ជិតុន្តិ ។ តេន ខោ បន សមយេន វិហារា ចម្មវទ្ធេហិ ឱគុម្ផិយន្តិ ។ ភិក្ខូ កុក្កុច្ចាយន្តា នាភិនិសីទន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ពន្ធនមត្តំ អភិនិសីទិតុន្តិ ។

[៦៧] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សឧបាហនា គាមំ បវិសន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ សឧបាហនេន គាមោ បវិសិតព្វោ យោ បវិសេយ្យ អាបត្តិ ទុក្កដស្ស ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ន សក្កោតិ វិនា ឧបាហនេន គាមំ បវិសិតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា សឧបាហនេន គាមំ បវិសិតុន្តិ ។



(គ្រោងស្បែកផ្សេងៗ) ហាម ភិក្ខុទាំងឡាយ ។ សម័យនោះឯង មានវិហារ(១) ដែលគេចងភ្ជាប់ដោយខ្សែស្បែកទាំងឡាយ ។ ភិក្ខុទាំងឡាយ រង្កៀសមិនហ៊ានអង្គុយលើ ។ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអង្គុយលើវិហារដែលគេគ្រាន់តែចងប៉ុណ្ណោះ ។

[៦៧] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុពាក់ស្បែកជើងហើយ ចូលទៅកាន់ស្រុក ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថដែលបរិភោគនូវកាមគុណ ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើងចូលទៅកាន់ស្រុកទេ ភិក្ខុណា(ពាក់)ចូលទៅ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង មានភិក្ខុ១រូប មានជម្ងឺ តែវៀរចាកស្បែកជើងក៏មិនអាចនឹងដើរចូលទៅកាន់ស្រុកបានឡើយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានជម្ងឺពាក់ស្បែកជើងចូលទៅកាន់ស្រុកបាន ។

---

១ សំដៅយកទីនៅ ទួចក្តីដំណេកសាលាជាដើម ។

[៦៨] តេន ខោ បន សមយេន អាយស្មា មហាកច្ចានោ អវន្តីសុ វិហរតិ កុររឃរេ បបតកេ[១] បព្វតេ ។ តេន ខោ បន សមយេន សោណោ ឧបាសកោ កុដិកណ្ណោ អាយស្មតោ មហាកច្ចានស្ស ឧបដ្ឋាកោ ហោតិ ។ អថ ខោ សោណោ ឧបាសកោ កុដិកណ្ណោ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោណោ ឧបាសកោ កុដិកណ្ណោ អាយស្មន្តំ មហាកច្ចានំ ឯតទវោច យថា យថាហំ ភន្តេ អយ្យេន មហាកច្ចានេន ធម្មំ ទេសិតំ អាជានាមិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ ឥច្ឆាមហំ ភន្តេ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតុំ បព្វាជេតុ មំ ភន្តេ អយ្យោ មហាកច្ចានោតិ ។ ឯវំ វុត្តេ

១ [illegible] ។





[៦៨] សម័យនោះឯង ព្រះមហាកច្ចានៈដ៏មានអាយុ គង់នៅលើភ្នំឈ្មោះបបាតៈ ទៀបក្រុងឈ្មោះកុររឃរៈ ក្នុងដែនអវន្តី ។ សម័យនោះឯង ឧបាសកឈ្មោះសោណកុដិកណ្ណ[១] ជាឧបដ្ឋាករបស់ព្រះមហាកច្ចានៈដ៏មានអាយុ ។ គ្រានោះ ឧបាសកឈ្មោះសោណកុដិកណ្ណ ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ ហើយក៏ថ្វាយបង្គំព្រះមហាកច្ចានៈដ៏មានអាយុ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះឧបាសកឈ្មោះសោណកុដិកណ្ណអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏បាននិយាយពាក្យនេះនឹងព្រះមហាកច្ចានៈដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ធម៌ដែលលោកម្ចាស់មហាកច្ចានៈបានសំដែងហើយ យ៉ាងណា ៗ ខ្ញុំករុណាក៏ដឹងច្បាស់ តែបុគ្គលដែលនៅគ្រប់គ្រងផ្ទះមិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះឲ្យបរិបូណ៌ពេញលេញឲ្យស្អាតស្មើនឹងស័ង្ខដែលបុគ្គលដុសខាត់ហើយ បពិត្រលោកដ៏ចំរើន ដូច្នេះខ្ញុំករុណាចង់កោរសក់នឹងពុកមាត់ ហើយស្លៀកដណ្តប់សំពត់កាសាយ ចាំងល្បាយ ហើយចេញចាកផ្ទះ ទៅបួសក្នុងភេទរបស់បុគ្គលគ្មានផ្ទះ បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់មហាកច្ចានៈ បំបួសខ្ញុំផង ។ កាលបើឧបាសកនោះនិយាយយ៉ាងនេះហើយ ព្រះមហាកច្ចានៈដ៏មានអាយុក៏បាន

១ ឧបាសកឈ្មោះសោណៈតែងពាក់គ្រឿងប្រដាប់ត្រចៀកមានដំឡៃមួយកោដិ ព.ដ.ទេ បរមត្ថ កង្ខាវ ទំព័រ៩៩ (អដ្ឋកថា) ។

អាយស្មា មហាកច្ចានោ សោណំ ឧបាសកំ កុដិ-កណ្ណំ ឯតទវោច ទុក្ករំ ខោ សោណ យាវជីវំ ឯក-សេយ្យំ ឯកភត្តំ ព្រហ្មចរិយំ ចរិតុំ ឥង្ឃ ត្វំ សោណ តត្ថេវ អគារិកភូតោ ពុទ្ធានំ សាសនំ អនុយុញ្ជ កាលយុត្តំ ឯកសេយ្យំ ឯកភត្តំ ព្រហ្មចរិយន្តិ ។ អថខោ សោណស្ស ឧបាសកស្ស កុដិកណ្ណស្ស យោ អហោសិ បព្វជ្ជាភិសង្ខារោ សោ បដិប្បស្សម្ភិ ។ ទុតិ-យម្បិ ខោ សោណោ ឧបាសកោ កុដិកណ្ណោ ។បេ។ តតិយម្បិ ខោ សោណោ ឧបាសកោ កុដិកណ្ណោ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ ឧបសង្ក-មិត្វា អាយស្មន្តំ មហាកច្ចានំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោណោ ឧបាស-កោ កុដិកណ្ណោ អាយស្មន្តំ មហាកច្ចានំ ឯតទវោច យថា យថាហំ ភន្តេ អយ្យេន មហាកច្ចានេន ធម្មំ ទេសិតំ អាជានាមិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ



និយាយពាក្យនេះនឹងសោណកុដិកណ្ណឧបាសកថា ម្នាលសោណៈ ការប្រព្រឹត្តនូវការដេកតែម្នាក់ឯង ចាំរក្សាភត្តតែមួយពេល ដើម្បីប្រព្រឹត្តព្រហ្មចរិយធម៌ ដរាបអស់មួយជីវិត មិនងាយនឹងធ្វើបានឡើយ ម្នាលសោណៈ ណ្ហើយចុះ អ្នកឯងនៅតែនៅជាគ្រហស្ថប្រកបតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺការដេកតែម្នាក់ឯង ការចាំរក្សាភត្តតែមួយនិងការប្រព្រឹត្តព្រហ្មចរិយធម៌ សមគួរតាមកាល គឺនៅជាគ្រហស្ថនោះចុះ ។ ការប្រុងប្រៀបនឹងបួសរបស់សោណកុដិកណ្ណឧបាសកនោះក៏បានរម្ងាប់ស្ងប់ស្ងាត់ទៅក្នុងវេលានោះឯង ។ សោណកុដិកណ្ណឧបាសក បានចូលទៅរកព្រះមហាកច្ចានៈជាគំរប់ពីរដងផង ។បេ។ សោណកុដិកណ្ណឧបាសក បានចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុជាគំរប់បីដងផង លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមហាកច្ចានៈដ៏មានអាយុ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះសោណកុដិកណ្ណឧបាសក អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏បានទូលនិយាយពាក្យនេះនឹងព្រះមហាកច្ចានៈដ៏មានអាយុថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលលោកម្ចាស់មហាកច្ចានៈបានសំដែងហើយយ៉ាងណា ៗ ខ្ញុំករុណាក៏ដឹងច្បាស់ (តែថា) បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តនូវព្រហ្មចរិយធម៌នេះ ឲ្យបានពេញលេញអស់ជើង ឲ្យបានស្អាតអស់ជើង

ចរិតុំ ឥច្ឆាមហំ ភន្តេ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតុំ បព្វាជេតុ មំ ភន្តេ អយ្យោ មហាកច្ចានោតិ ។ អថខោ អាយស្មា មហាកច្ចានោ សោណំ ឧបាសកំ កុដិកណ្ណំ បព្វាជេសិ ។ តេន ខោ បន សមយេន អវន្តិទក្ខិណាបថោ អប្បភិក្ខុកោ ហោតិ ។ អថខោ អាយស្មា មហាកច្ចានោ តិណ្ណំ វស្សានំ អច្ចយេន កិច្ឆេន កសិរេន តតោ តតោ ទសវគ្គំ ភិក្ខុសង្ឃំ សន្និបាតេត្វា អាយស្មន្តំ សោណំ ឧបសម្បាទេសិ ។ អថខោ អាយស្មតោ សោណស្ស វស្សំវុដ្ឋស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ សុតោយេវ ខោ មេ សោ ភគវា ឯទិសោ ច ឯទិសោ ចាតិ ន ច មយា សម្មុខា ទិដ្ឋោ គច្ឆេយ្យាហំ តំ ភគវន្តំ ទស្សនាយ អរហន្តំ សម្មាសម្ពុទ្ធំ សចេ មំ ឧបជ្ឈាយោ អនុជានេយ្យាតិ ។ អថខោ អាយស្មា សោណោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា មហាកច្ចានោ តេនុបសង្ក-



ដូចស័ង្ខដែលគេដុសខាត់ហើយទេ ។ បពិត្រព្រះលោកដ៏ចំរើន ឥឡូវខ្ញុំព្រះករុណាចង់កោរសក់និងពុកមាត់ហើយស្លៀកដណ្តប់សំពត់កាសាយចេញចាកផ្ទះទៅបួសក្នុងភេទរបស់បុគ្គលគ្មានផ្ទះ បពិត្រព្រះលោកដ៏ចំរើន សូមលោកម្ចាស់មហាកច្ចានៈបំបួសខ្ញុំផង ។ ព្រះមហាកច្ចានៈដ៏មានអាយុក៏បំបួសសោណកុដិកណ្ណឧបាសកក្នុងវេលានោះឯង ។ សម័យនោះឯង អវន្តិទក្ខិណាបថជនបទមានភិក្ខុតិចណាស់ ។ វេលានោះ ព្រះមហាកច្ចានៈដ៏មានអាយុឲ្យប្រជុំភិក្ខុសង្ឃមានពួក ១០ ដែលមកពីទិសនោះៗ ហើយឲ្យឧបសម្បទាសោណៈដ៏មានអាយុ ដោយក្រលំបាកពេកណាស់ លុះកន្លងនូវ ៣ ឆ្នាំទៅ (ទើបរកគណៈសង្ឃបានគ្រប់ ថ្វី ) ។ លំដាប់នោះ កាលសោណៈដ៏មានអាយុនៅចាំវស្សារួចហើយ នៅក្នុងទីស្ងាត់លាក់ខ្លួនសម្ងំក៏កើតការត្រិះរិះ ក្នុងចិត្តយ៉ាងនេះថា អាត្មាអញគ្រាន់តែបានឮថា ព្រះមានព្រះភាគនោះដែលបែបយ៉ាងនេះៗ តែអាត្មាអញមិនដែលឃើញព្រះមានព្រះភាគចំពោះមុខសោះ ។ បើឧបជ្ឈាយ៍អនុញ្ញាត ឲ្យអាត្មាអញទៅ អាត្មាអញគួរតែទៅឲ្យបានឃើញព្រះមានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធនោះ ។ គ្រានោះ ព្រះសោណៈដ៏មានអាយុ លុះវេលាថ្ងៃរសៀល ក៏ចេញអំពីទីលាក់ខ្លួនសម្ងំហើយ ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូល

មិត្តា អាយស្មន្តំ មហាកច្ចានំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សោណោ អាយស្មន្តំ មហាកច្ចានំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ សុតោយេវ ខោ មេ សោ ភគវា ឯទិសោ ច ឯទិសោ ចាតិ ន ច មយា សម្មុខា ទិដ្ឋោ គច្ឆេយ្យាហំ តំ ភគវន្តំ ទស្សនាយ អរហន្តំ សម្មាសម្ពុទ្ធំ សចេ មំ ឧបជ្ឈាយោ អនុជានេយ្យាតិ គច្ឆេយ្យាហំ ភន្តេ តំ ភគវន្តំ ទស្សនាយ អរហន្តំ សម្មាសម្ពុទ្ធំ សចេ មំ ឧបជ្ឈាយោ អនុជានាតីតិ ។ សាធុ សាធុ សោណ គច្ឆ ត្វំ សោណ តំ ភគវន្តំ ទស្សនាយ អរហន្តំ សម្មាសម្ពុទ្ធំ ទក្ខិស្សសិ ត្វំ សោណ តំ ភគវន្តំ បាសាទិកំ បសាទនីយំ សន្តិន្ទ្រិយំ សន្តមានសំ ឧត្តមទមថសមថមនុប្បត្តំ ទន្តំ គុត្តំ យតិន្ទ្រិយំ នាគំ តេនហិ ត្វំ សោណ មម វចនេន ភគវតោ បាទេ





ទៅដល់ហើយក៏ថ្វាយបង្គំព្រះមហាកច្ចានៈដ៏មានអាយុ រួចក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ លុះព្រះសោណៈដ៏មានអាយុអង្គុយនៅក្នុងទីដ៏សមគួរហើយបាននិយាយពាក្យនេះនឹងព្រះមហាកច្ចានៈដ៏មានអាយុថា បពិត្រលោកដ៏ចំរើន កាលខ្ញុំករុណានៅក្នុងទីស្ងាត់ ឈាក់ខ្លួនពួនសម្ងំក្នុងទីនេះ ក៏កើតការត្រិះរិះ ក្នុងចិត្តយ៉ាងនេះថា ខ្ញុំអញគ្រាន់តែបានឮថា ព្រះមានព្រះភាគមានភាពយ៉ាងនេះៗ តែខ្ញុំអញ មិនដែលឃើញព្រះមានព្រះភាគ ក្នុងទីចំពោះមុខបានឡើយសោះ បើឧបជ្ឈាយ៍អនុញ្ញាតឲ្យខ្ញុំអញទៅ ខ្ញុំគប្បីទៅ ឲ្យបានឃើញព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធនោះ បពិត្រលោកដ៏ចំរើន បើឧបជ្ឈាយ៍អនុញ្ញាតឲ្យខ្ញុំករុណាទៅ ខ្ញុំករុណាគួរនឹងទៅ ឲ្យបានឃើញព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធនោះ ។ ព្រះមហាកច្ចានៈក៏និយាយតបវិញថា នែសោណៈ ប្រពៃណាស់ហើយ នែសោណៈ លោកចូរទៅគាល់ព្រះមានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធនោះចុះ នែសោណៈ លោកមុខជា នឹងបានឃើញព្រះមានព្រះភាគនោះជាទីតាំងឲ្យកើតសេចក្តីជ្រះថ្លាគួរឲ្យជ្រះថ្លា មានឥន្ទ្រិយស្ងប់ហើយ មានព្រះទ័យស្ងប់ហើយ បានដល់នូវបញ្ញាសម្រាប់ទូន្មាន នឹងសមាធិសម្រាប់ស្ងប់ដ៏ឧត្តម បានទូន្មានព្រះអង្គហើយ បានរក្សាព្រះអង្គហើយ បានឈ្នះឥន្ទ្រិយហើយ បានព្រួសចាកកិលេសហើយ នែសោណៈ បើ

សិរសា វន្ទុ ឧបជ្ឈាយោ មេ ភន្តេ អាយស្មា មហាកច្ចានោ ភគវតោ បាទេ សិរសា វន្ទតិ ឯវញ្ច វទេតិ អវន្តិទក្ខិណាបថោ ភន្តេ អប្បភិក្ខុកោ តិណ្ណំ មេ វស្សានំ អច្ចយេន កិច្ឆេន កសិរេន តតោ តតោ ទសវគ្គំ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ឧបសម្បទំ អលត្ថំ អប្បេវនាម ភគវា អវន្តិទក្ខិណាបថេ អប្បតរេន គណេន ឧបសម្បទំ អនុជានេយ្យ អវន្តិទក្ខិណាបថេ ភន្តេ កណ្ហុត្តរា ភូមិ ខរា គោកណ្ដកហតា អប្បេវនាម ភគវា អវន្តិទក្ខិណាបថេ គណង្គណូបាហនំ អនុជានេយ្យ អវន្តិទក្ខិណាបថេ ភន្តេ នហានគរុកា មនុស្សា ឧទកសុទ្ធិកា អប្បេវនាម ភគវា អវន្តិទក្ខិណាបថេ ធុវនហានំ អនុជានេយ្យ អវន្តិទក្ខិណាបថេ ភន្តេ ចម្មានិ អត្ថរណានិ ឯឡកចម្មំ អជចម្មំ មិគចម្មំ សេយ្យថាបិ ភន្តេ មជ្ឈិមេសុ ជនបទេសុ



ដូច្នេះ លោកថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះដ៏មានព្រះភាគដោយសិរសាតាមពាក្យថា បពិត្រព្រះអង្គដ៏ចំរើន ឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គ ឈ្មោះមហាកច្ចានៈដ៏មានអាយុ សូមក្រាបថ្វាយបង្គំចំពោះព្រះបាទទាំងគូរបស់ព្រះដ៏មានព្រះភាគដោយសិរសា ផង ហើយឲ្យលោកក្រាបទូលយ៉ាងនេះ(ទៀត)ថា បពិត្រព្រះអង្គដ៏ចំរើន ដែនអវន្តិទក្ខិណាបថមានភិក្ខុតិចណាស់ ខ្ញុំព្រះអង្គប្រជុំភិក្ខុសង្ឃមានពួក ១០ អំពីប្រទេសនោះ ៗ ហើយបានឧបសម្បទាដោយលំបាកក្រៃពេកណាស់ លុះកន្លង ៣ ឆ្នាំទៅហើយ (បើស្រេច)ធ្វើម្ដេចហ្ន៎ ព្រះដ៏មានព្រះភាគគួរទ្រង់អនុញ្ញាតឲ្យឧបសម្បទាក្នុងដែនអវន្តិទក្ខិណាបថដោយគណៈសង្ឃឲ្យតិចល្មមទៅ បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនអវន្តិទក្ខិណាបថមានដែនដីខ្មៅស្អិតគ្រោតគ្រាតរឹងរើប រុបដោយស្នាមជើងគោ ធ្វើម្ដេចហ្ន៎ ព្រះដ៏មានព្រះភាគគួរទ្រង់អនុញ្ញាតស្បែកជើង ៤ ជាន់ឡើងទៅ ក្នុងដែនអវន្តិទក្ខិណាបថ បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនអវន្តិទក្ខិណាបថ ពួកមនុស្សកាន់ការងូតទឹកណាស់ ប្រកបដោយសេចក្ដីស្អាតព្រោះទឹក ធ្វើម្ដេចហ្ន៎ ព្រះដ៏មានព្រះភាគគួរទ្រង់អនុញ្ញាតការងូតទឹកឲ្យបានជានិច្ចក្នុងដែនអវន្តិទក្ខិណាបថ បពិត្រព្រះអង្គដ៏ចំរើន ដែនអវន្តិទក្ខិណាបថមានគម្រាលស្បែកច្រើន គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ បពិត្រព្រះអង្គដ៏ចំរើន ក្នុងមជ្ឈិមជនបទ

ឯរគុ មោរគុ មជ្ជារុ ជន្តុ ឯវមេវ ខោ ភន្តេ អវន្តិទក្ខិណាបថេ ចម្មានិ អត្ថរណានិ ឯឡកចម្មំ អជចម្មំ មិគចម្មំ អប្បេវនាម ភគវា អវន្តិទក្ខិណាបថេ ចម្មានិ អត្ថរណានិ អនុជានេយ្យ ឯឡកចម្មំ អជចម្មំ មិគចម្មំ ឯតរហិ ភន្តេ មនុស្សា និស្សីមគតានំ ភិក្ខូនំ ចីវរំ ទេន្តិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទេមាតិ តេ អាគន្ត្វា អារោចេន្តិ ឥត្ថន្នាមេហិ តេ អាវុសោ មនុស្សេហិ ចីវរំ ទិន្នន្តិ តេ កុក្កុច្ចាយន្តា ន សាទិយន្តិ មា នោ និស្សគ្គិយំ អហោសីតិ អប្បេវនាម ភគវា ចីវរេ បរិយាយំ អាចិក្ខេយ្យាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា សោណោ អាយស្មតោ មហាកច្ចានស្ស បដិស្សុណិត្វា ឧដ្ឋាយាសនា អាយស្មន្តំ មហាកច្ចានំ



មានស្មៅឈ្មោះឯរគុ(១) ស្មៅឈ្មោះមោរគុ(២) ស្មៅឈ្មោះមជ្ជារុ(៣) ស្មៅឈ្មោះជន្តុ(៤)យ៉ាងណាមិញ បពិត្រព្រះសម្ពុទ្ធដ៏ចំរើន ក្នុងដែនអវន្តិទក្ខិណាបថក៏មានសំពត់ស្បែក គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគដូច្នោះដែរ ធ្វើម្តេចហ្ន៎ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតសំពត់ស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ ក្នុងដែនអវន្តិទក្ខិណាបថ បពិត្រព្រះសម្ពុទ្ធដ៏ចំរើន សព្វថ្ងៃនេះ មនុស្សទាំងឡាយប្រគេនចីវរដល់ភិក្ខុដែលនៅក្រៅសីមាថា យើងប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះ ភិក្ខុទាំងនោះមកប្រាប់ថា នែអាវុសោ ពួកមនុស្សឈ្មោះនេះបានប្រគេនចីវរដល់លោកហើយ ភិក្ខុទាំងនោះក៏រង្កៀសមិនត្រេកអរព្រោះយល់ឃើញថាកុំឲ្យត្រូវនិស្សគ្គិយដល់យើងឡើយ ធ្វើម្តេចហ្ន៎ ព្រះដ៏មានព្រះភាគទ្រង់ប្រាប់បរិយាយដល់ភិក្ខុក្នុងចីវរ ។ ឯព្រះសោណៈដ៏មានអាយុបានទទួលស្តាប់ពាក្យព្រះមហាកច្ចានៈដ៏មានអាយុដោយពាក្យថា ករុណាលោកម្ចាស់ រួចហើយក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះមហាកច្ចានៈដ៏មានអាយុ ធ្វើប្រទក្សិណ

១-២ ៣-៤ តាមអដ្ឋកថា ថា ស្មៅទាំង ៤ យ៉ាងនេះគេតែងយកមកធ្វើជាកន្ទេលវែងខ្លះ កន្ទេលទន់ខ្លះ ឯស្មៅឈ្មោះឯរគុមានសម្ផស្សរឹងគ្រោតគ្រាត ស្មៅឈ្មោះមោរគុនោះមានចុងក្រហម មានសាច់ល្អិតទន់ មានសម្ផស្សល្អស្រួល គេតែងយកមកធ្វើជាកន្ទេលទន់សម្រាប់ដេក បាលតែដេកសន្ធឹងនៅហើយ លុះក្រោកចេញក៏ហើងឡើងវិញ ឯស្មៅឈ្មោះមជ្ជារុនោះ គេយកមកធ្វើជាសំពត់សាដកក៏បាន ស្មៅឈ្មោះជន្តុនោះ មានពណ៌ដូចកែវមណិ ។

អភិវាទេត្វា បទក្ខិណំ កត្វា សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ យេន សាវត្ថី តេន បក្កាមិ អនុបុព្វេន យេន សាវត្ថី ជេតវនំ អនាថបិណ្ឌិកស្ស អារាមោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥមស្ស អានន្ទ អាគន្តុកស្ស ភិក្ខុនោ សេនាសនំ បញ្ញាបេហីតិ ។ អថខោ អាយស្មា អានន្ទោ យស្ស ខោ មំ ភគវា អាណាបេតិ ឥមស្ស អានន្ទ អាគន្តុកស្ស ភិក្ខុនោ សេនាសនំ បញ្ញាបេហីតិ ឥច្ឆតិ ភគវា តេន ភិក្ខុនា សទ្ធឹ ឯកវិហារេ វត្ថុំ ឥច្ឆតិ ភគវា អាយស្មតា សោណេន សទ្ធឹ ឯកវិហារេ វត្ថុន្តិ យស្មឹ វិហារេ ភគវា វិហរតិ តស្មឹ វិហារេ អាយស្មតោ សោណស្ស សេនាសនំ បញ្ញាបេសិ ។

(៦៨) អថខោ ភគវា ពហុទេវ រត្តឹ អជ្ឈោកាសេ វីតិនាមេត្វា វិហារំ បាវិសិ ។ អាយស្មាបិ ខោ សោណោ ពហុទេវ រត្តឹ អជ្ឈោកាសេ វីតិនាមេត្វា វិហារំ បាវិសិ ។ អថខោ ភគវា រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ



ហើយទុកដាក់ស្រួលនូវសេនាសនៈ រួចកាន់យកបាត្រនិងចីវរ ចេញដើរ ដោយលំដាប់ទៅក្រុងសាវត្ថី ក៏ចូលទៅរកព្រះមានព្រះភាគ ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់នៅក្នុងទីដ៏សមគួរ ។ វេលានោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅក្រាលសេនាសនៈឲ្យអាគន្តុកភិក្ខុនេះ (បន្តិច) ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុគិតថា ព្រះមានព្រះភាគទ្រង់ត្រាស់បង្គាប់អញថា ម្នាលអានន្ទ អ្នកឯងចូរក្រាលសេនាសនៈឲ្យអាគន្តុកភិក្ខុនេះ (បន្តិច) ចំពោះភិក្ខុណា ព្រះមានព្រះភាគទ្រង់ប្រាថ្នាដើម្បីគង់នៅក្នុងវិហារ ១ ជាមួយនឹងភិក្ខុនោះគឺថា ព្រះមានព្រះភាគប្រាថ្នាដើម្បីគង់នៅក្នុងវិហារ ១ ជាមួយនឹងព្រះសោណៈដ៏មានអាយុ លុះគិតដូច្នេះហើយ ក៏ក្រាលសេនាសនៈចំពោះព្រះសោណៈដ៏មានអាយុក្នុងវិហារដែលព្រះមានព្រះភាគគង់នៅ ។

(៦៨) គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងទីកណ្ដាលវាលអស់រាត្រីជាច្រើន ទើបយាងចូលទៅកាន់វិហារ ។ ចំណែកខាងព្រះសោណៈដ៏មានអាយុក៏នៅក្នុងទីកណ្ដាលវាលអស់រាត្រីជាច្រើន ទើបចូលទៅកាន់វិហារដែរ ។ វេលានោះ ព្រះមានព្រះភាគទ្រង់តើនក្រោកឡើង

អាយស្មន្តំ សោណំ អជ្ឈេសិ បដិភាតុ តំ ភិក្ខុ ធម្មោ ភាសិតុន្តិ ។ ឯវំ ភន្តេតិ ខោ អាយស្មា សោណោ ភគវតោ បដិស្សុណិត្វា សោឡស អដ្ឋកវគ្គិកានិ សរេន អភាសិ ។ អថខោ ភគវា អាយស្មតោ សោណស្ស សរភញ្ញបរិយោសានេ អព្ភនុមោទិ សាធុ សាធុ ភិក្ខុ សុគ្គហិតានិ ខោ តេ ភិក្ខុ អដ្ឋកវគ្គិកានិ សុមនសិក-តានិ សូបធារិតានិ កល្យាណិយាសិ វាចាយ សមន្នា-គតោ វិសដ្ឋាយ អនេលគលាយ អត្ថស្ស វិញ្ញាបនិយា កតិវស្សោសិ ត្វំ ភិក្ខូតិ ។ ឯកវស្សោ អហំ ភគវាតិ ។ កិស្ស បន ត្វំ ភិក្ខុ ឯវំ ចិរំ អកាសីតិ ។ ចិរំ ទិដ្ឋោ មេ ភន្តេ កាមេសុ អាទីនវោ អបិច សម្ពាធា ឃរាវាសា ពហុកិច្ចា ពហុករណីយាតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ





ក្នុងបច្ចូសសម័យនៃរាត្រី ទ្រង់ត្រាស់បង្គាប់ព្រះសោណៈដ៏មានអាយុថា ម្នាលភិក្ខុ អ្នកគួរនឹកសំដែងធម៌បន្តិចទៅ ។ ព្រះសោណៈដ៏មានអាយុបានទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏សំដែងនូវសូត្រទាំងឡាយ មាននៅក្នុងអដ្ឋកវគ្គទាំងអស់ដោយសរភញ្ញ ។ លុះចប់សរភញ្ញរបស់ព្រះសោណៈដ៏មានអាយុហើយ ព្រះមានព្រះភាគ ក៏បានអនុមោទនាក្នុងខណៈនោះថា ម្នាលភិក្ខុ ពីរោះហើយ ៗ ម្នាលភិក្ខុ សូត្រទាំងឡាយដែលមានក្នុងអដ្ឋកវគ្គអ្នកបានរៀនមកត្រឹមត្រូវហើយ អ្នកបានធ្វើទុកក្នុងចិត្តល្អហើយ បានពិចារណាល្អហើយ អ្នកប្រកបដោយសំដីដ៏ពីរោះក្បោះក្បាយ ច្បាស់ពារពាស គួរនឹងញ៉ាំងជនឲ្យបានដឹងច្បាស់នូវសេចក្តី ម្នាលភិក្ខុ អ្នកមានវស្សាប៉ុន្មានហើយ ។ ព្រះសោណៈក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទើបបានតែ ១ វស្សាទេ ។ ព្រះមានព្រះភាគទ្រង់សួរថា ម្នាលភិក្ខុ ហេតុអ្វី បានជាអ្នកធ្វើការឲ្យយឺតយូរយ៉ាងនេះ (ក្នុងបួសម៉្លេះ) ។ ព្រះសោណៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ឯទោសក្នុងកាមទាំងឡាយ ខ្ញុំព្រះអង្គបានឃើញមកជាយូរហើយ តែថាធម្មតាឃរាវាស មានសេចក្តីចង្អៀតចង្អល់ច្រើន មានកិច្ចច្រើន មានការងារច្រើន ។ វេលានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឡើងនូវឧទាននេះក្នុងវេលានោះថា

ទិស្វា អាទីនវំ លោកេ
ញត្វា ធម្មំ និរូបធឹ
អរិយោ ន រមតី បាបេ
បាបេ ន រមតី សុចីតិ(១) ។

(៧០) អថខោ អាយស្មា សោណោ បដិសម្មោទតិ ខោ មំ ភគវា អយំ ខ្វស្ស កាលោ យំ មេ ឧបជ្ឈាយោ បដិវេទេសីតិ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ភគវតោ បាទេសុ សិរសា និបតិត្វា ភគវន្តំ ឯតទវោច ឧបជ្ឈាយោ មេ ភន្តេ អាយស្មា មហាកច្ចានោ ភគវតោ បាទេសុ(២) សិរសា វន្ទតិ ឯវញ្ច វទេតិ(៣) អវន្តិទក្ខិណា-បថោ ភន្តេ អប្បភិក្ខុកោ តិណ្ណំ មេ វស្សានំ អច្ចយេន កិច្ឆេន កសិរេន តតោ តតោ ទសវគ្គំ ភិក្ខុសង្ឃំ សន្និបាតេត្វា ឧបសម្បទំ អលត្ថំ អប្បេវនាម ភគវា អវន្តិទក្ខិណាបថេ អប្បតរេន គណេន ឧបសម្បទំ

១ ម. សាសនេ រមតី សុចីតិ ។ ២ បាទេសុ សទ្ទោ ន ទិស្សតិ ។ ៣ ម. វទតិ ។



បុគ្គលបានឃើញទោសក្នុងលោកហើយ
ដឹងនូវធម៌ដែលប្រាសចាកឧបធិក្កិលេស
ជាព្រះអរិយៈ រមែងមិនត្រេកអរក្នុងបាប
ជាបុគ្គលស្អាត រមែងមិនត្រេកអរក្នុងបាប ។

(៧០) គ្រានោះ ព្រះសោណៈដ៏មានអាយុដឹងថា ព្រះមានព្រះភាគទ្រង់ស្មោះសរទំនាក់អាត្មាអញដោយពិត ព្រះឧបជ្ឈាយ៍របស់អាត្មាអញបានផ្ញើពាក្យបណ្តាំណា កាលនេះជាកាលគួរ នឹងក្រាបទូលតាមពាក្យបណ្តាំនោះ ទើបក្រោកចាកអាសនៈធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាងហើយក្រាបទៀបព្រះបាទទាំងគូរបស់ព្រះមានព្រះភាគដោយសិរសា ហើយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គឈ្មោះមហាកច្ចានៈដ៏មានអាយុ សូមឱនសិរសាក្រាបថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះដ៏មានព្រះភាគជាម្ចាស់ ម្យ៉ាងទៀតលោកផ្តាំខ្ញុំព្រះអង្គក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ដែនអវន្តីទក្ខិណាបថមានភិក្ខុតិច (ចាប់ដើមតាំងពីខ្ញុំព្រះអង្គបានបួសជាសាមណេរ) កន្លងទៅ ៣ ឆ្នាំហើយ ទំរាំប្រជុំភិក្ខុសង្ឃបាន ១០ រូបដែលមកពីទិសនោះ ៗ ហើយទើបបានឧបសម្បទាដោយលំបាកក្រៃពេកណាស់ ធ្វើម្តេចហ្ន៎ ព្រះដ៏មានព្រះភាគគួរទ្រង់អនុញ្ញាតនូវឧបសម្បទាក្នុងដែន

## បច្ចុប្បន្នេ សោណត្ថេរវត្ថុ

អនុជានេយ្យ អវន្តិទក្ខិណាបថេ ភន្តេ កណ្ហុត្តរា ភូមិ ខរា គោកណ្ដកហតា អប្បេវនាម ភគវា អវន្តិទក្ខិណាបថេ គុណង្គុណូបាហនំ អនុជានេយ្យ អវន្តិទក្ខិណាបថេ ភន្តេ នហានគរុកា មនុស្សា ឧទកសុទ្ធិកា អប្បេវនាម ភគវា អវន្តិទក្ខិណាបថេ ធុវនហានំ អនុជានេយ្យ អវន្តិទក្ខិណាបថេ ភន្តេ ចម្មានិ អត្ថរណានិ ឯឡកចម្មំ អជចម្មំ មិគចម្មំ សេយ្យថាបិ ភន្តេ មជ្ឈិមេសុ ជនបទេសុ ឯរគុ មោរគុ មជ្ជារុ ជន្តុ ឯវមេវ ខោ ភន្តេ អវន្តិទក្ខិណាបថេ ចម្មានិ អត្ថរណានិ ឯឡកចម្មំ អជចម្មំ មិគចម្មំ អប្បេវនាម ភគវា អវន្តិទក្ខិណាបថេ ចម្មានិ អត្ថរណានិ អនុជានេយ្យ ឯឡកចម្មំ អជចម្មំ មិគចម្មំ ឯតរហិ ភន្តេ មនុស្សា និស្សីមគតានំ ភិក្ខូនំ ចីវរំ ទេន្តិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទេមាតិ តេ អាគន្ត្វា



## បច្ចុប្បន្នៈ និទានព្រះសោណត្ថេរ

អវន្តិទក្ខិណាបថដោយគណៈសង្ឃតិចជាងមុន បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនអវន្តិទក្ខិណាបថមានផែនដីខ្មៅស្អិត គ្រោតគ្រាតរដិបរដុបដោយស្នាមជើងគោ ។ ធ្វើម្តេចហ្ន៎ ព្រះដ៏មានព្រះភាគគួរទ្រង់អនុញ្ញាតស្បែកជើង ៤ ជាន់ឡើងទៅ ក្នុងដែនអវន្តិទក្ខិណាបថ បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនអវន្តិទក្ខិណាបថ ពួកមនុស្សប្រកាន់ការងូតទឹកណាស់ ប្រកបដោយសេចក្តីស្អាតព្រោះទឹក ធ្វើម្តេចហ្ន៎ ព្រះដ៏មានព្រះភាគគួរទ្រង់អនុញ្ញាតការងូតទឹកឲ្យបានជានិច្ច ក្នុងដែនអវន្តិទក្ខិណាបថ បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនអវន្តិទក្ខិណាបថ មានគម្រាលស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ បពិត្រព្រះអង្គដ៏ចំរើន ក្នុងមជ្ឈិមជនបទមានស្មៅឈ្មោះឯរគុ ស្មៅឈ្មោះមោរគុ ស្មៅឈ្មោះមជ្ជារុ ស្មៅឈ្មោះជន្តុ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនអវន្តិទក្ខិណាបថមានគម្រាលគេធ្វើអំពីស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ ក៏ដូច្នោះដែរ ធ្វើម្តេចហ្ន៎ ព្រះដ៏មានព្រះភាគគួរទ្រង់អនុញ្ញាតគម្រាលទាំងឡាយដែលគេធ្វើអំពីស្បែក គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ ក្នុងដែនអវន្តិទក្ខិណាបថ បពិត្រព្រះអង្គដ៏ចំរើន ក្នុងកាលឥឡូវនេះ មនុស្សទាំងឡាយតែងប្រគេនចីវរដើម្បីពួកភិក្ខុដែលនៅក្រៅសីមាថា យើងនឹងប្រគេនចីវរនេះដើម្បីភិក្ខុឈ្មោះនេះ ភិក្ខុទាំងនោះមកហើយប្រាប់ថា

អារោចេន្តិ ឥត្ថន្នាមេហិ តេ អាវុសោ មនុស្សេហិ ចីវរំ ទិន្នន្តិ តេ កុក្កុច្ចាយន្តា ន សាទិយន្តិ មា នោ និស្ស-គ្គិយំ អហោសីតិ អប្បេវនាម ភគវា ចីវរេ បរិយាយំ អាចិក្ខេយ្យាតិ ។

(៧១) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អវន្តិ-ទក្ខិណាបថោ ភិក្ខវេ អប្បភិក្ខុកោ អនុជានាមិ ភិក្ខវេ សព្វបច្ចន្តិមេសុ ជនបទេសុ វិនយធរបញ្ចមេន គណេន ឧបសម្បទំ ។ តត្រិមេ បច្ចន្តិមា ជនបទា បុរត្ថិមាយ ទិសាយ គជង្គលំ នាម និគមោ តស្ស បរេន មហា-សាលា តតោ បរា បច្ចន្តិមា ជនបទា ឱរតោ មជ្ឈេ ។ បុរត្ថិមទក្ខិណាយ ទិសាយ សល្លវតី នាម នទី តតោ បរា បច្ចន្តិមា ជនបទា ឱរតោ មជ្ឈេ ។ ទក្ខិណាយ ទិសាយ សេតកណ្ណិកំ នាម និគមោ តតោ បរា បច្ចន្តិមា ជនបទា ឱរតោ មជ្ឈេ ។ បច្ឆិមាយ ទិសាយ ថូណំ នាម ព្រាហ្មណគ្គាមោ



នែអាវុសោ ពួកមនុស្សឈ្មោះនេះបានប្រគេនចីវរចំពោះលោក ភិក្ខុទាំង-នោះតែងរង្កៀសមិនត្រេកអរដោយគិតថា កុំឲ្យមាននិស្សគ្គិយដល់យើងឡើយ ធ្វើដូចម្តេចហ្ន៎ ព្រះដ៏មានព្រះភាគទ្រង់គួរប្រាប់បរិយាយប្រកបក្នុងចីវរ ។

(៧១) ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកត្រាស់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ ដែនអវន្តិទក្ខិណាបថមានភិក្ខុតិច ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តិមជនបទ[១]ទាំងអស់ តថាគតអនុញ្ញាតឲ្យឧប-សម្បទាដោយគណៈសង្ឃមានវិនយធរ[២]ជាគំរប់ប្រាំ បានខាងបណ្តាជនបទទាំងនោះ ជនបទទាំងឡាយនេះឯងជាបច្ចន្តិមជនបទគឺ ក្នុងទិសខាងកើតមាននិគមឈ្មោះគជង្គល ខាងនាយគជង្គលនិគមនោះ មាននិគមឈ្មោះមហាសាលា ខាងនាយនិគមឈ្មោះមហាសាលានោះ ហៅថាបច្ចន្តិមជន-បទ ខាងក្នុងចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសអាគ្នេយ៍មានស្ទឹងឈ្មោះសល្លវតី ខាងនាយស្ទឹងសល្លវតីនោះ ហៅថាបច្ចន្តិមជនបទ ខាងក្នុងចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងត្បូង មាននិគមឈ្មោះសេតកណ្ណិក ខាងនាយសេតកណ្ណិកនិគមនោះ ហៅថាបច្ចន្តិមជនបទ ខាងក្នុងចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងលិចមានស្រុកព្រាហ្មណ៍ឈ្មោះថូនព្រាម

១ សំដៅដល់ប្រទេសឆ្ងាយក្រៅពីមជ្ឈិមប្រទេស ។ ២ សំដៅយក[illegible] ។

តតោ បរា បច្ចន្តិមា ជនបទា ឱរតោ មជ្ឈេ ។ ឧត្តរាយ ទិសាយ ឧសីរទ្ធជោ នាម បព្វតោ តតោ បរា បច្ចន្តិមា ជនបទា ឱរតោ មជ្ឈេ ។ អនុជានាមិ ភិក្ខវេ សព្វបច្ចន្តិមេសុ ជនបទេសុ វិនយធរបញ្ចមេន គណេន ឧបសម្បទំ ។ អវន្តិទក្ខិណាបថេ ភិក្ខវេ កណ្ហុត្តរា ភូមិ ខរា គោកណ្ដកហតា អនុជានាមិ ភិក្ខវេ សព្វបច្ចន្តិមេសុ ជនបទេសុ គុណង្គុណូបាហនំ ។ អវន្តិទក្ខិណាបថេ ភិក្ខវេ ន្ហានគរុកា មនុស្សា ឧទកសុទ្ធិកា អនុជានាមិ ភិក្ខវេ សព្វបច្ចន្តិមេសុ ជនបទេសុ ធុវន្ហានំ ។ អវន្តិទក្ខិណាបថេ ភិក្ខវេ ចម្មានិ អត្ថរណានិ ឯឡកចម្មំ អជចម្មំ មិគចម្មំ សេយ្យថាបិ ភិក្ខវេ មជ្ឈិមេសុ ជនបទេសុ ឯរគុ មោរគុ មជ្ជារុ ជន្តុ ឯវមេវ ខោ ភិក្ខវេ អវន្តិទក្ខិណាបថេ ចម្មានិ អត្ថរណានិ ឯឡកចម្មំ អជចម្មំ មិគចម្មំ



ខាងនាយស្រុកថូនព្រាហ្មណ៍នោះ ហៅថាបច្ចន្តិមជនបទ ខាងអាយចូលជាមជ្ឈិមជនបទ ។ ទិសខាងជើង មានភ្នំឈ្មោះឧសីរធជ ខាងនាយភ្នំនោះ ហៅថាបច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តិមជនបទទាំងឡាយបែបនេះ តថាគតអនុញ្ញាតឲ្យឧបសម្បទាដោយគណៈសង្ឃមានវិនយធរជាគំរប់ ៥ បាន ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដែនអវន្តិទក្ខិណាបថមានផែនដីខ្មៅស្អិតរឹងគ្រោតគ្រាតរើបរដុបដោយស្នាមជើងគោ ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តិមជនបទទាំងអស់ តថាគតអនុញ្ញាតស្បែកជើង ៤ ជាន់ឡើងទៅ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដែនអវន្តិទក្ខិណាបថ ពួកមនុស្សច្រើនកាន់ការងូតទឹកប្រកបដោយសេចក្ដីស្អាតព្រោះទឹក ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តិមជនបទទាំងអស់ តថាគតអនុញ្ញាតឲ្យការងូតទឹកបានជានិច្ច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដែនអវន្តិទក្ខិណាបថ មានកម្រាលស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ ម្នាលភិក្ខុទាំងឡាយ ក្នុងមជ្ឈិមជនបទទាំងឡាយ មានស្មៅឈ្មោះឯរគុ ស្មៅឈ្មោះមោរគុ ស្មៅឈ្មោះមជ្ជារុ ស្មៅឈ្មោះជន្តុ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ក្នុងដែនអវន្តិទក្ខិណាបថមានកម្រាលស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ

អនុជានាមិ ភិក្ខវេ សព្វប្បច្ចន្តិមេសុ ជនបទេសុ ចម្មានិ អត្ថរណានិ ឯឡកចម្មំ អជចម្មំ មិគចម្មំ ។ ឥធ បន ភិក្ខវេ មនុស្សា និស្សីមគតានំ ភិក្ខូនំ ចីវរំ ទេន្តិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទេមាតិ អនុជានាមិ ភិក្ខវេ សាទិតុំ ន តាវ តំ គណនូបគំ(១) យាវ ន ហត្ថំ គច្ឆតីតិ ។

ចម្មក្ខន្ធកំ បញ្ចមំ ។

ឥមម្ហិ ខន្ធកេ វត្ថូ តេសដ្ឋី ។

តស្សុទ្ទានំ

[៧៦] រាជា ច មាគធោ សោណោ
អសីតិសហស្សិស្សរោ
សាគតោ គិជ្ឈកូដស្មឹ
ពហុំ ទស្សេសិ ឧត្តរឹ ។

១ ឱ. គណនូបគំ ។



ក៏យកចីវរនោះថ្វាយ ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តិមជនបទទាំងអស់ តថាគតអនុញ្ញាតនូវស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានពួកមនុស្សប្រគេនចីវរដល់ភិក្ខុទាំងឡាយដែលនៅក្រៅសីមាថា យើងប្រគេនចីវរនេះចំពោះភិក្ខុឈ្មោះនេះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរចុះ ចីវរមិនទាន់មកដល់ដៃដរាបណា ចីវរនោះភិក្ខុមិនត្រូវរាប់ការគណនាចីវរ(១)ដរាបនោះ ។

ចប់ ចម្មក្ខន្ធកៈ ទី ៥ ។

ក្នុងខន្ធកៈនេះ មានវត្ថុ ៦៣ ។

ឧទ្ទាននៃចម្មក្ខន្ធកៈនោះ គឺ

[៧៦] រឿងព្រះបាទមាគធៈជាធំលើស្រុក ៨ ហ៊ឺន ១ រឿងសោណសេដ្ឋីបុត្រ ១ រឿងសាគតភិក្ខុ សំដែងឥទ្ធិបាដិហារ្យជាឧត្តរិមនុស្សធម៌ច្រើន លើភ្នំគិជ្ឈកូដ ១ ។

១ តាមធម្មតាក្នុងមជ្ឈិមទេស ភិក្ខុបានទទួលចីវរក្តី បានដឹងដំណឹងថាចីវរដែលគេនឹងប្រគេនក្តី ភិក្ខុត្រូវរាប់ថ្ងៃតាំងតែបានទទួលឬបានដឹងដំណឹងនោះ បើភិក្ខុមិនបានវិកប្បឬមិនបានអធិដ្ឋានឲ្យហួសកំណត់ ១០ ថ្ងៃទៅ ចីវរនោះជានិស្សគ្គិយ ឯបច្ចន្តិមជនបទ តាមព្រះពុទ្ធានុញ្ញាតនេះ ទើបចីវរមិនទាន់ដល់ដៃ ភិក្ខុមិនបាច់រាប់ថ្ងៃឡើយ ។

ឧព្វាទានុក្កដ្ឋិស្ស

ទីឃរំ ឯកាបលាសិកំ

ឥលោ បិតា សោមកិកា

អញ្ញេន្ទា កណ្ហមេរ៍ ៥ ។

មហាវគ្គ មហាជាមា

វត្តិកា ៥ បដិក្កិបំ

១ព្វកា ចូឡតាលី ៥

ក្ដលតិក្កមេណ្ឌជា ។





ឃើញសោណាគិកឬស្សាហ៍យប្រាប្រាញ្ញាយាមនៅត្រើតក
ញាតាក៏បែក ១ ឃើញព្រះដ៏មានព្រះភាគទ្រង់ចូលនាំឲ្យ
សោណាគិកជាកឡាយាមតាមខ្សែគំណ ១ ឃើញព្រះ
ដ៏មានព្រះភាគទ្រង់អនុញ្ញាតស្បែកជើងមួយជាន់ ១
ឃើញព្រះដ៏មានព្រះភាគទ្រង់ហាមស្បែកជើងពណ៌
ទៀត ពណ៌លឿង ពណ៌ក្រហម ពណ៌ហង្សបាទ
ពណ៌ខ្មៅ ។ ស្បែកជើងពណ៌ក្រហមក្រមៅ
(ដូចខ្នងក្អែប) និងពណ៌លឿងទុំ (ដូចផ្កាឈូក) ១
ឃើញទ្រង់ហាមខ្សែស្បែកជើងមានពណ៌ទៀតដែរ ១
ឃើញទ្រង់ហាមស្បែកជើងបិទកែងជើង ១ ឃើញទ្រង់
ហាមស្បែកជើងស្រោបជើងទាំងអស់ហួសកជើង ១
ឃើញទ្រង់ហាមស្បែកជើងដែលគេត្រងជាប់ព្រៀបម្ខាងខ្នង
ជើង១ ឃើញទ្រង់ហាមស្បែកជើងញាត់ដោយគរ១ ឃើញ
ទ្រង់ហាមស្បែកជើងមានពណ៌ដូចខ្ទង់ក្រុងដូច ស្លាបសត្វ
ទទា១ ឃើញទ្រង់ហាមស្បែកជើងមានខ្សែមានសណ្ឋាន
ដូចស្នែងកែះ១ ឃើញទ្រង់ហាមស្បែកជើងមានខ្សែមាន
សណ្ឋានដូចស្នែងពពែ១ ។ ឃើញទ្រង់ហាមស្បែក

វិច្ឆិកា មោរចិត្រា(១)
សីហព្យគ្ឃា ច ទីបិកា
អជិនុទ្ទា មជ្ជារី ច
កាឡលូកបរិក្ខដា ។
ផាលិតុបាហនា កិលា
ធោតខាណុខណ្ឌខា
តាលវេឡុតិណញ្ចេវ
មុញ្ជបព្វជហិន្តាលា ។
កមលកម្ពលសោវណ្ណា
រូបិកា មណិវេឡុរិយា(២)
ផលិកា កំសកាចា ច

១. មោរចិត្រា ច ។ ២. វេឡុរិយា ។



ជើងមានស្បែក មានសណ្ឋានដូចកន្ទុយសត្វខ្ទួយ ១ រឿងទ្រង់ហាមស្បែកជើងដែលដាក់ស្រែះដោយព្រួយកន្ទុយសត្វក្ងោក ១ រឿងទ្រង់ហាមស្បែកជើងវិចិត្រផ្សេង ៗ ១ រឿងទ្រង់ហាមស្បែកជើងដែលចំជាយដោយស្បែកសត្វសីហៈ សត្វខ្លាធំ សត្វខ្លាដំបង សត្វខ្លារខិន ១ ស្បែកកេ ស្បែកឆ្មា ស្បែក[illegible] ស្បែកទៀម ១ ។ រឿងទ្រង់អនុញ្ញាតស្បែកជើង ៤ ជាន់ឡើងទៅដល់ភិក្ខុមានផ្លាកជើងបែក ១ រឿងភិក្ខុមានដំបៅលេចទៅព្រោះជើង ១ រឿងភិក្ខុមិនលាងជើងហើយជាន់លើគ្រែតាំង ១ រឿងភិក្ខុជាន់លើផ្ទិតឈើ ១ រឿងឆព្វគ្គិយភិក្ខុពាក់ទ្រនាប់ជើងឈើក្តួសឡើងរុបរប ១ រឿងឆព្វគ្គិយភិក្ខុប្រើប្រាស់ទ្រនាប់ជើងស្លឹកត្នោត ១ រឿងឆព្វគ្គិយភិក្ខុប្រើប្រាស់ទ្រនាប់ជើងស្លឹកឫស្សី ១ រឿងឆព្វគ្គិយភិក្ខុប្រើទ្រនាប់ជើងស្មៅ ១ ... ស្មៅបាបុស ១ ... ស្មៅដំណាកកន្ទ្រាយ ១ ... ពន្លៃ ១ ។ ... ស្មៅមានខពណ៌ដូចផ្កាឈូក ១ ... សំពត់កម្ពល ១ មាស ១ ប្រាក់ ១ កែវមណី ១ កែវពិទូរ្យ ១ កែវផលិក ១ សំរិទ្ធ ១ កែវកញ្ចក់ ១

តិបុសីសញ្ញ សុត្តកា ។

កាវី យាចំ តិលាភោ ច

បុរិស យុត្តសីវិកា

សយជាតំ មហាចម្មា

កេចម្មេហិ ច ចាមរោ ។

តិហេំ ចម្មោត្ថហំ

ឋវិសត្តិ តិលាយហោ

មហាកដ្ឋាយណោ សោសោ

សហជន្តកាវត្ថិកំ ។



សំណាញ់ហាំង ១ សំណាកក ១ ទន់ផែនមួយ ៗ រឿង
ឆព្វគ្គិយភិក្ខុ ហាប់សាយរបោគោមានស្នែងជាដើម ១ រឿង
ឆព្វគ្គិយភិក្ខុជិះយាន ១ រឿងភិក្ខុឈឺ ១ រឿងព្រះសម្ពុទ្ធទ្រង់
អនុញ្ញាតយានចំម ដោយចុះសម្ប.សត្វណ្ណោល ១ រឿង
ព្រះសម្ពុទ្ធ ទ្រង់អនុញ្ញាតតែស្នែង ១ រឿងឆព្វគ្គិយភិក្ខុ
ប្រើប្រាស់ព្រាសយានរើនមហាសយនៈ ១ រឿងឆព្វគ្គិយភិក្ខុ
ប្រើប្រាស់ស្បែកសត្វធំ ១ រឿងឆព្វគ្គិយភិក្ខុប្រើប្រាស់
ស្បែកគោ ១ រឿងភិក្ខុណាមកជាធីតុរបស់ពុ.ធក
លាមក ១ ៗ រឿងព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យ
ភិក្ខុអង្គុយលើស្បែកដែលគ្រហស្ថក្រាល ១ រឿងវិហារ
ដែលគេចូនដោយវឹស្បែក ១ រឿងឆព្វគ្គិយភិក្ខុពាក់
ស្បែកដើម្បីចូលទៅកាន់ស្រុក ១ រឿងព្រះសម្ពុទ្ធទ្រង់
អនុញ្ញាតឲ្យភិក្ខុឈឺពាក់ស្បែកដើម្បីចូលទៅកាន់ស្រុក
ព្រឹទ ១ រឿងព្រះមហាកច្ចានៈ ១ រឿងព្រះសោណក្ខោ
សំផែនស្ងួតព្រែកបដោយវត្ថុ ៥ ដោយសារើសម្ដេង ១ ៗ

ឧបសម្បទំ បញ្ចហិ(១)

គណា ធុវសិនាយនា(២)

ចម្មត្ថរណានុញ្ញាសិ

ន តាវ គណនូបគំ

អទាសិ មេ វរេ បញ្ច

សោណកោដិស្ស នាយកោតិ ។

---

១ ឱ, បញ្ចគណំ ។ ២ ឱ, គណង្គណា ធុវសិនា ។



ហើយព្រះសម្ពុទ្ធទ្រង់អនុញ្ញាតនូវឧបសម្បទាកម្មដោយ
គណៈ ៥ រូប ១ ស្បែកជើង ៤ ជាន់ឡើងទៅ ១ ការងូតទឹក
ជានិច្ច ១ គ្រឿងលាស់ស្បែក ១ ទ្រង់អនុញ្ញាតឲ្យគិតក្នុងគ្រែ
អាសនៈជាប់ប្រមាណពាក់កណ្ដាលដែល មិនត្រូវឲ្យរាប់ក្នុងគ្រឿ
ឡើយ ១ ព្រះមានព្រះភាគជានាយកទ្រង់ប្រទានពរ
ទាំង ៥ ដល់ព្រះសោណកោដិហើយ ។

# ភេសជ្ជក្ខន្ធកំ

(៧៣) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខូនំ សារទិកេន អាពាធេន ផុដ្ឋានំ យាគុបិ បីតា ឧគ្គច្ឆតិ ភត្តំបិ ភុត្តំ ឧគ្គច្ឆតិ ។ តេ តេន កិសា ហោន្តិ លូខា ទុព្វណ្ណា ឧប្បណ្ឌុប្បណ្ឌុកជាតា ធមនិសន្ថតគត្តា ។ អទ្ទសា ខោ ភគវា តេ ភិក្ខូ កិសេ លូខេ ទុព្វណ្ណេ ឧប្បណ្ឌុប្បណ្ឌុកជាតេ ធមនិសន្ថតគត្តេ ទិស្វាន អាយស្មន្តំ អានន្ទំ អាមន្តេសិ កិន្នុ ខោ អានន្ទ ឯតរហិ ភិក្ខូ កិសា លូខា ទុព្វណ្ណា ឧប្បណ្ឌុប្បណ្ឌុកជាតា ធមនិសន្ថតគត្តាតិ ។ ឯតរហិ ភន្តេ ភិក្ខូនំ សារទិកេន អាពាធេន ផុដ្ឋានំ យាគុបិ បីតា ឧគ្គច្ឆតិ ភត្តំបិ ភុត្តំ ឧគ្គច្ឆតិ តេ តេន

# ភេសជ្ជក្ខន្ធកៈ

(៧៣) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកភិក្ខុកើតអាពាធ (ប្រមាត់) ក្នុងសារទកាល[១] បបរដែលហុតទៅក៏ចង្អោរចេញមកវិញ ភាយដែលឆាន់ទៅក៏ចង្អោរចេញមកវិញ ។ ព្រោះហេតុនោះ ពួកភិក្ខុទាំងនោះក៏មានខ្លួនស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់ កើតជាពណ៌លឿងស្លេកស្លាំង មានខ្លួនពេញដោយសរសៃ ។ ព្រះដ៏មានព្រះភាគបានទតឃើញភិក្ខុទាំងនោះស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់ កើតជាពណ៌លឿងស្លេកស្លាំង មានខ្លួនពេញដោយសរសៃ លុះទតឃើញហើយក៏ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា ម្នាលអានន្ទ ក្នុងវេលានេះ ហេតុដូចម្តេចបានជាពួកភិក្ខុស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជាពណ៌លឿងស្លេកស្លាំង មានខ្លួនពេញដោយសរសៃ ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងវេលានេះ ពួកភិក្ខុកើតអាពាធ (ប្រមាត់) ក្នុងសារទកាល បបរដែលហុតទៅក៏ចង្អោរចេញមកវិញ ភាយដែលឆាន់ទៅក៏ចង្អោរចេញមកវិញ ព្រោះ

---

១ កាលដែលជាទី ស្រៀវស្រាញ សន្សើមសន្សាញ់ គឺខែកត្តិកនិងខែមិគសិរ ទាំង ខាងដើមនៃហេមន្តរដូវ ។

កិសា លូខា ទុព្វណ្ណា ឧប្បណ្ឌុប្បណ្ឌុកជាតា ធមនិ-
សន្ថតគត្តា ។ អថខោ ភគវតោ រហោគតស្ស បដិ-
សល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ ឯតរហិ
ខោ ភិក្ខូនំ សារទិកេន អាពាធេន ផុដ្ឋានំ យាគុបិ បីតា
ឧគ្គច្ឆតិ ភត្តម្បិ ភុត្តំ ឧគ្គច្ឆតិ តេ តេន កិសា លូខា
ទុព្វណ្ណា ឧប្បណ្ឌុប្បណ្ឌុកជាតា ធមនិសន្ថតគត្តា កិន្នុ
ខោ អហំ ភិក្ខូនំ ភេសជ្ជំ អនុជានេយ្យំ យំ ភេសជ្ជញ្ចេវ
អស្ស ភេសជ្ជសម្មតញ្ច លោកស្ស អាហារត្ថញ្ច(១) ផរេយ្យ
ន ច ឱឡារិកោ អាហារោ បញ្ញាយេយ្យាតិ ។ អថខោ
ភគវតោ ឯតទហោសិ ឥមានិ ខោ បញ្ច ភេសជ្ជានិ
សេយ្យថីទំ សប្បិ នវនីតំ តេលំ មធុ ផាណិតំ ភេ-
សជ្ជានិ ចេវ ភេសជ្ជសម្មតានិ ច លោកស្ស អាហា-
រត្ថញ្ច ផរន្តិ ន ច ឱឡារិកោ អាហារោ បញ្ញាយតិ
យន្នូនាហំ ភិក្ខូនំ ឥមានិ បញ្ច ភេសជ្ជានិ អនុជា-

១ ម. អាហារត្ថញ្ច ។





អាពាធនោះ បានជាភិក្ខុទាំងនោះស្គាំងស្គម សៅហ្មង មានសម្បុរ
អាក្រក់ កើតជាពណ៌លឿងស្លេកស្លាំង មានខ្លួនពេញដោយសរសៃ ។
គ្រានោះ ព្រះមានព្រះភាគទ្រង់គង់សម្ងំនៅក្នុងទីស្ងាត់ ក៏មានព្រះ
តម្រិះត្រិះរំពឹងដូច្នេះថា ឥឡូវនេះ ពួកភិក្ខុកើតអាពាធ (ប្រចាំ)
ក្នុងសរទកាលហើយ បបរដែលផឹកទៅ ក៏ចង្អោរចេញមកវិញ បាយ
ដែលឆាន់ទៅ ក៏ចង្អោរចេញមកវិញ ព្រោះអាពាធនោះហើយបានជា
ភិក្ខុទាំងនោះទៅជាស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់ កើតជា
ពណ៌លឿងស្លេកស្លាំង មានខ្លួនពេញដោយសរសៃ (ឥឡូវ) វត្ថុដែល
ជាភេសជ្ជៈ ក៏មាន វត្ថុដែលគេសន្មតថាជាភេសជ្ជៈ ក៏មាន វត្ថុដែល
ផ្សាយទៅសម្រាប់ជាអាហាររបស់មនុស្សលោក ក៏មាន វត្ថុដែលជា
អាហារមិនបានគ្រោតគ្រាត ក៏មាន តើគួរតថាគតអនុញ្ញាតវត្ថុដូចម្តេច
ហើយសមគួរជាភេសជ្ជៈដល់ភិក្ខុទាំងឡាយហ្ន៎ ។ លំដាប់នោះ ព្រះ
មានព្រះភាគទ្រង់ត្រិះរំពឹងដូច្នេះថា ភេសជ្ជៈទាំង ៥ នេះគឺ ទឹកដោះថ្លា ១
ទឹកដោះខាប់ ១ ប្រេង ១ ទឹកឃ្មុំ ១ ស្ករអំពៅ ១ វត្ថុទាំងនេះជា
ភេសជ្ជៈផង ដែលគេសន្មតថាជាភេសជ្ជៈផង ផ្សាយទៅសម្រាប់ជា
អាហាររបស់មនុស្សលោកផង ជាអាហារមិនបានគ្រោតគ្រាតផង បើ
ដូច្នោះមានតែតថាគតអនុញ្ញាតភេសជ្ជៈទាំង ៥ នេះដល់ពួកភិក្ខុ ដើម្បី

ធេយ្យំ កាលេ បដិក្កមោ តាលេ បរិកុញ្ចិតុន្តិ ។ អដ្ឋោ ភគវា សាយណ្ហសមយេ(១) បដិសល្លាណា វុដ្ឋិតោ បតស្មិំ ឯតានេ បតស្មិំ បការណេ ធម្មំ ភាជំ ភាតា ភិក្ខុ អាមន្តេសិ ឥធ មយ្ហំ ភិក្ខវេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ ឯតរហិ ខោ ភិក្ខុនំ សាវត្ថិយំ អាហារេ ឧប្បាទំ យោគុបិ បិតា ទុក្ខុត្តិ កត្តុបំ កុត្តំ ទុក្ខុត្តិំ តេ តេន គិលាសា ល្អិតា ធុត្តល្លា ទុប្បណ្ណាបណ្ណាកជាតា ធមនិសន្ថត-គត្តា តាំន្ត្រោ អហំ ភិក្ខូនំ កេសន្ទំ អនុជានេយ្យំ កេសន្ទញ្ញោ អស្ស កេសន្ទីសម្មតញ្ច លោកស្ស អាហារត្តញ្ច ជហេយ្យុំ ន ច ទុក្ខុរិតោ អាហារេ បញ្ញា-យេយ្យាតិ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ សមាធិ ទោ បញ្ច កេសន្ទានំ សេយ្យថីទំ សប្បិ នវនីតំ តេលំ មធុ ផាណិតំ កេសន្ទានិ ចេវ កេសន្ទីសម្មតានិ ច

(១) សាយណ្ហសមយេន្តិបិ បាឋោ ។



ទ្រង់ត្រាស់ក្នុងកាលគួរ ដាក់ក្នុងកាលគួរ(១) ដូច្នេះ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ចេញអំពីទីសម្ងំក្នុងទីស្ងាត់ នោះ ក្នុងវេលានោះ ទើបព្រះមានព្រះភាគទ្រង់ចេញអំពីទីសម្ងំក្នុងទីស្ងាត់ នៅវេលាសាយណ្ហសម័យ ហើយទ្រង់ធ្វើធម្មីកថា ក្នុងព្រោះបោកក្ខុទាំង ឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងវេលានេះ តថាគតសម្ងំនៅក្នុងទីស្ងាត់ មានចិត្តត្រិះរិះដូច្នេះថា សព្វថ្ងៃនេះ ពួកភិក្ខុកើតអាពាធ (ប្រមាត់) ក្នុងសរទកាល ហើយ បបរដែលបានទៅគិលានភេសជ្ជៈមកវិញ ក្អួតចេញមកវិញ ព្រោះអាពាធនោះ ទើបស្គមស្គាំង ដែលដាក់ទៅក្នុងបោះពោះហើយចេញមកវិញ ព្រោះអាពាធនោះ ទើបស្គមស្គាំង មានសម្បុរក្រៀមក្រោះ កើតជាលឿងស្លេកស្លាំង មានសរសៃផុសឡើង ក្នុងសព្វសរីរៈ ក្នុងនោះដែលជាភេសជ្ជៈ ដែលគួរផ្តល់ថា ជាភេសជ្ជៈ ក្នុងនោះដូចជាគួរចំណីដែលគួរប្រើ ជាអាហារ ហើយនឹងមិនបាននូវគ្រោតគ្រាត ក្នុងលោក ក្នុងនោះជាអាហារ ដែលមិនបានធ្លាក់ភ្នាក់ ហេតុនោះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតភេសជ្ជៈដល់ភិក្ខុទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ដូចម្តេចដែលសមគួរជាភេសជ្ជៈផង ភេសជ្ជៈទាំង ៥ នេះ គឺទឹកដោះ ថ្លា ១ ទឹកដោះខាប់ ១ ប្រេង ១ ទឹកឃ្មុំ ១ ស្ករអំពៅ ១ របស់ទាំងនេះជាភេសជ្ជៈផង ដែលគេសន្មតថាជាភេសជ្ជៈផង ដូចជាគ្រឿងអាហារ

១ សំដៅយកតាំងពីពេលព្រឹករហូតដល់ថ្ងៃត្រង់ ។ គួរទៅតាមទំនៀមទម្លាប់ខ្លះ

ទៀត ។

លោកស្ស អាហារត្ថញ្ច ផរន្តិ ន ច ឱឡារិកោ អាហារោ បញ្ញាយតិ យន្នូនាហំ ភិក្ខូនំ ឥមានិ បញ្ច ភេសជ្ជានិ អនុជានេយ្យំ កាលេ បដិគ្គហេត្វា កាលេ បរិភុញ្ជិតុន្តិ ។ អនុជានាមិ ភិក្ខវេ តានិ បញ្ច ភេសជ្ជានិ កាលេ បដិគ្គហេត្វា កាលេ បរិភុញ្ជិតុន្តិ ។

(៣៦) តេន ខោ បន សមយេន ភិក្ខូ តានិ បញ្ច ភេសជ្ជានិ កាលេ បដិគ្គហេត្វា កាលេ បរិភុញ្ជន្តិ ។ តេសំ យានិបិ តានិ បាកតិកានិ លូខានិ ភោជនានិ តានិបិ នច្ឆាទេន្តិ បគេវ សេនេសិតានិ ។ តេ តេន ចេវ សារទិកេន អាពាធេន ផុដ្ឋា ឥមិនា ច ភត្តច្ឆាទកេន(១) តទុភយេន ភិយ្យោសោមត្តាយ កិសា ហោន្តិ លូខា ទុព្វណ្ណា ឧប្បណ្ឌុប្បណ្ឌុកជាតា ធមនិសន្ថតគត្តា ។ អទ្ទសា ខោ ភគវា តេ ភិក្ខូ កិសេ លូខេ ទុព្វណ្ណេ ឧប្បណ្ឌុប្បណ្ឌុកជាតេ ធមនិសន្ថតគត្តេ ទិស្វាន អាយស្មន្តំ អានន្ទំ អាមន្តេសិ កិន្នុ ខោ អានន្ទ ឯតរហិ ភិក្ខូ

១ ភត្តច្ឆាទកេនាតិបិ បាឋោ ។



របស់មនុស្សលោកផង ជាអាហារមិនចុនស្រាកស្រាកផង បើដូច្នោះមាន តែ តថាគតអនុញ្ញាតភេសជ្ជៈទាំង ៥ នេះដល់ភិក្ខុទាំងឡាយ ដើម្បីឲ្យភិក្ខុទទួលក្នុងកាលគួរ បរិភោគក្នុងកាលគួរ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទទួលភេសជ្ជៈទាំង ៥ នោះក្នុងកាលគួរ បរិភោគក្នុងកាលគួរ ។

(៣៦) សម័យនោះឯង ពួកភិក្ខុទទួលភេសជ្ជៈទាំង ៥ នោះក្នុងកាលគួរ ឆាន់ក្នុងកាលគួរ ។ សូម្បីភោជនដ៏សៅហ្មងធម្មតា(១)របស់ភិក្ខុទាំងនោះនោះហើយ ក៏ពុំចុះចិត្តឆាន់ទៀតផង ដល់ភោជនប្រណីតដែលជាទីគាប់ចិត្ត ។ ដោយអាពាធ (ប្រមាត់) កើតឡើងក្នុងសរទកាលនោះផង ដោយភត្តដែលមិនល្មមនេះផង ភិក្ខុទាំងនោះក៏រីងរៃតែមានខ្លួនស្គាំងស្គមសៅហ្មង មានសម្បុរក្រៀម កើតជាពពុះលឿងស្លេកស្លាំង មានខ្លួនពាសដោយសរសៃ ព្រោះហេតុទាំងពីរនោះ ។ ព្រះមានព្រះភាគ ទ្រង់បានទតឃើញភិក្ខុទាំងនោះរីងរៃ មានខ្លួនស្គាំងស្គមសៅហ្មង មានសម្បុរក្រៀម កើតជាពពុះលឿងស្លេកស្លាំង មានខ្លួនពាសដោយសរសៃ លុះទតឃើញហើយ ក៏ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ

១ សេចក្ដីថា ធំ និង វិនវីពេញនឹងភោជន ហាក់ដូចជានោះក៏ត្រូវបង់ចោលជាសៅហ្មងមិនមាន ប្រយោជន៍ពីសោះ ។

ភិយ្យោសោ មត្តាយ កិសា លូខា ទុព្វណ្ណា ឧប្បណ្ឌុ-ប្បណ្ឌុកជាតា ធមនិសន្ថតគត្តាតិ ។ ឯតរហិ ភន្តេ ភិក្ខូ តានិ បញ្ច ភេសជ្ជានិ កាលេ បដិគ្គហេត្វា កាលេ បរិភុញ្ជន្តិ តេសំ យានិបិ តានិ បាកតិកានិ លូខានិ ភោជនានិ តានិបិ នច្ឆាទេន្តិ បគេវ សេនេសិ-តានិ តេ តេន ចេវ សារទិកេន អាពាធេន ផុដ្ឋា ឥមិនា ច ភត្តាច្ឆាទកេន តទុភយេន ភិយ្យោសោ មត្តាយ កិសា លូខា ទុព្វណ្ណា ឧប្បណ្ឌុប្បណ្ឌុកជាតា ធមនិសន្ថតគត្តាតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ តានិ បញ្ច ភេសជ្ជានិ បដិគ្គហេត្វា កាលេបិ វិកាលេបិ បរិភុញ្ជិតុន្តិ ។

(៧៥) តេន ខោ បន សមយេន គិលានានំ ភិក្ខូនំ វសេហិ ភេសជ្ជេហិ អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ វសានិ ភេសជ្ជានិ



ឥឡូវនេះ ហេតុដូចម្តេចបានជាពួកភិក្ខុរីងរៃ មានខ្លួនស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់ កើតជាពពុះលឿងស្លេកស្លាំង មានខ្លួនពេញដោយសរសៃ ៗ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះពួកភិក្ខុទទួលភេសជ្ជៈទាំង ៥ នោះក្នុងកាលគួរ ឆាន់ក្នុងកាលគួរ លុះភោជនដ៏សៅហ្មងក៏មិនឆ្អែតរបស់ភិក្ខុទាំងនោះទៅហើយ កុំបីបាច់និយាយឡើយដល់ភោជនប្រណីតដែលជាភ្លក់សៅហ្មងដោយតាភាព (ប្រមាត់) ដែលកើតឡើងក្នុងសរទកាលនោះផង ដោយភត្តដែលមិនល្មមនោះផង ភិក្ខុទាំងនោះតែងរីងរៃមានខ្លួនស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់កើតជាពពុះលឿងស្លេកស្លាំង មានខ្លួនពេញដោយសរសៃ ព្រោះហេតុទាំងពីរនោះ ៗ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទទួលភេសជ្ជៈទាំង ៥ នោះ ឆាន់ក្នុងកាលគួរក៏បាន ក្នុងកាលមិនគួរក៏បាន(១) ៗ

(៧៥) សម័យនោះឯង ពួកភិក្ខុមានជម្ងឺត្រូវការដោយខ្លាញ់ជាថ្នាំ ៗ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ៗ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្លាញ់ជាភេសជ្ជៈ គឺខ្លាញ់

---

១ កាលគួរនឹងកាលដ៏ត្រូវណាស់ គឺតាំងពីព្រលឹមដល់ថ្ងៃត្រង់ ឯកាលមិនគួរនោះ គឺតាំងពីថ្ងៃជ្រេតរហូតដល់អរុណរះ ៗ

អច្ឆវសំ មច្ឆវសំ សុសុកាវសំ សូករវសំ គទ្រភវសំ កាលេ បដិគ្គហិតំ កាលេ និបក្កំ កាលេ សំសដ្ឋំ តេលបរិភោគេន បរិភុញ្ជិតុំ ។ វិកាលេ ចេ ភិក្ខវេ បដិគ្គហិតំ វិកាលេ និបក្កំ វិកាលេ សំសដ្ឋំ តញ្ចេ បរិភុញ្ជេយ្យ អាបត្តិ តិណ្ណំ ទុក្កដានំ ។ កាលេ ចេ ភិក្ខវេ បដិគ្គហិតំ វិកាលេ និបក្កំ វិកាលេ សំសដ្ឋំ តញ្ចេ បរិភុញ្ជេយ្យ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ កាលេ ចេ ភិក្ខវេ បដិគ្គហិតំ កាលេ និបក្កំ វិកាលេ សំសដ្ឋំ តញ្ចេ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស ។ កាលេ ចេ ភិក្ខវេ បដិគ្គហិតំ កាលេ និបក្កំ កាលេ សំសដ្ឋំ តញ្ចេ បរិភុញ្ជេយ្យ អនាបត្តីតិ ។

(៧៦) តេន ខោ បន សមយេន គិលានានំ ភិក្ខូនំ មូលេហិ ភេសជ្ជេហិ អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ មូលានិ ភេសជ្ជានិ ហលិទ្ទំ សិង្គិវេរំ វចំ វចត្ថំ អតិវិសំ កដុករោហិណឹ ឧសីរំ ភទ្ទមុត្តកំ



ខ្លាឃ្មុំ ខ្លាញ់ត្រី ខ្លាញ់ក្រពើ ខ្លាញ់ជ្រូក ខ្លាញ់លា ដែលភិក្ខុទទួលក្នុងកាលគួរ ចំអិនក្នុងកាលគួរ លាយត្រាំក្នុងកាលគួរ សម្រាប់ឲ្យភិក្ខុប្រើប្រាស់ដោយវិធីប្រើប្រាស់ដូចប្រេង (ជាសត្តាហកាលិក) បាន[១] ។ ម្នាលភិក្ខុទាំងឡាយ បើខ្លាញ់ដែលភិក្ខុបានទទួលក្នុងកាលមិនគួរ ចំអិនក្នុងកាលមិនគួរ លាយត្រាំក្នុងកាលមិនគួរ បើភិក្ខុប្រើប្រាស់ខ្លាញ់នោះ ត្រូវអាបត្តិទុក្កដបី ។ ម្នាលភិក្ខុទាំងឡាយ បើខ្លាញ់ដែលភិក្ខុទទួលក្នុងកាលគួរ តែចំអិនក្នុងកាលមិនគួរ លាយត្រាំក្នុងកាលមិនគួរ បើភិក្ខុប្រើប្រាស់ខ្លាញ់នោះ ត្រូវអាបត្តិទុក្កដពីរ ។ ម្នាលភិក្ខុទាំងឡាយ បើខ្លាញ់ដែលភិក្ខុទទួលក្នុងកាលគួរ ចំអិនក្នុងកាលគួរ តែលាយត្រាំក្នុងកាលមិនគួរ បើភិក្ខុប្រើប្រាស់ខ្លាញ់នោះ ត្រូវអាបត្តិទុក្កដមួយ ។ ម្នាលភិក្ខុទាំងឡាយ បើខ្លាញ់ដែលភិក្ខុទទួលក្នុងកាលគួរ ចំអិនក្នុងកាលគួរ លាយត្រាំក្នុងកាលគួរ បើភិក្ខុប្រើប្រាស់ខ្លាញ់នោះ មិនត្រូវអាបត្តិឡើយ ។

(៧៦) សម័យនោះឯង ពួកភិក្ខុមានជម្ងឺមានសេចក្តីត្រូវការដោយឫសឈើជាភេសជ្ជៈ ។ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវឫសឈើជាភេសជ្ជៈ គឺមើមរមៀត មើមខ្ញី មើមលំពាង មើមប្រស់ មើមគល់ក្តិស មើមរំដេង មើមស្បូវភ្លាំង មើមស្មៅក្រញូងផែក ម្យ៉ាងទៀត

យានិ វា បនញ្ញានិបិ អត្ថិ មូលានិ ភេសជ្ជានិ នេវ ខាទនីយេ ខាទនីយត្ថំ[១] ផរន្តិ ន ភោជនីយេ ភោជនីយត្ថំ[២] ផរន្តិ តានិ បដិគ្គហេត្វា យាវជីវំ បរិហរិតុំ សតិ បច្ចយេ បរិភុញ្ជិតុំ អសតិ បច្ចយេ បរិភុញ្ជន្តស្ស អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន គិលានានំ ភិក្ខូនំ មូលេហិ ភេសជ្ជេហិ បិដ្ឋេហិ អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ និសទំ និសទបោតកន្តិ ។

[៧៨] តេន ខោ បន សមយេន គិលានានំ ភិក្ខូនំ កសាវេហិ ភេសជ្ជេហិ អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ កសាវានិ ភេសជ្ជានិ និម្ពកសាវំ កុដជកសាវំ បដោលកសាវំ ផគ្គវកសាវំ នត្តមាលកសាវំ យានិ វា បនញ្ញានិបិ អត្ថិ កសាវានិ ភេសជ្ជានិ នេវ ខាទនីយេ ខាទនីយត្ថំ ផរន្តិ ន ភោជនីយេ ភោជនីយត្ថំ ផរន្តិ តានិ បដិគ្គហេត្វា យាវជីវំ បរិហរិតុំ សតិ បច្ចយេ បរិភុញ្ជិតុំ អសតិ បច្ចយេ បរិភុញ្ជន្តស្ស អាបត្តិ ទុក្កដស្សាតិ ។



មើមនៃវត្ថុណាជាភេសជ្ជៈ មិនផ្សាយទៅ ដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅ ដើម្បីភោជនីយៈក្នុងភោជនីយៈ ឲ្យភិក្ខុទទួលមើមទាំងឡាយនោះហើយរក្សាទុកដរាបដល់អស់ជីវិតបាន កាលបើមានហេតុទើបភិក្ខុឆាន់បាន កាលបើគ្មានហេតុ ហើយភិក្ខុឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកភិក្ខុមានជម្ងឺមានសេចក្ដីត្រូវការដោយម្សៅជាភេសជ្ជៈដែលកើតអំពីមូលមើម ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថ្មកិនធំនិងកូនថ្មកិន ។

(៨៧) សម័យនោះឯង ពួកភិក្ខុមានជម្ងឺមានសេចក្ដីត្រូវការដោយទឹកចត់ជាភេសជ្ជៈ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកចត់ជាភេសជ្ជៈ គឺទឹកចត់កើតអំពីដើមស្ដៅ ទឹកចត់កើតអំពីដើមខ្នុរព្រៃ ទឹកចត់កើតអំពីដើមសម្បូរថ្ម ទឹកចត់កើតអំពីល្វីងបណ្ដូលពេជ្រ ទឹកចត់កើតអំពីដើមចង្វាឬថ្នាំ ឬដទៃទៀត ទឹកចត់នៃវត្ថុណាជាភេសជ្ជៈ មិនផ្សាយទៅ ដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈក្នុងភោជនីយៈ ឲ្យភិក្ខុទទួលទឹកចត់ទាំងនោះហើយរក្សាទុកដរាបដល់អស់ជីវិតបាន កាលបើមានហេតុទើបភិក្ខុឆាន់បាន កាលបើគ្មានហេតុ ហើយភិក្ខុឆាន់ ត្រូវអាបត្តិទុក្កដ ។

(៧៨) តេន ខោ បន សមយេន គិលានានំ ភិក្ខូនំ បណ្ណេហិ ភេសជ្ជេហិ អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បណ្ណានិ ភេសជ្ជានិ និម្ពបណ្ណំ កុដជបណ្ណំ បដោលបណ្ណំ សុលសិបណ្ណំ[១] កប្បាសិបណ្ណំ យានិ វា បនញ្ញានិបិ អត្ថិ បណ្ណានិ ភេសជ្ជានិ នេវ ខាទនីយេ ខាទនីយត្ថំ ផរន្តិ ន ភោជនីយេ ភោជនីយត្ថំ ផរន្តិ តានិ បដិគ្គហេត្វា យាវជីវំ បរិហរិតុំ សតិ បច្ចយេ បរិភុញ្ជិតុំ អសតិ បច្ចយេ បរិភុញ្ជន្តស្ស អាបត្តិ ទុក្កដស្សាតិ ។

(៧៩) តេន ខោ បន សមយេន គិលានានំ ភិក្ខូនំ ផលេហិ ភេសជ្ជេហិ អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ផលានិ ភេសជ្ជានិ វិលង្គំ បិប្ផលឹ មរិចំ ហរីតកំ វិភីតកំ អាមលកំ គោដ្ឋផលំ[២] យានិ វា បនញ្ញានិបិ អត្ថិ ផលានិ ភេសជ្ជានិ នេវ ខាទនីយេ ខាទនីយត្ថំ ផរន្តិ ន ភោជនីយេ

១ សុលសិបណ្ណន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ គោដ្ឋផលន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។



(៧៨) សម័យនោះឯង ពួកភិក្ខុមានជម្ងឺមានសេចក្តីត្រូវការដោយស្លឹកឈើជាភេសជ្ជៈ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្លឹកឈើជាភេសជ្ជៈ គឺស្លឹកស្តៅ ស្លឹកខ្ទុំនីគន់ ស្លឹកតម្រូវថ្ងៃ ស្លឹកម្រះព្រៅ ឬដើមលើទណក់ ស្លឹកកប្បាស មួយទៀត ស្លឹកដទៃណាជាភេសជ្ជៈ មិនផ្សាយទៅ ដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅ ដើម្បីភោជនីយៈក្នុងភោជនីយៈ ឲ្យភិក្ខុទទួលស្លឹកទាំងនោះហើយទុក ដរាបទល់អស់ជាន កាលបើមានហេតុទើបភិក្ខុឆាន់បាន កាលបើគ្មានហេតុហើយភិក្ខុឆាន់ ត្រូវអាបត្តិទុក្កដ ។

(៧៩) សម័យនោះឯង ពួកភិក្ខុមានជម្ងឺមានសេចក្តីត្រូវការដោយផ្លែឈើជាភេសជ្ជៈ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្លែឈើជាភេសជ្ជៈ គឺផ្លែពិលង្គ ផ្លែដីប្លី ផ្លែម្រេច ផ្លែសម៉ ផ្លែសម៉ពិភេក ផ្លែកន្ទួតព្រៃ ផ្លែព្រកញ មួយទៀត ផ្លែឈើដទៃណាជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈ

ភោជនីយត្ថំ ផរន្តិ តានិ បដិគ្គហេត្វា យាវជីវំ បរិហរិតុំ សតិ បច្ចយេ បរិភុញ្ជិតុំ អសតិ បច្ចយេ បរិភុញ្ជន្តស្ស អាបត្តិ ទុក្កដស្សាតិ ។

(៨០) តេន ខោ បន សមយេន គិលានានំ ភិក្ខូនំ ជតូហិ ភេសជ្ជេហិ អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ជតូនិ ភេសជ្ជានិ ហិង្គុំ ហិង្គុជតុំ ហិង្គុសិបាដិកំ តកំ តកបត្តិំ តកបណ្ណិំ សជ្ជុលសំ យានិ វា បនញ្ញានិបិ អត្ថិ ជតូនិ ភេសជ្ជានិ នេវ ខាទនីយេ ខាទនីយត្ថំ ផរន្តិ ន ភោជនីយេ ភោជនីយត្ថំ ផរន្តិ តានិ បដិគ្គហេត្វា យាវជីវំ បរិហរិតុំ សតិ បច្ចយេ បរិភុញ្ជិតុំ អសតិ បច្ចយេ បរិភុញ្ជន្តស្ស អាបត្តិ ទុក្កដស្សាតិ ។



ក្នុងភោជនីយៈ ឱ្យភិក្ខុទទួលផ្លែឈើទាំងឡាយនោះ ហើយរក្សាទុកដរាបទល់អស់ជីវិត កាលបើមានហេតុ ទើបភិក្ខុឆាន់បាន កាលបើគ្មានហេតុទេ ហើយភិក្ខុឆាន់ ត្រូវអាបត្តិទុក្កដ ។

(៨០) សម័យនោះឯង ពួកភិក្ខុមានជម្ងឺមានសេចក្តីត្រូវការដោយជ័រឈើជាភេសជ្ជៈ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជ័រឈើជាភេសជ្ជៈ គឺជ័រដែលហូរចេញអំពីដើមហិង្គុ ១ ជ័រដែលគេយកស្លឹកទីទៃមកហិង្គុមកដាំស់ ១ ជ័រដែលគេយកតែស្លឹកហិង្គុតែម្យ៉ាងមកដាំស់ ១ (ជ័រទាំងបីយ៉ាងនេះជាជាតិហិង្គុទាំងអស់) ជ័រដែលហូរចេញអំពីត្រួយឈើ ១ ជ័រដែលហូរចេញអំពីស្លឹកឈើ ១ ជ័រដែលគេបេះស្លឹកឈើយកមកចៀន ១ កំញាន ១ មួយទៀត ជ័រឈើឯទៃណាដែលជាភេសជ្ជៈ មិនផ្សាយទៅ ដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈក្នុងភោជនីយៈ ឱ្យភិក្ខុទទួលជ័រឈើទាំងនោះ ហើយរក្សាទុកដរាបទល់អស់ជីវិត កាលបើមានហេតុ ទើបភិក្ខុឆាន់បាន កាលបើគ្មានហេតុទេ ហើយភិក្ខុឆាន់ ត្រូវអាបត្តិទុក្កដ ។

(៤១) តេន ខោ បន សមយេន គិលានានំ ភិក្ខូនំ លោណេហិ ភេសជ្ជេហិ អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ លោណានិ ភេសជ្ជានិ សាមុទ្ទំ កាឡលោណំ សិន្ធវំ ឧព្ភិទំ ពិលំ យានិ វា បនញ្ញានិបិ អត្ថិ លោណានិ ភេសជ្ជានិ នេវ ខាទនីយេ ខាទនីយត្ថំ ផរន្តិ ន ភោជនីយេ ភោជនីយត្ថំ ផរន្តិ តានិ បដិគ្គហេត្វា យាវជីវំ បរិហរិតុំ សតិ បច្ចយេ បរិភុញ្ជិតុំ អសតិ បច្ចយេ បរិភុញ្ជន្តស្ស អាបត្តិ ទុក្កដស្សាតិ ។

(៤២) តេន ខោ បន សមយេន អាយស្មតោ អានន្ទស្ស ឧបជ្ឈាយស្ស អាយស្មតោ ពេលដ្ឋសីសស្ស ថុល្លកច្ឆាពាធោ ហោតិ ។ តស្ស លសិកាយ ចីវរានិ កាយេ លគ្គន្តិ ។ តានិ ភិក្ខូ ឧទកេន តេមេត្វា តេមេត្វា អបកឌ្ឍន្តិ ។ អទ្ទសា ខោ ភគវា សេនាសនចារិកំ អាហិណ្ឌន្តោ តេ ភិក្ខូ តានិ ចីវរានិ ឧទកេន តេមេត្វា តេមេត្វា អបកឌ្ឍន្តេ ទិស្វាន





(៤១) សម័យនោះឯង ពួកភិក្ខុមានជម្ងឺមានសេចក្តីត្រូវការដោយអំបិលជាភេសជ្ជៈ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអំបិលជាភេសជ្ជៈ គឺអំបិលកើតក្បែរឆ្នេរសមុទ្រ មានថែបផ្ទុចដីខ្សាច់ អំបិលមានពណ៌ខ្មៅ (អំបិលប្រៃក្រៃ) អំបិលមានពណ៌សកើតលើភ្នំ អំបិលដែលមានពន្លកដុះកើតពីផែនដី (អំបិលដែលកើតអំពីភាពផែនដីមានរសប្រៃ) អំបិលមានពណ៌ក្រហមដែលគេចំអិនជាមួយនឹងគ្រឿងសម្ភារៈទាំងពួង ម្យ៉ាងទៀត អំបិលដទៃណាដែលជាភេសជ្ជៈ មិនផ្សាយទៅ ដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅ ដើម្បីភោជនីយៈក្នុងភោជនីយៈ ឲ្យភិក្ខុទទួលអំបិលទាំងនោះ ហើយរក្សាទុកដរាបដល់អស់ជីវិតបាន កាលបើមានហេតុ ទើបភិក្ខុឆាន់បាន កាលបើគ្មានហេតុទេ ហើយភិក្ខុឆាន់ ត្រូវអាបត្តិទុក្កដ ។

(៤២) សម័យនោះឯង ព្រះវេលដ្ឋសីសៈដ៏មានអាយុជាឧបជ្ឈាយ៍របស់ព្រះអានន្ទដ៏មានអាយុកើតបូសធំ ។ ចីវរដែលប្រឡាក់ដោយទឹករំអិលក៏ជាប់ស្អិតទៅនឹងកាយរបស់ព្រះវេលដ្ឋសីសៈនោះ ។ ពួកភិក្ខុក៏យកទឹកទៅលាបចីវរនោះឲ្យសើម ៗ ហើយបកចេញ ។ ព្រះដ៏មានព្រះភាគត្រាច់ចុះដើរទៅកាន់សេនាសនចារិក បានទតឃើញភិក្ខុទាំងនោះកំពុងយកទឹកទៅលាបចីវរទាំងនោះឲ្យសើម ៗ ហើយបកចេញ លុះទតហើយ

យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច កិមិមស្ស ភិក្ខវេ ភិក្ខុនោ អាពាធោតិ ។ ឥមស្ស ភន្តេ អាយស្មតោ ថុល្លកច្ឆាពាធោ លសិកាយ ចីវរានិ កាយេ លគ្គន្តិ តានិ មយំ ឧទកេន តេមេត្វា តេមេត្វា អបកឌ្ឍាមាតិ ។ អថ ខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ យស្ស កណ្ឌុ វា បិឡកា វា អស្សាវោ វា ថុល្លកច្ឆុ វា អាពាធោ កាយោ វា ទុគ្គន្ធោ ចុណ្ណានិ ភេសជ្ជានិ អគិលានស្ស ឆកណំ មត្តិកំ រជននិប្បក្កំ អនុជានាមិ ភិក្ខវេ ឧទុក្ខលំ មុសលន្តិ ។

(៨៣) តេន ខោ បន សមយេន គិលានានំ ភិក្ខូនំ ចុណ្ណេហិ ភេសជ្ជេហិ ចាលិតេហិ អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ



ទ្រង់ចូលទៅកាន់សំណាក់ភិក្ខុអង្គនោះ លុះចូលទៅដល់ហើយទ្រង់មានព្រះបន្ទូលត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះមានអាពាធដូចម្តេច ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះថេរៈដ៏មានអាយុនេះកើតបូសធំ ចីវរប្រឡាក់ដោយទឹករងើលជាប់ស្អិតទៅនឹងកាយ ខ្ញុំព្រះអង្គទាំងឡាយយកទឹកមកលាបចីវរទាំងនោះឲ្យសើមហើយបកចេញ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមានអាពាធ គឺកមរមាស់ក្តី បូសតូចក្តី អាពាធទឹករងើលក្តី បូសធំក្តី ឬកាយមានក្លិនអាក្រក់ តថាគតអនុញ្ញាតគ្រឿងលំអិតជាភេសជ្ជៈដល់ភិក្ខុនោះ តថាគតអនុញ្ញាតអាចម៍គោ ដីស្អិត នឹងកាកនៃគ្រឿងជ្រលក់ ដល់ភិក្ខុដែលមិនមានជម្ងឺ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតត្បាល់នឹងអង្រែ ។

(៨៣) សម័យនោះឯង ពួកភិក្ខុមានជម្ងឺមានសេចក្តីត្រូវការដោយគ្រឿងលំអិតជាភេសជ្ជៈ ដែលគេរែងរួចស្រេចហើយ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា

ភិក្ខវេ ចុណ្ណចាលិនិន្តិ ។ សណ្ហេហិ អត្ថោ ហោតិ ។ អនុជានាមិ ភិក្ខវេ ទុស្សចាលិនិន្តិ ។

[៨៦] តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ អមនុស្សិកាពាធោ ហោតិ ។ តំ អាចរិយុបជ្ឈាយា ឧបដ្ឋហន្តា នាសក្ខិំសុ អរោគំ កាតុំ ។ សោ សូករសូនំ គន្ត្វា អាមកមំសំ ខាទិ អាមកលោហិតំ បិវិ ។ តស្ស សោ អមនុស្សិកាពាធោ បដិប្បស្សម្ភិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អមនុស្សិកាពាធេ អាមកមំសំ អាមកលោហិតន្តិ ។

[៨៧] តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ ចក្ខុរោគាពាធោ ហោតិ ។ តំ ភិក្ខូ បរិគ្គហេត្វា ឧច្ចារម្បិ បស្សាវម្បិ និក្ខាមេន្តិ ។ អទ្ទសា ខោ ភគវា សេនាសនចារិកំ អាហិណ្ឌន្តោ តេ ភិក្ខូ តំ ភិក្ខុំ បរិគ្គហេត្វា



ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកញ្ច្រែងសម្រាប់រែងគ្រឿងល្អិត ។ (ពួកភិក្ខុមានជម្ងឺ)មានសេចក្តីត្រូវការដោយគ្រឿងលំអិតដ៏ល្អិតក្រៃលែង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកញ្ច្រែងសំពត់[១] ។

[៨៦] សម័យនោះឯង មានភិក្ខុ ១ រូបមានអាពាធកើតអំពីអមនុស្ស[២] ។ អាចារ្យនិងឧបជ្ឈាយ៍ជាអ្នកបម្រើភិក្ខុនោះក៏មិនអាចនឹងធ្វើភិក្ខុនោះឲ្យស្បើយរោគបាន ។ ភិក្ខុនោះទៅកាន់កន្លែងសម្លាប់ជ្រូក ហើយក៏ស៊ីសាច់ឆៅ[៣]ផឹកឈាមស្រស់[៤] ។ អាពាធរបស់ភិក្ខុនោះដែលកើតអំពីអមនុស្សនោះក៏រម្ងាប់ទៅ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសាច់ឆៅ ឈាមស្រស់ ដល់ភិក្ខុដែលមានអាពាធកើតអំពីអមនុស្ស ។

[៨៧] សម័យនោះឯង ភិក្ខុ ១ រូបមានអាពាធឈឺភ្នែក ។ ភិក្ខុទាំងឡាយតែងគ្រាហ៍ភិក្ខុនោះទៅឲ្យបន្ទោបង់ឧច្ចារៈផង បស្សាវៈផង ។ ព្រះមានព្រះភាគទ្រង់ត្រាច់ដំណើរទៅកាន់សេនាសនចារិក បានទតឃើញភិក្ខុ

១ ថង់សម្រាប់បិតគ្រឿងល្អិតមានខ្សែនៅតាមដើម ដែលហៅថា កញ្ច្រែង ។ ២ ជម្ងឺដែលពពួកបិសាចព្រាយចូល ។ ៣-៤ អដ្ឋកថាថា ភិក្ខុនោះមិនស៊ីសាច់ឆៅផឹកឈាមស្រស់នោះខ្លួនឯងទេ គឺខ្មោចដែលវាចូលភិក្ខុនោះវាស៊ីវាផឹក លុះស៊ីផឹកហើយវាចេញទៅ ។

ឧក្កាវាសិ បរស្សាវាសិ និក្ខមេត្តុ ជិស្សាន យោន តេ ភិក្ខូ ធេយ្យសង្កាមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច កិម៉- មស្ស ភិក្ខវេ ភិក្ខុនោ អាពាធោតិ ។ អយំ ភន្តេ អាយ- ស្មតោ ឧក្កាវាតាពាធោ ឥមំ មយំ បរិត្តហោតា ឧក្កាវាសិ បស្សាវាសិ និក្ខមេមាតិ ។ អថខោ ភគវា ឯតស្មិំ និទានេ ឯតស្មិំ បករណេ ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ អញ្ញនំ កាឡញ្ជនំ រសញ្ជនំ សោ- តញ្ជនំ គេរុកំ កបល្លន្តិ ។ អញ្ញនុបបិសេហិ[១] អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ចន្ទនំ តគរំ កាឡានុសារិយំ តាលីសំ ភទ្ទមុត្ត- កន្តិ ។ តេន ខោ បន សមយេន ភិក្ខូ ចុណ្ណានិ អញ្ជនានិ

១ ១. អញ្ញនុបបិសេហិ ។



ទាំងនោះកំពុងទាំងគ្នា ព្រោយភិក្ខុនោះទៅឲ្យបន្ទោបង់ចោលនូវផង បស្សាវៈផង ល្អះទទោយ៉ាញ្ញ ហើយគំរែងផ្ទួលទៅកាន់ឈើ ទៅភិក្ខុទាំងនោះ ល្អះថ្លួលទៅ ផលហើយ ទ្រង់មានក្លួក ត្រាស់នេះនឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំង ឡាយ ភិក្ខុនេះមានអាពាធដូចម្តេច ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន លោកដ៏មានអាយុនេះមានអាពាធឈឺភ្នែក ខ្ញុំ ព្រះអង្គទាំងឡាយទាំងគ្នា ព្រោយភិក្ខុនេះទៅឲ្យបន្ទោបង់ចោលនូវផង បស្សាវៈ ផង ។ គ្រោះនិមិត្តនេះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ធ្វើ ធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុ ទាំងឡាយ តថាគតអនុញ្ញាតថ្នាំបន្តក់ភ្នែក គឺថ្នាំបន្តក់ភ្នែកមានពណ៌ខ្មៅ (ដែលគេស្ងោរដោយគ្រឿងសម្ភារៈទាំងពួង) ថ្នាំបន្តក់ភ្នែកធ្វើពីរស (ដែល គេធ្វើដោយគ្រឿងសម្ភារៈផ្សេងៗ) ថ្នាំបន្តក់ភ្នែកដែលកើត ក្នុងទឹក ដែលនៅនឹងស្ទឹង (ដែលគេយកអំពីអន្លង់ស្ទឹង) ។ ពួកភិក្ខុមានសេចក្ដី ត្រូវការដោយវត្ថុដែលយកមកគិលលាយជាមួយគ្នានឹងថ្នាំបន្តក់ភ្នែក ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ខ្លឹមក្លាំពាក់ គគ្រាន ឫសស្មៅស្មៅក្រញូង ។ សម័យ នោះឯង ពួកភិក្ខុកុកថ្នាំបន្តក់ភ្នែកទាំងឡាយ ដែលជាមេម្សៅគល់សៀន

ថាលកេសុបិ សរាវកេសុបិ និក្ខិបន្តិ តិណចុណ្ណម្បិ បំសុកម្បិ ឱកិរិយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អញ្ជនិន្តិ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧច្ចាវចា អញ្ជនិយោ ធារេន្តិ សោវណ្ណមយំ រូបិយមយំ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ឧច្ចាវចា អញ្ជនី ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ អដ្ឋិមយំ ទន្តមយំ វិសាណមយំ នឡមយំ វេឡុមយំ កដ្ឋមយំ ជតុមយំ ផលមយំ លោហមយំ សង្ខនាភិមយន្តិ ។ តេន ខោ បន សមយេន អញ្ជនី អបារុតា



ទាំងឡាយខ្លះ ក្នុងថ្លុលទាំងឡាយខ្លះ (ថ្នាំបន្តក់ទាំងឡាយនោះ) ប្រឡូក ប្រឡូវទៅដោយកំទេចស្មៅទាំងឡាយខ្លះ ដោយធូលីដីទាំងឡាយខ្លះ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកញ្ចក់សម្រាប់ដាក់ថ្នាំបន្តក់ភ្នែក ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់កញ្ចក់សម្រាប់ដាក់ថ្នាំបន្តក់ភ្នែកខ្ពស់ទាប (គឺមានល្អមានអាក្រក់) គឺកញ្ចក់ធ្វើដោយមាសខ្លះ កញ្ចក់ធ្វើដោយប្រាក់ខ្លះ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថដែលបរិភោគកាមគុណ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់កញ្ចក់សម្រាប់ដាក់ថ្នាំបន្តក់ភ្នែកខ្ពស់ទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកញ្ចក់ធ្វើដោយឆ្អឹង(១) ធ្វើដោយភ្លុក ធ្វើដោយស្នែង ធ្វើដោយដើមបបុស ធ្វើដោយដើមឫស្សី ធ្វើដោយឈើ ធ្វើដោយជ័រឈើ ធ្វើដោយផ្លែឈើ ធ្វើដោយលោហធាតុ(២) ធ្វើដោយគូថស័ង្ខ ។ សម័យនោះឯង ពួកភិក្ខុមិនបានបិទកញ្ចក់សម្រាប់ដាក់ថ្នាំ

---

១ ឆ្អឹងលើកលែងតែឆ្អឹងមនុស្សចេញ ក្រៅពីនោះធ្វើអ្វីក៏បានទាំងអស់ ។ ២ គឺវត្ថុដែល ធ្វើពីធាតុស្ពាន់ ទង់ដែង ដែក សំណាំង សំណប៉ាហាំង ។

ហោន្តិ តិណចុណ្ណេហិបិ បំសុកេហិបិ ឱកិរិយន្តិ ។ ភគ-
វតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អបិធា-
នន្តិ ។ អបិធានំ និបតតិ ។ អនុជានាមិ ភិក្ខវេ សុត្តកេ-
ន ពន្ធិត្វា អញ្ជនិយា ពន្ធិតុន្តិ ។ អញ្ជនី ផលតិ ។ អនុ-
ជានាមិ ភិក្ខវេ សុត្តកេន សិព្វេតុន្តិ ។ តេន ខោ
បន សមយេន ភិក្ខូ អង្គុលិយា អញ្ជន្តិ អក្ខីនិ ទុក្ខានិ
ហោន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ
ភិក្ខវេ អញ្ជនិសលាកន្តិ ។ តេន ខោ បន សមយេន
ឆព្វគ្គិយា ភិក្ខូ ឧច្ចាវចា អញ្ជនិសលាកាយោ ធារេន្តិ
សោវណ្ណមយំ រូបិយមយំ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ
វិបាចេន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ឧច្ចាវចា អញ្ជនិសលា-
កា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជា-
នាមិ ភិក្ខវេ អដ្ឋិមយំ ទន្តមយំ វិសាណមយំ ។ បេ ។



បន្តក់ភ្នែក ត្រូវទាំងនីតាកក៏ខ្ទេចខ្ទី ដោយកំទេចស្មៅទាំងឡាយខ្លះ
ដោយអាចម៍ដីទាំងឡាយខ្លះ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏
មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអ-
នុញ្ញាតគម្របបន្តក់ ។ គម្របនោះធ្លាក់ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ
ទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុរុំបន្តក់ដោយខ្សែ ។ បន្តក់ក៏បេះ
បែក ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុ
ដេរដោយខ្សែ ។ សម័យនោះ ពួកភិក្ខុបន្តក់ភ្នែកដោយម្រាមដៃ ភ្នែកទាំង
ឡាយក៏មិនស្រួល ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះ
ភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចង្កឹះ
ថ្នាក់ ។ សម័យនោះ ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ចង្កឹះថ្នាក់ខ្ពស់ទាប
គឺចង្កឹះធ្វើដោយមាសខ្លះ ធ្វើដោយប្រាក់ខ្លះ ។ ពួកមនុស្សពោលទោស តិះ-
ដៀលបន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថអ្នកបរិភោគកាមគុណ ។ ភិក្ខុទាំង
ឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់
ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ចង្កឹះថ្នាក់ខ្ពស់
ទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគត
អនុញ្ញាតចង្កឹះដែលធ្វើដោយឆ្អឹង ធ្វើដោយភ្លុក ធ្វើដោយស្នែង ។ បេ ។ ធ្វើ

សង្ខនាភិមយន្តិ ។ តេន ខោ បន សមយេន អញ្ជនិស-លាកា ភូមិយំ បតតិ(១) ផរុសា ហោតិ ។ ភគវតោ ឯត-មត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សលាកោធានិ-យន្តិ ។ តេន ខោ បន សមយេន ភិក្ខូ អញ្ជនិម្បិ អញ្ជនិសលាកម្បិ ហត្ថេន បរិហរន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អញ្ជនិត្ថវិកន្តិ ។ អំ-សវទ្ធកោ(២) ន ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អំសវទ្ធកំ ពន្ធនសុត្តកន្តិ ។

(៤៦) តេន ខោ បន សមយេន អាយស្មតោ បិលិន្ទវច្ឆស្ស សីសាភិតាបោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ មុទ្ធនិ តេលកន្តិ ។ នក្ខមនីយោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ នត្ថុកម្មន្តិ ។ នត្ថុ គលតិ ។

១ ម. បតិតា ។ ២ ម. អំសពន្ធកោ ។



ហើយផ្ចិតសង្ខ ។ សម័យនោះ ចង្កឹះភ្នាក់ធ្លាក់ទៅលើផែនដី ចង្កឹះភ្នាក់នោះក៏គគ្រើមស្លាក ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបំពង់សម្រាប់ដាក់ចង្កឹះ ។ សម័យនោះឯង ពួកភិក្ខុកាន់ភ្នាក់សម្រាប់ដាក់ថ្នាំបន្តក់ភ្នែកផង ចង្កឹះភ្នាក់ផងទៅតែនឹងដៃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថង់សម្រាប់ដាក់ភ្នាក់ ។ ខ្សែយោងរបស់ថង់នោះក៏មិនទាន់មាន ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែយោងនិងខ្សែសម្រាប់ចង ។

(៤៦) សម័យនោះឯង ព្រះបិលិន្ទវច្ឆៈដ៏មានអាយុកើតជម្ងឺក្តៅក្បាល ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតប្រេងសម្រាប់លាបក្បាល ។ ព្រះបិលិន្ទវច្ឆៈក៏នៅតែអត់ទ្រាំរោគនោះមិនបាន ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនត្ថុកម្ម (គឺការហិតឬបញ្ចូលទៅតាមច្រមុះ) ។ ឯថ្នាំសម្រាប់ហិតឬបញ្ចូលទៅតាមច្រមុះក៏ហូរធ្លាយទៅ ។

ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ នត្ថុ-
ករណិន្តិ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ
ឧច្ចាវចា នត្ថុករណិយោ ធារេន្តិ សោវណ្ណមយំ រូបិយ-
មយំ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ សេយ្យ-
ថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោ-
ចេសុំ ។ ន ភិក្ខវេ ឧច្ចាវចា នត្ថុករណី ធារេតព្វា ។ យោ
ធារេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ អដ្ឋិមយំ
។ បេ ។ សង្ខនាភិមយន្តិ ។ នត្ថុ វិសមំ អាសិញ្ចិយ-
ន្តិ[១] ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ
ភិក្ខវេ យមកំ នត្ថុករណិន្តិ ។ នក្ខមនីយោ
ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ

---
១ ឱ. នត្ថុំ វិសមំ អាសិញ្ចន្តិ ។



ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបំពង់សម្រាប់បញ្ចូលថ្នាំតាមច្រមុះ (ដំបងនត្ថុ) ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់បំពង់នត្ថុផ្សេងៗ បំពង់នត្ថុធ្វើដោយមាសខ្លះ ធ្វើដោយប្រាក់ខ្លះ ។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថដែលបរិភោគកាមគុណ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់បំពង់នត្ថុផ្សេងៗទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបំពង់នត្ថុដែលធ្វើដោយឆ្អឹង ។ បេ ។ ធ្វើដោយខ្យងសង្ខ ។ ភិក្ខុទាំងឡាយបន្តក់ថ្នាំសម្រាប់នត្ថុមិនស្មើគ្នា[១] ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបំពង់សម្រាប់នត្ថុជាគូ[២] ។ ភិក្ខុទាំងនោះក៏នៅតែអត់ទ្រាំមិនបាន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា

---
១ ថ្នាំដែលចូលទៅតាមប្រហោងច្រមុះមិនស្មើគ្នា ខ្លះច្រើនខ្លះតិចពេក ។ ២ បំពង់ ឡើងស្មើគ្នាចូលទៅព្រមគ្នា ។

ភិក្ខវេ ធូមំ បាតុន្តិ ។ តញ្ញេវ វដ្ដឹ អាលិម្បេត្វា បិវន្តិ កណ្ឋោ ឌយ្ហតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ធូមនេត្តន្តិ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧច្ចាវចានិ ធូមនេត្តានិ ធារេន្តិ សោវណ្ណមយំ រូបិយមយំ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ឧច្ចាវចានិ ធូមនេត្តានិ ធារេតព្វានិ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ អដ្ឋិមយំ ។ បេ ។ សង្ខនាភិមយន្តិ ។ តេន ខោ បន សមយេន ធូមនេត្តានិ អបារុតានិ ហោន្តិ បាណកា បវិសន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អបិធានន្តិ ។ តេន ខោ បន សមយេន ភិក្ខូ ធូមនេត្តានិ ហត្ថេន បរិហរន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ធូមនេត្តថវិកន្តិ ។



ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យផឹកផ្សែង ។ ពួកភិក្ខុក៏យកទ្រនុំនោះមកលាបឲ្យជាប់ថ្នាំហើយផឹកទៅ (ក៏ត្រូវបំពង់ក) ក្តៅក ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវខ្សៀ ។ សម័យនោះឯង ឆព្វគ្គិយភិក្ខុប្រើប្រាស់ខ្សៀដ៏ខ្ពស់ទាប គឺខ្សៀធ្វើដោយមាសខ្លះធ្វើដោយប្រាក់ខ្លះ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថអ្នកបរិភោគកាមគុណ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ខ្សៀទាំងឡាយដ៏ខ្ពស់ទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សៀដែលធ្វើដោយឆ្អឹង ។ បេ ។ ដែលធ្វើដោយកូបសង្ខ ។ សម័យនោះឯង ភិក្ខុទាំងឡាយមិនបានបិទគម្របខ្សៀទុក សត្វតូច ៗ ក៏ចូលទៅក្នុងខ្សៀនោះ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវគម្រប ។ សម័យនោះឯង ពួកភិក្ខុកាន់ខ្សៀទៅដោយដៃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវថង់សម្រាប់ដាក់ខ្សៀ ។

ឯកតោ ឃំសិយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ យមកត្ថវិកន្តិ ។ អំសវទ្ធកោ ន ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អំសវទ្ធកំ ពន្ធនសុត្តកន្តិ ។

[៨៧] តេន ខោ បន សមយេន អាយស្មតោ បិលិន្ទវច្ឆស្ស វាតាពាធោ ហោតិ ។ វេជ្ជា ឯវមាហំសុ តេលំ បចិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តេលបាកន្តិ ។ តស្មិំ ខោ តេល- បាកេ មជ្ជំ បក្ខិបិតព្វំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តេលបាកេ មជ្ជំ បក្ខិបិតុន្តិ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អតិបក្ខិត្តមជ្ជានិ តេលានិ បចន្តិ តានិ បិវិត្វា មជ្ជន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ អតិបក្ខិត្តមជ្ជំ តេលំ បាតព្វំ យោ បិវេយ្យ យថាធម្មោ



ឯទៀតនឹងត្រូវបក់ចន្ទិតគ្នា ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវថង់ជាគូ ។ ខ្សែយោងរបស់ថង់ក៏មិនទាន់មាននៅឡើយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវខ្សែយោងនិងខ្សែសម្រាប់ចង ។

[៨៧] សម័យនោះឯង ព្រះបិលិន្ទវច្ឆមានអាពាធកើតអំពីខ្យល់ ។ ពេទ្យទាំងឡាយនិយាយយ៉ាងនេះថា ភិក្ខុត្រូវស្លប្រេង ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុស្លប្រេងបាន ។ ភិក្ខុទាំងឡាយត្រូវលាយទឹកស្រវឹងក្នុងប្រេងដែលស្លនោះ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលាយទឹកស្រវឹងក្នុងប្រេងដែលស្លបាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុស្លប្រេងលាយទឹកស្រវឹងច្រើនពេក លុះផឹកនូវប្រេងនោះក៏ស្រវឹង ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវផឹកប្រេងដែលគេលាយទឹកស្រវឹងច្រើនពេកទេ

ពាបេត្វា ។ អនុជានាមិ ភិក្ខវេ យស្មិំ តេលបាកេ មជ្ជស្ស ន វណ្ណោ ន គន្ធោ ន រសោ បញ្ញាយតិ ឯវរូបំ មជ្ជបក្ខិត្តំ តេលំ បាតុន្តិ ។ តេន ខោ បន សមយេន ភិក្ខូនំ ពហុំ អតិបក្ខិត្តមជ្ជំ តេលំ បក្កំ ហោតិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កថន្នុ ខោ អតិបក្ខិត្តមជ្ជេ តេលេ បដិបជ្ជិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អព្ភញ្ជនំ អធិដ្ឋាតុន្តិ ។ តេន ខោ បន សមយេន អាយស្មតោ បិលិន្ទវច្ឆស្ស ពហុំ[1] តេលំ បក្កំ ហោតិ ។ តេលភាជនំ ន វិជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តីណិ តុម្ពានិ លោហតុម្ពំ ការុតុម្ពំ ផលតុម្ពន្តិ ។ តេន ខោ បន សមយេន អាយស្មតោ បិលិន្ទវច្ឆស្ស អង្គវាតោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ

១ ម. ពហុំ ។



ភិក្ខុណាផឹក (ត្រូវឲ្យធ្វើទោសភិក្ខុនោះតាមធម៌)[1] ។ ម្នាលភិក្ខុទាំងឡាយ ប្រេងល្អណាដែលភិក្ខុចម្អិន គ្មានក្លិនគ្មានរសរបស់ទឹកស្រវឹងប្រាកដឡើងទេ តថាគតអនុញ្ញាតឲ្យភិក្ខុផឹកប្រេងដែលគេលាយទឹកស្រវឹងមានសភាពយ៉ាងនោះបាន ។ សម័យនោះឯង ពួកភិក្ខុស្លប្រេងលាយទឹកស្រវឹងច្រើនពេក ។ គ្រាពេលនោះ ភិក្ខុទាំងឡាយក៏មានសេចក្តីត្រិះរិះដូច្នេះថា ប្រេងដែលគេលាយនឹងទឹកស្រវឹងច្រើនពេក តើយើងត្រូវប្រតិបត្តិដូចម្តេច ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុតាំងទុកប្រេងដែលគេលាយទឹកស្រវឹងច្រើនពេកនោះជាថ្នាំកក មុណមកវិញ ។ សម័យនោះឯង ព្រះបិលិន្ទវច្ឆមានអាយុ មានប្រេងដែលស្លហើយជាច្រើន ។ តែគ្មានភាជន៍សម្រាប់ដាក់ប្រេង ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវតុម្ព (ពិកុណ្ឌទឹក) ទាំង ៣ យ៉ាង គឺតុម្ពធ្វើដោយលង្ហិនដែក ១ តុម្ពធ្វើដោយឈើ ១ តុម្ពធ្វើដោយផ្លែឈើ ១ ។ សម័យនោះឯង ព្រះបិលិន្ទវច្ឆមានអាយុកើតរោគខ្យល់ក្នុងអវយវៈ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គ

១ ត្រង់ឃ្លានេះសំដែងអាបត្តិបាចិត្តិយចេញ ។

សេទកម្មន្តិ ។ ន ក្ខមនីយោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សម្ភារសេទន្តិ ។ ន ក្ខមនីយោ ហោតិ ។ អនុជានាមិ ភិក្ខវេ មហាសេទន្តិ ។ ន ក្ខមនីយោ ហោតិ ។ អនុជានាមិ ភិក្ខវេ ភង្គោទកន្តិ ។ ន ក្ខមនីយោ ហោតិ ។ អនុជានាមិ ភិក្ខវេ ឧទកកោដ្ឋកន្តិ ។

(៨៨) តេន ខោ បន សមយេន អាយស្មតោ បិលិន្ទវច្ឆស្ស បព្វវាតោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ លោហិតំ មោចេតុន្តិ ។



ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសេទកម្ម (ការធ្វើឲ្យចេញញើស) ។ ព្រះបិលិន្ទវច្ឆមានអាយុក៏នៅតែតក់ត្រាំមិនធូរ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្អើនដោយស្លឹកឈើនិងមែកឈើផ្សេងៗ ។ ព្រះបិលិន្ទវច្ឆមានអាយុក៏នៅតែតក់ត្រាំមិនធូរ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យផ្អើនធំ[១] ។ ព្រះបិលិន្ទវច្ឆមានអាយុក៏នៅតែតក់ត្រាំមិនធូរ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកដែលដាំស្ងោរលាយនឹងស្លឹកឈើ មែកឈើផ្សេងៗ ។ ព្រះបិលិន្ទវច្ឆមានអាយុក៏នៅតែតក់ត្រាំមិនធូរ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបន្ទប់ទឹក[២] ។

(៨៨) សម័យនោះឯង ព្រះបិលិន្ទវច្ឆមានអាយុកើតរោគខ្យល់ចុកសៀតក្នុងសន្លាក់ដៃជើងជាដើម ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុគ្រើឈាមឲ្យហូរចេញផុត ។

១ អដ្ឋកថា ជា ត្រូវគេរ៉ាកើតភ្លើងឲ្យក្តៅក្នុងរណ្តៅឲ្យល្មមប្រមាណមួយជំហរបុរស រួចបំបែករណ្តៅនោះដោយភក់ខ្សាច់ដីឲ្យរាបស្មើហើយ ក្រាលស្លឹកឈើផ្សេងៗលើរណ្តៅនោះហើយ យកប្រេងលាបខ្លួនដេកត្រដេតលើរណ្តៅនោះឲ្យចេញញើសគឺស្រីរៈ ។ ២ អដ្ឋកថា ជា ស្រះដាក់ទឹកក្តៅឲ្យពេញក្នុងកាដធំឬស្នូកហើយចូលទៅធ្វើការងូតក្នុងបន្ទប់ទឹកនោះ ។

នក្ខមនីយោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ លោហិតំ មោចេត្វា វិសាណេន គាហេតុន្តិ ។

(៨៩) តេន ខោ បន សមយេន អាយស្មតោ បិលិន្ទវច្ឆស្ស បាទា ផាលិតា ហោន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បាទព្ភញ្ជនន្តិ ។ នក្ខមនីយោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បជ្ជំ អភិសង្ខរិតុន្តិ ។

(៩០) តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ គណ្ឌាពាធោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សត្ថកម្មន្តិ ។ កសាវោទកេន អត្ថោ ហោតិ ។ អនុជានាមិ ភិក្ខវេ កសាវោទកន្តិ ។ តិលកក្កេន អត្ថោ ហោតិ ។ អនុជានាមិ ភិក្ខវេ តិលកក្កន្តិ ។ កពឡិកាយ អត្ថោ



ព្រះបិលិន្ទវច្ឆមានអាយុក៏នៅតែអត់ទ្រាំមិនបាន ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផប់យកឈាមដោយ (ប៉ពង់) ស្នែងបាន ។

(៨៩) សម័យនោះឯង ព្រះបិលិន្ទវច្ឆមានអាយុមានបាទាបែក ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថ្នាំសម្រាប់លាបជើង ។ ព្រះបិលិន្ទវច្ឆមានអាយុក៏នៅតែអត់ទ្រាំមិនបាន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុតាក់តែងទឹកស្រៃ (សម្រាប់លាបជើងឲ្យស្រួល) ។

(៩០) សម័យនោះឯង ភិក្ខុមួយរូបមានអាពាធកើតពក ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសត្ថកម្ម (វះដោយកាំបិត) ។ (ភិក្ខុនោះ) មានសេចក្តីត្រូវការដោយទឹកចត់ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកចត់ ។ (ភិក្ខុនោះ) មានសេចក្តីត្រូវការដោយម្សៅល្ង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតម្សៅល្ង ។ (ភិក្ខុនោះ) មានសេចក្តីត្រូវការដោយដុំសំឡី

ហោតិ ។ អនុជានាមិ ភិក្ខវេ កពឡិកន្តិ ។ វណពន្ធន-
ចោឡេន អត្ថោ ហោតិ ។ អនុជានាមិ ភិក្ខវេ វណ-
ពន្ធនចោឡន្តិ ។ វណោ កណ្ឌុវតិ ។ អនុជានាមិ
ភិក្ខវេ សាសបកុដ្ឋេន ផោសិតុន្តិ ។ វណោ កិលិជ្ជិត្ថ ។
អនុជានាមិ ភិក្ខវេ ធូមំ កាតុន្តិ ។ វឌ្ឍមំសំ វុដ្ឋាតិ ។
អនុជានាមិ ភិក្ខវេ លោណសក្ខរិកាយ ឆិន្ទិតុន្តិ ។
វណោ ន រូហតិ ។ អនុជានាមិ ភិក្ខវេ វណតេលន្តិ ។
តេលំ គលតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុ-
ជានាមិ ភិក្ខវេ វិកាសិកំ សព្វំ វណបដិកម្មន្តិ ។

[៩១] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ
អហិនា ទដ្ឋោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោ-
ចេសុំ ។ អនុជានាមិ ភិក្ខវេ ចត្តារិ មហាវិកដានិ ទាតុំ



(សម្រាប់បិទមុខដំបៅ) ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកន្ទុំសណ្តូរ ភិក្ខុទាំងឡាយមានសេចក្តីត្រូវការដោយសំពត់សម្រាប់រុំដំបៅ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតំណាត់សំពត់សម្រាប់រុំដំបៅ ។ ដំបៅរមាស់ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលាបដោយម្សៅគ្រាប់ស្ពៃ ។ ដំបៅក៏ទទេឡើង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបំពុយដំបៅនោះ ។ (លុះបំពុយទៅហើយ) សាច់ក៏ដុះល្បៀនចេញមក ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុយកកំទេចឈាមនិងអំបិលក្រួសមកបន្តក់ (ដំបៅនោះចេញ) ។ (លុះបន្តក់ទៅហើយ) ដំបៅក៏មិនបានដុះសាច់ឡើង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតប្រេងសម្រាប់លាបដំបៅ ។ ប្រេងក៏ហៀរហូរចេញ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់សម្រាប់បិទប្រេងនិងថ្នាំគ្រប់ដំបៅទាំងអស់ ។

[៩១] សម័យនោះឯង មានភិក្ខុ១រូបពស់ចឹក ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យថ្នាំមហាវិកដ ៤ យ៉ាង

គូថំ មុត្តំ ឆារិកំ មត្តិកន្តិ ។ អថខោ ភិក្ខូនំ ឯតទហោសិ អប្បដិគ្គហិតានិ នុ ខោ ឧទាហុ បដិគ្គហេតព្វានីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សតិ កប្បិយការកេ បដិគ្គហាបេតុំ អសតិ កប្បិយការកេ សាមំ គហេត្វា បរិភុញ្ជិតុន្តិ ។ តេន ខោ បន សមយេន អញ្ញតរេន ភិក្ខុនា វិសំ បីតំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ គូថំ បាយេតុន្តិ ។ អថខោ ភិក្ខូនំ ឯតទហោសិ អប្បដិគ្គហិតោ នុ ខោ ឧទាហុ បដិគ្គហេតព្វោតិ[១] ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ យំ ករោន្តោ បដិគ្គណ្ហាតិ ស្វេវ បដិគ្គហោ កតោ ន បុន បដិគ្គហេតព្វោតិ ។

១ ម. បដិគ្គហេតព្វោ ។



គឺគូថ (លាមក)១ ទឹកមូត្រ (ទឹកនោម)១ ផេះ១ ដី១ ។ ក្នុងពេលនោះ ភិក្ខុទាំងឡាយ មានសេចក្ដីរង្កៀសថា យើងមិនបានទទួលប្រគេន ថ្នាំទាំងនេះទេ ឬត្រូវតែទទួលប្រគេនទើបបាន ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើមានកប្បិយការក:[១] តថាគតអនុញ្ញាតឲ្យភិក្ខុប្រើកប្បិយការក:នោះទទួលដំកល់បាន កាលបើគ្មានកប្បិយការក:ទេ តថាគតអនុញ្ញាតឲ្យភិក្ខុកាន់យកខ្លួនឯងហើយឆាន់ចុះ ។ សម័យនោះឯង ភិក្ខុ១រូបផឹកថ្នាំពិស ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផឹកគូថ (លាមកដែលលាយដោយទឹក) ។ ក្នុងពេលនោះ ភិក្ខុទាំងនោះមានសេចក្ដីរង្កៀសថា យើងមិនបានទទួលប្រគេន (នូវគូថនោះ) ទេ ឬថាត្រូវតែទទួលប្រគេនទើបបាន ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដូច្នេះ កាលបើភិក្ខុបន្ទោបង់គូថណាហើយបានទទួលទុក (ទុកថ្ងៃមុខ) លុះដល់ទៅថ្ងៃស្អែក គូថនោះឈ្មោះថាភិក្ខុបានទទួលរួចហើយ មិនបាច់ទទួលប្រគេនទៀតទេ ។

១ សំដៅយកបុគ្គលដែលប្រើសម្រាប់ធ្វើវត្ថុមិនគួរ ឲ្យជាវត្ថុគួរ ។

(៩២) តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ ឃរទិន្នកាពាធោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សីតាលោឡឹ បាយេតុន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ទុដ្ឋគហណិកោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អាមិសខារំ បាយេតុន្តិ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ បណ្ឌុរោគាពាធោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ មុត្តហរីតកំ បាយេតុន្តិ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ ឆវិទោសាពាធោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ គន្ធាលេបំ កាតុន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អភិសន្នកាយោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ វិរេចនំ បាតុន្តិ ។ អច្ឆកញ្ជិយ



(៩៦) សម័យនោះឯង ភិក្ខុ ១ រូបមានអាពាធព្រោះគ្រឿងស្នេហ៍ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផឹកទឹកលាយដោយភក់បំណាស់(១) ។ សម័យនោះឯង ភិក្ខុ ១ រូបមានអាពាធខូចធាតុភ្លើង(កើតរោគមួល) ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផឹកទឹកក្បុង(២) ។ សម័យនោះឯង ភិក្ខុ ១ រូបកើតរោគស្លេកលឿង ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់សម៉ដែលត្រាំដោយទឹកនោម(៣) ។ សម័យនោះឯង ភិក្ខុ ១ រូបមានអាពាធខូចសម្បុរ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើការលាបដោយគ្រឿងក្រអូប ។ សម័យនោះឯង ភិក្ខុមួយរូបមានកាយប្រកបដោយរោគទល់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផឹកថ្នាំបញ្ចុះ ។ (ភិក្ខុនោះ) មានសេចក្តីត្រូវការដោយ

១ ព្រះអង្គទ្រង់អនុញ្ញាតឲ្យភិក្ខុយកអាចម៍បំណាស់ដែលជាប់នឹងកាលនង្គ័លមកលាយនឹងទឹក ហើយផឹក ។ ២ អដ្ឋកថា ថា ឲ្យយកបាយមកដុតនឹងភ្លើងឲ្យឆេះជាផេះហើយច្រោះត្រងយក

អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អច្ឆកញ្ជិកន្តិ ។ អកដយូសេន អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អកដយូសន្តិ ។ កដាកដេន អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ កដាកដន្តិ ។ បដិច្ឆាទនីយេន អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បដិច្ឆាទនីយន្តិ ។

(៤៣) តេន ខោ បន សមយេន អាយស្មា បិលិន្ទវច្ឆោ រាជគហេ បព្ភារំ សោធាបេតិ លេណំ កត្តុកាមោ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ យេន អាយស្មា បិលិន្ទវច្ឆោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ បិលិន្ទវច្ឆំ អភិវាទេត្វា ឯកមន្តំ



ទឹកអង្ករថ្លា ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវទឹកអង្ករថ្លា ។ (ភិក្ខុទាំងនោះ) មានសេចក្តីត្រូវការដោយទឹកសណ្តែកបាយស្ងោរដែលគេមិនបានធ្វើឲ្យស្ងួត (គឺគេមិនបានគ្រឿងឲ្យស្អាតល្អ) ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកសណ្តែកបាយស្ងោរដែលគេមិនបានធ្វើឲ្យស្ងួត ។ (ភិក្ខុទាំងនោះ) មានសេចក្តីត្រូវការដោយទឹកសណ្តែកបាយស្ងោរដែលគេធ្វើឲ្យស្ងួត (គេបានគ្រឿងឲ្យស្អាតល្អ) ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកសណ្តែកបាយស្ងោរដែលគេធ្វើឲ្យស្ងួត ។ (ភិក្ខុទាំងនោះ) មានសេចក្តីត្រូវការដោយសាច់ដែលមានខ្ទិះស ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសាច់ដែលមានខ្ទិះស ។

(៤៣) សម័យនោះឯង ព្រះបិលិន្ទវច្ឆដ៏មានអាយុឲ្យគេជម្រះញកភ្នំក្បែរក្រុងរាជគ្រឹះ ព្រោះប្រាថ្នានឹងធ្វើរូងឲ្យទៅជាលេណ ។ គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារ យាងចូលទៅរកព្រះបិលិន្ទវច្ឆដ៏មានអាយុ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះបិលិន្ទវច្ឆដ៏មានអាយុ

និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ អាយស្មន្តំ បិលិន្ទវច្ឆំ ឯតទវោច កឹ ភន្តេ ថេរោ ការាបេតីតិ ។ បព្ភារំ មហារាជ សោធាបេមិ លេណំ កត្តុកាមោតិ ។ អត្ថោ ភន្តេ អយ្យស្ស អារាមិកេនាតិ ។ ន ខោ មហារាជ ភគវតា អារាមិកោ អនុញ្ញាតោតិ ។ តេនហិ ភន្តេ ភគវន្តំ បដិបុច្ឆិត្វា មម អារោចេយ្យាថាតិ ។ ឯវំ មហារាជាតិ ខោ អាយស្មា បិលិន្ទវច្ឆោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស បច្ចស្សោសិ ។ អថខោ អាយស្មា បិលិន្ទវច្ឆោ រាជានំ មាគធំ សេនិយំ ពិម្ពិសារំ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ អាយស្មតា បិលិន្ទវច្ឆេន ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា អាយស្មន្តំ បិលិន្ទវច្ឆំ អភិវាទេត្វា បទក្ខិណំ កត្វា



រួចគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះបាទមាគធរាជសេនិយពិម្ពិសារគង់ក្នុងទីដ៏សមគួរហើយ ក៏ទ្រង់មានព្រះបន្ទូលនឹងព្រះបិលិន្ទវច្ឆមានអាយុថា បពិត្រលោកដ៏ចំរើន ព្រះថេរៈប្រើឲ្យគេធ្វើអ្វី ។ ព្រះបិលិន្ទវច្ឆឆ្លើយថា បពិត្រមហារាជ អាត្មាភាពឲ្យគេជម្រះជង្រុកភ្នំ ព្រោះចង់ធ្វើគុហាទីដេក ។ ស្តេចសួរថា បពិត្រលោកដ៏ចំរើន លោកម្ចាស់មានសេចក្តីត្រូវការដោយអារាមិកជន[១] ដែរឬ ។ ព្រះបិលិន្ទវច្ឆឆ្លើយថា បពិត្រមហារាជ ព្រះដ៏មានព្រះភាគមិនទាន់អនុញ្ញាតអារាមិកជននៅឡើយទេ ។ ស្តេចទ្រង់មានព្រះបន្ទូលថា បពិត្រលោកដ៏ចំរើន បើដូច្នោះ សូមលោកក្រាបទូលសួរព្រះដ៏មានព្រះភាគហើយមកប្រាប់វិញ ។ ព្រះបិលិន្ទវច្ឆមានអាយុទទួលស្តាប់ព្រះបន្ទូលនៃព្រះបាទមាគធរាជសេនិយពិម្ពិសារដោយពាក្យថា សូមថ្វាយព្រះពរ មហារាជ ។ ព្រះបិលិន្ទវច្ឆមានអាយុក៏បានពន្យល់ព្រះបាទមាគធរាជសេនិយពិម្ពិសារឲ្យទ្រង់ឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហាន ឲ្យត្រេកអរ ដោយធម្មីកថា ។ លំដាប់នោះ ព្រះបាទមាគធរាជសេនិយពិម្ពិសារ កាលដែលព្រះបិលិន្ទវច្ឆមានអាយុបានពន្យល់ឲ្យទ្រង់ឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហាន ឲ្យត្រេកអរ ដោយធម្មីកថា រួចហើយក៏ទ្រង់ក្រោកចាកអាសនៈថ្វាយបង្គំព្រះបិលិន្ទវច្ឆមានអាយុ ធ្វើប្រទក្សិណហើយចៀស

១ ជនសម្រាប់ធ្វើការក្នុងអារាម

បក្កាមិ ។ អថខោ អាយស្មា បិលិន្ទវច្ឆោ ភគវតោ សន្តិកេ ទូតំ បាហេសិ រាជា ភន្តេ មាគធោ សេនិយោ ពិម្ពិសារោ អារាមិកំ ទាតុកាមោ កថំ នុ ខោ ភន្តេ បដិបជ្ជិតព្វន្តិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជា-នាមិ ភិក្ខវេ អារាមិកន្តិ ។ ទុតិយម្បិ ខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ យេនាយស្មា បិលិន្ទ-វច្ឆោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ បិលិន្ទវច្ឆំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ អាយស្មន្តំ បិលិន្ទវច្ឆំ ឯតទវោច អនុញ្ញាតោ ភន្តេ ភគវតា អារា-មិកោតិ ។ ឯវំ មហារាជាតិ ។ តេនហិ ភន្តេ អយ្យស្ស អារាមិកំ ទម្មីតិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ អាយស្មតោ បិលិន្ទវច្ឆស្ស អារាមិកំ ប-ដិស្សុណិត្វា វិស្សរិត្វា ចិរេន សតឹ បដិលភិត្វា អញ្ញតរំ



ចេញទៅ ។ ក្រោយពីនោះមក ព្រះបិលិន្ទវច្ឆដ៏មានអាយុបានប្រើបម្រើ ឲ្យទៅកាន់សំណាក់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់មានសេចក្តីប្រាថ្នានឹងប្រគេនខ្ញុំអារាមិកជន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្តេចទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅពួកភិក្ខុមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យភិក្ខុទទួល) អារាមិកជន ។ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់ចូលទៅកាន់សំណាក់ព្រះបិលិន្ទវច្ឆដ៏មានអាយុជាគំរប់ពីរដង លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះបិលិន្ទវច្ឆដ៏មានអាយុ ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់គង់ក្នុងទីដ៏សមគួរហើយក៏ទ្រង់មានព្រះបន្ទូលសួរនេះ នឹងព្រះបិលិន្ទវច្ឆដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ព្រះដ៏មានបុណ្យទ្រង់បានអនុញ្ញាតអារាមិកជនហើយឬ ។ ព្រះបិលិន្ទវច្ឆឆ្លើយថា ថ្វាយព្រះពរ មហារាជ ។ ព្រះបាទមាគធសេនិយពិម្ពិសារទ្រង់មានព្រះបន្ទូលថា បពិត្រលោកដ៏ចំរើន បើដូច្នោះ ខ្ញុំព្រះករុណានឹងប្រគេនអារាមិកជនដល់លោកម្ចាស់ ។ គ្រានោះឯង ព្រះបាទមាគធសេនិយពិម្ពិសារទទួលថា នឹងប្រគេនអារាមិកជនដល់ព្រះបិលិន្ទវច្ឆដ៏មានអាយុហើយក៏ទ្រង់ភ្លេចទៅ លុះយូរមកទើបបានទ្រង់រឭកឃើញ

សត្តមំ មហាមត្តំ អាមន្តេសិ យោ មយា ករណេ អយ្យស្ស អារាមិកោ បដិស្សុតោ ទិន្នោ សោ អារាមិកោតិ ។ ន តាវ ទេវ អយ្យស្ស អារាមិកោ ទិន្នោតិ ។ កីវចិរំ នុ ខោ ករណេ ឥតោ វត្តេ(១) ហោតីតិ ។ អថខោ សោ មហាមត្តោ រត្តិយោ គណេត្វា(២) បញ្ចាហំ មាគធំ សេនិយំ ពិម្ពិសារំ បវេទេសិ បញ្ច ទេវ រត្តិសតានីតិ ។ តេនហិ ករណេ អយ្យស្ស បញ្ច អារាមិកសតានិ ទេហីតិ(៣) ។ ឯវំ ទេវាតិ ខោ សោ មហាមត្តោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស បដិស្សុណិត្វា អាយស្មតោ បិលិន្ទវច្ឆស្ស បញ្ច អារាមិកសតានិ អទាសិ(៤) ។ បាដិយេក្កោ គាមោ និវិសិ ។ អារាមិកគាមកោតិបិ នំ អាហំសុ បិលិន្ទវច្ឆគាមកោតិបិ(៥) នំ អាហំសុ ។

[៩៦] តេន ខោ បន សមយេន អាយស្មា បិលិន្ទវច្ឆោ តស្មឹ គាមកេ កុលូបកោ ហោតិ ។ អថខោ អាយស្មា បិលិន្ទវច្ឆោ បុព្វណ្ហសមយំ និវាសេត្វា

១ ម. ហេតំ ។ ២ ម. វិគណេត្វា ។ ៣ ម. ទេហីតិ ។ ៤ ម. អទាសិ ។ ៥ ម. បិលិន្ទគាមកោតិបិ ។



ក៏មានព្រះបន្ទូលហៅមហាមាត្យម្នាក់ជាអ្នកសម្រេចកិច្ចការទាំងពួងថា ម្នាលនាយ អារាមិកជនណាដែលអញទទួលថា នឹងប្រគេនដល់លោកម្ចាស់ អារាមិកជននោះគេអញបានប្រគេនហើយឬ ។ មហាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះអង្គមិនទាន់បានប្រគេនអារាមិកជនដល់លោកម្ចាស់នៅឡើយទេ ។ ព្រះបាទពិម្ពិសារត្រាស់សួរថា ម្នាលនាយ តាំងពីថ្ងៃនោះមកដល់សព្វថ្ងៃនេះ កើតឡើងប៉ុន្មានរាត្រីហើយ ។ មហាមាត្យនោះបានរាប់រាត្រីទាំងឡាយ (ឃើញ) ហើយក៏ក្រាបបង្គំទូលព្រះបាទមាគធសេនិយពិម្ពិសារក្នុងវេលានោះថ្លែងថា បពិត្រព្រះសម្មតិទេព (បើគិតតាំងពីថ្ងៃនោះដល់មកថ្ងៃនេះ) ចំនួនប្រាំរយរាត្រីហើយ ។ ស្ដេចទ្រង់មានព្រះបន្ទូលថា ម្នាលនាយ បើដូច្នោះ ចូរអ្នកឯងប្រគេនអារាមិកជនប្រាំរយនាក់ដល់លោកម្ចាស់ចុះ ។ មហាមាត្យនោះ ទទួលស្ដាប់ព្រះបន្ទូលព្រះបាទមាគធសេនិយពិម្ពិសារ ដោយពាក្យថា ព្រះករុណាថ្លៃវិសេស ហើយក៏ប្រគេនអារាមិកជនប្រាំរយនាក់ដល់ព្រះបិលិន្ទវច្ឆដ៏មានអាយុ ។ (តាំងពីវេលានោះមក) ស្រុក (នោះ) ក៏តាំងនៅជាស្រុកមួយដោយឡែក ។ ពួកជនក៏ហៅស្រុកនោះថា អារាមិកគ្រាមខ្លះ បិលិន្ទវច្ឆគ្រាមខ្លះ ។

[៩៦] សម័យនោះឯង ព្រះបិលិន្ទវច្ឆដ៏មានអាយុជាជីតុន(១)ក្នុងស្រុកនោះ ។ គ្រានោះឯង ព្រះបិលិន្ទវច្ឆដ៏មានអាយុស្លៀកស្បង់តាំងពីព្រឹក

១ ជាអ្នកចាប់ចិត្តនៃត្រកូល ។

បត្តចីវរមាទាយ បិលិន្ទគាមកំ បិណ្ឌាយ បាវិសិ ។ តេន ខោ បន សមយេន តស្មឹ គាមកេ ឧស្សវោ ហោតិ ។ ទារកា អលង្កតា មាលាកិតា កីឡន្តិ ។ អថខោ អាយស្មា បិលិន្ទវច្ឆោ បិលិន្ទគាមកេ សបទានំ បិណ្ឌាយ ចរមានោ យេន អញ្ញតរស្ស អារាមិកស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ តេន ខោ បន សមយេន តស្សា អារាមិកិនិយា ធីតា អញ្ញេ ទារកេ អលង្កតេ មាលាកិតេ បស្សិត្វា រោទតិ មាលំ មេ ទេថ អលង្ការំ មេ ទេថាតិ ។ អថខោ អាយស្មា បិលិន្ទវច្ឆោ តំ អារាមិកិនឹ ឯតទវោច កិស្សាយំ ទារិកា រោទតីតិ ។ អយំ ភន្តេ ទារិកា អញ្ញេ ទារកេ អលង្កតេ មាលាកិតេ បស្សិត្វា រោទតិ មាលំ មេ ទេថ អលង្ការំ មេ ទេថាតិ កុតោ អម្ហាកំ ទុគ្គតានំ មាលា កុតោ អលង្ការោតិ ។ អថខោ



ហើយប្រដាប់ប្រដាយបាត្រនិងចីវរចូលទៅកាន់បិលិន្ទគ្រាម ដើម្បីបិណ្ឌបាត ។ សម័យនោះឯង ក្នុងស្រុកនោះមានល្បែងមហោស្រព ។ ក្មេងទារក(១)ក៏បានប្រដាប់ខ្លួនស្អិតស្អាងដោយកម្រងផ្កាហើយលេងមហោស្រព ។ គ្រាពេលនោះ ព្រះបិលិន្ទវច្ឆមានអាយុបានត្រាច់ទៅបិណ្ឌបាតតាមលំដាប់ត្រកូលក្នុងបិលិន្ទគ្រាម ហើយចូលទៅកាន់ផ្ទះអារាមិកជនម្នាក់ លុះចូលទៅដល់ហើយក៏គង់លើអាសនៈដែលគេក្រាលប្រគេន ។ សម័យនោះឯង ធីតា(២)របស់ប្រពន្ធអារាមិកជននោះឃើញក្មេងទារកដទៃប្រដាប់ខ្លួនស្អិតស្អាងដោយកម្រងផ្កា ក៏យំថា អ្នកម៉ែ ចូរឲ្យកម្រងផ្កាដល់ខ្ញុំ អ្នកម៉ែ ចូរឲ្យគ្រឿងប្រដាប់ដល់ខ្ញុំ ។ គ្រាពេលនោះ ព្រះបិលិន្ទវច្ឆមានអាយុបានពោលពាក្យនេះនឹងប្រពន្ធរបស់អារាមិកជននោះថា ព្រោះហេតុអ្វីបានជាទារិកា(៣)នេះយំ ។ ប្រពន្ធរបស់អារាមិកជននោះឆ្លើយថា បពិត្រលោកដ៏ចំរើន ទារិកានេះឃើញក្មេងទារកដទៃប្រដាប់ខ្លួនស្អិតស្អាងដោយកម្រងផ្កា ក៏យំថា អ្នកម៉ែ ចូរឲ្យកម្រងផ្កាដល់ខ្ញុំ អ្នកម៉ែ ចូរឲ្យគ្រឿងប្រដាប់ដល់ខ្ញុំផង ដូច្នេះ ឯយើងខ្ញុំទាំងនេះក្រីក្រជាអ្នកកំសត់ នឹងបានកម្រងផ្កាមកពីណា នឹងបានគ្រឿងប្រដាប់មកពីណា ។ គ្រានោះឯង ព្រះបិលិន្ទវច្ឆ

១ ក្មេងប្រុស ។ ២ កូនស្រី ។ ៣ ក្មេងស្រី ។

អាយស្មា បិលិន្ទវច្ឆោ អញ្ញតរំ តិណណ្ឌុបកំ គហេត្វា តំ អារាមិកិនឹ ឯតទវោច ហន្ទិមំ តិណណ្ឌុបកំ តស្សា ទារិកាយ សីសេ បដិមុញ្ចាហីតិ(១) ។ អថខោ សា អារាមិកិនី តំ តិណណ្ឌុបកំ គហេត្វា តស្សា ទារិកាយ សីសេ បដិមុញ្ចិ ។ សា អហោសិ សុវណ្ណមាលា អភិរូបា ទស្សនីយា បាសាទិកា ។ នត្ថិ តាទិសា រញ្ញោបិ អន្តេបុរេ សុវណ្ណមាលា ។ មនុស្សា រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស អារោចេសុំ អមុកស្ស ទេវ អារាមិកស្ស ឃរេ សុវណ្ណមាលា អភិរូបា ទស្សនីយា បាសាទិកា នត្ថិ តាទិសា ទេវស្សបិ អន្តេបុរេ សុវណ្ណមាលា កុតោ តស្ស ទុគ្គតស្ស និស្សំសយំ ចោរិកាយ អាភតាតិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ តំ អារាមិកកុលំ ពន្ធាបេសិ ។ ទុតិយម្បិ ខោ អាយស្មា បិលិន្ទវច្ឆោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ បិលិន្ទវច្ឆគាមកំ បិណ្ឌាយ បាវិសិ បិលិន្ទវច្ឆគាមកេ សបទានំ បិណ្ឌាយ ចរមានោ យេន តស្ស អារាមិកស្ស និវេសនំ

(១) បដិមុញ្ចាហិ ។



ដ៏មានអាយុកាន់យកកម្រងស្មៅមួយហើយ និយាយដូច្នេះនឹងស្ត្រីអារាមិកជននោះថា បើដូច្នោះនាងចូរពាក់កម្រងស្មៅនេះលើក្បាលទារិកានោះចុះ ។ លំដាប់ស្ត្រីអារាមិកជននោះក៏កាន់យកកម្រងស្មៅនោះហើយពាក់លើក្បាលទារិកានោះ ។ កម្រងស្មៅនោះក៏ក្លាយទៅជាកម្រងផ្កាមាស ល្អល្អះ គួរពិតពិលមើល ជាទីនាំឲ្យកើតសេចក្ដីជ្រះថ្លា ។ ទុកជាក្នុងព្រះរាជដំណាក់ក៏គ្មានកម្រងផ្កាមាសបែបនោះឡើយ ។ ពួកមនុស្សក៏ក្រាបបង្គំទូលព្រះបាទមាគធសេនិយពិម្ពិសារថា បពិត្រព្រះសម្មតិទេព ក្នុងផ្ទះអារាមិកជនឯណោះ មានកម្រងផ្កាមាស ល្អល្អះ គួរពិតពិលមើល ជាទីនាំឲ្យកើតសេចក្ដីជ្រះថ្លា ទុកជាក្នុងព្រះរាជវាំងរបស់ព្រះករុណាក៏គ្មានកម្រងផ្កាមាសបែបនោះឡើយ អារាមិកជននោះជាអ្នកកំសត់ទុគ៌ត នឹងមានកម្រងផ្កាមាសពីណា ប្រាកដជាលួចគេយកមកមិនខានឡើយ ។ គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារទ្រង់ប្រើឲ្យមនុស្សទៅចាប់ចងត្រកូលអារាមិកជននោះ ។ លុះវេលាព្រឹកព្រហាមឡើងជាថ្ងៃទីពីរ ព្រះបិលិន្ទវច្ឆៈដ៏មានអាយុស្លៀកស្បង់ប្រដាប់បាត្រនិងចីវរហើយចូលទៅបិណ្ឌបាតក្នុងបិលិន្ទវច្ឆគ្រាម កាលទៅត្រាច់បិណ្ឌបាតតាមលំដាប់ច្រកក្នុងបិលិន្ទវច្ឆគ្រាមហើយក៏ចូលទៅកាន់ផ្ទះអារាមិកជននោះ លុះចូលទៅដល់

តេនុបសង្កមិ ឧបសង្កមិត្វា បដិវិស្សកេ បុច្ឆិ កហំ ឥទំ(១) អារាមិកកុលំ គតន្តិ ។ ឯតិស្សា ភន្តេ សុវណ្ណមាលាយ ការណា រញ្ញា ពន្ធាបិតន្តិ ។ អថ ខោ អាយស្មា បិលិន្ទវច្ឆោ យេន រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថ ខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ យេនាយស្មា បិលិន្ទវច្ឆោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ បិលិន្ទវច្ឆំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ រាជានំ មាគធំ សេនិយំ ពិម្ពិសារំ អាយស្មា បិលិន្ទវច្ឆោ ឯតទវោច កិស្ស មហារាជ អារាមិកកុលំ ពន្ធាបិតន្តិ ។ តស្ស ភន្តេ អារាមិកស្ស ឃរេ សុវណ្ណមាលា អភិរូបា ទស្សនីយា បាសាទិកា នត្ថិ តាទិសា អម្ហាកម្បិ អន្តេបុរេ សុវណ្ណមាលា កុតោ តស្ស ទុគ្គតស្ស និស្សំសយំ ចោរិកាយ អាភតាតិ ។ អថ ខោ អាយស្មា បិលិន្ទវច្ឆោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស បាសាទំ សុវណ្ណន្តិ អធិមុច្ចិ ។ សោ អហោសិ សព្វសោវណ្ណ-

១ ម. ឥមំ ។



ហើយក៏សួរពួកមនុស្សដែលនៅជិតខាងថា ត្រកូលអារាមិកជននេះទៅឯណា ។ ពួកមនុស្សដែលនៅជិតខាងឆ្លើយថា បពិត្រលោកដ៏ចំរើន ត្រកូលអារាមិកជននេះស្ដេចឲ្យចាប់ចងយកទៅហើយ ព្រោះហេតុតែកម្រងផ្កាមាស (ដែលលោកម្ចាស់ឲ្យទៅ) នុ៎ះ ។ ឯព្រះបិលិន្ទវច្ឆមានអាយុក៏ចូលទៅកាន់ព្រះរាជនិវេសន៍របស់ព្រះបាទមាគធរាជសេនិយពិម្ពិសារ លុះចូលទៅដល់ហើយក៏គង់លើអាសនៈដែលគេក្រាលប្រគេន ។ គ្រានោះ ព្រះបាទមាគធរាជសេនិយពិម្ពិសារចូលទៅរកព្រះបិលិន្ទវច្ឆមានអាយុ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះបិលិន្ទវច្ឆមានអាយុហើយគង់ក្នុងទីសមគួរ លុះព្រះបាទមាគធរាជសេនិយពិម្ពិសារគង់ក្នុងទីសមគួរហើយ ព្រះបិលិន្ទវច្ឆមានអាយុបានថ្វាយព្រះពរសួរថា បពិត្រមហារាជ ហេតុអ្វីបានជាព្រះអង្គឲ្យគេចាប់ចងត្រកូលអារាមិកជនមក ។ ព្រះបាទពិម្ពិសារឆ្លើយថា បពិត្រលោកម្ចាស់ ព្រោះក្នុងផ្ទះអារាមិកជននោះមានកម្រងផ្កាមាសល្អល្អះ គួរពិតពិលរមិលរមើលជាទីនាំឲ្យកើតសេចក្ដីជ្រះថ្លា ទុកជាខាងក្នុងនៃវាំងរបស់ខ្ញុំក៏រកកម្រងផ្កាបែបនេះគ្មានដែរ អារាមិកជននោះជាមនុស្សកំសត់ទេ នឹងមានកម្រងផ្កាមាសពីណា ច្បាស់ជាលួចគេមកមិនខានឡើយ ។ គ្រានោះ ព្រះបិលិន្ទវច្ឆមានអាយុបានអធិដ្ឋានប្រាសាទរបស់ព្រះបាទមាគធរាជសេនិយពិម្ពិសារឲ្យទៅជាមាស (មួយកំពប) ។ ប្រាសាទនោះក៏ក្លាយទៅជា

មយោ ។ ឥទំ បន តេ មហារាជ តាវពហុំ សុវណ្ណំ កុតោ តំ ។ អញ្ញាតំ ភន្តេ អយ្យស្សេវេសោ(១) ឥទ្ធានុភាវោតិ តំ អារាមិកកុលំ មុញ្ចាបេសិ ។

[៤៨] មនុស្សា អយ្យេន កិរ បិលិន្ទវច្ឆេន សរាជិកាយ បរិសាយ ឧត្តរិមនុស្សធម្មំ ឥទ្ធិបាដិហារិយំ ទស្សិតន្តិ អត្តមនា អភិប្បសន្នា អាយស្មតោ បិលិន្ទវច្ឆស្ស បញ្ច ភេសជ្ជានិ អភិហរិំសុ សេយ្យថីទំ សប្បឹ នវនីតំ តេលំ មធុំ ផាណិតំ ។ បកតិយាបិ ចាយស្មា បិលិន្ទវច្ឆោ លាភី ហោតិ បញ្ចន្នំ ភេសជ្ជានំ លទ្ធំ លទ្ធំ បរិសាយ វិស្សជ្ជេតិ ។ បរិសា ចនស្ស ហោតិ ពាហុល្លិកា លទ្ធំ លទ្ធំ កោលម្ពេបិ ឃដេបិ បូរេត្វា បដិសាមេតិ បរិស្សាវនានិបិ ថវិកាយោបិ បូរេត្វា វាតបានេសុ លគ្គេតិ ។ តានិ ឱលីនវិលីនានិ តិដ្ឋន្តិ ។ ឧន្ទុរេហិបិ វិហារា ឱកិណ្ណវិកិណ្ណា ហោន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ អន្តោកោដ្ឋាគារិកា

១ ម. អយ្យស្ស ឯសោ ។



មាសសុទ្ធ ។ ព្រះបិលិន្ទវច្ឆមានអាយុថ្វាយព្រះពរសួរថា បពិត្រមហារាជ មាសច្រើនម្ល៉េះនេះ ព្រះអង្គបានមកពីណា ។ ព្រះរាជាទ្រង់ត្រាស់ឆ្លើយថា បពិត្រលោកដ៏ចំរើន ខ្ញុំដឹងហើយ នេះជាឥទ្ធានុភាពរបស់លោកម្ចាស់ទេតើ ទ្រង់បន្ទូលដូច្នេះហើយក៏ឲ្យគេដោះលែងត្រកូលអារាមិកជននោះទៅ ។

[៤៨] ពួកមនុស្សបានឮដំណឹងថា ព្រះបិលិន្ទវច្ឆមានអាយុសំដែងឥទ្ធិបាដិហារ្យជាឧត្តរិមនុស្សធម្មដល់បរិសទ្យព្រមទាំងស្តេចហើយក៏មានចិត្តត្រេកអរជ្រះថ្លានាំគ្នាយកភេសជ្ជៈទាំង ៥ គឺ ទឹកដោះរាវ ១ ទឹកដោះខាប់ ១ ប្រេង ១ ទឹកឃ្មុំ ១ ស្ករអំពៅ ១ មកប្រគេនព្រះបិលិន្ទវច្ឆមានអាយុ ។ ឯព្រះបិលិន្ទវច្ឆមានអាយុបានលាភមកហើយក៏តែងចែកដល់បណ្តាភេសជ្ជៈទាំង៥ ភេសជ្ជៈណាមួយដែលលោកបានមក ៗ (នោះ) ដល់បរិសទ្យជាធម្មតា ។ ចំណែកពួកបរិសទ្យរបស់ព្រះបិលិន្ទវច្ឆមានអាយុនោះជាមនុស្សលោភច្រើន ដែលយកភេសជ្ជៈទាំងឡាយ ទាំងដែលខ្លួនបានមក ៗ ទុកដាក់ពេញក្អាំងខ្លះ ពេញក្អមខ្លះ ពេញសម្ពត់ត្រងទឹកខ្លះ ពេញថង់ខ្លះ ហើយព្យួរទុកតាមបង្អួច ។ ភេសជ្ជៈទាំងនោះហៀរហូរតក់តប់ខ្ចាយ ។ កុដិក៏ដេរដាសដោយពួកកណ្តុរ ។ ពួកមនុស្សដើរទៅកាន់វិហារចារិកបានឃើញហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា

ឥមេ សមណា សក្យបុត្តិយា សេយ្យថាបិ រាជា មាគធោ សេនិយោ ពិម្ពិសារោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ ឯវរូបាយ ពាហុល្លាយ ចេតេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខូ ឯវរូបាយ ពាហុល្លាយ ចេតេន្តីតិ ។ សច្ចំ ភគវាតិ ។បេ។ វិគរហិត្វា ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ យានិ ខោ បន តានិ គិលានានំ ភិក្ខូនំ បដិសាយនីយានិ ភេសជ្ជានិ សេយ្យថីទំ សប្បិ នវនីតំ តេលំ មធុ ផាណិតំ តានិ បដិគ្គហេត្វា សត្តាហបរមំ សន្និធិការកំ បរិភុញ្ជិតព្វានិ តំ អតិក្កាមយតោ យថាធម្មោ ការេតព្វោតិ ។

ភេសជ្ជានុញ្ញាតភាណវារំ បឋមំ ។



ពួកសមណៈជាសក្យបុត្រនេះ មានរបស់ទុកដាក់ក្នុងឃ្លាំង ដូចជាព្រះបាទមាគធសេនិយពិម្ពិសារដែរ ។ ពួកភិក្ខុបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុមិនគួរនឹងមកសន្សំ (ភេសជ្ជៈ) ដោយសេចក្តីល្មោភច្រើនដែលដូច្នេះសោះ ។ ទើបភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុសន្សំ (ភេសជ្ជៈ) ដោយសេចក្តីល្មោភច្រើនដែលដូច្នេះ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។បេ។ ព្រះសម្ពុទ្ធទ្រង់តិះដៀលហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ភេសជ្ជៈទាំងឡាយណាដែលពួកភិក្ខុមានជម្ងឺគប្បីលិទ្ធភ្លក់ (ឆាន់) បាន គឺទឹកដោះថ្លា ១ ទឹកដោះខាប់ ១ ប្រេង ១ ទឹកឃ្មុំ ១ ស្ករអំពៅ ១ ភិក្ខុទទួលភេសជ្ជៈទាំងនោះហើយត្រូវទុកដាក់ឆាន់បានកំណត់ត្រឹម ៧ ថ្ងៃ ជាយ៉ាងយូរបំផុត បើភិក្ខុទុកភេសជ្ជៈទាំងនោះឲ្យកន្លងហួសពីកំណត់នោះទៅ ត្រូវឲ្យ[illegible] ឲ្យភិក្ខុនោះធ្វើតាមធម៌[១] ។

ចប់ ភាណវារៈពោលពីភេសជ្ជៈដែលព្រះមានព្រះភាគអនុញ្ញាតជាបឋម ។

---

១ ត្រូវឲ្យភិក្ខុនោះសំដែងអាបត្តិបាចិត្តិយចេញ ។

[៩៦] អថខោ ភគវា សាវត្ថិយំ យថាភិរន្តំ វិហរិត្វា យេន រាជគហំ តេន ចារិកំ បក្កាមិ ។ អទ្ទសា ខោ អាយស្មា កង្ខារេវតោ អន្តរាមគ្គេ គុឡករណំ ឱក្កមិត្វា គុឡេ បិដ្ឋម្បិ ឆារិកម្បិ បក្ខិបន្តេ ទិស្វាន អកប្បិយោ គុឡោ សាមិសោ ន កប្បតិ គុឡោ វិកាលេ បរិភុញ្ជិតុន្តិ កុក្កុច្ចាយន្តោ សបរិសោ គុឡំ ន បរិភុញ្ជតិ ។ យេបិស្ស សោតព្ពំ មញ្ញន្តិ តេបិ គុឡំ ន បរិភុញ្ជន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ កិមត្ថាយ(១) ភិក្ខវេ គុឡេ បិដ្ឋម្បិ ឆារិកម្បិ បក្ខិបន្តីតិ ។ ថទ្ធត្ថាយ ភគវាតិ ។ សចេ ភិក្ខវេ ថទ្ធត្ថាយ គុឡេ បិដ្ឋម្បិ ឆារិកម្បិ បក្ខិបន្តិ សោ ច គុឡោត្វេវ សំខ្យំ(២) គច្ឆតិ ។ អនុជានាមិ ភិក្ខវេ យថាសុខំ គុឡំ បរិភុញ្ជិតុំ ។ អទ្ទសា ខោ អាយស្មា កង្ខារេវតោ

១ ម. កិមត្ថិយា ។ ២ ម. សង្ខំ ។



[៩៦] គ្រានោះ ព្រះមានព្រះភាគគង់នៅក្រុងសាវត្ថីតាមព្រះអធ្យាស្រ័យហើយ ទ្រង់យាងទៅកាន់ចារិកក្រុងរាជគ្រឹះ ។ ព្រះកង្ខារេវតដ៏មានអាយុបានដើរចូលទៅកាន់រោងធ្វើស្ករអំពៅ ក្នុងចន្លោះផ្លូវ ហើយបានឃើញពួកជនកំពុងដាក់ម្សៅខ្លះ ផេះខ្លះលាយក្នុងស្ករអំពៅ លុះឃើញហើយ ក៏មានសេចក្ដីរង្កៀសថា ស្ករអំពៅលាយដោយអាមិសៈជាអកប្បិយៈ ប្រហែលជាស្ករអំពៅមិនគួរភិក្ខុនឹងឆាន់ក្នុងវេលាវិកាលទេដឹង (កាលរង្កៀសដូច្នេះហើយ) ព្រមទាំងបរិស័ទក៏មិនឆាន់ស្ករអំពៅឡើយ ។ ពួកភិក្ខុណាសំគាល់ពាក្យព្រះរេវតនោះថាជាពាក្យគួរស្ដាប់បាន ភិក្ខុទាំងនោះក៏មិនឆាន់ស្ករអំពៅដែរ ។ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកជនដាក់ម្សៅខ្លះ ផេះខ្លះ លាយក្នុងស្ករអំពៅដើម្បីប្រយោជន៍អ្វី ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ឲ្យស្អិត ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើគេដាក់ម្សៅខ្លះ ផេះខ្លះលាយក្នុងស្ករអំពៅត្រាតែឲ្យស្អិត (ប៉ុណ្ណោះទេ) ស្ករអំពៅនោះនៅតែហៅថាស្ករអំពៅដដែល ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ស្ករអំពៅ (នោះ) បានតាមសប្បាយ ។ ព្រះកង្ខារេវត

អគ្គកមគ្គេ ភិន្ទេ មុត្តំ ជាតំ បស្សិត្វា អកម្បិយា មុត្តា

បត្តាបំ មុត្តា ជាយន្តីតិ កុក្កុច្ចាយន្តា សមកំសា

មុត្តំ ន បរិភុញ្ជិតុំ ។ យេ បស្ស សោតពុំ មញ្ញន្តិ គេប មុត្តំ

ន បរិភុញ្ជិតុំ ។ គតភក្កា បំគមត្តំ អាភោបេសុំ ។ សបេ

ភិក្ខូ បបត្តាបំ មុត្តា ជាយន្តំ អនុជានាមិ ភិក្ខវេ យថាសុ-

ខំ មុត្តំ បរិភុញ្ជិតុំ ។ តេន ខោ បន សមយេន អញ្ញ-

តរស្ស ភិក្ខុនោ ឧទរភាតកាតោ ហោតិ ។ សោ លោ-

ហិតសោហិតំ(១) អហោសិ ។ តស្ស សោ ឧទរភាតកាតោ

———

១ ម. លោហិតសោហិតំ ។



ទឹកទាតហូរចេញសំណ្ដកចុងម្ខាងពីរខាង ក្នុងទីនោះ កណ្ដាល ផង ហូរចេញហើយក៏ស្រៀលជាសំណ្ដកចុងជាតកម្សៀរៈ ទុកជាចំនួនហើយ សំណ្ដកចុងក៏ចេញតែជ្រះទៀតទៀត កាលស្រៀលឆ្អួលហើយ ក្រមជាំពីចេញសម្ញក់មិនហាក់ខាត់សំណ្ដកចុងទៀយ ។ ពួកភិក្ខុណា- សំគាល់ការក្រោកស្ទាំងកែនោះជាំជាការស្មូស្លាប់ចុះ ភិក្ខុទាំងនោះក៏ មិនហ៊ានខាត់សំណ្ដកចុងនោះ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរ នុះចំពោះព្រះដ៏មានព្រះភាគ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចេសំណ្ដកចុងដែលរសនចំនេះហើយនៅតែជ្រះទៀតទៀត ម្នាលភិក្ខុ ទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុខាត់សំណ្ដកចុង (នោះ) ចុះ តាមសប្បាយ ។ ក៏សម័យនោះឯង ភិក្ខុមួយរូបមានការពោះកើតពីខ្យល់ កម្រោះ ។ ភិក្ខុនោះមានកន្ទុំឈ្មោះលោហិតសោហិតកៈ(១) ។ ភិក្ខុនោះ

———

១ ផ្ការបាតែកពណ៌យកគ្នាជាក់ ផ្កាឈ្មោះលោហិតសោហិតកៈនេះកើតពីស្ថានដ៏ត្រជាក់ ក្រហមក្រៀល ស្រឡៅតែនិងស្រឡៅទាំងគួរ មានស្រឡាលីសរជើងនិងអាវណ្ណ ផ្តែនិងសំណ្ដកល្អ ជើង និងល្បាយស្រឡៅ ប្រការមានស្រឡាលីសជើងនិងខ្លួលជើ ទាំងក្នុងមានផ្លែចេកជាជើង និងលម្អំលើទាំងក្នុងមានលម្អក់ល្ហនិងការកោះជាជើងនិងផ្ទាលាប់ និងហាលត្ថិជាផ្ទិមមាន ទឹកឃ្មុំ ទឹកគំពោ សម្ស៊ីលសំឡរជាជើង ហើយត្រៀមក្នុងការដំបាំទមាត់ការខាច្បដឹកទុកឲ្យល្អ ក់ណត់ ១ ថ្ងៃ ២ ថ្ងៃ ឬ ៣ ថ្ងៃក៏បាន ។ ផ្កានោះកើតនៅល្អមានពណ៌ផ្លែផ្ទាំងស្រក់ល្អរាប់ជាត់កែ ពាតខ្យល់ ក្អក ឃ្លត់ ស្អុយស្អៀងនិងឬសដូងពោះជាជើង ម្យ៉ាងទៀតផងក៏ល្អសម្រាប់ជាត់ក្រោយ ឆាយ ។

ឧទរវាតស្ស ឧប្បត្តិ ។ តតោ តោ ឋិតមត្តំ អាហារេតិ ។ អនុ-
ជានាមិ ភិក្ខវេ យថាសុខំ គិលានស្ស លោណសោ-
វីរកំ អគិលានស្ស ឧទកសម្ភិន្នំ បានបរិភោគេន
បរិភុញ្ជិតុន្តិ ។

(៩៧) អថេកោ តតោ អនុបុព្វេន ចារិកំ ចរមានោ
យេន រាជគហំ តទវសរិ ។ តត្រ សុទំ តតោ រាជគហេ
វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សម-
យេន តថាគត ឧទរវាតាពាធោ ហោតិ ។ អថខោ អា-
យស្មា អានន្ទោ បុព្វេបិ តថាគត ឧទរវាតាពាធោ តេក-
ដុលាយ យាគុយា ផាសុ ហោតីតិ សាមំ តិលំបិ តណ្ឌុ-
លំបិ មុគ្គំបិ វិញ្ញាបេត្វា អន្តោ វាសេត្វា អន្តោ សាមំ
បចិត្វា តថាគត ឧបនាមេសិ បិវតុ តតោ តេកដុលំ
យាគុន្តិ ។ ជានន្តាបិ តថាគតា បុច្ឆន្តិ ជានន្តាបិ ន





ក៏បាត់អាពាធកើតអំពីខ្យល់ក្នុងពោះនោះទៅ ។ ពួកភិក្ខុក្រាបបង្គំទូល
ដំណើរនុះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ
ទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឈឺ ឆាន់ថ្នាំឈ្មោះលោណសោវីរកៈ
(នោះ) បានតាមសប្បាយ ឲ្យភិក្ខុមិនឈឺឆាន់ថ្នាំលាយទឹកដោយវិធីប្រើ
ប្រាស់ដូចទឹក (មានទឹកផ្លែស្វាយជាដើម) បាន ។

(៩៧) គ្រានោះ ព្រះមានព្រះភាគទ្រង់យាងទៅកាន់ចារិកដោយលំ-
ដាប់ បានដល់ទៅក្រុងរាជគ្រឹះ ។ បានឮថា ព្រះមានព្រះភាគទ្រង់គង់នៅ
ក្នុងវត្តវេឡុវ័នកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះនោះ ។ សម័យនោះឯងព្រះ
ដ៏មានព្រះភាគទ្រង់អាពាធកើតអំពីខ្យល់ក្នុងព្រះឧទរ ។ គ្រានោះ ព្រះអា-
នន្ទដ៏មានអាយុគិតថា កាលអំពីមុនព្រះដ៏មានព្រះភាគទ្រង់អាពាធកើតអំពី
ខ្យល់ក្នុងព្រះឧទរ ទ្រង់បានសះស្បើយទៅវិញព្រោះ(សោយ)បបរឈ្មោះ
តេកដុលា[១] (លុះគិតដូច្នេះហើយ) ក៏សូមល្ងខ្លះ អង្ករខ្លះ សណ្តែកបាយខ្លះ
(បានហើយ) ទុកដាក់ក្នុងកន្លែងប្រយ័ត្នដោយខ្លួនឯង ចំអិនក្នុងកន្លែងប្រយ័ត្ន
ដោយខ្លួនឯង ទើបបង្អោនទៅថ្វាយព្រះដ៏មានព្រះភាគហើយក្រាបបង្គំ
ទូលថា សូមព្រះដ៏មានព្រះភាគទ្រង់សោយនូវបបរឈ្មោះតេកដុលា ។ ព្រះ
តថាគតទាំងឡាយទ្រង់ជ្រាបនូវហេតុហើយសួរក៏មាន ទ្រង់ជ្រាបហើយ

១ បបរសោយដោយរបស់បីយ៉ាងគឺ ល្ង អង្ករនិងសណ្តែក ។

បុច្ឆន្តិ កាលំ វិទិត្វា បុច្ឆន្តិ កាលំ វិទិត្វា ន បុច្ឆន្តិ អត្ថសញ្ហិតំ តថាគតា បុច្ឆន្តិ នោ អនត្ថសញ្ហិតំ អនត្ថសញ្ហិតេ សេតុឃាតោ តថាគតានំ ។ ទ្វីហាការេហិ ពុទ្ធា ភគវន្តោ ភិក្ខូ បដិបុច្ឆន្តិ ធម្មំ វា ទេសេស្សាម សាវកានំ វា សិក្ខាបទំ បញ្ញាបេស្សាមាតិ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ កុតាយំ អានន្ទ យាគូតិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ[១] អានន្ទ អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម ត្វំ អានន្ទ ឯវរូបាយ ពាហុល្លាយ ចេតេស្សសិ យទបិ អានន្ទ អន្តោ វុដ្ឋំ តទបិ អកប្បិយំ យទបិ អន្តោ បក្កំ តទបិ

១ ម. អននុច្ឆវិយំ ។



មិនសួរក៏មាន ទ្រង់ជ្រាបច្បាស់នូវកាលគួរហើយសួរក៏មាន ទ្រង់ជ្រាបច្បាស់នូវកាលគួរហើយមិនសួរក៏មាន ឯព្រះតថាគតទាំងឡាយ ព្រះអង្គតែងសួរតែការណាដែលប្រកបដោយប្រយោជន៍ ការដែលមិនប្រកបដោយប្រយោជន៍ ព្រះអង្គមិនសួរឡើយ ព្រោះព្រះតថាគតទាំងឡាយទ្រង់បានផ្ដាច់បង់នូវកម្មមិនប្រកបដោយប្រយោជន៍ទាំងឡាយដោយអរិយមគ្គប្រសើរស្រឡះហើយ ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទាំងឡាយ តែងតែទ្រង់សួរពួកភិក្ខុដោយអាការពីរយ៉ាង គឺសួរដើម្បីសំដែងធម៌ម្យ៉ាង ដើម្បីនឹងបញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយម្យ៉ាង ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ហៅព្រះអានន្ទដ៏មានអាយុមកហើយ ទ្រង់ត្រាស់សួរថា ម្នាលអានន្ទ បបរនេះបានមកពីណា ។ ទើបព្រះអានន្ទដ៏មានអាយុក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលអានន្ទ កម្មដែលអ្នកធ្វើនេះមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនរបស់សមណៈ មិនគួរ មិនគួរធ្វើ ម្នាលអានន្ទ អ្នកឯងមិនសមបើនឹងត្រិះរិះដើម្បីសេចក្ដីប្រាថ្នាច្រើនមានសភាពយ៉ាងនេះទេ ម្នាលអានន្ទ អាមិសៈណាដែលភិក្ខុទុកក្នុងអាវាស (អកប្បិយកុដិ) អាមិសៈនោះក៏ទៅជាអកប្បិយៈ (មិនគួរ) ដែរ អាមិសៈណាដែលភិក្ខុចំអិនក្នុងអាវាស (អកប្បិយកុដិ) អាមិសៈនោះ

អកប្បិយំ យទបិ សាមំ បក្កំ តទបិ អកប្បិយំ នេតំ អានន្ទ អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ អន្តោ វុត្ថំ អន្តោ បក្កំ សាមំ បក្កំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស ។ អន្តោ ចេ ភិក្ខវេ វុត្ថំ អន្តោ បក្កំ សាមំ បក្កំ តញ្ចេ បរិភុញ្ជេយ្យ អាបត្តិ តិណ្ណំ ទុក្កដានំ ។ អន្តោ ចេ ភិក្ខវេ វុត្ថំ អន្តោ បក្កំ អញ្ញេហិ បក្កំ តញ្ចេ បរិភុញ្ជេយ្យ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ អន្តោ ចេ ភិក្ខវេ វុត្ថំ ពហិ បក្កំ សាមំ បក្កំ តញ្ចេ បរិភុញ្ជេយ្យ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ ពហិ ចេ ភិក្ខវេ វុត្ថំ អន្តោ បក្កំ សាមំ បក្កំ





ក៏ទៅជាអកប្បិយៈដែរ អាមិសៈណាដែលភិក្ខុចំអិនដោយខ្លួនឯង អាមិសៈនោះ ក៏ទៅជាអកប្បិយៈដែរ ម្នាលអានន្ទ កំពើដែលអ្នកធ្វើនេះ មិនមែនជាទីជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីបរិភោគអាមិសៈដែលជាអន្តោវុត្ថ (គឺភោជនដែលភិក្ខុទុកខាងក្នុងអកប្បិយកុដិ) អាមិសៈដែលជាអន្តោបក្ក (គឺភោជនដែលភិក្ខុចំអិនខាងក្នុងអកប្បិយកុដិ) អាមិសៈដែលជាសាមំបក្ក (គឺភោជនដែលភិក្ខុចំអិនដោយខ្លួនឯង) ទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជនខាងក្នុងអកប្បិយកុដិផង ចំអិនខាងក្នុងអកប្បិយកុដិផង ចំអិនដោយខ្លួនឯងផង បើភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិទុក្កដបី ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជនខាងក្នុងអកប្បិយកុដិ ចំអិនខាងក្នុងអកប្បិយកុដិ តែប្រើពួកអ្នកដទៃចំអិនឲ្យ បើភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិទុក្កដពីរ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជនខាងក្នុងអកប្បិយកុដិ ចំអិនខាងក្រៅអកប្បិយកុដិ តែភិក្ខុចំអិនខ្លួនឯង បើភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិទុក្កដពីរ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជនខាងក្រៅអកប្បិយកុដិ ចំអិនខាងក្នុងអកប្បិយកុដិ តែភិក្ខុចំអិនខ្លួនឯង បើភិក្ខុ

តញ្ចេ បរិភុញ្ជេយ្យ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ អន្តោ ចេ ភិក្ខវេ វុត្ថំ ពហិ បក្កំ អញ្ញេហិ បក្កំ តញ្ចេ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស ។ ពហិ ចេ ភិក្ខវេ វុត្ថំ អន្តោ បក្កំ អញ្ញេហិ បក្កំ តញ្ចេ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស ។ ពហិ ចេ ភិក្ខវេ វុត្ថំ ពហិ បក្កំ សាមំ បក្កំ តញ្ចេ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស ។ ពហិ ចេ ភិក្ខវេ វុត្ថំ ពហិ បក្កំ អញ្ញេហិ បក្កំ តញ្ចេ បរិភុញ្ជេយ្យ អនាបត្តីតិ ។

[៤៨] តេន ខោ បន សមយេន ភិក្ខូ ភគវតា សាមបាកោ(១) បដិក្ខិត្តោតិ បុនបាកេ កុក្កុច្ចាយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បុនបាកំ បចិតុន្តិ ។

១ ម. សាមំ បាកោ ។



ឆាន់ភោជននោះ ត្រូវអាបត្តិទុក្កដពីរ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជនខាងក្នុងអកប្បិយកុដិ ចំអិនខាងក្រៅអកប្បិយកុដិ តែប្រើពួកអ្នកដទៃចំអិនឲ្យ បើភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិទុក្កដមួយ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជនខាងក្រៅអកប្បិយកុដិ ចំអិនខាងក្នុងអកប្បិយ-កុដិ តែប្រើពួកអ្នកដទៃចំអិនឲ្យ បើភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិទុក្កដមួយ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជនខាងក្រៅអកប្បិយ-កុដិ ចំអិនខាងក្រៅអកប្បិយកុដិ តែភិក្ខុចំអិនខ្លួនឯង បើភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិទុក្កដមួយ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជនខាងក្រៅអកប្បិយកុដិ ចំអិនខាងក្រៅអកប្បិយកុដិ តែប្រើពួកអ្នកដទៃចំអិនឲ្យ បើភិក្ខុឆាន់ភោជននោះ មិនត្រូវអាបត្តិទេ ។

(៤៨) សម័យនោះឯង ពួកភិក្ខុនឹកថា ការចំអិនខ្លួនឯង ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ក៏រង្កៀសក្នុងការចំអិនថែមទៀត ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចំអិនថែមទៀតបាន ។

(៥៥) តេន ខោ បន សមយេន រាជគហេ ទុព្ភិក្ខំ ហោតិ ។ មនុស្សា លោណម្បិ តេលម្បិ តណ្ឌុលម្បិ ខាទនីយម្បិ អារាមំ អាហរន្តិ ។ តានិ ភិក្ខូ ពហិ វាសេន្តិ ឧក្កបិណ្ឌកាបិ ខាទន្តិ ចោរាបិ ហរន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អន្តោ វាសេតុន្តិ ។ អន្តោ វាសេត្វា ពហិ បចន្តិ ។ ទមកា បរិវារេន្តិ ។ ភិក្ខូ អវិស្សដ្ឋា បរិភុញ្ជន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អន្តោ បចិតុន្តិ ។ ទុព្ភិក្ខេ កប្បិយការកា ពហុតរំ ហរន្តិ អប្បតរំ ភិក្ខូនំ ទេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សាមំ បចិតុំ ។ អនុជានាមិ ភិក្ខវេ អន្តោ វុដ្ឋំ អន្តោ បក្កំ សាមំ បក្កន្តិ ។





(៥៥) សម័យនោះឯង ក្រុងរាជគ្រឹះកើតទុរ្ភិក្ខ (អត់ឃ្លាន) ។ មនុស្សទាំងឡាយបាននាំយកអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ ទៅកាន់អារាម ។ ភិក្ខុទាំងឡាយទុកវត្ថុទាំងនោះខាងក្រៅ(វិហារ) ពួកសត្វឧក្កបិណ្ឌ[1]ទាំងឡាយស៊ីខ្លះ ពួកចោរលួចយកទៅខ្លះ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទុក (វត្ថុទាំងនោះ) ខាងក្នុងកប្បិយកុដិបាន ។ ភិក្ខុទាំងឡាយទុក (វត្ថុទាំងនោះ) ខាងក្នុងកប្បិយកុដិហើយ ឲ្យគេចំអិនខាងក្រៅ ពួកជនអ្នកស៊ីដែលនាំគ្នាចោមរោមស៊ី ។ ភិក្ខុទាំងឡាយមិនសូវចិត្ត (ប្រកបដោយសេចក្តីរង្កៀស) ក៏បរិភោគទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចំអិនខាងក្នុងកប្បិយកុដិបាន ។ កាលដែលស្រុកកើតអត់ឃ្លាន ពួកកប្បិយការកជននាំយកវត្ថុច្រើនទៅ ប្រគេនតែបន្តិចបន្តួចដល់ពួកភិក្ខុ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចំអិនដោយខ្លួនឯងបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទុកវត្ថុខាងក្នុងកប្បិយកុដិបាន ឲ្យចំអិនខាងក្នុងកប្បិយកុដិបាន ឲ្យចំអិនដោយខ្លួនឯងបាន ។

១ [illegible]

(១០០) តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ កាសីសុ វស្សំវុត្ថា រាជគហំ គច្ឆន្តា ភគវន្តំ ទស្សនាយ អន្តរាមគ្គេ ន លភឹសុ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ ពហុញ្ច ផលខាទនីយំ អហោសិ ន ច កោចិ កប្បិយការកោ ។ អថខោ តេ ភិក្ខូ កិលន្តរូបា យេន រាជគហំ វេឡុវនំ កលន្ទកនិវាបោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ អាចិណ្ណំ ខោ បនេតំ ពុទ្ធានំ ភគវន្តានំ អាគន្តុកេហិ ភិក្ខូហិ សទ្ធឹ បដិសម្មោទិតុំ ។ អថខោ ភគវា តេ ភិក្ខូ ឯតទវោច កច្ចិ ភិក្ខវេ ខមនីយំ កច្ចិ យាបនីយំ កច្ចិត្ថ អប្បកិលមថេន អទ្ធានំ អាគតា កុតោ ច តុម្ហេ ភិក្ខវេ អាគច្ឆថាតិ ។ ខមនីយំ ភគវា យាបនីយំ ភគវា ឥធ មយំ ភន្តេ កាសីសុ



(១០០) សម័យនោះឯង ពួកភិក្ខុច្រើនរូបនៅចាំវស្សាក្នុងដែនកាសី ហើយក៏នាំគ្នាទៅកាន់ក្រុងរាជគ្រឹះដើម្បីគាល់ព្រះមានព្រះភាគ លុះទៅដល់ពាក់កណ្ដាលផ្លូវ ក៏រកភោជនសៅហ្មងក្ដី ឧត្ដមក្ដី ឲ្យឆ្អែតតាមប្រាថ្នាមិនបាន (ឃើញ) មានតែផ្លែឈើដែលគួរទំពាស៊ីជាច្រើន តែរកបុគ្គលជាកប្បិយការកគ្មាន ។ ភិក្ខុទាំងនោះមានរូបកាយលំបាក ក៏នាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងវត្តវេឡុវ័នកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចក៏អង្គុយនៅក្នុងទីសមគួរ ។ ការដែលរីករាយជាមួយនឹងពួកភិក្ខុអាគន្តុកៈនេះឯងជាប្រពៃណីរបស់ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយ (គ្រប់ព្រះអង្គ) ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់មានព្រះបន្ទូលសួរនឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយល្មមអត់ទ្រាំសេចក្ដីលំបាកបានដែរឬទេ ល្មមញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅបានស្រួលដែរឬទេ អ្នក (រាល់គ្នា) ដើរមកតាមផ្លូវឆ្ងាយមិនលំបាកទេឬ ម្យ៉ាងទៀត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមកអំពីណា ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយល្មមអត់ទ្រាំបាន បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយល្មមញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅស្រួលបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងឡាយនៅចាំវស្សាក្នុងដែនកាសី ហើយ

វស្សំ វុត្ថា រាជគហំ អាគច្ឆន្តា ភគវន្តំ ទស្សនាយ អន្ត-
រាមគ្គេ ន លភិំសុ លូខស្ស វា បណីតស្ស វា ភោជនស្ស
យាវទត្ថំ បារិបូរឹ ពហុញ្ច ផលខាទនីយំ អហោសិ កប្-
បិយការកោ ច ន អហោសិ តេន មយំ កិលន្តរូបា
អទ្ធានំ អាគតាតិ ។ អថខោ ភគវា ឯតស្មឹ និទានេ
ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ
អនុជានាមិ ភិក្ខវេ យត្ថ ផលខាទនីយំ បស្សតិ
កប្បិយការកោ ច ន ហោតិ សាមំ គហេត្វា ហរិត្វា
កប្បិយការកេ បស្សិត្វា ភូមិយំ និក្ខិបិត្វា បដិគ្គ-
ហាបេត្វា បរិភុញ្ជិតុំ ។ អនុជានាមិ ភិក្ខវេ ឧគ្គហិ-
តំ បដិគ្គហិតុន្តិ ។

(១០១) តេន ខោ បន សមយេន អញ្ញតរស្ស ព្រាហ្មណស្ស នវា ច តិលា នវញ្ច មធុ ឧប្បន្នា ហោន្តិ ។ អថ ខោ តស្ស ព្រាហ្មណស្ស ឯតទហោសិ យន្នូនាហំ នវេ ច តិលេ នវញ្ច មធុំ ពុទ្ធប្បមុខស្ស ភិក្ខុសង្ឃស្ស ទទេយ្យន្តិ ។ អថ ខោ សោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធិំ សម្មោទិ





មកកាន់ក្រុងរាជគ្រឹះ ដើម្បីគាល់ព្រះសម្ពុទ្ធទ្រង់នេះ លុះមកដល់ពាក់កណ្ដាលផ្លូវ ក៏រកភោជនសៅហ្មងក្ដី ឧត្ដមក្ដី ដើម្បីឲ្យបានឆ្អែតបរិបូណ៌ គ្មាន ( ឃើញ ) មានតែផ្លែឈើដែលគួរទំពាស៊ីជាច្រើន តែកប្បិយការកៈគ្មាន ហេតុនោះបានជាខ្ញុំព្រះអង្គទាំងឡាយ មានរូបកាយលំបាកមកតាមផ្លូវឆ្ងាយ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយទ្រង់ត្រាស់ហៅភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ( បើភិក្ខុណា ) បានឃើញផ្លែឈើដែលគួរទំពាស៊ីក្នុងទីណា តែកប្បិយការកៈគ្មាន តថាគតអនុញ្ញាតឲ្យ ( ភិក្ខុនោះ ) កាន់ខ្លួនឯង ហើយនាំយកទៅ លុះឃើញកប្បិយការកៈហើយ ត្រូវដាក់ចុះលើផែនដី ឲ្យកប្បិយការកៈប្រគេនហើយ ឆាន់ចុះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទទួលរបស់ទុកមក គឺតែដែលភិក្ខុកាន់យកហើយបាន ។

(១០១) សម័យនោះឯង ប្រេងល្ងថ្មីនិងទឹកឃ្មុំថ្មីកើតឡើងដល់ព្រាហ្មណ៍ម្នាក់ ។ ឯព្រាហ្មណ៍នោះក៏ត្រិះរិះថា បើដូច្នោះ មានតែអាត្មាអញប្រគេនប្រេងល្ងថ្មីនិងទឹកឃ្មុំថ្មី ដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ ទើបព្រាហ្មណ៍នោះចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ បានស្មោះសរីរកាយទៅនឹងព្រះដ៏មានព្រះភាគ លុះធ្វើសេចក្ដី

សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ សោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ សោ ព្រាហ្មណោ ភគវតោ អធិវាសនំ វិទិត្វា បក្កាមិ ។ អថខោ សោ ព្រាហ្មណោ តស្សា រត្តិយា អច្ចយេន បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន តស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។ អថខោ សោ ព្រាហ្មណោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ



គួរជាទីរីករាយ គួរជាទីរលឹកឲ្យសម្រេចហើយ ក៏ឈរនៅក្នុងទីសមគួរ ។ លុះព្រាហ្មណ៍នោះឈរនៅក្នុងទីសមគួរហើយ បានទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន សូមព្រះគោតមដ៏ចំរើន ព្រមទាំងភិក្ខុសង្ឃទទួលភត្តរបស់ខ្ញុំព្រះអង្គដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ ចំណែកព្រាហ្មណ៍នោះដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តហើយ ក៏ចៀសចេញទៅ ។ លុះកន្លងរាត្រីនោះទៅហើយ ព្រាហ្មណ៍នោះបានតាក់តែងខាទនីយភោជនីយាហារយ៉ាងឧត្តមស្រេចហើយ ទើបឲ្យក្រាបបង្គំទូលនូវកាលទៅចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន វេលានេះសមគួរហើយ ភត្តស្រេចហើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ហើយប្រដាប់ដោយបាត្រនិងចីវរពេលព្រឹក យាងទៅកាន់ផ្ទះព្រាហ្មណ៍នោះ លុះយាងទៅដល់ហើយទ្រង់គង់លើអាសនៈដែលព្រាហ្មណ៍តាក់តែងទុកព្រមទាំងភិក្ខុសង្ឃ ។ ឯព្រាហ្មណ៍នោះបានអង្គាសដោយខាទនីយភោជនីយាហារ ( បន្ថែមចំណាច ) ដ៏ឆ្ងាញ់ពិសារដោយដៃខ្លួនឯងចំពោះព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ ព្រាំងឃាត់ឃាត់ប្រកែកថាលែងទទួលទៀត លុះព្រះដ៏មានព្រះភាគទ្រង់សោយស្រេចលែងលូកព្រះហស្តទៅក្នុងបាត្រ (ព្រាហ្មណ៍) ក៏អង្គុយក្នុងទីសមគួរ ។ លុះ

និសិន្នំ ខោ តំ ព្រាហ្មណំ ភគវា ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ តស្ស ព្រាហ្មណស្ស អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ យេសំ ខោ មយា អត្ថាយ ពុទ្ធប្បមុខោ ភិក្ខុសង្ឃោ និមន្តិតោ នវេ ច តិលេ នវញ្ច មធុំ ទស្សាមីតិ តេ មយា បមុដ្ឋា ទាតុំ យន្នូនាហំ នវេ ច តិលេ នវញ្ច មធុំ កោលម្ពេហិ ច ឃដេហិ ច អារាមំ ហរាបេយ្យន្តិ ។ អថខោ សោ ព្រាហ្មណោ នវេ ច តិលេ នវញ្ច មធុំ កោលម្ពេហិ ច ឃដេហិ ច អារាមំ ហរាបេត្វា[១] យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ សោ ព្រាហ្មណោ ភគវន្តំ ឯតទវោច យេសំ ខោ មយា ភោ គោតម អត្ថាយ ពុទ្ធប្បមុខោ ភិក្ខុសង្ឃោ និមន្តិតោ នវេ ច តិលេ នវញ្ច មធុំ ទស្សាមីតិ តេ មយា បមុដ្ឋា ទាតុំ បដិគ្គណ្ហាតុ មេ ភវំ គោតមោ នវេ ច តិលេ នវញ្ច មធុន្តិ ។ តេនហិ ព្រា-

១ ម. ហរាបេត្វា ។



ព្រាហ្មណ៍នោះគង្គុយនៅក្បែរទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយទ្រង់ក្រោកចាកអាសនៈយាងចៀសចេញទៅ ។ កាលព្រះដ៏មានព្រះភាគយាងចេញទៅមិនយូរប៉ុន្មាន ព្រាហ្មណ៍នោះក៏មានសេចក្តីត្រិះរិះដូច្នេះថា ការដែលអញនិមន្តព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានមកដោយមានបំណងថានឹងប្រគេនល្ងថ្មីនិងទឹកឃ្មុំថ្មី ដើម្បីប្រយោជន៍ដល់ប្រគេនល្ងនិងទឹកឃ្មុំណា ល្ងនិងទឹកឃ្មុំនោះអាត្មាអញភ្លេចប្រគេនទៅហើយ បើដូច្នោះមានតែអាត្មាអញឲ្យគេនាំយកនូវល្ងថ្មីនិងទឹកឃ្មុំថ្មីដោយក្រឡនិងក្អមទៅកាន់អារាម ។ ទើបព្រាហ្មណ៍នោះឲ្យគេនាំយកល្ងថ្មីនិងទឹកឃ្មុំថ្មីដោយក្រឡនិងក្អមទៅកាន់អារាមហើយបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឈរនៅក្បែរទីសមគួរ ។ លុះព្រាហ្មណ៍នោះឈរនៅក្បែរទីសមគួរហើយបានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គបាននិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានដោយមានបំណងថានឹងប្រគេនល្ងថ្មីនិងទឹកឃ្មុំថ្មី ដើម្បីប្រយោជន៍ដល់ល្ងនិងទឹកឃ្មុំណា ល្ងនិងទឹកឃ្មុំនោះខ្ញុំព្រះអង្គភ្លេចប្រគេន សូមព្រះគោតមដ៏ចំរើនទទួលយកល្ងថ្មីនិងទឹកឃ្មុំថ្មីរបស់ខ្ញុំព្រះអង្គ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍

ព្រាហ្មណោ ភិក្ខូ នេយ្យាតិ ។ តេន ខោ បន សមយេន ឆ ភិក្ខូ ឧក្កុដ្ឋេ អប្បមត្តកេនបិ បវារេន្តិ បដិសង្ខាបិ បដិគ្គហេតុំ សព្វោ ច សង្ឃោ បវារិតោ ហោតិ ។ ភិក្ខូ កុក្កុច្ចាយន្តា ន បដិគ្គណ្ហន្តិ ។ បដិគ្គណ្ហថ(១) ភិក្ខវេ បរិភុញ្ជថ អនុជានាមិ ភិក្ខវេ តតោ នីហដំ ភុត្តាវិនា បវារិតេន អនតិរិត្តំ បរិភុញ្ជិតុន្តិ ។

(១០៦) តេន ខោ បន សមយេន អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស ឧបដ្ឋាកកុលំ សង្ឃស្ស អត្ថាយ ខាទនីយំ ទាបេសិ(២) អយ្យស្ស ឧបនន្ទស្ស ទស្សេត្វា សង្ឃស្ស ទស្សាមាតិ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ គាមំ បិណ្ឌាយ បវិដ្ឋោ ហោតិ ។ អថ ខោ តេ មនុស្សា អារាមំ គន្ត្វា

១ ម. បដិគ្គណ្ហថ ។ ២ សីហ. ចម. ភាជនីយំ ខាទនីយំ ។



បើដូច្នោះ អ្នកឯងនឹងត្រូវប្រគេនផលដល់ភិក្ខុទាំងឡាយចុះ ។ គ្រានោះឯង កាលព្រាហ្មណ៍ក្រោកព្រឹក (អត់បាយ) ភិក្ខុទាំងឡាយក៏ហាមឃាត់ថា ល្មមបពិត្រ ល្មមខ្លះ(១) តិចណាស់ហើយ ហាមឃាត់ខ្លះ(២) ម្យ៉ាងទៀត សង្ឃទាំងអស់ក៏បាននាំមកគ្រប់ហើយ ។ ពួកភិក្ខុក៏នៅស្ងៀម ហើយមិនហាមឃាត់ទទួល ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលចុះ ចូរឆាន់ចុះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលឆាន់ហើយ ហាមភត្តហើយ ឆាន់ភោជនមិនមែនជារបស់ដែលសល់ពីភិក្ខុឈឺ ឬមិនបានធ្វើវិនយកម្ម ដែលគេនាំយកមកអំពីទីដែលគេនិមន្តនោះបាន ។

(១០៦) សម័យនោះឯង ត្រកូលឧបដ្ឋាករបស់ឧបនន្ទសក្យបុត្រ បានតាក់តែងខាទនីយៈ ទុកដើម្បីប្រយោជន៍ដល់សង្ឃហើយថា ពួកយើងនឹងបង្ហាញដល់លោកម្ចាស់ឧបនន្ទហើយ សឹមប្រគេនសង្ឃចុះ ។ គ្រានោះឯង ឧបនន្ទសក្យបុត្រដ៏មានអាយុចូលទៅស្រុកដើម្បីបិណ្ឌបាត ។ ឯមនុស្សទាំងនោះក៏ទៅកាន់អារាមហើយសួរភិក្ខុទាំងឡាយថា

១ ក្នុងអដ្ឋកថាថា កាលបើគេយកប្រគេនតែបន្តិចបន្តួចហើយ ភិក្ខុទាំងឡាយក៏ហាមឃាត់មិនទទួលទៀត ។ ២ ភិក្ខុកំណត់ដឹងថា យើងអាចឆាន់ពួកអាហារប្រកបព្រោះទៅដោយវត្ថុមានប្រមាណប៉ុណ្ណេះ ព្រោះតែសល់អំពីគ្រាដែលភិក្ខុឯទៀតចុះ ហើយក៏ហាមឃាត់មិនទទួល ។

ភិក្ខុ ចុតិស្ស តស្ស កាលេ អយ្យោ ឧបដ្ឋាតិ ។ បិណ្ឌាតោ កាយស្ស ឧបនេត្វា សក្យបុត្តោ តស្ស បិណ្ឌាយ បវិដ្ឋោតិ ។ អថ កាលេ ទានស្ស អយ្យស្ស ឧបដ្ឋស្ស ធម្មេត្វា សព្វស្ស ញាតកត្តិ ។ កតវតោ បិតមត្ថំ អាគេចេសុំ ។ តេនាហ ភិក្ខវេ បដិក្កហេត្វា និក្ខិបថ យាវ ឧបនន្ទោ អាគច្ឆតីតិ ។ អថខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ បុរេភត្តំ កុលានិ បយិរុបាសិត្វា ទិវា អាគច្ឆតិ ។ តេន ខោ បន សមយេន ភិក្ខុ ទុព្ភិក្ខំ អប្បមត្តកោបិ បវារេន្តិ បដិសង្ខាយ បដិក្ខិបន្តិ សព្វោ ច សង្ឃោ បវារិតោ ហោតិ ។ ភិក្ខូ កុក្កុច្ចាយន្តា ន បដិគ្គណ្ហន្តិ ។ បដិគ្គណ្ហថ ភិក្ខវេ បរិភុញ្ជថ អនុជានាមិ ភិក្ខវេ បុរេភត្តំ បដិគ្គហិតំ ភុត្តាវិនា បវារិតេន អនតិរិត្តំ បរិភុញ្ជិតុន្តិ ។



បពិត្រលោកដ៏ចំរើន លោកម្ចាស់ឧបនន្ទទៅណាហើយ ។ ពួកភិក្ខុប្រាប់ថា ម្នាលឧបាសកទាំងឡាយ ឧបនន្ទសក្យបុត្រដ៏មានអាយុនុ៎ះចូលទៅស្រុកដើម្បីបិណ្ឌបាតហើយ ។ មនុស្សទាំងនោះប្រាប់ពួកភិក្ខុថា បពិត្រលោកដ៏ចំរើន ខាទនីយៈនេះពួកយើងត្រូវបង្ហាញផលលោកម្ចាស់ឧបនន្ទសិន ហើយសឹមប្រគេនដល់សង្ឃ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះអ្នកទាំងឡាយចូរទទួលទុកទំរាំតែឧបនន្ទវិលមកដល់ ។ លំដាប់នោះ ឧបនន្ទសក្យបុត្រដ៏មានអាយុ ចូលទៅកាន់ត្រកូលទាំងឡាយក្នុងវេលាមុនភត្ត ហើយវិលត្រឡប់មកក្នុងវេលាថ្ងៃត្រង់ ។ សម័យនោះឯង កាលស្រុកកើតទុរ្ភិក្ស (អត់បាយ) ភិក្ខុទាំងឡាយហាមឃាត់ត្រូវបន្តិចបន្តួច គំពារណហើយក៏ហាមឃាត់ខ្លះ ។ មួយទៀត សង្ឃទាំងអស់ក៏បានហាមភត្តរួចហើយ ។ ពួកភិក្ខុក៏រង្កៀសមិនហ៊ានទទួល ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលចុះ ចូរឆាន់ចុះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលបរិភោគហើយ ហាមភត្តរួចហើយ ឆាន់អាហារដែលមិនមែនជាបស់ដែលនាំពីភិក្ខុណា ឬមិនបានធ្វើវិនយកម្ម ដែលភិក្ខុបានទទួលក្នុងវេលាមុនភត្ត (នោះ) បាន ។

(៦០៣) អថខោ ភគវា រាជគហេ យថាភិរន្តំ វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន សាវត្ថី តទវសរិ ។ តត្រ សុទំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មតោ សារីបុត្តស្ស កាយឌាហាពាធោ ហោតិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ ឯតទវោច បុព្វេ តេ អាវុសោ សារីបុត្ត កាយឌាហាពាធោ កេន ផាសុ ហោតីតិ ។ ភិសេហិ ច មេ អាវុសោ មុឡាលិកាហិ ចាតិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ សេយ្យថាបិ នាម ពលវា បុរិសោ សមិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សមិញ្ជេយ្យ ឯវមេវ ជេតវនេ អន្តរហិតោ មន្ទាកិនិយា បោក្ខរណិយា តីរេ បាតុរហោសិ ។ អទ្ទសា ខោ អញ្ញតរោ នាគោ អាយស្មន្តំ មហាមោគ្គល្លានំ ទូរតោវ អាគច្ឆន្តំ ទិស្វាន អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច ឯតុ ខោ ភន្តេ អយ្យោ



(៦០៣) គ្រានោះ ព្រះមានព្រះភាគទ្រង់គង់ក្នុងក្រុងរាជគ្រឹះតាមសមគួរដល់ព្រះអធ្យាស្រ័យហើយ យាងចេញទៅកាន់ចារិកទៅឯក្រុងសាវត្ថី ទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ទើបបានទៅដល់ក្រុងសាវត្ថី ។ បានឮថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថីនោះ ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុមានអាពាធក្ដៅក្រហាយក្នុងកាយ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ និយាយពាក្យនេះនឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលអាវុសោសារីបុត្ត កាលពីមុន លោកមានអាពាធក្ដៅក្រហាយក្នុងកាយ តើលោកបានជាសះស្បើយដោយថ្នាំអ្វី ។ ព្រះសារីបុត្តតបថា ម្នាលអាវុសោ ខ្ញុំបានជាសះស្បើយដោយមើមឈូកនឹងក្រអៅឈូក ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុបាត់ខ្លួនអំពីវត្តជេតពនហើយ ទៅប្រាកដឡើងមាត់ស្រះបោក្ខរណីឈ្មោះមន្ទាកិនីដោយឆាប់រហ័ស ដូចជាបុរសមានកំឡាំង លាចេញនូវដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដៃដែលខ្លួនលាចេញ ។ មាននាគ ១ បានឃើញព្រះមហាមោគ្គល្លានដ៏មានអាយុមកអំពីចម្ងាយ លុះឃើញហើយបាននិយាយពាក្យនេះនឹងព្រះមហាមោគ្គល្លានដ៏មានអាយុថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់មហាមោគ្គល្លានមកចុះ បពិត្រ

មហាមោគ្គល្លានោ ស្វាគតំ ភន្តេ អយ្យស្ស មហា-
មោគ្គល្លានស្ស កេន ភន្តេ អយ្យស្ស អត្ថោ កឹ ទម្មីតិ ។
ភិសេហិ ច មេ អាវុសោ អត្ថោ មុឡាលិកាហិ ចាតិ ។
អថខោ សោ នាគោ អញ្ញតរំ នាគំ អាណាបេសិ តេនហិ
ភណេ អយ្យស្ស ភិសេ ច មុឡាលិកាយោ ច យាវទត្ថំ
ទេហីតិ ។ អថខោ សោ នាគោ មន្ទាកិនឹ បោក្ខរណឹ
ឱគាហេត្វា សោណ្ឌាយ ភិសមុឡាលិកាយោ[១] អព្វា-
ហិត្វា សុវិក្ខាលិតំ វិក្ខាលេត្វា ភណ្ឌិកំ ពន្ធិត្វា យេ-
នាយស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ។ អថខោ
អាយស្មា មហាមោគ្គល្លានោ សេយ្យថាបិ នាម ពលវា
បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ
សម្មិញ្ជេយ្យ ឯវមេវ មន្ទាកិនិយា បោក្ខរណិយា តីរេ
អន្តរហិតោ ជេតវនេ បាតុរហោសិ ។ សោបិ ខោ នាគោ
មន្ទាកិនិយា បោក្ខរណិយា តីរេ អន្តរហិតោ ជេតវនេ
បាតុរហោសិ ។ អថខោ សោ នាគោ អាយស្មតោ
មហាមោគ្គល្លានស្ស ភិសេ ច មុឡាលិកាយោ ច
បដិគ្គាហាបេត្វា ជេតវនេ អន្តរហិតោ មន្ទាកិនិយា

១ ម. ភិសា មុឡាលិកា ។



លោកដ៏ចំរើន លោកម្ចាស់មហាមោគ្គល្លានមកល្អហើយ បពិត្រលោក
ដ៏ចំរើន លោកម្ចាស់ត្រូវការដោយអ្វី ខ្ញុំបាទនឹងប្រគេនលោកម្ចាស់ ។
ព្រះមហាមោគ្គល្លានតបថា ម្នាលអាវុសោ យើងត្រូវការដោយមើមឈូក
និងក្រអៅឈូក ។ ទើបនាគនោះបង្គាប់ទៅនាគដទៃថា ម្នាលនាយ
បើដូច្នោះ អ្នកចូរប្រគេនមើមឈូកនិងក្រអៅឈូកដល់លោកម្ចាស់តាម
សេចក្តីត្រូវការចុះ ។ ឯនាគនោះចុះទៅកាន់ស្រះបោក្ខរណីឈ្មោះមន្ទាកិនី
ហើយដកយកនូវមើមឈូកនិងក្រអៅឈូកដោយប្រមោយហើយលាង
ស្អាតល្អចងជាសំណុំ ចូលទៅរកព្រះមហាមោគ្គល្លានដ៏មានអាយុ ។
លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុបាត់ខ្លួនពីមាត់ស្រះបោក្ខ-
រណីឈ្មោះមន្ទាកិនីទៅប្រាកដនៅក្នុងវត្តជេតពនវិញដោយឆាប់រហ័ស ដូច
ជាបុរសមានកំឡាំង លាដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដៃដែលខ្លួនលា
ចេញ ។ ឯនាគនោះបាត់ខ្លួនអំពីមាត់ស្រះបោក្ខរណីឈ្មោះមន្ទាកិនីទៅ
ប្រាកដនៅក្នុងវត្តជេតពនដែរ ទើបនាគនោះបានឲ្យព្រះមហាមោគ្គល្លានដ៏
មានអាយុទទួលមើមឈូកនិងក្រអៅឈូក ហើយក៏បាត់ខ្លួនអំពីវត្តជេតពន

បោក្ខរណិយា តីរេ បាតុរហោសិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ អាយស្មតោ សារីបុត្តស្ស ភិសេ ច មុឡាលិកាយោ ច ឧបនាមេសិ ។ អថខោ អាយស្មតោ សារីបុត្តស្ស ភិសេ ច មុឡាលិកាយោ ច បរិភុត្តស្ស កាយឌាហាពាធោ បដិប្បស្សម្ភិ ។ ពហូ ភិសា ច មុឡាលិកាយោ ច អវសិដ្ឋា ហោន្តិ ។ តេន ខោ បន សមយេន ភិក្ខូ ទុព្ភិក្ខេ អប្បមត្តកេបិ បវារេន្តិ បដិសង្ខាបិ បដិក្ខិបន្តិ សព្វោ ច សង្ឃោ បវារិតោ ហោតិ ។ ភិក្ខូ កុក្កុច្ចាយន្តា ន បដិគ្គណ្ហន្តិ ។ បដិគ្គណ្ហថ ភិក្ខវេ បរិភុញ្ជថ អនុជានាមិ ភិក្ខវេ វនដ្ឋំ បោក្ខរដ្ឋំ ភុត្តាវិនា បវារិតេន អនតិរិត្តំ បរិភុញ្ជិតុន្តិ ។

(១០៦) តេន ខោ បន សមយេន សាវត្ថិយំ ពហុំ ផលខាទនីយំ ឧប្បន្នំ ហោតិ កប្បិយការកោ ច ន ហោតិ ។ ភិក្ខូ កុក្កុច្ចាយន្តា ផលំ ន បរិភុញ្ជន្តិ ។



ទៅប្រាកដទៀតមាត់ស្រះបោក្ខរណីឈ្មោះមន្ទាកិនីវិញ ។ ចំណែកព្រះមហាមោគ្គល្លានដ៏មានអាយុក៏បង្អោនមើមឈូកនឹងក្រសៅឈូកទៅព្រះសារីបុត្តដ៏មានអាយុ ។ ឯព្រះសារីបុត្តមានអាយុកាលបានឆាន់មើមឈូកនឹងក្រសៅឈូកហើយ ក៏បានសះជាអាពាធដែលក្តៅក្រហល់ក្រហាយក្នុងកាយ ។ មើមឈូកនឹងក្រសៅឈូកគឺសល់នៅជាច្រើន ។ សម័យនោះឯង កាលស្រុកកើតទុរ្ភិក្ស ( អត់បាយ ) ភិក្ខុទាំងឡាយក៏ហាមឃាត់នូវចង្ហាន់បន្តិចបន្តួច ពិចារណាហើយក៏ហាមឃាត់ផង ម្យ៉ាងទៀត សង្ឃទាំងអស់ក៏បានហាមភត្តរួចហើយ ។ ភិក្ខុមានសេចក្តីរង្កៀស ក៏មិនហ៊ានទទួល ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលចុះ ចូរឆាន់ចុះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលឆាន់ហើយ ហាមភត្តរួចហើយ ឆាន់ភោជនមិនមែនជារបស់ដែលកើតពីភិក្ខុឈឺ ឬមិនបានធ្វើវិនយកម្ម ដែលតាំងនៅក្នុងព្រៃ តាំងនៅក្នុងស្រះឈូកបាន ។

(១០៦) សម័យនោះឯង ក្នុងក្រុងសាវត្ថីមានផលសម្រាប់ទំពាស៊ី គឺផ្លែឈើកើតឡើងជាច្រើន តែកប្បិយការកៈគ្មាន ។ ភិក្ខុទាំងឡាយមានសេចក្តីរង្កៀស ក៏មិនហ៊ានឆាន់ផ្លែឈើឡើយ ។ ភិក្ខុទាំងឡាយ

ភគវតោ ឋិតមត្តំ អាហោសិ ។ អនុជានាមិ ភិក្ខវេ អពីជំ និព្វដ្ដពីជំ អកតកប្បំ ផលំ បរិភុញ្ជិតុំ ។

[១០៨] អថខោ ភគវា សាវត្ថិយំ យថាភិរន្តំ វិហរិត្វា យេន រាជគហំ តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន រាជគហំ តទវសរិ ។ តត្រ សុទំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ ភគន្ទលាពាធោ ហោតិ ។ អាកាសគោត្តោ វេជ្ជោ សត្ថកម្មំ ករោតិ ។ អថខោ ភគវា សេនាសនចារិកំ អាហិណ្ឌន្តោ យេន តស្ស ភិក្ខុនោ វិហារោ តេនុបសង្កមិ ។ អទ្ទសា ខោ អាកាសគោត្តោ វេជ្ជោ ភគវន្តំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន ភគវន្តំ ឯតទវោច អាគច្ឆតុ ភវំ គោតមោ ឥមស្ស ភិក្ខុនោ វច្ចមគ្គំ បស្សតុ សេយ្យថាបិ គោធាមុខន្តិ ។ អថខោ ភគវា មំ ខ្វាយំ មោឃបុរិសោ ឧប្បណ្ឌេតីតិ តតោ វ បដិនិវត្តិត្វា ឯតស្មឹ



ក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ផ្លែឈើដែលគ្មានគ្រាប់ (ផ្លែឈើខ្ចី) ទាំងផ្លែឈើដែលខ្លួនបានចោះយកគ្រាប់ចេញ (ដូចផ្លែទុរេនជាដើម) សូម្បីមិនបានធ្វើឲ្យជាកប្បិយ ក៏គួរ (ឆាន់បាន) ។

(១០៨) លំដាប់នោះ ព្រះដ៏មានព្រះភាគគង់នៅក្នុងក្រុងសាវត្ថីសមគួរដល់ព្រះអធ្យាស្រ័យហើយ ទ្រង់យាងទៅកាន់ចារិកក្រុងរាជគ្រឹះ ទ្រង់យាងទៅដោយលំដាប់ ហើយបានដល់នៅក្រុងរាជគ្រឹះ ។ បានឮថា ព្រះមានព្រះភាគទ្រង់គង់នៅវត្តវេឡុវន កលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះនោះឯង ។ សម័យនោះឯង ភិក្ខុ ១ រូបកើតអាពាធឫសដូងបាត ។ ពេទ្យឈ្មោះអាកាសគោត្រធ្វើសត្ថកម្ម (កាត់ឫសដូងបាតនោះ) ដោយកាំបិត ។ ខណៈពេលនោះ ព្រះមានព្រះភាគទ្រង់យាងទៅកាន់ចារិកសេនាសនៈ ក៏បានយាងទៅកាន់លំនៅរបស់ភិក្ខុនោះ ។ ពេទ្យឈ្មោះអាកាសគោត្រ បានឃើញព្រះដ៏មានព្រះភាគយាងមកអំពីចម្ងាយ លុះឃើញហើយក៏បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា សូមព្រះគោតមដ៏ចំរើនទ្រង់យាងមកទតផ្លូវឧច្ចារៈរបស់ភិក្ខុនេះ ដូចជាមាត់សត្វទន្សង ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា មោឃបុរសនេះចំអកឲ្យតថាគតទេតើ ដូច្នេះហើយក៏ទ្រង់យាងត្រឡប់ចាកទីនោះទៅ

និទានេ ឯតស្មិំ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ អត្ថិ កិរ ភិក្ខវេ អមុកស្មិំ វិហារេ ភិក្ខុ គិលា-នោតិ ។ អត្ថិ ភគវាតិ ។ កិំ តស្ស ភិក្ខវេ ភិក្ខុនោ អាពាធោតិ ។ តស្ស ភន្តេ អាយស្មតោ សម្ពាធេ គណ្ឌាពាធោ អាកាសគោត្តោ វេជ្ជោ សត្ថកម្មំ ករោតីតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ ភិក្ខវេ តស្ស មោឃបុរិសស្ស អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម សោ ភិក្ខវេ មោឃបុរិសោ សម្ពាធេ សត្ថកម្មំ ការាបេស្សតិ សម្ពាធេ ភិក្ខវេ សុខុមា ឆវិ ទុរោបយោ វណោ ទុប្បរិហារំ សត្ថំ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ សម្ពាធេ សត្ថកម្មំ ការាបេតព្វំ យោ ការាបេយ្យ អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន ឆព្វគ្គិយា



ព្រោះនិទាននេះ ដំណើរនេះ ទើបទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងវិហារឯណោះមានភិក្ខុឈឺពិតមែនឬទេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ មាន ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឈឺដូចម្ដេច ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន លោកដ៏-មានអាយុនោះ កើតបូសក្នុងទ្វារធំ ពេទ្យឈ្មោះអាកាសគោត្រកំពុងធ្វើសត្ថកម្ម ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំង-ឡាយ អំពើនៃមោឃបុរសនោះមិនសមគួរ មិនទំនង មិនសមរម្យ មិនជារបស់សមណៈ មិនគួរគប្បី មិនមែនជាកិច្ចត្រូវធ្វើទេ ម្នាលភិក្ខុទាំងឡាយ មោឃបុរសនោះមិនគួរឲ្យគេធ្វើសត្ថកម្មក្នុងទីចង្អៀតទេ ម្នាលភិក្ខុទាំងឡាយ ស្បែកក្នុងទីចង្អៀតជារបស់ទន់ល្អិត មានដំបៅសះបានដោយក្រ កម្របុគ្គលនឹងយកកាំបិតទៅប្រើក្នុងទីចង្អៀតបាន ម្នាលភិក្ខុទាំងឡាយ អំពើនុះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេធ្វើសត្ថកម្មក្នុងទីចង្អៀតទេ ភិក្ខុណាឲ្យគេធ្វើ ត្រូវអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង

ភិក្ខូ ភគវតា សត្ថកម្មំ បដិក្ខិត្តន្តិ វត្ថិកម្មំ ការាបេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ វត្ថិកម្មំ ការាបេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខូ វត្ថិកម្មំ ការាបេន្តីតិ ។ សច្ចំ ភគវាតិ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ សម្ពាធស្ស សាមន្តា(១) ទ្វង្គុលេ សត្ថកម្មំ វា វត្ថិកម្មំ វា ការាបេតព្វំ យោ ការាបេយ្យ អាបត្តិ ថុល្លច្ចយស្សាតិ ។

(១០៦) អថខោ ភគវា រាជគហេ យថាភិរន្តំ វិហរិត្វា យេន ពារាណសី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន ពារាណសី តទវសរិ ។ តត្រ សុទំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ តេន ខោ បន សមយេន ពារាណសិយំ សុប្បិយោ ច ឧបាសកោ សុប្បិយា ច ឧបាសិកា

១ សមន្តា ។





ឆព្វគ្គិយភិក្ខុគិតថា ព្រះដ៏មានព្រះភាគទ្រង់ហាមការធ្វើសត្ថកម្មហើយ ទើបឲ្យគេធ្វើវត្ថិកម្មវិញ (ការ[illegible]) ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងឲ្យគេធ្វើវត្ថិកម្មសោះ ។ លំដាប់នោះ ភិក្ខុទាំងនោះក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកឆព្វគ្គិយភិក្ខុឲ្យគេធ្វើវត្ថិកម្ម ពិតមែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។បេ។ ព្រះអង្គទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេធ្វើសត្ថកម្ម ឬវត្ថិកម្ម ក្នុងទីជិតដោយជុំវិញនៃទីចង្អៀតប្រមាណពីរធ្នាប់ទេ ភិក្ខុណាឲ្យគេធ្វើ ត្រូវអាបត្តិថុល្លច្ច័យ ។

(១០៦) គ្រានោះ ព្រះមានព្រះភាគគង់នៅក្នុងក្រុងរាជគ្រឹះសមគួរតាមព្រះអធ្យាស្រ័យហើយ ទ្រង់យាត្រាចេញទៅកាន់ចារិកក្រុងពារាណសី កាលទ្រង់យាត្រាទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ក្រុងពារាណសីនោះ ។ បានឮថា ព្រះដ៏មានព្រះភាគគង់នៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសីនោះ ។ គ្រានោះឯង ក្នុងក្រុងពារាណសីមានជន ២ នាក់ គឺឧបាសកឈ្មោះសុប្បិយៈ ១ ឧបាសិកាឈ្មោះសុប្បិយា ១ ជាអ្នក

ឧភតោ(១) បសន្នា ហោតិ ទាយិកា ការិកា សង្ឃុបដ្ឋាកា ។ អថខោ សុប្បិយា ឧបាសិកា អារាមំ គន្ត្វា វិហារេន វិហារំ បរិវេណេន បរិវេណំ ឧបសង្កមិត្វា ភិក្ខូ បុច្ឆតិ កោ ភន្តេ គិលានោ កស្ស កិំ អាហរិយតូតិ ។ តេន ខោ បន សមយេន អញ្ញតរេន ភិក្ខុនា វិរេចនំ បីតំ ហោតិ ។ អថខោ សោ ភិក្ខុ សុប្បិយំ ឧបាសិកំ ឯតទវោច មយា ខោ ភគិនិ វិរេចនំ បីតំ អត្ថោ មេ បដិច្ឆាទនីយេនាតិ ។ សុដ្ឋុ អយ្យ អាហរិយិស្សតីតិ ឃរំ គន្ត្វា អន្តេវាសិំ អាណាបេសិ គច្ឆ ភណេ បវត្តមំសំ ជានាហីតិ ។ ឯវំ អយ្យេតិ ខោ សោ បុរិសោ សុប្បិយាយ ឧបាសិកាយ បដិស្សុណិត្វា កេវលកប្បំ ពារាណសិំ អាហិណ្ឌន្តោ ន អទ្ទស បវត្តមំសំ ។ អថខោ សោ បុរិសោ យេន សុប្បិយា ឧបាសិកា តេនុបសង្កមិ ឧបសង្កមិត្វា សុប្បិយំ ឧបាសិកំ ឯតទវោច នត្ថយ្យេ បវត្តមំសំ មាឃាតោ អជ្ជាតិ ។ អថខោ សុប្បិយាយ ឧបាសិកាយ ឯតទហោសិ តស្ស
... ភិក្ខុនោ បដិច្ឆាទនីយំ អលភន្តស្ស



មានសេចក្ដីជ្រះថ្លា ជាអ្នកឲ្យទាន ជាអ្នកធ្វើការបម្រើសង្ឃ ។ លំដាប់នោះ សុប្បិយាឧបាសិកាបានទៅកាន់វត្តហើយដើរចូលទៅគ្រប់វិហារគ្រប់ទីបរិវេណ ហើយសួរភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ មានលោកម្ចាស់អង្គណាឈឺខ្លះដែរ លោកម្ចាស់អង្គណាត្រូវការឲ្យខ្ញុំករុណាយករបស់អ្វីមកប្រគេនដែរ ។ វេលានោះឯង ភិក្ខុ ១ រូបបានផឹកថ្នាំបញ្ចុះ ។ ភិក្ខុនោះក៏និយាយនឹងសុប្បិយាឧបាសិកាដូច្នេះថា ម្នាលនាង អាត្មាបានផឹកថ្នាំបញ្ចុះ អាត្មាត្រូវការដោយសាច់ដែលមានឱជារស ។ សុប្បិយាឧបាសិកានិយាយថា ល្អហើយ លោកម្ចាស់ ខ្ញុំនឹងឲ្យគេយកមកប្រគេន (និយាយដូច្នេះហើយ) បានទៅដល់ផ្ទះហើយ ក៏បង្គាប់កូនឈ្នួលថា ម្នាលនាយ អ្នកចូរទៅ អ្នកចូរដឹង (ចូរទិញ) នូវសាច់សត្វដែលស្លាប់ស្រាប់ ។ បុរសនោះបានទទួលពាក្យសុប្បិយាឧបាសិកាថា បាទ អ្នកម្ចាស់ ហើយក៏ដើររកសាច់អស់ទាំងក្រុងពារាណសី មិនបានឃើញសាច់សត្វដែលស្លាប់ស្រាប់ឡើយ ។ បុរសនោះបានចូលទៅរកសុប្បិយាឧបាសិកា លុះចូលទៅដល់ហើយបាននិយាយដូច្នេះនឹងសុប្បិយាឧបាសិកាថា បពិត្រអ្នកម្ចាស់ គ្មានសាច់សត្វដែលស្លាប់ស្រាប់ទេ ព្រោះថ្ងៃនេះគ្មានគេសម្លាប់សត្វសោះ ។ លំដាប់នោះ សុប្បិយាឧបាសិកាមានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលបើភិក្ខុឈឺនោះឯងមិនបានសាច់ដែលមានឱជារស

អាពាធោ វា អភិវឌ្ឍិស្សតិ កាលកិរិយា វា ភវិស្សតិ ន ខោ មេ តំ បតិរូបំ យាហំ បដិស្សុណិត្វា ន ហារាបេយ្យន្តិ ។ បោត្ថនិកំ គហេត្វា ឩរុមំសំ ឧក្កន្តិត្វា ទាសិយា អទាសិ ហន្ទ ជេ ឥមំ មំសំ សម្បាទេត្វា អមុកស្មិំ វិហារេ ភិក្ខុ គិលានោ តស្ស ទជ្ជេហិ យោ ច មំ បុច្ឆតិ គិលានាតិ បដិវេទេហិ ឧត្តរាសង្គេន ឩរុំ វេឋេត្វា ឱវរកំ បវិសិត្វា មញ្ចកេ និបជ្ជិ ។ អថ ខោ សុប្បិយោ ឧបាសកោ ឃរំ គន្ត្វា ទាសិំ បុច្ឆិ កហំ សុប្បិយាតិ ។ ឯសាយ្យ ឱវរកេ និបន្នាតិ ។ អថ ខោ សុប្បិយោ ឧបាសកោ យេន សុប្បិយា ឧបាសិកា តេនុបសង្កមិ ឧបសង្កមិត្វា សុប្បិយំ ឧបាសិកំ ឯតទវោច កិស្ស និបន្នាសីតិ ។ គិលានម្ហីតិ ។ កិំ តេ អាពាធោតិ ។ អថ ខោ សុប្បិយា ឧបាសិកា សុប្បិយស្ស ឧបាសកស្ស ឯតមត្ថំ អារោចេសិ ។ អថ ខោ សុប្បិយោ ឧបាសកោ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ យាវ សទ្ធាយំ



អាពាធនឹងរឹតតែចំរើនឡើង ឬមួយនឹងធ្វើកាលកិរិយាទៅមិនខាន (អញ្ចឹង) អាត្មាអញ បានទទួលពាក្យហើយមិនប្រគេនសាច់ ដល់ព្រះថេរជាម្ចាស់ឲ្យតែ យកទៅប្រគេនវិញ គឺជាការមិនសមគួរដល់អញសោះ ។ សុប្បិយាឧបាសិកាក៏កាន់យកកាំបិតសម្រាប់ចាក់សាច់មកកាត់សាច់ភ្លៅ(របស់ខ្លួន) ហើយហុចឲ្យទៅទាសីថា ហ៎ នាងឯងចូរយកសាច់នេះទៅតាក់តែង ហើយយកទៅប្រគេនដល់ភិក្ខុឈឺក្នុងវិហារឯណោះចុះ ម្យ៉ាងទៀត (បើមាន) ភិក្ខុណាសួរគេអញ នាងឯងចូរប្រាប់ថាអញឈឺ (និយាយត្រឹមនេះហើយ) បានរុំភ្លៅដោយសំពត់សម្រាប់ដណ្ដប់ហើយចូលទៅក្នុងបន្ទប់ ដេកលើគ្រែ ។ លំដាប់នោះ សុប្បិយឧបាសកបានទៅកាន់ផ្ទះហើយសួរទាសីថា នាងសុប្បិយាទៅណា ។ ទាសីនោះប្រាប់ថា បពិត្រអ្នកម្ចាស់ អ្នកម្ចាស់នោះសម្រាន្តក្នុងបន្ទប់ ។ លំដាប់នោះ សុប្បិយឧបាសកបានចូលទៅរកសុប្បិយាឧបាសិកា លុះចូលទៅដល់ហើយសួរសុប្បិយាឧបាសិកាថា ម៉េចនៅថា ព្រោះហេតុអ្វីបានជានាងដេក ។ សុប្បិយាឧបាសិកាឆ្លើយថា ខ្ញុំឈឺ ។ សុប្បិយឧបាសកសួរថា នាងឈឺអ្វី ។ ទើបសុប្បិយាឧបាសិកាប្រាប់សេចក្ដីនេះដល់សុប្បិយឧបាសក (ដោយសព្វគ្រប់) ។ លំដាប់នោះ សុប្បិយឧបាសកនឹកថា អើហ្ន៎ អស្ចារ្យពេកណាស់ អើហ្ន៎ ចំឡែកពេកណាស់ សុប្បិយា

សុប្បិយា បសន្នា យត្រ ហិ នាម អត្តនោបិ មំសានិ
បរិច្ចត្តានិ កឹ បនិមាយ(១) អញ្ញំ កិញ្ចិ អទេយ្យំ ភ-
វិស្សតីតិ ហដ្ឋោ ឧទគ្គោ យេន ភគវា តេនុបសង្កមិ
ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។
ឯកមន្តំ និសិន្នោ ខោ សុប្បិយោ ឧបាសកោ ភគ-
វន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ
ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា
តុណ្ហីភាវេន ។ អថខោ សុប្បិយោ ឧបាសកោ ភគវ-
តោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេ-
ត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ សុប្បិយោ
ឧបាសកោ តស្សា រត្តិយា អច្ចយេន បណីតំ ខាទនី-
យំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អា-
រោចាបេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ
ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន
សុប្បិយស្ស ឧបាសកស្ស និវេសនំ តេនុបសង្កមិ ឧប-
សង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។
អថខោ សុប្បិយោ ឧបាសកោ យេន ភគវា តេនុបសង្កមិ



ឧបាសិកានេះជាស្រីមានសទ្ធាជ្រះថ្លាមែន សម្បូណ៌សាច់របស់ខ្លួនក៏លះបង់បាន ចំណង់បើវត្ថុដទៃឯទៀត ឧបាសិកានេះនឹងមិនឲ្យដូចម្តេចបាន គិតដូច្នេះហើយក៏មានចិត្តរីករាយខ្ពស់ឡើង បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ លុះសុប្បិយឧបាសកអង្គុយក្នុងទីសមគួរហើយបានក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគព្រមទាំងព្រះភិក្ខុសង្ឃនិមន្តទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយការស្ងៀម ។ លំដាប់នោះ សុប្បិយឧបាសកបានដឹងថា ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ លុះកន្លងរាត្រីនោះទៅហើយសុប្បិយឧបាសកក៏បានតាក់តែងខាទនីយភោជនីយាហារដ៏ឧត្តមហើយ ក៏ឲ្យមនុស្សទៅក្រាបបង្គំទូលកាលសមគួរចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពេលសមគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះ វេលាព្រឹក ព្រះដ៏មានព្រះភាគទ្រង់ស្បង់ហើយប្រដាប់ដោយបាត្រនិងចីវរ យាងទៅកាន់ផ្ទះសុប្បិយឧបាសក លុះយាងទៅដល់ហើយគង់លើអាសនៈដែលគេរៀបចំថ្វាយព្រមទាំងភិក្ខុសង្ឃ ។ គ្រានោះ សុប្បិយឧបាសកបានចូលទៅគាល់

ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ សុប្បិយំ ឧបាសកំ ភគវា ឯតទវោច កហំ សុប្បិយាតិ ។ គិលានា ភគវាតិ ។ តេនហិ អាគច្ឆតូតិ ។ ន ភគវា ឧស្សហតីតិ ។ តេនហិ បរិគ្គហេត្វាបិ អានេថាតិ ។ អថខោ សុប្បិយោ ឧបាសកោ សុប្បិយំ ឧបាសិកំ បរិគ្គហេត្វា អានេសិ ។ តស្សា សហ ទស្សនេន ភគវតោ តាវមហា វណោ រូឡ្ហោ អហោសិ សុច្ឆវី លោមជាតោ ។ អថខោ សុប្បិយោ ច ឧបាសកោ សុប្បិយា ច ឧបាសិកា អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ តថាគតស្ស មហិទ្ធិកតា មហានុភាវតា យត្រ ហិ នាម សហ ទស្សនេន ភគវតោ តាវមហា វណោ រូឡ្ហោ ភវិស្សតិ សុច្ឆវី លោមជាតោតិ ហដ្ឋា ឧទគ្គា ពុទ្ធប្បមុខំ



ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីសមគួរ ។ លុះសុប្បិយឧបាសកឈរនៅក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់មានបន្ទូលសួរដូច្នេះថា នាងសុប្បិយានៅក្នុងទីណា ។ សុប្បិយឧបាសកក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ នាងសុប្បិយាឈឺ ។ ព្រះអង្គទ្រង់មានបន្ទូលថា បើដូច្នោះ (ចូរ) នាងសុប្បិយាចូលមក ។ សុប្បិយឧបាសកក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ នាងសុប្បិយាមិនអាចនឹងមកបានទេ ។ ព្រះអង្គទ្រង់ត្រាស់ថា បើដូច្នោះ អ្នកទាំងឡាយចូរគ្រាហ៍នាំយកមក ។ លំដាប់នោះ សុប្បិយឧបាសកបានគ្រាហ៍សុប្បិយាឧបាសិកានាំមកថ្វាយ ។ ខណៈដែលព្រះមានព្រះភាគទ្រង់ទតឃើញ (ការណ៍) ដំបៅរបស់នាងដែលធំដល់ម្លោះ ក៏ដុះសាច់សះជាមានសម្បុរល្អ មានរោមដុះពេញឡើងវិញមួយរំពេច ។ លំដាប់នោះ សុប្បិយឧបាសកនិងសុប្បិយាឧបាសិកាបាននិយាយគ្នាថា អើហ្ន៎ អស្ចារ្យពេកណាស់ អើហ្ន៎ ចំឡែកពេកណាស់ ព្រះតថាគតមានឫទ្ធិច្រើន មានអានុភាពច្រើន ត្រង់តែព្រះអង្គទ្រង់បានទតឃើញមួយរំពេច ដំបៅដែលធំដល់ម្លោះក៏ដុះសាច់សះជាមានសម្បុរល្អមានរោមដុះពេញឡើងវិញ (អ្នកទាំងនោះ) មានចិត្តរីករាយខ្ពស់ឡើង ក៏អង្គាសខាទនីយភោជនីយាហារ

សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិំសុ ។ អថខោ ភគវា សុប្បិយញ្ច ឧបាសកំ សុប្បិយញ្ច ឧបាសិកំ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេ-ជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។

[១០៧] អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ កោ ភិក្ខវេ សុប្បិយំ ឧបាសិកំ មំសំ វិញ្ញាបេសីតិ ។ ឯវំ វុត្តេ សោ ភិក្ខុ ភគវន្តំ ឯតទវោច អហំ ខោ ភន្តេ សុប្បិយំ ឧបាសិកំ មំសំ វិញ្ញាបេសិន្តិ[១] ។ អា-ហារិយិត្ថ ភិក្ខូតិ ។ អាហារិយិត្ថ ភគវាតិ ។ បរិភុញ្ជិ

១ វិញ្ញាបេមីតិ កត្ថចិ បោត្ថកេ ទិស្សតិ ។



(បង្អែមចំណាប) ដ៏ឆ្ងាញ់ពីសា ដោយដៃៗខ្លួន ចំពោះព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែឃាត់លោកថាកកលែងទទួលទៀត លុះព្រះដ៏មានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏នាំគ្នាអង្គុយក្នុងទីសមគួរ ។ លំដាប់នោះ ព្រះមានព្រះភាគញ៉ាំងសុប្បិយឧបាសកនិងសុប្បិយាឧបាសិកា ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។

[១០៧] គ្រានោះឯង ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃហើយត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាសូមសាច់អំពីសុប្បិយាឧបាសិកា ។ កាលបើព្រះដ៏មានព្រះភាគត្រាស់សួរយ៉ាងនេះហើយ ភិក្ខុនោះក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានសូមសាច់អំពីសុប្បិយាឧបា-សិកា ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកបានឲ្យគេនាំយកសាច់មកហើយឬទៅ ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គបានឲ្យគេនាំយកសាច់នោះមកហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា

ត្វំ ភិក្ខូតិ ។ បរិភុញ្ជាហំ ភគវាតិ ។ បដិវេក្ខិ ត្វំ ភិក្ខូតិ ។ នាហំ ភគវា បដិវេក្ខិន្តិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស អប្បដិវេក្ខិត្វា មំសំ បរិភុញ្ជិស្សសិ មនុស្សមំសំ ខោ តយា មោឃបុរិស បរិភុត្តំ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ សន្តិ ភិក្ខវេ មនុស្សា សទ្ធា បសន្នា តេហិ អត្តនោបិ មំសានិ បរិច្ចត្តានិ ន ភិក្ខវេ មនុស្សមំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ថុល្លច្ចយស្ស ។ ន ច ភិក្ខវេ អប្បដិវេក្ខិត្វា មំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១០៨) តេន ខោ បន សមយេន រញ្ញោ ហត្ថី មរន្តិ ។ មនុស្សា ទុព្ភិក្ខេ ហត្ថិមំសំ បរិភុញ្ជន្តិ ភិក្ខូនំ បិណ្ឌាយ ចរន្តានំ ហត្ថិមំសំ ទេន្តិ ។ ភិក្ខូ ហត្ថិមំសំ



ម្នាលភិក្ខុ អ្នកបានឆាន់ហើយឬនៅ ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គបានឆាន់ហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ (មុននឹងឆាន់) អ្នកបានពិចារណាដែរឬទេ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនបានពិចារណាទេ ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯងមិនសមបើនឹងមិនពិចារណាហើយហ៊ានឆាន់សាច់ (ដូច្នេះ) សោះ ម្នាលមោឃបុរស អ្នកឯងឆាន់សាច់មនុស្សពិតហើយ ម្នាលមោឃបុរស អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ទ្រង់តិះដៀលរួចហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សដែលមានសទ្ធា មានសេចក្តីជ្រះថ្លា មនុស្សទាំងនោះសូម្បីតែសាច់របស់ខ្លួនឯងក៏គង់លះបង់បាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់មនុស្សទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិថុល្លច្ច័យ ។ មួយទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបានពិចារណាជាមុនហើយ មិនត្រូវឆាន់សាច់ទេ ភិក្ខុណាឆាន់ត្រូវអាបត្តិទុក្កដ ។

(១០៨) សម័យនោះឯង មានដំរីរបស់ស្តេចស្លាប់ជាច្រើន ។ ចួនជាវេលាស្រេកអត់ឃ្លាន មនុស្សទាំងឡាយនាំគ្នាស៊ីសាច់ដំរី ក៏បានប្រគេនសាច់ដំរីដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុទាំងឡាយ

បរិភុញ្ជន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ហត្ថិមំសំ បរិភុញ្ជិស្សន្តិ រាជង្គំ ហត្ថី សចេ រាជា ជានេយ្យ ន តេសំ(១) អត្តមនោ អស្សាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ហត្ថិមំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន រញ្ញោ អស្សា មរន្តិ ។ មនុស្សា ទុព្ភិក្ខេ អស្សមំសំ បរិភុញ្ជន្តិ ភិក្ខូនំ បិណ្ឌាយ ចរន្តានំ អស្សមំសំ ទេន្តិ ។ ភិក្ខូ អស្សមំសំ បរិភុញ្ជន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា អស្សមំសំ បរិភុញ្ជិស្សន្តិ រាជង្គំ អស្សា សចេ រាជា ជានេយ្យ ន តេសំ អត្តមនោ អស្សាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ អស្សមំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន មនុស្សា ទុព្ភិក្ខេ សុនខមំសំ បរិភុញ្ជន្តិ ភិក្ខូនំ

១ ម. តេសំ ។

៤៧០


ក៏នាំគ្នាឆាន់សាច់ដំរី ។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណសក្យបុត្រមិនសមបើនឹងហ៊ានឆាន់សាច់ដំរីសោះ ដំរីក៏ជាអង្គ (យាន) របស់ស្តេច បើស្តេចទ្រង់ជ្រាប មុខជាខ្ញាល់នឹងភិក្ខុទាំងនោះមិនខាន ។ ពួកភិក្ខុក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ដំរីទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង (មាន) សេះរបស់ស្តេចស្លាប់ជាច្រើន ។ ក្នុងវេលាស្រេកអត់ឃ្លាន មនុស្សទាំងឡាយនាំគ្នាស៊ីសាច់សេះ ក៏ប្រគេនសាច់សេះដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុទាំងឡាយក៏នាំគ្នាឆាន់សាច់សេះ ។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណសក្យបុត្រមិនសមបើនឹងហ៊ានឆាន់សាច់សេះទេ ព្រោះសេះជាអង្គ (យាន) របស់ស្តេចដែរ បើស្តេចទ្រង់ជ្រាបមុខជាខ្ញាល់នឹងភិក្ខុទាំងនោះមិនខាន ។ ពួកភិក្ខុក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់សេះទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង វេលាស្រេកអត់ឃ្លាន មនុស្សទាំងឡាយនាំគ្នាស៊ីសាច់ឆ្កែ ក៏ប្រគេនសាច់ឆ្កែដល់ពួកភិក្ខុដែលត្រាច់ទៅ

បិណ្ឌាយ ចរន្តានំ សុនខមំសំ ទេន្តិ ។ ភិក្ខូ សុន-
ខមំសំ បរិភុញ្ជន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបា-
ចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា សុន-
ខមំសំ បរិភុញ្ជិស្សន្តិ ជេគុច្ឆោ សុនខោ បដិក្កូលោតិ ។
ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ សុនខមំសំ
បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។
តេន ខោ បន សមយេន មនុស្សា ទុព្ភិក្ខេ អហិ-
មំសំ បរិភុញ្ជន្តិ ភិក្ខូនំ បិណ្ឌាយ ចរន្តានំ អហិមំសំ
ទេន្តិ ។ ភិក្ខូ អហិមំសំ បរិភុញ្ជន្តិ ។ មនុស្សា
ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា
សក្យបុត្តិយា អហិមំសំ បរិភុញ្ជិស្សន្តិ ជេគុច្ឆោ អហិ
បដិក្កូលោតិ ។ សុបស្សោបិ នាគរាជា យេន ភគវា
តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ
អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ សុបស្សោ នាគរាជា
ភគវន្តំ ឯតទវោច សន្តិ ភន្តេ នាគា អស្សទ្ធា អប្ប-
សន្នា តេ អប្បមត្តកេហិ ភិក្ខូ វិហេឋេយ្យុំ សាធុ
ភន្តេ អយ្យា អហិមំសំ ន បរិភុញ្ជេយ្យុន្តិ ។ អថខោ



បិណ្ឌបាត ។ ភិក្ខុទាំងឡាយក៏ឆាន់សាច់ឆ្កែ ។ ពួកមនុស្សពោល
ទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណសក្យបុត្រមិនសមបើនឹងហ៊ាន
ឆាន់សាច់ឆ្កែសោះ ព្រោះឆ្កែជាសត្វគួរខ្ពើមរអើម ។ ភិក្ខុទាំងឡាយ
ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់
ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ឆ្កែទេ ភិក្ខុណាឆាន់ ត្រូវ
អាបត្តិទុក្កដ ។ សម័យនោះឯង ពេលស្រេកអត់បាយ មនុស្ស
ទាំងឡាយស៊ីសាច់ពស់ ក៏បានប្រគេនសាច់ពស់ដល់ពួកភិក្ខុដែល
ត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុទាំងឡាយក៏ឆាន់សាច់ពស់ ។ ពួក
មនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណសក្យបុត្រមិន
សមបើនឹងហ៊ានឆាន់សាច់ពស់សោះ ព្រោះពស់ជាសត្វគួរខ្ពើមរអើម ។
ចំណែកខាងស្តេចនាគឈ្មោះសុបស្សបានចូលទៅគាល់ព្រះដ៏មានព្រះ-
ភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះមានព្រះភាគហើយឋិតនៅ
ក្នុងទីសមគួរ ។ លុះសុបស្សនាគរាជឋិតនៅក្នុងទីសមគួរហើយ បានក្រាប
បង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន នាគទាំងឡាយ
ជាសត្វគ្មានសទ្ធា គ្មានសេចក្តីជ្រះថ្លាទេ តែងតែពួកនាគទាំងនោះបៀត-
បៀនភិក្ខុទាំងឡាយខ្លះមិនខាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូម
អង្វរ សូមកុំឲ្យលោកម្ចាស់ទាំងឡាយឆាន់សាច់ពស់ឡើយ ។ លំដាប់នោះ

ភគវា សុបស្សំ នាគរាជានំ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ សុបស្សោ នាគរាជា ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ អហិមំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។

តេន ខោ បន សមយេន លុទ្ទកា(១) សីហំ ហន្ត្វា សីហមំសំ បរិភុញ្ជន្តិ ភិក្ខូនំ បិណ្ឌាយ ចរន្តានំ សីហមំសំ ទេន្តិ ។ ភិក្ខូ សីហមំសំ បរិភុញ្ជិត្វា អរញ្ញេ វិហរន្តិ ។ សីហា សីហមំសគន្ធេន ភិក្ខូ បរិបាតេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ សីហមំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។

តេន ខោ បន សមយេន លុទ្ទកា ព្យគ្ឃំ ហន្ត្វា ព្យគ្ឃមំសំ បរិភុញ្ជន្តិ ភិក្ខូនំ បិណ្ឌាយ ចរន្តានំ ព្យគ្ឃមំសំ ទេន្តិ ។ ភិក្ខូ ព្យគ្ឃមំសំ បរិភុញ្ជិត្វា អរញ្ញេ វិហរន្តិ



ព្រះមានព្រះភាគញ៉ាំងសុបស្សនាគរាជ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ។ លុះសុបស្សនាគរាជ ដែលព្រះដ៏មានព្រះភាគ ទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណាចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ពស់ទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

សម័យនោះឯង ពួកព្រានសម្លាប់សត្វសីហៈហើយស៊ីសាច់សីហៈ ក៏បានប្រគេនសាច់សីហៈដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ពួកភិក្ខុឆាន់សាច់សីហៈហើយក៏ទៅនៅក្នុងព្រៃ ។ ពួកសត្វសីហៈធុំក្លិនសាច់សីហៈ ក៏សម្លាប់ភិក្ខុជាច្រើន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់សីហៈទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

សម័យនោះឯង ពួកព្រានសម្លាប់ខ្លាធំហើយស៊ីសាច់ខ្លាធំ ក៏បានប្រគេនសាច់ខ្លាធំដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ពួកភិក្ខុឆាន់សាច់ខ្លាធំហើយ ទៅនៅក្នុងព្រៃ ។

ព្យគ្ឃា ព្យគ្ឃមំសគន្ធេន ភិក្ខូ បរិបាតេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ព្យគ្ឃមំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន មនុស្សា ទីបិំ ហន្ត្វា ទីបិមំសំ បរិភុញ្ជន្តិ ភិក្ខូនំ បិណ្ឌាយ ចរន្តានំ ទីបិមំសំ ទេន្តិ ។ ភិក្ខូ ទីបិមំសំ បរិភុញ្ជិត្វា អរញ្ញេ វិហរន្តិ ។ ទីបី ទីបិមំសគន្ធេន ភិក្ខូ បរិបាតេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ទីបិមំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន មនុស្សា អច្ឆំ ហន្ត្វា អច្ឆមំសំ បរិភុញ្ជន្តិ ភិក្ខូនំ បិណ្ឌាយ ចរន្តានំ អច្ឆមំសំ ទេន្តិ ។ ភិក្ខូ អច្ឆមំសំ បរិភុញ្ជិត្វា អរញ្ញេ វិហរន្តិ ។ អច្ឆា អច្ឆមំសគន្ធេន ភិក្ខូ បរិបាតេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ អច្ឆមំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន មនុស្សា តរច្ឆំ ហន្ត្វា តរច្ឆមំសំ បរិភុញ្ជន្តិ ភិក្ខូនំ



ពួកខ្លាធំបានធុំក្លិនសាច់ខ្លាធំក៏សម្លាប់ភិក្ខុជាច្រើន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ខ្លាធំទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកព្រានសម្លាប់ខ្លាដំបង ហើយស៊ីសាច់ខ្លាដំបង ក៏បានប្រគេនសាច់ខ្លាដំបងដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ពួកភិក្ខុឆាន់សាច់ខ្លាដំបងហើយ ក៏ទៅនៅក្នុងព្រៃ ។ ពួកខ្លាដំបងបានធុំក្លិនសាច់ខ្លាដំបងក៏សម្លាប់ភិក្ខុជាច្រើន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ខ្លាដំបងទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកព្រានសម្លាប់សត្វខ្លាឃ្មុំ ហើយស៊ីសាច់ខ្លាឃ្មុំ ក៏បានប្រគេនសាច់ខ្លាឃ្មុំដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ពួកភិក្ខុឆាន់សាច់ខ្លាឃ្មុំ ហើយក៏ទៅនៅក្នុងព្រៃ ។ ពួកខ្លាឃ្មុំបានធុំក្លិនសាច់ខ្លាឃ្មុំ ហើយក៏សម្លាប់ភិក្ខុជាច្រើន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ខ្លាឃ្មុំទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកព្រានសម្លាប់សត្វឆ្កែព្រៃ ហើយស៊ីសាច់ឆ្កែព្រៃ ក៏បានប្រគេនសាច់

បិណ្ឌាយ ចរន្តានំ តរច្ឆមំសំ ទេន្តិ ។ ភិក្ខូ តរច្ឆមំសំ បរិភុញ្ជិត្វា អរញ្ញេ វិហរន្តិ ។ តរច្ឆា តរច្ឆមំសគន្ធេន ភិក្ខូ បរិបាតេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ តរច្ឆមំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។

សុប្បិយាភាណវារំ និដ្ឋិតំ ទុតិយំ ។

[១០៩] អថខោ ភគវា ពារាណសិយំ យថាភិរន្តំ វិហរិត្វា យេន អន្ធកវិន្ទំ តេន ចារិកំ បក្កាមិ មហតា ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេលសេហិ ភិក្ខុសតេហិ ។ តេន ខោ បន សមយេន ជានបទា មនុស្សា ពហុំ លោណម្បិ តេលម្បិ តណ្ឌុលម្បិ ខាទនីយម្បិ សកដេសុ អារោបេត្វា ពុទ្ធប្បមុខស្ស ភិក្ខុសង្ឃស្ស បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធា ហោន្តិ យទា បដិបាដឹ លភិស្សាម តទា ភត្តំ ករិស្សាមាតិ បញ្ចមត្តានិ ច វិឃាសាទសតានិ ។ អថខោ ភគវា អនុបុព្វេន ចារិកំ ចរមានោ យេន អន្ធកវិន្ទំ តទវសរិ ។ អថខោ អញ្ញតរស្ស ព្រាហ្មណស្ស បដិបាដឹ អលភន្តស្ស ឯតទហោសិ អតីតានិ[1] ខោ មេ ទ្វេ

១. ឩសិតានិ ។



ខ្លាត្រីដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុទាំងឡាយឆាន់សាច់ខ្លាត្រី ហើយគង់នៅក្នុងព្រៃ ។ ពួកខ្លាត្រីបានធុំក្លិនសាច់ខ្លាត្រីហើយ ក៏សម្លាប់ភិក្ខុជាច្រើន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ខ្លាត្រីទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

ចប់ សុប្បិយាភាណវារៈ ទី ២ ។

[១០៩] គ្រានោះ ព្រះដ៏មានព្រះភាគគង់នៅក្នុងក្រុងពារាណសី សមគួរតាមព្រះអធ្យាស្រ័យហើយ ក៏យាងចេញទៅកាន់ចារិកទៅឯអន្ធកវិន្ទប្រទេស ជាមួយនឹងភិក្ខុសង្ឃជាច្រើនប្រមាណមួយពាន់ពីររយហាសិបរូប ។ សម័យនោះឯង ពួកមនុស្សអ្នកជនបទបានផ្ទុកអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ ក្នុងរទេះទាំងឡាយហើយក៏ដើរទៅតាមក្រោយ ៗ ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ ពួកមនុស្សអ្នកស៊ីដែលប្រមាណប្រាំរយ ទាំងគិតថា (យើ) ក្នុងវេលាដែលបានលំដាប់ (វេន) នៃភត្តក្នុងកាលណា នឹងធ្វើភត្តក្នុងកាលនោះ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកតាមលំដាប់ ក៏បានដល់ទៅអន្ធកវិន្ទប្រទេសនោះ ។ លំដាប់នោះ កាលព្រាហ្មណ៍ម្នាក់មិនបានលំដាប់ (វេន) នៃភត្ត ក៏មានសេចក្តីរំពឹងយ៉ាងនេះថា អាត្មាអញបានដើរតាមភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន

មាសានិ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ អនុពន្ធស្ស យទា បដិបា-
ទី លភិស្សាមិ តទា ភត្តំ ករិស្សាមីតិ ន ច មេ បដិបាទី
លព្ភតិ អហញ្ចម្ហិ ឯកកោ ពហុ ច មេ ឃរាវាសត្ថោ
ហាយតិ យន្នូនាហំ ភត្តគ្គំ ឱលោកេយ្យំ យំ ភត្តគ្គេ
នាស្ស តំ បដិយាទេយ្យន្តិ ។ អថខោ សោ ព្រាហ្មណោ
ភត្តគ្គំ ឱលោកេន្តោ ទ្វេ នាទ្ទស យាគុញ្ច មធុគោឡ-
កញ្ច ។ អថខោ សោ ព្រាហ្មណោ យេនាយស្មា អានន្ទោ
តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតទវោច
ឥធ មេ ភោ អានន្ទ បដិបាទី អលភន្តស្ស ឯតទហោសិ
អតិក្កន្តានិ ខោ មេ ទ្វេ មាសានិ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ
អនុពន្ធស្ស យទា បដិបាទី លភិស្សាមិ តទា ភត្តំ ក-
រិស្សាមីតិ ន ច មេ បដិបាទី លព្ភតិ អហញ្ចម្ហិ ឯកកោ
ពហុ ច មេ ឃរាវាសត្ថោ ហាយតិ យន្នូនាហំ ភត្តគ្គំ
ឱលោកេយ្យំ យំ ភត្តគ្គេ នាស្ស តំ បដិយាទេយ្យន្តិ



ដល់ទៅ ២ ខែហើយ ដោយគិតថា បើអាត្មាអញបានលំដាប់ (វេន) នៃភត្តកាលណា នឹងធ្វើភត្តកាលនោះ ឥឡូវលំដាប់ (វេន) នៃភត្ត អាត្មាអញមិនទាន់បាននៅឡើយ ខ្លួនអញទៀតសោតក៏តែម្នាក់ឯង ទាំងប្រយោជន៍ជាឃរាវាសរបស់អាត្មាអញទៀតក៏សាបសូន្យទៅជាច្រើន បើដូច្នោះមានតែអាត្មាអញទៅត្រួតមើលរោងភត្ត វត្ថុណាគ្មានក្នុងរោងភត្ត អាត្មាអញគប្បីតាក់តែងវត្ថុនោះ ។ វេលាដែលព្រាហ្មណ៍នោះទៅមើលរោងភត្តក៏មិនឃើញវត្ថុពីរយ៉ាង គឺបបរនិងនំមានរសផ្អែមឡើយ(១) ។ ទើបព្រាហ្មណ៍នោះចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយនិយាយនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចំរើន កាលខ្ញុំករុណាមិនបានលំដាប់ (វេន) នៃភត្តទាំងនេះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញដើរតាមភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានដល់ ២ ខែហើយ ដោយគិតថា (បើ)អាត្មាអញបានលំដាប់(វេន)នៃភត្តពេលណា នឹងធ្វើភត្តពេលនោះ ឥឡូវអាត្មាអញមិនទាន់បានលំដាប់(វេន)នៃភត្តនៅឡើយ ខ្លួនអញទៀតសោតក៏តែម្នាក់ឯង ទាំងប្រយោជន៍ជាឃរាវាសរបស់អញទៀតក៏សាបសូន្យទៅជាច្រើន បើដូច្នោះមានតែអាត្មាអញទៅត្រួតមើលរោងភត្ត វត្ថុណាគ្មានក្នុងរោងភត្ត អាត្មាអញនឹងតាក់តែង

១ ក្នុងដីកាថា នំដែលគេលាយដោយឃ្មុំនិងស្ករជាដើម ។

សោ ខោ អហំ ភោ អានន្ទ ភត្តគ្គំ ឱលោកេន្តោ នាទ្ទសំ យាគុញ្ច មធុគោឡកញ្ច សចាហំ ភោ អានន្ទ បដិយាទេយ្យំ យាគុញ្ច មធុគោឡកញ្ច បដិគ្គណ្ហេយ្យ មេ ភវំ គោតមោតិ ។ តេនហិ ព្រាហ្មណ ភគវន្តំ បដិបុច្ឆិស្សាមីតិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ តេនហិ អានន្ទ បដិយាទេតូតិ ។ តេនហិ ព្រាហ្មណ បដិយាទេហីតិ ។ អថខោ សោ ព្រាហ្មណោ តស្សា រត្តិយា អច្ចយេន បហូតំ យាគុញ្ច មធុគោឡកញ្ច បដិយាទាបេត្វា ភគវតោ ឧបនាមេសិ បដិគ្គណ្ហាតុ មេ ភវំ គោតមោ យាគុញ្ច មធុគោឡកញ្ចាតិ ។ តេនហិ ព្រាហ្មណ ភិក្ខូនំ ទេហីតិ ។ ភិក្ខូ កុក្កុច្ចាយន្តា ន បដិគ្គណ្ហន្តិ ។ បដិគ្គណ្ហថ ភិក្ខវេ បរិភុញ្ជថាតិ ។



វត្ថុនោះ ( យាគូនិងនំ ) បពិត្រព្រះអានន្ទដ៏ចំរើន កាលខ្ញុំព្រះករុណាទៅមើលរោងភត្ត មិនបានឃើញវត្ថុគឺយាគូ និងបបរនិងនំមានរសផ្អែមឡើយ បពិត្រព្រះអានន្ទដ៏ចំរើន បើខ្ញុំករុណាតាក់តែងបបរនិងនំមានរសផ្អែមទុកថ្វាយ ព្រះគោតមដ៏ចំរើនទ្រង់ទទួលរបស់ខ្ញុំករុណាដែរឬ ។ ព្រះអានន្ទឆ្លើយថា ម្នាលព្រាហ្មណ៍ បើដូច្នោះចាំអាត្មាទូលសួរព្រះដ៏មានព្រះភាគសិន ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុបានក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះឲ្យព្រាហ្មណ៍នោះតាក់តែងចុះ ។ ទើបព្រះអានន្ទទៅប្រាប់ព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរតាក់តែងចុះ ។ លុះរាត្រីនោះកន្លងទៅហើយ ឯព្រាហ្មណ៍នោះតាក់តែងបបរនិងនំមានរសផ្អែមជាច្រើន ក៏បានបង្អោនថ្វាយចំពោះព្រះដ៏មានព្រះភាគ ហើយទូលថា សូមព្រះគោតមដ៏ចំរើនទ្រង់ទទួលបបរនិងនំមានរសផ្អែមរបស់ខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរប្រគេនដល់ភិក្ខុទាំងឡាយចុះ ។ ពួកភិក្ខុរង្កៀសមិនហ៊ានទទួល ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលចុះ ចូរឆាន់ចុះ ។

អថខោ សោ ព្រាហ្មណោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតាយ យាគុយា ច មធុគោឡកេន ច សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ ធោតហត្ថំ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តំ ព្រាហ្មណំ ភគវា ឯតទវោច ទសយិមេ(១) ព្រាហ្មណ អានិសំសា យាគុយា កតមេ ទស យាគុំ ទេន្តោ អាយុំ ទេតិ វណ្ណំ ទេតិ សុខំ ទេតិ ពលំ ទេតិ បដិភាណំ ទេតិ យាគុ បីតា ខុទ្ទំ បដិហនតិ បិបាសំ បដិវិនោទេតិ វាតំ អនុលោមេតិ វត្ថឹ សោធេតិ អាមាវសេសំ បាចេតិ ឥមេ ខោ ព្រាហ្មណ ទសានិសំសា យាគុយាតិ ។

[១១០] យោ សញ្ញតានំ បរទត្តភោជិនំ
កាលេន សក្កច្ច ទទាតិ យាគុំ
ទសស្ស ឋានានិ អនុប្បវេច្ឆតិ
អាយុញ្ច វណ្ណញ្ច សុខំ ពលញ្ច
បដិភាណមស្ស ឧបជាយតេ តតោ

១ ម. ទសិមេ ។



ព្រាហ្មណ៍នោះអង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានដោយបបរនិងនំមានរសផ្អែមជាច្រើនដោយដៃរបស់ខ្លួន ឲ្យឆ្អែតស្កប់ស្កល់ ព្រោះតែលោកប្រកែកលែងទទួលទៀត លុះព្រះដ៏មានព្រះភាគទ្រង់លាងព្រះហស្តស្រេចលែងលូកព្រះហស្តទៅក្នុងបាត្រហើយ (ព្រាហ្មណ៍) ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រាហ្មណ៍នោះអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់មានបន្ទូលដូច្នេះថា ម្នាលព្រាហ្មណ៍ អានិសង្សបបរនេះមាន ១០ យ៉ាង អានិសង្សបបរ ១០ យ៉ាងនោះតើដូចម្តេច គឺបុគ្គលអ្នកឲ្យបបរឈ្មោះថា ឲ្យអាយុ ១ ឲ្យពណ៌សម្បុរ ១ ឲ្យសេចក្តីសុខ ១ ឲ្យកម្លាំងកាយ ១ ឲ្យប្រាជ្ញា ១ បបរដែលបុគ្គលផឹកទៅហើយរមែងបំបាត់សេចក្តីឃ្លាន ១ បំបាត់បង់សេចក្តីស្រេក ១ ញុំាងខ្យល់ឲ្យបើកទៅស្រួល ១ ញុំាងទីសោរៃឲ្យស្អាត ១ ញុំាងអាហារដែលសេសសល់ឲ្យរលួយ ១ ម្នាលព្រាហ្មណ៍ អានិសង្សបបរមាន ១០ យ៉ាងនេះឯង ។

[១១០] ជនណាឲ្យបបរដោយគោរពដល់ពួកសមណៈ
ដែលចាំអាស្រ័យ គ្រឿងបរិភោគដែលអ្នកដទៃឲ្យ តាម
កាលគួរ (ជននោះ) ឈ្មោះថា ឲ្យនូវហេតុនៃអានិសង្ស
ទាំង ១០ យ៉ាង គឺ អាយុ ១ ពណ៌សម្បុរ ១ សេចក្តីសុខ ១
កម្លាំងកាយ ១ ប្រាជ្ញារបស់បុគ្គលនោះតែងកើតឡើង ១

ខុទំ បិបាសំ          ព្យបនេតិ វាតំ
សោធេតិ វត្ថឹ         បរិបាចេតិ ភុត្តំ ។
ភេសជ្ជមេតំ          សុគតេន វណ្ណិតំ ។
តស្មា ហិ យាគុំ       អលមេវ ទាតុំ
និច្ចំ មនុស្សេន        សុខត្ថិកេន
ទិព្វានិ វា            បត្ថយតា សុខានិ
មនុស្សសោភគ្គតមិច្ឆតា[១] វា ។

(១១១) អថខោ ភគវា តំ ព្រាហ្មណំ ឥមាហិ គាថាហិ អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ យាគុញ្ច មធុគោឡកញ្ចាតិ ។

(១១២) អស្សោសុំ ខោ មនុស្សា ភគវតា កិរ ភិក្ខូនំ យាគុ អនុញ្ញាតា មធុគោឡកញ្ចាតិ ។ តេ កាលស្សេវ ភោជ្ជយាគុំ បដិយាទេន្តិ មធុគោឡកញ្ច ។ ភិក្ខូ កាលស្សេវ ភោជ្ជយាគុកេ ធាតា មធុគោឡកេន

១ ម. មនុស្សសោភគ្គតំ ។ បច្ចតាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។



បបរនោះរមែងកំចាត់បង់នូវសេចក្ដីឃ្លាន ១ សេចក្ដីស្រេក ១ ធីញុំាងខ្យល់ (ឲ្យបានដើរស្រួល) ១ ញុំាងទីសារវៀនឲ្យស្អាត ១ ញុំាងភក្តឲ្យរលួយ ១ ។ នេះជាភេសជ្ជៈដែលព្រះសុគតទ្រង់សរសើរហើយ ។ ព្រោះហេតុនោះ អ្នកមានសេចក្ដីត្រូវការបានសេចក្ដីសុខជារបស់មនុស្សក្ដី ប្រាថ្នាសេចក្ដីសុខជារបស់ទិព្វក្ដី ចង់បានសេចក្ដីល្អលើសលើក្នុងមនុស្សក្ដី គួរឲ្យបបរជានិច្ចចុះ ។

(១១១) លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់អនុមោទនាចំពោះព្រាហ្មណ៍នោះដោយគាថាទាំងនេះហើយ ទ្រង់ក្រោកចាកអាសនៈយាងចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាហើយត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យភិក្ខុឆាន់) បបរនិងនំមានរសផ្អែមបាន ។

(១១២) ពួកមនុស្សបានឮដំណឹងថា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតបបរនិងនំមានរសផ្អែមដល់ភិក្ខុទាំងឡាយ (ដូច្នោះ) ហើយ ។ មនុស្សទាំងនោះក៏នាំគ្នាតាក់តែងបបរភោជ្ជ[១] និងនំមានរសផ្អែម ពីព្រឹកព្រហាម (មកប្រគេនភិក្ខុទាំងឡាយ) ។ ពួកភិក្ខុបានឆាន់បបរភោជ្ជ

១ បបរដែលគេធ្វើអំពីរបស់ទាំង ៥ គឺ ល្ង ១ អង្ករ ១ សណ្ដែក ១ ទឹក ១ ស្ករ ១ ដែលគេឲ្យឈ្មោះថា ភោជ្ជយាគូ តាមសិក្ខាបទទី ៤ នៃភោជនវគ្គ ។

៦ កម្មក្ខេ ច ចិត្តរូបំ កុញ្ញត្តិ ។ តេន ខោ បន សម-
យេន អញ្ញតរេន ការុណាយ្យសន្តេន មហាមត្តេន ស្វាត-
នាយ ពុទ្ធប្បមុខោ ភិក្ខុសង្ឃោ និមន្តិតោ ហោតិ ។
អថខោ តស្ស ការុណាយ្យសន្តស្ស មហាមត្តស្ស ឯតទហោ-
សិ យន្នូនាហំ អឌ្ឍតេលសន្នំ ភិក្ខុសតានំ អឌ្ឍតេ-
លសានិ មំសបាតិសតានិ បដិយាទេយ្យំ ឯកមេកស្ស
ភិក្ខុនោ ឯកមេកំ មំសបាតិំ ឧបនាមេយ្យន្តិ ។ អថ-
ខោ សោ ការុណាយ្យសន្តោ មហាមត្តោ តស្សា រត្តិយា
អច្ចយេន បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា
អឌ្ឍតេលសានិ ច មំសបាតិសតានិ ភគវតោ កាលំ
អារោចាបេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ
ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ
យេន តស្ស ការុណាយ្យសន្តស្ស មហាមត្តស្ស និវេសនំ
តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ
សទ្ធិំ ភិក្ខុសង្ឃេន ។ អថខោ សោ ការុណាយ្យសន្តោ
មហាមត្តោ ភត្តគ្គេ ភិក្ខូ បរិវិសតិ ។ ភិក្ខូ ឯវមាហំសុ



ទំនិញតាមសេដ្ឋីម្នាក់ក្រោកព្រហាមហើយ លុះទៅដល់ក្នុងកើតក្តៅទៀត
កុំមិនបានឆ្ងាញ់ពិសា ។ សម័យនោះឯង មានមហាមាត្យម្នាក់ជាអ្នក
មានសេចក្តីជ្រះថ្លាថ្មី (មិនទាន់មុតមាំ) បាននិមន្តភិក្ខុសង្ឃមានព្រះពុទ្ធ
ជាប្រធានដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ លំដាប់នោះ មហាមាត្យអ្នកមាន
សេចក្តីជ្រះថ្លាថ្មីនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះមានតែ
គួរតាក់តែងភាជន៍បញ្ហាន់សាច់ចំនួនមួយពាន់ពីររយហាសិបសម្រាប់
(ឲ្យល្មម) ដល់ភិក្ខុមួយពាន់ពីររយហាសិបរូប ហើយប្រគេនបញ្ហាន់
សាច់មួយសម្រាប់ៗ ដល់ភិក្ខុមួយរូបៗ ។ ឯមហាមាត្យអ្នកមានសេចក្តី
ជ្រះថ្លាថ្មីនោះ លុះកន្លងរាត្រីនោះទៅក៏បានតាក់តែងខាទនីយភោជនីយៈដ៏
ឧត្តម និងបញ្ហាន់សាច់មួយពាន់ពីររយហាសិបសម្រាប់ ហើយក៏ប្រើបម្រើ
ឲ្យទៅក្រាបបង្គំទូលវេលាឆាន់ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះ
អង្គដ៏ចំរើន វេលានេះល្មមហើយ ភត្តសម្រេចហើយ ។ គ្រានោះ វេលា
ព្រឹកព្រហាមព្រះដ៏មានព្រះភាគទ្រង់ស្បង់ហើយប្រដាប់បាត្រនិងចីវរ
ស្តេចយាងទៅកាន់ផ្ទះមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ លុះយាង
ទៅដល់ហើយទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ មួយអន្លើដោយ
ភិក្ខុសង្ឃ ។ ឯមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះបានអង្គាសពួកភិក្ខុក្នុង
រោងភត្ត ។ ភិក្ខុទាំងឡាយបាននិយាយយ៉ាងនេះថា ម្នាលអាវុសោ អ្នកចូរ

ថោកំ អាវុសោ ទេហិ ថោកំ អាវុសោ ទេហីតិ ។ មា ខោ តុម្ហេ ភន្តេ អយំ តរុណប្បសន្នោ មហាមត្តោតិ ថោកំ ថោកំ បដិគ្គណ្ហាថ ពហុំ មេ ខាទនីយំ ភោជនីយំ បដិយត្តំ អឌ្ឍតេលសានិ ច មំសបាតិសតានិ ឯកមេកស្ស ភិក្ខុនោ ឯកមេកំ មំសបាតិំ ឧបនាមេស្សាមិ បដិគ្គណ្ហថ ភន្តេ យាវទត្ថន្តិ ។ ន ខោ មយំ អាវុសោ ឯតំ ការណា ថោកំ ថោកំ បដិគ្គណ្ហាម អបិច មយំ កាលស្សេវ ភោជ្ជយាគុយា ពីបាតា មធុគោឡកេន ច តេន មយំ ថោកំ ថោកំ បដិគ្គណ្ហាមាតិ ។ អថខោ សោ តរុណប្បសន្នោ មហាមត្តោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភទ្ទន្តា មយា និមន្តិតា អញ្ញស្ស ភោជ្ជយាគុំ បរិភុញ្ជិស្សន្តិ ន ចាហំ បដិពលោ យាវទត្ថំ ទាតុន្តិ កុបិតោ អនត្តមនោ អាសាទនាបេក្ខោ ភិក្ខូនំ បត្តេ បូរេន្តោ អគមាសិ ភុញ្ជថ វា ហរថ វាតិ ។ អថខោ សោ តរុណប្បសន្នោ មហាមត្តោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ



ឲ្យ (ភត្ត) តែបន្តិចចុះ ម្នាលអាវុសោ អ្នកចូរឲ្យតែបន្តិចបន្តួចហើយ ។ មហាមាត្យនិយាយថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ទាំងឡាយកុំទទួលភត្តបន្តិចបន្តួចដោយគិតថា មហាមាត្យនេះមានសេចក្តីជ្រះថ្លាថ្មី ៗ ខាទនីយភោជនីយៈ ខ្ញុំបានចាត់ចែងទុកហើយជាច្រើន គឺចង្ហាន់សាច់មួយពាន់ពីររយហាសិបសម្រាប់ផង ខ្ញុំនឹងប្រគេនចង្ហាន់សាច់មួយសម្រាប់ ៗ ដល់ភិក្ខុមួយរូប ៗ បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ទាំងឡាយទទួលដរាបដល់ឆ្អែត ។ ពួកភិក្ខុនិយាយតបថា ម្នាលអាវុសោ យើងទាំងឡាយទទួលភត្តបន្តិច ៗ ព្រោះហេតុប៉ុណ្ណេះក៏ទេ យើងទាំងឡាយឆាន់បបរភោជ្ជនិងនំសេវ៉ែមផ្អែមតាំងពីព្រឹកព្រលឹមហើយ ព្រោះហេតុនោះ បានជាយើងទទួលភត្តតែបន្តិច ៗ ។ លំដាប់នោះ មហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ខ្ញុំបាននិមន្តលោកម្ចាស់ទាំងឡាយរួចហើយ មិនសមបើនឹងទៅឆាន់បបរភោជ្ជរបស់អ្នកដទៃទៀតសោះ ( លោកម្ចាស់ភ្លេចក្រែង ) ខ្ញុំមិនអាចនឹងប្រគេនឲ្យឆាន់ឆ្អែតបានទេ ។ មហាមាត្យនោះ មានសេចក្តីក្រោធតូចចិត្តប្រាថ្នានឹងទោស កាលដាក់បាត្រភិក្ខុទាំងឡាយពេញហើយក៏ដើរទៅនិយាយថា ចូរលោកឆាន់ចង្ហាន់ក្តី នាំយកទៅក្តី (ក៏តាមចិត្តចុះ) ។ លំដាប់នោះ មហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះបានអង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានដោយខាទនីយ

បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេ-ត្វា សម្បវារេត្វា ភគវន្តំ ភុត្តាវី ឱនីតបត្តបាណី ឯក-មន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តំ ករុណាប្ប-សន្នំ មហាមត្តំ ភគវា ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយា-សនា បក្កាមិ ។ អថខោ តស្ស ករុណាប្បសន្នស្ស មហាមត្តស្ស អចិរបក្កន្តស្ស ភគវតោ អហុ កុក្កុច្ចំ អហុ វិប្បដិសារោ អលាភា វត មេ ន វត មេ លាភា ទុល្លទ្ធំ វត មេ ន វត មេ សុលទ្ធំ យោហំ ភគវតោ អនត្តមនោ អាសាទនាបេក្ខោ កុម្ភកំ បត្តេ ធូហេត្វា អក្ខាសិ កុញ្ជ ភ ហារេថ ភិក្ខុំ តុណ្ហិ មយា តបាំ បស្សុតំ បុញ្ញំ វា អបុញ្ញំ វា ភវិ ។ អថខោ សោ ករុណាប្ប-សន្នោ មហាមត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្ក-មិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ករុណាប្បសន្នោ មហាមត្តោ ភគវន្តំ



ភោជនីយៈដ៏ឧត្តមដោយដៃខ្លួនឲ្យឆ្អែតស្កប់ស្កល់ ត្រាតែលោកប្រកែកលែងទទួលទៀត លុះព្រះដ៏មានព្រះភាគទ្រង់សោយស្រេចលែងលូកព្រះហស្តទៅក្នុងបាត្រហើយ (មហាមាត្យ) ក៏អង្គុយក្នុងទីសមគួរ ។ លុះមហាមាត្យអ្នកមានសេចក្តីជ្រះថ្លានោះអង្គុយនៅក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយទ្រង់ក្រោកចាកអាសនៈយាងចេញទៅ ។ ឯមហាមាត្យអ្នកមានសេចក្តីជ្រះថ្លានោះ កាលព្រះដ៏មានព្រះភាគយាងចេញទៅមិនយូរប៉ុន្មាន ក៏កើតសេចក្តីរង្កៀសចិត្ត សេចក្តីក្តៅក្រហាយថា លាភអញឥតលាភទេតើ លាភរបស់អាត្មាអញគ្មានសោះទេហ្ន៎ ការនឹងអាត្មាភាពជាមនុស្សលោកក៏អាត្មាអញបានដោយក្រម មិនមែនអាត្មាអញបានដោយល្អទេ (ព្រោះ) អាត្មាអញទើបនឹងចិត្តព្រោះចាប់នឹងទោស បានជាក់បាត្រព្រះអង្គទាំងឡាយឲ្យពេញហើយដើរចៀសចេញទៅនិយាយថា លោកចាំទឹកឡាយចូរដាក់ក្តាំយកទៅក្ត (កំភាមចិត្តចុះ) កម្មដែលអាត្មាអញសន្សំមកជាច្រើនហើយ (នោះ) នឹងជាបុណ្យឬជាបាបហ្ន៎ ។ ឯមហាមាត្យអ្នកមានសេចក្តីជ្រះថ្លានោះក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ លុះមហាមាត្យអ្នកមានសេចក្តីជ្រះថ្លានោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូល

ឯតទវោច ឥធ មយ្ហំ ភន្តេ អចិរបក្កន្តស្ស ភគវតោ អហុទេវ កុក្កុច្ចំ អហុ វិប្បដិសារោ អលាភា វត មេ ន វត មេ លាភា ទុលទ្ធំ វត មេ ន វត មេ សុលទ្ធំ យោហំ ភិក្ខូ? អនត្តមនោ អាសាទនាបេក្ខោ ភិក្ខូនំ បត្តេ បូរេសឹ ភុញ្ជថ វា ហរថ វា កឹ នុ ខោ មយា ពហុំ បសុតំ បុញ្ញំ វា អបុញ្ញំ វា កឹ នុ ខោ មយា ភន្តេ ពហុំ បសុតំ បុញ្ញំ វា អបុញ្ញំ វាតិ ។ យទគ្គេន តយា អាវុសោ ស្វាតនាយ ពុទ្ធប្បមុខោ ភិក្ខុសង្ឃោ និមន្តិតោ តទគ្គេន តេ ពហុំ បុញ្ញំ បសុតំ យទគ្គេន តេ ឯកមេកេន ភិក្ខុនា ឯកមេកំ សិត្ថំ បដិគ្គហិតំ តទគ្គេន តេ ពហុំ បុញ្ញំ បសុតំ សគ្គា តេ អារទ្ធាតិ ។ អថខោ សោ តុរុណាប្ប-សន្នោ មហាមត្តោ លាភា កិរ មេ សុលទ្ធំ កិរ មេ



ព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន កាលដែលព្រះដ៏មានព្រះភាគយាងចេញទៅមិនយូរប៉ុន្មាន ក្នុងវេលានោះ ខ្ញុំព្រះអង្គក៏មានសេចក្តីរង្កៀសនឹងសេចក្តីក្តៅក្រហាយថា អាត្មាអញឥតលាភទេតើ លាភរបស់អាត្មាអញគ្មានសោះទេហ្ន៎ ទំនងអត្តភាពជាមនុស្សដែលអាត្មាអញបានដោយកម្រ មិនមែនអាត្មាអញបានដោយងាយទេ ( ព្រោះ ) អាត្មាអញខឹងអន់ចិត្ត ប្រាថ្នានឹងរិះគន់ បានដាក់បាត្រភិក្ខុទាំងឡាយឱ្យពេញហើយ ដើរចៀសចេញទៅនិយាយថា លោកទាំងឡាយចូរឆាន់ក្តី នាំយកទៅក្តី (ក៏តាមចិត្តចុះ) កម្មដែលអាត្មាអញបានសន្សំមកជាច្រើនហើយ ( នេះ ) ទីនឹងជាបុណ្យ ឬជាបាបហ្ន៎ បពិត្រព្រះអង្គដ៏ចំរើន កម្មដែលខ្ញុំព្រះអង្គបានសន្សំមកជាច្រើនហើយ ( នេះ ) តើនឹងជាបុណ្យឬជាបាប ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអាវុសោ កំណត់ត្រឹមតែព្រះពុទ្ធជាប្រធានដែលអ្នកបាននិមន្តដើម្បីឆាន់ក្នុងថ្ងៃស្អែកដោយចំណែកណា ចំណែកដែលអ្នកបានសន្សំហើយនោះក៏ជាបុណ្យយ៉ាងច្រើន គ្រាប់បាយមួយគ្រាប់ៗ របស់អ្នកដែលភិក្ខុមួយរូបៗ ទទួលហើយដោយចំណែកណា ចំណែកដែលអ្នកបានសន្សំនោះក៏ជាបុណ្យយ៉ាងច្រើនហើយ ឈ្មោះថាអ្នកឯងប្រារព្ធយកឋានសួគ៌ហើយ ។ ឯមហាមាត្យអ្នកមានសេចក្តីជ្រះថ្លានោះក៏គិតថា ប្រហែលជាលាភរបស់អាត្មាអញហើយ ប្រហែល

ពហុំ ឥតរំ មយា បុញ្ញំ បសុតំ សត្ថា ឥតរំ មេ អារព្ភាតិ ហដ្ឋោ ឧទគ្គោ ឧឡារំ សោ កតវត្ថុ អភិក្កមេត្វា មនុស្សានំ តេភ្យា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ ភិក្ខូ អញ្ញត្រ និមន្តិតា អញ្ញស្ស ភោជ្ជយាគុំ បរិភុញ្ជន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិ-សា អញ្ញត្រ និមន្តិតា អញ្ញស្ស ភោជ្ជយាគុំ បរិភុញ្ជិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ អញ្ញត្រ និមន្តិតេន អញ្ញស្ស ភោជ្ជយាគុ បរិភុញ្ជិតព្វា យោ បរិភុញ្ជេយ្យ យថាធម្មោ ការេតព្វោតិ ។



ជាការអញបានធ្វើកុសលជាមនុស្សល្អហើយ ប្រហែលជាការអញបានសន្សំបុណ្យជាច្រើនហើយ ប្រហែលជាឈ្មោះថា ការអញប្រព្រឹត្តយកឋានសួគ៌ហើយ ក៏មានចិត្តរីករាយស្រស់ស្រាយឡើងក្រៃពេកពន់ពេក ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ គ្រានោះ ដោយនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកបានទិមន្តពួកភិក្ខុទៅក្នុងត្រកូលដទៃហើយ ភិក្ខុទាំងនោះទៅឆាន់បបរកញ្ជូររបស់ត្រកូលឯទៀតវិញ ពិតមែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ បាននិមន្តក្នុងត្រកូលដទៃហើយ មិនសមបើទៅឆាន់បបរកញ្ជូររបស់ត្រកូលឯទៀតសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ។ បេ ។ ទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុទទួលនិមន្តក្នុងត្រកូលដទៃហើយ មិនត្រូវឆាន់បបរកញ្ជូររបស់ត្រកូលឯទៀតទេ ភិក្ខុណាឆាន់ ត្រូវឲ្យគេធ្វើតាមធម៌ ( គឺឲ្យសំដែងអាបត្តិចេញ ) ។

(១១៣) អថខោ ភគវា អន្ធកវិន្ទេ យថាភិរន្តំ វិហរិត្វា យេន រាជគហំ តេន ចារិកំ បក្កាមិ មហតា ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេឡសេហិ ភិក្ខុសតេហិ ។ តេន ខោ បន សមយេន វេលដ្ឋោ(១) កច្ចានោ រាជគហា អន្ធកវិន្ទំ អទ្ធានមគ្គប្បដិបន្នោ ហោតិ បញ្ចមត្តេហិ សកដសតេហិ សព្វេហេវ គុឡកុម្ភបូរេហិ ។ អទ្ទសា ខោ ភគវា វេលដ្ឋំ កច្ចានំ ទូរតោវ អាគច្ឆន្តំ ទិស្វាន មគ្គា ឱក្កម្ម អញ្ញតរស្មឹ រុក្ខមូលេ និសីទិ ។ អថខោ វេលដ្ឋោ កច្ចានោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ វេលដ្ឋោ កច្ចានោ ភគវន្តំ ឯតទវោច ឥច្ឆាមហំ ភន្តេ ឯកមេកស្ស ភិក្ខុនោ ឯកមេកំ គុឡកុម្ភំ ទាតុន្តិ ។ តេនហិ ត្វំ កច្ចាន ឯកំយេវ គុឡកុម្ភំ អាហរាតិ ។ ឯវំ ភន្តេតិ ខោ វេលដ្ឋោ កច្ចានោ ភគវតោ បដិស្សុណិត្វា ឯកំយេវ គុឡកុម្ភំ អាទាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច អាភតោ ភន្តេ

១ ម. ពេលដ្ឋោ ។



(១១៣) គ្រានោះ ព្រះដ៏មានព្រះភាគគង់នៅក្នុងអន្ធកវិន្ទប្រទេស តាមសមគួរដល់ព្រះអធ្យាស្រ័យហើយ ទ្រង់យាងចេញទៅកាន់ចារិកក្នុងរាជគ្រឹះ មួយអន្លើដោយភិក្ខុសង្ឃច្រើនប្រមាណមួយពាន់ពីររយហាសិបរូប ។ សម័យនោះឯង បុរសឈ្មោះវេលដ្ឋកច្ចាន បានផ្ទុកក្អមស្ករអំពៅពេញរទេះ៥រយហើយ ក៏ចេញចាកក្រុងរាជគ្រឹះទៅតាមផ្លូវឆ្ពោះទៅកាន់អន្ធកវិន្ទប្រទេស ។ ព្រះដ៏មានព្រះភាគបានទតឃើញវេលដ្ឋកច្ចានដើរមកអំពីចម្ងាយ លុះទតឃើញហើយទ្រង់យាងចៀសអំពីផ្លូវទៅគង់ក្រោមម្លប់ឈើមួយ ។ លំដាប់នោះ វេលដ្ឋកច្ចានបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចឈរនៅក្នុងទីសមគួរ ។ លុះវេលដ្ឋកច្ចានឈរនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចង់ប្រគេនស្ករអំពៅ១ក្អម ៗ ដល់ភិក្ខុមួយរូប ៗ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកចូរនាំយកស្ករអំពៅតែមួយក្អមមកមើលសិន ។ វេលដ្ឋកច្ចានបានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយយកស្ករអំពៅមួយក្អមដើរចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន

គុឡកុម្ភោ កថាហំ ភន្តេ បដិបជ្ជាមីតិ ។ តេនហិ ត្វំ កច្ចាន ភិក្ខូនំ គុឡំ ទេហីតិ ។ ឯវំ ភន្តេតិ ខោ វេលដ្ឋោ កច្ចានោ ភគវតោ បដិស្សុណិត្វា ភិក្ខូនំ គុឡំ ទត្វា ភគវន្តំ ឯតទវោច ទិន្នោ ភន្តេ ភិក្ខូនំ គុឡោ ពហុ ចាយំ គុឡោ អវសិដ្ឋោ កថាហំ ភន្តេ បដិបជ្ជាមីតិ ។ តេនហិ ត្វំ កច្ចាន ភិក្ខូនំ គុឡំ យាវទត្ថំ ទេហីតិ ។ ឯវំ ភន្តេតិ ខោ វេលដ្ឋោ កច្ចានោ ភគវតោ បដិស្សុណិត្វា ភិក្ខូនំ គុឡំ យាវទត្ថំ ទត្វា ភគវន្តំ ឯតទវោច ទិន្នោ ភន្តេ ភិក្ខូនំ គុឡោ យាវទត្ថោ ពហុ ចាយំ គុឡោ អវសិដ្ឋោ កថាហំ ភន្តេ បដិបជ្ជាមីតិ ។ តេនហិ ត្វំ កច្ចាន ភិក្ខូ គុឡេហិ សន្តប្បេហីតិ ។ ឯវំ ភន្តេតិ ខោ វេលដ្ឋោ កច្ចានោ



ខ្ញុំព្រះអង្គបានយកក្អមស្ករអំពៅមកហើយ បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯងចូរប្រគេនស្ករអំពៅដល់ភិក្ខុទាំងឡាយចុះ ។ វេលដ្ឋកច្ចាន ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយប្រគេនស្ករអំពៅ ដល់ភិក្ខុទាំងឡាយ រួចក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានប្រគេនស្ករអំពៅ ដល់ពួកភិក្ខុរួចហើយ ស្ករអំពៅនេះនៅសល់ជាច្រើន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯងចូរប្រគេនស្ករអំពៅដល់ពួកភិក្ខុ ដរាបដល់អស់ចំណង់ចុះ ។ វេលដ្ឋកច្ចានទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយបានប្រគេនស្ករអំពៅដល់ពួកភិក្ខុ ដរាបដល់អស់ចំណង់ រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានប្រគេនស្ករអំពៅដល់ពួកភិក្ខុ ដរាបដល់អស់ចំណង់ហើយ តែស្ករអំពៅនេះនៅសល់ច្រើន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះអ្នកឯងចូរឲ្យពួកភិក្ខុឆាន់ឆ្អែតស្កប់ស្កល់ដោយស្ករអំពៅទាំងឡាយចុះ ។ វេលដ្ឋកច្ចាន

កច្ចានោ បដិស្សុណិត្វា ភិក្ខូ គុឡេហិ សន្តប្បេសិ ។ បត្តេបិ ភិក្ខូ ឃដេបិ ពូរេសុំ បរិស្សាវនានិបិ ថវិកាយោបិ ពូរេសុំ ។ អថខោ វេលដ្ឋោ កច្ចានោ ភិក្ខូ គុឡេហិ សន្តប្បេត្វា ភគវន្តំ ឯតទវោច សន្តប្បិតា ភន្តេ ភិក្ខូ គុឡេហិ ពហុ ចាយំ គុឡោ អវសិដ្ឋោ កថាហំ ភន្តេ បដិបជ្ជាមីតិ ។ តេនហិ ត្វំ កច្ចាន វិឃាសាទានំ គុឡំ ទេហីតិ ។ ឯវំ ភន្តេតិ ខោ វេលដ្ឋោ កច្ចានោ ភគវតោ បដិស្សុណិត្វា វិឃាសាទានំ គុឡំ ទត្វា ភគវន្តំ ឯតទវោច ទិន្នោ ភន្តេ វិឃាសាទានំ គុឡោ ពហុ ចាយំ គុឡោ អវសិដ្ឋោ កថាហំ ភន្តេ បដិបជ្ជាមីតិ ។ តេនហិ ត្វំ កច្ចាន វិឃាសាទានំ គុឡំ



ទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយបាន ញ៉ាំងពួកភិក្ខុឲ្យឆ្អែតស្កប់ស្កល់ ដោយស្ករអំពៅទាំងឡាយ ។ ភិក្ខុពួកខ្លះដាក់ពេញបាត្រក៏មាន ដាក់ក្នុងសំពត់ត្រងទឹកក៏មាន ដាក់ពេញថង់យាមក៏មាន ។ លុះបេលដ្ឋកច្ចានបានឲ្យពួកភិក្ខុបានឆ្អែតស្កប់ស្កល់ ដោយស្ករអំពៅទាំងឡាយហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឲ្យពួកភិក្ខុបានឆ្អែតស្កប់ស្កល់ ដោយស្ករអំពៅទាំងឡាយហើយ តែស្ករអំពៅនេះនៅសល់ច្រើន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្ដេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯងចូរឲ្យស្ករអំពៅដល់ពួកមនុស្សអ្នកស៊ីដែលចុះ ។ បេលដ្ឋកច្ចានបានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយឲ្យស្ករអំពៅដល់ពួកមនុស្សអ្នកស៊ីដែល រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឲ្យស្ករអំពៅដល់ពួកមនុស្សអ្នកស៊ីដែលហើយ តែស្ករអំពៅនេះនៅសល់ច្រើន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្ដេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯងចូរឲ្យស្ករអំពៅដល់ពួកមនុស្សអ្នកស៊ីដែល

យាវទត្ថំ ទេហីតិ ។ ឯវំ ភន្តេតិ ខោ វេលដ្ឋោ កច្ចានោ ភគវតោ បដិស្សុណិត្វា វិឃាសាទានំ គុឡំ យាវទត្ថំ ទត្វា ភគវន្តំ ឯតទវោច ទិន្នោ ភន្តេ វិឃាសាទានំ គុឡោ យាវទត្ថោ ពហុ ចាយំ គុឡោ អវសិដ្ឋោ កថាហំ ភន្តេ បដិបជ្ជាមីតិ ។ តេនហិ ត្វំ កច្ចាន វិឃាសាទេ គុឡេហិ សន្តប្បេហីតិ ។ ឯវំ ភន្តេតិ ខោ វេលដ្ឋោ កច្ចានោ ភគវតោ បដិស្សុណិត្វា វិឃាសាទេ គុឡេហិ សន្តប្បេសិ ។ ឯកច្ចេ វិឃាសាទា កោ-ឡម្ពេបិ ឃដេបិ បូរេសុំ បិដកានិបិ ឧច្ឆង្គេបិ បូរេសុំ ។ អថខោ វេលដ្ឋោ កច្ចានោ វិឃាសាទេ គុឡេហិ សន្ត-ប្បេត្វា ភគវន្តំ ឯតទវោច សន្តប្បិតា ភន្តេ វិឃាសាទា គុឡេហិ ពហុ ចាយំ គុឡោ អវសិដ្ឋោ កថាហំ ភន្តេ



ចែកឲ្យអស់ចំណែកចុះ ។ វេលដ្ឋកច្ចានបានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ហើយក៏ឲ្យស្ករអំពៅដល់ពួកមនុស្សអ្នកស៊ីដែល ចែកឲ្យអស់ចំណែក រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឲ្យស្ករអំពៅដល់ពួកមនុស្សអ្នកស៊ីដែល ចែកឲ្យអស់ចំណែកហើយ តែថាស្ករអំពៅនេះក៏នៅសល់ច្រើន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកចូរឲ្យពួកមនុស្សអ្នកស៊ីដែលឆ្អែតស្កប់ស្កល់ដោយស្ករអំពៅតាំងពីឡូវចុះ ។ វេលដ្ឋកច្ចានបានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគដោយពាក្យថា ព្រះករុណា ព្រះអង្គ ហើយឲ្យពួកមនុស្សអ្នកស៊ីដែលឆ្អែតស្កប់ស្កល់ដោយស្ករអំពៅតាំងពីឡូវ ។ ពួកមនុស្សអ្នកស៊ីដែលខ្លះដាក់ពេញត្រឡោកក៏មាន ដាក់ពេញក្អមក៏មាន វេចនឹងសម្ពត់ក្រមាក៏មាន ដាក់ពេញថ្នក់ក៏មាន ។ លំដាប់នោះ វេលដ្ឋកច្ចានបានឲ្យពួកមនុស្សអ្នកស៊ីដែលឆ្អែតស្កប់ស្កល់ដោយស្ករអំពៅតាំងពីឡូវ រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឲ្យពួកមនុស្សអ្នកស៊ីដែលឆ្អែតស្កប់ស្កល់ដោយស្ករអំពៅតាំងពីឡូវហើយ តែថាស្ករអំពៅនេះនៅសល់ច្រើន បពិត្រ

បដិបជ្ជាមីតិ ។ នាហន្តំ កច្ចាន បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិ-យា បជាយ សទេវមនុស្សាយ យស្ស សោ គុឡោ បរិភុត្តោ សម្មាបរិណាមំ គច្ឆេយ្យ អញ្ញត្រ តថាគតស្ស វា តថាគតសាវកស្ស វា ។ តេនហិ ត្វំ កច្ចាន តំ គុឡំ អប្បហរិតេ វា ឆឌ្ឌេហិ អប្បាណកេ វា ឧទកេ ឱបិ-លាបេហីតិ ។ ឯវំ ភន្តេតិ ខោ ពេលដ្ឋោ កច្ចានោ ភគវតោ បដិស្សុណិត្វា តំ គុឡំ អប្បាណកេ ឧទកេ ឱបិលាបេសិ ។ អថខោ សោ គុឡោ ឧទកេ បក្ខិត្តោ ចិច្ចិដាយតិ ចិដិចិដាយតិ សន្ធូបាយតិ សម្បធូបាយតិ សេយ្យថាបិ នាម ផាលោ ទិវសំ សន្តត្តោ ឧទកេ បក្ខិត្តោ ចិច្ចិដាយតិ ចិដិចិដាយតិ សន្ធូបាយតិ សម្បធូបាយតិ ឯវមេវ សោ គុឡោ ឧទកេ បក្ខិត្តោ ចិច្ចិដាយតិ ចិដិចិដាយតិ សន្ធូបាយតិ សម្បធូបា-យតិ ។ អថខោ ពេលដ្ឋោ កច្ចានោ សំវិគ្គោ លោមហដ្ឋ-ជាតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ



ព្រះអង្គនៅច្រើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន ក្នុងលោកព្រមទាំងទេវលោក ព្រមទាំងមារ ព្រមទាំងព្រហ្ម ក្នុងពួកសត្វព្រមទាំងសមណព្រាហ្មណ៍ព្រមទាំងសម្មតិ-ទេវនិងមនុស្ស តថាគតមិនដែលឃើញអ្នកណាមួយបានស្ករអំពៅហើយ ស្ករអំពៅនោះរលួយទៅដោយស្រួលទេ វៀរលែងតែតថាគតឬសាវករបស់-តថាគតប៉ុណ្ណោះ ម្នាលកច្ចាន បើដូច្នោះ ចូរអ្នកឯងចោលស្ករអំពៅនោះទៅក្នុងទីដែលគ្មានស្មៅស្រស់ ឬចាក់ចោលទៅក្នុងទឹកដែលគ្មានសត្វតិចតួច ។ ពេលដ្ឋកច្ចានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ហើយចាក់ចោលស្ករអំពៅនោះទៅក្នុងទឹកដែលគ្មានសត្វ ។ ឯស្ករអំពៅដែលពេលដ្ឋកច្ចានចាក់ចុះទៅក្នុងទឹកនោះ ក៏លាន់ឮសិរៀងថា ចិច្ចិដិ ចិដិចិដិ ហុយផ្សែងឡើងដេរដាស គួរនាដូចផាលនង្គ័លនៅហាលថ្ងៃអស់មួយថ្ងៃហើយ បុគ្គលចាក់ចុះទៅក្នុងទឹក រមែងឮសិរៀងថា ចិច្ចិដិ ចិដិចិដិ ហុយផ្សែងឡើងដេរដាសយ៉ាងណាមិញ ស្ករអំពៅនោះដែលបុគ្គលចាក់ចុះទៅក្នុងទឹកហើយ រមែងឮសិរៀងថា ចិច្ចិដិ ចិដិចិដិ ហុយផ្សែងឡើងដេរដាសដូច្នោះដែរ ។ លំដាប់នោះឯង ពេលដ្ឋ-កច្ចានមានសេចក្តីស្លុតចិត្តកើតព្រឺព្រួចអស់ទាំងរោម ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ

អភិក្កមេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នស្ស ខោ ផលគ្គុស្ស កច្ចានស្ស ភគវា អនុបុព្វិកថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា ភគវា អញ្ញាសិ ផលគ្គុំ កច្ចានំ កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ ឧទគ្គចិត្តំ បសន្នចិត្តំ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ ផលគ្គុស្ស កច្ចានស្ស តស្មិំយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យង្កិញ្ចិ សមុទយធម្មំ សព្វំ តំ និរោធធម្មន្តិ ។ អថខោ ផលគ្គោ កច្ចានោ ទិដ្ឋធម្មោ បត្តធម្មោ វិទិតធម្មោ បរិយោគាឡ្ហធម្មោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុសាសនេ ភគវន្តំ ឯតទវោច





រួចអង្គុយនៅក្នុងទីសមគួរ ។ លុះផលគ្គុកច្ចានអង្គុយនៅក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់សំដែងអនុបុព្វីកថា គឺទ្រង់ប្រកាសអំពីទាន ១ អំពីសីល ១ អំពីស្ថានសួគ៌ ១ អំពីទោសដ៏លាមកសៅហ្មងរបស់កាមទាំងឡាយ ១ និងអានិសង្សនៃការចេញចាកកាម ១ ។ វេលាណាព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ផលគ្គុកច្ចានមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តរីករាយឡើង មានចិត្តជ្រះថ្លា វេលានោះ ក៏ទ្រង់ប្រកាសនូវធម្មទេសនាដែលព្រះពុទ្ធទាំងឡាយទ្រង់លើកឡើងប្រកាសដោយព្រះអង្គឯង គឺទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ។ ធម្មតាសំពត់ស្អាតប្រាសចាកស្នាមខ្មៅ គួរទទួលទឹកជ្រលក់បានយ៉ាងល្អយ៉ាងណាមិញ ផលគ្គុកច្ចានក៏បានកើតធម្មចក្ខុ គឺសេចក្តីយល់ឃើញប្រាសចាកធូលី ប្រាសចាកគ្រឿងសៅហ្មង លើអាសនៈនោះឯង ដូច្នេះថា ធម្មជាតិណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតិទាំងអស់នោះ ក៏រលត់ទៅវិញជាធម្មតា យ៉ាងនេះដែរ ។ គ្រាដែលផលគ្គុកច្ចានបានឃើញសច្ចធម៌ហើយ បានដល់សច្ចធម៌ហើយ បានដឹងច្បាស់សច្ចធម៌ហើយ បានយល់ចុះកាន់សច្ចធម៌ហើយ បានឆ្លងនូវវិចិកិច្ឆា កំចាត់បង់នូវសេចក្តីងឿងឆ្ងល់ ដល់នូវភាពជាអ្នកក្លៀវក្លា មិនជឿនូវបុគ្គលដទៃក្នុងសាសនានៃព្រះសាស្តា ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ

អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

[១១៦] អថខោ ភគវា អនុបុព្វេន ចារិកំ ចរមានោ យេន រាជគហំ តទវសរិ ។ តត្រ សុទំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន រាជគហេ គុឡោ ឧស្សន្នោ ហោតិ ។ ភិក្ខូ គិលានស្សេវ ភគវតា គុឡោ អនុញ្ញាតោ នោ អគិលានស្សាតិ កុក្កុច្ចាយន្តា គុឡំ ន បរិភុញ្ជន្តិ ។



យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ឧបមាដូចជាមនុស្សផ្ងាររបស់ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ពុំនោះដូចជាមនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទបាំង ពុំនោះសោតដូចជាមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេង ពុំគឺដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា ឲ្យមនុស្សដែលមានភ្នែកភ្លឺមើលឃើញនូវរូបទាំងឡាយ យ៉ាងណាមិញ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ប្រកាសហើយដោយអនេកបរិយាយ ក៏យ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះសូមដល់ព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹក សូមព្រះដ៏មានព្រះភាគចាំទុកនូវខ្ញុំថាជាឧបាសកអ្នកដល់ (នូវព្រះរតនត្រ័យ) ជាទីពឹងរឭកដោយជីវិតរាប់តាំងពីថ្ងៃនេះជាដើមទៅ ។

(១១៦) គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកតាមលំដាប់ដរាបដល់ទៅក្រុងរាជគ្រឹះនោះ ។ បានឮថា ព្រះមានព្រះភាគគង់ក្នុងវត្តវេឡុវ័នកលន្ទកនិវាបស្ថានជិតក្រុងរាជគ្រឹះនោះ ។ សម័យនោះ ឯស្ករអំពៅកើតឡើងជាច្រើនក្នុងក្រុងរាជគ្រឹះ ។ ពួកភិក្ខុក៏រង្កៀសថា ស្ករអំពៅព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតចំពោះតែភិក្ខុមានជម្ងឺ ប៉ុណ្ណោះ មិនបានទ្រង់អនុញ្ញាតដល់ភិក្ខុគ្មានជម្ងឺឡើយ ក៏មិនហ៊ានឆាន់ស្ករអំពៅ ។

កត្វា ឯកមន្តំ អបក្កមេសុំ ។ អនុជានាមិ ភិក្ខវេ គិលានស្ស គុឡំ អគិលានស្ស គុឡោទកន្តិ ។

[៣០៤] អថខោ ភគវា រាជគហេ យថាភិរន្តំ វិហរិត្វា យេន បាដលិគ្គាមោ តេន ចារិកំ បក្កាមិ មហតា ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេឡសេហិ ភិក្ខុសតេហិ ។ អថខោ ភគវា អនុបុព្វេន ចារិកំ ចរមានោ យេន បាដលិគ្គាមោ តទវសរិ ។ អស្សោសុំ ខោ បាដលិគ្គាមិកា ឧបាសកា ភគវា កិរ បាដលិគ្គាមំ អនុប្បត្តោតិ ។ អថខោ បាដលិគ្គាមិកា ឧបាសកា យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិំសុ ។ ឯកមន្តំ និសិន្នេ ខោ បាដលិគ្គាមិកេ ឧបាសកេ ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ បាដលិគ្គាមិកា ឧបាសកា ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា



ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្ករអំពៅដល់ភិក្ខុមានជម្ងឺ (អនុញ្ញាត) ទឹកស្ករអំពៅដល់ភិក្ខុគ្មានជម្ងឺ ។

(១១៤) លំដាប់នោះ ព្រះមានព្រះភាគទ្រង់គង់នៅក្រុងរាជគ្រឹះតាមសមគួរដល់ព្រះអធ្យាស្រ័យហើយ ទើបយាងចេញទៅកាន់ចារិកក្នុងបាដលិគ្រាមមួយអន្លើដោយភិក្ខុសង្ឃច្រើនប្រមាណមួយពាន់ពីររយហាសិបរូប ។ គ្រាកាលព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់នៅបាដលិគ្រាមនោះ ។ ពួកឧបាសកនៅក្នុងបាដលិគ្រាមបានឮដំណឹងថា ព្រះដ៏មានព្រះភាគទ្រង់យាងមកដល់បាដលិគ្រាមហើយ ។ គ្រានោះ ពួកឧបាសកនៅក្នុងបាដលិគ្រាមបាននាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះពួកឧបាសកអ្នកនៅក្នុងបាដលិគ្រាមអង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ។ លំដាប់នោះ ពួកឧបាសកអ្នកនៅក្នុងបាដលិគ្រាម លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យ

ភគវន្តំ ឯតទវោចុំ អធិវាសេតុ នោ ភន្តេ ភគវា អាវសថាគារំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ បាដលិគាមិកា ឧបាសកា ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន អាវសថាគារំ តេនុបសង្កមឹសុ ឧបសង្កមិត្វា សព្វសន្ថរឹ អាវសថាគារំ សន្ថរិត្វា អាសនានិ បញ្ញាបេត្វា ឧទកមណិកំ បតិដ្ឋាបេត្វា តេលប្បទីបំ អារោបេត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ បាដលិគាមិកា ឧបាសកា ភគវន្តំ ឯតទវោចុំ សព្វសន្ថរិសន្ថតំ ភន្តេ អាវសថាគារំ អាសនានិ បញ្ញត្តានិ ឧទកមណិកោ បតិដ្ឋាបិតោ តេលប្បទីបោ អារោបិតោ យស្សទានិ ភន្តេ ភគវា កាលំ មញ្ញតីតិ ។ អថខោ ភគវា និវាសេត្វា



រីករាយហើយដោយធម្មីកថា ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគព្រមទាំងភិក្ខុសង្ឃទទួលយករោងសំណាក់របស់យើងខ្ញុំទាំងឡាយ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ លំដាប់នោះ ពួកឧបាសកអ្នកនៅស្រុកបាដលិគ្រាមបានដឹងថា ព្រះមានព្រះភាគទ្រង់ទទួលហើយ ក៏នាំគ្នាក្រោកចាកអាសនៈក្រាបថ្វាយបង្គំព្រះមានព្រះភាគធ្វើប្រទក្សិណហើយចូលទៅកាន់រោងសំណាក់ លុះចូលទៅដល់ហើយក៏បានក្រាលរោងសំណាក់ដោយគ្រឿងក្រាលសព្វគ្រប់ហើយ ក៏តែងតាំងអាសនៈទាំងឡាយនិងផ្តល់ក្អមទឹក តែងតាំងប្រទីបប្រេង ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះមានព្រះភាគហើយឋិតនៅក្នុងទីសមគួរ ។ ពួកឧបាសកអ្នកនៅស្រុកបាដលិគ្រាមបានឋិតនៅក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន រោងសំណាក់យើងខ្ញុំបានក្រាលគ្រឿងក្រាលសព្វគ្រប់ហើយ អាសនៈទាំងឡាយយើងខ្ញុំបានតែងតាំងស្រេចហើយ ក្អមទឹកយើងខ្ញុំបានផ្តល់ទុកហើយ ប្រទីបប្រេងយើងខ្ញុំបានតែងតាំងស្រេចហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគសំគាល់កាលដ៏គួរនឹងនិមន្តទៅក្នុងកាលឥឡូវនេះ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ហើយ

បត្តចីវរមាទាយ សទ្ធិំ ភិក្ខុសង្ឃេន យេន អាវស-
ថាគារំ តេនុបសង្កមិ ឧបសង្កមិត្វា បាទេ បក្ខាលេត្វា
អាវសថាគារំ បវិសិត្វា មជ្ឈិមំ ថម្ភំ និស្សាយ បុរត្ថា-
ភិមុខោ(១) និសីទិ ។ ភិក្ខុសង្ឃោបិ ខោ បាទេ បក្ខា-
លេត្វា អាវសថាគារំ បវិសិត្វា បច្ឆិមំ ភិត្តិំ និស្សាយ
បុរត្ថាភិមុខោ(២) និសីទិ ភគវន្តំយេវ បុរក្ខត្វា ។ បាដ-
លិគាមិកាបិ ខោ ឧបាសកា បាទេ បក្ខាលេត្វា
អាវសថាគារំ បវិសិត្វា បុរត្ថិមំ ភិត្តិំ និស្សាយ បច្ឆាភិ-
មុខា(៣) និសីទឹសុ ភគវន្តំយេវ បុរក្ខត្វា ។ អថខោ
ភគវា បាដលិគាមិកេ ឧបាសកេ អាមន្តេសិ ។

[១១៦] បញ្ចិមេ គហបតយោ អាទីនវា ទុស្សី-
លស្ស សីលវិបត្តិយា ។ កតមេ បញ្ច ។ ឥធ គហបត-
យោ ទុស្សីលោ សីលវិបន្នោ បមាទាធិករណំ មហតិំ
ភោគជានិំ និគច្ឆតិ ។ អយំ បឋមោ អាទីនវោ ទុស្សី-
លស្ស សីលវិបត្តិយា ។ បុន ចបរំ គហបតយោ

១-២ ឱ. បុរត្ថិមាភិមុខោ ។ ៣ ឱ. បច្ឆិមាភិមុខា ។



ប្រដាប់ដោយបាត្រនិងចីវរ យាងទៅកាន់ទីសំណាក់ជាមួយនឹងភិក្ខុសង្ឃ
លុះយាងទៅដល់ហើយ ទ្រង់លាងព្រះបាទទាំងគូហើយ ក៏យាងចូល
ទៅកាន់ទីសំណាក់ ។ ទ្រង់គង់ផ្អែកនឹងសសរកណ្ដាល បែរព្រះភក្ត្រទៅ
ទិសខាងកើត ។ ពួកភិក្ខុក៏បានលាងជើងហើយចូលទៅកាន់ទីសំណាក់
ដែរ ហើយអង្គុយផ្អែកនឹងជញ្ជាំងទិសខាងលិច បែរមុខទៅទិសខាងកើត
ឈមមុខទ្រង់ទៅរកព្រះដ៏មានព្រះភាគ ។ ចំណែកពួកឧបាសកអ្នកនៅក្នុង
បាដលិគ្រាមក៏បានលាងជើងហើយនាំគ្នាចូលទៅកាន់ទីសំណាក់ហើយ
អង្គុយផ្អែកនឹងជញ្ជាំងខាងកើត បែរមុខទៅទិសខាងលិច ឈមមុខទ្រង់
ទៅរកព្រះដ៏មានព្រះភាគដែរ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់
ត្រាស់ហៅពួកឧបាសកអ្នកនៅក្នុងបាដលិគ្រាមមកហើយទ្រង់ត្រាស់ថា ។

(១១៦) ម្នាលគហបតីទាំងឡាយ ទោសទាំង ៥ ប្រការនេះ ជា
ទោសនៃបុគ្គលទ្រុស្តសីល(១) ព្រោះវិបត្តិចាកសីល ។ ទោសទាំង ៥ ប្រការ
នោះតើដូចម្ដេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលទ្រុស្តសីល ព្រោះវិ-
បត្តិចាកសីល ក្នុងលោកនេះ តែងដល់នូវសេចក្ដីសាបសូន្យនៃសម្បត្តិធំ ព្រោះ
ហេតុមកពីសេចក្ដីប្រមាទ ។ នេះជាទោសទី ១ នៃបុគ្គលទ្រុស្តសីល ព្រោះ
វិបត្តិចាកសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត

១ ក្នុងគម្ពីរសារត្ថទីបនីកាត់ជាពីរបទ អធិប្បាយថាយ៉ាងនេះ គឺបុគ្គលមិនបានសមាទាន
សីល ឬសមាទានសីលហើយតែសីលខ្ទេចទៅវិញ ។

ទុស្សីលស្ស សីលវិបន្នស្ស បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ ។ អយំ ទុតិយោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ គហបតយោ ទុស្សីលោ សីលវិបន្នោ យញ្ញទេវ បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ អវិសារទោ ឧបសង្កមតិ មង្កុភូតោ ។ អយំ តតិយោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ គហបតយោ ទុស្សីលោ សីលវិបន្នោ សម្មូឡ្ហោ កាលំ ករោតិ ។ អយំ ចតុត្ថោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ គហបតយោ ទុស្សីលោ សីលវិបន្នោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ អយំ បញ្ចមោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ ឥមេ ខោ គហបតយោ បញ្ច អាទីនវា ទុស្សីលស្ស សីលវិបត្តិយា ។



បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ តែងមានកិត្តិសព្ទអាក្រក់ ឮខ្ចរខ្ចាយទៅ ។ នេះជាទោសទី ២ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ (បើ) ចូលទៅកាន់បរិសទ្យណា ទោះបីជាខត្តិយបរិសទ្យក្តី ជាព្រាហ្មណ៍បរិសទ្យក្តី ជាគហបតិបរិសទ្យក្តី ជាសមណបរិសទ្យក្តី ក៏គ្មានក្លៀវក្លា មានតែមុខចុះ ហើយដើរចូលទៅ ។ នេះជាទោសទី ៣ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ វេលាទៀបស្លាប់ តែងវង្វេងស្មារតី ។ នេះជាទោសទី ៤ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ រមែងទៅកាន់អបាយ[១](តិរច្ឆាន) ទុគ្គតិ[២](ប្រេត) វិនិបាត[៣](អសុរកាយ) និរយ (នរក) ។ នេះជាទោសទី ៥ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ។ ម្នាលគហបតីទាំងឡាយ ទោសទាំង ៥ ប្រការនេះឯង ជាទោសនៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ។

១ ច្រកទេសប្រាសចាកសេចក្តីសុខ ។ ២ ទីដំណើរនៃទុក្ខផ្សេងៗ ។ ៣ ចូរមើលវិន័យបិដក មហាវិភង្គភាគទី ១ ទំព័រ ១៤ ជាដើម ។

(១១៧) បញ្ចិមេ គហបតយោ អានិសំសា សីលវតោ សីលសម្បទាយ ។ កតមេ បញ្ច ។ ឥធ គហបតយោ សីលវា សីលសម្បន្នោ អប្បមាទាធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ ។ អយំ បឋមោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ គហបតយោ សីលវតោ សីលសម្បន្នស្ស កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ ។ អយំ ទុតិយោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ គហបតយោ សីលវា សីលសម្បន្នោ យញ្ញទេវ បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមតិ អមង្កុភូតោ ។ អយំ តតិយោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ គហបតយោ សីលវា សីលសម្បន្នោ អសម្មូឡ្ហោ កាលំ ករោតិ ។ អយំ





(១១៧) ម្នាលគហបតីទាំងឡាយ អានិសង្សទាំង ៥ ប្រការនេះជា អានិសង្សនៃបុគ្គលមានសីល បរិបូណ៌ដោយសីល ។ អានិសង្សទាំង ៥ ប្រការនោះតើដូចម្តេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលមានសីល បរិបូណ៌ដោយសីល ក្នុងលោកនេះ តែងបាននូវគំនរនៃសម្បត្តិដ៏ច្រើន ព្រោះមកពីសេចក្តីមិនប្រមាទ ។ នេះជាអានិសង្សទី ១ នៃបុគ្គលមានសីល បរិបូណ៌ដោយសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលមានសីល បរិបូណ៌ដោយសីលហើយ តែងមានកិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ។ នេះជាអានិសង្សទី ២ នៃបុគ្គលមានសីល បរិបូណ៌ដោយសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលមានសីល បរិបូណ៌ដោយសីលហើយ (បើ) ចូលទៅកាន់បរិសទ្យណា ទោះបីជាខត្តិយបរិសទ្យក្តី ជាព្រាហ្មណបរិសទ្យក្តី ជាគហបតិបរិសទ្យក្តី ជាសមណបរិសទ្យក្តី ក៏ក្លៀវក្លា មិនទន់មុខទុះ គឺជាមិនក្រអឺមក្រអៀម ហើយដើរចូលទៅ ។ នេះជាអានិសង្សទី ៣ នៃបុគ្គលមានសីល បរិបូណ៌ដោយសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលមានសីល បរិបូណ៌ដោយសីលហើយ លុះវេលាទៀបស្លាប់ ក៏មិនវង្វេងស្មារតីឡើយ ។ នេះជាអានិសង្សទី ៤

ចតុត្ថោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ គហបតយោ សីលវា សីលសម្បន្នោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ អយំ បញ្ចមោ អានិសំសោ សីលវតោ សីលសម្បទាយ ។ ឥមេ ខោ គហបតយោ បញ្ច អានិសំសា សីលវតោ សីលសម្បទាយាតិ ។

(១១៨) អថខោ ភគវា បាដលិគាមិកេ ឧបាសកេ ពហុទេវ រត្តឹ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧយ្យោជេសិ អភិក្កន្តា ខោ គហបតយោ រត្តិ យស្សទានិ តុម្ហេ(១) កាលំ មញ្ញថាតិ ។ ឯវំ ភន្តេតិ ខោ បាដលិគាមិកា ឧបាសកា ភគវតោ បដិស្សុណិត្វា(២) ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កមឹសុ ។ អថខោ ភគវា អចិរបក្កន្តេសុ បាដលិគាមិកេសុ ឧបាសកេសុ សុញ្ញាគារំ បាវិសិ ។

---

១ ឱក្រមិបោត្ថកេសុ បាឋោ នត្ថិ ។ ២ បដិស្សុត្វាតិ បាឋោ ។



នៃបុគ្គលមានសីល ប្រព្រឹត្តដោយសីល ។ ម្នាលគហបតីទាំងឡាយ ការប្រពៃដទៃមានតទៅទៀត បុគ្គលមានសីល ប្រព្រឹត្តដោយសីលហើយ លុះរលាយខន្ធបន្ទាប់អំពីមរណៈ រមែងទៅកាន់មនុស្សលោក ឬទេវលោក ។ នេះជាអានិសង្សទី ៥ នៃបុគ្គលមានសីល ប្រព្រឹត្តដោយសីល ។ ម្នាលគហបតីទាំងឡាយ អានិសង្សទាំង ៥ ប្រការនេះឯង ជាអានិសង្សនៃបុគ្គលមានសីល ប្រព្រឹត្តដោយសីល ។

(១១៨) គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឧបាសកទាំងឡាយនៅក្នុងបាដលិគ្រាមឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាអស់រាត្រីជាច្រើន ហើយបញ្ជូនទៅដោយព្រះពុទ្ធដីកាថា ម្នាលគហបតីទាំងឡាយ រាត្រី (បឋមយាម) កន្លងទៅហើយ អ្នកទាំងឡាយចូរដឹងនូវកាលដ៏គួរនឹងត្រឡប់ទៅវិញក្នុងកាលឥឡូវនេះចុះ ។ ឧបាសកទាំងឡាយនៅក្នុងបាដលិគ្រាមបានទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រោកចាកទីអង្គុយថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ វេលាដែលឧបាសកទាំងឡាយនៅក្នុងបាដលិគ្រាមចៀសចេញទៅមិនយូរប៉ុន្មាន ព្រះអង្គក៏ទ្រង់យាងចូលទៅកាន់សុញ្ញាគារដ្ឋាន (ផ្ទះស្ងាត់) ។

[១១៨] តេន ខោ បន សមយេន សុនីធវស្សការា មគធមហាមត្តា បាដលិគាមេ នគរំ មាបេន្តិ វជ្ជីនំ បដិពាហាយ ។ អទ្ទសា(១) ខោ ភគវា រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សម្ពហុលា ទេវតាយោ បាដលិគាមេ វត្ថូនិ បរិគ្គណ្ហន្តិយោ យស្មឹ បទេសេ មហេសក្ខា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ មហេសក្ខានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ យស្មឹ បទេសេ មជ្ឈិមា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ មជ្ឈិមានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ យស្មឹ បទេសេ នីចា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ នីចានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ កេ នុ ខោ អានន្ទ បាដលិគាមេ នគរំ មាបេន្តីតិ ។ សុនីធវស្សការា ភន្តេ មគធមហាមត្តា បាដលិគាមេ នគរំ មាបេន្តិ

១-២ ម. អទ្ទស ។



[១១៨] សម័យនោះឯង មហាមាត្យនៅក្នុងដែនមគធៈឈ្មោះ សុនីធៈ ១ វស្សការៈ ១ នាំគ្នាកសាងក្រុងក្នុងបាដលិគ្រាម ដើម្បីនឹងការពារពួករាជត្រកូលដែលនៅក្នុងដែនវជ្ជី ។ ព្រះមានព្រះភាគទ្រង់តើនឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយទ្រង់ទតដោយទិព្វចក្ខុដ៏ស្អាតកន្លងលើសចក្ខុរបស់មនុស្ស ក៏ទតឃើញពួកទេវតាជាច្រើនកំពុងគយគន់មើលទីកន្លែងសង់ផ្ទះក្នុងបាដលិគ្រាម ។ ទេវតាមានសក្តិធំ គយគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេចនិងរាជមហាមាត្យដែលមានសក្តិធំទាំងឡាយ ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ទេវតាមានសក្តិជាកណ្តាល គយគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេចនិងរាជមហាមាត្យដែលមានសក្តិជាកណ្តាលទាំងឡាយ ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ទេវតាមានសក្តិទាបគយគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេចនិងរាជមហាមាត្យដែលមានសក្តិទាបទាំងឡាយ ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកហើយទ្រង់ត្រាស់ថា ម្នាលអានន្ទ ជនពួកណាហ្ន៎ គេសាងក្រុងក្នុងបាដលិគ្រាម ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន មហាមាត្យក្នុងដែនមគធៈឈ្មោះសុនីធៈនិងវស្សការៈសាង

វជ្ជីនំ បដិពាហាយាតិ ។ សេយ្យថាបិ នាម អានន្ទ ទេវេហិ តាវតឹសេហិ សទ្ធឹ មន្តេត្វា ឯវមេវ ខោ អានន្ទ សុនីធវស្សការា មគធមហាមត្តា បាដលិគាមេ នគរំ មាបេន្តិ វជ្ជីនំ បដិពាហាយ ។ ឥធាហំ អានន្ទ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ អទ្ទសំ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សម្ពហុលា ទេវតាយោ បាដលិគាមេ វត្ថូនិ បរិគ្គណ្ហន្តិយោ ។ យស្មឹ បទេសេ មហេសក្ខា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ មហេសក្ខានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ យស្មឹ បទេសេ មជ្ឈិមា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ មជ្ឈិមានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ យស្មឹ បទេសេ នីចា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ



ក្រុងក្នុងបាដលិគ្រាម ដើម្បីនឹងការពារនូវពួករាជត្រកូលដែលនៅក្នុងដែនវជ្ជី ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ មហាមាត្យនៅក្នុងដែនមគធៈឈ្មោះសុនីធៈនិងវស្សការៈបានប្រឹក្សាគ្នានឹងពួកទេវតាក្នុងស្ថានតាវត្តិង្ស(១) ជាយ៉ាងណាមិញ ម្នាលអានន្ទ មហាមាត្យនៅក្នុងដែនមគធៈឈ្មោះសុនីធៈនិងវស្សការៈសាងក្រុងក្នុងបាដលិគ្រាម ដើម្បីនឹងការពារនូវពួករាជត្រកូលក្នុងដែនវជ្ជី យ៉ាងនោះដែរ ម្នាលអានន្ទ តថាគតក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រីក្នុងសុញ្ញាគារដ្ឋាន ( ផ្ទះស្ងាត់ ) នេះ ហើយមើលដោយចក្ខុជាទិព្វដ៏ស្អាតកន្លងវិស័យចក្ខុរបស់មនុស្ស បានឃើញពួកទេវតាជាច្រើនកំពុងតែយកគន់មើលទីកន្លែងសង់ផ្ទះក្នុងបាដលិគ្រាម ។ ពួកទេវតាមានសក្តិធំយកគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេចនិងរាជមហាមាត្យដែលមានសក្តិធំ ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ទេវតាមានសក្តិជាកណ្តាល គន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេចនិងរាជមហាមាត្យដែលមានសក្តិជាកណ្តាល ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ទេវតាមានសក្តិថោកគន់មើលទីកន្លែងសង់ផ្ទះ ក្នុងប្រទេសណា ចិត្តរបស់

---

១ អដ្ឋកថាពន្យល់ថា ពួកមហាមាត្យដែលសាងក្រុងក្នុងបាដលិគ្រាម ក៏ហាក់ដូចជាបានទៅប្រឹក្សាគ្នានឹងទេវតាក្នុងស្ថានតាវត្តិង្ស ។

ខីរោទំ តត្ថ ភរន្តំ ភជមហាមត្តានំ ចិត្តានំ ធម្មិ ធិរេ-

សង្ខាតំ មាបេតុំ យោជនា អានន្ទ អាយាចំ(១) អាយតនំ

យោជនា វណ្ណិតុំបេហោ(២) វត្ថុំ អត្តនោ ភរិស្សតិ ចាជ-

លិបុត្តំ បុរភេទនំ ចាជលិបុត្តស្ស ខោ អានន្ទ តយោ

អន្តរាយា ភវិស្សន្តិ អគ្គិតោ វា ឧទកតោ វា អព្ភន្តរតោ

វា មិថុភេទាតិ ។

[១៦០] អថខោ សុចិរវិស្សុតា ភ មគធមហាមត្តា

យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវតា សទ្ធិំ

សម្មោទិំសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា

ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ សុចិរវិស្សុតា ភ

មគធមហាមត្តា ភគវន្តំ ឯតទវោចុំ អធិវាសេតុ នោ ភវំ

គោតមោ អជ្ជតនាយ ភត្តំ សទ្ធិំ ភិក្ខុសង្ឃេនាតិ ។

---

១ ឱ. អាយំ ។ ២ ឱ. វណិប្បថោ ។



ស្ដេចទឹកដមហាមាត្យដែលមានសក្តិធំ កំពុងសាងទៅដើម្បីនឹងសាង

ល់ទៅក្នុងប្រទេសនោះដែរ ម្នាលអានន្ទ ទីប្រជុំរបស់ពួកអរិយបុគ្គលក៏និង-

ឡាយដែលមានទំនិញមកលក់មានប្រមាណ ទីនឹងផ្ទេរទំនិញដែលមានទំនិញមកលក់-

មានប្រមាណ បាដលិបុត្រនេះតែមួយក្រុងប្រសើរជាងទីប្រជុំព្រះអរិយបុគ្គលនិង

ផ្ទេរទំនិញមកលក់នោះ ម្យ៉ាងទៀត ជាកន្លែងបែកស្បោងផ្លូវបណ្តោងទ្រព្យ

ម្នាលអានន្ទ ក្រុងបាដលិបុត្រនុះជាទីមានសេចក្តីអន្តរាយ ៣ យ៉ាង គឺ

អន្តរាយអំពីភ្លើង ១ អន្តរាយអំពីទឹក ១ អន្តរាយអំពីបែកធ្លាយក្នុង គឺបែក

បាក់គ្នានឹងគ្នា ១ ។

(១៦០) គ្រានោះ មហាមាត្យទៅក្នុងដែនមគធៈឈ្មោះសុចិរៈនិង

វិស្សុតៈ (ទាំង២) ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់

ហើយក៏ពោលពាក្យរាក់ទាក់សំណេះសំណាលទៅកេព្រះមានព្រះភាគ

លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យគួររំលឹក លុះឲ្យកើត

សេចក្តីស្និទ្ធស្នាលហើយ ទើបឋិតនៅក្នុងទីសមគួរ ។ លុះមហាមាត្យក្នុង

ដែនមគធៈឈ្មោះសុចិរៈនិងវិស្សុតៈឋិតនៅក្នុងទីសមគួរហើយក៏ពោល

ពាក្យថ្វាយនឹងព្រះមានព្រះភាគថា សូមព្រះគោតមដ៏ចំរើនទទួលភត្ត

របស់ខ្ញុំព្រះអង្គទាំងឡាយដើម្បីឆាន់ក្នុងថ្ងៃស្អែក មួយអន្លើដោយភិក្ខុសង្ឃ ។

អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ សុនីធវស្សការា មគធមហាមត្តា ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា បក្កមឹសុ ។ អថខោ សុនីធវស្សការា មគធមហាមត្តា(១) បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសុំ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន សុនីធវស្សការានំ មគធមហាមត្តានំ បរិវេសនា(២) តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។ អថខោ សុនីធវស្សការា មគធមហាមត្តា ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ សុនីធវស្សការេ មគធមហាមត្តេ ភគវា ឥមាហិ គាថាហិ អនុមោទិ

១ ឯត្ថន្តរេ សកេ និវេសនេ បាឋោ អត្ថិ ។ ២ និវេសនន្តិ កត្ថចិ បោត្ថកេ អត្ថិ ។



ព្រះមានព្រះភាគទ្រង់ទទួលនិមន្តដោយការស្ងៀម ។ គ្រានោះ មហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈ ដឹងថាព្រះមានព្រះភាគទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ហើយដើរចេញទៅ ។ គ្រានោះ មហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈ ក៏តាក់តែងខាទនីយភោជនីយាហារដ៏ឧត្តម (រួចហើយ) ចាត់បម្រើឲ្យទៅក្រាបបង្គំទូលកាលដ៏គួរ ដល់ព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន កាល (នេះជាកាលគួរហើយ) ភត្តក៏សម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ ហើយប្រដាប់ដោយបាត្រនិងចីវរក្នុងវេលាព្រឹក យាងចូលទៅកាន់លំនៅមហាមាត្យ នៅក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈ លុះយាងចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេរៀបចំថ្វាយជាមួយនឹងភិក្ខុសង្ឃ ។ គ្រានោះ មហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈ ក៏អង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយខាទនីយភោជនីយាហារ ដ៏ឆ្ងាញ់ពិសា ដោយដៃខ្លួន គ្រាន់តែភិក្ខុសង្ឃហាមឃាត់ លុះកំណត់ដឹងថា ព្រះមានព្រះភាគទ្រង់សោយរួចហើយ ដាក់ព្រះហស្តចុះចាកបាត្រ ហើយក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ លុះមហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈ អង្គុយនៅក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគទ្រង់អនុមោទនា ដោយព្រះគាថាទាំងឡាយនេះថា

(១៦១) យស្មឹ បទេសេ កប្បេតិ
វាសំ បណ្ឌិតជាតិយោ
សីលវន្តេត្ថ ភោជេត្វា
សញ្ញតេ ព្រហ្មចារិនោ(១)
យា តត្ថ ទេវតា អាសុំ
តាសំ ទក្ខិណមាទិសេ ។
តា បូជិតា បូជយន្តិ
មានិតា មានយន្តិ នំ
តតោ នំ អនុកម្បន្តិ
មាតា បុត្តំវ ឱរសំ ។
ទេវតានុកម្បិតោ បោសោ
សទា ភទ្រានិ បស្សតិ ។

(១៦៦) អថខោ ភគវា សុនីធវស្សការេ មគធមហាមត្តេ ឥមាហិ គាថាហិ អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមិ ។ តេន ខោ បន សមយេន សុនីធវស្សការា មគធមហាមត្តា ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពទ្ធា ហោន្តិ យេនជ្ជ សមណោ គោតមោ ទ្វារេន និក្ខមិស្សតិ តំ

---

១. ព្រហ្មចារិយេ ។



(១៦១) មនុស្ស ជាបណ្ឌិតជាតិ រមែងសម្រេចនូវការនៅក្នុងប្រទេសណាហើយ គឺតែងឲ្យពួកបុគ្គលអ្នកមានសីល ដែលសង្រួមល្អ ប្រព្រឹត្តធម៌ដ៏ប្រសើរ ឲ្យបរិភោគក្នុងទីលំនៅរបស់ខ្លួន ហើយគួរតាំងឧទ្ទិសផលទក្ខិណាទាន (ឲ្យចំណែកបុណ្យ) ដល់ពួកទេវតាដែលនៅក្នុងប្រទេសនោះ (ផងទៀត) ។ ទេវតាទាំងនោះ តែងបូជាចំពោះមនុស្សដែលបានបូជាដល់ខ្លួន តែងរាប់អានចំពោះមនុស្សដែលរាប់អានដល់ខ្លួន តែងអនុគ្រោះមនុស្សនោះ ដូចជាមាតាអនុគ្រោះបុត្រដែលខ្លួនបង្កើតអំពីទ្រូងឲ្យចំរើនឡើង ។ មនុស្សដែលទេវតាបានអនុគ្រោះហើយ គឺតែងឃើញនូវសេចក្តីចំរើនសព្វៗកាល ។

(១៦៦) លំដាប់នោះ ព្រះមានព្រះភាគទ្រង់អនុមោទនាដោយព្រះគាថាទាំងឡាយនេះចំពោះមហាមាត្យនៅក្នុងដែនមគធៈឈ្មោះសុនីធៈនិងវស្សការៈ (ចប់ហើយ) ក៏ទ្រង់ក្រោកចាកអាសនៈយាងចេញទៅ ។ សម័យនោះឯង មហាមាត្យនៅក្នុងដែនមគធៈឈ្មោះសុនីធៈនិងវស្សការៈ ដើរតាមព្រះមានព្រះភាគអំពីក្រោយៗ ដោយគិតថា ក្នុងថ្ងៃនេះព្រះសមណគោតមនឹងយាងចេញទៅតាមទ្វារណា ទ្វារនោះនឹងបានឈ្មោះថា

គោតមទ្វារំ នាម ភវិស្សតិ យេន តិត្ថេន គង្គំ នទិំ ឧត្តរិស្សតិ តំ គោតមតិត្ថំ នាម ភវិស្សតីតិ ។ អថខោ ភគវា យេន ទ្វារេន និក្ខមិ តំ គោតមទ្វារំ នាម អហោសិ ។ អថខោ ភគវា យេន គង្គា នទី តេនុបសង្កមិ ។ តេន ខោ បន សមយេន គង្គា នទី បូរា ហោតិ សមតិត្តិកា[១] កាកបេយ្យា ។ មនុស្សា អញ្ញេ នាវំ បរិយេសន្តិ អញ្ញេ ឧឡុម្បំ បរិយេសន្តិ អញ្ញេ កុល្លំ ពន្ធន្តិ ឱរា បារំ គន្តុកាមា ។ អទ្ទសា (ខោ) ភគវា តេ មនុស្សេ អញ្ញេ នាវំ បរិយេសន្តេ អញ្ញេ ឧឡុម្បំ បរិយេសន្តេ អញ្ញេ កុល្លំ ពន្ធន្តេ ឱរា បារំ គន្តុកាមេ ទិស្វាន សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ គង្គាយ នទិយា ឱរិមតីរេ[២] អន្តរហិតោ បារិមេ តីរេ បច្ចុដ្ឋាសិ សទ្ធិំ ភិក្ខុសង្ឃេន ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

១ ឱ. សមតិត្ថិកា ។ ២ ឱ. ឱរិមតីរេ ។



គោតមទ្វារ នឹងឆ្លងស្ទឹងគង្គាតាមកំពង់ណា កំពង់នោះនឹងបានឈ្មោះថា គោតមតិត្ថ ។ គ្រានោះ ព្រះដ៏មានព្រះភាគស្តេចយាងចេញតាមទ្វារណា ទ្វារនោះក៏ឈ្មោះថា គោតមទ្វារ ជាប្រក្រតី (ដល់សព្វថ្ងៃនេះ) ។ វេលានោះ ព្រះដ៏មានព្រះភាគស្តេចយាងចូលទៅកាន់ស្ទឹងគង្គា ។ ស្ទឹងគង្គាមានទឹកពេញប្រៀបព្រៀមស្មើនឹងមាត់ច្រាំង ល្មមសត្វក្អែកនឹងផឹកបាន ។ មនុស្សពួកខ្លះរកទូក មនុស្សពួកខ្លះរកផែ មនុស្សពួកខ្លះចងក្បូន ប្រាថ្នានឹងឆ្លងពីត្រើយខាងអាយ ទៅកាន់ត្រើយខាងនាយ ។ ព្រះដ៏មានព្រះភាគទ្រង់បានឃើញមនុស្សទាំងនោះ គឺមនុស្សពួកខ្លះកំពុងរកទូក មនុស្សពួកខ្លះកំពុងរកផែ មនុស្សពួកខ្លះកំពុងចងក្បូន ប្រាថ្នានឹងឆ្លងពីត្រើយខាងអាយទៅត្រើយខាងនាយ លុះព្រះដ៏មានព្រះភាគទ្រង់ឃើញហើយក៏ទម្លាក់ព្រះអង្គបាត់ (មួយរំពេច) អំពីត្រើយខាងអាយនៃស្ទឹងគង្គា ទៅប្រាកដនៅត្រើយខាងនាយជាមួយនឹងភិក្ខុសង្ឃ ឧបមាដូចជាបុរសមានកំឡាំង លាចេញនូវដើមដៃដែលបត់ចូល ឬបត់ចូលនូវដើមដៃដែលលាចេញ ឆាប់រហ័សដូច្នោះឯង ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់នូវសេចក្តីនោះហើយ ទើបបន្លឺឡើងនូវឧទានគាថានេះ ក្នុងវេលានោះថា

យេ តរន្តិ អណ្ណវំ សរំ
សេតុំ កត្វាន វិសជ្ជ បល្លលានិ
កុល្លំ ហិ ជនោ បពន្ធតិ
តិណ្ណា មេធាវិនោ ជនាតិ ។

[១៦៣] អថ ខោ ភគវា យេន កោដិគ្គាមោ តេនុបសង្កមិ ។ តត្រ សុទំ ភគវា កោដិគ្គាមេ វិហរតិ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ចតុន្នំ ភិក្ខវេ អរិយសច្ចានំ អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច កតមេសំ ចតុន្នំ ទុក្ខស្ស ភិក្ខវេ អរិយសច្ចស្ស អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ទុក្ខសមុទយស្ស អរិយសច្ចស្ស ។ បេ ។ ទុក្ខនិរោធស្ស អរិយសច្ចស្ស ។ បេ ។ ទុក្ខនិរោធគាមិនិយា



ពួកជនណាឆ្លងស្ទឹងគឺតណ្ហាដ៏ជ្រៅទូលាយបាន (ពួកជនទាំងនោះ) តែងធ្វើស្ពានគឺអរិយមគ្គ មិនប៉ះពាល់ទីជាទំនាបពាក់ទឹកឡើយហើយឆ្លងបាន សេចក្តីពិតថា ជនឯម្នាក់ (ដែលប្រាថ្នានឹងឆ្លងទឹកបន្តិចបន្តួច) តែងចងក្បូន (ទើបឆ្លងទៅបាន) ឯជនជាអ្នកប្រាជ្ញពាក់ទឹកឡើយ គឺព្រះពុទ្ធនិងសាវករបស់ព្រះពុទ្ធ លោកបានឆ្លងរួចស្រេចហើយ ។

[១៦៣] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់យាងចូលទៅកាន់កោដិគ្រាម[*] ។ បានឮថា ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកោដិគ្រាមនោះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយក្នុងកោដិគ្រាមនោះមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី អន្ទោលទៅនឹងត្រាច់ស្ទុះទៅកាន់ភពតូចធំយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹងនិងមិនបានចាក់ធ្លុះនូវអរិយសច្ចទាំង ៤ អរិយសច្ចទាំង ៤ ដូចម្តេចខ្លះ ម្នាលភិក្ខុទាំងឡាយ តថាគតនិងអ្នកទាំងឡាយអន្ទោលទៅ ត្រាច់ស្ទុះទៅកាន់ភពតូចធំយ៉ាងនេះជាយូរ ព្រោះមិនបានត្រាស់ដឹងនិងមិនបានចាក់ធ្លុះនូវទុក្ខអរិយសច្ច នូវទុក្ខសមុទយអរិយសច្ច ។ បេ ។ នូវទុក្ខនិរោធអរិយសច្ច ។ បេ ។ តថាគត

* ក្នុងគម្ពីរសារត្ថទីបនីជាដីកាវិនយសមន្ត ពន្យល់សេចក្តីថា កោដិគ្រាមនោះនៅត្រង់កន្លែងកំពូលប្រាសាទនៃស្តេចមហាបនាទដែលលិចចុះទៅក្នុងផែនដី (មើលមង្គលត្ថទីបនីក្នុងគគ្គិយ-គាថា សំឡាកថា) ។

បដិបទាយ អរិយសច្ចស្ស(១) អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច តយិទំ ភិក្ខវេ ទុក្ខំ អរិយសច្ចំ អនុពុទ្ធំ បដិវិទ្ធំ ទុក្ខសមុទយោ(២) អរិយសច្ចំ អនុពុទ្ធំ បដិវិទ្ធំ ទុក្ខនិរោធោ(៣) អរិយសច្ចំ អនុពុទ្ធំ បដិវិទ្ធំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ អនុពុទ្ធំ បដិវិទ្ធំ ឧច្ឆិន្នា ភវតណ្ហា ខីណា ភវនេត្តិ នត្ថិទានិ បុនព្ភវោតិ ។

(១៦៦) ចតុន្នំ អរិយសច្ចានំ
យថាភូតំ អទស្សនា
សំសិតំ ទីឃមទ្ធានំ
តាសុ តាស្វេវ ជាតិសុ ។
តានិ ឯតានិ ទិដ្ឋានិ
ភវនេត្តិ សមូហតា
ឧច្ឆិន្នំ មូលំ ទុក្ខស្ស
នត្ថិទានិ បុនព្ភវោតិ ។

---

១ ឱ. ទុក្ខនិរោធគាមិនិយា បដិបទាយ អរិយសច្ចស្ស ។ ២-៣ សព្វត្ថ ទុក្ខសមុទយន្តិ ច ទុក្ខនិរោធន្តិ ច លិខិតន្តិ ។



នឹងអ្នកទាំងឡាយអន្ទោលទៅក្រឡាប់ក្រឡិនទៅកាន់ផ្លូវឆ្ងាយនេះយូរ ព្រោះមិនបានត្រាស់ដឹងនឹងមិនបានចាក់ធ្លុះនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ចនោះ តថាគតនឹងអ្នកទាំងឡាយបានត្រាស់ដឹង បានចាក់ធ្លុះហើយ ទុក្ខសមុទយអរិយសច្ចនោះ តថាគតនឹងអ្នកទាំងឡាយបានត្រាស់ដឹង បានចាក់ធ្លុះហើយ ទុក្ខនិរោធអរិយសច្ចនោះតថាគតនឹងអ្នកទាំងឡាយបានត្រាស់ដឹងបានចាក់ធ្លុះហើយ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចនោះ តថាគតនឹងអ្នកទាំងឡាយបានត្រាស់ដឹង បានចាក់ធ្លុះហើយ ភវតណ្ហា តថាគតនឹងអ្នកទាំងឡាយផ្តាច់ផ្តិលហើយ តម្រេកតណ្ហាសម្រាប់ដឹកនាំទៅកាន់ភពក៏អស់ហើយ ឥឡូវនេះគ្មានភពថ្មីទៀតទេ ។

(១៦៦) ការអន្ទោលទៅកាន់ផ្លូវឆ្ងាយក្នុងជាតិទាំងឡាយនោះ ៗ ឯង ព្រោះមិនបានឃើញនូវអរិយសច្ចទាំង៤ជាតាមពិត ៗ អរិយសច្ចទាំង៤នេះឯង តថាគតនឹងអ្នកទាំងឡាយបានឃើញហើយ តណ្ហាជាអ្នកដឹកនាំទៅកាន់ភព ក៏តថាគតនឹងអ្នកទាំងឡាយគាស់រំលើងហើយ ឫសនៃសេចក្តីទុក្ខ ក៏តថាគតនឹងអ្នកកាត់ផ្តាច់ចោលហើយ ឥឡូវនេះគ្មានភពថ្មីទៀតទេ ។

(១៦៩) អស្សោសិ ខោ អម្ពបាលី គណិកា ភគវា កិរ កោដិគ្គាមំ អនុប្បត្តោតិ ។ អថ ខោ អម្ពបាលី គណិកា ភទ្ទានិ ភទ្ទានិ យានានិ យោជាបេត្វា ភទ្ទំ ភទ្ទំ យានំ អភិរុហិត្វា ភទ្ទេហិ ភទ្ទេហិ យានេហិ វេសាលិយា និយ្យាសិ ភគវន្តំ ទស្សនាយ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកា វ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អម្ពបាលឹ គណិកំ ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថ ខោ អម្ពបាលី គណិកា ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថ ខោ អម្ពបាលី គណិកា ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា



(១៦៩) នាងអម្ពបាលីជាស្រីគណិកា បានឮដំណឹងថា ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរមកកាន់កោដិគ្រាម ។ លំដាប់នោះឯង នាងអម្ពបាលីជាស្រីគណិកា បានប្រើគេឲ្យទឹមយានដ៏ល្អៗហើយ ក៏ឡើងជិះយានដ៏ល្អៗ ចេញទៅអំពីក្រុងវេសាលី ដោយយានដ៏ល្អៗទាំងឡាយនោះ ដើម្បីជួបនឹងព្រះដ៏មានព្រះភាគ ហើយដាក់យានទុកត្រង់ទីមួយ ចុះអំពីយានដើរទៅដោយជើងទទេ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីសមគួរ ។ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់នាងអម្ពបាលីជាស្រីគណិកា ដែលអង្គុយក្នុងទីសមគួរ (នោះ)ឯង ឲ្យយល់ត្រម ឲ្យកាន់យកត្រម ឲ្យរីករាយ ឲ្យត្រេកអរដោយធម្មីកថា ។ លំដាប់នោះ នាងអម្ពបាលីជាស្រីគណិកា លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យយល់ត្រម ឲ្យកាន់យកត្រម ឲ្យរីករាយ ឲ្យត្រេកអរ ដោយធម្មីកថាហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក មួយអន្លើដោយភិក្ខុសង្ឃ ។ ព្រះដ៏មានព្រះភាគទ្រង់បានទទួលនិមន្តដោយតុណ្ហីភាព ។ គ្រានោះ នាងអម្ពបាលីជាស្រីគណិកា ដឹងថាព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តហើយ ទើបក្រោកចាកទីអង្គុយថ្វាយបង្គំលាព្រះដ៏មានព្រះភាគធ្វើ

ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អស្សោសុំ ខោ វេសាលិកា លិច្ឆវី ភគវា កិរ កោដិគាមំ អនុប្បត្តោតិ ។ អថខោ វេសាលិកា លិច្ឆវី ភទ្ទានិ ភទ្ទានិ យានានិ យោជាបេត្វា ភទ្ទំ ភទ្ទំ យានំ អភិរុហិត្វា ភទ្ទេហិ ភទ្ទេហិ យានេហិ វេសាលិយា និយ្យឹសុ(១) ភគវន្តំ ទស្សនាយ ។ អប្បេកច្ចេ លិច្ឆវី នីលា ហោន្តិ នីលវណ្ណា នីលវត្ថា នីលាលង្ការា អប្បេកច្ចេ លិច្ឆវី បីតា ហោន្តិ បីតវណ្ណា បីតវត្ថា បីតាលង្ការា អប្បេកច្ចេ លិច្ឆវី លោហិតកា ហោន្តិ លោហិតកវណ្ណា លោហិតកវត្ថា លោហិតកាលង្ការា អប្បេកច្ចេ លិច្ឆវី ឱទាតា ហោន្តិ ឱទាតវណ្ណា ឱទាតវត្ថា ឱទាតាលង្ការា ។ អថខោ អម្ពបាលី គណិកា ទហរានំ ទហរានំ លិច្ឆវីនំ អក្ខេន អក្ខំ ចក្កេន ចក្កំ យុគេន យុគំ បដិវដ្ដេសិ(២) ។ អថខោ តេ លិច្ឆវី អម្ពបាលឹ គណិកំ ឯតទវោចុំ កិស្ស ជេ

១ ឱ. និយ្យាសុំ ។ ២ ឱ. បដិវត្តេសិ ។



ប្រទក្សិណ ហើយចៀសចេញទៅ ។ ពួកស្តេចលិច្ឆវីក្រុងវេសាលីបានឮដំណឹងថា ព្រះដ៏មានព្រះភាគទ្រង់ស្តេចដល់កោដិគ្រាម ។ ពួកស្តេចលិច្ឆវីក្រុងវេសាលីក៏ឲ្យពួកសារថីទឹមយានដ៏ល្អៗ ហើយឡើងគង់យានដ៏ល្អៗ ចេញអំពីក្រុងវេសាលីទៅដោយយានដ៏ល្អៗ ដើម្បីចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ ស្តេចលិច្ឆវីពួកខ្លះលាបពណ៌ខៀវ មានសម្បុរខៀវ(១) ទ្រង់ព្រះពស្ត្រខៀវ(២) មានគ្រឿងតែងខ្លួនក៏ខៀវ(៣) ស្តេចលិច្ឆវីពួកខ្លះលាបពណ៌លឿង មានសម្បុរលឿង ទ្រង់ព្រះពស្ត្រលឿង មានគ្រឿងតែងខ្លួនក៏លឿង ស្តេចលិច្ឆវីពួកខ្លះលាបពណ៌ក្រហម មានសម្បុរក្រហម ទ្រង់ព្រះពស្ត្រក្រហម មានគ្រឿងតែងខ្លួនក៏ក្រហម ស្តេចលិច្ឆវីពួកខ្លះលាបពណ៌ស មានសម្បុរស ទ្រង់ព្រះពស្ត្រស មានគ្រឿងតែងខ្លួនក៏ស ។ លំដាប់នោះ នាងអម្ពបាលីជាស្រីពេស្យា បរបែដល់ធ្នាលដោយធ្នាល បំបរនឹមដោយនឹម បំបរកង់ដោយកង់ បំបរភ្លៅដោយភ្លៅ (នៃយាន) របស់ពួកស្តេចលិច្ឆវីកំលោះៗ ។ គ្រានោះ ស្តេចលិច្ឆវីទាំងនោះនិយាយនឹងនាងអម្ពបាលីជាស្រីពេស្យាថា ម្នាលជេ អម្ពបាលី ព្រោះហេតុអ្វីបានជានាងមក

១-២-៣ ក្នុងអដ្ឋកថាវិនយបិដកនិយាយថា សូម្បីកាំរថ-ទង់-ស្បែក-ដំបងជន្លួញ ក៏សុទ្ធតែប្រដាប់ដោយមាសនិងកែវមានសម្បុរខៀវទាំងអស់ ទាំងលឿង-ក្រហម-ស ក៏ដូច្នោះ ។

អត្តទាលំ អច្ឆាតំ ឧហាកន្តំ ឧហាកន្តំ លិច្ឆវីនំ ត្វំសោ-
យ ត្វំសំ យុគេន យុគំ ចក្កេន ចក្កំ អក្ខេន អក្ខំ
បដិវត្តេសិ ។ តថា ហិ ឯន មយា អយ្យបុត្តា ស្វា-
ហាយ គុទ្ទប្បមុខោ កិច្ចុសមេជ្ជា ឆិមន្តិតោតិ ។ ទេហិ
ជេ អត្តទាលំ អច្ឆាតំ បត់ កត្តំ សាតសមាសេ្សាតិ ។
សមេចិ មេ អយ្យបុត្តា វេសាលី សាមារំ ឧជ្ជេយ្យាឆ
ទេវ ឧច្ចាយាំ តំ កត្តត្តិ ។ អថខោ តេ លិច្ឆវី អត្ថុ-
លី[១] គោរជេសុំ បាជិតច្ឆ[២] វត តោ អត្តកាយ
បាជិតច្ឆ[៣] វត តោ អត្តកាយាតិ ។ អថខោ តេ
លិច្ឆវី យេន កតភ តេទុបសង្កមឹសុ ។ អទ្ធសា ខោ
កតភ តេ លិច្ឆវី ទូរតោ វ អាគច្ឆន្តេ ទិស្វាន កិច្ចា
អាមន្តេសិ យេហិ កិច្ចាវេ កិច្ចាហិ ទេហិ តាវត្តិសា
អភិនន្ទបុត្តា ឯលោកេថ កិច្ចាវេ លិច្ឆវីហិសំ អបលោកេថ

១ ម. គន្តុលី ។ ២.៣ ជិតច្ឆ ។





ប្រែដល់ចង្កូលដោយចង្កូល ចំហាំនឹងដោយចំហាំ ចំហាំកង់នឹងដោយកង់
ចំហាំក្តៅដោយក្តៅ (ផ្ទៃយាន) របស់យើងជាស្តេចលិច្ឆវីកំឡោះៗ ។
នាងមល្លិកាតបថា បពិត្រអយ្យបុត្ត[១]ទាំងឡាយ ព្រោះថា ខ្ញុំបាន
ទំរង់កត្តសម្បត្តិប្រាកដជាប្រែងមើលទឹកឆាន់កដទៃស្អែក ។ ស្តេច
លិច្ឆវីទាំងអស់នោះមានព្រះបន្ទូលថា ម្នាលមេមល្លិកា ចូរនាំឲ្យ
កត្តនេះមកយើងចុះ (ដើម្បីនឹងឲ្យមើលឲ្យបាន) ចំនួន ១ សែនកហាបណៈ ។
នាងមល្លិកាតបថា បពិត្រអយ្យបុត្ត ខ្ញុំពាក្យពាក្រវត្តប្រមានក្រុងវេសាលី
ព្រមទាំងសួយសារគេកវេទមាននៅកន្លែងតម្រូវមកឆ្វេង ខ្ញុំកំមិនព្រមថ្វាយ
កត្តនោះឡើយ ។ ព្រោះនោះ ស្តេចលិច្ឆវីទាំងនោះទ្រង់ប្រមាទព្រះហស្តហើយ
ពោលថា ម្នាលអ្នកទាំងឡាយចាំមើល យើងនាញមាតុគ្រាមហើយ ម្នាល
គោយើងចាំមើល យើងនាញមាតុគ្រាមហើយ ។ លំដាប់នោះ ស្តេច
លិច្ឆវីទាំងនោះ (គំនិត) ចូលទៅកាន់ទីដែលព្រះមានព្រះភាគគង់នៅ ។
ព្រះមានព្រះភាគទ្រង់ទតឃើញស្តេចលិច្ឆវីទាំងនោះកំពុងយាងមកអំពី
ចម្ងាយ លុះឃើញហើយទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ
ភិក្ខុណាដែលមិនធ្លាប់ឃើញទេវតា ក្នុងស្ថានតាវត្តិង្សទេ ម្នាលភិក្ខុទាំង
ឡាយ អ្នកទាំងឡាយចូរមើលពួកលិច្ឆវីបរិស័ទចុះ អ្នកទាំងឡាយ

១ អយ្យបុត្ត គឺព្រះអង្គម្ចាស់ ។

ភិក្ខវេ លិច្ឆវីបរិសំ ឧបសំហរថ ភិក្ខវេ លិច្ឆវីបរិសំ តាវតឹសបរិសន្តិ ។ អថខោ តេ លិច្ឆវី យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកាវ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ តេ លិច្ឆវី ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ តេ លិច្ឆវី ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ភគវន្តំ ឯតទវោចុំ អធិវាសេតុ នោ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវុត្ថម្ហិ លិច្ឆវី ស្វាតនាយ អម្ពបាលិយា គណិកាយ ភត្តន្តិ ។ អថខោ តេ លិច្ឆវី អង្គុលឹ ពោថេសុំ បរជិតម្ហ[១] វត ភោ អម្ពកាយ បរជិតម្ហ[២] វត ភោ អម្ពកាយាតិ ។ អថខោ តេ លិច្ឆវី ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា

---

១-២ ជិតម្ហ ។



ចូរសំឡឹងមើលពួកលិច្ឆវីបរិស័ទឲ្យរឿយ ៗ ចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រៀបធៀបពួកលិច្ឆវីបរិស័ទ នោះនឹងពួកទេវតាក្នុងជាន់តាវត្តិង្សមើលចុះ ។ លំដាប់នោះ ស្ដេចលិច្ឆវីទាំងនោះក៏ជិះយានទៅត្រឹមទីមួយ ហើយចុះអំពីយានដើរទៅដោយជើងទទេ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគរួចអង្គុយនៅក្នុងទីសមគួរ ។ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ពួកស្ដេចលិច្ឆវីដែលអង្គុយក្នុងទីសមគួរនោះឯង ឲ្យយល់ច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចកហាន ឲ្យរីករាយ ដោយធម្មីកថា ។ ឯស្ដេចលិច្ឆវីទាំងនោះ ដែលព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យយល់ច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចកហាន ឲ្យរីករាយដោយធម្មីកថាហើយក៏ពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគព្រមទាំងភិក្ខុសង្ឃទទួលភត្តរបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែក ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលលិច្ឆវីទាំងឡាយ តថាគតបានទទួលភត្តរបស់នាងអម្ពបាលីជាស្រីផ្កាមាសក្នុងថ្ងៃស្អែករួចទៅហើយ ។ លំដាប់នោះ ស្ដេចលិច្ឆវីទាំងនោះទះម្រាមព្រះហស្តហើយពោលថា ម្នាលគ្នាយើងដ៏ចំរើន យើងចាញ់មាតុគ្រាមហើយ ម្នាលគ្នាយើងដ៏ចំរើន យើងចាញ់មាតុគ្រាមហើយ ។ លំដាប់នោះ ស្ដេចលិច្ឆវីទាំងនោះត្រេកអររីករាយ តាមភាសិតរបស់ព្រះដ៏មានព្រះភាគហើយ

ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា កោដិគ្គាមេ យថាភិរន្តំ វិហរិត្វា យេន នាតិកា(១) តេនុបសង្កមិ ។ តត្រ សុទំ ភគវា នាតិកេ(២) វិហរតិ គិញ្ជកាវសថេ ។ អថខោ អម្ពបាលី គណិកា តស្សា រត្តិយា អច្ចយេន សកេ អារាមេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន អម្ពបាលិយា គណិកាយ បរិវេសនា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធិំ ភិក្ខុសង្ឃេន ។ អថខោ អម្ពបាលី គណិកា ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នា ខោ អម្ពបាលី គណិកា ភគវន្តំ ឯតទវោច ឥមាហំ ភន្តេ

១-២ ម. ញាតិកា ញាតិកេ ។



ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។ គ្រានោះ ព្រះដ៏មានព្រះភាគគង់នៅក្នុងកោដិគ្រាមគួរតាមព្រះអធ្យាស្រ័យហើយ យាងទៅកាន់នាទិកាប្រទេស ។ ព្រះអង្គទ្រង់គង់នៅក្នុងរោងឥដ្ឋក្នុងនាទិកាប្រទេសនោះឯង ។ លុះព្រលឹមឡើង នាងអម្ពបាលីជាស្រីគណិកា ក៏តាក់តែងខាទនីយភោជនីយាហារ (បង្អែមចំណាប) ក្នុងអារាម (ផ្ទះ) របស់ខ្លួន ហើយចាត់បម្រើឲ្យទៅក្រាបបង្គំទូលកាលគួរដល់ព្រះដ៏មានព្រះភាគថា កាលគួរហើយព្រះអង្គ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ហើយប្រដាប់ប្រដាយកបាត្រនិងចីវរវេលាព្រលឹម យាងស្ដេចទៅកាន់ទីអង្គាស (ចង្ហាន់) របស់នាងអម្ពបាលីជាស្រីគណិកា លុះយាងទៅដល់ហើយទើបគង់លើអាសនៈដែលគេក្រាលថ្វាយព្រមទាំងភិក្ខុសង្ឃ ។ គ្រានោះ នាងអម្ពបាលីជាស្រីគណិកាអង្គាសថ្វាយខាទនីយភោជនីយាហារ (បង្អែមចំណាប) ដ៏ឆ្ងាញ់ពិសារដោយដៃខ្លួនឯងចំពោះព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ គ្រាកាលព្រះដ៏មានព្រះភាគទ្រង់ឈប់ទទួល សោយស្រេចហើយ លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ទើប (នាង) អង្គុយនៅក្នុងទីសមគួរ ។ កាលបើនាងអម្ពបាលីជាស្រីគណិកាអង្គុយនៅក្នុងទីដ៏សមគួរហើយ ទើបពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមថ្វាយនូវ

អម្ពបាលិវនំ ពុទ្ធប្បមុខស្ស ភិក្ខុសង្ឃស្ស ទម្មីតិ ។ បដិគ្គហេសិ ភគវា អារាមំ ។ អថខោ ភគវា អម្ពបាលឹ គណិកំ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា យេន មហាវនំ តេនុបសង្កមិ ។ តត្រ សុទំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។

លិច្ឆវិភាណវារំ និដ្ឋិតំ ។

[១៦៦] តេន ខោ បន សមយេន អភិញ្ញាតា អភិញ្ញាតា លិច្ឆវី សន្ថាគារេ សន្និសិន្នា សន្និបតិតា អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសន្តិ ធម្មស្ស វណ្ណំ ភាសន្តិ សង្ឃស្ស វណ្ណំ ភាសន្តិ ។ តេន ខោ បន



អម្ពបាលិវ័នរបស់ខ្ញុំ ដល់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ទទួលនូវអារាម (នោះ) ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់នាងអម្ពបាលីជាស្រីគណិកាឲ្យយល់ព្រម ឲ្យកាន់យកព្រម ឲ្យត្រេកអរ ឲ្យរីករាយដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈ យាងទៅកាន់ព្រៃមហាវ័ន ។ ឮថា ព្រះមានព្រះភាគ គង់នៅក្នុងកូដាគារសាលាក្នុងមហាវ័ន ជិតក្រុងវេសាលីនោះឯង ។

ចប់ វារៈពោលអំពីស្តេចលិច្ឆវី ។

[១៦៦] សម័យនោះឯង ពួកស្តេចលិច្ឆវីដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញៗក្រៃលែង អង្គុយប្រជុំគ្នាក្នុងរោងសម្រាប់ទទួលភ្ញៀវ ហើយពោលសរសើរគុណព្រះពុទ្ធ[១] ពោលសរសើរគុណព្រះធម៌[២] ពោលសរសើរគុណព្រះសង្ឃ[៣] ដោយបរិយាយជាច្រើន ។ សម័យនោះ សីហសេនាបតិ

១ ក្នុងដីកាពន្យល់សេចក្តីថា ពោលសរសើរពុទ្ធគុណដោយបរិយាយ ៣ គឺញាណក្ខបរិយាយ ១ លោកក្ខបរិយាយ ១ ពុទ្ធក្ខបរិយាយ ១ ។ ២ ពោលសរសើរធម្មគុណដោយចំណែកនិកាយ ៥ ចំណែក ៣ អង្គសត្ថុសាសន៍ ៩ ធម្មក្ខន្ធ ៨៤.០០០ ។ ៣ ពោលសរសើរសង្ឃគុណដោយអំណាច បញ្ជាក់ថា ភទ្ទិយរាជ មហាកប្បិនរាជ បុក្កុស យសកុលបុត្ត សោណសេដ្ឋីបុត្ត រដ្ឋបាលកុលបុត្ត (សោភិតអម្បាលនេះជាដើម) ស្តាប់ធម៌ហើយបាននូវសទ្ធា លះស្វេតច្ឆត្រ រាជសម្បត្តិ សះទី សេនាបតិ ទំនងសេដ្ឋី ទីជាតាយឃ្លាំង ចេញបួសក្នុងសាសនារបស់ព្រះសាស្តា ។

សមយេន សីហោ សេនាបតិ និគណ្ឋសាវកោ តស្សំ បរិសាយំ និសិន្នោ ហោតិ ។ អថខោ សីហស្ស សេនាបតិស្ស ឯតទហោសិ និស្សំសយំ ខោ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ភវិស្សតិ តថា ហិមេ អភិញ្ញាតា អភិញ្ញាតា លិច្ឆវី សន្ធាគារេ សន្និសិន្នា សន្និបតិតា អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសន្តិ ធម្មស្ស វណ្ណំ ភាសន្តិ សង្ឃស្ស វណ្ណំ ភាសន្តិ យន្នូនាហំ តំ ភគវន្តំ ទស្សនាយ ឧបសង្កមេយ្យំ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ អថខោ សីហោ សេនាបតិ យេន និគណ្ឋោ នាដបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា និគណ្ឋំ នាដបុត្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សីហោ សេនាបតិ និគណ្ឋំ នាដបុត្តំ ឯតទវោច ឥច្ឆាមហំ ភន្តេ សមណំ គោតមំ ទស្សនាយ ឧបសង្កមិតុន្តិ ។ កឹ បន ត្វំ សីហ កិរិយវាទោ សមានោ អកិរិយវាទំ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សសិ សមណោ ហិ សីហ គោតមោ អកិរិយវាទោ អកិរិយាយ ធម្មំ ទេសេតិ



ជាសាវកនិគ្រន្ថក៏អង្គុយនៅក្នុងកណ្ដាលបរិសទ្យនោះដែរ ។ ទើបសីហសេនាបតិត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគនោះប្រាកដជាព្រះអរហន្តសម្មាសម្ពុទ្ធពិតមិនសង្ស័យឡើយ ព្រោះហេតុនោះ ពួកស្ដេចលិច្ឆវីជាច្រើនដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្រៃលែងអង្គុយប្រជុំគ្នាក្នុងរោងសម្រាប់ទទួលភ្ញៀវ ហើយពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយបរិយាយជាច្រើន បើដូច្នោះមានតែអាត្មាអញចូលទៅ ដើម្បីឃើញព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ (លមើល) ។ លំដាប់នោះ សីហសេនាបតិចូលសំដៅទៅត្រង់ទីដែលនិគណ្ឋនាដបុត្តនៅ លុះចូលទៅដល់ហើយក៏សំពះនិគណ្ឋនាដបុត្តហើយអង្គុយនៅក្នុងទីសមគួរ ។ លុះសីហសេនាបតិអង្គុយនៅក្នុងទីសមគួរហើយ ទើបនិយាយទៅនឹងនិគណ្ឋនាដបុត្តថា បពិត្រលោកដ៏ចំរើន ខ្ញុំចង់ចូលទៅឃើញព្រះសមណគោតម (ម្ដងមើល) ។ និគណ្ឋនាដបុត្តពោលថា ម្នាលសីហៈ អ្នកឯងជាអ្នកនិយាយចំពោះកិច្ចការថាត្រូវធ្វើ នឹងចូលទៅមើលសមណគោតមជាអ្នកពោលពាក្យឃាត់កិច្ចការថាមិនត្រូវធ្វើដូចម្ដេចបាន ម្នាលអ្នកសីហៈ ព្រោះសមណគោតមជាអ្នកពោលពាក្យឃាត់កិច្ចការថាមិនត្រូវធ្វើ សំដែងធម៌ហាមកិច្ចការថាមិនត្រូវធ្វើ នឹង

តេន ច សាវកេ វិនេតីតិ ។ អថខោ សីហស្ស សេនាប-
តិស្ស យោ អហោសិ គមិកាភិសង្ខារោ ភគវន្តំ ទស្សនា-
យ សោ បដិប្បស្សម្ភិ ។ ទុតិយម្បិ ខោ ។បេ។ តតិយម្បិ
ខោ អភិញ្ញាតា អភិញ្ញាតា លិច្ឆវី សន្ថាគារេ សន្និសិន្នា
សន្និបតិតា អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសន្តិ
ធម្មស្ស វណ្ណំ ភាសន្តិ សង្ឃស្ស វណ្ណំ ភាសន្តិ ។ តតិ-
យម្បិ ខោ សីហស្ស សេនាបតិស្ស ឯតទហោសិ
និស្សំសយំ ខោ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ
ភវិស្សតិ តថា ហិមេ អភិញ្ញាតា អភិញ្ញាតា លិច្ឆវី
សន្ថាគារេ សន្និសិន្នា សន្និបតិតា អនេកបរិយាយេន
ពុទ្ធស្ស វណ្ណំ ភាសន្តិ ធម្មស្ស វណ្ណំ ភាសន្តិ សង្ឃស្ស
វណ្ណំ ភាសន្តិ កឹ ហិ មេ ករិស្សន្តិ និគណ្ឋា អបលោកិ-
តា វា អនបលោកិតា វា យន្នូនាហំ អនបលោកេត្វា
និគណ្ឋេ តំ ភគវន្តំ ទស្សនាយ ឧបសង្កមេយ្យំ អរហន្តំ
សម្មាសម្ពុទ្ធន្តិ ។ អថខោ សីហោ សេនាបតិ បញ្ចហិ
រថសតេហិ ទិវា ទិវស្ស វេសាលិយា និយ្យាសិ ភគវន្តំ
ទស្សនាយ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា



ទូន្មានសាវកទាំងឡាយ ដោយពោលពាក្យថាកិច្ចការធ្វើមិនត្រូវនោះ
ផង ។ និងការរៀបចំដំណើររបស់សីហសេនាបតី ដើម្បីនឹងទៅឃើញព្រះដ៏
មានព្រះភាគ (នុ៎ះ) ក៏ស្ងប់ទៅ ។ ពួកស្តេចលិច្ឆវីដែលមានកេរ្តិ៍ឈ្មោះ
ល្បីល្បាញក្រៃលែង អង្គុយប្រជុំគ្នាក្នុងរោងសម្រាប់ចូលគៀរ ហើយ
ពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរ
គុណព្រះសង្ឃ ដោយបរិយាយជាច្រើនអស់វារៈជាគំរប់ពីរដងផង ។បេ។
អស់វារៈជាគំរប់បីដងផង ។ ឯសីហសេនាបតីក៏មានសេចក្តីត្រិះរិះអស់វារៈជា
គំរប់បីដងថា ព្រះដ៏មានព្រះភាគនោះព្រះអង្គជាព្រះអរហន្តសម្មាសម្ពុទ្ធ
ប្រាកដឥតសង្ស័យឡើយ ព្រោះហេតុនោះហើយបានជាពួកស្តេចលិច្ឆវី
ទាំងនេះដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្រៃលែង អង្គុយប្រជុំគ្នាក្នុងរោង
សម្រាប់ចូលគៀរ ហើយពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរ
គុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយបរិយាយជាច្រើន
និគណ្ឋទាំង (នេះ) ទោះអញលាក្តី មិនលាក្តី នឹងធ្វើអ្វីអញ បើដូច្នោះគាត់
អញមិនបាច់លានិគណ្ឋទាំង (នេះ) ទេ គួរតែចូលទៅឃើញព្រះដ៏មានព្រះ
ភាគជាព្រះអរហន្តសម្មាសម្ពុទ្ធនោះវិញចុះ ។ លំដាប់នោះ សីហសេនាបតី
ចេញទៅអំពីក្រុងវេសាលី ដោយរថ ៥០០ គ្រឿងក្នុងវេលាថ្ងៃ ដើម្បីនឹងឃើញព្រះ
ដ៏មានព្រះភាគ ហើយជិះយានទៅត្រឹមទីសមគួរ ទើបចុះអំពីយានដើរទៅ

យានា បច្ចោរោហិត្វា បត្តិកោវ យេន ភគវា តេនុប-
សង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសី-
ទិ ។ ឯកមន្តំ និសិន្នោ ខោ សីហោ សេនាបតិ ភគវន្តំ
ឯតទវោច សុតម្មេតំ ភន្តេ អកិរិយវាទោ សមណោ
គោតមោ អកិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ
វិនេតីតិ យេ តេ ភន្តេ ឯវមាហំសុ អកិរិយវាទោ សម-
ណោ គោតមោ អកិរិយាយ ធម្មំ ទេសេតិ តេន ច
សាវកេ វិនេតីតិ កច្ចិ តេ ភន្តេ ភគវតោ វុត្តវាទិនោ
ន ច ភគវន្តំ អភូតេន អព្ភាចិក្ខន្តិ ធម្មស្ស ច អនុធម្មំ
ព្យាករោន្តិ ន ច កោចិ សហធម្មិកោ វាទានុវាទោ
គារយ្ហំ ឋានំ អាគច្ឆតិ អនព្ភក្ខាតុកាមា ហិ មយំ ភន្តេ
ភគវន្តន្តិ ។



ដោយយានជំនិះទេ ចូលទៅដោយថ្មើរជើងត្រង់ទៅកាន់ទីដែលព្រះដ៏មានព្រះភាគគង់នៅ លុះ
ចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។
លុះសីហសេនាបតីអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មាន
ព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឮថា ព្រះសមណ
គោតមជាអ្នកពោលឃាត់កិច្ចការថាមិនគួរធ្វើ សំដែងធម៌ឃាត់កិច្ចការថា
មិនគួរធ្វើ តាំងទូន្មានសាវកទាំងឡាយដោយពោលពាក្យឃាត់កិច្ចការថា
មិនគួរធ្វើដូច្នោះដែរ បពិត្រព្រះអង្គដ៏ចំរើន ជនទាំងឡាយណាពោលយ៉ាង
នេះថា ព្រះសមណគោតមជាអ្នកពោលឃាត់កិច្ចការថាមិនគួរធ្វើ សំដែង
ធម៌ឃាត់កិច្ចការថាមិនគួរធ្វើ តាំងទូន្មានសាវកទាំងឡាយដោយពោល
ពាក្យឃាត់កិច្ចការថាមិនគួរធ្វើដូច្នោះដែរ បពិត្រព្រះអង្គដ៏ចំរើន ជនទាំង
នោះពោលត្រូវតាមពាក្យរបស់ព្រះអង្គ មិនមែនពោលបង្កាច់ព្រះអង្គ
ដោយពាក្យមិនពិតទេឬ ឬក៏ព្រះអង្គតែងពោលព្យាករនូវធម៌សមគួរ
ដល់ធម៌ ប្រសិនបើមានសហធម្មិកណាមួយបានពោលត្រាប់តាមព្រះពុទ្ធ-
ដីកាដែលព្រះអង្គបានពោល (នោះ) ក៏មិនបានដល់នូវហេតុគួរតិះដៀល
ឡើយ បពិត្រព្រះអង្គដ៏ចំរើន ព្រោះហេតុនោះហើយ បានជាយើង
ខ្ញុំព្រះអង្គមិនចង់ពោលបង្កាច់ព្រះដ៏មានព្រះភាគ ។

(១៦៧) អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អកិរិយវាទោ សមណោ គោតមោ អកិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ កិរិយវាទោ សមណោ គោតមោ កិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ឧច្ឆេទវាទោ សមណោ គោតមោ ឧច្ឆេទាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ជេគុច្ឆី សមណោ គោតមោ ជេគុច្ឆិតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ វេនយិកោ សមណោ គោតមោ វិនយាយ ធម្មំ ទេសេតិ តេន ច សាវកេ



(១៦៧) ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសីហៈ មានហេតុដែលជនឯទៀតអ្នកផងដទៃថា ចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកពោលពាក្យថាអកិរិយាថា មិនត្រូវធ្វើ សំដែងធម៌ដោយអកិរិយាថា មិនត្រូវធ្វើ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា មិនត្រូវធ្វើនោះផង ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ មានហេតុដែលជនឯទៀតអ្នកផងដទៃថា ចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកពោលថា ត្រូវធ្វើកិរិយា សំដែងធម៌ថា ត្រូវធ្វើ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថាត្រូវធ្វើនោះផង ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ មានហេតុដែលជនឯទៀតអ្នកផងដទៃថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកពោលពាក្យកាត់ផ្តាច់ផ្តិលទោតើ សំដែងធម៌ ដើម្បីកាត់ផ្តាច់ផ្តិល ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថាត្រូវកាត់ផ្តាច់ផ្តិលនោះផង ដែលថានោះត្រូវហើយ ។ ម្នាលសីហៈ មានហេតុដែលជនឯទៀតអ្នកផងដទៃថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកខ្ពើមរអើម សំដែងធម៌ ដើម្បីខ្ពើមរអើម ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ត្រូវខ្ពើមរអើមនោះផង ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ មានហេតុដែលជនឯទៀតអ្នកផងដទៃថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកបំផ្លាញទោតើ សំដែងធម៌ ដើម្បីបំផ្លាញ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា

វិនេតីតិ ។ អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ តបស្សី សមណោ គោតមោ តបស្សិតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អបគព្ភោ សមណោ គោតមោ អបគព្ភតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អស្សត្ថោ សមណោ គោតមោ អស្សត្ថាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អកិរិយវាទោ សមណោ គោតមោ អកិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អហញ្ហិ សីហ អកិរិយំ វទាមិ កាយទុច្ចរិតស្ស វចីទុច្ចរិតស្ស មនោទុច្ចរិតស្ស អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ អកិរិយំ វទាមិ អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា



ក្រៅអំពីពាក្យនោះដែរ ដែលគេថាចំពោះព្រះអង្គហើយ ។ ម្នាលសីហៈ មានហេតុដែលជនគួរឲ្យអ្នកផងនិយាយចំពោះតថាគតថា ព្រះសមណគោតមជាអ្នកដុតកំដៅនូវបាប សំដែងធម៌ដើម្បីដុតកំដៅ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ឲ្យដុតកំដៅនោះដែរ ដែលគេថាចំពោះព្រះអង្គហើយ ។ ម្នាលសីហៈ មានហេតុដែលជនគួរឲ្យអ្នកផងនិយាយចំពោះតថាគតថា ព្រះសមណគោតមជាមនុស្សអស់កំណើត សំដែងធម៌ ដើម្បីមិនឲ្យមានកំណើត ទាំងទូន្មានសាវកទាំងឡាយដោយពាក្យមិនមានកំណើតនោះដែរ ដែលគេថាចំពោះព្រះអង្គហើយ ។ ម្នាលសីហៈ មានហេតុដែលជនគួរឲ្យអ្នកផងនិយាយចំពោះតថាគតថា ព្រះសមណគោតមជាអ្នកទំនុកបំរុង សំដែងធម៌ ដើម្បីទំនុកបំរុង ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ឲ្យទំនុកបំរុងនោះដែរ ដែលគេថាចំពោះព្រះអង្គហើយ ។ ម្នាលសីហៈ ចំណែកដែលគួរឲ្យអ្នកផងថា ចំពោះតថាគតថា ព្រះសមណគោតមជាអ្នកពោលពាក្យថា មិនធ្វើ សំដែងធម៌ដោយថាមិនធ្វើ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា មិនធ្វើនោះដែរ ដែលគេថាចំពោះព្រះអង្គហើយ តើដូចម្តេច ម្នាលសីហៈ ព្រោះតថាគតពោលថា មិនធ្វើនូវកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ទាំងពោលយ៉ាងថា មិនធ្វើនូវអកុសលធម៌ដ៏លាមកច្រើនប្រការ ម្នាលសីហៈ ចំណែកនេះឯងហើយ ដែលគួរឲ្យ

វទមានោ វទេយ្យ អកិរិយវាទោ សមណោ គោតមោ អកិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ កិរិយវាទោ សមណោ គោតមោ កិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អហញ្ហិ សីហ កិរិយំ វទាមិ កាយសុចរិតស្ស វចីសុចរិតស្ស មនោសុចរិតស្ស អនេកវិហិតានំ កុសលានំ ធម្មានំ កិរិយំ វទាមិ អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ កិរិយវាទោ សមណោ គោតមោ កិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ឧច្ឆេទវាទោ សមណោ គោតមោ ឧច្ឆេទាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អហញ្ហិ សីហ ឧច្ឆេទំ វទាមិ រាគស្ស ទោសស្ស មោហស្ស អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ ឧច្ឆេទំ



អ្នកដទៃថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកពោលនូវកិច្ចការថាមិនធ្វើ សំដែងធម៌ដោយថាមិនធ្វើ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថាមិនធ្វើនោះផង ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ ចំណែកដែលគួរឲ្យអ្នកដទៃថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកពោលថាធ្វើ សំដែងធម៌ថាធ្វើ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថាធ្វើនោះផង ដែលគេថានោះត្រូវហើយ តើដូចម្ដេច ។ ម្នាលសីហៈ ព្រោះតថាគតពោលថា ធ្វើចំពោះតែកាយសុចរិត វចីសុចរិត មនោសុចរិត ទាំងពោលថា ធ្វើចំពោះតែកុសលធម៌ដែលមានប្រយោជន៍ច្រើនប្រការ ម្នាលសីហៈ ចំណែកនេះឯងហើយ ដែលគួរឲ្យអ្នកដទៃថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកពោលថាធ្វើ សំដែងធម៌ថាធ្វើ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថាធ្វើនោះផង ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ ចំណែកដែលគួរឲ្យអ្នកដទៃថា ព្រះសមណគោតម ជាអ្នកពោលពាក្យកាត់ផ្ដាច់ផ្ដិល សំដែងធម៌ដើម្បីកាត់ផ្ដាច់ផ្ដិល ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថាត្រូវកាត់ផ្ដាច់ផ្ដិល ដែលគេថានោះត្រូវហើយ តើដូចម្ដេច ។ ម្នាលសីហៈ ព្រោះតថាគតពោលថា ត្រូវកាត់ផ្ដាច់ផ្ដិលរាគៈ ទោសៈ មោហៈ ទាំងពោលថាត្រូវកាត់ផ្ដាច់ផ្ដិលនូវ ចំពោះតែអកុសលធម៌អាក្រក់

វទាមិ អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ឧច្ឆេទវាទោ សមណោ គោតមោ ឧច្ឆេទាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ជេគុច្ឆី សមណោ គោតមោ ជេគុច្ឆិតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អហញ្ហិ សីហ ជិគុច្ឆាមិ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ជិគុច្ឆាមិ[១] អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ជេគុច្ឆី សមណោ គោតមោ ជេគុច្ឆិតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ វេនយិកោ សមណោ គោតមោ វិនយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អហញ្ហិ សីហ វិនយាយ ធម្មំ ទេសេមិ រាគស្ស

១ ម. ជេគុច្ឆិតាយ ធម្មំ ទេសេមិ ។



ប្រៀនប្រដៅ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគត ព្រោះសមណគោតម ជាអ្នកពោលពាក្យកាត់ផ្តាច់ផ្តិល សំដែងធម៌ដើម្បីកាត់ផ្តាច់ផ្តិល ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ត្រូវកាត់ផ្តាច់ផ្តិល ដែលគេថាដោយត្រូវហើយ ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថាចំពោះតថាគត ព្រោះសមណគោតម ជាអ្នកខ្ពើមរអើម សំដែងធម៌ដើម្បីការខ្ពើមរអើម ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ត្រូវខ្ពើមរអើមនោះដែរ ដែលគេថាដោយត្រូវហើយ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះតថាគតខ្ពើមចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត នឹងខ្ពើមចំពោះសេចក្តីប្រកបចិត្ត ផ្តួបផ្តិតទៅរកអកុសលធម៌ជាច្រើនប្រការ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគត ព្រោះសមណគោតម ជាអ្នកខ្ពើមរអើម សំដែងធម៌ដើម្បីការខ្ពើមរអើម ទាំងទូន្មានសាវកទាំងឡាយដោយការខ្ពើមរអើមនោះដែរ ដែលគេថាដោយត្រូវហើយ ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថាចំពោះតថាគត ព្រោះសមណគោតម ជាអ្នកបំផ្លាញ សំដែងធម៌ដើម្បីបំផ្លាញ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ត្រូវបំផ្លាញនោះដែរ ដែលគេថាដោយត្រូវហើយ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះតថាគតសំដែងធម៌ចំពោះផ្លូវប្រតិបត្តិដែលបំផ្លាញបង់នូវរាគៈ

ទោសស្ស មោហស្ស អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ វិនយាយ ធម្មំ ទេសេមិ អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ វេនយិកោ សមណោ គោតមោ វិនយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ តបស្សី សមណោ គោតមោ តបស្សិតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ តបនីយាហំ សីហ បាបកេ អកុសលេ ធម្មេ វទាមិ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ យស្ស ខោ សីហ តបនីយា បាបកា អកុសលា ធម្មា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទធម្មា តមហំ តបស្សីតិ វទាមិ តថាគតស្ស ខោ សីហ តបនីយា បាបកា អកុសលា ធម្មា បហីនា



ទោសៈ មោហៈ និងសំដែងធម៌ដើម្បីប្រែបង្ហាត់បង្ហាញបង់នូវអកុសល-ធម៌ដ៏លាមកច្រើនប្រការ ម្នាលសីហៈ នេះឯងហេតុ ដែលគួរឲ្យអ្នកផងនិយាយដោយហេតុនោះ ថា ព្រះសមណគោតម ជាអ្នកបង្ហាត់ សំដែងធម៌ដើម្បីបង្ហាត់ ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថាត្រូវបង្ហាត់នោះផង ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ ចំណែកដែលគួរឲ្យអ្នកផងនិយាយដោយហេតុនោះ ថា ព្រះសមណគោតម ជាអ្នកដុតកំដៅ សំដែងធម៌ដើម្បីដុតកំដៅ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថាត្រូវដុតកំដៅនោះផង ដែលគេថានោះត្រូវហើយ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះតថាគតពោលថា កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ជាទីតាំងនៃសេចក្តីក្តៅក្រហាយ ជាអកុសលធម៌ដ៏លាមក ម្នាលសីហៈ អកុសលធម៌ដ៏លាមកទាំងឡាយ ដែលជាទីតាំងនៃសេចក្តីក្តៅក្រហាយ (នោះ) បើអ្នកណាបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យស ព្រោះមិនកើតទៀតឡើយអស់លើនី ដូចជាដើមត្នោតដែលគេក្រឡាស់រំលើងឫសដុសកចោលទៀតហើយ បានធ្វើឲ្យលែងមានបែបភាពទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ តថា-គតហៅអ្នកនោះថា អ្នកដុតកំដៅ ម្នាលសីហៈ អកុសលធម៌ដ៏លាមកទាំងឡាយដែលជាទីតាំងនៃសេចក្តីក្តៅក្រហាយ (នោះ) តថាគតឯងបានលះ

ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទធម្មា អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ តបស្សី សមណោ គោតមោ តបស្សិតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អបគព្ភោ សមណោ គោតមោ អបគព្ភតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ យស្ស ខោ សីហ អាយតឹ គព្ភសេយ្យា បុនព្ភវាភិនិព្វត្តិ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទធម្មា តមហំ អបគព្ភោតិ វទាមិ តថាគតស្ស ខោ សីហ អាយតឹ



ស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើតែសព្រោប់កើតទៀតឡើយអស់ហើយ ដូចដើមត្នោតដែលគេកាប់បាល តាស់កាលលើឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម្មតាលែងមានកំណើតតទៅខាងមុខហើយ ម្នាលសីហៈ ចំនួននេះឯងហើយ ដែលគួរឲ្យអ្នកផងនិយាយចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកដុតកំដៅ សំដែងធម៌ដើម្បីដុតកំដៅ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យជាគ្រឿងដុតកំដៅនោះដែរ ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ ចំនួនដែលគួរឲ្យអ្នកផងនិយាយចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកផ្តត់កំណើត សំដែងធម៌ដើម្បីមិនឲ្យមានកំណើត ទាំងទូន្មានសាវកទាំងឡាយដោយពាក្យជាមិនឲ្យមានកំណើតនោះដែរ ដែលគេថានោះត្រូវហើយ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះកិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើតក្នុងភពតទៅខាងមុខទៀត របស់បុគ្គលណា បានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើតែសព្រោប់កើតទៀតឡើយអស់ហើយ ដូចដើមត្នោតដែលគេកាប់បាលតាស់កាលលើឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម្មតាលែងមានកំណើតតទៅខាងមុខទៀតហើយ តថាគតហៅអ្នកនោះថា អ្នកផ្តត់កំណើត ម្នាលសីហៈ កិរិយាដេកក្នុងគភ៌តទៅទៀតនិងដំណើរកើត

គព្ភសេយ្យា បុនព្ភវាភិនិព្វត្តិ បហីនា ឧច្ឆិន្នមូលា តាលា-
វត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទធម្មា អយំ
ខោ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមា-
នោ វទេយ្យ អបគព្ភោ សមណោ គោតមោ អបគព្ភតាយ
ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ កតមោ ច
សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមា-
នោ វទេយ្យ អស្សត្ថោ សមណោ គោតមោ អស្សា-
សាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។
អហញ្ហិ សីហ អស្សត្ថោ បរមេន អស្សាសេន អស្សា-
សាយ ច ធម្មំ ទេសេមិ តេន ច សាវកេ វិនេមិ
អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន



ក្នុងគភ៌តទៅខាងមុខទៀត តថាគតបានលះស្រឡះហើយ បានផ្ដាច់ផ្ដិល ឫសគល់អស់ហើយ បានធ្វើឲ្យស្រឡាប់កើតទៀតឲ្យអស់លើង ដូចដើមត្នោតដែលគេក្រឡែល គាស់រំលើងឡើងវិញផុត តទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាព តទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើត តទៅខាងមុខទៀតហើយ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងនិយាយចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកឥតកំណើត សំដែងធម៌ដើម្បីមិនឲ្យមានកំណើត ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យមិនឲ្យមានកំណើតនោះដែរ ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងនិយាយចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកទំនុកបំរុងចិត្ត សំដែងធម៌ដើម្បីទំនុកបំរុង ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យជាទំនុកបំរុងនោះដែរ ដែលគេថានោះត្រូវហើយ តើដូចម្ដេច ។ ម្នាលសីហៈ ព្រោះតថាគតជាអ្នកទំនុកបំរុងចិត្ត សំដែងធម៌ដើម្បីទំនុកបំរុង ដោយសេចក្ដីទំនុកបំរុងដ៏ឧត្ដម (១) ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យជាទំនុកបំរុងនោះដែរ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងនិយាយ

១ ក្នុងទីនេះថា ទំនុកបំរុងដើម្បីឲ្យបានសម្រេចមគ្គ ៤ និងផល ៤ ។

សម្មា វទមានោ វទេយ្យ អស្សត្ថោ សមណោ គោតមោ អស្សាសាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។

(១៦៨) ឯវំ វុត្តេ សីហោ សេនាបតិ ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

អនុវិច្ចការំ ខោ សីហ ករោហិ អនុវិច្ចការោ



ចំពោះតថាគតថា ព្រះសមណគោតមជាអ្នកទំនុកចិត្ត សំដែងធម៌ដើម្បីទំនុកចិត្ត ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថាឲ្យទំនុកចិត្តនោះផង ដែលគេថានោះត្រូវហើយ ។

[១៦៨] កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ សីហសេនាបតីក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះអង្គសំដែងហើយដោយអនេកបរិយាយយ៉ាងនេះ ប្រៀបដូចជាមនុស្សផ្ងាររបស់ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ពុំនោះដូចជាមនុស្ស បើកបង្ហាញរបស់ដែលគេលាក់បាំងទុក ពុំនោះសោតដូចជាមនុស្សអ្នកប្រាប់ផ្លូវដល់អ្នកវង្វេង ឬក៏ដូចជាមនុស្សកាន់ប្រទីបប្រេងទៅក្នុងទីងងឹតដោយគិតថា មនុស្សមានភ្នែកមើលឃើញនូវរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹង សូមព្រះដ៏មានព្រះភាគទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកដល់ហើយនូវព្រះរតនត្រ័យជាទីពឹងស្មើដោយជីវិត តាំងអំពីថ្ងៃនេះទៅ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសីហៈ អ្នកឯងចូរធ្វើនូវការពិចារណាមើលសិន ឯការពិចារណាមើល (នោះ)

តុម្ហាទិសានំ ញាតមនុស្សានំ សាធុ ហោតីតិ ។ ឥមិ-នាបាហំ ភន្តេ ភគវតោ ភិយ្យោសោមត្តាយ អត្តមនោ អភិរទ្ធោ យំ មំ ភគវា ឯវមាហ អនុវិច្ចការំ សីហ ករោហិ អនុវិច្ចការោ តុម្ហាទិសានំ ញាតម-នុស្សានំ សាធុ ហោតីតិ មំ(១) ហិ ភន្តេ អញ្ញតិត្ថិយា សា-វកំ លភិត្វា កេវលកប្បំ វេសាលឹ បដាកំ បរិហរេយ្យុំ សីហោ នោ អម្ហាកំ សេនាបតិ សាវកត្តំ ឧបគតោតិ អថ ច បន មំ ភគវា ឯវមាហ អនុវិច្ចការំ ខោ សីហ ករោហិ អនុវិច្ចការោ តុម្ហាទិសានំ ញាតមនុស្សានំ សាធុ ហោតីតិ ឯសាហំ ភន្តេ ទុតិយម្បិ ភគវន្តំ សរ-ណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។ ទីឃរត្តំ

---
១ ម. មមំ ។



ជាកិច្ចប្រពៃរបស់មនុស្សជាអ្នកដឹងទាំងឡាយ ដូចអ្នកឯង (នេះ) ។ សីហៈ-សេនាបតីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គត្រេកអររីករាយ ជាច្រើនលើសជាងប្រមាណ តាមព្រះពុទ្ធដីការបស់ព្រះមានព្រះភាគនេះ ដ្បិតព្រះមានព្រះភាគទ្រង់ត្រាស់នឹងខ្ញុំព្រះអង្គថា ម្នាលសីហៈ ចូរអ្នកឯងធ្វើនូវការគិតជញ្ជឹងមើលសិន ឯការគិតជញ្ជឹងមើល (នោះ) ជាកិច្ចប្រពៃរបស់មនុស្សជាអ្នកដឹងទាំងឡាយ ដូចអ្នកឯង (នេះ) បពិត្រព្រះអង្គដ៏ចំរើន តិរ្ថិយដទៃទាំងឡាយ បាននូវខ្ញុំព្រះអង្គជាសាវក មុខជាគេនាំគ្នាលើកទង់ដើរជុំវិញក្រុងវេសាលីទាំងអស់ រួច (គេប្រកាសសេចក្តី) ថា យើងទាំងឡាយបានសីហសេនាបតីមកជាសាវកហើយ តែក្នុងកាលឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលសីហៈ ចូរអ្នកឯងធ្វើនូវការគិតជញ្ជឹងមើលសិន ឯការគិតជញ្ជឹងមើល (នោះ) ជាកិច្ចប្រពៃរបស់មនុស្សជាអ្នកដឹងទាំងឡាយ ដូចអ្នកឯង (នេះ) បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹង ជាគំរប់ពីរដង សូមព្រះដ៏មានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសកដល់ព្រះរតនត្រ័យ ជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃនេះទៅ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសីហៈ

ខោ តេ សីហ និគណ្ឋានំ ឱបានភូតំ កុលំ យេន នេសំ ឧបគតានំ បិណ្ឌកំ(១) ទាតព្វំ មញ្ញេយ្យាសីតិ ។ ឥមិនាបាហំ ភន្តេ ភគវតោ ភិយ្យោសោមត្តាយ អត្តមនោ អភិរទ្ធោ យំ មំ ភគវា ឯវមាហ ទីឃរត្តំ ខោ តេ សីហ និគណ្ឋានំ ឱបានភូតំ កុលំ យេន នេសំ ឧបគតានំ បិណ្ឌកំ ទាតព្វំ មញ្ញេយ្យាសីតិ សុតម្មេតំ ភន្តេ សមណោ គោតមោ ឯវមាហ មយ្ហមេវ ទានំ ទាតព្វំ ន អញ្ញេសំ ទានំ ទាតព្វំ មយ្ហមេវ សាវកានំ ទានំ ទាតព្វំ ន អញ្ញេសំ សាវកានំ ទានំ ទាតព្វំ មយ្ហមេវ ទិន្នំ មហប្ផលំ ន អញ្ញេសំ ទិន្នំ មហប្ផលំ មយ្ហមេវ សាវកានំ ទិន្នំ មហប្ផលំ ន អញ្ញេសំ សាវកានំ ទិន្នំ មហប្ផលន្តិ អថ ច បន មំ ភគវា និគណ្ឋេសុបិ ទានេ សមាទបេតិ អបិច ភន្តេ មយមេត្ថ កាលំ

១ ម. បិណ្ឌកំ ។



ត្រកូលរបស់អ្នកជាអណ្តូងទឹកបម្រើពួកនិគណ្ឋ ជាយូរណាស់មកហើយ អ្នកសំគាល់ថាបុគ្គលណា គឺគួរឲ្យបិណ្ឌបាតដល់ក្មួយដែលចូលមកនោះ ។ សីហសេនាបតីក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គត្រេកអររីករាយជាច្រើនលើសប្រមាណ ដោយព្រះដីការបស់ព្រះមានព្រះភាគនេះ ព្រោះព្រះមានព្រះភាគទ្រង់ត្រាស់នឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលសីហៈ ត្រកូលរបស់អ្នកជាអណ្តូងទឹកបម្រើពួកនិគណ្ឋ ជាយូរណាស់មកហើយ អ្នកសំគាល់ថាបុគ្គលណា គឺគួរឲ្យបិណ្ឌបាតដល់និគណ្ឋដែលចូលមកនោះវិញ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះខ្ញុំព្រះអង្គស្តាប់បានហើយ ថាព្រះសមណគោតមទ្រង់ត្រាស់នឹងខ្ញុំយ៉ាងនេះថា អ្នកត្រូវឲ្យទានដល់តថាគតតែម្យ៉ាង មិនត្រូវឲ្យទានដល់ពួកនិគណ្ឋដទៃទេ អ្នកត្រូវឲ្យទានដល់សាវករបស់តថាគតតែម្យ៉ាង មិនត្រូវឲ្យទានដល់ពួកសាវករបស់ពួកនិគណ្ឋដទៃទេ ទានដែលអ្នកឲ្យហើយដល់តថាគត ជាទានមានផលច្រើន ទានដែលអ្នកឲ្យហើយដល់ពួកនិគណ្ឋដទៃ ជាទានមិនមានផលច្រើនទេ ទានដែលអ្នកឲ្យហើយដល់ពួកសាវករបស់តថាគត ជាទានមានផលច្រើន ទានដែលអ្នកឲ្យហើយដល់ពួកសាវករបស់និគណ្ឋដទៃ ជាទានមិនមានផលច្រើនទេ ក៏ក្នុងកាលឥឡូវនេះ ព្រះមានព្រះភាគបបួលខ្ញុំព្រះអង្គឲ្យធ្វើទានដល់ពួកនិគណ្ឋ (វិញ) បពិត្រព្រះអង្គដ៏ចំរើន ប៉ុន្តែខ្ញុំព្រះអង្គដឹងកាល

ជានិស្សាម ឯសាហំ ភន្តេ ទុតិយម្បិ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។ អថខោ ភគវា សីហស្ស សេនាបតិស្ស អនុបុព្វីកថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា ភគវា អញ្ញាសិ សីហំ សេនាបតឹ កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ ឧទគ្គចិត្តំ បសន្នចិត្តំ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ សីហស្ស សេនាបតិស្ស តស្មិំយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំកិញ្ចិ សមុទយធម្មំ សព្វំ តំ និរោធធម្មន្តិ ។ អថខោ សីហោ





ដឹងសម្ពុកនិការឡើយនេះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹង ជាគំរប់ពីរដង សូមព្រះដ៏មានព្រះភាគទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់ព្រះរតនត្រ័យជាទីពឹងស្មើដោយជីវិត តាំងអំពីថ្ងៃនេះទៅ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់សំដែងអនុបុព្វីកថាដល់សីហសេនាបតី គឺសំដែងនូវទានកថា សីលកថា សគ្គកថា ទោសរបស់កាមទាំងឡាយដ៏លាមកសៅហ្មង និងអានិសង្សក្នុងការចេញបួស ។ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា សីហសេនាបតីមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តរីករាយ មានចិត្តជ្រះថ្លា ក្នុងកាលណាហើយ ក្នុងកាលនោះ ព្រះអង្គក៏សំដែងនូវធម្មទេសនាដែលព្រះពុទ្ធទាំងឡាយតែងលើកឡើងសំដែងដោយព្រះអង្គឯង គឺ (សំដែង) ទុក្ខ សមុទយ និរោធ មគ្គ ។ ឧបមាសំពត់ស្អាតមិនដែលប្រឡាក់ដោយវត្ថុមានពណ៌ខ្មៅ គួរទទួលទឹកជ្រលក់ដោយល្អប្រពៃ យ៉ាងណាមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់សីហសេនាបតីក្នុងទីអង្គុយនោះឯងថា ធម្មជាតណាមួយមានសេចក្ដីកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះតែងរលត់ទៅវិញជាធម្មតា ក៏មានឧបមេយ្យដូច្នោះឯង ។ គ្រានោះ

សេនាបតិ ទិដ្ឋធម្មោ បត្តធម្មោ វិទិតធម្មោ បរិយោគាឡ្ហ-ធម្មោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុ សាសនេ ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធិំ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ សីហោ សេនាបតិ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ សីហោ សេនាបតិ អញ្ញតរំ បុរិសំ អា-ណាបេសិ គច្ឆ ភណេ បវត្តមំសំ ជានាហីតិ ។ អថខោ សីហោ សេនាបតិ តស្សា រត្តិយា អច្ចយេន បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន សីហស្ស សេនាបតិស្ស និវេសនំ តេនុបសង្កមិ ឧប-សង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធិំ ភិក្ខុសង្ឃេន ។ តេន ខោ បន សមយេន សម្ពហុលា និគណ្ឋា





សីហសេនាបតិបានឃើញធម៌ហើយ បានដល់ធម៌ហើយ បានត្រាស់ដឹងធម៌ហើយ ឈមចុះកាន់ធម៌ស៊ប់ហើយ ឆ្លងផុតសេចក្តីសង្ស័យហើយ កាត់បង់នូវសេចក្តីងឿងឆ្ងល់ ជាអ្នកដល់នូវសេចក្តីក្លាហាន ដែលជឿស្តាប់អ្នកដទៃ ក្នុងសាសនារបស់ព្រះសាស្តា ទើបក្រាបទូលព្រះដ៏-មានព្រះភាគដោយពាក្យថ្វាយបង្គំថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគព្រមទាំងភិក្ខុសង្ឃទទួលភត្តរបស់ខ្ញុំព្រះអង្គដើម្បីស្អែកនេះ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ គ្រានោះ សីហ-សេនាបតីដឹងថាព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្តហើយក៏ក្រោកចាកទីអង្គុយថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចេញទៅ ។ ទើបសីហសេនាបតីបង្គាប់បុរសម្នាក់ថា នែនាយ អ្នកឯងចូរទៅរកសាច់សត្វស្លាប់ស្រាប់មក ។ លុះកន្លងរាត្រីយប់នោះហើយ ទើបសីហ-សេនាបតីតាក់តែងខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពិសា ហើយចាត់បម្រើឲ្យទៅក្រាបទូលនូវភត្តកាលដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន (កាលនេះ) ជាកាលសមគួរហើយ ភត្តក៏សម្រេចហើយ ។ គ្រានោះក្នុងបុព្វណ្ហសម័យ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ហើយទ្រង់បាត្រចីវរយាងទៅកាន់ផ្ទះសីហសេនាបតី លុះចូលទៅដល់ហើយក៏គង់លើអាសនៈដែលគេក្រាលបម្រុងទុកព្រមទាំងភិក្ខុសង្ឃ ។ សម័យនោះឯង និគណ្ឋទាំងឡាយ

វេសាលិយំ រថិយាយ រថិយំ សិង្ឃាដកេន សិង្ឃាដកំ ពាហា បគ្គយ្ហ កន្ទន្តិ អជ្ជ សីហេន សេនាបតិនា ថូលំ បសុំ វធិត្វា សមណស្ស គោតមស្ស ភត្តំ កតំ តំ សមណោ គោតមោ ជានំ ឧទ្ទិស្ស កតំ មំសំ បរិភុញ្ជតិ បដិច្ចកម្មន្តិ ។ អថខោ អញ្ញតរោ បុរិសោ យេន សីហោ សេនាបតិ តេនុបសង្កមិ ឧបសង្កមិត្វា សីហស្ស សេនាបតិស្ស ឧបកណ្ណកេ អារោចេសិ យគ្ឃេ ភន្តេ ជានេយ្យាសិ ឯតេ សម្ពហុលា និគណ្ឋា វេសាលិយំ រថិយាយ រថិយំ សិង្ឃាដកេន សិង្ឃាដកំ ពាហា បគ្គយ្ហ កន្ទន្តិ អជ្ជ សីហេន សេនាបតិនា ថូលំ បសុំ វធិត្វា សមណស្ស គោតមស្ស ភត្តំ កតំ តំ សមណោ គោតមោ ជានំ ឧទ្ទិស្ស កតំ មំសំ បរិភុញ្ជតិ បដិច្ចកម្មន្តិ ។ អលំ អយ្យ(១) ទីឃរត្តម្បិ តេ អាយស្មន្តា អវណ្ណកាមា ពុទ្ធស្ស អវណ្ណកាមា ធម្មស្ស អវណ្ណកាមា សង្ឃស្ស ន ច បន តេ អាយស្មន្តា ជីរន្តិ(២) តំ ភគវន្តំ អសតា តុច្ឆា មុសា អភូតេន អព្ភាចិក្ខន្តា ន ច មយំ ជីវិតហេតុបិ សញ្ចិច្ច បាណំ ជីវិតា វោរោបេយ្យាមាតិ ។

១ ម. អយ្យោ ។ ២ ម. ជិរន្តិ ។



ច្រើន (ទាំងនោះ) ស្រែកប្រែក ទៅគ្រប់ផ្លូវក្រៀបនីកនិងក្រុងវេសាលី ហើយផ្លូវបែកទីកន្លែងកន្ទ្រញថា ថ្ងៃនេះសីហសេនាបតីសម្លាប់សត្វចិញ្ចឹមធំធាត់ ។ ធ្វើភត្តប្រគេនសមណគោតម សមណគោតមដឹងថា សាច់គេធ្វើចំពោះខ្លួន ក៏នៅតែឆាន់សាច់នោះដែរ ។ គ្រានោះ មានបុរសម្នាក់ ចូលទៅរកសីហសេនាបតី លុះចូលទៅដល់ហើយនិយាយខ្សិបជិតត្រចៀកសីហសេនាបតីថា បពិត្រលោកដ៏ចំរើន សូមលោកជ្រាបចុះ ពួកនិគ្រន្ថទាំងអម្បាលនេះជាច្រើន (ទាំងនោះ) ស្រែកប្រែក ទៅគ្រប់ផ្លូវក្រៀបនីកនិងក្រុងវេសាលី ហើយផ្លូវបែកទីកន្លែងកន្ទ្រញថា ថ្ងៃនេះសីហសេនាបតីសម្លាប់សត្វចិញ្ចឹមធំធាត់ ។ ធ្វើភត្តប្រគេនសមណគោតម សមណគោតមដឹងថា សាច់គេធ្វើចំពោះខ្លួនហើយ ក៏នៅតែឆាន់សាច់នោះដែរ ។ សីហសេនាបតីនិយាយថា ម្នាលអ្នក ចូរកុំនិយាយឡើយ លោកដ៏មានអាយុទាំងអម្បាលនោះប្រាថ្នានូវពោលទោសព្រះពុទ្ធ ប្រាថ្នានូវពោលទោសព្រះធម៌ ប្រាថ្នានូវពោលទោសព្រះសង្ឃ អស់កាលជាយូរមកហើយ លោកដ៏មានអាយុទាំងអម្បាលនោះ ពោលបង្កាច់ព្រះដ៏មានព្រះភាគនោះដោយរបស់ដែលមិនមាន ដោយពាក្យទទេ ដោយពាក្យមុសាក៏ទ ដោយពាក្យមិនពិត មិនអស់មិនហើយឡើយ ទាំងការពិត (នោះ) យើងមិនក្លែងផ្តាច់បង់ជីវិតសត្វ ព្រោះហេតុជីវិត (របស់ខ្លួន) ទេ ។

អថខោ សីហោ សេនាបតិ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ សីហំ សេនាបតឹ ភគវា ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ ជានំ ឧទ្ទិស្ស កតំ មំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ តិកោដិបរិសុទ្ធំ មច្ឆមំសំ អទិដ្ឋំ អស្សុតំ អបរិសង្កិតន្តិ ។

(១៦៤) តេន ខោ បន សមយេន វេសាលី សុភិក្ខា ហោតិ សុសស្សា សុលភបិណ្ឌា សុករា ឧញ្ឆេន បគ្គហេន យាបេតុំ ។ អថខោ ភគវតោ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យានិ តានិ មយា ភិក្ខូនំ អនុញ្ញាតានិ ទុព្ភិក្ខេ ទុស្សស្សេ



គ្រានោះ សីហសេនាបតីអង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ដោយខាទនីយភោជនីយដ៏ផ្ចិតផ្ចង់ គ្រាន់តែព្រះដ៏មានព្រះភាគទ្រង់សោយចប់ចំពុល សោយរួចស្រេច ដាក់ព្រះហស្តចាកព្រះបាត្រ ទើបអង្គុយនៅទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់សីហសេនាបតីដែលអង្គុយក្នុងទីដ៏សមគួរ ឲ្យយល់ព្រម ឲ្យកាន់យកព្រម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈយាងចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះ ភាគទ្រង់ធ្វើធម្មីកថាហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកហើយទ្រង់ (បញ្ញត្ត) ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបើដឹងថា សាច់គេធ្វើចំពោះ(ខ្លួន) កុំគប្បីបរិភោគ ភិក្ខុណាបរិភោគ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតត្រីនិងសាច់ដែលបរិសុទ្ធដោយចំណុច ៣ យ៉ាង គឺមិនបានឃើញ មិនបានឮ មិនបានរង្កៀស ។

[១៦៤] សម័យនោះឯង ក្រុងវេសាលីមានភិក្ខាងាយបរិបូណ៌ មានសន្ទូងល្អ មានបិណ្ឌបាតបានស្រួល ងាយនឹងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានដោយការស្វែងរកនិងការព្យាយាម ។ គ្រានោះ ព្រះមានព្រះភាគទ្រង់យាងទៅកាន់ទីស្ងាត់ សម្ងំនៅក្នុងព្រះឈាន ទើបទ្រង់ត្រិះរិះដោយព្រះទ័យយ៉ាងនេះថា ខាទនីយភោជនីយៈទាំងឡាយណាដែលតថាគតបានអនុញ្ញាតហើយដល់ភិក្ខុទាំងឡាយក្នុងកាលដែលស្រុកមានអំណត់

ទុល្លភប័ណ្ណោ អច្ឆោវត្ថំ អច្ឆោបត្តំ សាមំបត្តំ ឧក្កុដិក-
ប្បដិក្ខិត្តំ គតោ ចីវរំ ឧបក្កន្តំ បដិក្ខិត្តំ វេជ្ជំ
មោទក្ខាវេជ្ជំ អដ្ឋាចិ ទុ មោ តាចំ ភិក្ខុ បរិក្ខុញ្ញត្តិ ។
អជមោ កតកំ ហោយព្ភសមយំ បដិសល្លានា វុដ្ឋិតោ
កាយសុន្ទំ អាចខ្ទំ អាមន្តេសំ យាចិ តាចំ អានន្ទ មយោ
ភិក្ខូនំ អនុញ្ញាតាចំ ទុត្តិច្ចោ ទុស្សស្សេ ទុល្លភប័ណ្ណោ
អច្ឆោវត្ថំ អច្ឆោបត្តំ សាមំបត្តំ ឧក្កុដិកប្បដិក្ខិត្តំ
គតោ ចីវរំ ឧបក្កន្តំ បដិក្ខិត្តំ វេជ្ជំ មោទក្ខាវេជ្ជំ
អដ្ឋាបំ ទុ មោ តាចំ ភិក្ខុ បរិក្ខុញ្ញត្តិ ។ បរិក្ខុញ្ញត្តិ
កតកំតិ ។ អជមោ កតកំ ឯកស្មឹ ចំណោ ឯកស្មឹ
បតការណោ ជម្មឹ តាចំ កាត្វា ភិក្ខុ អាមន្តេសិ





មានសន្ធិមិនល្អ មានប័ណ្ណផុតផុងដោយលំបាក ពិតាទទីយកោជនីយៈ
ដែលទុកដាក់តាន់កន្ទី (អកប្បិយកុដិ) ចំអិនតាន់កន្ទី (អកប្បិយកុដិ)
ភិក្ខុចំអិនដោយខ្លួនឯង ភិក្ខុទទួលរបស់ជានុគ្គហិត ដែលគេនាំមកអំពី
ទីនោះ ដែលភិក្ខុទទួលប្រគេនក្នុងវេលាមុនភត្ត វត្ថុនៅក្នុងព្រៃ វត្ថុ
នៅក្នុងស្រះ ក៏ក្នុងទីនេះ ភិក្ខុទាំងឡាយនៅបរិភោគក្តុតាំងនោះឬ ។
លំដាប់នោះ ព្រះដ៏មានព្រះភាគចេញអំពីការសម្ងំនៅក្នុងព្រៃកម្ពុជាភក្កនីវេ-
លាសៀលហើយទ្រង់ត្រាស់ហៅព្រះអានន្ទថាមានអាយុមក ទ្រង់(សួរ)
ថា ម្នាលអានន្ទ ខាទនីយភោជនីយៈទាំងឡាយណាដែលកថាតគបាន
អនុញ្ញាតហើយដល់ភិក្ខុទាំងឡាយ ក្នុងកាលមានអំណត់ មានសន្ធិមិន
ល្អ មានប័ណ្ណផុតផុងដោយលំបាក ពិតាទទីយកោជនីយៈដែលទុកដាក់
តាន់កន្ទី ដីចំអិនតាន់កន្ទី (អកប្បិយកុដិ) ភិក្ខុចំអិនដោយខ្លួនឯង ភិក្ខុទទួល
របស់ជានុគ្គហិត ដែលគេនាំមកអំពីទីនោះ ដែលភិក្ខុទទួលប្រគេនក្នុងវេលា
មុនភត្ត វត្ថុនៅក្នុងព្រៃ វត្ថុនៅក្នុងស្រះ ក៏ក្នុងទីនេះនៅតែភិក្ខុទាំង-
ឡាយនៅបរិភោគក្តុតាំងនោះឬ ។ ព្រះអានន្ទក្រាបបង្គំទូលថា
បពិត្រព្រះដ៏មានព្រះភាគ ភិក្ខុទាំងឡាយនៅបរិភោគនៅឡើយ ។
គ្រានោះឯង ដល់ពេលល្ងាច ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា
ត្រាស់ហៅភិក្ខុទាំងឡាយមកហើយទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ

យានិ តានិ ភិក្ខវេ មយា ភិក្ខូនំ អនុញ្ញាតានិ ទុព្ភិក្ខេ ទុស្សស្សេ ទុល្លភបិណ្ឌេ អន្តោវុត្ថំ អន្តោបក្កំ សាមំបក្កំ ឧគ្គហិតប្បដិគ្គហិតកំ តតោ នីហដំ បុរេភត្តំ បដិគ្គហិតំ វនដ្ឋំ បោក្ខរដ្ឋំ តានាហំ អជ្ជតគ្គេ បដិក្ខិបាមិ ។ ន ភិក្ខវេ អន្តោវុត្ថំ អន្តោបក្កំ សាមំបក្កំ ឧគ្គហិតប្បដិគ្គហិតកំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស ។ ន ច ភិក្ខវេ តតោ នីហដំ បុរេភត្តំ បដិគ្គហិតំ វនដ្ឋំ បោក្ខរដ្ឋំ ភុត្តាវិនា បវារិតេន អនតិរិត្តំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ យថាធម្មោ ការេតព្វោ ។

(១៣១) តេន ខោ បន សមយេន ជានបទា មនុស្សា ពហុំ លោណំបិ តេលំបិ តណ្ឌុលំបិ ខាទនីយំបិ សកដេសុ អារោបេត្វា ពហារាមកោដ្ឋកេ



ខាទនីយភោជនីយៈ ទាំងឡាយណា ដែលតថាគតអនុញ្ញាតហើយដល់ភិក្ខុទាំងឡាយក្នុងកាលមានអំណត់ មានសស្សមិនល្អ មានបិណ្ឌបាតបានដោយលំបាក, គឺខាទនីយភោជនីយៈដែលទុកដាក់ខាងក្នុង ចំអិនខាងក្នុង (អកប្បិយកុដិ) ភិក្ខុចំអិនខ្លួនឯង ភិក្ខុទទួលរបស់ជាឧគ្គហិត ដែលគេនាំមកអំពីទីនោះ ដែលភិក្ខុទទួលប្រគេនក្នុងវេលាមុនភត្ត ផ្លែឈើក្នុងព្រៃ ផ្លែឈើក្នុងស្រះ សព្វថ្ងៃនេះ តថាគតហាមខាទនីយភោជនីយៈទាំងនោះ តាំងពីថ្ងៃនេះទៅ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបរិភោគខាទនីយភោជនីយៈជាអន្តោវុត្ថ ( ទុកដាក់ខាងក្នុងអកប្បិយកុដិ ) អន្តោបក្ក ( ចំអិនខាងក្នុងអកប្បិយកុដិ ) សាមំបក្ក (ភិក្ខុឲ្យចំអិនខ្លួនឯង) ឧគ្គហិតប្បដិគ្គហិត (ការទាំមុនហើយទើបឲ្យគេប្រគេន ) បើភិក្ខុណាបរិភោគ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុឆាន់រួចហើយ ហាមភត្តហើយ ភិក្ខុមិនត្រូវឆាន់អនតិរិត្តភោជន (ភោជនលើស) គឺខាទនីយភោជនីយៈដែលគេយកនាំមកអំពីទីនោះ ភិក្ខុទទួលក្នុងវេលាមុនភត្ត ផ្លែដែលកើតនៅក្នុងព្រៃ ផ្លែដែលកើតនៅក្នុងស្រះ បើភិក្ខុណាបរិភោគ វិនយធរត្រូវកាត់សេចក្តីតាមអាបត្តិ ។

(១៣១) សម័យនោះឯង ពួកមនុស្សអ្នកជនបទផ្ទុកអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយាហារខ្លះ ក្នុងរទេះទាំងឡាយ ហើយ

សកដបរិវដ្ដំ ករិត្វា អច្ឆន្តិ យទា បដិបាដិំ លភិស្សាម តទា ភត្តំ ករិស្សាមាតិ ។ មហា ច មេឃោ ឧគ្គតោ ហោតិ ។ អថខោ តេ មនុស្សា យេនាយស្មា អានន្ទោ តេនុបសង្កមិំសុ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតទវោចុំ ឥធ ភន្តេ អានន្ទ អម្ហាកំ លោណម្បិ តេលម្បិ តណ្ឌុលម្បិ ខាទនីយម្បិ សកដេសុ និក្ខិត្តា តិដ្ឋន្តិ មហា ច មេឃោ ឧគ្គតោ កថំ នុ ខោ ភន្តេ អានន្ទ បដិបជ្ជិតព្វន្តិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ តេនហានន្ទ សង្ឃោ បច្ចន្តិមំ វិហារំ កប្បិយភូមិំ សម្មន្និត្វា តត្ថ វាសេតុ យំ សង្ឃោ អាកង្ខតិ វិហារំ វា អឌ្ឍយោគំ វា បាសាទំ វា ហម្មិយំ វា គុហំ វា ។ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ វិហារំ



បរិក្ខារនេះមកឈប់នៅក្បែរក្លោងទ្វារទាំងក្រៅផ្ទះហើយបង់ថា យើងទាំងឡាយនឹងបានទទួលដាប់(ទឹកដោះ)គ្រប់កាលណា យើងនឹងធ្វើភត្តប្រាយសង្ឃ)គ្រប់កាលនោះ ។ (ក្នុងពេលនោះ) មហាមេឃក៏ឡើង ។ គ្រានោះ ពួកមនុស្សទាំងឡាយនោះចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ទើបទូលព្រះអានន្ទដ៏មានអាយុដោយពាក្យដូច្នេះថា បពិត្រព្រះអានន្ទដ៏ចំរើន មនុស្សអ្នកនៅគ្រប់ផ្ទះយើងខ្ញុំ អំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយាហារខ្លះ ដែលដាក់ក្នុងរទេះទាំងឡាយ ហើយមកឈប់នៅក្បែរក្លោងទ្វារនេះ ក្នុងពេលនោះមហាមេឃក៏ឡើង បពិត្រព្រះអានន្ទដ៏ចំរើន មនុស្សអ្នកនៅគ្រប់ផ្ទះទាំងនោះ គួរប្រតិបត្តិដូចម្ដេចទៅ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ បើសង្ឃប្រាថ្នានៅទីណា គឺវិហារក្ដី អឌ្ឍយោគក្ដី ប្រាសាទក្ដី ប្រាសាទក្រឡិលក្ដី គូហាក្ដីដែលនៅជុំវិញក្រោយគេ សង្ឃត្រូវសន្មត(នូវទីនោះ) ឲ្យជាកប្បិយភូមិ ហើយឲ្យអ្នកផងទាំងនោះនៅក្នុងទីនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ គឺភិក្ខុឈ្លាសប្រតិពលគប្បីប្រកាសឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ខ្ញុំ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតវិហារឈ្មោះនេះឲ្យជា

កប្បិយកុដឹ សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ វិហារំ កប្បិយកុដឹ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស វិហារស្ស កប្បិយកុដិយា សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ វិហារោ កប្បិយកុដិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ តេន ខោ បន សមយេន មនុស្សា តត្ថ សម្មុតិកាយ[1] កប្បិយកុដិយា យាគុយោ បចន្តិ ភត្តានិ បចន្តិ សូបានិ សម្បាទេន្តិ មំសានិ កោដ្ដេន្តិ កដ្ឋានិ ផាលេន្តិ ។ អស្សោសិ ខោ ភគវា រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ ឧច្ចាសទ្ទំ មហាសទ្ទំ កាកោរវសទ្ទំ សុត្វាន អាយស្មន្តំ អានន្ទំ អាមន្តេសិ កិន្នុ ខោ សោ អានន្ទ ឧច្ចាសទ្ទោ មហាសទ្ទោ កាកោរវសទ្ទោតិ ។ ឯតរហិ ភន្តេ មនុស្សា តត្ថ សម្មុតិកាយ កប្បិយកុដិយា យាគុយោ បចន្តិ ភត្តានិ បចន្តិ សូបានិ សម្បាទេន្តិ

១ [illegible] ។



កប្បិយកុដិ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតវិហារឈ្មោះនេះឲ្យជាកប្បិយកុដិ ។ ការសន្មតវិហារឈ្មោះនេះឲ្យជាកប្បិយកុដិ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម បើមិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីនិយាយឡើង ។ សង្ឃបានសន្មតវិហារឈ្មោះនេះឲ្យជាកប្បិយកុដិហើយ ។ ការសន្មតនេះសមគួរដល់សង្ឃ ហេតុនោះបានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវដំណើរនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។ សម័យនោះឯង មនុស្សទាំងឡាយដាំបបរដាំបាយស្លសម្លចំអិនសាច់ពុះអុស ធ្វើសំឡេងគឹកកងក្នុងកប្បិយកុដិ ដែលសង្ឃសន្មតឲ្យនោះឯង ។ ព្រះដ៏មានព្រះភាគទ្រង់តើនឡើងក្នុងវេលាបច្ចូសសម័យនៃរាត្រី បានឮសំឡេងគឹកកងខ្លាំង ខ្ញៀវក្អែក[1] លុះឮហើយ ទើបទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកសួរថា ម្នាលអានន្ទ សំឡេងគឹកកងខ្លាំង ខ្ញៀវក្អែក នោះតើជាសំឡេងអ្វី ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងវេលានេះ មនុស្សទាំងឡាយដាំបបរដាំបាយស្ល

១ សំឡេងដូចក្អែកស្រែក ។

មំសំ បចន្តិ កដ្ឋានិ ផាលេន្តិ សោ អហោសិ

ឧច្ចាសទ្ទោ មហាសទ្ទោ កាកោរកសទ្ទោតិ ។ អថខោ

ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ

កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ សម្មុតិកា[១] កប្បិ-

យភូមិ បរិភុញ្ជិតព្វា យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស ។

អនុជានាមិ ភិក្ខវេ តិស្សោ កប្បិយភូមិយោ ឧស្សាវ-

នន្តិកំ គោនិសាទិកំ គហបតិកន្តិ[២] ។ តេន ខោ បន

សមយេន អាយស្មា យសោជោ គិលានោ ហោតិ ។

តស្សត្ថាយ ភេសជ្ជានិ អាហរិយន្តិ ។ តានិ ភិក្ខូ

ពហិ វាសេន្តិ ។ ឧក្កាបិណ្ឌកាបិ ខាទន្តិ ចោរាបិ

ហរន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ

១ ឱ. សម្មុតិ ។ ២ ឱ. គហបតិន្តិ ។



សម្ល ស្ងោរសាច់ ពុះអុសក្នុងកប្បិយភូមិ ដែលសង្ឃសន្មតនោះឯង ហាក់ក្រ ព្រះដ៏មានព្រះភាគ សំឡេងក៏កងខ្ទរខ្ទារ នោះជាសំឡេងខ្ពស់ឯង ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុមិនគួរប្រើប្រាស់នូវកប្បិយភូមិ ដែលសង្ឃសន្មតទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវកប្បិយភូមិបីយ៉ាង គឺឧស្សាវនន្តិកា[១] ១ គោនិសាទិកា[២] ១ គហបតិ-កា[៣] ១ ។ សម័យនោះឯង យសោជភិក្ខុដ៏មានអាយុមានជម្ងឺ ។ មនុស្សទាំងឡាយនាំភេសជ្ជៈដើម្បីប្រយោជន៍ដល់លោកមក ។ ភិក្ខុទាំងឡាយទុកដាក់ភេសជ្ជៈទាំងនោះខាងក្រៅ (លំនៅ) ។ សត្វតូចៗ (មានកណ្ដុរ) ស៊ីខ្លះ ចោរខ្លះ លួចយកទៅខ្លះ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា

១ អដ្ឋកថា កប្បិយកុដិដែលសង្ឃសូត្រប្រកាសថា កប្បិយកុដិ កបាម យើងទាំងឡាយធ្វើកប្បិយកុដិដូច្នេះជាដើម ហើយកសាងឡើង ឈ្មោះថា ឧស្សាវនន្តិកា ។ ២ វត្តមុខ ឬទាល់ឬ ដែលជាសំព្រឹត្រៀតថេរៈនោះ នូវជាកប្បិយកុដិបាន ឈ្មោះថា គោនិសាទិកា ១ មានពីរយ៉ាងគឺ សេនាសនៈដែលគ្មានរបង ឬជញ្ជាំង ឈ្មោះថា អារាមគោនិសាទិកា ១ សេនាសនៈទាំងអស់ដែលមានរបង ឬជញ្ជាំងខ្លះក្តី មិនមានខ្លះក្តី ឈ្មោះថា វិហារគោនិសាទិកា ១ ។ ៣ មនុស្សទាំងឡាយកសាងអាវាសហើយពោលនិមន្តថា សូមលោកម្ចាស់ទាំងឡាយ ប្រើប្រាស់នូវ (កប្បិយកុដិ) នេះចុះ កប្បិយកុដិនេះឈ្មោះថា គហបតិកា ។

ភិក្ខវេ សម្មុតិំ(១) កប្បិយភូមឹ បរិភុញ្ជិតុំ ។ អនុជានាមិ ភិក្ខវេ ចតស្សោ កប្បិយភូមិយោ ឧស្សាវនន្តិកំ គោនិសាទិកំ គហបតិំ សម្មុតិកន្តិ ។

(១៣១) តេន ខោ បន សមយេន ភទ្ទិយេ នគរេ(២) មេណ្ឌកោ គហបតិ បដិវសតិ ។ តស្ស ឯវរូបោ ឥទ្ធានុភាវោ ហោតិ សីសំ នហាយិត្វា ធញ្ញាគារំ សម្មជ្ជាបេត្វា ពហិទ្វារេ និសីទតិ ។ អន្តលិក្ខា ធញ្ញស្ស ធារា ឱបតិត្វា ធញ្ញាគារំ បូរេតិ ។ ភរិយាយ ឯវរូបោ ឥទ្ធានុភាវោ ហោតិ ឯកំយេវ អាឡ្ហកថាលិកំ ឧបនិសីទិត្វា ឯកញ្ច សូបភិញ្ជនកំ(៣) ទាសកម្មករបោរិសំ ភត្តេន បរិវិសតិ ។ ន តាវ ខីយតិ យាវ សា ន វុដ្ឋាតិ ។ បុត្តស្ស ឯវរូបោ ឥទ្ធានុភាវោ ហោតិ ឯកំយេវ សហស្សត្ថវិកំ គហេត្វា ទាសកម្មករបោរិសស្ស ឆម្មាសិកំ វេតនំ ទេតិ ។ ន តាវ ខីយតិ យាវស្ស

១ ម. សម្មតឹ ។ ២ ម. ភទ្ទិយនគរេ ។ ៣ ម. សូបព្យញ្ជនកំ ។





ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយប្រើប្រាស់នូវកប្បិយភូមិ ដែលសង្ឃសន្មតឲ្យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវកប្បិយភូមិ ៤ យ៉ាងគឺ ឧស្សាវនន្តិកា ១ គោនិសាទិកា ១ គហបតិកា ១ សម្មុតិកា(១) ១ ។

(១៣១) សម័យនោះឯង មេណ្ឌកគហបតិនៅក្នុងក្រុងភទ្ទិយៈ ។ សេដ្ឋីនោះមានឫទ្ធានុភាពយ៉ាងនេះ គឺកាលដែលបានមុជសិរសា (ក្បាល) រួចហើយ ឲ្យគេបោសជម្រកស្រូវហើយ ទើបអង្គុយខាងក្រៅទ្វារ ។ ធារស្រូវក៏ស្រោចធ្លាក់ចុះមកអំពីអាកាសពេញជម្រក ។ ឯភរិយា (របស់សេដ្ឋីនោះ) មានឫទ្ធានុភាពយ៉ាងនេះ គឺចូលទៅអង្គុយជិតថាសមួយមានចំណុះមួយអាឡ្ហក(២) នឹងចានសម្លមួយសម្រាប់ដាក់សម្លនិងម្ហូប ហើយអង្គាសពួកបុរសជាទាសកម្មករដោយភត្ត ។ បើសេដ្ឋីនីយ៉ាងមិនទាន់ក្រោកឡើង ភត្តនោះក៏មិនទាន់អស់ទៅ ។ កូនប្រុស (របស់សេដ្ឋីនោះ) មានឫទ្ធានុភាព គឺកាន់យកថង់ទ្រព្យមួយពាន់ (កហាបណៈ) ហើយឲ្យប្រាក់ដល់បុរសជាទាសកម្មករអស់ប្រាំមួយខែ ។ បើកូននៅតែកាន់ថង់របស់

១ ភូមិដែលសង្ឃប្រកាសនូវញត្តិទុតិយកម្មសន្មតឲ្យជាកប្បិយភូមិ ហៅថា សម្មតិកា ។
២ ប្រមាណជា[illegible] ។

ហត្ថគតា ។ សុណិសាយ ឯវរូបោ ឥទ្ធានុភាវោ ហោតិ ឯកំយេវ ចតុទោណិកំ បិដកំ ឧបនិសីទិត្វា ទាសកម្មករបោរិសស្ស ឆម្មាសិកំ ភត្តំ ទេតិ ។ ន តាវ ខីយតិ យាវ សា ន វុដ្ឋាតិ ។ ទាសស្ស ឯវរូបោ ឥទ្ធានុភាវោ ហោតិ ឯកេន នង្គលេន កសន្តស្ស សត្ត សីតាយោ គច្ឆន្តិ ។ អស្សោសិ ខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ អម្ហាកំ កិរ វិជិតេ ភទ្ទិយនគរេ មេណ្ឌកោ គហបតិ បដិវសតិ តស្ស ឯវរូបោ ឥទ្ធានុភាវោ សីសំ នហាយិត្វា ធញ្ញាគារំ សម្មជ្ជាបេត្វា ពហិទ្វារេ និសីទតិ អន្តលិក្ខា ធញ្ញស្ស ធារា ឱបតិត្វា ធញ្ញាគារំ បូរេតិ ភរិយាយ ឯវរូបោ ឥទ្ធានុភាវោ ឯកំយេវ អាឡ្ហកថាលិកំ ឧបនិសីទិត្វា ឯកញ្ច សូបពិញ្ជនកំ ទាសកម្មករបោរិសំ បរិវិសតិ ន តាវ ខីយតិ យាវ សា ន វុដ្ឋាតិ បុត្តស្ស ឯវរូបោ ឥទ្ធានុភាវោ ឯកំយេវ សហស្សត្ថវិកំ គហេត្វា ទាសកម្ម-



សេដ្ឋីបុត្តនោះដរាបណា ថង់នោះក៏មិនចេះអស់ទៅដរាបនោះ ។ កូនប្រសាស្រី(របស់សេដ្ឋីនោះ)មានឥទ្ធានុភាពខាងមុខការចូលទៅអង្គុយជិតកញ្ច្រែមួយមានចំណុះ ៤ ទោណ[1] ហើយឲ្យភត្តដល់បុរសជាទាសកម្មករអស់ប្រាំមួយខែ ។ បើកូនប្រសាស្រីរបស់សេដ្ឋីនោះមិនទាន់ក្រោកឡើងដរាបណា ភត្តនោះក៏មិនចេះអស់ទៅដរាបនោះ ។ ខ្ញុំប្រុស(របស់សេដ្ឋីនោះ)មានឥទ្ធានុភាពខាងមុខការភ្ជួរស្រែដោយនង្គ័លតែមួយ មានគាប់ចំណារប្រាំពីរបែកចេញទៅ ។ ព្រះបាទមាគធសេនិយពិម្ពិសារ បានឮដំណឹងថា មេណ្ឌកគហបតិនៅក្នុងក្រុងភទ្ទិយៈ ក្នុងដែនរបស់យើង (នេះ) ជាមានឥទ្ធានុភាពបែបនេះ គឺកក់សក់ខ្លួនស្រឡះ រួចប្រើគេឲ្យបោសជង្រុកស្រូវហើយ ទើបអង្គុយខាងក្រៅទ្វារ ធារស្រូវក៏ធ្លាក់ចុះមកពីអាកាសពេញតាំងជង្រុកពូន ភរិយារបស់សេដ្ឋីនោះមានឥទ្ធានុភាពខាងចូលទៅអង្គុយជិតឆ្នាំងមួយមានចំណុះមួយអាឡ្ហក និងសម្លមួយសម្រាប់ជាគ្រឿងផ្សំនឹងម្ហូបគ្រៀម ហើយអង្គាសបុរសជាទាសកម្មករដោយភត្ត បើសេដ្ឋីភរិយានោះមិនទាន់ក្រោកឡើងដរាបណា ភត្តនោះក៏មិនចេះអស់ទៅដរាបនោះ ។ កូនប្រុសរបស់សេដ្ឋីនោះមានឥទ្ធានុភាពខាងកាន់យកថង់ទាន

---

១ បួនអាឡ្ហក មួយទោណនឹង ១៦ នាឡិ ។

ករបោរិសស្ស ឆម្មាសិកំ វេតនំ ទេតិ ន តាវ ខី-
យតិ យាវស្ស ហត្ថគតា សុណិសាយ ឯវរូបោ ឥទ្ធា-
នុភាវោ ឯកំយេវ ចតុទោណិកំ បិដកំ ឧបនិសីទិត្វា
ទាសកម្មករបោរិសស្ស ឆម្មាសិកំ ភត្តំ ទេតិ ន តាវ ខី-
យតិ យាវ សា ន វុដ្ឋាតិ ទាសស្ស ឯវរូបោ ឥទ្ធា-
នុភាវោ ឯកេន នង្គលេន កសន្តស្ស សត្ត សីតាយោ
គច្ឆន្តីតិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសា-
រោ អញ្ញតរំ សព្វត្ថកំ មហាមត្តំ អាមន្តេសិ អម្ហាកំ
កិរ ភណេ វិជិតេ ភទ្ទិយេ នគរេ មេណ្ឌកោ គហបតិ
បដិវសតិ តស្ស ឯវរូបោ ឥទ្ធានុភាវោ សីសំ នហាយិ-
ត្វា ធញ្ញាគារំ សម្មជ្ជាបេត្វា ពហិទ្វារេ និសីទតិ អន្ត-
លិក្ខា ធញ្ញស្ស ធារា ឱបតិត្វា ធញ្ញាគារំ បូរេតិ ។បេ។
ទាសស្ស ឯវរូបោ ឥទ្ធានុភាវោ ឯកេន នង្គលេន
កសន្តស្ស សត្ត សីតាយោ គច្ឆន្តិ គច្ឆ ភណេ ជា-
នាហិ យថា មយា សាមំ ទិដ្ឋំ ឯវំ តវ ទិដ្ឋំ
ភវិស្សតីតិ ។ ឯវំ ទេវាតិ ខោ សោ មហាមត្តោ រញ្ញោ
មាគធស្ស សេនិយស្ស ពិម្ពិសារស្ស បដិស្សុណិត្វា





ចំណុះមួយពាន់កហាបណៈ ហើយឲ្យវេតនដល់បុរសជាទាសកម្មករអស់ប្រាំ
មួយខែ បើថង់នៅតែក្នុងដៃរបស់សេដ្ឋីបុត្រនោះដរាបណា ប្រាក់នោះក៏មិន
ចេះអស់ទៅដរាបនោះ កូនប្រសាស្រីរបស់សេដ្ឋីនោះមានឥទ្ធានុភាពគឺនឹង
ចូលទៅអង្គុយជិតកញ្ជើមួយមានចំណុះ៤ទោណៈ ហើយឲ្យភត្តដល់បុរសជា
ទាសកម្មករអស់ប្រាំមួយខែ បើកូនប្រសាស្រីសេដ្ឋីនោះមិនទាន់ក្រោក
ឡើងដរាបណា ភត្តនោះក៏មិនចេះអស់ទៅដរាបនោះ ខ្ញុំប្រុសរបស់
សេដ្ឋីនោះមានឥទ្ធានុភាពគឺឯការភ្ជួរស្រែដោយនង្គ័លតែមួយ មានគាប់
បំណាះប្រាំពីរបែកចេញទៅ ។ ឯព្រះបាទមាគធសេនិយពិម្ពិសារទ្រង់
ហៅនូវសព្វត្ថកមហាមាត្យ[១]ម្នាក់មកហើយទ្រង់មានព្រះបន្ទូលថា នែនាយ
ឮថាមេណ្ឌកគហបតីនៅក្នុងក្រុងភទ្ទិយៈ ក្នុងដែនរបស់យើង (នេះ) មាន
ឥទ្ធានុភាពនឹងគុណវិសេស៖ រួចប្រើគេឲ្យបោសជង្រុកស្រូវហើយ
អង្គុយខាងក្រៅទ្វារ ធារស្រូវស្រាប់តែធ្លាក់ចុះមកអំពីអាកាសពេញទាំង
ជង្រុក ។បេ។ ខ្ញុំប្រុសរបស់សេដ្ឋីនោះមានឥទ្ធានុភាពគឺឯការភ្ជួរ
ស្រែដោយនង្គ័លតែមួយ មានគាប់បំណាះប្រាំពីរបែកចេញទៅ នែនាយ
អ្នកចូរទៅឲ្យដឹងការ (នេះ) អ្នកនឹងឃើញដោយខ្លួនដូចជាយើងឃើញខ្លួនឯងដែរ ។
មហាមាត្យនោះទទួលព្រះរាជឱង្ការនៃព្រះបាទមាគធសេនិយពិម្ពិសារ

១ អាមាត្យដែលសម្រេចរាជការទាំងអស់ ។

ចតុរង្គិនិយា សេនាយ យេន ភទ្ទិយំ តេន បាយាសិ អនុបុព្វេន យេន ភទ្ទិយំ យេន មេណ្ឌកោ គហបតិ តេនុបសង្កមិ ឧបសង្កមិត្វា មេណ្ឌកំ គហបតឹ ឯតទវោច អហញ្ហិ គហបតិ រញ្ញា អាណត្តោ អម្ហាកំ កិរ ភណេ វិជិតេ ភទ្ទិយេ នគរេ មេណ្ឌកោ គហបតិ បដិវសតិ តស្ស ឯវរូបោ ឥទ្ធានុភាវោ សីសំ នហាយិត្វា ធញ្ញាគារំ សម្មជ្ជាបេត្វា ពហិទ្វារេ និសីទតិ អន្តលិក្ខា ធញ្ញស្ស ធារា ឱបតិត្វា ធញ្ញាគារំ បូរេតិ ។ បេ ។ ទាសស្ស ឯវរូបោ ឥទ្ធានុភាវោ ឯកេន នង្គលេន កសន្តស្ស សត្ត សីតាយោ គច្ឆន្តិ គច្ឆ ភណេ ជានាហិ យថា មយា សាមំ ទិដ្ឋោ ឯវំ តវ ទិដ្ឋោ ភវិស្សតីតិ បស្សាម តេ គហបតិ ឥទ្ធានុភាវន្តិ ។ អថខោ មេណ្ឌកោ គហបតិ សីសំ នហាយិត្វា ធញ្ញាគារំ សម្មជ្ជាបេត្វា ពហិទ្វារេ និសីទិ ។ អន្តលិក្ខា ធញ្ញស្ស ធារា ឱបតិត្វា ធញ្ញាគារំ បូរេសុំ ។ ទិដ្ឋោ តេ គហបតិ ឥទ្ធានុភាវោ ភរិយាយ តេ ឥទ្ធានុភាវំ បស្សាមាតិ[1] ។ អថខោ មេណ្ឌកោ គហបតិ

១ ម. បស្សិស្សាមាតិ ។



ជាមួយពលក្បួនទ័ពជា យាត្រាចេញហើយព្រះសម្មតទេព ហើយក្រោយមក ទៅកាន់ក្រុងភទ្ទិយៈតាមលំដាប់ ជាមួយនឹងសេនាមានអង្គ ៤ ចូលទៅរកមេណ្ឌកគហបតិ លុះចូលទៅដល់ហើយ ទើបនិយាយនឹងមេណ្ឌកគហបតិថា ម្នាលគហបតិ យើងនេះឯងត្រូវព្រះរាជាទ្រង់ត្រាស់បង្គាប់មកថា ម្នាលនាយ ឮថាមេណ្ឌកគហបតិនៅក្នុងក្រុងភទ្ទិយៈក្នុងដែនរបស់យើង (នេះ) មានឥទ្ធានុភាពយ៉ាងនេះ គឺកក់ក្បាលស្រស់រួចប្រើគេឲ្យបោសជង្រុកស្រូវហើយ ទើបអង្គុយខាងក្រៅទ្វារ ធារស្រូវក៏ស្រោចចុះមកអំពីអាកាសពេញជង្រុក ។ បេ ។ ខ្ញុំប្រុសរបស់សេដ្ឋីនោះមានឥទ្ធានុភាពគឺ កំពុងភ្ជួរស្រែដោយនង្គ័លតែមួយ មានរងចំណារជ្រោះប្រាំពីរបែកចេញទៅ ម្នាលនាយ អ្នកចូរទៅឲ្យដឹងការ(ដែល)អ្នកឃើញហើយ ដូចជាយើងឃើញផ្ទាល់នឹងភ្នែក ម្នាលគហបតិ ព្រោះនេះ យើងចង់ឃើញឥទ្ធានុភាពរបស់អ្នក ។ គ្រានោះ មេណ្ឌកគហបតិកក់ក្បាលស្រស់រួចប្រើគេឲ្យបោសជង្រុកស្រូវហើយ ទើបអង្គុយខាងក្រៅទ្វារ ធារស្រូវក៏ស្រោចចុះមកអំពីអាកាសពេញជង្រុក ។ មហាមាត្យនិយាយថា ម្នាលគហបតិ ឥទ្ធានុភាពរបស់អ្នក យើងក៏បានឃើញហើយ តែយើងចង់ឃើញឥទ្ធានុភាពភរិយារបស់អ្នកទៀត ។ ទើបមេណ្ឌកគហបតិបង្គាប់ទៅភរិយាថា

ភរិយំ អាណាបេសិ តេនហិ ចតុរង្គិនឹ សេនំ ភត្តេន បរិវិសាហីតិ[១] ។ អថខោ មេណ្ឌកស្ស គហបតិស្ស ភរិយា ឯកំយេវ អាឡ្ហកថាលិកំ ឧបនិសីទិត្វា ឯកញ្ច សូបតិដ្ឋានំ ចតុរង្គិនឹ សេនំ ភត្តេន បរិវិសិ ។ ន តាវ ខីយតិ យាវ សា ន វុដ្ឋាតិ ។ ទិដ្ឋោ ខោ គហបតិ ភរិយាយ ឥទ្ធានុភាវោ បុត្តស្ស តេ ឥទ្ធានុភាវំ បស្សិស្សាមាតិ ។ អថខោ មេណ្ឌកោ គហបតិ បុត្តំ អាណាបេសិ តេនហិ ចតុរង្គិនិយា សេនាយ ឆមាសិកំ វេតនំ ទេហីតិ ។ អថខោ មេណ្ឌកស្ស គហបតិស្ស បុត្តោ ឯកំយេវ សហស្សត្ថវិកំ គហេត្វា ចតុរង្គិនិយា សេនាយ ឆមាសិកំ វេតនំ អទាសិ ។ ន តាវ ខីយតិ យាវស្ស ហត្ថគតា ។ ទិដ្ឋោ ខោ គហបតិ បុត្តស្ស ឥទ្ធានុភាវោ សុណិសាយ តេ ឥទ្ធានុភាវំ បស្សិស្សាមាតិ ។ អថខោ មេណ្ឌកោ គហបតិ សុណិសំ អាណាបេសិ តេនហិ ចតុរង្គិនិយា សេនាយ ឆមាសិកំ ភត្តំ ទេហីតិ ។ អថខោ មេណ្ឌកស្ស គហបតិស្ស សុណិសា ឯកំយេវ

១ ម. បរិវេសាហីតិ ។



នែនាង បើដូច្នោះ ចូរនាងអង្គាសសេនាមានអង្គ ៤ ដោយភត្តចុះ ។ លំដាប់នោះ ភរិយារបស់មេណ្ឌកគហបតីចូលទៅអង្គុយជិតឆ្នាំងមានចំណុះមួយអាឡ្ហក និងនឹងសម្លមួយសម្រាប់ដាក់សម្លនិងម្ហូបគ្រៀម ហើយអង្គាសសេនាមានអង្គ ៤ ដោយភត្ត ។ សេដ្ឋីភរិយានោះមិនទាន់ក្រោកឡើងដរាបណា ភត្តនោះក៏មិនចេះអស់ទៅដរាបនោះ ។ មហាមាត្យនិយាយថា ម្នាលគហបតី ឥទ្ធានុភាពភរិយារបស់អ្នក យើងបានឃើញហើយ តែយើងចង់ឃើញឥទ្ធានុភាពកូនប្រុសរបស់អ្នកទៀត ។ មេណ្ឌកគហបតីបង្គាប់ទៅកូនប្រុសថា នែកូន បើដូច្នោះ អ្នកចូរឲ្យប្រាក់ឈ្នួលដល់សេនាមានអង្គ ៤ អស់ប្រាំមួយខែចុះ ។ លំដាប់នោះ កូនរបស់មេណ្ឌកគហបតី កាន់យកថង់មានចំណុះមួយពាន់កហាបណៈ ហើយឲ្យប្រាក់ឈ្នួលដល់សេនាមានអង្គ ៤ អស់ប្រាំមួយខែ ។ ថង់នៅក្នុងដៃរបស់សេដ្ឋីបុត្រនោះដរាបណា ប្រាក់នោះក៏មិនចេះអស់ទៅដរាបនោះ ។ មហាមាត្យនិយាយថា ម្នាលគហបតី ឥទ្ធានុភាពកូនប្រុសរបស់អ្នកយើងបានឃើញហើយ តែយើងចង់ឃើញឥទ្ធានុភាពកូនប្រសាស្រីរបស់អ្នកទៀត ។ មេណ្ឌកគហបតីបង្គាប់ទៅកូនប្រសាស្រីថា នែនាង បើដូច្នោះ នាងចូរឲ្យភត្តដល់សេនាមានអង្គ ៤ អស់ប្រាំមួយខែចុះ ។ លំដាប់នោះ កូនប្រសាស្រីរបស់មេណ្ឌកគហបតីចូលទៅអង្គុយជិតល្អីមួយមាន

ចតុទោណិកំ បិដកំ ឧបនិសីទិត្វា ចតុរង្គិនិយា សេ-នាយ ឆម្មាសិកំ ភត្តំ អទាសិ ។ ន តាវ ខីយតិ យាវ សា ន វុដ្ឋាតិ ។ ទិដ្ឋោ តេ គហបតិ សុណិសា-យ ឥទ្ធានុភាវោ ទាសស្ស តេ ឥទ្ធានុភាវំ បស្សាមាតិ ។ តេនហិ សាមិ ទាសស្ស ឥទ្ធានុភាវំ ខេត្តេ បស្ស-ថាតិ ។ អលំ គហបតិ ទិដ្ឋោ តេ ទាសស្សាបិ ឥទ្ធានុ-ភាវោតិ ។ អថខោ សោ មហាមត្តោ ចតុរង្គិនិយា សេ-នាយ សទ្ធឹ បុនទេវ រាជគហំ បច្ចាគញ្ឆិ យេន រាជា មាគធោ សេនិយោ ពិម្ពិសារោ តេនុបសង្កមិ ឧបសង្កមិត្វា រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស ឯតមត្ថំ អារោ-ចេសិ ។

(១៣២) អថខោ ភគវា វេសាលិយំ យថាភិរន្តំ វិហរិត្វា យេន ភទ្ទិយំ តេន ចារិកំ បក្កាមិ មហតា ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេលសេហិ ភិក្ខុសតេហិ ។ អថខោ ភគវា អនុបុព្វេន ចារិកំ ចរមានោ យេន ភទ្ទិយំ តទវសរិ ។ តត្រ សុទំ ភគវា ភទ្ទិយេ វិហរតិ ជាតិ



ចំណុះ ៤ ទោណ ហើយឲ្យភត្តដល់សេនាមានអង្គ ៤ អស់ប្រាំមួយខែ ។ កូនប្រសាស្រីរបស់សេដ្ឋីនោះមិនទាន់ក្រោកឡើងដរាបណា ភត្តនោះក៏មិនចេះអស់ទៅដរាបនោះ ។ មហាមាត្យនិយាយថា ម្នាលគហបតិ ឥទ្ធានុភាពកូនប្រសាស្រីរបស់អ្នក យើងបានឃើញហើយ យើងចង់ឃើញឥទ្ធានុភាពខ្ញុំប្រុសរបស់អ្នកទៀត ។ មេណ្ឌកគហបតិនិយាយតបថា បពិត្រអ្នកជាម្ចាស់ ចូរឥទ្ធានុភាពខ្ញុំប្រុសរបស់ខ្ញុំ អ្នកត្រូវឃើញក្នុងស្រែ (ឯណោះ) ។ មហាមាត្យក៏និយាយថា ម្នាលគហបតិ ល្មមហើយ ៗ ឥទ្ធានុភាពខ្ញុំប្រុសរបស់អ្នក (ទុកដូចជា) យើងបានឃើញហើយដែរ ។ លំដាប់នោះ មហាមាត្យនោះត្រឡប់មកកាន់ក្រុងរាជគ្រឹះវិញ ព្រមដោយសេនាមានអង្គ ៤ ចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសារ លុះចូលទៅដល់ហើយ ទើបក្រាបទូលដំណើរនុ៎ះដល់ព្រះបាទមាគធសេនិយពិម្ពិសារ (ដោយសព្វគ្រប់) ។

(១៣៦) គ្រានោះឯង ព្រះដ៏មានព្រះភាគគង់នៅក្នុងក្រុងវេសាលីគួរតាមព្រះអធ្យាស្រ័យហើយ ទើបទ្រង់ស្ដេចចេញទៅកាន់ចារិកក្នុងក្រុងភទ្ទិយៈ ជាមួយនឹងភិក្ខុសង្ឃជាច្រើន គឺភិក្ខុមួយពាន់ពីររយហាសិបរូប ។ ក្នុងកាលនោះ កាលព្រះមានព្រះភាគត្រាច់ទៅកាន់ចារិកដោយលំដាប់ ក៏យាងដល់ក្រុងភទ្ទិយៈនោះ ។ បានឮថា ព្រះមានព្រះភាគគង់

យាតិ ។ អស្សោសិ ខោ ខេណ្ណោ គហបតិ សម-
ណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា
បព្ពជិតោ កក្កុយំ អនុប្បត្តោ កក្កុយេ វិហរតិ ជាតិ-
យាវនេ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ
កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មា-
សម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អ-
នុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ



គនិគម ទៀបក្រុងកក្កុយៈនោះ ។ ខេណ្ណកគហបតីបានឮច្បាស់ ( ឮ
ម៉ែណាំនោះហើយ ទើបប្រកាសសេចក្ដីថា ) ម្នាលគ្នាយើង បានឮថា ព្រះ
សមណគោតមជាសក្យបុត្រ ចេញចាកសក្យត្រកូលទៅបួសព្រះផ្នួស
ស្ដេចយាងមកដល់ក្រុងកក្កុយៈដោយលំដាប់ ហើយគង់ក្នុងនិគម ទៀប
ក្រុងកក្កុយៈ កិត្តិសព្ទដ៏ពីរោះរបស់ព្រះគោតមដ៏ចម្រើននោះ ខ្ចរខ្ចាយសុះ
សាយយ៉ាងនេះថា ព្រះមានព្រះភាគនោះព្រះអង្គទ្រង់ព្រះនាមថា អរហំ
ព្រោះព្រះអង្គឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាង ថា សម្មាសម្ពុទ្ធោ
ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ
ថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជានឹងចរណៈ ; គឺ
សេចក្ដីចេះដឹងនឹងកិច្ចដែលបុគ្គលគប្បីប្រព្រឹត្ត ថា សុគតោ ព្រោះព្រះ
អង្គមានដំណើរល្អទៅកាន់ព្រះនិព្វាន ថា លោកវិទូ ព្រោះព្រះអង្គជ្រាប
ច្បាស់នូវត្រៃលោក ថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ
រកបុគ្គលណាមួយស្មើគ្មាន ថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាន
នូវបុរសដែលគួរទូន្មានបាន ថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាគ្រូ
នៃទេវតានឹងមនុស្សទាំងឡាយ ថា ពុទ្ធោ ព្រោះព្រះអង្គបានត្រាស់ដឹងនូវ

ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ(១) កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។ អថខោ មេណ្ឌកោ គហបតិ ភទ្រានិ ភទ្រានិ យានានិ យោជាបេត្វា ភទ្រំ ភទ្រំ យានំ អភិរុហិត្វា ភទ្រេហិ ភទ្រេហិ យានេហិ ភទ្ទិយា និយ្យាសិ ភគវន្តំ ទស្សនាយ ។ អទ្ទសំសុ ខោ សម្ពហុលា តិត្ថិយា មេណ្ឌកំ គហបតឹ ទូរតោវ អាគច្ឆន្តំ ទិស្វាន មេណ្ឌកំ គហបតឹ ឯតទវោចុំ កហំ ត្វំ គហបតិ គច្ឆសីតិ ។ គច្ឆាមហំ ភន្តេ សមណំ គោតមំ ទស្សនាយាតិ ។ កឹ បន ត្វំ គហបតិ កិរិយវាទោ សមានោ អកិរិយវាទំ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សសិ សមណោ ហិ គហបតិ គោតមោ អកិរិយវាទោ អកិរិយាយ ធម្មំ ទេសេតិ តេន

១ ម. សព្យញ្ជនំ ។



ដោយសច្ចធម៌ ជា ភគវា ព្រោះព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះអង្គបានត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់នូវព្រះញាណចំពោះព្រះអង្គ ហើយញ៉ាំងលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញ៉ាំងពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឲ្យបានត្រាស់ដឹងផង ព្រះអង្គទ្រង់សំដែងធម៌ពីរោះបទដើម ពីរោះបទកណ្ដាល និងពីរោះបទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈដ៏ពេញបរិបូណ៌បរិសុទ្ធអស់ជើង គឺដំណើរដែលបានឃើញបានជួបនឹងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនោះជាការប្រពៃពេក ។ លំដាប់នោះមេណ្ឌកគហបតីឲ្យមនុស្សទឹមយានដ៏ល្អ ៗ ហើយជិះយានដ៏ល្អ ៗ មានយានដ៏ល្អ ៗ ចេញអំពីក្រុងភទ្ទិយៈដើម្បីគាល់ព្រះមានព្រះភាគ ។ ពួកតិរ្ថិយជាច្រើនរូបបានឃើញមេណ្ឌកគហបតីកំពុងមកពីចម្ងាយល្មមឃើញហើយបាននិយាយពាក្យនេះនឹងមេណ្ឌកគហបតីថា នែគហបតី អ្នកទៅណា ។ មេណ្ឌកគហបតីនិយាយថា បពិត្រលោកដ៏ចំរើន ខ្ញុំទៅគាល់ព្រះសមណគោតម ។ ពួកតិរ្ថិយនិយាយថា នែគហបតី អ្នកឯងជាកិរិយវាទ (អ្នកពោលពាក្យថាត្រូវធ្វើកិច្ចការ) នឹងចូលទៅគាល់សមណគោតមជាអកិរិយវាទ (អ្នកពោលពាក្យថាកិច្ចការជាមិនត្រូវធ្វើ) ដូចម្ដេចបាន គហបតី ព្រោះសមណគោតមជាអកិរិយវាទ សំដែងធម៌តាមបែបអកិរិយវាទ ។

ច សាដកា វិជតីតិ ។ អថខោ មេណ្ឌកស្ស គហប-តិស្ស ឯតទហោសិ និស្សំសយំ ខោ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ភវិស្សតិ យថយិមេ តិត្ថិយា ទុស្ស-យន្តីតិ(១) យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកោវ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នស្ស ខោ មេណ្ឌកស្ស គហបតិស្ស ភគវា អនុបុព្វិកថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេ-សំ នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា ភគវា អញ្ញាសិ មេណ្ឌកំ គហបតិំ កល្លចិត្តំ មុទុចិត្តំ វិនីវរ-ណចិត្តំ ឧទគ្គចិត្តំ បសន្នចិត្តំ អថ យា ពុទ្ធានំ សា-មុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគត-

១ ម. ទូសយន្តីតិ ។



ម្យ៉ាងទៀត សមណគោតមនោះខ្ញុំបានឮពួកសាវកតែងតែមកនិយាយទោសនោះដែរ ។ លំដាប់នោះឯង មេណ្ឌកគហបតិមានសេចក្ដីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគនោះច្បាស់ជាអរហំសម្មាសម្ពុទ្ធឥតសង្ស័យទៀតឡើយ គួរតែអញទៅគាល់នោះណ៎ា ដីសជាប្រាកដ គួរប្រើរទេះសេះនិងយានតាមត្រឹមណាក៏ទៅដោយយានត្រឹមនោះ ហើយចុះពីយានដើរទៅដោយជើងទទេ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ ព្រះមានព្រះភាគទ្រង់សំដែងអនុបុព្វីកថាដល់មេណ្ឌកគហបតិដែលអង្គុយនៅក្នុងទីសមគួរ អនុបុព្វីកថានោះដូចម្ដេចខ្លះ (ឯអនុបុព្វីកថានោះ) គឺ ព្រះមានព្រះភាគទ្រង់ប្រកាស ទានកថា (សំដែងអំពីការឲ្យទាន) សីលកថា (សំដែងអំពីការរក្សាសីល) សគ្គកថា (សំដែងពីឋានសួគ៌) ទោសរបស់កាមទាំងឡាយដ៏ថោកទាបដ៏សៅហ្មង ក៏អានិសង្សក្នុងការចេញចាកកាម ។ កាលណាបើព្រះដ៏មានព្រះភាគបានជ្រាបថា មេណ្ឌកគហបតិមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនី-វរណ៍ មានចិត្តរីករាយឡើង មានចិត្តជ្រះថ្លាហើយ ទើបព្រះអង្គទ្រង់ប្រកាសធម្មទេសនាដែលព្រះពុទ្ធទាំងឡាយទ្រង់លើកឡើងសំដែងដោយព្រះអង្គឯង គឺទុក្ខ សមុទយ និរោធ មគ្គ ក្នុងកាលនោះ ។ ធម្មតាសំពត់ស្អាត

កាឡេក្កំ សព្ពនេរ ផេដំ បដិក្ខេយ្យ បរិមេ មេណ្ឌ-
កស្ស គហបតិស្ស តស្មឹយេវសេន ភិជំ វិតបលំ
ជម្មបញ្ញំ ឱធាតិ យន្តិញ្ញំ សមុទយធម្មំ សព្ពំ តំនិរោ-
ធធម្មន្តិ ។ អថខោ មេណ្ឌកោ គហបតិ ទិដ្ឋធម្មោ
បត្តធម្មោ វិទិតធម្មោ បរិយោគាឡ្ហធម្មោ តិណ្ណវិចិកិច្ឆោ
វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុ សា-
សនេ គតវត្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ
សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា
វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា
តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ
ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ
ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុ-





ព្រះសាស្តាកម្ចាត់បង់ទៅផ្លូវនូវទឹកដែលកាត់ដោយស្រែលទាន យ៉ាងណាមិញ
មេណ្ឌកគហបតីកើតធម្មចក្ខុ គឺសោតាបត្តិមគ្គ ព្រះសាស្តាគន្លឹះ ព្រះសាស្តា
បន្ទូល សើកសេចក្ដីនោះថា (ហើយគិតថា ណាមួយ) ជួយខ្ញុំផង របស់ណា
មួយដែលមានសេចក្ដីកើតឡើងជាធម្មតា របស់ទាំងនោះក៏មានសេចក្ដី-
រលត់ទៅជាធម្មតា ក៏មានទំហំយ៉ាងនេះដែរ ។ លំដាប់ដែលមេណ្ឌកគហប-
តីបានឃើញធម៌ សម្រេចធម៌ ដឹងធម៌ជាក់ច្បាស់ យល់ច្បាស់នូវធម៌
ហើយ ឆ្លងផុតបាត់សេចក្ដីសង្ស័យ ប្រាសចាកសេចក្ដីសង្ស័យ ដល់នូវ
សេចក្ដីក្លៀវក្លា មិនជឿនឹងអ្នកដទៃ ក្នុងសាសនានៃព្រះសាស្តា បានក្រាប
បង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះធម៌ទេសនា
របស់ព្រះអង្គពីរោះណាស់ហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រះធម៌ទេសនា
របស់ព្រះអង្គពីរោះណាស់ហើយ បពិត្រព្រះអង្គដ៏ចំរើន ដូចជាបុគ្គល
ផ្ងារវត្ថុដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ឬប្រាប់ផ្លូវដល់អ្នកវង្វេង
ឬទ្រោលប្រទីបប្រេងក្នុងទីងងឹតដោយគិតថា ពួកមនុស្សមានភ្នែក (ភ្លឺ)
នឹងបានឃើញរូបទាំងឡាយបាន ។ មួយទៀត យ៉ាងណាមិញ ធម៌ដែលព្រះដ៏មាន
ព្រះភាគទ្រង់ប្រកាសហើយដោយបរិយាយដ៏ច្រើន ក៏មានឧបមេយ្យដូច្នោះ
ដែរ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះដ៏មានព្រះ
ភាគផង ព្រះធម៌ផង ភិក្ខុសង្ឃផង ជាទីពឹងទីរលឹក សូមព្រះដ៏មានព្រះភាគ

សង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ[១] អធិវាសេតុ ច មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ មេណ្ឌកោ គហបតិ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ មេណ្ឌកោ គហបតិ តស្សា រត្តិយា អច្ចយេន បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន មេណ្ឌកស្ស គហបតិស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។ អថខោ មេណ្ឌកស្ស គហបតិស្ស ភរិយា ច បុត្តោ ច សុណិសា ច ទាសោ ច យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ តេសំ ភគវា អនុបុព្វិំកថំ កថេសិ សេយ្យថីទំ

១ ម. គតន្តិ ។



ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់ព្រះរតនត្រ័យជាទីពឹងរលឹកស្មើដោយជីវិតតាំងពីកាលនេះជាដើម បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទ្រង់ទទួលភត្តរបស់ខ្ញុំព្រះអង្គដើម្បីឆាន់ក្នុងថ្ងៃស្អែកជាមួយនឹងព្រះភិក្ខុសង្ឃ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព (ការស្ងៀម) ។ លំដាប់នោះឯង មេណ្ឌកគហបតីដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគធ្វើប្រទក្សិណហើយចៀសចេញទៅ ។ លំដាប់នោះ លុះកន្លងរាត្រីនោះទៅ មេណ្ឌកគហបតីក៏ឲ្យមនុស្សតាក់តែងខាទនីយភោជនីយាហារដ៏ថ្លៃថ្នូរ ហើយឲ្យអ្នកបម្រើទៅក្រាបបង្គំទូលកាលគួរដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាល (នេះ) ជាកាលគួរហើយ ភត្តសម្រេចហើយ ។ ទើបព្រះដ៏មានព្រះភាគទ្រង់ស្បង់ហើយទ្រង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ យាងចូលទៅកាន់លំនៅរបស់មេណ្ឌកគហបតី លុះយាងចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុកហើយ ជាមួយនឹងភិក្ខុសង្ឃ ។ វេលានោះ ប្រពន្ធ កូនប្រុស កូនប្រសាស្រី និងខ្ញុំប្រុសរបស់មេណ្ឌកគហបតី ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ ព្រះមានព្រះភាគទ្រង់សំដែងនូវអនុបុព្វីកថាដល់ជនទាំងនោះ អនុបុព្វីកថានោះដូចម្តេច

ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ
សង្កិលេសំ នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា
ភគវា អញ្ញាសិ តេ កល្លចិត្តេ មុទុចិត្តេ វិនីវរណចិត្តេ
ឧទគ្គចិត្តេ បសន្នចិត្តេ អថ យា ពុទ្ធានំ សាមុក្កំសិកា
ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ
មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ
សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ តេសំ តស្មឹ
យេវាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ
សមុទយធម្មំ សព្វំ តំ និរោធធម្មន្តិ ។ តេ ទិដ្ឋធម្មា បត្ត-
ធម្មា វិទិតធម្មា បរិយោគាឡ្ហធម្មា តិណ្ណវិចិកិច្ឆា វិគត-
កថំកថា វេសារជ្ជប្បត្តា អបរប្បច្ចយា សត្ថុ សាសនេ
ភគវន្តំ ឯតទវោចុំ អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ





ពួកកុលបុត្តទាំងនោះ គឺព្រះដ៏មានព្រះភាគទ្រង់ប្រកាសទានកថា សីលកថា
សគ្គកថា ទោសរបស់កាមទាំងឡាយដ៏ថោកទាបដ៏សៅហ្មង និងអានិសង្ស
ក្នុងការចេញចាកកាម ។ កាលណាបើព្រះដ៏មានព្រះភាគបានទ្រង់ជ្រាប
ថា ពួកកុលបុត្តទាំងនោះមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនី-
វរណៈ មានចិត្តរីករាយឡើង និងមានចិត្តជ្រះថ្លាហើយ ក៏ទ្រង់ប្រកាសធម្ម-
ទេសនាដែលព្រះពុទ្ធទាំងឡាយទ្រង់លើកឡើងសំដែងដោយព្រះអង្គឯង
គឺទុក្ខ ហេតុឲ្យកើតទុក្ខ សេចក្ដីរលត់ទុក្ខ និងបដិបទាជាផ្លូវទៅកាន់ទីរលត់
ទុក្ខ ក្នុងកាលនោះ ។ សំពត់ស្អាតប្រាសចាកមន្ទិលនៅគួរទទួលទឹក
ជ្រលក់បានដោយស្រួលបាន យ៉ាងណាមិញ ពួកកុលបុត្តទាំងនោះក៏កើតធម្មចក្ខុ គឺ
សោតាបត្តិមគ្គប្រាសចាកធូលីប្រាសចាកមន្ទិលលើអាសនៈនោះឯង (ហើយ
ពិចារណាឃើញ) ដូច្នេះថា របស់ណាមួយដែលមានការកើតឡើងជា
ធម្មតា របស់ទាំងនោះក៏មានសេចក្ដីរលត់ទៅជាធម្មតា ក៏មានឧបមេយ្យ
ដូច្នេះឯង ពួកកុលបុត្តទាំងនោះបានឃើញធម៌ បានដល់ធម៌ បានដឹងធម៌ច្បាស់
ឈ្វេងយល់ធម៌ចុះមកកាន់ធម៌ហើយ ឆ្លងផុតចាកសេចក្ដីសង្ស័យ ប្រាសចាក
សេចក្ដីសង្ស័យថាដូចម្ដេច ដល់នូវសេចក្ដីក្លៀវក្លា មិនជឿបុគ្គលដទៃក្នុងសាសនាព្រះ
សាស្ដាហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏
ចំរើន ព្រះធម៌របស់ព្រះអង្គភ្លឺករណាស់ហើយ បពិត្រព្រះអង្គដ៏ចំរើន

សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯតេ មយំ ភន្តេ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណំ គតេតិ ។ អថខោ មេណ្ឌកោ គហបតិ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មេណ្ឌកោ គហបតិ ភគវន្តំ ឯតទវោច យាវ ភន្តេ ភគវា ភទ្ទិយេ វិហរតិ អហំ ពុទ្ធប្បមុខស្ស ភិក្ខុសង្ឃស្ស ធុវភត្តេនាតិ(១) ។

១ ម. យាវ ភន្តេ ភគវា ភទ្ទិយេ វិហរតិ តាវ អហំ ។ ល ។ ធុវភត្តេនាតិ ។



ព្រះពុទ្ធវចនៈរបស់ព្រះអង្គពីរោះណាស់ហើយ បពិត្រព្រះអង្គដ៏ចំរើន ដូចជាបុគ្គលផ្ងារវត្ថុដែលគេផ្កាប់ ឬបើកបង្ហាញវត្ថុដែលគេបិទាំង ឬប្រាប់ផ្លូវដល់មនុស្សដែលវង្វេងផ្លូវ ឬទ្រោលប្រទីបប្រេងក្នុងទីងងឹតដោយគិតថា ពួកមនុស្សមានចក្ខុនឹងឃើញរូបទាំងឡាយបាន មានឧបមាយ៉ាងណាមិញ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ប្រកាសហើយ ដោយបរិយាយជាច្រើន ក៏មានឧបមេយ្យដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងឡាយនេះសូមដល់ព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងរលឹក សូមព្រះដ៏មានព្រះភាគចាំទុកនូវយើងខ្ញុំទាំងឡាយថាជាឧបាសក ដល់នូវព្រះរតនត្រ័យជាទីរលឹកស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើម ។ វេលានោះ មេណ្ឌកគហបតីបានអង្គាសនូវខាទនីយភោជនីយាហារ (បង្អែមចំអាប) ដ៏ឧត្តមល្អិតស្អាតដោយដៃខ្លួនឯងចំពោះព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ ត្រាតែដល់លោកប្រកែកថាមិនទទួលទៀត លុះព្រះដ៏មានព្រះភាគទ្រង់សោយស្រេចហើយ ទ្រង់លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះមេណ្ឌកគហបតីអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគគង់នៅក្នុងក្រុងភទ្ទិយៈអស់កាលណា ខ្ញុំព្រះអង្គនឹងផ្គត់ផ្គង់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានដោយភត្តដែលត្រូវថ្វាយជានិច្ចអស់កាលនោះ ។

អថខោ ភគវា មេណ្ឌកំ គហបតឹ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។

(១៣៣) អថខោ ភគវា ភទ្ទិយេ យថាភិរន្តំ វិហរិត្វា មេណ្ឌកំ គហបតឹ អនាបុច្ឆា យេន អង្គុត្តរាបោ[១] តេន ចារិកំ បក្កាមិ មហតា ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេឡសេហិ ភិក្ខុសតេហិ ។ អស្សោសិ ខោ មេណ្ឌកោ គហបតិ ភគវា កិរ យេន អង្គុត្តរាបោ តេន ចារិកំ បក្កន្តោ មហតា ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេឡសេហិ ភិក្ខុសតេហីតិ ។ អថខោ មេណ្ឌកោ គហបតិ ទាសេ ច កម្មករេ ច អាណាបេសិ តេនហិ ភណេ ពហុំ លោណញ្ច តេលញ្ច តណ្ឌុលញ្ច ខាទនីយញ្ច សកដេសុ អារោបេត្វា អាគច្ឆថ អឌ្ឍតេឡសានិ ច គោបាលកសតានិ អឌ្ឍតេឡសានិ ធេនុសតានិ អាទាយ អាគច្ឆន្តុ យត្ថ ភគវន្តំ បស្សិស្សាម តត្ថ ធារុណ្ហេន[២] ខីរេន ភោជេស្សាមាតិ ។ អថខោ មេណ្ឌកោ គហបតិ ភគវន្តំ

១ អង្គុត្តរាបោតិ ភវិតព្វំ ។ ២ ម. តរុណេន ។



ទើបព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យមេណ្ឌកគហបតិយល់តាម ឲ្យប្រតិបត្តិតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។

(១៣៣) គ្រានោះ ព្រះមានព្រះភាគ គង់នៅក្រុងភទ្ទិយៈ គួរតាមអធ្យាស្រ័យ ហើយទ្រង់មិនលាមេណ្ឌកគហបតិ ក៏យាងទៅកាន់ចារិកក្នុងអង្គុត្តរាបជនបទ ជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួនមួយពាន់ពីររយហាសិបរូប ។ មេណ្ឌកគហបតីបានឮថា ព្រះដ៏មានព្រះភាគយាងចេញទៅកាន់ចារិកក្នុងអង្គុត្តរាបជនបទជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួនមួយពាន់ពីររយហាសិបរូប ។ ទើបមេណ្ឌកគហបតីបង្គាប់ពួកខ្ញុំប្រុសនឹងពួកកម្មករថា ម្នាលអ្នកទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយផ្ទុកអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ ឲ្យច្រើនក្នុងរទេះទាំងឡាយមក ម្យ៉ាងទៀត ឲ្យគោបាលមួយពាន់ពីររយហាសិបនាក់ ចូរនាំមេគោមួយពាន់ពីររយហាសិបមក (ថា) យើងជួបនឹងព្រះដ៏មានព្រះភាគក្នុងទីណា យើងនឹងនិមន្តព្រះដ៏មានព្រះភាគឲ្យឆាន់ទឹកដោះស្រស់ថ្មីៗ ក្នុងទីនោះ ។ មេណ្ឌកគហបតីក៏បានផ្គត់ផ្គង់ព្រះដ៏មានព្រះភាគក្នុង

អន្តរាមគ្គេ ភត្តាយ សម្បាទេសិ ។ អថខោ មេណ្ឌកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ មេណ្ឌកោ គហបតិ ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ មេណ្ឌកោ គហបតិ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា[1] ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ មេណ្ឌកោ គហបតិ តស្សា រត្តិយា អច្ចយេន បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន មេណ្ឌកស្ស គហបតិស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។ អថខោ មេណ្ឌកោ គហបតិ អឌ្ឍតេឡសានិ គោបាលកសតានិ អាណាបេសិ តេនហិ ភណេ ឯកមេកំ ធេនុំ គហេត្វា



ទឹកឃ្លាំង[1] តាក់តែងស្បៀងផ្លូវ ។ លំដាប់នោះ មេណ្ឌកគហបតីចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចឈរក្នុងទីសមគួរ ។ លុះមេណ្ឌកគហបតីឈរក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទ្រង់ទទួលភត្តរបស់ខ្ញុំព្រះអង្គដើម្បីឆាន់ក្នុងថ្ងៃស្អែកជាមួយនឹងភិក្ខុសង្ឃ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ ឯមេណ្ឌកគហបតីដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ លុះកន្លងរាត្រីនោះទៅ មេណ្ឌកគហបតីឲ្យមនុស្សតាក់តែងខាទនីយភោជនីយាហារដ៏ផូរផង់ហើយ ក៏ឲ្យក្រាបបង្គំទូលកាលគួរដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាល (នេះ) ជាកាលគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ហើយទ្រង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ក៏ទ្រង់យាងទៅកាន់ដំណាក់របស់មេណ្ឌកគហបតី លុះយាងទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយជាមួយនឹងភិក្ខុសង្ឃ ។ ទើបមេណ្ឌកគហបតីបង្គាប់ពួកអ្នកឃ្វាលគោមួយពាន់ពីររយហាសិបនាក់ថា ម្នាលអ្នកទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយយកមេគោមួយៗ មកប្រមូលទុកដើម្បីត្រូវយកទឹក

[1] ឃ្លាំងទឹកក្នុងផ្លូវ បានដល់ទីដែលគេទៅផងរបស់ដោយផ្លូវឆ្ងាយ ។

ឯកមេកស្ស ភិក្ខុនោ ឧបតិដ្ឋថ តរុណេន(១) ខីរេន ភោជេស្សាមាតិ ។ អថ ខោ មេណ្ឌកោ គហបតិ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ តរុណេន ច ខីរេន ។ ភិក្ខូ កុក្កុច្ចាយន្តា ខីរំ ន បដិគ្គណ្ហន្តិ ។ បដិគ្គណ្ហថ ភិក្ខវេ បរិភុញ្ជថាតិ ។ អថ ខោ មេណ្ឌកោ គហបតិ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា សម្បវារេត្វា តរុណេន ច ខីរេន ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មេណ្ឌកោ គហបតិ ភគវន្តំ ឯតទវោច សន្តិ ភន្តេ មគ្គា កន្តារា អប្បោទកា អប្បភក្ខា ន សុករា អបាថេយ្យេន គន្តុំ សាធុ ភន្តេ ភគវា ភិក្ខូនំ បាថេយ្យំ អនុជានាតូតិ ។ អថ ខោ ភគវា មេណ្ឌកំ គហបតឹ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថ ខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ

១. តរុណេន ។



ដោះស្រស់ថ្មីៗ ហើយយើងនឹងប្រគេនភិក្ខុមួយអង្គៗ ដាច់ ។ ទើបមេណ្ឌកគហបតីអង្គាសព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ឧត្តម នឹងទឹកដោះស្រស់ដែលរូតថ្មីៗ ដោយដៃខ្លួនឯង ។ ភិក្ខុទាំងឡាយមានសេចក្តីរង្កៀសមិនហ៊ានទទួលទឹកដោះស្រស់ ។ ព្រះដ៏មានព្រះភាគទ្រង់មានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលឆាន់ចុះ ។ លំដាប់នោះឯង មេណ្ឌកគហបតីអង្គាសព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ឧត្តម នឹងទឹកដោះស្រស់ដែលរូតថ្មីៗ ដោយដៃខ្លួន លុះព្រះដ៏មានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះមេណ្ឌកគហបតីអង្គុយក្នុងទីសមគួរហើយបានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ផ្លូវមានផ្លូវកន្តារទាំងឡាយដែលមានទឹកតិច មានភក្សាហារតិច ដែលអ្នកគ្មានស្បៀងមិនអាចនឹងទៅបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមឱកាស សូមព្រះដ៏មានព្រះភាគអនុញ្ញាតស្បៀងដល់ភិក្ខុទាំងឡាយ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ឲ្យមេណ្ឌកគហបតីយល់តាម ឲ្យប្រតិបត្តិតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈ ចៀសចេញទៅ ។ ព្រោះនិទាននេះ

ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ បញ្ច គោរសេ ខីរំ ទធឹ តក្កំ នវនីតំ សប្បឹ ។ សន្តិ ភិក្ខវេ មគ្គា កន្តារា អប្បោទកា អប្បភក្ខា ន សុករា អបាថេយ្យេន គន្តុំ ។ អនុជានាមិ ភិក្ខវេ បាថេយ្យំ បរិយេសិតុំ តណ្ឌុលោ តណ្ឌុលត្ថិកេន មុគ្គោ មុគ្គត្ថិកេន មាសោ មាសត្ថិកេន លោណំ លោណត្ថិកេន គុឡោ គុឡត្ថិកេន តេលំ តេលត្ថិកេន សប្បិ សប្បិត្ថិកេន ។ សន្តិ ភិក្ខវេ មនុស្សា សទ្ធា បសន្នា តេ កប្បិយការកានំ ហត្ថេ ហិរញ្ញសុវណ្ណំ(១) ឧបនិក្ខិបន្តិ ឥមិនា យំ អយ្យស្ស កប្បិយំ តំ ទេថាតិ ។ អនុជានាមិ ភិក្ខវេ យំ តតោ កប្បិយំ តំ សាទិតុំ ន ត្វេវាហំ ភិក្ខវេ កេនចិ បរិយាយេន ជាតរូបរជតំ សាទិតព្វំ បរិយេសិតព្វន្តិ វទាមិ ។

១ ម. ហិរញ្ញំ ។





ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវគោរស ៥ គឺទឹកដោះស្រស់១ ទឹកដោះជូរ១ ខ្លាញ់១ ទឹកដោះខាប់១ ទឹកដោះថ្លា១ ។ ម្នាលភិក្ខុទាំងឡាយ មានផ្លូវកន្តារដែលមានទឹកតិច មានភក្សាហារតិច ដែលអ្នកដំណើរស្បៀងមិនងាយនឹងរកបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុស្វែងរកស្បៀងបាន គឺភិក្ខុត្រូវការអង្ករ ស្វែងរកអង្ករបាន ត្រូវការសណ្ដែកបាយ ស្វែងរកសណ្ដែកបាយបាន ត្រូវការសណ្ដែកជមាស ស្វែងរកសណ្ដែកជមាសបាន ត្រូវការអំបិល ស្វែងរកអំបិលបាន ត្រូវការស្ករអំពៅ ស្វែងរកស្ករអំពៅបាន ត្រូវការប្រេង ស្វែងរកប្រេងបាន ត្រូវការទឹកដោះថ្លា ស្វែងរកទឹកដោះថ្លាបាន ។ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងឡាយមានសទ្ធាជ្រះថ្លា មនុស្សទាំងនោះទុកដាក់មាសនិងប្រាក់ក្នុងដៃកប្បិយការកៈទាំងឡាយដោយពាក្យថា របស់ណាគួរដល់លោកម្ចាស់ ចូរអ្នកទាំងឡាយប្រគេនរបស់នោះដោយមាសនិងប្រាក់នេះចុះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុត្រេកអរចំពោះវត្ថុជាកប្បិយៈ (ដែលកើត) អំពីមាសនិងប្រាក់នោះបាន ម្នាលភិក្ខុទាំងឡាយ តែតថាគតមិនពោលថា ត្រេកអរ ត្រេកអរ ត្រូវតែស្វែងរកមាសនិងប្រាក់ផ្ទាល់ ដោយបរិយាយណាមួយឡើយ ។

[១៣៤] អថខោ ភគវា អនុបុព្វេន ចារិកំ ចរមានោ យេន អាបណំ តទវសរិ ។ អស្សោសិ ខោ កេណិយោ ជដិលោ សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ អាបណំ អនុប្បត្តោ(១) តំ ខោ បន ភវន្តំ គោតមំ ឯវំកល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា

១ ម. និគ្គហ អាបណេ វិហរតិ សព្វ អត្ថិ ។



[១៣៤] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ត្រាច់ទៅកាន់ចារិកដោយលំដាប់ បានយាងទៅដល់អាបណនិគម ។ ជដិលឈ្មោះកេណិយៈបានឮដំណឹងថា នែអ្នកដ៏ចំរើន ឮថាព្រះសមណគោតមជាសក្យបុត្រ (ចេញ) ចាកសក្យត្រកូលទៅទ្រង់ព្រះផ្នួស ស្ដេចមកដល់អាបណនិគមដោយលំដាប់ កិត្តិសព្ទដ៏ពីរោះរបស់ព្រះគោតមដ៏ចំរើននោះឯង ខ្ចរខ្ចាយសុះសាយយ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសេចក្ដីសៅហ្មងស្រប់ហើយ ថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ដោយប្រពៃចំពោះព្រះអង្គ ថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ ថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់ព្រះនិព្វាន ថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ថា ពុទ្ធោ ព្រោះព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ថា ភគវា ព្រោះព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះអង្គបានត្រាស់ដឹង ធម៌ដែលជាក់ច្បាស់នូវព្រះនិព្វាន

សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ
សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ
អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិ-
កល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ
សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ
បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ
ទស្សនំ ហោតីតិ ។ អថខោ កេណិយស្ស ជដិ-
លស្ស ឯតទហោសិ កិន្នុ ខោ អហំ សមណស្ស
គោតមស្ស ហរាបេយ្យន្តិ ។ អថខោ កេណិយស្ស
ជដិលស្ស ឯតទហោសិ យេបិ ខោ តេ ព្រាហ្ម-
ណានំ បុព្វកា ឥសយោ មន្តានំ កត្តារោ មន្តានំ
បវត្តារោ យេសមិទំ ឯតរហិ ព្រាហ្មណា បោរាណំ
មន្តបទំ គីតំ បវុត្តំ សមិហិតំ តទនុគាយន្តិ តទនុភា-
សន្តិ ភាសិតមនុភាសន្តិ វាចិតមនុវាចេន្តិ សេយ្យថីទំ
អដ្ឋកោ វាមកោ វាមទេវោ វេស្សាមិត្តោ យមតគ្គិ អង្គីរសោ





ចំពោះព្រះអង្គហើយ ញុំាងលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្ម-
លោក ញុំាងពពួកសត្វព្រមទាំងសមណៈនិងព្រាហ្មណ៍ ញុំាងមនុស្ស
ជាសម្មតិទេពនិងមនុស្សដ៏សេសឲ្យបានត្រាស់ដឹងផង ព្រះអង្គសំដែងធម៌
ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ទ្រង់ប្រកាសព្រហ្មចរិយ
ធម៌ព្រមទាំងអត្ថព្រមទាំងព្យញ្ជនៈ ពេញបរិបូណ៌ ដ៏បរិសុទ្ធអស់ជើង ក៏ដំ-
ណើរដែលបានឃើញបានជួបនូវព្រះអរហន្តទាំងឡាយមានសភាពយ៉ាងនេះ
នោះ ជាការប្រពៃពេក ។ លំដាប់នោះ កេណិយជដិលមានសេចក្តីត្រិះរិះ
ដូច្នេះថា នួអាត្មាអញគប្បីនាំយករបស់អ្វីហ្ន៎ទៅថ្វាយព្រះសមណគោតម ។ ទើប
កេណិយជដិលមានសេចក្តីត្រិះរិះដូច្នេះថា ពួកឥសីទាំងឡាយណា ដែលជា
បុព្វបុរសរបស់ព្រាហ្មណ៍ទាំងឡាយ ដែលជាអ្នកកសាងមន្ត ជាអ្នកឲ្យមន្ត
បទមន្តបុរាណនេះដែលពួកឬសីណា បានច្រៀងមកហើយ បានពោលមក
ហើយ បានសន្សំមកច្រើនហើយ សព្វថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយ
តែងច្រៀងតាមបទមន្តនោះ តែងស្រូត្រតាមបទមន្តនោះ តែងពោល
តាមបទមន្តដែលឬសីទាំងឡាយនោះពោលហើយ តែងបង្រៀនតាមបទ
មន្តដែលឬសីទាំងឡាយនោះបង្រៀនមកហើយ ដូចជាព្រាហ្មណ៍ឈ្មោះ
អដ្ឋកៈ ព្រាហ្មណ៍ឈ្មោះវាមកៈ ព្រាហ្មណ៍ឈ្មោះវាមទេវៈ ព្រាហ្មណ៍
ឈ្មោះវេស្សាមិត្តៈ ព្រាហ្មណ៍ឈ្មោះយមតគ្គិ ព្រាហ្មណ៍ឈ្មោះអង្គីរសៈ

ភារទ្វាជោ វាសេដ្ឋោ កស្សបោ ភគុ រត្តូបរតា វិរតា វិកាលភោជនា តេ ឯវរូបានិ បានានិ សាទិយឹសុ សមណោបិ គោតមោ រត្តូបរតោ វិរតោ វិកាលភោជនា អរហតិ សមណោបិ គោតមោ ឯវរូបានិ បានានិ សាទិតុន្តិ បហូតំ បានំ បដិយាទាបេត្វា កាជេហិ គាហាបេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ កេណិយោ ជដិលោ ភគវន្តំ ឯតទវោច បដិគ្គណ្ហាតុ មេ ភវំ គោតមោ បានន្តិ ។ តេនហិ កេណិយ ភិក្ខូនំ ទេហីតិ ។ ភិក្ខូ កុក្កុច្ចាយន្តា ន បដិគ្គណ្ហន្តិ ។ បដិគ្គណ្ហថ ភិក្ខវេ បរិភុញ្ជថាតិ ។ អថខោ កេណិយោ ជដិលោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បហូតេហិ បានេហិ សហត្ថា សន្តប្បេត្វា សម្បវារេត្វា



ព្រាហ្មណ៍ឈ្មោះភារទ្វាជៈ ព្រាហ្មណ៍ឈ្មោះវាសេដ្ឋៈ ព្រាហ្មណ៍ឈ្មោះកស្សបៈ ព្រាហ្មណ៍ឈ្មោះភគុ ពួកព្រាហ្មណ៍ទាំងនោះជាអ្នកវៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគខុសកាល (គឺចាប់តាំងពីថ្ងៃត្រង់ទៅដល់អរុណរះ) ក៏ត្រេកអរនឹងទឹកបានទាំងឡាយមានសភាពយ៉ាងនេះ សូម្បីព្រះសមណគោតមក៏ជាអ្នកវៀរចាកការបរិភោគក្នុងរាត្រី វៀរចាកវិកាលភោជន ព្រះសមណគោតមគួរត្រេកអរនឹងទឹកបានទាំងឡាយមានសភាពយ៉ាងនេះដែរហើយ ក៏ឲ្យគេតាក់តែងទឹកបានជាច្រើន ឲ្យគេទៅហាម ដោយរែកទាំងឡាយហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏រីករាយជាមួយនឹងព្រះដ៏មានព្រះភាគ ហើយពោលនូវពាក្យគួររីករាយ សំណេះសំណាលគួររលឹកហើយ ក៏បានឈរនៅក្នុងទីដ៏សមគួរ ។ លុះកេណិយជដិលឈរនៅក្នុងទីដ៏សមគួរហើយបានក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា សូមព្រះគោតមដ៏ចំរើនទទួលទឹកបានរបស់ខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគមានព្រះបន្ទូលថា នែកេណិយៈ បើដូច្នោះ អ្នកចូរប្រគេនដល់ភិក្ខុទាំងឡាយចុះ ។ ភិក្ខុទាំងឡាយរង្កៀសមិនហ៊ានទទួល ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយទទួលឆាន់ចុះ ។ គ្រានោះ កេណិយជដិលក៏បានអង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ ដោយទឹកបានទាំងឡាយដ៏ច្រើន ដោយដៃខ្លួនឯង

ភគវន្តំ ធោតហត្ថំ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ កេណិយំ ជដិលំ ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថ ខោ កេណិយោ ជដិលោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ មហា ខោ កេណិយ ភិក្ខុសង្ឃោ អឌ្ឍតេឡសានិ ភិក្ខុសតានិ ត្វញ្ច ព្រាហ្មណេសុ អភិប្បសន្នោតិ ។ ទុតិយម្បិ ខោ កេណិយោ ជដិលោ ភគវន្តំ ឯតទវោច កិញ្ចាបិ ភោ គោតម មហា ភិក្ខុសង្ឃោ អឌ្ឍតេឡសានិ ភិក្ខុសតានិ អហញ្ច ព្រាហ្មណេសុ អភិប្បសន្នោ អធិវាសេតុ មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ មហា ខោ កេណិយ ភិក្ខុសង្ឃោ អឌ្ឍតេឡសានិ ភិក្ខុសតានិ ត្វញ្ច ព្រាហ្មណេសុ អភិប្បសន្នោតិ ។ តតិយម្បិ ខោ កេណិយោ ជដិលោ ភគវន្តំ ឯតទវោច កិញ្ចាបិ





កាលដឹងថាព្រះដ៏មានព្រះភាគទ្រង់លាងព្រះហស្តហើយ លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏អង្គុយក្នុងទីសមគួរមួយ ។ លុះកេណិយជដិលអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគក៏ទ្រង់ពន្យល់ឲ្យឃើញតាម ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ ឯកេណិយជដិល កាលព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញតាម ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏បានក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគដូច្នេះថា សូមព្រះគោតមដ៏ចំរើនព្រមទាំងភិក្ខុសង្ឃទទួលភត្តខ្ញុំព្រះអង្គដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះដ៏មានព្រះភាគមានព្រះបន្ទូលថា នែកេណិយៈ ភិក្ខុសង្ឃច្រើនណាស់ ចំនួនមួយពាន់ពីររយហាសិបអង្គ អ្នកសោតក៏ជ្រះថ្លាក្នុងពួកព្រាហ្មណ៍ទាំងឡាយហើយ ។ កេណិយជដិលបានក្រាបទូលពាក្យនេះនឹងព្រះមានព្រះភាគ អស់វារៈជាគំរប់ពីរដងទៀតថា បពិត្រព្រះគោតមដ៏ចំរើន ទុកជាភិក្ខុសង្ឃច្រើនចំនួនមួយពាន់ពីររយហាសិបអង្គក្តី ទុកជាខ្ញុំព្រះអង្គជ្រះថ្លាក្នុងពួកព្រាហ្មណ៍ទាំងឡាយក្តី សូមព្រះគោតមដ៏ចំរើនព្រមទាំងភិក្ខុសង្ឃទទួលភត្តខ្ញុំព្រះអង្គដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែកេណិយៈ ភិក្ខុសង្ឃច្រើនណាស់ ចំនួនមួយពាន់ពីររយហាសិបអង្គ អ្នកឯងសោតក៏ជ្រះថ្លាក្នុងពួកព្រាហ្មណ៍ទាំងឡាយហើយ ។ កេណិយជដិលបានទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគ

ភោ គោតម មហា ភិក្ខុសង្ឃោ អឌ្ឍតេឡសានិ ភិក្ខុសតានិ អហញ្ច ព្រាហ្មណេសុ អភិប្បសន្នោ អធិវាសេតុ មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធិំ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ កេណិយោ ជដិលោ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ ភគវា ឯតស្មិំ និទានេ ឯតស្មិំ បករណេ ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ អដ្ឋ បានានិ អម្ពបានំ ជម្ពុបានំ ចោចបានំ មោចបានំ មធុកបានំ មុទ្ទិកបានំ សាលុកបានំ ផារុសកបានំ ។ អនុជានាមិ ភិក្ខវេ សព្វំ ផលរសំ ឋបេត្វា ធញ្ញផលរសំ ។ អនុជានាមិ ភិក្ខវេ សព្វំ បត្តរសំ ឋបេត្វា ឌក្កាការសំ(១) ។

១ ម. ឌាករសំ ។



អស់វារៈជាគំរប់បីផងថា បពិត្រព្រះគោតមដ៏ចំរើន ទុកជាភិក្ខុសង្ឃច្រើន ចំនួនមួយពាន់ពីររយហាសិបអង្គក្តី ទុកជាខ្ញុំព្រះអង្គជ្រះថ្លាក្នុងពួកព្រាហ្មណ៍ទាំងឡាយក្តី ក៏សូមព្រះគោតមដ៏ចំរើនព្រមទាំងភិក្ខុសង្ឃទទួលភត្តខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ លំដាប់នោះ កេណិយជដិលដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកបានទាំងឡាយ ៨ យ៉ាង គឺ ទឹកផ្លែស្វាយ ទឹកផ្លែព្រីង ទឹកផ្លែចេកមានគ្រាប់ ទឹកផ្លែចេកឥតគ្រាប់ ទឹកផ្លែស្រគំ ទឹកផ្លែចន្ទូរ ទឹកក្រអៅឈូក ទឹកផ្លែមាក់ប្រាង(១) ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកផ្លែឈើគ្រប់យ៉ាង វៀរលែងតែទឹកផ្លែស្រូវ(២) ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកស្លឹកឈើគ្រប់យ៉ាង វៀរលែងតែទឹកបន្លែដែលឆ្អិនហើយ(៣) ។

១ អដ្ឋកថា ថា ទឹកអដ្ឋបានទាំង ៨ នេះ ជារបស់ត្រជាក់ក្តី ក្តៅដោយកំដៅថ្ងៃក្តី បើចំអិនដោយភ្លើងមិនគួរ ។ ២ បានដល់ស្រូវ ៧ ប្រការ ។ ៣ សេចក្តីថា ស្លឹកឈើដែលគេយកមកស្លល់ ជារបស់គួរក្នុងកាលគ្រប់ប្រមាណ ស្លឹកឈើដែលជាយាវជីវិកក្តី បើចំអិនលាយនឹងទឹកត្រជាក់ក្តី គួរអស់កាល ៧ ថ្ងៃ បើចំអិនដោយទឹកស្អុយគួរតែក្នុងបុរេភត្ត បើចំអិនដោយទឹកដោះខាប់ មិនគួរ ស្លឹកឈើដែលចំអិនដោយវត្ថុឯទៀតៗ ក៏ហៅថា សេចក្តីដែរ ។

អនុជានាមិ ភិក្ខវេ សព្វំ បុប្ផរសំ ឋបេត្វា មធុក-បុប្ផរសំ ។ អនុជានាមិ ភិក្ខវេ ឧច្ឆុរសន្តិ ។ អថ-ខោ កេណិយោ ជដិលោ តស្សា រត្តិយា អច្ចយេន សកេ អស្សមេ បណីតំ ខាទនីយំ ភោជនីយំ បដិយា-ទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន កេណិយស្ស ជដិ-លស្ស អស្សមោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។ អថខោ កេ-ណិយោ ជដិលោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា សម្បវា-រេត្វា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ កេណិយំ ជដិលំ ភគវា ឥមាហិ គាថាហិ អនុមោទិ ។



ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកផ្កាឈើគ្រប់យ៉ាង លើកលែងតែទឹកផ្កាស្រមំ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកអំពៅ ។ លុះកន្លងរាត្រីនោះទៅ កេណិយជដិលឲ្យគេតាក់តែងខាទនីយភោជនីយាហារដ៏ថ្លៃថ្លានៅក្នុងអាស្រមខ្លួន ហើយឲ្យក្រាបបង្គំទូលកាល ដល់ព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន កាលនេះជាកាលគួរ ភត្តសម្រេចហើយ ។ វេលានោះ ក្នុងបុព្វណ្ហសម័យ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ ហើយប្រដាប់បាត្រ និងចីវរ យាងចូលទៅកាន់អាស្រមរបស់កេណិយជដិល លុះយាងចូលទៅហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយជាមួយនឹងភិក្ខុសង្ឃ ។ លំដាប់នោះឯង កេណិយជដិលបានអង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ថ្លៃថ្លាដោយដៃខ្លួនឯង កាលដែលព្រះដ៏មានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះកេណិយជដិលអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់អនុមោ-ទនាដោយគាថាទាំងឡាយនេះថា ។

(១៣៨) អគ្គិហុត្តមុខា យញ្ញា
សាវិត្តី ឆន្ទសោ[១] មុខំ
រាជា មុខំ មនុស្សានំ
នទីនំ សាគរោ មុខំ
នក្ខត្តានំ មុខំ ចន្ទោ
អាទិច្ចោ តបតំ មុខំ
បុញ្ញមាកង្ខមានានំ
សង្ឃោ វេ យជតំ មុខន្តិ ។

អថខោ ភគវា កេណិយំ ជដិលំ ឥមាហិ គាថាហិ អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមិ ។

(១៣៩) អថខោ ភគវា អាបណេ យថាភិរន្តំ វិហរិត្វា យេន កុសិនារា តេន ចារិកំ បក្កាមិ មហតា ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេឡសេហិ ភិក្ខុសតេហិ ។ អស្សោសុំ ខោ កោសិនារកា មល្លា ភគវា កិរ កុសិនារំ អាគច្ឆតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេឡសេហិ ភិក្ខុសតេហីតិ ។ តេ សង្គរំ អកំសុ

១. សាវិត្តីឆន្ទសោ ។



(១៣៨) យញ្ញៈទាំងឡាយមានការបូជាភ្លើង ជាប្រធាន សាវិត្តីឆន្ទ ជាប្រធានរបស់ឆន្ទសាស្ត្រ ស្តេចជាប្រធានរបស់មនុស្សទាំងឡាយ សាគរ ជាប្រធានរបស់ស្ទឹងទាំងឡាយ ព្រះចន្ទ ជាប្រធាននៃនក្ខត្តឫក្សទាំងឡាយ ព្រះអាទិត្យ ជាប្រធាននៃពន្លឺទាំងឡាយ ព្រះសង្ឃប៉ុណ្ណោះ ជាប្រធានរបស់មនុស្សទាំងឡាយ ដែលប្រាថ្នានូវបុណ្យ ហើយបូជា ។

គ្រានោះឯង ព្រះមានព្រះភាគទ្រង់អនុមោទនា ដោយគាថាទាំងឡាយនេះចំពោះកេណិយជដិលហើយ ក៏ទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។

(១៣៩) គ្រានោះឯង ព្រះដ៏មានព្រះភាគគង់នៅក្នុងអាបណនិគម ដោយសមគួរដល់ព្រះអធ្យាស្រ័យហើយ ទើបយាងទៅកាន់ចារិកក្រុងកុសិនារា ជាមួយនឹងភិក្ខុសង្ឃដ៏ច្រើន ចំនួនមួយពាន់ពីររយហាសិបរូប ។ ពួកស្តេចមល្លទាំងឡាយនៅក្នុងក្រុងកុសិនារាបានឮដំណឹងថា ព្រះដ៏មានព្រះភាគ ព្រមទាំងភិក្ខុសង្ឃដ៏ច្រើន ចំនួនមួយពាន់ពីររយហាសិបរូប យាងមកកាន់ក្រុងកុសិនារា ។ ពួកមល្លក្សត្រទាំងនោះបានធ្វើការប្រជុំគ្នាថា

យោ ភគវតោ បច្ចុគ្គមនំ ន ករិស្សតិ បញ្ច សតានិ ទណ្ឌោតិ ។ តេន ខោ បន សមយេន រោជោ មល្លោ អាយស្មតោ អានន្ទស្ស សហាយោ ហោតិ ។ អថខោ ភគវា អនុបុព្វេន ចារិកំ ចរមានោ យេន កុសិនារា តទវសរិ ។ កោសិនារកា មល្លា ភគវតោ បច្ចុគ្គមនំ អកំសុ ។ អថខោ រោជោ មល្លោ ភគវតោ បច្ចុគ្គមនំ ករិត្វា យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧប- សង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ រោជំ មល្លំ អាយស្មា អានន្ទោ ឯតទវោច ឧឡារំ ខោ តេ ឥទំ អាវុសោ រោជ យំ ត្វំ ភគវតោ បច្ចុគ្គមនំ អកាសីតិ ។ នាហំ ភន្តេ អានន្ទ ពហុកតោ ពុទ្ធេ វា ធម្មេ វា សង្ឃេ វា អបិច ញាតីហិ សង្កេតោ កតោ យោ ភគវតោ បច្ចុគ្គមនំ ន ករិស្សតិ បញ្ច សតានិ ទណ្ឌោតិ សោ ខោ អហំ(១) ភន្តេ អានន្ទ ញាតីនំ ទណ្ឌភយា

១ ម. សោខោហំ ។



អ្នកណាមិនធ្វើការក្រោកទទួលព្រះមានព្រះភាគ អ្នកនោះត្រូវពិន័យជាប្រាក់ ៥០០ កហាបណៈ (មិនខាន) ។ គឺសម័យនោះឯង មល្លក្សត្រឈ្មោះរោជៈជាសំឡាញ់ព្រះអានន្ទដ៏មានអាយុ ។ លំដាប់នោះឯង ព្រះមានព្រះភាគកាលត្រាច់ទៅកាន់ចារិកដោយលំដាប់ ក៏បានយាងទៅដល់ក្រុងកុសិនារានោះ ។ ពួកមល្លក្សត្រនៅក្នុងក្រុងកុសិនារាក៏បានធ្វើការក្រោកទទួលព្រះដ៏មានព្រះភាគ ។ លំដាប់នោះឯង រោជមល្លក្សត្រក៏ធ្វើការក្រោកទទួលព្រះដ៏មានព្រះភាគដែរ ហើយចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះអានន្ទដ៏មានអាយុហើយ ក៏ឈរក្នុងទីសមគួរ ។ ព្រះអានន្ទដ៏មានអាយុបានពោលពាក្យនេះនឹងរោជមល្លក្សត្រដែលឈរក្នុងទីសមគួរដូច្នេះថា នែរោជៈដ៏មានអាយុ អ្នកបានធ្វើការក្រោកទទួលណា ចំពោះព្រះមានព្រះភាគ ការក្រោកទទួលនេះ ជាការប្រពៃរបស់អ្នកហើយ ។ រោជមល្លក្សត្រទូលថា បពិត្រព្រះអានន្ទដ៏ចំរើន ខ្ញុំមិនមែនធ្វើ (សេចក្តីគោរព) ច្រើន ព្រោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃទេ ប៉ុន្តែពួកញាតិបានធ្វើការប្តេជ្ញាថា អ្នកណាមិនធ្វើការក្រោកទទួលព្រះមានព្រះភាគ អ្នកនោះនឹងត្រូវពិន័យជាប្រាក់ ៥០០ កហាបណៈមិនខាន បពិត្រព្រះអានន្ទដ៏ចំរើន ខ្ញុំបានធ្វើការក្រោកទទួលព្រះមានព្រះភាគយ៉ាងនេះ ព្រោះខ្លាច

ឯវាហំ ភគវតោ បច្ចុគ្គមនំ អកាសិន្តិ ។ អថខោ អាយស្មា អានន្ទោ អនត្តមនោ អហោសិ កថំ ហិ នាម រោជោ មល្លោ ឯវំ វក្ខតីតិ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អយំ ភន្តេ រោជោ មល្លោ អភិញ្ញាតោ ញាតមនុស្សោ មហិទ្ធិកោ ខោ បន ឯវរូបានំ ញាតមនុស្សានំ ឥមស្មឹ ធម្មវិនយេ បសាទោ សាធុ ភន្តេ ភគវា តថា ករោតុ យថា រោជោ មល្លោ ឥមស្មឹ ធម្មវិនយេ បសីទេយ្យាតិ ។ ន ខោ តំ អានន្ទ ទុក្ករំ តថាគតេន យថា រោជោ មល្លោ ឥមស្មឹ ធម្មវិនយេ បសីទេយ្យាតិ ។ អថខោ ភគវា រោជំ មល្លំ មេត្តេន ចិត្តេន ផរិត្វា ឧដ្ឋាយាសនា វិហារំ បាវិសិ ។ អថខោ រោជោ មល្លោ ភគវតោ មេត្តេន ចិត្តេន ផុដ្ឋោ សេយ្យថាបិ នាម គាវី តរុណវច្ឆា ឯវមេវ វិហារេន វិហារំ បរិវេណេន បរិវេណំ ឧបសង្កមិត្វា ភិក្ខូ បុច្ឆតិ កហំ



ភ័យរបស់ពួកញាតិទេ ។ គ្រានោះឯង ព្រះអានន្ទដ៏មានអាយុមានសេចក្តីតាក់អន់ចិត្តថា រោជមល្លក្សត្រមិនសមបើនឹងហ៊ាននិយាយយ៉ាងនេះសោះ ។ វេលានោះ ព្រះអានន្ទដ៏មានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន រោជមល្លក្សត្រនេះជាអ្នកល្បីល្បាញ ជាមនុស្សមានគេស្គាល់ (ច្រើន) មានឫទ្ធិច្រើន ពួកមនុស្សដែលមានគេស្គាល់ច្រើនមានសភាពយ៉ាងនេះ រមែងមានសេចក្តីជ្រះថ្លាក្នុងធម្មវិន័យនេះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមឱកាស រោជមល្លក្សត្រគប្បីជ្រះថ្លាក្នុងធម្មវិន័យនេះយ៉ាងណា សូមព្រះដ៏មានព្រះភាគទ្រង់ធ្វើយ៉ាងនោះ ។ ព្រះដ៏មានព្រះភាគមានព្រះបន្ទូលថា ម្នាលអានន្ទ រោជមល្លក្សត្រគប្បីជ្រះថ្លា ក្នុងធម្មវិន័យនេះដោយហេតុណា ហេតុនោះតថាគតមិនលំបាកធ្វើទេ ។ ទើបព្រះដ៏មានព្រះភាគមានព្រះទ័យប្រកបដោយមេត្តាផ្សាយទៅកាន់រោជមល្លក្សត្រ ហើយទ្រង់ក្រោកចាកអាសនៈយាងចូលទៅកាន់វិហារ ។ ឯរោជមល្លក្សត្រកាលបើព្រះដ៏មានព្រះភាគមានព្រះទ័យមេត្តាផ្សាយមកប៉ះពាល់ហើយ ក៏ចូលទៅត្រង់វិហារត្រង់បរិវេណ ដូចជាមេគោមានកូនខ្ចីដូច្នោះឯង ហើយក៏សួរពួកភិក្ខុថា

នុ ខោ ភន្តេ ឯតរហិ សោ ភគវា វិហរតិ អរហំ សម្មា-សម្ពុទ្ធោ ទស្សនកាមា ហិ មយំ តំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ ឯសោវុសោ រោជ វិហារោ សំវុតទ្វារោ តេន អប្បសទ្ទោ ឧបសង្កមិត្វា អតរមានោ អាលិន្ទំ បវិសិត្វា ឧក្កាសិត្វា អគ្គឡំ អាកោដេហិ វិវរិស្សតិ តេ ភគវា ទ្វារន្តិ ។ អថខោ រោជោ មល្លោ យេន សោ វិហារោ សំវុតទ្វារោ តេន អប្បសទ្ទោ ឧបសង្ក-មិត្វា អតរមានោ អាលិន្ទំ បវិសិត្វា ឧក្កាសិត្វា អគ្គឡំ អាកោដេសិ(១) ។ វិវរិ ភគវា ទ្វារំ ។ អថខោ រោជោ មល្លោ វិហារំ បវិសិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នស្ស ខោ រោជស្ស មល្លស្ស ភគវា អនុបុព្វិំ កថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេ-សំ នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា ភគវា អញ្ញាសិ រោជំ មល្លំ កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ

១ ម. អាកោដេសិ ។



លោកដ៏ចំរើន ឥឡូវនេះព្រះដ៏មានព្រះភាគជាអរហំសម្មាសម្ពុទ្ធព្រះអង្គនោះ គង់ទីណា ត្បិតយើងខ្ញុំចង់ឃើញព្រះដ៏មានព្រះភាគជាអរហំសម្មាសម្ពុទ្ធ អង្គនោះ ។ ពួកភិក្ខុប្រាប់ថា នែអាវុសោរោជៈ ព្រះដ៏មានព្រះភាគ(ទ្រង់គង់) ក្នុងវិហារដែលគេបិទទ្វារនុ៎ះ ចូរអ្នកមានសម្លេងតិចចូលទៅជិតកុំរួស រាន់ ចូលទៅកាន់របៀង ក្អកស្រែមហើយគោះសន្ទះទ្វារ ព្រះដ៏មាន ព្រះភាគនឹងបើកទ្វារឲ្យអ្នក ។ វេលានោះ រោជមល្លក្សត្រចូលទៅកាន់វិហារ ដែលគេបិទនោះ ដោយស្ងប់ស្ងាត់សម្លេងតិចមិនរួសរាន់ចូលទៅកាន់របៀង ក្អកស្រែមហើយគោះសន្ទះទ្វារ ។ ព្រះដ៏មានព្រះភាគក៏ទ្រង់បើកទ្វារឲ្យ ។ គ្រានោះ រោជមល្លក្សត្រចូលទៅកាន់វិហារថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះរោជមល្លក្សត្រអង្គុយក្នុងទីសមគួរ ហើយ ទើបព្រះដ៏មានព្រះភាគទ្រង់សំដែងអនុបុព្វីកថា អនុបុព្វីកថានោះគឺ ដូចម្ដេច (ឯអនុបុព្វីកថានោះ) គឺព្រះដ៏មានព្រះភាគទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា ទោសរបស់កាមទាំងឡាយដ៏លាមកសៅហ្មងនិងអានិ-សង្សក្នុងការចេញចាកកាម ។ កាលណាបើព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា រោជមល្លក្សត្រមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ

ឧទគ្គចិត្តំ បសន្នចិត្តំ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ រោជស្ស មល្លស្ស តស្មឹយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ សមុទយធម្មំ សព្វំ តំ និរោធធម្មន្តិ ។ អថខោ រោជោ មល្លោ ទិដ្ឋធម្មោ បត្តធម្មោ វិទិតធម្មោ បរិយោគាឡ្ហធម្មោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុសាសនេ ភគវន្តំ ឯតទវោច សាធុ ភន្តេ អយ្យា មមញ្ញេវ បដិគ្គណ្ហេយ្យុំ ចីវរបិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារំ នោ អញ្ញេសន្តិ ។ យេសំ ខោ រោជ សេក្ខេន(១) ញាណេន សេក្ខេន ទស្សនេន ធម្មោ

១ ឱ. សេខេន ។





មានចិត្តរីករាយ មានចិត្តជ្រះថ្លាហើយ ព្រះអង្គក៏ទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយទ្រង់លើកឡើងសំដែងដោយព្រះអង្គឯង គឺ ទុក្ខ ហេតុនាំឲ្យកើតទុក្ខ ធម៌ជាគ្រឿងរលត់ទុក្ខ និងសេចក្តីប្រតិបត្តិទៅកាន់ទីរលត់ទុក្ខនៃសត្វនោះ ។ ធម្មតាសំពត់ស្អាតប្រាសចាកមន្ទិលនៅតែទទួលទឹកជ្រលក់ដោយស្រួលបានយ៉ាងណាមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់រោជមល្លក្សត្រិយ៍ក្នុងអាសនៈនោះឯង (ហើយគិតថា ណា ឃើញ) ថា របស់ណាមួយមានសេចក្តីកើតឡើងជាធម្មតា របស់ទាំងអស់នោះមានសេចក្តីរលត់ទៅជាធម្មតា ដូច្នោះឯង ។ លំដាប់នោះ រោជមល្លក្សត្រ មានឃើញធម៌ បានលុះធម៌ បានដឹងធម៌ច្បាស់ បានចុះនូវកាន់កន្លងធម៌ហើយ ឆ្លងផុតចាកសេចក្តីសង្ស័យ ប្រាសចាកសេចក្តីសង្ស័យ ដល់នូវសេចក្តីក្លៀវក្លា មិនជឿបុគ្គលដទៃក្នុងសាសនានៃព្រះសាស្តា ហើយបានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមឲ្យពួក លោកម្ចាស់ទាំងឡាយគួរទទួលចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារ គឺថ្នាំជាបច្ច័យដល់មនុស្សមានជម្ងឺ របស់ខ្ញុំព្រះអង្គតែម្យ៉ាង កុំទទួលរបស់ពួកបុគ្គលដទៃ ។ ព្រះមានព្រះភាគមានព្រះបន្ទូលថា ម្នាលរោជៈ ពួកជនណាមួយឃើញធម៌ដោយញាណជាសេក្ខៈ ដោយទស្សនៈជាសេក្ខៈ ដូចជាធម៌ដែលអ្នកបាន

ទិដ្ឋា សេយ្យថាបិ តយោ តេសំ ឃរំ ហោតិ អហោ
នូន អយ្យា អម្ហាកញ្ញេវ បដិគ្គណ្ហេយ្យុំ ចីវរបិណ្ឌបាត-
សេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ នោ អញ្ញេសន្តិ
តេនហិ រោជ តវ ចេវ បដិគ្គណ្ហិស្សន្តិ អញ្ញេសញ្ចាតិ ។
តេន ខោ បន សមយេន កុសិនារាយំ បណីតានំ
ភត្តានំ ភត្តបដិបាដិ អដ្ឋិតា[១] ហោតិ ។ អថ ខោ
ពេជស្ស ព្រាហ្មណស្ស បដិបាដឹ អលភន្តស្ស ឯតទហោសិ
យន្នូនាហំ ភត្តគ្គំ ឱលោកេយ្យំ យំ ភត្តគ្គេ នាស្ស[២] តំ
បដិយាទេយ្យន្តិ ។ អថ ខោ សោ ព្រាហ្មណោ ភត្តគ្គំ
ឱលោកេន្តោ ទ្វេ នាទ្ទស យាគុញ្ច មធុគោឡកញ្ច ។
អថ ខោ សោ ព្រាហ្មណោ យេនាយស្មា អានន្ទោ តេនុប-
សង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតទវោច
ឥធ មេ ភោ អានន្ទ បដិបាដឹ អលភន្តស្ស ឯតទ-
ហោសិ យន្នូនាហំ ភត្តគ្គំ ឱលោកេយ្យំ យំ ភត្តគ្គេ
នាស្ស តំ បដិយាទេយ្យន្តិ សោ ខោ អហំ ភោ
អានន្ទ ភត្តគ្គំ ឱលោកេន្តោ ទ្វេ នាទ្ទសំ យាគុញ្ច

១ ម. អសណ្ឋិតា ។ ២ ម. នត្ថិ ។



ឃើញហើយ ផលតានីនោះតែងមានគំនិតយ៉ាងនេះថា ឱហ្ន៎ លោកម្ចាស់
ទាំងឡាយគប្បីទទួលចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជា
បច្ច័យដល់អ្នកមានជម្ងឺ របស់យើងទាំងឡាយតែម្យ៉ាង កុំទទួលរបស់ជន
ទាំងឡាយដទៃឡើយ រោជៈ បើដូច្នោះ ភិក្ខុទាំងឡាយនឹងទទួលរបស់
អ្នកផង របស់ពួកជនឯទៀតផង ។ ក៏សម័យនោះឯង ក្នុងក្រុងកុសិនារា
ពួកជនបានតាក់តែងលំដាប់ភត្តដ៏ឧត្តម ។ គ្រានោះឯង ព្រាហ្មណ៍ម្នាក់
កាលមិនបានលំដាប់ភត្ត ( ដាក់វេនភត្ត ) ក៏មានសេចក្ដីត្រិះរិះដូច្នេះថា បើ
ដូច្នោះ គួរតែអញត្រួតត្រាមើលរោងភត្ត វត្ថុណាមិនមានក្នុងរោងភត្ត គួរ
អញតាក់តែងវត្ថុនោះ ។ កាលព្រាហ្មណ៍ត្រួតត្រាមើលរោងភត្តមិនបាន
ឃើញវត្ថុពីរយ៉ាង គឺ យាគូ ១ ខាទនីយៈធ្វើដោយឃ្មុំ ១ ។ លំដាប់
នោះ ព្រាហ្មណ៍ក៏ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅហើយ
បាននិយាយពាក្យនេះនឹងព្រះអានន្ទដ៏មានអាយុថា បពិត្រព្រះអានន្ទដ៏
ចំរើន កាលខ្ញុំមិនបានលំដាប់ភត្តក្នុងក្រុងកុសិនារានេះ ក៏មានសេចក្ដី
ត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអាត្មាអញត្រួតត្រាមើលរោងភត្ត វត្ថុណា
មិនមានក្នុងរោងភត្ត គួរតែអាត្មាអញតាក់តែងវត្ថុនោះឡើង បពិត្រព្រះអានន្ទ
ដ៏ចំរើន កាលខ្ញុំនោះត្រួតត្រាមើលរោងភត្តមិនបានឃើញវត្ថុពីរមុខ គឺយាគូ ១

បិដ្ឋខាទនីយញ្ច សាធាហំ ភន្តេ អានន្ទ បដិយាទេយ្យំ យាគុញ្ច បិដ្ឋខាទនីយញ្ច បដិគ្គណ្ហេយ្យ មេ ភគវាតិ ។ តេនហិ ព្រាហ្មណ ភគវន្តំ បដិបុច្ឆិស្សាមីតិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ តេនហិ អានន្ទ បដិយាទេតូតិ ។ តេនហិ ព្រាហ្មណ បដិ-យាទេហីតិ ។ អថខោ សោ ព្រាហ្មណោ តស្សា រត្តិយា អច្ចយេន បហូតំ យាគុញ្ច បិដ្ឋខាទនីយញ្ច បដិយាទា-បេត្វា ភគវតោ ឧបនាមេសិ បដិគ្គណ្ហាតុ មេ ភន្តេ ភគវា យាគុញ្ច បិដ្ឋខាទនីយញ្ចាតិ ។ តេនហិ ព្រាហ្មណ ភិក្ខូនំ ទេហីតិ ។ ភិក្ខូ កុក្កុច្ចាយន្តា ន បដិគ្គ-ណ្ហន្តិ ។ បដិគ្គណ្ហថ ភិក្ខវេ បរិភុញ្ជថាតិ ។ អថខោ សោ ព្រាហ្មណោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បហូតេហិ យាគូហិ ច បិដ្ឋខាទនីយេហិ ច សហត្ថា សន្ត-ប្បេត្វា សម្បវារេត្វា ភគវន្តំ ធោតហត្ថំ ឱនីតបត្តបាណឹ



ខាទនីយៈធ្វើដោយម្សៅ ១ បពិត្រព្រះអានន្ទដ៏ចំរើន បើខ្ញុំនឹងតាក់តែងនូវបបរ ខាទនីយៈធ្វើដោយម្សៅនេះ តើព្រះមានព្រះភាគនឹងទទួលរបស់ខ្ញុំទេ ។ ព្រះអានន្ទតបថា នែព្រាហ្មណ៍ បើដូច្នោះ អាត្មានឹងសួរសេចក្តីក្រាបបង្គំទូលព្រះដ៏មានព្រះភាគសិន ។ ទើបព្រះអានន្ទដ៏មានអាយុក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់មានបន្ទូលថា ម្នាលអានន្ទ បើដូច្នោះ ចូរព្រាហ្មណ៍នោះតាក់តែងចុះ ។ ព្រះអានន្ទដ៏-មានអាយុប្រាប់ថា នែព្រាហ្មណ៍ បើដូច្នោះ ចូរអ្នកតាក់តែងចុះ ។ លុះកន្លងរាត្រីនោះទៅ ទើបព្រាហ្មណ៍ឲ្យគេតាក់តែងនូវបបរនឹងខាទនីយៈធ្វើដោយម្សៅដ៏ច្រើន ហើយបង្អោនចូលទៅថ្វាយដល់ព្រះមានព្រះភាគ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទទួលនូវបបរនឹងខាទនីយៈធ្វើដោយម្សៅរបស់ខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់មានបន្ទូលថា នែព្រាហ្មណ៍ បើដូច្នោះ ចូរអ្នកប្រគេនដល់ភិក្ខុទាំងឡាយចុះ ។ ភិក្ខុទាំងឡាយបានសេចក្តីរង្កៀសក៏មិនហ៊ានទទួល (ភិក្ខុទាំងនោះ) ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយទទួលឆាន់ចុះ ។ ទើបព្រាហ្មណ៍អង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់-ស្កល់ដោយបបរនឹងខាទនីយៈធ្វើពីម្សៅ ដោយដៃខ្លួនឯង លុះព្រះមានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ រោជំ មល្លំ ភគវា ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ សព្វញ្ច សាកំ សព្វញ្ច បិដ្ឋខាទនីយន្តិ ។

[១៣៧] អថខោ ភគវា កុសិនារាយំ យថាភិរន្តំ វិហរិត្វា យេន អាតុមា តេន ចារិកំ បក្កាមិ មហតា ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេឡសេហិ ភិក្ខុសតេហិ ។ តេន ខោ បន សមយេន អញ្ញតរោ វុឌ្ឍបព្វជិតោ អាតុមាយំ បដិវសតិ ។ តស្ស ទ្វេ ទារកា ហោន្តិ មញ្ជុកា បដិភាណេយ្យកា ទក្ខា[១] បរិយោទាតសិប្បា សកេ អាចរិយកេ នហាបិតកម្មេ ។ អស្សោសិ ខោ សោ វុឌ្ឍបព្វជិតោ ភគវា កិរ អាតុមំ អាគច្ឆតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេឡសេហិ ភិក្ខុសតេហីតិ ។ អថខោ សោ វុឌ្ឍបព្វជិតោ តេ

១ ឱដ្ឋលា អនលេស្សាតិ ពន្ធចិ ហោន្តេ ទិស្សតិ ។



ក៏អង្គុយក្នុងទីសមគួរ ។ លុះរោជមល្លគ្រាន់តែអង្គុយនៅក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ពន្យល់ ឲ្យប្រតិបត្តិតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបន្លែគ្រប់មុខផង នំចំណីធ្វើពីម្សៅគ្រប់មុខផង ។

[១៣៧] គ្រានោះ ព្រះដ៏មានព្រះភាគគង់នៅក្នុងក្រុងកុសិនារាតាមគាប់ព្រះហឫទ័យហើយ ទ្រង់យាងទៅកាន់ចារិកក្នុងក្រុងអាតុមាជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួនមួយពាន់ពីររយហាសិបរូប ។ ក៏សម័យនោះឯង ភិក្ខុ[១]មួយរូប ធ្លាប់ធ្វើជាងកោរកាត់ បួសឯចាស់ នៅក្នុងក្រុងអាតុមា ។ ទារក[២]ពីរនាក់របស់ភិក្ខុនោះ មានសំនៀងពីរោះ ប្រកបដោយសេចក្តីវាងវៃ មិនខ្ជិលច្រអូស សម្រេចសិល្បៈក្នុងវិជ្ជាកោរកាត់ក្នុងសំណាក់អាចារ្យរបស់ខ្លួន ។ ភិក្ខុបួសឯចាស់នោះបានឮដំណឹងថា ព្រះដ៏មានព្រះភាគស្តេចព្រមទាំងភិក្ខុសង្ឃជាច្រើន ចំនួនមួយពាន់ពីររយហាសិបរូប មកកាន់ក្រុងអាតុមា ។ គ្រានោះឯង ភិក្ខុបួសឯចាស់នោះ

១ តាមសេចក្តីអដ្ឋកថា ភិក្ខុនោះឈ្មោះសុភទ្ទ ។ ២ ក្មេងពីរនាក់នេះជាកូនរបស់ភិក្ខុ កាលនៅជាគហស្ថនោះ ។

ទារកេ ឯតទវោច ភគវា កិរ តាតា អាតុមំ អាគច្ឆតិ មហតា ភិក្ខុសង្ឃេន សទ្ធិំ អឌ្ឍតេឡសេហិ ភិក្ខុសតេហិ គច្ឆថ តុម្ហេ តាតា ខុរភណ្ឌំ អាទាយ នាឡិយាវាបកេន អនុឃរកំ អនុឃរកំ អាហិណ្ឌថ លោណម្បិ តេលម្បិ តណ្ឌុលម្បិ ខាទនីយម្បិ សំហរថ[១] ភគវតោ អាគតស្ស យាគុបានំ ករិស្សាមាតិ ។ ឯវំ តាតាតិ ខោ តេ ទារកា តស្ស វុឌ្ឍបព្វជិតស្ស បដិស្សុណិត្វា ខុរភណ្ឌំ អាទាយ នាឡិយាវាបកេន អនុឃរកំ អនុឃរកំ អាហិណ្ឌន្តិ លោណម្បិ តេលម្បិ តណ្ឌុលម្បិ ខាទនីយម្បិ សំហរន្តា ។ មនុស្សា តេ ទារកេ មញ្ជុកេ បដិភានេយ្យកេ បស្សិត្វា យេបិ ន ការាបេតុកាមា តេបិ ការាបេន្តិ ការាបេត្វាបិ ពហុំ ទេន្តិ ។ អថខោ តេ ទារកា ពហុំ លោណម្បិ តេលម្បិ តណ្ឌុលម្បិ ខាទនីយម្បិ សំហរឹសុ ។ អថខោ ភគវា អនុបុព្វេន ចារិកំ ចរមានោ យេន អាតុមា តទវសរិ ។ តត្រ សុទំ ភគវា អាតុមាយំ វិហរតិ ភុសាគារេ ។ អថខោ សោ វុឌ្ឍ

១ សំហរត្ថ ។



បាននិយាយពាក្យនេះនឹងទារកទាំងឡាយនោះថា ម្នាលកូនទាំងឡាយ ឮថា ព្រះមានព្រះភាគ ព្រមទាំងព្រះភិក្ខុសង្ឃជាច្រើន ចំនួនមួយពាន់ពីររយហាសិបរូប ស្តេចមកកាន់ក្រុងអាតុមា ម្នាលកូនទាំងឡាយ ចូរអ្នកទាំងឡាយនាំយកគ្រឿងកោរសក់ ព្រមទាំងបំពង់ ហើយដើរទៅកាន់ផ្ទះជាលំដាប់ៗ ចូរប្រមូលអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ ដើម្បីនឹងធ្វើយាគុបានថ្វាយដល់ព្រះមានព្រះភាគ ដែលទ្រង់ស្តេចមកដល់ ។ ទារកទាំងនោះទទួលពាក្យភិក្ខុបួសចាស់នោះថា ករុណា លោកឪពុក ហើយក៏នាំយកគ្រឿងកោរសក់ ព្រមទាំងបំពង់ ដើរទៅកាន់ផ្ទះជាលំដាប់ៗ ប្រមូលអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ ។ មនុស្សទាំងឡាយឃើញទារកទាំងនោះមានសំដីពីរោះ ប្រកបដោយសេចក្តីរីករាយ ទុកជាអ្នកណាមិនចង់ឲ្យធ្វើ (កោរសក់) អ្នកទាំងនោះក៏ឲ្យធ្វើ លុះឲ្យធ្វើហើយក៏ឲ្យរបស់ជាច្រើន ។ ឯទារកទាំងនោះ ប្រមូលអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ ជាច្រើន ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាច់ទៅកាន់ចារិក ដោយលំដាប់ ក៏ចូលដល់ទៅក្រុងអាតុមា ។ បានឮថា ព្រះមានព្រះភាគគង់នៅក្នុងភុសាគារ[១] ជិតក្រុងអាតុមានោះ ។ លុះកន្លងរាត្រីនោះទៅ ទើបភិក្ខុបួសចាស់នោះឲ្យ

១ ពាក្យថាភុសាគារ ប្រែថាផ្ទះអង្កាម មានន័យថា ដើមឡើយនៅទីនោះ គេយកអង្កាមចេញពីខាងក្នុងហើយធ្វើឲ្យល្អ ដោយសារទីនោះ ទុកជាសាលា ។

ប្បព្វជិតោ តស្សា រត្តិយា អច្ចយេន បហុតំ យាគុំ បដិយាទាបេត្វា ភគវតោ ឧបនាមេសិ បដិគ្គណ្ហាតុ មេ ភន្តេ ភគវា យាគុន្តិ ។ ជានន្តាបិ តថាគតា បុច្ឆន្តិ ជានន្តាបិ ន បុច្ឆន្តិ កាលំ វិទិត្វា បុច្ឆន្តិ កាលំ វិទិត្វា ន បុច្ឆន្តិ អត្ថសញ្ហិតំ តថាគតា បុច្ឆន្តិ នោ អនត្ថសញ្ហិតំ អនត្ថសញ្ហិតេ សេតុឃាតោ តថាគតានំ ។ ទ្វីហាការេហិ ពុទ្ធា ភគវន្តោ ភិក្ខូ បដិបុច្ឆន្តិ ធម្មំ វា ទេសេស្សាម សាវកានំ វា សិក្ខាបទំ បញ្ញាបេស្សាមាតិ ។ អថ ខោ ភគវា តំ វុឌ្ឍបព្វជិតំ ឯតទវោច កុតាយំ ភិក្ខុ យាគូតិ ។ អថ ខោ សោ វុឌ្ឍបព្វជិតោ ភគវតោ ឯតមត្ថំ អារោចេសិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ(១) មោឃបុរិស អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម ត្វំ មោឃបុរិស បព្វជិតោ អកប្បិយេ សមាទបេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។ បេ ។

១ ម. អននុច្ឆវិយំ ។



ចាត់ចែងបបរជាច្រើន ហើយបង្អោនចូលថ្វាយចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទទួលបបររបស់ខ្ញុំព្រះអង្គ ។ ព្រះតថាគតទាំងឡាយទ្រង់ជ្រាបហើយសួរក៏មាន ទ្រង់ជ្រាបហើយមិនសួរក៏មាន ទ្រង់ជ្រាបកាលគួរហើយសួរក៏មាន ទ្រង់ជ្រាបកាលគួរហើយមិនសួរក៏មាន ព្រះតថាគតទាំងឡាយសួរតែហេតុដែលប្រកបដោយប្រយោជន៍ មិនសួរហេតុដែលមិនប្រកបដោយប្រយោជន៍ឡើយ ព្រោះហេតុមិនប្រកបដោយប្រយោជន៍ ព្រះតថាគតទាំងឡាយសម្លាប់បង់ហើយដោយអរិយមគ្គ ។ ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយទ្រង់សួរពួកភិក្ខុដោយហេតុពីរប្រការ គឺទ្រង់សួរដើម្បីនឹងសំដែងធម៌ ១ ដើម្បីនឹងបញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយ ១ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគមានព្រះបន្ទូលនេះនឹងភិក្ខុបួសចាស់នោះថា នែភិក្ខុ បបរនេះអ្នកឯងបានមកពីណា ។ ទើបភិក្ខុបួសចាស់នោះក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរស អំពើនេះមិនសមគួរ មិនទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើ នែមោឃបុរស អ្នកឯងជាអ្នកបួស មិនសមបើនឹងបបួល (គេឲ្យធ្វើ) ក្នុងការមិនគួរសោះ នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ ។

វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ បព្វ-ជិតេន អកប្បិយេ សមាទបេតព្វំ យោ សមាទបេយ្យ អាបត្តិ ទុក្កដស្ស ។ ន ច ភិក្ខវេ នហាបិតបុព្វេន ខុរភណ្ឌំ បរិហរិតព្វំ យោ បរិហរេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[១៣៨] អថខោ ភគវា អាតុមាយំ យថាភិរន្តំ វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ ។ អថខោ ភគវា អនុបុព្វេន ចារិកំ ចរមានោ យេន សាវត្ថី តទ-វសរិ ។ តត្រ សុទំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សាវត្ថិយំ ពហុំ ផលខាទនីយំ ឧប្បន្នំ ហោតិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កិន្នុ ខោ ភគវតា ផលខាទនីយំ អនុញ្ញាតំ កឹ អននុញ្ញាតន្តិ ។ ភគវតោ ឯតមត្ថំ អា-រោចេសុំ ។ អនុជានាមិ ភិក្ខវេ សព្វំ ផលខាទនីយន្តិ ។



លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយ (មកហើយទ្រង់មានព្រះបន្ទូល)ថា ម្នាលភិក្ខុទាំងឡាយ បព្វជិតមិនត្រូវបបួល (អ្នកដទៃ) ក្នុងការមិនគួរទេ បព្វជិតណាបបួល ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុដែលធ្លាប់ធ្វើជាងកោរសក់ (មកពីដើម) មិនត្រូវរក្សាគ្រឿងប្រដាប់កាំបិតកោរទុកទេ ភិក្ខុណារក្សាទុក ត្រូវអាបត្តិទុក្កដ ។

[១៣៨] គ្រានោះឯង ព្រះមានព្រះភាគគង់នៅក្នុងក្រុងអាតុមា គួរតាមព្រះអធ្យាស្រ័យហើយ ក៏ទ្រង់យាងទៅកាន់ចារិកក្រុងសាវត្ថី ។ លុះព្រះមានព្រះភាគទ្រង់ត្រាច់ទៅកាន់ចារិក ដោយលំដាប់ បានដល់ទៅក្រុងសាវត្ថីនោះ ។ បានឮថា ព្រះមានព្រះភាគគង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថីនោះ ។ គ្រាសម័យនោះឯង ក្នុងក្រុងសាវត្ថីមានផ្លែឈើជាខាទនីយៈ[១] កើតច្រើនណាស់ ។ ទើបភិក្ខុទាំងឡាយមានសេចក្ដីត្រិះរិះដូច្នេះថា ផ្លែឈើជាខាទនីយៈ ដូចម្ដេចដែលព្រះមានព្រះភាគទ្រង់អនុញ្ញាត ផ្លែឈើជាខាទនីយៈដូចម្ដេច ដែលព្រះមានព្រះភាគមិនបានអនុញ្ញាត ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្លែឈើជាខាទនីយៈគ្រប់យ៉ាង ។

---

១ ផ្លែឈើដែលគួរទំពាស៊ី ។

(១៣៩) តេន ខោ បន សមយេន សង្ឃិកានិ ពីជានិ បុគ្គលិកាយ ភូមិយា រោបិយន្តិ បុគ្គលិកានិ ពីជានិ សង្ឃិកាយ ភូមិយា រោបិយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សង្ឃិកានិ ភិក្ខវេ ពីជានិ បុគ្គលិកាយ ភូមិយា រោបិតានិ ភាគំ ទត្វា បរិភុញ្ជិតព្វានិ បុគ្គលិកានិ ពីជានិ សង្ឃិកាយ ភូមិយា រោបិតានិ ភាគំ ទត្វា បរិភុញ្ជិតព្វានីតិ ។

(១៤០) តេន ខោ បន សមយេន ភិក្ខូនំ កិស្មិញ្ចិ កិស្មិញ្ចិ ឋានេ កុក្កុច្ចំ ឧប្បជ្ជតិ កិន្នុ ខោ ភគវតា អនុញ្ញាតំ កឹ អននុញ្ញាតន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ យំ ភិក្ខវេ មយា ឥទំ ន កប្បតីតិ អប្បដិក្ខិត្តំ តញ្ចេ អកប្បិយំ អនុលោមេតិ កប្បិយំ បដិពាហតិ តំ វោ ន កប្បតិ ។ យំ ភិក្ខវេ





(១៣៩) គឺសម័យនោះឯង មនុស្សទាំងឡាយដាំពូជឈើទាំងឡាយជារបស់សង្ឃក្នុងដីជារបស់បុគ្គល ដាំពូជឈើទាំងឡាយជារបស់បុគ្គលក្នុងដីជារបស់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ (បើ) ពូជឈើទាំងឡាយជារបស់សង្ឃដែលដាំក្នុងដីជារបស់បុគ្គល ត្រូវភិក្ខុឲ្យចំណែក[១] (ដល់ម្ចាស់ដី) ហើយសឹមបរិភោគ (បើ) ពូជឈើទាំងឡាយជារបស់បុគ្គលដែលដាំក្នុងដីជារបស់សង្ឃ ត្រូវភិក្ខុឲ្យចំណែក (ដល់ម្ចាស់ដី) ហើយសឹមបរិភោគ ។

(១៤០) គឺសម័យនោះឯង ភិក្ខុទាំងឡាយកើតសេចក្តីរង្កៀស ក្នុងកន្លែងដ៏ផ្សេងៗថា របស់អ្វីខ្លះដែលព្រះដ៏មានព្រះភាគអនុញ្ញាត របស់អ្វីដែលព្រះដ៏មានព្រះភាគមិនបានអនុញ្ញាត ។ ពួកភិក្ខុក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គមានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានហាមទុកថា របស់នេះមិនគួរ បើរបស់នោះអនុលោមតាមរបស់មិនគួរ ឃាត់របស់គួរ របស់នោះមិនគួរដល់អ្នកទាំងឡាយឡើយ ម្នាលភិក្ខុទាំងឡាយ របស់ណាដែល

១ អដ្ឋកថា ថា ត្រូវចែកជា ១០ ភាគ ហើយត្រូវយក ១ ភាគដែលជាភាគទី ១០ ឲ្យដល់ម្ចាស់ដី សល់ក្រៅពីនោះ ៩ ភាគត្រូវបានម្ចាស់ពូជ ។ រឿងនេះយកតែសេចក្តី ដោយហេតុតាមអដ្ឋកថាក្នុងផ្សំប ។

មយា ឥទំ ន កប្បតីតិ អប្បដិក្ខិត្តំ តញ្ចេ កប្បិយំ អនុលោមេតិ អកប្បិយំ បដិពាហតិ តំ វោ កប្បតិ យំ ភិក្ខវេ មយា ឥទំ កប្បតីតិ អននុញ្ញាតំ តញ្ចេ អកប្បិយំ អនុលោមេតិ កប្បិយំ បដិពាហតិ តំ វោ ន កប្បតិ យំ ភិក្ខវេ មយា ឥទំ កប្បតីតិ អននុញ្ញាតំ តញ្ចេ កប្បិយំ អនុលោមេតិ អកប្បិយំ បដិពាហតិ តំ វោ កប្បតីតិ ។

[១៤១] អថ ខោ ភិក្ខូនំ ឯតទហោសិ កប្បតិ នុ ខោ យាវកាលិកេន យាមកាលិកំ ន នុ ខោ កប្បតិ កប្បតិ នុ ខោ យាវកាលិកេន សត្តាហ-កាលិកំ ន នុ ខោ កប្បតិ កប្បតិ នុ ខោ យាវ-កាលិកេន យាវជីវិកំ ន នុ ខោ កប្បតិ កប្បតិ នុ ខោ យាមកាលិកេន សត្តាហកាលិកំ ន នុ ខោ កប្បតិ កប្បតិ នុ ខោ យាមកាលិកេន យាវជីវិកំ ន នុ ខោ កប្បតិ កប្បតិ នុ ខោ សត្តាហកាលិកេន យាវជីវិកំ ន នុ ខោ កប្បតីតិ ។ ភគវតោ ឯតមត្ថំ អារោ-ចេសុំ ។ យាវកាលិកេន ភិក្ខវេ យាមកាលិកំ



តថាគតមិនបានហាមទុកថា របស់នេះមិនគួរ បើរបស់នោះអនុលោមចូលរបស់គួរ ឃាត់របស់មិនគួរ របស់នោះគួរដល់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនអនុញ្ញាតទុកថា របស់នេះគួរ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះមិនគួរដល់អ្នកទាំងឡាយឡើយ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានអនុញ្ញាតទុកថា របស់នេះគួរ បើរបស់នោះអនុលោមចូលរបស់គួរ ឃាត់របស់មិនគួរ របស់នោះគួរដល់អ្នកទាំងឡាយ ។

[១៤១] គ្រានោះឯង ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា វត្ថុជាយាមកាលិក (ដែលច្រឡំ) ដោយវត្ថុជាយាវកាលិក គួរឬមិនគួរទេ វត្ថុជាសត្តាហកាលិក (ច្រឡំ) ដោយវត្ថុជាយាវកាលិក គួរឬមិនគួរទេ វត្ថុជាយាវជីវិក (ច្រឡំ) ដោយវត្ថុជាយាវកាលិក គួរឬមិនគួរទេ វត្ថុជាសត្តាហ-កាលិក (ច្រឡំ) ដោយវត្ថុជាយាមកាលិក គួរឬមិនគួរទេ វត្ថុជាយាវជីវិក (ច្រឡំ) ដោយវត្ថុជាយាមកាលិក គួរឬមិនគួរទេ វត្ថុជាយាវជីវិក (ច្រឡំ) ដោយវត្ថុជាសត្តាហកាលិក គួរឬមិនគួរទេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គមានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ វត្ថុជាយាមកាលិក (ច្រឡំ) ដោយវត្ថុជាយាវកាលិក

## ភេសជ្ជក្ខន្ធកេ យាមកាលិកាទិកថា

តទហុប្បដិគ្គហិតំ កាលេ កប្បតិ វិកាលេ ន កប្បតិ យាវកាលិកេន ភិក្ខវេ សត្តាហកាលិកំ តទហុប្បដិគ្គហិតំ កាលេ កប្បតិ វិកាលេ ន កប្បតិ យាវកាលិកេន ភិក្ខវេ យាវជីវិកំ តទហុប្បដិគ្គហិតំ កាលេ កប្បតិ វិកាលេ ន កប្បតិ យាមកាលិកេន ភិក្ខវេ សត្តាហកាលិកំ តទហុប្បដិគ្គហិតំ យាមេ កប្បតិ យាមាតិក្កន្តេ ន កប្បតិ យាមកាលិកេន ភិក្ខវេ យាវជីវិកំ តទហុប្បដិគ្គហិតំ យាមេ កប្បតិ យាមាតិក្កន្តេ ន កប្បតិ សត្តាហកាលិកេន ភិក្ខវេ យាវជីវិកំ តទហុប្បដិគ្គហិតំ សត្តាហំ កប្បតិ សត្តាហាតិក្កន្តេ ន កប្បតីតិ ។

ភេសជ្ជក្ខន្ធកំ និដ្ឋិតំ ឆដ្ឋំ ។

ឥមម្ហិ ខន្ធកេ វត្ថូ ឯកសតំ ឆក្កំ ។



## ភេសជ្ជក្ខន្ធកៈ ពាក្យពោលអំពីកាលិកមានយាមកាលិកជាដើម

ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរប្រើតែក្នុងកាល មិនគួរក្នុងវិកាលទេ ម្នាលភិក្ខុទាំងឡាយ វត្ថុជាសត្តាហកាលិក (ច្រឡំ) ដោយវត្ថុជាយាវកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរប្រើតែក្នុងកាល មិនគួរក្នុងវិកាលទេ ម្នាលភិក្ខុទាំងឡាយ វត្ថុជាយាវជីវិក (ច្រឡំ) ដោយវត្ថុជាយាវកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរប្រើតែក្នុងកាល មិនគួរក្នុងវិកាលទេ ម្នាលភិក្ខុទាំងឡាយ វត្ថុជាសត្តាហកាលិក (ច្រឡំ) ដោយវត្ថុជាយាមកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរប្រើតែក្នុងយាម កន្លងយាមទៅហើយ មិនគួរទេ ម្នាលភិក្ខុទាំងឡាយ វត្ថុជាយាវជីវិក (ច្រឡំ) ដោយវត្ថុជាយាមកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរប្រើតែក្នុងយាម កន្លងយាមទៅហើយមិនគួរទេ ម្នាលភិក្ខុទាំងឡាយ វត្ថុជាយាវជីវិក (ច្រឡំ) ដោយវត្ថុជាសត្តាហកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរអស់ ៧ ថ្ងៃ ហួស ៧ ថ្ងៃទៅហើយមិនគួរទេ ។

ចប់ ភេសជ្ជក្ខន្ធកៈ ទី ៦ ។

ក្នុងខន្ធកៈនេះមាន ១០៦ រឿង ។

## តស្សុទ្ទានំ

[១៦៦] សារទិកេ វិកាលេបិ
វសំ មូលេ បិដ្ឋេហិ ច
កសាវេហិ បណ្ណំ ផលំ
ជតុ លោណំ ច ឆក្កណំ(១)
ចុណ្ណំ ចាលិនី មំសញ្ច
អញ្ជនំ ឧបបិសនំ
អញ្ជនី ឧច្ចាបារុតា
សលាកា សលាកោធនី
ថវិកំ វទ្ធកំ(២)សុត្តំ
មុទ្ធនិតេលនត្ថុ ច
នត្ថុករណី ធូមញ្ច

១ ឧ. ជតុលោណកំ ឆកណំ ច ។ ២ ឧ. ពទ្ធកំ ។



## ឧទ្ទាននៃភេសជ្ជក្ខន្ធកៈនោះគឺ

[១៦៦] រឿងភិក្ខុកើតអាពាធក្នុងសរទកាល ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យភិក្ខុឆាន់ភេសជ្ជ ជាមួយនឹងកាលក្តី ខុសកាលក្តី ១ រឿងទ្រង់អនុញ្ញាតខ្លាញ់ ១ រឿងទ្រង់អនុញ្ញាតមើមឈើ ១ រឿងភិក្ខុត្រូវការដោយថ្នាំដែលកិនជាម្សៅ ១ រឿងទ្រង់អនុញ្ញាតថ្នាំទឹកចត់ ១ រឿងទ្រង់អនុញ្ញាតថ្នាំស្លឹកឈើ ១ រឿងទ្រង់អនុញ្ញាតថ្នាំផ្លែឈើ ១ រឿងទ្រង់អនុញ្ញាតថ្នាំជ័រឈើ ១ រឿងទ្រង់អនុញ្ញាតអំបិល ១ រឿងទ្រង់អនុញ្ញាតអាចម៍គោ ចំទំទាំលំអិត ១ រឿងទ្រង់អនុញ្ញាតគ្រឿងរែងថ្នាំលំអិត ១ រឿងទ្រង់អនុញ្ញាតសាច់ឆៅនិងឈាមស្រស់ ១ រឿងទ្រង់អនុញ្ញាតថ្នាំបន្តក់ភ្នែកនិងគ្រឿងលំអិតសម្រាប់លាប ១ រឿងភិក្ខុប្រើក្លាក់ថ្នាំផ្សេង ៗ ១ រឿងក្លាក់ថ្នាំគ្មានគម្រប ១ រឿងទ្រង់អនុញ្ញាតចង្កឹះក្លាក់ថ្នាំ ១ រឿងទ្រង់អនុញ្ញាតស្រោមចង្កឹះ ១ រឿងទ្រង់អនុញ្ញាតថង់ក្លាក់ ១ រឿងទ្រង់អនុញ្ញាតខ្សែយោងនិងខ្សែសម្រាប់ចង ១ រឿងទ្រង់អនុញ្ញាតប្រេងសម្រាប់លាបក្បាល ១ រឿងទ្រង់អនុញ្ញាតការនត្ថុ ១ រឿងទ្រង់អនុញ្ញាតបំពង់សម្រាប់នត្ថុ ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុផឹកផ្សែង ១

នេត្តញ្ចាបិធនត្ថវិ(១)

តេលបាកេសុ មជ្ជញ្ច

អតិក្ខិត្តំ អព្ភញ្ជនំ

តុម្ពំ សេទំ សម្ភារញ្ច

មហាភង្គោទកំ តថា

ទកកោដ្ឋំ លោហិតញ្ច

វិសាណំ បាទព្ភញ្ជនំ

គណ្ឌំ សត្ថំ កសាវញ្ច

តិលកក្កំ កពឡិកំ

ចោឡំ សាសបកុដ្ឋញ្ច

ធូមសក្ខរិកាយ ច

១ ម. នេត្តញ្ចាបិធានំថវី ។





រឿងទ្រង់អនុញ្ញាតកខ្សៀរ ១ រឿងទ្រង់អនុញ្ញាតថង់ខ្សៀរ ១ រឿងទ្រង់អនុញ្ញាតការស្លាប្រេង ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុដាក់គ្រឿងស្រវឹងទៅក្នុងប្រេងស្ល ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុដាក់ប្រេងដែលដាក់គ្រឿងស្រវឹងច្រើនពេក ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុអង្គាសខាត់លាប ១ រឿងទ្រង់អនុញ្ញាតភាជនៈសម្រាប់ដាក់ប្រេង ១ រឿងទ្រង់អនុញ្ញាតការស្ទួន ១ រឿងទ្រង់អនុញ្ញាតការស្ទួនដោយគ្រឿងសម្ភារៈ ១ រឿងទ្រង់អនុញ្ញាតការស្ទួនធំ ១ រឿងទ្រង់អនុញ្ញាតទឹកដែលស្ងោរដោយស្លឹកឈើផែកឈើ ១ រឿងទ្រង់អនុញ្ញាតបន្ទប់ទឹក ១ រឿងទ្រង់អនុញ្ញាតឲ្យដួចយកឈាម ទិងអនុញ្ញាតស្នែងសម្រាប់ដួចឈាម ១ រឿងទ្រង់អនុញ្ញាតថ្នាំសម្រាប់លាបជើង និងអនុញ្ញាតឲ្យភិក្ខុដាក់-ផែនទឹកស្រវឹង (សម្រាប់លាបជើងឲ្យស្រួល) ១ រឿងទ្រង់អនុញ្ញាតសត្ថកម្ម ១ រឿងទ្រង់អនុញ្ញាតទឹកចត់ ១ រឿងទ្រង់អនុញ្ញាតម្សៅល្ង ១ រឿងទ្រង់អនុញ្ញាតដុំសក្តិ ១ រឿងទ្រង់អនុញ្ញាតសំពត់សម្រាប់រុំដំបៅ ១ រឿងទ្រង់អនុញ្ញាតឲ្យ-ភិក្ខុលាបដំបៅ ដោយម្សៅគ្រាប់ស្ពៃ ១ រឿងទ្រង់អនុញ្ញាតឲ្យធ្វើការចំហុយ ១ រឿងទ្រង់អនុញ្ញាត ឲ្យបក្រិតដំបៅ.

វណ្ណគេហំ វិកាសាយំ(១)

វិគដញ្ច បដិក្ខិបំ

គុឡំ ឥកពេឡ្កោ លោណឡ្យំ ច

ទាវំ មុគ្គហរីតកី

គព្ភា វិរេចនញ្ចេវ

អញ្ជនគំ គាជាគង់

បដិច្ចាឧធំ បត្តាភុ

អាកម៌ សត្តាហោធ ច

គុឡំ មុគ្គំ សុចិរញ្ច(២)

សាមតាកា ហុងាបាច

បុរាតុញ្ញាសិ ទុក្កិត្ថោ

ផលញ្ច គិលាធានធំ

---

១ ន. វិកាលិកំ ។ ២ ន. សោវិរញ្ច ។



ដោយទឹកអម្បិល ១ រឿងទ្រង់អនុញ្ញាតស្រែចងសម្រាប់លាយ ផលម្ជូរ ១ រឿងទ្រង់អនុញ្ញាត សំពត់សម្រាប់ប្រែង ១ រឿងទ្រង់អនុញ្ញាតថ្នាំមហាវិកដ ១ រឿងទ្រង់អនុញ្ញាតការចម្អិនប្រេងខ ១ រឿងទ្រង់អនុញ្ញាតឲ្យផឹកធូប ១ រឿងទ្រង់អនុញ្ញាតនាឡបំណាស់ ១ រឿងទ្រង់អនុញ្ញាតទឹកក្បូង ១ រឿងទ្រង់អនុញ្ញាតសម្រែកទឹកបុត្រ ១ រឿងទ្រង់អនុញ្ញាតការលាបជាយ រឿងក្រអូប ១ រឿងទ្រង់អនុញ្ញាតថ្នាំបញ្ចុះ ១ រឿងទ្រង់អនុញ្ញាតទឹកអង្ករ ១ រឿងទ្រង់អនុញ្ញាតទឹកសណ្ដកបាយស្ងោរ ១ រឿងអនុញ្ញាតទឹកស្ងោរសាច់ ១ រឿងព្រះបិលិន្ទវច្ឆត្ថេរ [illegible] ទ្រង់អនុញ្ញាតការ [illegible] ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុឈឺទុកគេសជ្ជៈបាន ៧ ថ្ងៃ ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុឆាន់ស្ករអំពៅ ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុឆាន់សណ្ដែកបាយ ១ រឿងទ្រង់អនុញ្ញាតថ្នាំរលាយ ណោសោវីរកៈ ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់ភក្ដាសាមបក្ក ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុចំអិនថែមទៀត ១ រឿងក្រឡប់ទ្រង់អនុញ្ញាតអន្តោវុត្ថ អន្តោបក្ក និងសាមបក្ក ក្នុងគ្រាកាលអត់បាយ ១ រឿងទ្រង់អនុញ្ញាតផ្លែឈើជាខាទនីយៈនឹងអនុញ្ញាត

បុរេភត្តំ  កាយដាហោ

ជំពូទ្ទញ្ញ  កកន្ទុល

វត្ថិកម្មញ្ច  សុប្បិយា ច

មនុស្សមំសមេវ ច

ហត្ថិអស្សា  សុនខោ ច

អហិ  សីហព្យគ្ឃទីបិនំ

អច្ឆតរច្ឆមំសញ្ច

បដិបាទិ ច យាគុ ច

តរុណំ  អញ្ញត្រ  គុឡំ

សុនិធាវសថាគារំ

គង្គា  កោដិសច្ចកថា



ល្ហុងថាចនីយ:១ រឿងបុរេភត្ត១ រឿងក្តៅក្រហាយក្នុងកាយ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុឆាន់ផ្លែឈើដែលគ្មានពូជ ១ រឿងភិក្ខុមានរោគប្ញសដូងបាត ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុធ្វើវត្ថិកម្មនឹងសត្ថកម្ម១ រឿងសុប្បិយាឧបាសិកា១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់មនុស្ស១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់សេះ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់ឆ្កែ ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់ពស់ ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់សីហ:១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់ខ្លាធំ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់ខ្លាដម្បង១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់ខ្លាឃ្មុំ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់ឆ្កែព្រៃ១ រឿងលំដាប់ភត្ត(បបរ)១ រឿងទ្រង់អនុញ្ញាតបបរ១ រឿងមហាមាត្យមានសេចក្តីជ្រះថ្លាថ្មី១ រឿងភិក្ខុដែលគេនិមន្តក្នុងទីដទៃហើយមិនត្រូវឆាន់បរម្បរភត្តដទៃ ១ រឿងទ្រង់អនុញ្ញាតស្ករអំពៅដល់ភិក្ខុមានជម្ងឺ ១ រឿងមហាមាត្យឈ្មោះសុនីធ១ រឿងព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងផ្ទះសំណាក់បាដលិគ្រាម១ រឿងស្ទឹងគង្គា ១ រឿងព្រះដ៏មានព្រះភាគគង់នៅក្នុងកោដិគ្រាមហើយទ្រង់សំដែងចតុរារិយសច្ច ១

អម្ពបាលី ច លិច្ឆវី

ឧទ្ទិស្ស កតំ សុភិក្ខំ

បុនទេវ បដិក្ខិបិ

មេឃោ យសោ(១) មេណ្ឌកោ ច

គោរសំ បាថេយ្យកេន ច

កេណី អម្ពោ ជម្ពុ ចោច

មោចមធុមុទ្ទិកសាលុកំ

ផារុសកា ឌាកបិដ្ឋំ

អាតុមាយំ នហាបិតោ

សាវត្ថិយំ ផលំ ពីជំ

តស្មិំ ជាតេ ច កាលិកាតិ(២) ។

---

១ ម. យសោតិ ។ ២ ម. កាលិកេតិ ។





រឿងស្រីគណិកាឈ្មោះអម្ពបាលីនិងស្តេចលិច្ឆវី ១ រឿងសាច់ដែលគេធ្វើចំពោះភិក្ខុ ១ រឿងក្រុងវេសាលីសម្បូណ៌បាយ ១ រឿងទ្រង់ត្រឡប់ហាមម្តងទៀតនូវវត្ថុដែលជាអន្តោវុត្ថអន្តោបក្កនិងសាមំបក្ក ១ រឿងមហាមេឃ ១ រឿងគ្រហបតីឈ្មោះយសមានជ័យ ១ រឿងមេណ្ឌកគហបតីនិងរឿងទ្រង់អនុញ្ញាតគោ-រសប្រាំ ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុស្វែងរកស្បៀងបាន ១ រឿងកេណិយជដិលនិងរឿងទ្រង់អនុញ្ញាតទឹកបានផ្លែស្វាយ ទឹកបានផ្លែព្រីង ទឹកបានផ្លែចេកមានគ្រាប់ ទឹកបានផ្លែចេកឥតគ្រាប់ ទឹកបានផ្លែស្រល់ ទឹកបានផ្លែចន្ទន៍ ទឹកបានក្រអៅឈូក ទឹកបានផ្លែមាក់ប្រាង ១ រឿងទ្រង់អនុញ្ញាតអន្លក់និងទាំងពួងៈ ធ្វើដោយម្សៅ ១ រឿងភិក្ខុចាស់ជាជាងកោរសក់ នៅក្នុងក្រុងអាតុមា ១ រឿងទ្រង់អនុញ្ញាតផ្លែឈើជាទាំងពួងៈ ក្នុងក្រុងសាវត្ថី ១ រឿងពូជឈើជារបស់សង្ឃនៅក្នុងទីដីជារបស់បុគ្គល ១ រឿងភិក្ខុមានសេចក្តីសង្ស័យក្នុងទីដោយអង្គ ២ ១ រឿងកាលិកលាយគ្នា ១ ។

# សង្ខេបខន្ធកប្រែបំមាតិកា

លេខទំព័រ


## វស្សូបនាយិកក្ខន្ធកៈ ១

ការនៅចាំវស្សាព្រះអង្គមានព្រះភាគទ្រង់អនុញ្ញាត. . . . . . . . . . . . . . ២
និទានឆព្វគ្គិយភិក្ខុ. . . . . . . . . . . . . . . . . . . . . . . . . ៣
ការចូលវស្សា. . . . . . . . . . . . . . . . . . . . . . . . . . . ៤
កិរិយាធ្វើនូវការព្រឹស្សប់មកវិញក្នុងរវាង ៧ ថ្ងៃ. . . . . . . . . . . . . . . ៨
អន្តរាយទាំងឡាយកើតឡើងដល់ពួកភិក្ខុដែលនៅចាំវស្សា. . . . . . . . . . . ៣៧
អន្តរាយទាំងឡាយមានដល់ពួកភិក្ខុដែលចូលវស្សា. . . . . . . . . . . . . . ៤១
ការបំបែកសង្ឃកើតឡើងដល់ពួកភិក្ខុដែលចូលវស្សា. . . . . . . . . . . . . ៤៣
និទានភិក្ខុ ១ រូបមានសេចក្តីប្រាថ្នាដើម្បីចូលវស្សាក្នុងលំនៅរបស់គង្វាលគោ. . . . ៤៨
ពួកភិក្ខុចូលវស្សាក្នុងទីកសិណដើម. . . . . . . . . . . . . . . . . . . . ៤៩
សង្ឃប្បញ្ញាត្តិកតិកា ភិក្ខុមិនត្រូវបួសកុលបុត្តក្នុងកណ្តាលវស្សា. . . . . . . . . ៥១
និទានឧបនន្ទសក្យបុត្ត. . . . . . . . . . . . . . . . . . . . . . . . ៥២
ការនៅចាំវស្សាក្នុងអាវាសទាំងឡាយពីរ. . . . . . . . . . . . . . . . . . ៥៣
ត្រូវអាបត្តិទុក្កដព្រោះទទួលពាក្យហើយ. . . . . . . . . . . . . . . . . . ៥៥
ឧទ្ទាននៃវស្សូបនាយិកក្ខន្ធកៈ. . . . . . . . . . . . . . . . . . . . . ៦៣

## បវារណាក្ខន្ធកៈ ៦៦

និទានភិក្ខុច្រើនរូបជាមិត្តគ្រួសារនឹងគ្នាចូលវស្សា. . . . . . . . . . . . . . . ៗ
មូគវត្ត (វត្តរបស់មនុស្សគ) ជាតិត្ថិយសមាទាន. . . . . . . . . . . . . . . ៦៧
អធិប្បាយបវារណា. . . . . . . . . . . . . . . . . . . . . . . . . . ៧៤
បវារណាកម្មមាន ៤ (គឺអធម្មេនវគ្គបវារណា ១ បណ្តាសង្ឃបវារណា ១). . . . . . . ៧៧
ការឲ្យនូវបវារណានៃភិក្ខុឈឺ. . . . . . . . . . . . . . . . . . . . . . ៧៩
អន្តរាយទាំងឡាយកើតឡើងក្នុងវេលានៃបវារណាកម្ម . . . . . . . . . . . . ៨៣

លេខទំព័រ

ឧណាឡើបវារណាទីងនៅចំពោះបវារណា........................ ៨៥
ភិក្ខុ ៣ រូបបវារណាដល់គ្នានឹងគ្នា........................ ៨៧
ភិក្ខុ ២ រូបបវារណាដល់គ្នានឹងគ្នា........................ ៨៨
និទានភិក្ខុ ១ រូបត្រូវអធិដ្ឋានក្នុងថ្ងៃបវារណា........................ ៩០
ការបវារណានៃភិក្ខុអ្នកមិនមានសភាគាបត្តិ........................ ៩៣
និទានមហាសិរិកភិក្ខុ និយាយពីភិក្ខុអ្នកបវារណាមិនត្រូវអាបត្តិមាន ១៥ យ៉ាង.... ៩៨
ពួកភិក្ខុជាច្រើនដែលស្លាប់ជាច្រើនរៀបគ្នាមាន ១៥ យ៉ាង........................ ១០០
ពួកភិក្ខុមានសេចក្ដីស្ទើរមាន ១៥ យ៉ាង........................ ១០៣
ពួកភិក្ខុមានបំណងនឹងបំបែកសង្ឃមាន ១៥ យ៉ាង........................ ១០៥
ផ្លែរបស់អាវាសិកភិក្ខុនឹងអាគន្តុកភិក្ខុផ្សេងគ្នា........................ ១០៧
ការបវារណារបស់ពួកភិក្ខុដែលមានសេចក្ដីសង្ស័យជាដើម........................ ១០៩
ការបវារណារបស់ពួកភិក្ខុដែលមានសំកសស្មើគ្នាជាដើម........................ ១១៣
ភិក្ខុមិនត្រូវទៅក្នុងថ្ងៃបវារណានោះ........................ ១១៨
កាលភិក្ខុទីបរិសុទ្ធអស់ហើយ ភិក្ខុមិនត្រូវបវារណា........................ ១១៩
រឿងអាវាស ១ ក្នុងកោសលជនបទកើតសង្គ្រាមក្នុងថ្ងៃបវារណានោះ........................ ១២០
ការបវារណាដោយថ្វីការបវារណាជាដើម........................ ១២១
និទានពុទ្ធប្បញ្ញត្តិភិក្ខុត្រូវអាបត្តិហើយបវារណា........................ ១២៥
បវារណាដែលភិក្ខុបានឃាត់នឹងបវារណាដែលភិក្ខុមិនបានឃាត់........................ ១២៧
ការឃាត់នូវបវារណាចំពោះភិក្ខុនឹងគ្នា........................ ១២៩
សេចក្ដីយល់ផ្សេង ៗ ក្នុងការត្រូវអាបត្តិ........................ ១៣៥
ពួកភិក្ខុអ្នកធ្វើការប្រេទ្ធប្រកាន់ជាដើម........................ ១៣៩
ការធ្វើនូវបវារណាសង្គហៈនៃភិក្ខុពួកច្រើនរៀនគ្នាជាដើម........................ ១៤៥
ការធ្វើនូវបវារណាសង្គហៈ........................ ១៤៩
ឧទ្ទាននៃបវារណាខន្ធក........................ ១៥០



លេខទំព័រ

ចម្មក្ខន្ធកៈ ១៦៣
និទានកូនសេដ្ឋីឈ្មោះសោណកោឡិវិសៈ........................ ៉
និទានព្រះសោណត្ថេរ........................ ១៦៤
និទានព្រះសោណត្ថេរ........................ ១៦៤
វីណាសូត្រឧបមា........................ ១៦៧
ការបញ្ញត្តិស្បែកជើងជាន់តែមួយ........................ ១៧៥
ស្បែកជើង ៤ ជាន់ឡើងទៅដែលគេពាក់ហើយដោះប្រើគេ (ស្បែកជើងចាស់)........................ ១៧៩
ភិក្ខុមិនត្រូវពាក់ស្បែកជើងចូលក្នុងវត្ត........................ ១៨០
និទានភិក្ខុមានបាតជើងលេចទៅជាដំបៅ........................ ១៨២
ភិក្ខុមិនត្រូវពាក់ទ្រនាប់ជើងឈើ........................ ១៨៥
ភិក្ខុមិនត្រូវពាក់ទ្រនាប់ជើងស្លឹកត្នោត........................ ១៨៧
(ពួកភិក្ខុឆព្វគ្គិយ) ពាក់ទ្រនាប់ជើងមានបការផ្សេង ៗ........................ ១៨៩
សេចក្ដីបញ្ញត្តិនូវទ្រនាប់ជើងជាអាបត្តិ........................ ១៩០
និទានពុទ្ធប្បញ្ញត្តិភិក្ខុចាប់ស្នែងមេគោជាដើម........................ ១៩២
ភិក្ខុមិនត្រូវចាប់មេគោ........................ ១៩៣
និទានពុទ្ធប្បញ្ញត្តិភិក្ខុទៅដោយយានដែលទឹមដោយគោញី........................ ១៩៤
ការទ្រង់អនុញ្ញាតនូវគ្រែស្បែង........................ ១៩៥
បញ្ហាសយនមហាសយនៈ........................ ១៩៨
ភិក្ខុមិនត្រូវប្រើប្រាស់ស្បែកសត្វធំ........................ ១៩៩
និទានភិក្ខុបាប........................ ២០០
ភិក្ខុមិនត្រូវពាក់ស្បែកជើងចូលទៅកាន់ស្រុក........................ ២០៣
និទានព្រះសោណត្ថេរ........................ ២០៥
ព្រះដ៏មានព្រះភាគទ្រង់ប្រទានពរ ៥ យ៉ាងដល់ព្រះសោណត្ថេរ........................ ២០៦
ទ្រង់ក្រាលនៃទម្លាប់ទេស........................ ២០៨
ឧទ្ទាននៃចម្មក្ខន្ធក........................ ២០៩

លេខទំព័រ

### ភេសជ្ជកថា ២២០


និទានកំពុងកំណាព (ប្រយោគ) . . . . . . . . . . . . . . . . . . . . [illegible]
មាសអំពីភេសជ្ជកាំ ៤ . . . . . . . . . . . . . . . . . . . . . ២២៣
រោគយកំពីភេសជ្ជមានខ្លាញ់ជាដើម . . . . . . . . . . . . . . . . ២២៨
រោគយកំពីភេសជ្ជមានទឹកដល់ជាដើម . . . . . . . . . . . . . . . ២២៧
រោគយកំពីភេសជ្ជមានសំជាដើម . . . . . . . . . . . . . . . . . ២២៩
រោគយកំពីភេសជ្ជមានម្រៀងលិតិតជាដើម . . . . . . . . . . . . . ២៣០
រោគយកំពីការទ្រង់អនុញ្ញាតភេសជ្ជមានជុំខ្ទាក់ភ្លែកជាដើម . . . . . . ២៣៣
រោគយកំពីការទ្រង់អនុញ្ញាតនូវបន្តិះភ្ញាក់ . . . . . . . . . . . . . ២៣៥
និទានបិលិន្ទវច្ចត្ថេរមានអាយុកើតជម្ងឺក្តៅក្បាល . . . . . . . . . . ២៣៦
រោគយកំពីការទ្រង់អនុញ្ញាតភេសជ្ជមានប្រេងលាយក្បួយជាដើម . . . . ២៣៧
និទានបិលិន្ទវច្ចត្ថេរ . . . . . . . . . . . . . . . . . . . . . ២៣៩
និទានកំពុងប្រមានអាពាធកើតតក . . . . . . . . . . . . . . . . ២៤២
ថ្នាំបញ្ចូលក្នុង ៤ យ៉ាង . . . . . . . . . . . . . . . . . . . . ២៤៣
រោគយកំពីកំពុងមានអាពាធផ្សេង ៗ . . . . . . . . . . . . . . . ២៤៥
និទានព្រះបិលិន្ទវច្ចត្ថេរ និយាយអំពីការទ្រង់អនុញ្ញាតនូវអារាមិកជន . . . ២៤៧
និទានព្រះបិលិន្ទវច្ចត្ថេរ និយាយអំពីកម្រងផ្កាជាវិការនៃមាស . . . . . ២៤៩
និទានព្រះបិលិន្ទវច្ចត្ថេរ និយាយអំពីភេសជ្ជ ៥ យ៉ាង . . . . . . . . ២៥៣
និទានព្រះបិលិន្ទវច្ចត្ថេរ រោគយកំពីស្ករអំពៅ . . . . . . . . . . . ២៥៥
ព្រះអង្គមានព្រះភាគទ្រង់អាពាធកើតដំណឹងក្នុងព្រះឧទរ . . . . . . . ២៥៧
ភេសជ្ជដែលភិក្ខុទុកក្នុងបរិវេណក្នុងភាជន៍យកុដិជ័នបំពេញដោយខ្លួនឯង . . ២៥៩
និទានព្រាហ្មណ៍ ១ រូប . . . . . . . . . . . . . . . . . . . . . ២៦៣
និទានបេលដ្ឋកច្ចាន . . . . . . . . . . . . . . . . . . . . . ២៦៧
ព្រះសារីបុត្តមានអាពាធក្តៅក្រហាយក្នុងកាយ . . . . . . . . . . . ២៦៨
ការទ្រង់អនុញ្ញាតនូវឫសឈើដែលជាមូលជាដើម . . . . . . . . . . . ២៧១




លេខទំព័រ


សព្វកម្ម (ការវះកាត់ដំបៅ) វត្ថិកម្ម (ការបន្តក់ថ្នាំ) . . . . . . . . . . . . ២៧៣
(ភិក្ខុមិនគួរបរិភោគ) សាច់ដែលមនុស្សសម្លាប់ . . . . . . . . . . . . ២៧៥
និទានសុប្បិយាឧបាសិកា . . . . . . . . . . . . . . . . . . . . ២៧៧
រោគយកំពីសាច់ដែលមិនគួរ . . . . . . . . . . . . . . . . . . . ២៧៩
និទានព្រាហ្មណ៍ ១ រូប . . . . . . . . . . . . . . . . . . . . ២៨៥
រោគយកំពីអាមិសស្បៀងអស់ ១០ យ៉ាង . . . . . . . . . . . . . . ២៨៧
និទានមហាមាត្យ (ម្នាក់) ជាអ្នកមានសេចក្តីជ្រះថ្លាថ្មី (មិនទាន់យូរ) . . . . . ២៨៩
សេចក្តីរង្កៀសរបស់មហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មី . . . . . . . . ២៩០
និទានបុរសឈ្មោះវេលដ្ឋកច្ចាន និយាយអំពីការប្រគេនស្ករអំពៅ . . . . . ២៩២
ពុទ្ធបញ្ញត្តិដែលទាក់ទងរបស់បុរសឈ្មោះវេលដ្ឋកច្ចាន . . . . . . . . . ២៩៩
និទានពួកភិក្ខុរង្កៀសមិនហ៊ានឆាន់ស្ករអំពៅ . . . . . . . . . . . . ៣០០
រោគយកំពីការទ្រង់ទទួលឧបោសថាគារ . . . . . . . . . . . . . . ៣០១
ទេសនា ៤ ប្រការនៃបុគ្គលដែលល្អជាប់ព្រហ្មចរិយា . . . . . . . . . . ៣០៣
អានិសង្ស ៥ ប្រការនៃបុគ្គលមានសីលល្អចូលក្នុងសង្គ្រោះ . . . . . . . ៣០៥
និទានមហាមាត្យឈ្មោះសុនីធនិងវស្សការ . . . . . . . . . . . . . . ៣០៧
អនុមោទនាគាថា . . . . . . . . . . . . . . . . . . . . . . . ៣១១
បដិសារណសម្ពោធនគាថា . . . . . . . . . . . . . . . . . . . . ៣១៣
និទានគាមណីកាសាលីជាត្រើសុភាសិត . . . . . . . . . . . . . . ៣១៥
និទានស្តេចលិច្ឆវីក្នុងក្រុងវេសាលី . . . . . . . . . . . . . . . ៣១៧
និទានសីហសេនាបតី រោគយកំពីពុទ្ធដំណើរ . . . . . . . . . . . . ៣២០
និទានសីហសេនាបតី រោគយកំពីទេវមានអភិវាទជាដើម . . . . . . . . ៣២៥
និទានសីហសេនាបតី ការបំរើនិគន្ថតាមវិន័យខ្លួនជាងមុន . . . . . . . ៣៣១
និទានសីហសេនាបតី រោគយកំពីសាច់ដែលគេធ្វើចំពោះ (ខ្លួន) . . . . . . ៣៣៥
ភិក្ខុការពារសាច់ដែលគេធ្វើចំពោះ (ខ្លួន) មិនត្រូវអាបត្តិ . . . . . . . . . ៣៣៧
និទានឧបាសកបណ្ឌុកម្ពល និយាយអំពីការសន្មតិកប្បិយភូមិ . . . . . . ៣៣៩

# សង្ខិតបន្ទុលប្រាប់មាតិកា


លេខទំព័រ

កញ្ញុយកូទី ៤ យក៏ង និកាយមេល្អូកនយបទិ: . . . . . . . . . . . . . . . . . ៣៤៣
និកាយមេល្អូកនយបទិ អនុភាពនៃមេឃមនុស្សលោកនយបទ៏ចាប់ផ្តើម. . . . . . . ៣៦៨
និកាយមេល្អូកនយបទិ គ្រូគុណលោកប៉ា. . . . . . . . . . . . . . . . . . . . ៣៦៩
និកាយមេល្អូកនយបទិ គន្ថុក្កំកាប៉ា. . . . . . . . . . . . . . . . . . . . ៣៧០
និកាយមេល្អូកនយបទិ ការសំដែងនូវការនៃខ្ញុំបាទបាឡកម្ពុជា . . . . . . . . . ៣៧១
ឧប្បត្តិ និងសោកាបត្តិមគ្គនៃមេល្អូកនយបទិ. . . . . . . . . . . . . . . . . ៣៧៨
និកាយមេល្អូកនយបទិ ការឧទ្ទិសនៃមេល្អូកនយបទ៏(ចោះ). . . . . . . . . . ៣៧៦
ការប្រែទំនុកច្រៀងកន្សោមកាព្យសាសច្រៀង. . . . . . . . . . . . . . . . . ៣៧៩
និកាយមហាសុំយានសីល. . . . . . . . . . . . . . . . . . . . . . . . . . ៣៦៨
និកាយមេល្អូក្ខប្រែកាំរឡាយរាវក្នុងក្រុងកុសលតា. . . . . . . . . . . . . . ៣៦៦
និកាយមេល្អូក្ខត្រៃឈ្មោះហាវ ការចេញនូវការប្រែកទទួលព្រះជីមានព្រៃរាប. . . . ៣៦៣
និកាយមេល្អូក្ខត្រៃឈ្មោះរាវ គន្ថុក្កំកាប៉ា. . . . . . . . . . . . . . . . . ៣៦៩
និកាយមហាជមេល្អូក្ខត្រ. . . . . . . . . . . . . . . . . . . . . . . . . ៣៨០
និកាយភិក្ខុខ្លួនឯងផល. . . . . . . . . . . . . . . . . . . . . . . . . ៣៨១
តែលាក់តីមនុស្សជាំគួចហៃហ៏រាល់សម្ប(ក្នុងដី)របស់បុគ្គល. . . . . . . . . . ៣៨៨
ពោលអំពីការសិក្សាគេលោមរកាលីកតាំងមើ. . . . . . . . . . . . . . . . . ៣៨៩
ទុក្ខនៃមេសប្តិក្នុង. . . . . . . . . . . . . . . . . . . . . . . . . . . ៣៩០


---


សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយប្រាក់សំណាកនៃ អ្នកមានឈ្មោះខាងក្រោមនេះ ៖

Printing costs were met through the gift of

WaL Sotoshu Syutokuin Temple The Rev. Zendo Matsunaga
363 Okitsuhoncho, Shimizu-shi, Shizuoka-ken 424-02 Japon

この本は次の方によって復刻されました。

宗教法人 曹洞宗 宗徳院 松永然道
〒424-02 静岡県清水市興津本町363
☎0543-69-2244